# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ក្បាលនាគ ផ្លូវចូលទៅប្រាសាទបឹងមាលា - ខេត្តសៀមរាប ( សតវត្សទី១២ មុនអង្គរវត្ត )


ឆ្នាំទី ៥២ លេខ ១ ខែ មករា - កុម្ភៈ - មីនា

ព.ស ២៥៤១ គ.ស ១៩៩៨

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ


ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ឌារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ឫទ្ធាង**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## និវេទនកថា

ទស្សនាវដ្តីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងាររបស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្តីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាពរវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្ប-ធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

The *Kambuja Suriya Magazine* is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ


**I.** អក្សរសាស្ត្រពុទ្ធសាសនា ៖

- ធមិគ្រឹះនៃពុទ្ធសាសនា - ត ( ឈេន អៀម ) ........ ១

**II.** អក្សរសាស្ត្រទូទៅ ៖

- វចនស័ព្ទវិទ្យា នៃភាសាខ្មែរបច្ចុប្បន្ន - ត (ឡុង សៀម) ........ ២៣
- មតិបញ្ញត្តិអំពីរដ្ឋនិងរាជសម្បត្តិ ( ឈេន អៀម ) ........ ៤៥
- ពុទ្ធិដ៏កំពូល (ព្រះតេជព្រះគុណ គិឃ្លសេ សែនអ៊ិនជោស) ........ ៧៩
- ប្រាសាទបឹងមាលា (ខៀវ បញ្ញាវុឌ្ឍ ) ........ ៩៨
- ទំនួញត្បាល់កិន (មៀច ប៉ុណ្ណ) ........ ១០០

**III.** កំណាត់ និងប្រវត្តិការណ៍ ៖

- គ្រានិងផ្លិតមន្ត្រីសង្ឃ (ម៉ី យ៉ាំ) ........ ១០៣
- ពិធីទទួលសៀវភៅ / ១៩៩៧ ពីអង្គការ WCRP ........ ១១១

# ធម៌ត្រិះ នៃ ពុទ្ធសាសនា ( ក )

ដោយ លោក ភីទ័រ ដ. សន្តិនា
( By Peter D. Santina )
បកប្រែដោយ : **ឈន អៀម**

## (IV)
## អរិយសច្ចៈបួន - ភាគទី ២

កាលណាយើងនិយាយពីការបញ្ចប់ទុក្ខ ពោលគឺ សច្ចៈនៃការរំលត់ទុក្ខ (ទុក្ខនិរោធសច្ចៈ), យើងកំពុងនិយាយពីគោលដៅនៃពុទ្ធមាគ៌ា ។ នៅក្នុងកន្លែងមួយ ព្រះពុទ្ធមានបន្ទូលថា បីដូចជាមហាសាគរ ទោះបីជាធំទូលំទូលាយ, ក៏វាមានរសជាតិតែមួយគឺ រសជាតិប្រៃ, ឯព្រះធម៌របស់ព្រះអង្គក៏ដូចនោះដែរ ។ ទោះបីជាមានប្រការច្រើន, ព្រះធម៌ទាំងអស់នោះទូលំទូលាយស្មើមហាសាគរ ក៏មានរសជាតិតែមួយប៉ុណ្ណោះ ហើយរសជាតិនោះ គឺរសជាតិព្រះនិព្វាន ។ ដូចលោកអ្នកនឹងបានឃើញ ថ្វីបើព្រះធម៌របស់ព្រះពុទ្ធមានប្រការច្រើនដូចជា អរិយសច្ចៈបួន, មាគ៌ាប្រតិបត្តិ, បដិច្ចសមុប្បាទ, លក្ខណៈបី, និងគោលធម៌ដទៃទៀត, ព្រះធម៌ទាំងអស់នេះមានគោលដៅតែមួយគត់ជាប្រចាំ, ហើយគោលដៅនោះ គឺការរំលត់នូវទុក្ខ ។ នេះគឺជាគោលដៅដែលនាំអោយមានពាក្យប្រៀនប្រដៅប្លែកៗទាំងអស់ ឃើញមាននៅក្នុងពុទ្ធសាសនា, ដែលប្រាប់ទិសដៅ និងគោលបំណងទាំងឡាយរបស់ពាក្យប្រៀនប្រដៅ ( ព្រះធម៌ ) ទាំងនោះ ។ ការបញ្ចប់ទុក្ខ គឺជាគោលដៅនៃការប្រតិបត្តិពុទ្ធ-

សាសនា, តែថាការបញ្ចប់ទុក្ខនេះ មិនមែនជាអ្វីមួយដែលឃោងមិនដល់, ដែលហួសពីការណ៍ពិតនោះទេ ។ ហេតុការណ៍នេះ គួរអោយជាប់ចិត្តណាស់ ពិព្រោះម្សិលមិញ គេបានសុំអោយខ្ញុំនិយាយពីដើមកំណើត និងការរីកចំរើននៃសាសនាសេមីទិក[១] (the semitic religions) ហើយនៅទីបញ្ចប់នៃការប្រជុំ មានបញ្ហាមួយ ដែលគេបានលើកឡើងថា « តើអ្វីទៅជាគោលដៅចុងក្រោយរបស់សាសនាសេមីទិក ហើយអ្វីទៅជាការខុសគ្នារវាងគោលដៅខាងផ្លូវចិត្ត ដែលសាសនាសេមីទិកបានផ្សព្វផ្សាយ និងគោលដៅដែលពុទ្ធសាសនាបានប្រៀនប្រដៅ ? » ក្នុងករណីសាសនាសេមីទិក, ខ្ញុំគិតថា វាជាការល្អត្រូវនិយាយថា មានគោលដៅពីរយ៉ាង ។ គោលដៅមួយ ឃោងទៅរកជីវិតបច្ចុប្បន្ន, ហើយត្រូវបានសំដែងក្នុងន័យកសាងអាណាចក្រមួយនៃមេត្តាធម៌, សេចក្តីចំរើនល្អលាស់ និងយុត្តិធម៌នៅក្នុងលោកនេះ ។ គោលដៅមួយទៀតខ្ពង់ខ្ពស់ជាង ឃោងទៅរកការសំរេចបានស្ថានសួគ៌ នៅក្នុងជីវិតជាតិក្រោយ ។ ប៉ុន្តែ នៅក្នុងពុទ្ធសាសនា យើងមានការពិចារណាទូលំទូលាយច្រើនជាង ។ និយាយម្យ៉ាងទៀត, គោលដៅនៃការបញ្ចប់ទុក្ខ ដែលព្រះពុទ្ធទ្រង់បានសំដែងនេះ គឺមានអត្ថន័យទូលំទូលាយ និងគម្ភីរភាពណាស់ ។ ពិព្រោះថាកាលណាយើងនិយាយអំពីការបញ្ចប់ទុក្ខ យើងអាចសំដៅន័យដល់ការបញ្ចប់ទុក្ខក្នុងពេលបច្ចុប្បន្ននេះ ឬមួយជាបណ្តោះអាសន្ន ឬមួយជារៀងរហូត ។ ចូរយើងពិចារណាមើល តើយើងអាចពន្យល់សភាវៈនេះអោយល្អិតល្អន់ជាងបានទេ ។ សន្មតថា យើងគាប់ជួនកំពុងមិតក្នុងភាពក្រីក្រយ៉ាងខ្លាំង - ខ្វះខាតស្បៀងអាហារ, ថ្នាំពេទ្យ, សាលារៀន ជាដើម ។ មានទុក្ខច្រើនយ៉ាង ដូចជា ការកើត, ជំងឺ, ជរា, ការព្រាត់ប្រាសពីមនុស្សជាទីស្រឡាញ់, ការជួបទាក់ទងជាមួយមនុស្សដែលយើងមិន

---

(១) សាសនារបស់ក្រុមពូជជាតិទាំងឡាយ រួមមានជាតិជ្វីស និងអារ៉ាប់, ហើយកាលពីពេលមុនរួមមានជនជាតិ ហ្វេនីស៊ីយាង និងអាស្ស៊ីរីយាងផង ។

ចូលចិត្ត ។ កាលណា យើងស្តារស្ថានភាពហ្នឹងបាន តាមរយៈការធ្វើអោយសំរេចបាននូវវឌ្ឍនភាព, តាមរយៈការអភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាល និងប្រព័ន្ធអប់រំ, ទុក្ខជាច្រើនយ៉ាងរបស់យើង ត្រូវបានកាត់បន្ថយ ។ ពុទ្ធសាសនាប្រៀនប្រដៅថា សុភ-មង្គល ឬទុក្ខសោកណាមួយ, ដែលបានទទួលនៅក្នុងជីវិតនេះ គឺជាលទ្ធផលនៃអំពើរបស់យើងកសាងពីក្នុងជាតិមុន ។ ម្យ៉ាងទៀត ប្រសិនបើយើងកំពុងឋិតក្នុងស្ថាន-ភាពមានភ័ព្វសំណាង, ស្ថានភាពទាំងនេះ គឺជាលទ្ធផលនៃអំពើល្អ ឬអំពើអំណោយផលដល់សុខភាពដែលបានធ្វើពីជាតិមុន ។ ដូចគ្នានេះដែរ, អ្នកទាំងឡាយដែលធ្លាក់ខ្លួនទៅក្នុងស្ថានភាពមិនសូវមានភ័ព្វសំណាង, ស្ថានភាពទាំងនោះ ក៏ជាលទ្ធផលនៃអំពើអកុសលដែលបានកសាងក្នុងជាតិមុនដែរ ។

តើពុទ្ធសាសនាប្រៀនប្រដៅអ្វីខ្លះក្នុងផ្លូវបញ្ចប់ទុក្ខ ? ការប្រតិបត្តិពុទ្ធ-សាសនាផ្តល់អោយនូវសុភមង្គលបែបណាមួយរយៈពេលខ្លីនៅក្នុងជាតិនេះ ។ សុភមង្គលនេះ អាចជាប្រភេទសម្ភារៈក្នុងន័យមានស្ថានភាពខាងសម្ភារៈគ្រាន់បើ, ឬវាអាចជាប្រភេទខាងស្មារតីក្នុងន័យមានសេចក្តីសុខស្ងប់ធំជាង ឬមានសុភមង្គលផ្លូវចិត្ត ។ ស្ថានភាពទាំងអស់នេះ អាចធ្វើអោយសំរេចបាននៅក្នុងជាតិនេះផ្ទាល់ ។ នេះគឺជាទិដ្ឋភាពមួយ នៃការបញ្ចប់ទុក្ខនៅក្នុងជីវិតនេះ ។ ហើយទិដ្ឋភាពនេះ គឺមានតម្លៃស្មើនឹងអ្វីដែលសាសនាសេមីទិកហៅថា រាជាណាចក្រលើដែនដី ( the kingdom on earth ) ។ បន្ថែមលើទិដ្ឋភាពនេះ, ការបញ្ចប់ទុក្ខមានន័យថាសុភមង្គល និងសំណាងល្អក្នុងជាតិក្រោយ, ក្នុងន័យថាមានកំណើតជាថ្មីក្នុងកាលៈទេសៈប្រកបដោយសំណាងល្អ, ក្នុងកាលៈទេសៈមានសុភមង្គល, មានភាពសម្បូររុងរឿង, មានសុខភាពល្អ, មានសុខុមាលភាព, មានជោគជ័យ . ល . ។ ហើយស្ថានភាពនេះ អាចកើតមានក្នុងសភាពជាមនុស្សនៅលើផែនដីនេះ ឬអាចកើតមាននៅក្នុងទេវលោក (the heavens) ។ យើងអាចប្រដូចស្ថានភាពនេះទៅនឹងស្ថានសួគ៌ ដែលសាសនា

សេមីទិកបាននិយាយ ។ គោលដៅរបស់ពុទ្ធសាសនាពុំដើមទី សំដៅសុភមង្គល និងសេចក្តីចំរើនរុងរឿងនៅក្នុងជាតិនេះ និងជាតិក្រោយ ។ ប៉ុន្តែ គោលដៅរបស់ពុទ្ធ-សាសនាឈានហួសពីនេះទៅទៀត, ហើយគឺត្រង់កន្លែងហ្នឹងហើយដែលពុទ្ធ-សាសនាខុសប្លែកពីសាសនាសេមីទិក ពីព្រោះពុទ្ធសាសនា មិនគ្រាន់តែសន្យាសុភ-មង្គល និងសេចក្តីរុងរឿងនៅក្នុងជាតិនេះ និងជាតិក្រោយប៉ុណ្ណោះទេ, ពុទ្ធសាសនាផ្តល់អោយនូវការរំដោះផងដែរ គឺព្រះនិព្វាន ដ៏ជាការរំលត់ទាំងស្រុងជ្រះស្រឡះ និងរៀងរហូតនៃសេចក្តីទុក្ខ ។ នេះគឺជាគោលដៅវែងឆ្ងាយចុងក្រោយនៃពុទ្ធសាសនា ។

កាលណាយើងនិយាយអំពីនិព្វាន យើងជួបប្រទះនឹងបញ្ហានៃការពន្យល់ប្រាប់ខ្លះៗ ពីព្រោះ កាលណាយើងនិយាយពីបទពិសោធន៍, ចរិតជាក់លាក់នៃបទពិសោធន៍នោះមិនអាចចម្លងទៅអោយគ្នាបានទេ ។ គេត្រូវពិសោធដោយខ្លួនគេផ្ទាល់ ។ នេះគឺការណ៍ពិតចំពោះបទពិសោធន៍ទាំងអស់ ទោះជាបទពិសោធន៍ទាំងនោះ ជាបទពិសោធន៍នៃរសជាតិស្ករ, អំពិល, សូកូឡា ឬអ្វីក៏ដោយ ។ បទពិសោធន៍ទាំងអស់នេះមិនអាចយកមកពិពណ៌នាដោយជាក់លាក់បានទេ ។ ខ្ញុំតែងសាកសួរជាញឹកញយ មនុស្សនៅសិង្ហបុរីនេះ ដើម្បីបញ្ជាក់ចំណុចនេះ ។ ចូរជញ្ជឹងគិតមើលថាខ្ញុំទើបបានមកដល់សិង្ហបុរីថ្មីៗ ហើយខ្ញុំមិនទាន់បានបរិភោគផ្លែធូរេនទេ ។ តើខ្ញុំអាចពិពណ៌នាច្បាស់លាស់នូវរសជាតិនៃផ្លែធូរេនបានឬទេ, បើខ្ញុំមិនទាន់ទាំងបានបរិភោគផ្លែធូរេនមួយដោយខ្លួនឯងផង ? យើងអាចពិពណ៌នាអំពីផ្លែធូរេន តាមមធ្យោបាយប្រៀបធៀប ឬប្រដូច ឬតាមមធ្យោបាយអវិជ្ជមានកម្ម ។ គឺតួយ៉ាងដូចជា លោកអ្នកអាចនិយាយថា ធូរេនមានរសជាតិជូរបន្តិច, វាមានសភាពដូចជាអាហារ ។ លោកអ្នកអាចនិយាយថា ធូរេន គឺប្រហាក់ប្រហែលផ្លែខ្នុរ ឬលោកអ្នកអាចនិយាយថា ផ្លែធូរេនមិនដូចផ្លែចេកទេ ។ ដូច្នេះ យើងមានប្រភេទបញ្ហាដូចៗគ្នាកាលណាយើងត្រូវសាកល្បងពិពណ៌នាអំពីនិព្វាន ។ យើងឃើញថា ព្រះពុទ្ធ និងគ្រូ

ប្រដៅពុទ្ធសាសនា បានប្រើប្រភេទពាក្យប្រៀបប្រដូចទាំងនេះ ដើម្បីពិពណ៌នាអំពីនិព្វាន ។

ព្រះពុទ្ធបានពិពណ៌នានិព្វាន ថាជាសុភមង្គល, ជាសន្តិភាព, ជាសភាវៈអមតៈដ៏ឧត្តម ។ ដូចគ្នានេះដែរ, ព្រះពុទ្ធបានពិពណ៌នានិព្វាន ថាជាសភាវៈឥតអ្នកបង្កើត, ឥតរូប, ជាសភាវៈហួសឆ្ងាយពីផែនដី, ហួសឆ្ងាយពីទឹក, ភ្លើង, ខ្យល់, ហួសឆ្ងាយពីព្រះអាទិត្យ និងព្រះចន្ទ, ស្ទង់ជម្រៅមិនដល់, វាស់ប្រវែងមិនបាន ។ ដូច្នេះយើងមានវិធីដោះស្រាយបញ្ហាពីរយ៉ាង ដើម្បីពិពណ៌នាព្រះនិព្វាន ។ វិធីទីមួយគឺ វិធីដោះស្រាយជាវិជ្ជមាន ដែលនៅក្នុងវិធីនេះ យើងប្រដូចនិព្វានទៅនឹងអ្វីមួយដែលយើងធ្លាប់ពិសោធនៅក្នុងលោកនេះ, ឧទាហរណ៍ កាលណាគេពិសោធ (ទទួលបាន) សុភមង្គលធំធេងជាមួយនឹងសន្តិភាពផ្លូវចិត្តយ៉ាងជ្រាលជ្រៅ គេអាចនឹកគិតថា គេកំពុងតែពិសោធពន្លឺព្រាលៗនៃនិព្វានហើយ ។ ប៉ុន្តែ ផ្លែខ្នុរមិនមែនដូចគ្នានឹងផ្លែធូរេនដោយពិតប្រាកដទេ ។ ដូចគ្នានេះដែរ, យើងអាចនិយាយថា និព្វានមិនដូចនឹងអ្វីមួយនៅក្នុងលោកនេះទេ, មិនដូចបទពិសោធន៍ណាមួយដែលយើងធ្លាប់ជួបប្រទះជារៀងរាល់ថ្ងៃទេ ។ និព្វាន គឺគ្មានអ្នកបង្កើត ។ និព្វានឈានហួសព្រះអាទិត្យ និងព្រះចន្ទ ។ និព្វានឈានហួសពីនាមនិងរូប ទាំងអស់នេះដែលយើងធ្លាប់គិត, ធ្លាប់ទាក់ទង, ឬតាមរយៈនាមនិងរូបនោះ យើងធ្លាប់ទទួលបទពិសោធន៍ពីពិភពលោកនេះទៅទៀត ។ ចំណុចនៃការពន្យល់រៀបរាប់ទាំងនេះគឺ : ដើម្បីយល់អ្វីជានិព្វានដោយពិតប្រាកដ វាទាល់តែគេទទួលបទពិសោធន៍នៃនិព្វាននោះដោយខ្លួនឯង ។ ដើម្បីស្គាល់ធូរេនដូចនឹងអ្វីដោយពិតប្រាកដបាន, វាទាល់តែគេធ្លាប់បានបរិភោគផ្លែធូរេននោះ គ្មានសេចក្ដីអធិប្បាយណា គ្មានការពិពណ៌នាណា ទោះល្អិតល្អន់យ៉ាងណាក៏ដោយអំពីផ្លែធូរេន អាចប្រៀបបាននឹងបទពិសោធន៍នៃការបរិភោគផ្លែធូរេនមួយបានទេ ។ គេត្រូវពិសោធការបញ្ចប់ទុក្ខដោយខ្លួនឯង ហើយមាគ៌ាដែលគេត្រូវដើរ

តាមដើម្បីបញ្ចប់ទុក្ខ គឺតាមរយៈការបំបាត់ហេតុនៃទុក្ខ គឺបំបាត់រាគៈ, ទោសៈ, និង អវិជ្ជា ។ កាលណាគេបានបំបាត់ហេតុនៃទុក្ខបានទាំងស្រុងហើយ, បន្ទាប់មក គេនឹង ពិសោធនិព្វានដោយខ្លួនគេផ្ទាល់ ។

តើគេត្រូវបន្សាត់បង់នូវហេតុទាំងឡាយនៃទុក្ខយ៉ាងដូចម្តេច ? តើអ្វីជា មធ្យោបាយ, ហើយតាមរយៈមធ្យោបាយនេះ តើគេអាចបន្សាត់បង់មន្ទិលសៅហ្មង ដែលនាំទៅរកទុក្ខយ៉ាងដូចម្តេច ? នោះគឺជាមាគ៌ា ដែលព្រះពុទ្ធបានប្រៀនប្រដៅ ។ មាគ៌ានោះ គឺជាមាគ៌ាកណ្តាល ពោលគឺ មជ្ឈិមបដិបទា ។ លោកអ្នកអាចរំលឹកឡើង វិញថា ជីវភាពរបស់ព្រះពុទ្ធ មុនព្រះអង្គបានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ បានឆ្លង កាត់សម័យកាលពីរផ្សេងគ្នាស្រឡះ ។ សម័យកាលមុនអភិនិស្ក្រមណ៍ គឺជាសម័យ កាលដែលព្រះអង្គសេពសោយនូវប្រណីតភាពគ្រប់យ៉ាង ( កាមសុខ ) ដែលអាច កើតមាន ។ យ៉ាងណាមិញ, យើងបានដឹងថា ព្រះអង្គមានប្រាសាទបី, ប្រាសាទ និមួយៗ សម្រាប់រដូវមួយ ។ ព្រះអង្គបានពិសោធប្រណីតភាពដ៏មានវិសាលភាព ដែលយើងពិបាកស្មានបាន ។ សម័យកាលប្រណីតភាពនេះ ត្រូវបានជំនួសដោយរយៈ ពេលប្រាំមួយឆ្នាំ នៃតបកម្មដ៏តឹងតែងបំផុត និងអត្តកិលមថកម្ម ( គឺការប្រព្រឹត្តកាន់ វត្តយ៉ាងតឹង ដើម្បីធ្វើកាយ និងចិត្តអោយស្ងប់ ) ក្រោយពេលព្រះអង្គបានបោះបង់ កាមសុខនៃជីវិត, ជាសម័យកាលដែលព្រះអង្គរស់នៅកណ្តាលវាល, ស្លៀកពាក់ សម្លៀកបំពាក់គ្រោតគ្រាត និងតមអាហារអស់ពេលយ៉ាងវែង ។ បន្ថែមលើការតម អាហារទាំងនេះ ព្រះអង្គបានពិសោធនូវការឈឺចាប់ នៃការធ្វើបាបរាងកាយតាមរយៈ ការប្រព្រឹត្តផ្សេងៗ ដើម្បីធ្វើកាយនិងចិត្តអោយស្ងប់ ដូចជាផ្ទំលើគ្រែមានបន្លា និង អង្គុយនៅកណ្តាលហ្វូងភ្នក់ភ្លើង ក្រោមកំដៅព្រះអាទិត្យថ្ងៃត្រង់ ។ បន្ទាប់ពីបានពិ- សោធនូវអច្ចន្តភាពនៃកាមសុខនិងអត្តកិលមថកម្ម ពោលគឺក្រោយពេលបានទៅដល់ កំរិតកំពូលនៃអច្ចន្តភាពទាំងនោះហើយ, ព្រះអង្គបានរកឃើញនូវភាពឥតខ្លឹមសារនៃ

អច្ចន្តភាពទាំងនោះ ហើយព្រះអង្គបានរកឃើញផ្លូវកណ្ដាលដែលចៀសផុតពីអច្ចន្ត-ភាពនៃការត្រេកត្រអាលក្នុងសេចក្ដីសប្បាយនៃវិញ្ញាណ ( កាមសុខល្លិកានុយោគ ) និងការប្រព្រឹត្តវត្តប្រតិបត្តិយ៉ាងតឹងដើម្បីរម្ងាប់កាយ-ចិត្ត (អត្តកិលមថានុយោគ) ។ គឺតាមរយៈការដឹងច្បាស់នូវធម្មជាតិនៃអច្ចន្តភាពក្នុងបទពិសោធន៍ផ្ទាល់របស់ព្រះអង្គនេះហើយ ទើបព្រះអង្គអាចឈានដល់មាគ៌ាកណ្ដាល (មជ្ឈិមបដិបទា), ជាមាគ៌ាដែលចៀសផុតពីអច្ចន្តភាពទាំងពីរ ។ ដូចដែលយើងនឹងឃើញនៅក្នុងសប្ដាហ៍ក្រោយៗ, មជ្ឈិមបដិបទាអាចមានការបកស្រាយជ្រាលជ្រៅ និងប្រកបដោយអត្ថន័យ, ប៉ុន្តែ សំខាន់បំផុត និងសារវន្តបំផុត, បដិបទាមានន័យថា ការស្គាល់ប្រ-មាណក្នុងវិធីដោះស្រាយបញ្ហារបស់ខ្លួនចំពោះការរស់នៅ, ការស្គាល់ប្រមាណក្នុងអាកប្បកិរិយារបស់ខ្លួន, និងការស្គាល់ប្រមាណក្នុងវត្ថុទាំងឡាយទាំងពួង ។ យើងប្រើឧទាហរណ៍ ពិណខ្សែបីដើម្បីពន្យល់បំភ្លឺមជ្ឈិមបដិបទា ។ សម័យមួយនោះ, មានសាវ័កមួយអង្គរបស់ព្រះពុទ្ធព្រះនាមសោណៈ ដែលបានហាត់ធ្វើសមាធិយ៉ាងតឹងរ៉ឹងពេកទៅ ទាល់តែលោកមិនអាចមានការជឿនលឿនក្នុងសមាធិរបស់លោកបាន ។ លោកបានចាប់ផ្ដើមគិតបោះបង់ចោលជីវភាពរបស់លោកជាភិក្ខុសង្ឃ ។ ព្រះពុទ្ធទ្រង់បានជ្រាបពីសន្ដានចិត្តរបស់ភិក្ខុនោះ ទ្រង់បានមានពុទ្ធដីកាចំពោះភិក្ខុនោះថា : « ម្នាលសោណៈ, មុនពេលលោកមកបួសជាភិក្ខុ, លោកគឺជាអ្នកភ្លេងម្នាក់ » ។ ភិក្ខុសោណៈបានទូលតបវិញថា ពិតដូច្នោះមែន ។ ពេលនោះ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា : « ក្នុងឋានៈជាអ្នកភ្លេង តើខ្សែពិណបែបណាបង្កើតបានសំឡេងពិរោះរណ្ដំបាន ។ តើខ្សែរឹតតឹងពេកឬ ? » សោណភិក្ខុទូលតបថា « មិនមែនទេ, ខ្សែរឹតតឹងពេកបង្កើតចេញសំឡេងមិនពិរោះទេ ហើយលើសនេះទៀត វានឹងដាច់នៅពេលណាមួយ » ។ - « ចុះខ្សែរឹតធូរពេកឬ ? » - « ហ្នឹងក៏ពុំមែនដែរ, ខ្សែដែលរឹតធូរពេក មិនបង្កើតបានសំឡេងរណ្ដំទេ ។ ខ្សែដែលបង្កើតបានសំឡេង

រណ្ដំ គឺខ្សែដែលរឹតមិនតឹងពេក និងមិនធូរពេក » ។ ដូច្នេះ នៅទីនេះ ជីវិតប្រកបដោយប្រណីតភាព គឺជាជីវិតធូរលុងពេក គ្មានវិន័យ ។ ជីវិតប្រព្រឹត្តធ្វើអោយរាងកាយឈឺចាប់ ( អត្តកិលមថកម្ម ) គឺជាជីវិតតឹងពេក, ធ្ងន់ធ្ងរពេក បីដូចជាបណ្ដាលអោយចិត្ត និងរូបកាយត្រូវវិនាស ប្រៀបបាននឹងខ្សែពិណរឹតតឹងពេក ត្រៀមតែនឹងដាច់នៅពេលណាមួយ ។

តាមការណ៍ជាក់ស្ដែង, មាគ៌ានាំទៅរកគោលដៅរបស់ព្រះពុទ្ធ គឺដូចជាវេជ្ជបញ្ញាដូច្នោះ ។ កាលណា វេជ្ជបណ្ឌិតដ៏ជំនាញម្នាក់ព្យាបាលអ្នកជំងឺធ្ងន់, វេជ្ជបញ្ញារបស់លោកមិនមែនសម្រាប់តែព្យាបាលរូបកាយប៉ុណ្ណោះទេ, ប៉ុន្តែសម្រាប់ព្យាបាលផ្លូវចិត្តផងដែរ ។ ប្រសិនបើមនុស្សម្នាក់មានការឈឺចាប់, ជាឧទាហរណ៍, ដោយជំងឺបេះដូង, គេមិនត្រូវអោយតែថ្នាំទៅមនុស្សនោះប៉ុណ្ណោះទេ ។ គេត្រូវសុំអោយមនុស្សនោះត្រួតមើលអាហាររបស់ខ្លួន, ហើយអោយចៀសវាងស្ថានភាពពិបាកផ្លូវចិត្ត ។ នៅទីនេះដែរ, កាលណាយើងក្រឡេកមើលសេចក្ដីណែនាំដោយឡែកទាក់ទងនឹងការប្រតិបត្តិតាមមាគ៌ាបញ្ចប់នូវទុក្ខ, យើងអាចឃើញថា សេចក្ដីណែនាំទាំងនោះ និយាយយោងដល់មិនមែនតែត្រឹមអំពើតាមផ្លូវកាយ និងវាចារបស់មនុស្សប៉ុណ្ណោះទេ, ប៉ុន្តែទាក់ទងដល់ចិត្តគំនិតរបស់មនុស្សនោះផងដែរ ។ និយាយមួយបែបទៀត, អរិយមគ្គប្រាំបីយ៉ាងដ៏ជាមាគ៌ានាំទៅដល់ការបញ្ចប់ទុក្ខ គឺជាមាគ៌ារួមពោលគឺ ជាវិធីព្យាបាលរោគប្រមូលចងក្រងឡើង ។ វិធីនេះ ត្រូវបានប្រើសម្រាប់ព្យាបាលរោគអោយជាសះស្បើយតាមរយៈការបំបាត់នូវហេតុ, តាមរយៈការព្យាបាលដែលអនុវត្តមិនគ្រាន់តែចំពោះរាងកាយប៉ុណ្ណោះទេ ប៉ុន្តែចំពោះចិត្តថែមទៀត ។

សម្មាទិដ្ឋិ ( ការយល់ដឹងត្រូវ ) គឺជាជំហានដំបូងនៃអរិយមគ្គទាំងប្រាំបីប្រការ ឬអរិយដ្ឋង្គិកមគ្គ ហើយបន្ទាប់មកមាន សម្មាសង្កប្បៈ (ការត្រិះរិះត្រូវ), សម្មាវាចា (ការពោលពាក្យត្រូវ), សម្មាកម្មន្តៈ (ការងារ ឬអំពើត្រូវ), សម្មាអាជីវៈ

(ការចិញ្ចឹមជីវិតត្រូវ), សម្មាវាយាមៈ (ការព្យាយាមត្រូវ), សម្មាសតិ (ការរលឹកត្រូវ) និងសម្មាសមាធិ (ការតាំងចិត្តត្រូវ) ។ ហេតុអ្វីបានជាយើងចាប់ផ្តើមពីសម្មាទិដ្ឋិមុននេះក៏ព្រោះថា ដើម្បីឡើងភ្នំ យើងត្រូវតែមើលកំពូលភ្នំអោយឃើញច្បាស់ ។ នៅក្នុងន័យនេះ, ជំហានទីមួយ ត្រូវពឹងផ្អែកលើជំហានបន្ទាប់ ។ យើងត្រូវមើលអោយឃើញគោលដៅរបស់យើង ប្រសិនបើយើងចង់ធ្វើដំណើរតាមផ្លូវ ដើម្បីទៅដល់គោលដៅនោះ ។ ក្នុងន័យនេះ សម្មាទិដ្ឋិ ប្រាប់ទិសនិងតម្រង់ទិសជំហានដទៃទៀតតាមផ្លូវ ។ ក្នុងទីនេះ យើងឃើញថា ជំហានពីរដំបូងគឺ សម្មាទិដ្ឋិ និងសម្មាសង្កប្បៈយោងទៅរកចិត្ត ។ តាមរយៈសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ យើងកំចាត់បង់នូវអវិជ្ជា, លោភៈ និងទោសៈ ។ ប៉ុន្តែ ប៉ុណ្ណោះមិនទាន់គ្រប់គ្រាន់ដើម្បីនិយាយថា តាមរយៈសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ យើងកំចាត់បានអវិជ្ជា, លោភៈ និងទោសៈទេ ពិព្រោះដើម្បីសំរេចបានសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ យើងត្រូវការអប់រំ និងជំរះអោយបរិសុទ្ធ នូវចិត្តនិងកាយរបស់យើងផងដែរ ។ បែបបទដែលកិច្ចការនេះត្រូវធ្វើ គឺតាមរយៈជំហានមាគ៌ាប្រាំមួយផ្សេងទៀត ។ យើងជំរះអោយបរិសុទ្ធ នូវអត្តិភាពរូបកាយរបស់យើង ដើម្បីអោយវាងាយស្រួលជំរះអោយស្អាតនូវចិត្តរបស់យើង, ហើយយើងជំរះអោយបរិសុទ្ធនូវចិត្តរបស់យើង ដើម្បីអោយវាងាយស្រួលចាប់យកសម្មាទិដ្ឋិបាន ។

ដើម្បីអោយស្រួលស្តាប់ ស្រួលយល់, អរិយដ្ឋង្គិកមគ្គ (មាគ៌ាដ៏ប្រសើរប្រាំបីយ៉ាង) ត្រូវបានគេចែកតាមទម្លាប់រៀងមកជាបីក្រុមសម្រាប់ហ្វឹកហ្វឺន ឬបីបែបសម្រាប់ប្រតិបត្តិ គឺ ៖ សីល (ចរិយាធម៌ ឬការប្រព្រឹត្តល្អ), សមាធិ (ការជញ្ជឹងគិត ឬការអភិវឌ្ឍចិត្ត), និងបញ្ញា (សមត្ថភាពវែកញែកអ្វីត្រូវ អ្វីពិត ហើយវិនិច្ឆ័យ និងប្រព្រឹត្តទៅតាមនោះ) ។ ជំហានមាគ៌ាទាំងប្រាំបីយ៉ាង ក៏ត្រូវបានបែងចែកទៅជាបែបបទប្រតិបត្តិបីយ៉ាង ដូចតទៅ ៖ សម្មាវាចា, សម្មាកម្មន្តៈ, និងសម្មាអា

ជីវៈ ត្រូវចាត់ចូលក្នុងបែបបទនៃការប្រព្រឹត្តល្អ ពោលគឺ សីល, សម្មាវាយាមៈ, សម្មាសតិ, និងសម្មាសមាធិ ត្រូវចាត់ចូលក្នុងបែបបទនៃការអភិវឌ្ឍចិត្ត ពោលគឺ សមាធិ រីឯសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ត្រូវចាត់ចូលក្នុងបែបបទនៃបញ្ញា (ពោលគឺ សមត្ថភាពសម្លឹងឃើញអ្វីពិត អ្វីត្រូវ ហើយវិនិច្ឆ័យ និងប្រព្រឹត្តទៅតាមនោះ) ។ ដោយហេតុតែមានការចាំបាច់ដើម្បីធ្វើអោយបរិសុទ្ធនូវវាចា និងអំពើ មុនពេលយើងអាចធ្វើចិត្តរបស់យើងអោយស្អាតបរិសុទ្ធ, យើងត្រូវផ្តើមវឌ្ឍនភាពរបស់យើង តាមគន្លងមាគ៌ានៃចរិយាល្អ ពោលគឺ សីល ។ ដោយហេតុថា អរិយដ្ឋង្គិកមគ្គ គឺជាមធ្យោបាយដើម្បីទៅដល់គោលដៅនៃពុទ្ធសាសនា, យើងនឹងចំណាយពេលបីសប្តាហ៍ក្រោយនេះ ដើម្បីសិក្សាពិចារណាមាគ៌ាប្រតិបត្តិបីយ៉ាងនេះ ។

*

* *

## (V)

## សីលធម៌

កាលពីសប្តាហ៍កន្លងទៅ, យើងបានបញ្ចប់ការសិក្សារបស់យើងអំពីអរិយសច្ចៈបួនរួចហើយ, ហើយក្នុងការសិក្សានេះ, ប្រធានបទចុងក្រោយដែលយើងបានសិក្សា គឺមាគ៌ាដ៏ប្រសើរប្រាំបីយ៉ាង (អរិយដ្ឋង្គិកមគ្គ) ដើម្បីបញ្ចប់នូវទុក្ខ ។ យើងបានប្រើការប្រដូចទៅនឹងការឡើងភ្នំ នៅពេលយើងបាននិយាយអំពីការដើរលើមាគ៌ាប្រាំបីយ៉ាងទៅកាន់ការបញ្ចប់ទុក្ខ ។ យើងបាននិយាយថា បីដូចជាពេលគេឡើងភ្នំ ជំហានដំបូង ពឹងផ្អែកលើជំហានចុងក្រោយ, ជំហានចុងក្រោយ ក៏ពឹងផ្អែកលើ

ជំហានដំបូង ពីព្រោះយើងត្រូវបើកភ្នែកសម្លឹងយ៉ាងម៉ឺងម៉ាត់នូវកំពូលភ្នំ ប៉ុន្តែយើងក៏ត្រូវប្រុងប្រយ័ត្នមិនអោយជំពប់ដើងនៅពេលកំពុងបោះជំហានដំបូងឡើងតាមផ្លូវទៅកាន់កំពូលភ្នំ ។ ដូច្នេះនៅទីនេះ ក្នុងការឡើងភ្នំ កំណាត់ផ្លូវនិមួយៗ ពឹងផ្អែកលើកំណាត់ផ្លូវទាំងឡាយផ្សេងទៀត ។ ក្នុងករណីនេះ ចំពោះមាគ៌ាដ៏ប្រសើរប្រាំបីយ៉ាង, ជំហានទាំងអស់នៃមាគ៌ាតែងមានចំណងទាក់ទងគ្នាទៅវិញទៅមក, អាស្រ័យគ្នាទៅវិញទៅមក ។ យើងពុំអាចបោះបង់ចោលជំហានឯណានីមួយបានទេ ។ ប៉ុន្តែថាសម្រាប់គោលបំណងប្រតិបត្តិ ជំហានទាំងប្រាំបីនៃមាគ៌ាត្រូវបានចែកចេញជាបែបបទប្រតិបត្តិបីយ៉ាង ឬជាផ្នែកហ្វឹកហ្វឺនបីយ៉ាង ។ ផ្នែកទាំងបីនេះគឺ សីល, សមាធិ, និងបញ្ញា ។ បើគិតតាមទ្រឹស្តី និងតាមរចនាសម្ព័ន្ធ, ជំហានដំបូង ពឹងផ្អែកលើជំហានចុងក្រោយ, ទោះបីជំហានទាំងពីរ ពឹងផ្អែកលើគ្នាទៅវិញទៅមកក៏ដោយ, ប៉ុន្តែ ក្នុងន័យប្រតិបត្តិជាក់ស្តែង, កាលណាគេឡើងភ្នំ គេត្រូវឡើងតាមជំរាលដ៏ទាបបំផុត ជាដំបូង ។ គេអាចតម្រង់ចិត្តឆ្ពោះទៅកាន់កំពូលភ្នំ, ប៉ុន្តែដើម្បីទៅដល់ទីនោះ គេត្រូវដើរតាមជំរាលទាបជាដំបូងសិន ។ គឺដោយសំអាងហេតុផលជាក់ស្តែងនេះហើយដែលយើងឃើញជំហានទាំងប្រាំបី នៃអរិយមគ្គផ្តុំគ្នាទៅជាបែបបទប្រតិបត្តិបីយ៉ាង ។

ក្នុងបណ្តាបែបបទទាំងបីនេះ បែបបទដំបូងគេ គឺសីល ( ការប្រព្រឹត្តល្អ ឬចរិយាល្អ ) ។ សីល បង្កើតបានជាគ្រឹះសម្រាប់ដំណើរជឿនលឿនវែងឆ្ងាយនៅលើមាគ៌ា, សម្រាប់ការរីកចំរើនផ្ទាល់ខ្លួនវែងឆ្ងាយ ។ គេនិយាយថា បីដូចជាព្រះធរណីធ្វើជាមូលដ្ឋានសម្រាប់វត្ថុទាំងឡាយមានជីវិត និងឥតជីវិតទាំងអស់, ដូចគ្នានេះដែរសីល គឺជាគ្រឹះនៃគុណធម៌ទាំងអស់ ។ កាលណាយើងក្រឡេកមើលជុំវិញខ្លួនយើង យើងអាចឃើញថា វត្ថុសព្វយ៉ាងមិតនៅលើផែនដី ទោះជាអគារក្តី ទោះជាដើមឈើ និងរុក្ខាលតាវល្លិក្តី ឬជាសត្វធាតុក្តី ។ ព្រះធរណីឬផែនដី គឺជាគ្រឹះ, ហើយក្នុង

បែបបទដូចគ្នានេះ សីលគឺជាគ្រឹះនៃគុណធមិទាំងអស់, គុណសម្បត្តិទាំងអស់, សមិទ្ធិទាំងអស់ រាប់តាំងពីសមិទ្ធិលោកិយ រហូតដល់សមិទ្ធិបរលោក, រាប់តាំងពីជោគជ័យ, ភ័ព្វសំណាងល្អ រហូតទៅដល់ជំនាញក្នុងសមាធិ, បញ្ញា និងការត្រាស់ដឹង ។ តាមរយៈពាក្យឧបមានេះ, យើងអាចយល់បាននូវសារប្រយោជន៍ នៃសីល (ចរិយាល្អ) ទុកដូចជាគ្រឹះសម្រាប់ការប្រតិបត្តិតាមមាគ៌ា, ទុកដូចជាមូលដ្ឋានសម្រាប់សំរេចអោយបាននូវលទ្ធផលលើមាគ៌ា ។

ព្រោះហេតុអ្វី ទើបយើងយកពេលសង្កត់លើសារប្រយោជន៍ នៃសីល ទុកដូចជាគ្រឹះសម្រាប់សេចក្តីជឿនលឿនលើមាគ៌ា ? ហេតុផល គឺថា វាមានទំនោរមួយ ចាត់ទុកសីលជាសភាវៈគួរអោយធុញទ្រាន់ ស្ងួតស្រពន់ ។ សមាធិ ហាក់ដូចជាធ្វើអោយចិត្តរំភើបជាង, ជាប់ចិត្តជាង ។ ទស្សនវិជ្ជាមានការទាក់ទាញចិត្តបែបណាមួយអំពីសមាធិនេះ ។ វាមាននិន្នាការដ៏គ្រោះថ្នាក់មួយចំពោះការមិនយកចិត្តគិតគូរពីសារប្រយោជន៍ នៃសីល ហើយឈានទៅរកផ្នែករំភើបចិត្តជាងនៃមាគ៌ា ។ ប៉ុន្តែប្រសិនបើយើងមិនបង្កើតអោយបាននូវគ្រឹះនៃសីលទេ, យើងនឹងមិនសំរេចជោគជ័យក្នុងការឈានជើងដើរលើផ្នែកទាំងឡាយផ្សេងទៀត នៃមាគ៌ាបានឡើយ ។

យើងត្រូវយល់ពីបែបបទ ដែលនៅក្នុងនេះ សិក្ខាបទ និងបទបញ្ញត្តិទាំងឡាយនៃសីល ត្រូវបានកំណត់ឡើងនៅក្នុងវង្សពុទ្ធសាសនា ពិព្រោះ វាមានបែបបទច្រើន ដែលនៅក្នុងនេះ ក្រមសីលធមិ ឬក្រមចរិយាធមិត្រូវបានបង្កើតឡើង ។ ប្រសិនបើ លោកអ្នកក្រឡេកមើលក្រមសីលធមិរបស់សាសនាធំៗ, លោកអ្នកនឹងឃើញថា វាមានភាពស្របគ្នាមួយគួរអោយភ្ញាក់ ។ ប្រសិនបើ លោកអ្នកក្រឡេកមើលពាក្យប្រៀនប្រដៅសីលធមិរបស់កុងហ្វូស៊ីស (Confucius), របស់ឡៅត្ស៊ី (Lao Tzu), របស់ព្រះពុទ្ធ, របស់គ្រូប្រដៅសាសនាហិណ្ឌូ, របស់អ្នកកាន់គ្រីស្តសាសនា, របស់អ្នកកាន់សាសនាឥស្លាម, និង របស់អ្នកកាន់សាសនាជ្វីស,

លោកអ្នកនឹងឃើញថា ចំពោះបទបញ្ញត្តិជាគ្រឹះនៃសីលធម៌ វាមានកំរិតស្របគ្នាយ៉ាងទូលំទូលាយ ។ ប៉ុន្តែ នៅពេលបទបញ្ញត្តិទាំងឡាយ នៅក្នុងករណីដ៏ច្រើនស្របគ្នា, អាកប្បកិរិយា, បែបបទទាំងឡាយ ដែលនៅក្នុងនេះ បទបញ្ញត្តិទាំងឡាយត្រូវបានគេបង្ហាញ, គេយល់ និងបកស្រាយផ្សេងពីគ្នាយ៉ាងសម្បើម ពីសាសនាមួយ ទៅសាសនាមួយ ។ ជាសំខាន់ ដោយនិយាយរួមជាទូទៅ វាមានបែបបទពីរយ៉ាង ដែលនៅក្នុងនេះ ក្រមសីលធម៌អាចត្រូវបានបង្កើតឡើង ។ បែបបទទីមួយ យើងអាចអោយឈ្មោះថា បែបបទអាជ្ញាព្រឹត្ត ( ដែលប្រើអាជ្ញា ) ហើយបែបបទមួយទៀតយើងអោយឈ្មោះថា បែបបទប្រជាធិបតេយ្យ ។ ហើយឧទាហរណ៍ដ៏ល្អមួយសម្រាប់បញ្ជាក់បែបបទទីមួយគឺ អាទិទេពបង្ហូរចុះនូវបទបញ្ជាដប់ប្រការទៅអោយលោក ម៉ូស៊ីស (Moses) ដែលស្ថិតនៅលើកំពូលភ្នំ ។ ចំណែកនៅក្នុងពុទ្ធលទ្ធិវិញខ្ញុំគិតថា អ្វីដែលយើងមាននៅក្នុងទីនេះ អាចត្រូវបានហៅថា បែបបទប្រជាធិប-តេយ្យមួយ ដើម្បីបង្កើតឡើងនូវបទបញ្ញត្តិនៃសីល (ចរិយាល្អ) ។ លោកអ្នកអាចឆ្ងល់ថា ហេតុអ្វីខ្ញុំនិយាយដូច្នេះ ។ នៅទីបំផុត យើងក៏មានបទបញ្ញត្តិនៃសីល ចារឹកទុកនៅក្នុងគម្ពីរ ។ ដូច្នេះ លោកអ្នកអាចសួរថា តើនេះមិនដូចគ្នាទៅនឹងព្រះអាទិទេពផ្តល់ក្បួនទៅអោយលោក ម៉ូស៊ីស (Moses) ទេឬ ? ប៉ុន្តែ ខ្ញុំគិតថា នេះមិនដូចគ្នាដោយពិតប្រាកដទេ ពិព្រោះ បើយើងពិនិត្យមើលគម្ពីរអោយជិតដល់ទៅ យើងប្រា-កដជាឃើញថា អ្វីឋិតនៅពីក្រោយបទបញ្ញត្តិនៃសីល ហើយនិងគោលការណ៍ទាំងឡាយដែលស្ថិតនៅពីក្រោយនោះគឺ គ្រឹះនៃបទបញ្ញត្តិរបស់សីល, គឺគោលការណ៍ទាំងឡាយនៃសមភាព និងអញ្ញមញ្ញភាព ( ភាពយល់គ្នាទៅវិញទៅមក ) ។

អ្វីដែលសមភាពសំដៅដល់ គឺថា សព្វសត្វមានជីវិត ត្រូវមានភាពស្មើគ្នានៅក្នុងអាកប្បកិរិយាជាសារវន្តរបស់គេ ។ និយាយម្យ៉ាងទៀត, សព្វសត្វមានជីវិតប្រាថ្នាចង់បានសេចក្តីសុខ ។ គេខ្លាចការឈឺចាប់, មរណភាព, និងសេចក្តីទុក្ខ ។ សត្វ

ទាំងអស់ចង់មានជីវិតរស់នៅ, ចង់បានសុភមង្គល និងសន្តិសុខ ។ សេចក្តីប្រាថ្នានេះ គឺមានពិតចំពោះសព្វសត្វ ក៏ដូចមានពិតចំពោះខ្លួនយើងដែរ ។ យើងអាចអោយឈ្មោះសមភាពនេះថា មហាសកលភាព (the great universality) នៃទស្សន.វិស័យរបស់ពុទ្ធសាសនា ដែលនៅក្នុងទស្សនៈនេះ សត្វមានជីវិតទាំងអស់មានភាពស្មើៗគ្នា ។ ផ្អែកលើមូលដ្ឋាននៃសមភាពនេះ យើងមានការលើកទឹកចិត្តអោយប្រ.ព្រឹត្តប្រកបដោយសេចក្តីភ្ញាក់រលឹកចំពោះគ្នាទៅវិញទៅមក ។

អញ្ញមញ្ញភាព (ពោលគឺ ភាពយោគយល់គ្នាទៅវិញទៅមក) មានអត្ថន័យថា យើងមិនចូលចិត្តអោយគេសម្លាប់យើង, លួចប្លន់សម្បត្តិយើង, រំលោភបំពានយើង ... ជាដើមទេ, ក៏ដូចគ្នានេះ សព្វសត្វមានជីវិតដទៃទៀត ក៏មិនចូលចិត្តអោយមានរឿងបែបនោះកើតមានចំពោះគេដែរ ។ គេអាចដាក់ចេញគោលការណ៍អញ្ញ.មញ្ញភាពនេះយ៉ាងសាមញ្ញ ដោយនិយាយថា « ចូរកុំប្រព្រឹត្តចំពោះអ្នកឯទៀត ក្នុងបែបបទណាដែលអ្នកមិនចង់អោយគេប្រព្រឹត្តចំពោះខ្លួនអ្នក » ។ យោងតាមគោលការណ៍សមភាព និងអញ្ញមញ្ញភាព វាពុំមានការពិបាកដើម្បីមើលឃើញថា តើគេត្រូវមានជំហរយ៉ាងណា គេត្រូវបង្កើតគ្រឹះសម្រាប់បទបញ្ញត្តិនៃចរិយាល្អ (សីល) យ៉ាងណានោះទេ ។

ឥឡូវ ចូរយើងមើលអោយចំអត្ថន័យនៃសីល នៅក្នុងលទ្ធិពុទ្ធសាសនា ។ បែបបទប្រតិបត្តិសីល រួមមានផ្នែកបី នៃអរិយដ្ឋង្គិកមគ្គ ហើយផ្នែកទាំងបីនោះ គឺសម្មាវាចា, សម្មាកម្មន្តៈ, និងសម្មាអាជីវៈ ។ វាចា គឺជាផ្នែកមួយដ៏មានសារសំខាន់បំផុតនៃជីវិតរបស់យើង ។ ជាញឹកញាប់ យើងច្រើនមើលស្រាលអានុភាពនៃវាចា ។ ជាញឹកញយ យើងច្រើនតែប្រើការត្រួតពិនិត្យតិចតួចណាស់ទៅលើសមត្ថភាព នៃវាចា ។ នេះមិនគួរអោយមានប្រការដូចនេះទេ ។ យើងទាំងអស់គ្នា តែងបានទទួលការឈឺចាប់ខ្លាំងណាស់ ដោយពាក្យសំដីរបស់អ្នកណាមួយ នៅពេលណាមួយនៃជីវិត

របស់យើង ។ ហើយដូចគ្នានេះដែរ យើងបានទទួលការលើកទឹកចិត្ត ដោយពាក្យសំដីរបស់អ្នកណាមួយផ្សេង ។ នៅក្នុងឆាកនយោបាយ យើងអាចឃើញថា តើមានឥទ្ធិពលយ៉ាងណា អ្នកដែលមានសមត្ថភាពនិយាយឆ្លើយឆ្លងប្រកបដោយប្រសិទ្ធភាព អ្នកដែលមានសមត្ថភាពនិយាយជះឥទ្ធិពលយ៉ាងធំសម្បើមមកលើប្រជាពលរដ្ឋ ដើម្បីអោយមានភាពល្អ ឬដើម្បីអោយមានភាពអាក្រក់ ។ លោក ហ៊ិតឡែរ, លោក ឈឺរឈិល, លោក ម៉ាវតាំង លូថែរ ឃីង គឺជាវាគ្មិនដ៏ពូកែអស្ចារ្យ ដែលមានសមត្ថភាពគ្របសង្កត់លើមនុស្សរាប់លាននាក់ ដោយសារពាក្យសំដីរបស់គេ ។ និយាយពាក្យអសុរោះមួយម៉ាត់ អាចធ្វើអោយមានរបួសយ៉ាងជ្រៅជាងអាវុធទៅទៀត ។ ពាក្យទន់ភ្លន់មួយម៉ាត់ អាចផ្លាស់ប្តូរហឫទ័យ និងចិត្តរបស់ឧក្រិដ្ឋជនក្បាលរឹងបំផុតបាន ។ ប្រហែលជាលើសលប់អ្វីៗឯទៀត, សមត្ថភាពនៃវាចា (ការនិយាយស្តី) ធ្វើអោយមនុស្សខុសប្លែកពីសត្វ ។ ដូច្នេះ ប្រសិនបើគេត្រូវអភិវឌ្ឍសង្គមមួយដែលនៅក្នុងសង្គមនោះ ភាពសុខដុមរមនា, សុខុមាលភាព, ការប្រាស្រ័យទាក់ទងគ្នា និងសហប្រតិបត្តិការ គឺជាគោលដៅដែលត្រូវសំរេចអោយបាន, នោះគេត្រូវត្រួតពិនិត្យ, បណ្តុះបណ្តាល និងប្រើប្រាស់សមត្ថភាពនៃវាចា (ការនិយាយស្តី) អោយបានសមស្រប ។

បទបញ្ញត្តិទាំងអស់ នៃសីលមានជាប់ទាក់ទងនឹងការគោរព ដែលមានគ្រឹះចិតនៅលើការយល់ដឹងពីសមភាព និងអញ្ញមញ្ញភាព ។ នៅក្នុងបរិបទនេះ សម្មាវាចា ( ការនិយាយស្តីត្រឹមត្រូវ ) មានជាប់ទាក់ទងនឹងការគោរពពាក្យសច្ចៈ និងការគោរពសុខុមាលភាពរបស់អ្នកដទៃ ។ ប្រសិនបើគេនិយាយស្តីប្រកបដោយលក្ខណៈវិនិច្ឆ័យទាំងនេះនៅក្នុងចិត្ត, គេនឹងបណ្តុះបណ្តាលបាននូវសម្មាវាចា ហើយតាមរយៈនេះ គេនឹងសំរេចបាននូវភាពសុខដុមយ៉ាងធំធេងនៅក្នុងសង្គម ។ តាមទម្លាប់, យើងតែងនិយាយអំពីទិដ្ឋភាពបួនយ៉ាងនៃសម្មាវាចា ។ សម្មាវាចា មានន័យថា ចៀសវាងការ

និយាយកុហក, ចៀសវាងការនិយាយដើម ឬនិយាយមួលបង្កាច់, ចៀសវាងការនិយាយពាក្យទាក់ដោត, ចៀសវាងការនិយាយពាក្យប៉ប៉ាច់ប៉ប៉ោច ។ មានអ្នកខ្លះក្នុងចំណោមអស់លោក អាចនៅចាំពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធចំពោះ រាហុល ទាក់ទងនឹងសារសំខាន់ នៃការចៀសវាងនិយាយកុហក ។ ព្រះអង្គបានប្រើឧបករណ៍ គឺភាជន៍មួយ ។ ភាជន៍មានទឹកមួយចំនួនតិចនៅក្នុងបាត រួចព្រះអង្គទ្រង់សាកសួរថា, « ម្នាលរាហុល, ចូរមើលទឹកតិចតួចនេះនៅក្នុងបាតភាជន៍ ។ អ្នកទាំងឡាយណាជាមនុស្សឥតអៀនខ្មាស ចូលចិត្តនិយាយកុហក, គុណធម៌របស់គេទាំងនោះមានតិចតួច, ការលះបង់ទ្រព្យចេញបួសរបស់គេ ក៏មានគុណធម៌តិចតួច បីដូចជាទឹកតិចតួចនៅក្នុងភាជន៍ដូច្នេះ » ។ បន្ទាប់មក ព្រះពុទ្ធទ្រង់បានជះទឹកនោះចោល ហើយទ្រង់មានពុទ្ធដីកាថា « អ្នកទាំងឡាយណាដែលមិនអៀនខ្មាសនឹងការនិយាយកុហក តែងគ្រវែងចោលគុណធម៌របស់ខ្លួន បីដូចជាទឹកនេះ ត្រូវបានជះចោលដូច្នេះ » ។ បន្ទាប់មក ព្រះពុទ្ធបានបង្ហាញដល់រាហុល នូវភាជន៍ទទេ ហើយទ្រង់មានពុទ្ធដីកាថា « ទទេយ៉ាងនេះ, គុណធម៌របស់អ្នកទាំងឡាយនោះ ដែលបានលះបង់ទ្រព្យចេញសាងផ្នួសហើយមានទម្លាប់និយាយកុហក » ។

ដោយប្រការយ៉ាងនេះ ព្រះអង្គបានយកភាជន៍ជាមធ្យោបាយបញ្ជាក់ចំណុចថា ការនិយាយកុហកមានជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការប្រព្រឹត្តអំពើជាកុសលរបស់ខ្លួន, ចរិយាល្អរបស់ខ្លួន, ចរិតល្អរបស់ខ្លួន ។ ពេលណា យើងមានទំនុកចិត្តថា យើងអាចប្រព្រឹត្តតាមបែបមួយ ហើយនិយាយតាមបែបមួយផ្សេង, បន្ទាប់មក យើងនឹងមិនញញើតដើម្បីប្រព្រឹត្តអាក្រក់ឡើយ, ពិព្រោះយើងជឿទុកចិត្តថា យើងអាចបិទបាំងអំពើអាក្រក់របស់យើងបានដោយការនិយាយកុហក ។ ហេតុនេះ ការនិយាយកុហក បើកទ្វារអោយអំពើអកុសលគ្រប់យ៉ាងចូលបាន ។ ពាក្យពោលមួលបង្កាច់នាំមកនូវការបែកបាក់គ្នា ។ វាបង្កើតអោយមានជម្លោះក្នុងចំណោមមិត្ត

ភក្តិ ។ វាបង្កើតអោយមានការឈឺចាប់ និងបែកបាក់សាមគ្គីភាព ។ ដូច្នេះដោយហេតុថា គេមិនចង់អោយមានការបែកបាក់អំពីមិត្តភក្តិរបស់គេតាមរយៈពាក្យពោលមួលបង្កាច់, ហេតុនេះ គេមិនត្រូវនិយាយមួលបង្កាច់អ្នកដទៃឡើយ ។ យ៉ាងដូច្នេះទៀត គេមិនត្រូវរំលោភបំពានអ្នកដទៃដោយពាក្យទ្រគោះ, ប៉ុន្តែ ផ្ទុយទៅវិញ គេគប្បីនិយាយដោយសំដីរាបសាទៅកាន់អ្នកឯទៀត បើដូចជាគេចង់បានអោយអ្នកដទៃនិយាយមកកាន់ខ្លួនគេយ៉ាងដូច្នេះ ។ ទាក់ទងនឹងការនិយាយពាក្យឥតប្រយោជន៍, ជាញឹកញយ លោកអ្នកតែងឮគេនិយាយថា យើងមិនអាចបណ្តោយខ្លួនអោយលង់ក្នុងការនិយាយពាក្យឥតប្រយោជន៍ណាមួយបានទេ ។ នេះមិនមែនសំដៅអំពើអាក្រក់ហ្នឹងទេ ។ ក្នុងទីនេះ ប្រភេទនៃការនិយាយពាក្យឥតប្រយោជន៍ ដែលសំដៅជាពិសេស គឺយោងទៅរកការនិយាយខ្សឹបខ្សៀវប្រកបដោយចិត្តប្រទូសរ៉ាយ, សំដៅបំពេញចិត្តខ្លួន, ដើម្បីសេចក្តីសប្បាយផ្ទាល់ខ្លួន, ដោយនិយាយរៀបរាប់ពីកំហុស, គឺចំណុចខ្សោយរបស់អ្នកដទៃ ។ ជាជំនួសការប្រើសមត្ថភាពនៃវាចានេះ ដែលមានឥទ្ធិពលខ្លាំងក្លាធ្វើអោយគេខូចចិត្តសម្រាប់បំពេញចិត្តខ្លួន, សម្រាប់រំលោភបំពានលើអ្នកដទៃ, សម្រាប់ចំណាយពេលឥតប្រយោជន៍ បង្ខូចប្រយោជន៍អ្នកដទៃ, ហេតុអ្វីក៏មិនប្រើសមត្ថភាពវាចានេះក្នុងន័យស្ថាបនា ដើម្បីនិយាយទាក់ទងគ្នាប្រកបដោយអត្ថន័យល្អ, ដើម្បីបង្រួបបង្រួមអ្នកដទៃ, ដើម្បីជំរុញអោយចេះយោគយល់គ្នារវាងអ្នកជិតខាង និងមិត្តភក្តិ, និងដើម្បីផ្តល់ដំបូន្មានប្រកបដោយអត្ថរសជួយសង្គ្រោះគ្នា ។ មានពេលមួយនោះ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា : «បិយវាចា គឺផ្អែមល្ហែមដូចទឹកឃ្មុំ, សច្ចវាចា គឺល្អដូចបុប្ផា រីឯមិច្ឆាវាចា គឺជាអកុសលនិងសៅហ្មង» ។ ដូច្នេះ ចូរយើងខិតខំសម្រាប់ជាកុសលផ្ទាល់ខ្លួនយើងផង និងជាកុសលសម្រាប់អ្នកដទៃផង បណ្តុះនូវសម្មាវាចា, ការគោរពពាក្យសច្ចៈ, និងការគោរពសុខុមាលភាពនៃអ្នកដទៃ ។

ផ្នែកបន្ទាប់នៃមាតិា ដែលរាប់បញ្ចូលក្នុងក្រុមសីល (ចរិយាល្អ) ដែរគឺ សម្មាកម្មន្តៈ ។ សម្មាកម្មន្តៈ រួមមានការគោរពចំពោះជីវិត, ការគោរពចំពោះទ្រព្យសម្បត្តិ (អ្នកដទៃ), និងការគោរពចំពោះទំនាក់ទំនងផ្លូវខ្លួន ។ យើងនឹងរំលឹកឡើងវិញ នូវអ្វីដែលបាននិយាយកន្លងទៅអំពីជីវិតដ៏ជាទីស្រឡាញ់ចំពោះសព្វសត្វ ។ មាននិយាយនៅក្នុងគម្ពីរធម្មបទថា សត្វទាំងអស់តែងភិតភ័យញ័ររន្ធត់ចំពោះទណ្ឌកម្ម, សព្វសត្វតែងភ័យខ្លាចសេចក្តីស្លាប់, ហើយថា សត្វមានជីវិតទាំងអស់ តែងស្រឡាញ់ជីវិត ។ ដោយប្រការដូចនេះទៀត ទន្ទឹមនឹងរក្សាទុកក្នុងចិត្ត នូវគោលការណ៍សមភាព និងអញ្ញមញ្ញភាព, យើងមិនគប្បីសម្លាប់សត្វមានជីវិតទេ ។ គេអាចត្រៀមខ្លួនទទួលយកគោលការណ៍នេះអនុវត្តចំពោះមនុស្សទាំងឡាយ, ប៉ុន្តែ យើងក៏គួរយកចិត្តទុកដាក់អនុវត្តចំពោះសត្វមានជីវិតដទៃទៀត ។ ការអភិវឌ្ឍន៍ខ្លះៗ ក្នុងបណ្តាការអភិវឌ្ឍន៍ដែលយើងបានឃើញ កំពុងកើតមាននៅក្នុងពិភពនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ អាចផ្តល់វិភាគទានសម្រាប់ជាគំនិតដល់អ្នកគិតសេរីដែលមានសេចក្តីសង្ស័យ ។ កាលណាគេបំផ្លាញពូជសត្វល្អិតណាមួយ, តើគេប្រាកដក្នុងចិត្តដោយដាច់ខាតថា បានបំពេញអំពើល្អដ៏ធំធេង, អំពើល្អសំរាប់រយៈពេលវែងដល់បរិដ្ឋានឬទេ ? ឬមួយក៏យើងផ្តល់វិភាគទានមួងម្កាល ដោយមិនដឹងខ្លួនដល់អតុល្យភាព ដែលបង្កើតអោយមានបញ្ហាដ៏ធំធេងក្នុងពេលអនាគត ? ការគោរពចំពោះទ្រព្យសម្បត្តិ គឺមិនលួចទ្រព្យសម្បត្តិពីអ្នកដទៃ ឬឆបោកអ្នកដទៃ ។ នេះជាប្រការសំខាន់ ពិព្រោះ អ្នកទាំងឡាយណាដែលកាន់យកនូវអ្វីដែលគេមិនបានអោយដោយអំពើលួច, ដោយអំពើឆបោក គឺត្រូវមានពិរុទ្ធភាពចំពោះការដាច់សិក្ខាបទនេះស្មើនឹងអ្នកទាំងឡាយណាដែលបានលួចដោយកំរោលដែរ ។ និយាយម្យ៉ាងទៀត និយោជកដែលមិនបានសងដល់និយោជិត នូវប្រាក់ខែដ៏សុចរិតដែលជាផលនៃពលកម្មរបស់គេ ត្រូវមានពិរុទ្ធភាពចំពោះការកាន់យកនូវអ្វីដែលគេមិនបានអោយ ។

ដូចគ្នានេះដែរ និយោជិតដែលទទួលយកប្រាក់ថ្លៃឈ្នួល ហើយគេចវេះមិនបំពេញភារកិច្ច ត្រូវមានទោសចំពោះការខ្វះសេចក្ដីគោរពចំពោះទ្រព្យសម្បត្តិ (អ្នកដទៃ) ។ នៅទីបញ្ចប់ សេចក្ដីគោរពចំពោះទំនាក់ទំនងផ្ទាល់ខ្លួន មានន័យថាចៀសវាងអំពើផិតក្បត់ចិត្តប្ដី-ប្រពន្ធ ( អតិចរិយា ), ចៀសវាងការប្រព្រឹត្តខុសក្នុងការសេពកាម ។ អស់លោកអ្នកអាចឃើញថា ប្រសិនបើគោលការណ៍ណែនាំទាំងនេះ ត្រូវបានបណ្ដុះបណ្ដាលដោយស្មោះត្រង់នៅក្នុងសង្គម, តើសង្គមមួយបែបនេះ នឹងបានជាទីកន្លែងដ៏ប្រសើរសម្រាប់ការរស់នៅយ៉ាងណា ?

ជំហានទីបីនៃអរិយដ្ឋង្គិកមគ្គ ដែលបានរួមបញ្ចូលក្នុងមាគ៌ាប្រតិបត្តិនៃសីលគឺ សម្មាអាជីវៈ ។ សម្មាអាជីវៈ គឺជាផែកផាងមួយនៃច្បាប់របស់សម្មាកម្មន្តៈ ចំពោះតួនាទីរបស់បុគ្គលក្នុងឋានៈជាមេគ្រួសារម្នាក់នៅក្នុងសង្គម ។ យើងបានឃើញថា ចំពោះសម្មាវាចា និងសម្មាកម្មន្តៈ, គោលការណ៍ជាគ្រឹះនៅពីក្រោយបទបញ្ញត្តិ គឺសេចក្ដីគោរពចំពោះសច្ចៈ, ចំពោះជីវិត, ចំពោះទ្រព្យសម្បត្តិ និងទំនាក់ទំនងផ្ទាល់ខ្លួន ។ សម្មាអាជីវៈមានន័យថា គេមិនត្រូវចិញ្ចឹមជីវិតក្នុងផ្លូវមួយឈានដល់ការបំពានគោលការណ៍ទាំងឡាយនេះ ដែលជាគោលការណ៍គ្រឹះនៃសីលនោះទេ ។ និយាយដោយចំទៅ, គឺមានការចិញ្ចឹមជីវិតប្រាំយ៉ាង ដែលពុទ្ធសាសនិកជនមិនគប្បីប្រកាន់យក ។ នោះគឺ ជួញសត្វសម្លាប់យកសាច់, ជួញទាសករ (ជួញមនុស្ស), ជួញសស្ត្រាវុធ, ជួញថ្នាំពុល, និងជួញគ្រឿងស្រវឹង ពោលគឺគ្រឿងញៀន និងសុរាមេរ័យ ។ ការចិញ្ចឹមជីវិតទាំងប្រាំយ៉ាងនេះ មិនត្រូវបានគេជំរុញអោយធ្វើទេ, ពិព្រោះផ្ដល់ជំងឺដល់សង្គម និងពិព្រោះវារំលោភលើគោលការណ៍ នៃសេចក្ដីគោរពចំពោះជីវិតជាដើម ។ មុខរបរជំនួញសម្លាប់សត្វលក់សាច់ រំលោភលើសេចក្ដីគោរពចំពោះជីវិត ។ ការជួញទាសករ រំលោភលើសេចក្ដីគោរពចំពោះជីវិត និងទំនាក់ទំនងផ្ទាល់ខ្លួន ។ ការជួញគ្រឿងសស្ត្រាវុធសម្លាប់មនុស្ស រំលោភលើគោលការណ៍នៃសេចក្ដី

គោរពចំពោះជីវិត ។ ការជួញថ្នាំពុល រំលោភលើគោលការណ៍នៃសេចក្ដីគោរពចំពោះជីវិត ។ ការជួញគ្រឿងស្រវឹង រំលោភលើគោលការណ៍នៃសេចក្ដីគោរពចំពោះសុខុមាលភាពនៃអ្នកដទៃ ។ ជំនួញទាំងអស់នេះ ផ្ដល់ចំណែកអោយមានអសន្តិសុខ, ទុក្ខលំបាក និងការបែកបាក់គ្នាក្នុងសង្គម ។

តើសីលប្រព្រឹត្តទៅយ៉ាងដូចម្ដេច ? យើងបាននិយាយហើយថា ចំពោះសង្គម, ការប្រព្រឹត្តតាមច្បាប់បញ្ញត្តិនៃសីល បង្កើតឡើងនូវសង្គមមួយប្រកបដោយភាពសុខដុម និងសន្តិភាព ។ គោលដៅសង្គមទាំងអស់ អាចត្រូវបានសម្រេចតាមរយៈគោលការណ៍ និងបទបញ្ញត្តិនៃសីលដែលផ្អែកលើការទទួលស្គាល់ជាមូលដ្ឋាននៃសមភាព និងអញ្ញមញ្ញភាព ។ បន្ថែមលើនេះ, បុគ្គលម្នាក់ៗ ទទួលបានអត្ថប្រ-យោជន៍ផងដែរ តាមរយៈការប្រព្រឹត្តកាន់សីល ។ នៅក្នុងព្រះសូត្រមួយ, ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា, « អ្នកណាមួយ ដែលបានប្រព្រឹត្តកាន់ខ្ជាប់នូវសេចក្ដីគោរពចំពោះជីវិតជាដើមហើយ អ្នកនោះរមែងមានអារម្មណ៍ថា ខ្លួនគឺជាស្ដេចគ្រងរាជ្យត្រឹមត្រូវមួយអង្គ ហើយសត្រូវរបស់ព្រះអង្គសុំចុះចាញ់ ។ គេមានអារម្មណ៍សុខសន្តិភាព និងក្សេមក្សាន្ត » ។ ការប្រកាន់ខ្ជាប់នូវសីលបង្កើតអោយមានក្នុងខ្លួននៃបុគ្គលម្នាក់ៗ នូវរសជាតិនៃសន្តិភាព, ស្ថិរភាព, សន្តិសុខ និងថាមពលព្ធដ៏ផ្ទៃក្នុង ។ ពេលណាគេបានបង្កើតសន្តិភាពផ្ទៃក្នុងនោះបានហើយ, បន្ទាប់មក គេអាចអនុវត្តប្រកបដោយផ្លែផ្កា និងដោយជោគជ័យនូវជំហានដទៃទៀត នៃមាគ៌ា ។ គេអាចបណ្ដុះបណ្ដាល និងធ្វើអោយរីកចំរើននូវសមាធិ ។ គេអាចសម្រេចបាននូវបញ្ញាតែកាលណាគេបង្កើតបាននូវគ្រឹះចាំបាច់នៃសីលទាំងខាងក្នុងទាំងខាងក្រៅ នៅក្នុងទំនាក់ទំនងរបស់ខ្លួនគេជាមួយអ្នកឯទៀត និងនៅក្នុងខ្លួនគេផ្ទាល់ប៉ុណ្ណោះ ។

ដោយសេចក្ដីសង្ខេបខ្លី, នេះគឺជាប្រភព, អត្ថន័យ និងគោលដៅនៃសីល ។ ខ្ញុំសូមនិយាយតែមួយចំណុចទេ មុនពេលខ្ញុំឈប់និយាយថ្ងៃនេះ, ហើយ

ចំណុចនោះ គឺថា កាលណាគេក្រឡេកមើលឃើញបទបញ្ញត្តិនៃសីល, គេតែងនិយាយជាញឹកញយថា តើគេអាចប្រតិបត្តិតាមបទបញ្ញត្តិនៃសីលយ៉ាងដូចម្តេចកើត ។ វាមានការលំបាកពេកណាស់ ដើម្បីកាន់តាមសិក្ខាបទនានា ។ ឧទាហរណ៍ជាតួយ៉ាង, សូម្បីតែសិក្ខាបទហាមឃាត់ការសម្លាប់ជីវិត ជួនកាលហាក់មានការលំបាកដ៏ក្រៃលែង ដើម្បីប្រតិបត្តិតាម ។ កាលណា លោកអ្នកបោសសំអាតចង្ក្រានរបស់លោកអ្នក, លោកអ្នកអាចនឹងសម្លាប់សត្វស្រមោចចៀសមិនផុត ។ នៅមានទៀត, គឺវាអាចមានការលំបាកដើម្បីកាន់ខ្ជាប់ជានិច្ចនូវសិក្ខាបទនៃសម្មាវាចា ។ តើយើងត្រូវដោះស្រាយបញ្ហានេះ ដែលជាបញ្ហាពិតមួយយ៉ាងដូចម្តេច ? នេះមិនមែនជាចំណុច ថាតើយើងអាចកាន់តាមសិក្ខាបទទាំងអស់នៃសីលគ្រប់ពេល ឬយ៉ាងណានោះទេ ។ បញ្ហាគឺថា ប្រសិនបើបទបញ្ញត្តិទាំងឡាយនៃសីល គឺជាច្បាប់ស្ថាបនាឡើងត្រឹមត្រូវល្អ, ប្រសិនបើយើងអាចទទួលយកថា សមភាព និងអញ្ញមញ្ញភាព គឺជាគោលការណ៍ទាំងឡាយដែលយើងជឿ, ប្រសិនបើយើងទទួលស្គាល់ថា បទបញ្ញត្តិទាំងឡាយ គឺសមស្របដើម្បីអនុវត្តគោលការណ៍ទាំងឡាយនោះ, បើដូច្នោះ វាជាករណីយកិច្ចរបស់យើងដើម្បីប្រតិបត្តិតាម, ដើម្បីកាន់តាមបទបញ្ញត្តិទាំងឡាយដោយដាច់ខាតគ្រប់វេលា ។ ប៉ុន្តែ គេនិយាយថា ប្រសិនបើយើងទទួលយកថា ដើម្បីរស់នៅជាសុខជាមួយខ្លួនយើង និងអ្នកដទៃ, យើងត្រូវគោរពជីវិតនៃសត្វមានជីវិតដទៃទៀត, គោរពទ្រព្យសម្បត្តិរបស់គេទាំងនោះ, ‑ ល ‑ ។ ហើយប្រសិនបើមានស្ថានភាពណាមួយកើតឡើង ដែលនៅក្នុងនោះ, យើងឃើញថា យើងមិនអាចអនុវត្តតាមបទបញ្ញត្តិណាមួយបាននៅក្នុងស្ថានភាពពិសេសណាមួយ, ពេលនោះ ការអាក់ខាននោះពុំមែនជាកំហុសនៃបទបញ្ញត្តិទេ ។ នោះវាគ្រាន់តែជាចន្លោះរវាងការប្រតិបត្តិរបស់យើងផ្ទាល់ និងឧត្តមគតិប៉ុណ្ណោះ ។

កាលណាអ្នកកាន់ចង្កូតនាវា ដឹកនាំនាវារបស់គេឆ្លងកាត់មហាសាគរ តាម

រយៈការមើលផ្កាយ, គេពុំអាចដើរតាមដោយត្រឹមត្រូវពិតប្រាកដនូវផ្លូវ ដែលផ្កាយបានចង្អុលប្រាប់នោះទេ ។ ប៉ុន្តែថា ផ្កាយគឺជាមគ្គុទ្ទេសក៍របស់គេ ហើយដោយដើរតាមផ្កាយ ទោះបីមិនបានទៀងទាត់ ឬប្រហាក់ប្រហែល, គេក៏បានទៅដល់ទីដៅរបស់គេ ។ ដូចគ្នានេះដែរ កាលណាយើងអនុវត្តតាមបទបញ្ញត្តិនៃសីល, យើងមិនអួតអាងថា យើងអាចកាន់តាមបទបញ្ញត្តិទាំងអស់នោះ គ្រប់ពេលវេលានោះទេ ។ ព្រោះហេតុនោះហើយទើបសីលសិក្ខាបទទាំងប្រាំ ត្រូវបានគេហៅថា *សិក្ខាបទបណ្តុះបណ្តាល* ហើយដោយហេតុនេះ យើងអាចទទួលកាន់សិក្ខាបទទាំងឡាយនោះម្តងហើយម្តងទៀត ។ អ្វីដែលយើងទទួលបាននៅក្នុងបទបញ្ញត្តិនៃសីល គឺក្របខណ្ឌមួយ ដែលនៅក្នុងក្របខណ្ឌនេះ យើងអាចខិតខំដើម្បីរស់នៅស្របតាមគោលការណ៍គ្រឹះ ដែលបំភ្លឺអោយយល់នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, នោះគឺគោលការណ៍នៃសមភាពនៃសព្វសត្វមានជីវិត និងគោលការណ៍នៃសេចក្តីគោរពចំពោះមនុស្សសត្វឯទៀត ។

*( នៅមាន ត )*

*« គួរគប្បីឱ្យមួយរយ តែមិនគួរធ្វើឱ្យកើតវិវាទទេ នេះជាមតិអ្នកប្រាជ្ញ,*
*សូម្បីមិនមានមូលហេតុអ្វីជាមាំមួន ហើយក៏ធ្វើឱ្យកើតវិវាទដែរ*
*នេះជាលក្ខណៈមនុស្សល្ងង់ទេ » ។*

ហិតោបទេស

# វចនសព្ទវិទ្យា នៃ ភាសាខ្មែរបច្ចុប្បន្ន (ត)

## Lexicologie du Khmer Moderne

២. *ឡិចសែមដើមបង្កើតដោយក្រុមព្យញ្ជនៈ*

ក្នុងភាសាខ្មែរយើង អាចរកបានពាក្យមួយព្យាង្គ ប្រហែល ៥.០០០ ក្នុងនោះចំនួន ២.០០០ ពាក្យ បង្កើតដោយក្រុមព្យញ្ជនៈផ្សេងៗ ។ យើងអាចចាត់ទុកថាពាក្យខាងក្រោមនេះ ជាពាក្យកម្ចាយពីមុនមក ( ឧទាហរណ៍ : ក្មើយ ) ជាពាក្យកម្ចីពីភាសាបរទេស ( ឧទាហរណ៍ : ផ្លែ ) ជាពាក្យបានមកពីការទទួលយកស្លូវខុសពីពាក្យអតីតទ្វេព្យាង្គ ( ឧទាហរណ៍ : តងៃ > ថ្ងៃ ) ឬ អតីតឫសមន-ខ្មែរ ( ឧទាហរណ៍ បី ) ។ ប៉ុន្តែ ក្នុងចំនួននេះ មានពាក្យមួយចំនួន ត្រូវបង្កើតដោយក្រុមព្យញ្ជនៈផ្ញើជើងពៀកពុំបាន ប៉ុន្តែមានកំលាំងសំនួនវោហារធំធេង ( mots expressifs ) ឬមាននិយមន័យរស់រវើក ពិបាកបកស្រាយអោយបានត្រឹមត្រូវក្នុងភាសាមួយផ្សេង ហើយគឺពាក្យទាំងនេះហើយ ដែលយើងវិភាគខាងក្រោមនេះ :

2-1 ក្ង /kṅ/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលទាក់ទងនឹងភាពមិនប្រក្រតីក្នុងរាងកាយ ។ ក្រុមព្យញ្ជនៈ [ ក្ង ] /kṅ/ ដែលជាព្យញ្ជនៈស្ទះទាំងពីរ ប៉ុន្តែ ព្យញ្ជនៈមួយមានខ្យល់ច្រមុះខ្ចរខ្ចារ ។ គេអាចនិយាយបានម្យ៉ាងទៀតថា ព្យញ្ជនៈទីពីរ [ ង ] នៅក្នុងក្រុម គឺជាផ្នត់ជែកមួយបែប ។

ក្ងង់ /kṅan/ ( វៀច )

ក្ងក់ /kṅak/ ( រមួល )

ក្ងួរ /kṅuor/ ( និយាយនឹងច្រមុះ )

ក្ងិច /kṅic/ ( ទាល, រមួល, ក្ងិកក្ងក់ )

ក្ងែង /kṅaeṅ/ ( រមួល, « ដៃ » )

ក្ងេះ /kṅeh/ ( អាក្រក់ )

ក្ងាន /kṅan/ ( សត្វក្ងាន )

ក្ងោក /kṅaok/ ( សត្វក្ងោក )

2-2 ខ្ញ /khña/ , /khñ/ សំដែងបញ្ចាក់នូវអ្វីទាក់ទងនឹងការកញ្ជក់ចលនាខុសចង្វាក់ ដែលបង្ហាញពីការមិនសប្បាយ ឬសប្បាយចិត្ត ។ ក្នុងឡិចសែម [ ខ្ញ ] ខ្លះ មានព្យញ្ជនៈខ្លាំង ខ្ទុះ [ ក ] [ ខ ] បូកផ្សំនឹងព្យញ្ជនៈខ្យល់ច្រមុះ [ ញ ] ដែលបញ្ចាក់នូវចលនាញាប់ ឬកន្ត្រាក់ ។

ខ្ញាក /khñak/ ( កំរើកយ៉ាងខ្លាំង )

ខ្ញៀវ /khñiev/ ( ស្រែកជាពួក )

ខ្ញក /khñak/ ( សម្រែកមេមាន់ )

ខ្ញៅ /khñao/ ( ក្រចៅ )

ខ្ញី /khñi/ ( បញ្ចេញអាការៈមិនពេញចិត្ត )

ខ្ញាល់ /khñal/ ( ខឹង « ព្រះសង្ឃ, ស្ដេច » )

2-3 ខ្ដ /khta/,/kht/ សំដែងគំនិតបញ្ចាក់អ្វីទាក់ទងនឹងភាព ឬចលនាកន្ត្រាក់ឡើងលើ ។ ឡិចសែម [ ខ្ថ ] , [ ខ្ដ ] កកើតដោយការប៉ះទង្គិចរវាងព្យញ្ជនៈ [ ក ] + ព្យញ្ជនៈធ្មេញ [ ត ] ។

ខ្ដរ khdar ( ព្រោកប្រាជ្ញ )

ខ្ដើត khdoet ( មានទឹកមុខមើលងាយ )

ខ្ដើយ khdoey ( មនុស្សខ្ដើយ )

ខ្ទត khtat ( មេមាន់ខ្ទត )

ខ្ទួយ khduoy ( សត្វខ្ទួយ )

2-4 ខ្ព /khba/ , /khp/ , /khb/ សំដែងគំនិតទាក់ទងនឹងអ្វីដែលមានអារម្មណ៍ ឬចលនាឡើង លើក ។ ឡិចសែម [ ខ្ព ] /khp/ កកើតឡើងដោយព្យញ្ជនៈខ្លាំង ហើយស្ទះពីរ រួមផ្សំកម្លាំងគ្នា ។

ខ្ពង់ /khban/ ( ដីខ្ពស់ )

ខ្ពស់ /khbas/ ( ខ្ពស់ )

ខ្ពប /khbap/ ( ពោបឡើងដើមឈើ )

ខ្ពើម /khboem/ ( ស្អប់ )

ខ្ពោក /khbaok/ ( ពាក្យពណ៌នាពីវត្ថុមួយធ្លាក់យ៉ាងខ្ពស់មកពីលើ )

2-5 ខ្វ /khva/ , /khv/ សំដែងគំនិតបញ្ជាក់នូវអ្វីទាក់ទងនឹងភាពរហ័សរហួន ចលនាខុសចង្វាក់ និងខុសប្រក្រតីភាព ។ ក្រុមព្យញ្ជនៈ [ ខ្វ ] កកើតឡើងដោយការផ្សំព្យញ្ជនៈស្ទះ [ ក ] + អឌ្ឍព្យញ្ជនៈ ( ពាកកណ្ដាលព្យញ្ជនៈ ពាក់កណ្ដាលស្រៈ ) [ វ ] ដែលសំដែងភាពល្វតល្វន់ មិននឹងន [ ខ្វ ] ទាំងអស់មាន ៤៨ ហើយភាគច្រើននៃពាក្យទាំងនេះ ជាពាក្យត្រាប់សូរ ។

ខ្វិច /khvic/ ( ចលនាដៃយ៉ាងរហ័ស )

ខ្វៀក /khviek/ ( សរសេររហ័ស )

ខ្វែង /khvaeṅ/ ( បញ្ឆោស, គង )

ខ្វិន /khvin/ ( ពិការជើង )

ខ្វៀន /khvien/ ( ខ្ចីហើយកោង )

ខ្វោក /khvaok/ ( ពាក្យសំគាល់សំឡេងរបោក )

2-6 ធ្ង /thn̊/ , /dhn̊/ សំដែងគំនិតបញ្ជាក់នូវអ្វីទាក់ទងនឹងភាពធ្ងន់ធ្ងរ ពានតឹង ។ ឡិចសែម [ ធ្ង ] កកើតឡើងដោយការផ្សំព្យញ្ជនៈធ្មេញ [ ត ] ឬ [ធ] + ព្យញ្ជនៈ [ង] ។ ទាំងអស់ធ្វើអោយមានភាពតឹងតែងក្នុងការបន្លឺសំឡេង ។

ថ្ងួច /thn̊uoc/ ( ក្របីថ្ងួច )

ថ្ងូរ /thn̊ur/ ( ថ្ងូរ )

ធ្ងន់ /dhn̊an/ ( ធ្ងន់, លំបាក )

ធ្ងោល /dhn̊aol/ ( លេចឡើងដោយលំបាក )

2-7 ល្វ ល្ព /lva/ , /lba/ , /lv/ , /lb/ សំដែងនូវគំនិតទាក់ទងនឹងអ្វីដែលទន់ភ្លន់ សុខដុម ។ ចំណាប់អារម្មណ៍ពីភាពទន់ភ្លន់ និងសុខដុម សំដែងយ៉ាងច្បាស់ក្នុងពាក្យដែលកើតតាមការផ្ទួនពាក្យ ។

ល្វន់ /lvan/ ( ទន់ )

ល្វត /lvat/ ( ជ្រាយ )

ល្ពាក់ /lbak/ ( ដើមល្ពាក់ )

ល្វែតល្វន់ /lvaet-lvan/ ( រាងស្ដួមហើយទន់ ( ស្រ្តី )

ល្ពេញល្ពៅ /lbeñ-lbau/ ( ទន់ហើយស្រស់ )

ល្វឹងល្វើយ /lvin̊-lvoey/ ( ធំធេង )

2-8 ស្ព /sb/ សំដែងគំនិតបញ្ជាក់នូវអ្វីដែលស្រទន់ ស្អោត ឬជ្រាយ ៖

ស្ពឹង /sbin/ ( ហើមហើយរលួយ )

ស្ពឹក /sbik/ ( ជំងឺស្ពឹក )

ស្ពែត /sbaet/ ( ផត )

ស្ពៀត /sbiet/ ( សំពៀត )

ស្ពោត /sbaot/ ( ស្វិតហើយស្គោត )

ស្ពុល /sbul'/ ( ហើមស្ពុល )

ចំពោះក្រុមព្យញ្ជនៈផ្សេងទៀត ចំនួនប្រហែល ៨០ ក្នុងភាសាខ្មែរ មានតែ ១០ ក្រុមព្យញ្ជនៈខាងលើនេះទេ ដែលផ្តល់នូវនិយមន័យសាំញ៉ាំ ។ សម្រាប់ក្រុមព្យញ្ជនៈផ្សេងដទៃទៀត មានកំណត់សំគាល់ពីរយ៉ាង អាចដាក់ចំណងជើងបាន :

• *ក្នុងក្រុមព្យញ្ជនៈជាមួយព្យញ្ជនៈ [ រ ] /r/ « នៅទីតាំងទី ២ »* ព្យញ្ជនៈនាំមកនូវទម្ងន់និយមន័យដ៏ធំធេង និងមានឥទ្ធិពលរបៀបនេះលើសេម៉ង់ទិកនៃពាក្យជាប់ជាមួយ ។

ដូចនេះ ក្នុងពាក្យទោល ៣២៣ បង្កើតដោយក្រុមព្យញ្ជនៈផ្តើម [ ក្រ ], [ គ្រ ] , [ ច្រ ] , [ ជ្រ ] , [ ត្រ ] , [ ទ្រ ] , [ ប្រ ] , [ ព្រ ] និង [ ស្រ ] យើងអាចរកបានតែ ២១ ពាក្យ ជានាមស័ព្ទទូទៅ ប្រមាណ ៦៥ % នៃចំនួនសរុប ក្រៅពីនោះ សុទ្ធសឹងជាគុណស័ព្ទ និងជាកិរិយាវិសេសន៍ ។ ក្រុមព្យញ្ជនៈទាំងនេះផ្តល់ឋាមពល (dynamisme) ភាពរស់រវើកដល់ពាក្យទាំងឡាយ ។

• *ក្នុងក្រុមព្យញ្ជនៈជាមួយព្យញ្ជនៈ /h/ « នៅទីតាំងទី ២ »* មានបញ្ហាសេម៉ង់ទិកសាំញ៉ាំបានចោទឡើង ដែលការសិក្សាពីការវិវត្តន៍នៃព្យញ្ជនៈ បញ្ចេញខ្យល់ និងបន្សំរបស់វា ជាមួយព្យញ្ជនៈដទៃទៀត និងអាចអោយកំណត់ធម្មជាតិរបស់ព្យញ្ជនៈនីមួយៗ ដូចបានលើកមកពណ៌នាខាងលើ ។ ជាធម្មតា យើងបានរកឃើញតែពាក្យជាមួយព្យញ្ជនៈផ្តើមបញ្ចេញខ្យល់ លើកលែងតែពាក្យកម្ចីទាំងអស់ សុទ្ធសឹងជាកិរិយាស័ព្ទពាក្យត្រាប់ស្នូរ និងឧទានស័ព្ទ គឺជាពាក្យសំដែងពីគំនិត : ដង្ហើម, ដង្ហក់, ប្រឹងប្រែង, ហាត់ហៅ, ថប់ដង្ហើម, ញញ័រ ។ បន្ទុកសេម៉ង់ទិកនៃព្យញ្ជនៈបញ្ចេញខ្យល់ /h/ ក្នុងក្រុមព្យញ្ជនៈ សំដែងយ៉ាងច្បាស់ក្នុងពាក្យជាមួយក្រុមព្យញ្ជនៈផ្តើម ដូចជា : kh, ph, mh, lh ។

ឧទាហរណ៍ :

ម្ហេត /mhet/ ( ហាត់យ៉ាងខ្លាំង )

ម្ហប /mhap/ ( កំរើកបបូរមាត់ញ័រ១ )

ម្ហាត /mhat/ ( រលីមរលោម )

ខំ /kham/ ( ខិតខំ )

ល្ហេវ /lhev/ ( ទូលាយហើយក្រៀមក្រោះ )

ល្ហើយ /lhoey ( ធូរស្រាល )

ផែល /phael/ ( ប៉េលប៉ាលលើផ្ទៃទឹក )

៣- *ក្រៅពីការសិក្សានេះ យើងអាចទាញគំនិតទូទៅបានខ្លះលើភាពសំដែងនៃស្រះ និងស្រះផ្សំក្នុងពាក្យ បំពេញមុខងារជាប្រេឌីកា គឺជាកិរិយាស័ព្ទ ជាកិរិយាវិសេសន៍ ។*

3-1 អ /a/ សំដែងការផ្ដើមចលនា ការបង្កើត

3-2 អា /a/ សំដែងគម្លាត

3-3 /a/ /a'/ សំដែងការរាំងស្ទះ ឧបសគ្គ ទាល់ច្រក

3-4 អិ ~ អិ /i/i/ សំដែងពីភាពតូចល្អិត ភាពរហ័សរហួន ។ គំនិតស្ដីពីការរហ័សរហួន និងភាពតូចល្អិត លេចចេញយ៉ាងច្បាស់ ក្នុងករណីដែលស្រះនេះ ផ្សំជាមួយព្យញ្ជនៈក្រអូម [ ច ] ។

3-5 អី ~ អី /i/ "i/ សំដែងការបន្ដឹង ការជ្រាត

3-6 អឺ ~ អឺ /i/ɨ:i/ សំដែងលំញ័រសូររន្ធិផ្ទាយ គំនិតបន្ដឹង និងលំញ័រ សំដែងយ៉ាងច្បាស់ក្នុងករណីដែលស្រះ /i/ , /i/ ប្រកបជាមួយព្យញ្ជនៈច្រមុះបំពង់ក [ ង ] /ŋ/ ។

3-7 អុ ~ អុំ /u/ សំដែងចលនាចុះក្រោមជំរៅ ។ ក៏ប៉ុន្តែ កាលណា

ស្រះខ្លីនេះ ប្រកបជាមួយព្យញ្ជនៈច្រមុះ បបូរមាត់ /m/ វាសំដែងគំនិត រមូរ ប្រមូល ឯកភាព ។

3-8 អើ ~ អឺ /oe/aə/ សំដែងការបង្កើនចលនាឡើងទៅលើ ត្រូវកត់សំគាល់ថា ព្យញ្ជនៈចុងខ្លះនៃពាក្យជាមួយស្រះផ្សំ [ អើ ] , [ អឺុ ] /aə /, អាចចាត់ទុកលើទស្សនៈ ឌីយ៉ាក្រូនិក (តាមការវិវឌ្ឍន៍ប្រវត្តិសាស្ត្រ) ជាសំណល់នៃផ្នត់ចុងពីអតីតកាលដ៏យូរអង្វែងមកហើយ ។

3-9 អៀ /ie/ , /i / សំដែងពីការពង្វាង ការបង្រួមបន្ទេរ ។

3-10 អែ ~ អៃ /ae ,/ae/, /ɛː/ សំដែងការឃ្លាត ការបែងចែក

3-11 អោ ~ អៅ /o/ , /ao/ សំដែងការចុះភាពដុនដាប ។

នេះជាគំនូរទំនាក់ទំនងសេម៉ង់ទិកក្នុងប្រព័ន្ធស្រះ និងស្រះផ្សំ ក្នុងភាសាខ្មែរ ។

ព្រួញក្នុងគំនូរ បង្ហាញខ្សែទំនាក់ទំនងនេះ




ជាទូទៅ ពាក្យឡិចសែម (lexèmes primaires) ឬបឋមឡិចសែមខ្មែរ ឬពាក្យខ្មែរដើម គឺជាពាក្យប្រើប្រាស់ឡើងដើម្បីបញ្ជាក់នូវសំនូរនៃស័ព្ទខ្មែរដែលដក់នូវន័យ ឬនិយមន័យមួយច្បាស់លាស់ ។ គេអាចនិយាយបានថា ឡិចសែមដើម មានទម្រង់ជាពាក្យឯកព្យាង្គ ឬព្យាង្គដែលកកើតដោយ ៖

- ស្រះសំយោគ ( diptongue ) គឺស្រះ + ស្រះ (V + V)

. ព្យញ្ជនៈ + ស្រៈ + ព្យញ្ជនៈ ( C + V + C )

. ព្យញ្ជនៈ + ព្យញ្ជនៈ ( C + C )

ឯកតាទាំងនេះ គេអាចហៅបានម្យ៉ាងទៀតថា អ៊ីដេអូហ្វូន ( idéo-phones ) គឺជាសំនួរប្រកបដោយន័យ ឬនិយមន័យណាមួយ ឬមួយសំនួរដែលទាក់ទាញអោយមានអារម្មណ៍ណាមួយច្បាស់លាស់ ។

ឯកតាន័យវចនស័ព្ទទាំងនេះ ដែលដក់នូវនិយមន័យដើមដ៏ច្បាស់លាស់ អាចបង្កបង្កើតពាក្យ និងសន្តានពាក្យ រាប់រយ រាប់ពាន់ ក្នុងភាសាខ្មែរ ។ ពាក្យបរទេស មានទាំងសំស្ក្រឹត បាលី ចិន សៀម បារាំង ពុំអាចហៅបានជាឡិចសែមខ្មែរដើមទេ ។ ជាពិសេស ការយល់នូវប្រព័ន្ធ និងធម្មភាពនៃការវិវត្តន៍របស់ឡិចសែមដើម ព្រមទាំងពាក្យកម្លាយ ឬពាក្យរណ្តំបរិវារស័ព្ទ និងដែនសេម៉ង់ទិករបស់ពាក្យ អាចអោយមានចំណេះដឹងចំពោះការវិភាគនៃវាក្យស័ព្ទខ្មែរដើមទៀតផង ។

ឡិចសែមដើម គឺជាពាក្យជាមូលដ្ឋាននៃវាក្យស័ព្ទ ដែលត្រូវបានអ្នកនិពន្ធ និងកវីប្រើប្រាស់ ដើម្បីបង្កើតសោភណភាពនៃវណ្ណកម្មរបស់ខ្លួន ។ កំណាព្យពិរោះ ឬមានភាពរស់រវើក លុះត្រាតែកវីចេះ ហើយយល់នូវប្រព័ន្ធនៃឡិចសែមដើម ។ ឧទាហរណ៍ជាក់ស្តែងគឺ កំណាព្យរឿងរាមកេរ្តិ៍, រឿងទុំទាវ របស់ភិក្ខុសោម និងកំណាព្យ " គុកកាមកិលេស " របស់លោក កេង វ៉ាន់សាក់ ។

វត្តមាននៃប្រព័ន្ធឡិចសែមដើម និងសន្តានពាក្យប្រកបដោយបរិមាណ ដ៏ធំៗនៅក្នុងភាសាខ្មែរ បញ្ជាក់អោយដឹងថា ភាសាខ្មែរមានអាយុដ៏យូរអង្វែងជាងភាសាអន្តរជាតិធំៗដទៃទៀតខ្លះ នៅឧបទ្វីបអឺរ៉ុប មានភាសាបារាំង និងអង់គ្លេសជាដើម ។ អាយុដ៏យូរអង្វែងនៃភាសាខ្មែរ បានលាតសន្ធឹងមិនតិចជាងពីរពាន់ឆ្នាំ មុនគ្រិស្តសករាជមកហើយ ។

តាមការស្រាវជ្រាវរបស់សាស្ត្រាចារ្យ ហ្គេអ៊ីហ្វ្លូត ឃើញថា ឡិចសែមដើម ដែលដូចគ្នានឹងឡិចសែមដើមខ្មែរ មានស្ថិតនៅក្នុងភាសាមន-ខ្មែរដទៃជាច្រើននៅដែនឥណ្ឌូចិន ។

វាក្យស័ព្ទពន្យល់នូវប្រព័ន្ធឡិចសែមដើមនៅក្នុងភាសាខ្មែរ និងដែនសេម៉ង់ទិករបស់ឡិចសែមនីមួយៗ ដែលមាននៅក្នុងពាក្យ ឫស កម្លាយ និងរណ្តំបរិវារស័ព្ទ ។

១. អក ~ អក់

ឧទាហរណ៍ :

អក : បង្អក
អក់ : ដិអក់
ហក់ : ដង្ហក់, ហោកហក់
ខក : បង្ខក, រខក, ខកខាន
ខក់ : បង្ខក់, ខក់ៗ
កក : បង្កក, កំណក, ស្កក
វក់ : ពង្វក់, វិលវក់, វក់វី

២. អន់ ~ អួន

ឧទាហរណ៍ :

អន់ : បង្អន់, សំអន់, សម្រន់, ស្រន់, បន់ស្រន់
តន់ : តូចតន់, ក្តន់, ណែនក្តន់
បន់ : ដិបន់, បែបន់, បន់ស្រន់
ទន់ : បន្ទន់, ទម្រន់, ទន់ទាប, ទន់ភ្លន់
អួន : កួន, ប្អូន, អួនថយ ( អន់ថយ )

៣. អប់ ~ អ៊ប់

ឧទាហរណ៍ :

អប់ : ផ្អប់, បង្អប់, ប្រអប់, ស្អប់, ទឹកអប់

ហប់ : បង្ហប់

ថប់ : បន្ថប់, ថប់តែ, ធុញថប់

កប់ : បង្កប់, ស្កប់, កំណប់, កប់ក្តោង, ស្កប់ស្កល់

ទប់ : ផ្ទប់, ខ្ទប់, ទំនប់, បន្ទប់, ទប់ទល់

ឈប់ : បឈ្ឈប់, ជំហប់, ឈប់ឈរ

៤. អល់ ~ អ៊ល់

ឧទាហរណ៍ :

ទល់ : ចន្ទល់, ប្រទល់, ទប់ទល់, តទល់

ជល់ : បញ្ជល់, ឈ្មុល, ឈ្មុសឈ្មុល

កល់ : តំកល់, បង្កល់, នឹងថ្កល់, ថ្កល់, កំណល់, ខ្នល់ខ្នើយ

ហល់ : កំហល់, បង្ហល់, ក្រហល់ក្រហាយ, តក់ក្រហល, ហោលហល់

អល់ : ឆ្អល់, អល់ឯក, ឆ្អែតឆ្អល់

វល់ : រវល់, រវីរវល់, វិលវល់, អំពល់, ខ្វល់, ខ្វល់ខ្វាយ

ងុល : ងប់ងុល, ងងុល

៥. អៀ ~ អៀក ~ អៀត ~ អៀប

ឧទាហរណ៍ :

កៀរ : កៀរគរ

កៀក : ប្រកៀក, កៀកកើយ, ក្បៀក

ចង្អៀត : ចង្អៀតចង្អល់

បៀត : តៀ្បត, បៀតបៀន, ដិបៀត

ជ្រៀត : បញ្ជ្រៀត, ជ្រៀតជ្រែក

គៀប : ថ្កៀប, បង្កៀប, ដង្កៀប

៦. អៀង ( ទំពារអៀង ) ៩, ១២, ៩៧

ឧទាហរណ៍ :

កៀង : បង្កៀង, កៀងគរ

ឆៀង : បញ្ឆៀង, ចំហៀង, ឈ្មាង

ផ្អៀង : បង្អៀង, ផ្អៀងផ្អង

វាង : ពង្វាង, ក្វៀង, រវាង

ល្អៀង : លំអៀង,

វៀង : ជ្រៀង, ពង្រាង

៧. អៀច ~ អៀស

ឧទាហរណ៍ :

វៀច : បង្វៀច, កង្វៀច

វៀស : គ្រវៀស, គួសវៀស

ញៀច : ក្រញៀច

ចៀស : បញ្ចៀស, ជិលៀស, ចៀសវាង

គៀស : គ្រលៀស

កៀស : កំនៀស, កៀ្បស, ឃ្នាស

៨. អ៊ឹង ~ អ៊ិត ~ អ៊ឹង

ឧទាហរណ៍ :

តឹង : បន្តឹង, តឹងរ៉ឹង, តឹងតែង

រឹង : ពង្រឹង, ទ្រឹង, ចរឹង, រឹងត្អឹង, រឹងរូស, ប្រឹង, ប្រឹងប្រែង

អឹង : អឹងកង, អឹងអាប់

ប៊ិត : ក្បិត, ត្បិត

៩. អិត ~ អ៊ិត

ឧទាហរណ៍ :

កិត : កកិត, ប្រកិត

ឆិត : បញ្ឆិត, បញ្ឆិតបញ្ឆៀង, ឆិតៗ, ប្រឆិត

ដិត : ដិតដាម, ផ្ដិត

ជិត : ជំនិត, ជិតជិត, ភ្ជិត

បិត : ត្បិតត្បៀត, បំណិត, កាំបិត

សិត : សសិត, ត្រសិត, ស្និតស្នាល, (ស្និទ្ធស្នាល)

ស្រិត : សម្រិត, សម្រិតសម្រាំង, សរិត

លិត : រលិតរលាត

រិត : រិតត្បិត, ពង្រិត, ស្រិត, ប្រឹត, ប្រឹតប្រៀង

ខិត : បង្ខិត, កំហិត, ខិតខំ

ចិត : ចំណិត, ផ្ចិតផ្ចង់

ល្អិត : លំអិត, ល្អិតល្អោច

ស្អិត : ស្អិតរមួត

ហិត : រហិតរហៃ

១០. អិច ~ អ៊ិច

ឧទាហរណ៍ :

តិច : បន្តិច, បន្តិចបន្តួច, តិចតួច, ក្តិច

បិច : ច្បិចច្បើម, ច្បិច, បបិច, បបិចបបោច

ទិច : ទ្រនិច

ប្រិច : ប៉ប្រិច, ប្រិចៗ

ព្រិច : ព្រិចៗ, ពព្រិចភ្នែក

លិច : ពន្លិច, ផ្លិច, លិចលង់, ខាងលិច

ស្រិច : ស្រិចៗ, សស្រិច, ស្រស្រិកសស្រាក់

មិច : មមិច, មមិចមមើម, ធ្មេច

១១. អប់ ~ អ៊ប់, អល់ ~ អ៊ល់

ឧទាហរណ៍ :

កប់ : បង្កប់, កំណប់, ផ្កប់, ខ្ទប់

ចប់ : បញ្ចប់, ចប់ចុងជួន

ខ្ទប់ : កញ្ចប់, កញ្ចិបកញ្ចប់

តប់ : តប់ប្រមល់, ប្រតប់, ប្រពាយប្រតប់

ថប់ : ធុញថប់, បន្ថប់

សប់ : ស្អប់

ឡប់ : បន្លប់, ឡប់ឡែ, ឡប់ៗ, សន្លប់

គប់ : សង្គប់, សេពគប់

គ្រប់ : បង្គ្រប់, គម្រប់

កល់ : កំណល់, ខ្នល់

សល់ : បន្សល់, សំណល់, រសាប់រសល់

ញល់ : ពញ្ញល់, ញោះញល់

ជល់ : ប្រជល់, បញ្ជល់ ~ ឈ្មុសឈ្មុល ~ ឈ្មោល

ដល់ : ផ្ដល់, ប្រដល់, ថ្នល់

ទល់ : ប្រទល់, ~ ផ្ទាល់, ចន្ទល់

១២. អប ~ អឹប

ឧទាហរណ៍ :

អប : អែបអប, ផ្អប

តប : តតប, ឆ្លើយតប

កប : កាក់កប, ប្រកប

រប : ប្រប, ស្រប, សម្រប, សម្របសម្រួល, រណប, រណោបរណាប

១៣. អស់ ~ អឹស់

ឧទាហរណ៍ :

អស់ : បង្អស់, មិនអស់មិនហើយ, ទាំងអស់

សោះ : ខ្សោះ, បន្សោះ, សោះអង្គើយ, សោះកក្រោះ រសេះរសោះ

តោះ : តោះតើយ, តេះតោះ, តោះមម៉ោះ

លោះ : រលោះ, រំលោះ

ដោះ : រំដោះ, រដោះ, បណ្ដោះ, ដំណោះស្រាយ

គោះ : រងោះរងើ្គ
គ្រោះ : សោះកគ្រោះ, គ្រៀមគ្រោះ, រថគ្រោះ

១៤. អាក់ ~ អ៊ាក់

ឧទាហរណ៍ :

អាក់ : រអាក់រអួល, បង្អាក់, ផ្អាក
កាក់ : រកាក់រកុប, កាក់កប
តាក់ : តតាក់តតុប, តាក់ៗ
ទាក់ : ប្រទាក់, ផ្ទាក់, ទទាក់, ប្រទាក់ប្រទាញ, ទ្រមាក់ អន្ទាក់, បន្ទាក់, ទាក់ទាញ, អន្ទាក់អន្ទង, ទំនាក់ ទាក់ទង, ទំនាក់ទំនង, ទំនាក់ទំនួល, ស្ទាក់ស្ទើរ, ស្ទាក់, ទាក់ទិន
ដាក់ : បណ្ដាក់, ថ្នាក់, ថ្នាំងថ្នាក់, រដាក់រដុប, ដំណាក់
ពាក់, : ពពាក់, ពពាក់ពពូន, បំពាក់, បំពាក់បំប៉ន, ពំនាក់, ពឹងពាក់, ពំនាក់អាស្រ័យ, ជំពាក់, ភ្ញាក់, ជំពាក់ជំពិន
វាក់ : វាក់វិន, ចង្វាក់, ឆ្វាក់, ស្វាក់, សង្វាក់
ធាក់ : ត្រធាក់, ទធាក់
បាក់ : បំបាក់, កំបាក់, បាក់បែក, បំបែកបំបាក់, កំបិកំបាក់
ចាក់ : ចចាក់, ប្រកាប់ប្រចាក់
ម្លាក់ : ទម្លាក់
លាក់ : លាក់លៀម, លាក់លួច, រលាក់, សន្លាក់, គន្លាក់, ស្លាក់, ផ្លាក់, ចម្លាក់

១៥. អាយ ~ អ៊ាយ

ឧទាហរណ៍ :

ឆ្ងាយ : ចង្ងាយ

ឈាយ : រលាយ, រំលាយ, ល្បាយ

អាយ : នាយអាយ, ក្អាកក្អាយ

ឆ្ងាយ : ចម្ងាយ

ណាយ : ជិនណាយ, នឿយណាយ

ចាយ : ចំណាយ, ចាយវាយ, ខ្ចាយ, កម្ចាយ, ខ្ចរខ្ចាយ

ឆាយ : ឈ្ងួសឆាយ

កាយ : កកាយ, កកេរកកាយ, ខ្ទាយ

ផាយ : បំផាយ, ប៉ផាត់ប៉ផាយ

សាយ : រសាយ, ផ្សព្វផ្សាយ, សាយភាយ, ផ្សាយ, រំសាយ

រាយ : ប្រាយ, របាយ ( ការណ៍ ), ព្រាយ, ពង្រាយ, ពព្រាយ

រាយមាយ, រាយប៉ាយ, ស្រាយ, សម្រាយ, ដោះស្រាយ

រាត់រាយ

ឡាយ : បន្លាយ, ប្រឡាយ, អន្លាយ, ទាំងឡាយ,

តាយ : ប្រតាយប្រតប់, រតាយ, អន្ទេអន្តាយ

ក្លាយ : កម្លាយ, ក្លែងក្លាយ

វាយ : ប្រវាយ, ប្រវាយប្រតប់, រវើរវាយ

ភាយ : រំភាយ, បំភាយ, ភាយៗ, សាយភាយ

ធ្លាយ : ទម្លាយ, ធ្លុះធ្លាយ

ពាយ : រពាយ, ពពាយនាយ, ស្ពាយ, សំពាយ, សំពោងសំពាយ

ពព្រាយ, ញាយ
នាយ : ឯនាយ, នាយអាយ
ទាយ : ទស្សន៍ទាយ, ទំនាយ
រង្គាយ : រង្គោះរង្គាយ, ស្គុសស្គាយ, ល្គងល្គាយ
ជាយ : ជាយៗ, ជជាយ
លាយ : រលាយ, រំលាយ, ធ្លាយ, ទម្លាយ, ផ្លាយ

១៦. អុក ~ អ៊ុក

ឧទាហរណ៍ :

អុក : ផ្អុក, រំអុក
ទុក : ផ្ទុក, បន្ទុក, បន្ទុកបណ្ដាក់, ទំនុក, ទុកដាក់
ចុក : ឆ្នុក, ចំណីចំណុក, បញ្ចុក, បញ្ចុកបន្សី
រុក : រន្ទុក, រុករាន, របុករបក, រុករើ
បុក : អំបុក, បំបុក
លុក : គ្រលុក, លុកលុយ ភ្លុក

១៧. អុះ ~ អ៊ុះ

ឧទាហរណ៍ :

ចុះ : បញ្ចុះ, ចំណុះ, ចំរុះ
រុះ : ជម្រុះ
ជុះ : ជ្រុះ, ជំរុះ, ជជុះ
លុះ : រលុះរលាយ, ធ្លុះ, ធ្លុះធ្លាយ, ឆ្លុះ, ចន្លុះ, ខ្លុះ

ដុះ : បណ្ដុះ, ដំណុះ, ដុះដាល
ផ្ទុះ : បន្ទុះ, សន្ទុះ, ស្ទុះ
ពុះ : ពពុះ, បំពុះ, ពំនុះ, រំពុះ
សុះ : សស្ទុះ, បន្សុះ, សុះសាយ

១៨- អុញ ~ អ៊ុញ
ឧទាហរណ៍ :
សុញ : រសេញរសុញ, ស្រុញ, សុញសាញ
កុញ : អង្កុញ, កកកុញ
តុញ : កន្តុញ, កន្តុញកន្តៀ, តេញតុញ, កន្តេញកន្តុញ
ធុញ : ធុញទ្រាន់, ធុញថប់

១៩- អុំ ~ អ៊ុំ, អំ ~ អ៊ឹ
ឧទាហរណ៍ :
កុំ ~ កុម : ក្រុម
ដុំ : បណ្ដុំ, ផ្ដុំ, ប្រមូលផ្ដុំ, ដុំកំភួន
ជុំ : ប្រជុំ, បញ្ជុំ, ភ្ជុំ, ភ្ជុំភ្ជរ, ជួបជុំ
ឃុំ : បង្ឃុំ, ឃុំឃាំង
សុំ ~ ស៊ុំ : សំណុំ, ត្រសុំ, ត្រសាយត្រសុំ, អន្សម, ស៊ុំទ្រម
រុំ : របុំ, ជំរំ ~ រោម ~ របោម
ហ៊ុំ : ហ៊ុំព័ទ្ធ, ផាហ៊ុំ
តុំ : ផ្ដុំ, បង្គុំ, ផ្សំផ្ដុំ, គំនុំ, ឃ្មុំ

ងំ : សំងំ, រងំ, ផ្ងំ

ក្លំ : ក្លៀវក្លំ, មូលក្លំ

២០. អូង ~ អ៊ូង

ឧទាហរណ៍ :

ខ្ញូង : ក្រហ្វូង, ប្រហោង, កំហ្វូង

ដ្ខូង : អណ្តូង, ដាំដ្ខូង ~ ស្រទ្វូង ~ ត្បូង

រ្វង : ទ្រ្វង, ទ្រទ្វូង

ឈ្វូង : ឆកឈ្វូង

២១. អូច ~ អូញ

ឧទាហរណ៍ :

ហ្វូច : បង្ហូច

ខ្វូច : គំនួច, គ្រហ្វូច

គ្វូច : កំនួច, ខ្យល់គ្វូច

ដ្វូច : ដំនួច, ផ្តួច, ផ្តួចផ្តើម

រ្វូញ : ជ្រួញ, បំព្រួញ, ពង្រួញ, ក្រួញក្រាប, រ្វួញរា

ទ្វូញ : ទំនួញ

២២. អើក ~ អ៊ើក

ឧទាហរណ៍ :

លើក : ល្បើក, រំលើក, លើកលែង

ពើក : ពំនើក, ពពើក, ពើកៗ, រពើក

បើក : របើក, ប៉ើក១

គ្រើក : កគ្រើក, កំរើក

តើក : ត្អើក, តតើក, តតាក់តតើក, តើក១

រើក : ររើក, រិររើក, ក្ញើក១

២៣. អើង ~ អ៊ើង , អើន ~ អ៊ើន

ឧទាហរណ៍ :

អើង : រើសអើង

ពើង : បំពើង, ពើតពើង, រំពើករំពើង

ឡើង : ដំឡើង, រំលើង, រលើង

ថ្កើង : តំកើង, ថ្កើងថ្កាន

ប៉ើង : បំប៉ើង, ចំបើង

កើន : បង្កើន, កំណើន, បង្កបង្កើន, គ្រើន

ច្រើន : ចំរើន, ចំរុងចំរើន

២៤. អើត ~ អ៊ើត

ឧទាហរណ៍ :

តើត : ចំតើត

ឆើត : ឆើតឆាយ,

ភ្លើត : ភ្លើតភ្លើន

កើត : បង្កើត, កំណើត, ខ្មើត, បង្កបង្កើត, ស្លើត, ខាងកើត

២៥. អើ ~ អ៊ើ

ឧទាហរណ៍ :

លើ : លីលើ, រលោក់រលើ, លលើលលើ

ងើ : ល្ងើ, ល្ងីល្ងើ, ល្ងាក់ល្ងើ

លើស : បំផ្លើស, ពន្លើស, ល្មើស

ហើរ : បង្ហើរ, ហោះហើរ

ហើយ : បង្ហើយ, រំហើយ, រហើយ

ហើប : បង្ហើប, រហើប

សើ : សើៗ, សើរើ, សរសើរ, ស្មើ, សំណើ

២៦. អៀក ~ អៀត ~ អៀប

ឧទាហរណ៍ :

កៀក : បង្កៀក, កៀកកើយ

បៀត : បៀតបៀន, ត្បៀត

ច្រៀក : ចំរៀក

២៧. អែក ~ អ៊ែក , អែង ~ អ៊ែង

ឧទាហរណ៍ :

បែក : បំបែក, ផ្នែក, ប៉ែក, បាក់បែក

ចែក : ចំណែក, បំណែងចែក, ចែកចាយ

គែក : ប្រគែក

ជែក : ជ្រែក, ជជែក

រែក : អំរែក, ព្រែក, រាំរែក

កែង : ត្រលែងកែង, ខ្នែង

បែង : បំណែង, ចំបែង, អំបែង, សំដែង, (ផ្ទះសំបែង)

ជែង : ជ្រែង, ជ្រោមជ្រែង

វែក : ល្វែក, លង្វែក, វែកញែក, ភ្នែក

វែង : ល្វែង, ប្រវែង, វង្វែង, ស្វះស្វែង

ឡែក : ប្លែក, ចំឡែក, រំលែក

លែង : ថ្លែង, លះលែង, គ្រលែង, ព្រលែង

២៨. អាំង ~ អាំង

ឧទាហរណ៍ :

យាំង : បង្យាំង, ឃុំយាំង

ខាំង : បង្ខាំង, ខាខាំង, ខ្នាំង

រាំង : របាំង, រនាំង, រារាំង

ប៉ាំង : បិទបាំង, ក្បាំង

រាំង : ររាំង, រាំងនន

ពាំង : ពាំងពារ

ឆាំង : ប្រឆាំង ~ ច្បាំង, ចំបាំង

កាំង ឬ គាំង : ស្រឡាំងកាំង

២៩. អេះ

ឧទាហរណ៍ :

បេះ : របេះ, ប្រេះ, ប្រឡេះ

កេះ : ខ្វេះ, កកេះកកាយ

ឆេះ : បញ្ឆេះ, ប្រឆេះ

ផេះ : ផេះផង់, ប្រផេះ

( នៅមាន ត )

ឯកសារជំនួយអ្នកសិក្សាស្រាវជ្រាវវប្បធម៌

# មតិបញ្ញត្តិអំពីរដ្ឋ និង រាជសម្បត្តិ នៅទ្វីបអាស៊ីអាគ្នេយ៍

# Conceptions of State and Kingship in Southeast Asia

Robert Heine - Geldern

បកប្រែដោយ **ឈន អៀម**

នៅពេលដែលប្រព័ន្ធនយោបាយទាំងមូលរបស់ទ្វីបអាស៊ីអាគ្នេយ៍ ហាក់ដូចកំពុងឋិតនៅក្នុងខួបថ្មីមួយនៃការអភិវឌ្ឍន៍ ដែលគ្របដណ្តប់ដោយពលានុភាពក្នុងស្រុក, ការរិះរកអោយឃើញគ្រឹះមនោគមវិជ្ជារបស់ការគ្រប់គ្រងក្នុងស្រុក នឹងបានជាកិច្ចការចាំបាច់ ហើយប្រហែលជាការរិះរកនេះ នឹងមានសារសំខាន់ច្រើនជាងអត្ថប្រយោជន៍ខាងទ្រឹស្តីសុទ្ធសាធទៀតផង ។ តើអ្វីខ្លះជាមតិបញ្ញត្តិខាងសាសនានិងទស្សនវិជ្ជាដែលទ្រទ្រង់និងបង្កើតរូបរាងអោយរដ្ឋទាំងឡាយនៃទ្វីបអាស៊ីអាគ្នេយ៍ ? តើមតិបញ្ញត្តិទាំងនោះ ឋិតថេរនៅជាកំឡាំងរស់នៅឡើយ ដែលយើងត្រូវយកមកពិចារណា ឬជាមតិបញ្ញត្តិស្លាប់បាត់កន្លងទៅហើយ ? តើយើងអាចបញ្ចូលគំនិតថ្មីទៅក្នុងប្រពៃណីចាស់, តាមរយៈនេះ យើងចៀសវាងបានការផ្តាច់ទាំងស្រុង ជាមួយអតីតកាល, ដ៏ជាការរលំរលើងដ៏គ្រោះថ្នាក់នៃគំនិត និងវប្បធម៌របស់បូព៌ាប្រទេសបានដែរឬទេ ?

ដោយសារឱកាសមានព្រំដែនកំណត់ ខ្ញុំត្រូវដាក់កំហិតខ្លួនខ្ញុំ នៅត្រឹមការពិភាក្សាអំពីមតិបញ្ញត្តិជាមូលគ្រឹះនៃរដ្ឋ និងរាជសម្បត្តិ នៅក្នុងភាគដែនដីទាំងនោះនៃទ្វីបអាស៊ីអាគ្នេយ៍ ដែលអរិយធម៌ហិណ្ឌូ និងពុទ្ធសាសនា បានរីកដុះដាល ។

## មហន្តលោកធាតុ និង ខុទ្ទកលោកធាតុ (MACROCOSMOS AND MICROCOSMOS)

ចំណោះដឹងដំបូងដែលយើងត្រូវពិចារណា គឺជំនឿក្នុងភាពស្របគ្នារវាងមហន្តលោកធាតុ និង ខុទ្ទកលោកធាតុ, រវាងលោកធាតុ និងពិភពលោករបស់មនុស្ស ។ យោងតាមជំនឿនេះ មនុស្សជាតិឋិតនៅជាប្រចាំក្រោមឥទ្ធិពលនៃកំឡាំងផ្សាយចេញមកពីទិសនានា និងអំពីតារា និងផ្កាយព្រះគ្រោះទាំងឡាយ ។ កំឡាំងទាំងនោះ អាចបង្កើតអោយមានសុខុមាលភាព និងសេចក្តីចំរុងចំរើន ឬបង្កើតអោយមានគ្រោះមហន្តរាយ, យោងទៅតាមសភាពការណ៍ដែលថា តើបុគ្គលម្នាក់ៗ ឬក្រុមសង្គម, ជាពិសេសគឺ រដ្ឋ បានសំរេចជោគជ័យក្នុងការធ្វើអោយជីវិត និងសកម្មភាពរបស់គេ មានសុខដុមរមនាជាមួយលោកធាតុ បាន ឬអត់ ។ បុគ្គលម្នាក់ៗ អាចសំរេចបាននូវសុខុមាលភាពបែបនេះ ដោយត្រូវធ្វើតាមការចង្អុលប្រាប់របស់ហោរាសាស្ត្រ, យាមទស្សន៍ទាយថ្ងៃមានលាភ និងថ្ងៃឥតលាភ និងក្បួនបន្ទាប់បន្សំដទៃទៀតជាច្រើន ។ សុខុមាលភាពរវាងអាណាចក្រ និងលោកធាតុ ត្រូវបានសំរេចឡើងតាមការរៀបចំចាត់តាំងអាណាចក្រ អោយទៅជារូបភាពរបស់លោកធាតុ, ទុកដូចជាលោកធាតុខ្នាតតូចមួយ ( ខុទ្ទកលោកធាតុ ) ។

គេបានដឹងច្បាស់ថា គោលការណ៍ហោរាសាស្ត្រ ឬយើងអាចហៅថា គោលការណ៍លោកធាតុមន្តអាគម ( Cosmos-magic principle ) មានដើមកំណើតនៅកន្លែងណាមួយក្នុងក្បែរបូព៌ា ( the Near East ) ។ គោលការណ៍

នេះមានគ្រឹះរឹងមាំនៅក្នុងប្រទេសបាប៊ីឡូន នាសហស្សវត្សទិ ៣ មុន គ.ស. ហើយមានសេចក្ដីចង្អុលប្រាប់ខ្លះថា វាអាចកើតមានមុននេះទៀត យ៉ាងហោចណាស់ក៏នៅពាក់កណ្ដាលសហស្សវត្សទិ ៤ ដែរ, ហើយប្រហែលជាឆ្ងាយជាងនេះទៀតផង ។ យើងក៏មានសេចក្ដីចង្អុលប្រាប់ផងដែរថា គោលការណ៍នេះបានកើតមាននៅក្នុងប្រទេសឥណ្ឌា ភាគពាយ័ព្យ នៅក្នុងពាក់កណ្ដាលទីពីរ នៃសហស្សវត្សទិ ៣ ។ គោលការណ៍នេះ បានជះឥទ្ធិពលលើទ្វីបអឺរុបតាមផ្លូវផ្សេងៗ និងនៅពេលផ្សេងៗ, ជាពិសេស ក្នុងអំឡុងសម័យកាលអារ្យធម៌ក្រិក ( Hellenism ) និងសម័យកាលអាណាចក្ររ៉ូម៉ាំង ហើយនិងក្នុងមជ្ឈិមយុគ ។ គេពិបាកនិយាយប្រាប់ថាតើនៅពេលណា គោលការណ៍នេះបានមកដល់ប្រទេសចិនជាដំបូង ។ ទោះជាយ៉ាងនេះក្ដី គោលការណ៍នេះ បានរីកចំរើននៅទីនោះ ទៅជាប្រព័ន្ធមួយមានឯកទេសយ៉ាងខ្ពស់ នៅក្នុងអំឡុងសម័យកាលរាជវង្ស ជូ និង ហាន ។ គោលការណ៍នេះបានមកដល់ទ្វីបអាស៊ីអាគ្នេយ៍ តាមច្រកប្រទេសឥណ្ឌា ក៏ដូចជាតាមច្រកប្រទេសចិនដែរ ហើយឥទ្ធិពលទាំងនេះ អាចបញ្ជាក់បាននូវភាពលេចត្រដែតនៅទីនោះ និងភាពរឹងមាំ ដែលគោលការណ៍នេះបានឋិតនៅក្នុងសន្ដានចិត្តនៃប្រជាជនបណ្ដាប្រទេសឯនាយឥណ្ឌា និងប្រទេសឥណ្ឌូណេស៊ី ។ ជីវិតដ៏យូរលង់ និងការផ្សព្វផ្សាយនៃគោលការណ៍នេះ ទៅលើភូមិភាគដ៏ធំទូលាយ ដោយមានវប្បធម៌ប្លែកៗពីគ្នា, ហើយសូម្បីតែយ៉ាងនេះក្ដី ហេតុដែលគោលការណ៍នេះឋិតថេរបាននោះ ក៏ព្រោះតែចេះសម្របសម្រួលខ្លួនទៅនឹងសាសនាធំៗនៅក្នុងស្រុក, ទៅនឹងទ្រង់ទ្រាយជំនឿរបស់អ្នកស្រុក ក៏ដូចជាជំនឿសាសនាហិណ្ឌូ, ពុទ្ធសាសនា និងសាសនា កុងហ្វ៊ុយ-ស៊ីសដែរ, ហើយមានពេលខ្លះ ត្រូវចេះសម្របខ្លួនទៅនឹងសាសនាគ្រឹស្ដ និងឥស្លាមថែមទៀត, ដោយហេតុនេះ វាបានបង្កើតចេញជាលទ្ធផលនាំអោយមានការរីកចំរើនជាច្រើនបែប ច្រើនយ៉ាង ដោយច្រើនតែមានលក្ខណៈផ្សេងៗគ្នា យ៉ាងខ្លាំង ។

គឺដោយសារមានទិដ្ឋភាពពិសេស ស្ដីពីគោលការណ៍លោកធាតុ-មន្តអាគម ដូចមានបញ្ជាក់នៅក្នុងការរៀបចំចាត់តាំងរបស់ព្រះរាជាណាចក្រកាន់ហិណ្ឌូសាសនា និងពុទ្ធសាសនា ក្នុងទ្វីបអាស៊ីអាគ្នេយ៍ (ហើយក៏មានខ្លះ នៅក្នុងរដ្ឋទាយាទកាន់សាសនាមូហាំម៉ាត់ ក្នុងប្រទេសម៉ាឡេ និងឥណ្ឌូណេស៊ី) ផងដែរ, ទើបបានជាយើងយកចិត្តទុកដាក់នៅក្នុងទីនេះ ។

## ទំនាក់ទំនងរវាងរដ្ឋ និង លោកធាតុ

ដោយហេតុតែទស្សនៈទ្រឹស្ដី សិក្សាទំនាក់ទំនងរវាងរដ្ឋ និងលោកធាតុបង្កើតបានជាប្រធានបទមួយដ៏សំខាន់ របស់អក្សរសាស្ត្រចិនបុរាណ, យើងស្វែងរកដោយឥតប្រយោជន៍ នូវការសិក្សាទ្រឹស្ដី ស្ដីពីប្រធានបទនេះ នៅក្នុងអក្សរសាស្ត្រផ្សេងៗ នៃទ្វីបអាស៊ីអាគ្នេយ៍ (១) ។ ប៉ុន្តែថា, វាមានភស្តុតាងយ៉ាងសន្ធឹកសន្ធាប់ អំពីមូលដ្ឋាននៃលោកធាតុវិទ្យា ស្ដីពីរដ្ឋ និងរាជសម្បត្តិ នៅក្នុងភូមិភាគនេះ ។ គេបានរកឃើញភស្តុតាងនេះ នៅក្នុងអត្ថបទជាច្រើននៃអក្សរសាស្ត្រ និងសិលាចារឹក, នៅក្នុងគោរម្យងារ របស់ក្សត្រ , ក្សត្រិយានី និងមន្ត្រី, នៅក្នុងចំនួនតួលេខ « លោក-ធាតុ » សម្រាប់ក្សត្រិយានី , រដ្ឋមន្ត្រី, ព្រាហ្មណ៍បុរោហិត, ខេត្ត, ... ល, នៅក្នុងពិធី និងទំនៀមទម្លាប់, នៅក្នុងស្នាដៃសិល្បៈ, នៅក្នុងការរៀបចំប្លង់ និងរចនា-សម្ពន្ធនៃរាជធានី, វាំង, ប្រាសាទ ។ គេគ្រាន់តែត្រូវការដាក់ភស្តុតាងផ្សេងៗ ទាំងនេះបញ្ចូលគ្នា ដើម្បីបង្កើតបានជារូបភាពមួយច្បាស់បង្គួរ ។ រូបភាពនេះ នឹងមានលក្ខណៈកាន់តែគ្រប់គ្រាន់នៅក្នុងទ្វីបអាស៊ីអាគ្នេយ៍នេះ ត្រង់ទីណាដែលទម្រង់ចាស់

(១) ប៉ុន្តែ, គេត្រូវពិចារណាផងដែរថា អក្សរសាស្ត្រភូមា, មន និងថៃ មិនទាន់ត្រូវបានគេសិក្សាអោយបានម៉ត់ចត់នៅឡើយទេ ។

នៃរដ្ឋកាន់ពុទ្ធសាសនា និងរាជសម្បត្តិនិយមពុទ្ធសាសនា បានរស់រានរហូតមកដល់សម័យកាលថ្មីៗនេះ ។ នៅក្នុងទីប្រជុំកោះ មិនមានរូបភាពច្បាស់លាស់ទេ បណ្តាលមកពីឥទ្ធិពលសាសនាម្ហូហាំម៉ាត់ និងឥទ្ធិពលអឺរ៉ុប ។

យោងតាមទ្រឹស្តីព្រាហ្មណ៍, ពិភពលោកនេះ មានទ្វីបមួយ មានមណ្ឌលមូល ឈ្មោះថា ជម្ពូទ្វីប ព័ទ្ធជុំវិញដោយសមុទ្រ ៧ ជាន់ និងទ្វីប ៧ ជាន់ មានសណ្ឋានមូល ។ ហួសពីសមុទ្រ ៧ ជាន់នេះទៅ ពិភពលោកត្រូវបិទជិតដោយជួរភ្នំដ៏ធំស្តើមស្តែមួយ ។ នៅមណ្ឌលកណ្តាលជម្ពូទ្វីប ហើយនេះគឺជាមណ្ឌលកណ្តាលពិភពលោក, មានភ្នំមេរុតាំងនៅ គឺជាភ្នំលោកធាតុ ដែលព្រះអាទិត្យ, ព្រះចន្ទ, និងតារាទាំងឡាយធ្វើដំណើរគោចរជុំវិញភ្នំនេះ ។ នៅលើកំពូលភ្នំ មានឋានទេវតាព័ទ្ធជុំវិញដោយវិមានរបស់លោកបាលទាំងប្រាំបី ឬហៅថា ទេវតាឆ្មាំពិភពលោក ។

នៅក្នុងប្រព័ន្ធពុទ្ធសាសនាវិញ ក៏មាននិយាយថាភ្នំមេរុ គឺជាមណ្ឌលកណ្តាលនៃលោកធាតុដែរ ។ ភ្នំមេរុព័ទ្ធជុំវិញដោយជួរភ្នំប្រាំពីរជាន់ ហើយជួរភ្នំនិមួយៗ ខ័ណ្ឌដាច់ពីគ្នាដោយសមុទ្រមួយជាន់ៗ មានសណ្ឋានមូល ។ នៅឯនាយជួរភ្នំក្រោយបង្អស់, មានមហាសាគរលាតសន្ធឹង ដែលនៅក្នុងមហាសាគរនេះមានទ្វីបបួនតាំងនៅ, ទ្វីបនិមួយៗ ឋិតនៅក្នុងទិសធំមួយ ក្នុងបណ្តាទិសធំទាំងបួន ។ ទ្វីបឋិតនៅខាងត្បូងភ្នំមេរុ មានឈ្មោះថា ជម្ពូទ្វីប ដ៏ជាលំនៅស្ថានរបស់មនុស្ស ។ ក្នុងទីនេះដែរ, លោកធាតុ ត្រូវបានព័ទ្ធជុំវិញដោយជញ្ជាំងសិលាដ៏ធំសម្បើមមួយ ដែលជាជួរភ្នំចក្រវាល ។ នៅលើជំរាលភ្នំមេរុ មានឋានសួគ៌ជាន់ទាបបំផុតតាំងនៅ, គឺជាស្ថានរបស់មហារាជទាំងបួនអង្គ ( ចាតុម្មហារាជិកាសួគ៌ ), ដ៏ជាឆ្មាំរក្សាពិភពលោក ។ នៅលើកំពូលភ្នំមេរុ គឺជាស្ថានសួគ៌ជាន់ទីពីរ, ដ៏ជាលំនៅស្ថានរបស់ទេវតាទាំងសាមសិបបីអង្គ ដោយមាន សុទស្សនៈ ជាបុរីរបស់ទេវតា ដែលនៅក្នុងបុរីនេះ ព្រះឥន្ទ គឺជាស្តេចគ្រងរាជ្យ ។ នៅពីខាងលើកំពូលភ្នំមេរុ, មានស្ថានសួគ៌

ដែលជាន់និមួយៗ ថិតនៅពីលើគ្នា[១] បន្តបន្ទាប់ ។

យើងនឹងឃើញថា ប្រព័ន្ធព្រហ្មញ្ញសាសនា និងប្រព័ន្ធពុទ្ធសាសនា, បើទោះជាមានការខុសគ្នាខ្លះនៅក្នុងផ្នែករាយរងក៏ដោយ, ក៏មានការស្រុបគ្នាក្នុងលក្ខណៈជាមូលដ្ឋានដែរ : ដូចជាទ្រង់ទ្រាយមណ្ឌលមូល និងការរៀបចំក្នុងតំបន់សហាមណ្ឌលមូលជុំវិញភ្នំមេរុ របស់សាសនាទាំងពីរនេះ ។ រូបភាពសង្ខេប អំពីប្រព័ន្ធសាសនាណាមួយ ក្នុងបណ្ដាសាសនាទាំងពីរនេះ មានអត្ថន័យជានិមិត្តរូបដូចគ្នា សម្រាប់អ្នកជឿសាសនាទាំងពីរ ។

## ធានីជាមណ្ឌលមន្តអាគមរបស់អាណាចក្រ

នៅក្នុងទ្វីបអាស៊ីអាគ្នេយ៍, លើសជាងនៅក្នុងទ្វីបអឺរុបទៅទៀត, ធានីតាំងនៅជាតំណាងប្រទេសទាំងមូល ។ ធានីមានឥទ្ធិពលជាងមជ្ឈមណ្ឌលនយោបាយ និងវប្បធម៌របស់ជាតិទៅទៀត : វាជាមជ្ឈមណ្ឌលមន្តអាគម (មជ្ឈមណ្ឌលទាក់ទាញចិត្តដ៏អស្ចារ្យ) របស់អាណាចក្រ ។ ដំណើរដើរ ឬហែប្រទក្សិណជុំវិញធានីទាំងនៅក្នុងប្រទេសសៀម ទាំងនៅក្នុងប្រទេសខ្មែរ កាលពីអតីតកាល ក៏ដូចជានៅក្នុងបច្ចុប្បន្ន បង្កើតបានជាផ្នែកមួយដ៏មានសារសំខាន់បំផុតក្នុងបណ្ដាផ្នែកសំខាន់ៗបំផុត នៃពិធីអភិសេក ។ តាមរយៈដំណើរហែប្រទក្សិណជុំវិញនេះ ព្រះរាជាទ្រង់កាន់កាប់ជាកម្មសិទ្ធិ មិនគ្រាន់តែលើរាជធានីប៉ុណ្ណោះទេ, ប៉ុន្តែ លើព្រះរាជាណាចក្រទាំងមូល ។ ចំណែកឯរចនាសម្ពន្ធលោកធាតុវិទ្យានៃប្រទេសជារួម អាចត្រូវបានគេបង្ហាញឡើងតាមរយៈតួលេខ និងទីតាំងនៃខែត្រទាំងឡាយ និងតាមរយៈមុខងារ

(១) តាមធម្មតា មានឋានសួគ៌ទាំងអស់ ២៦ ជាន់ រួមទាំងស្ថានសួគ៌នៅលើភ្នំមេរុផង, ប៉ុន្តែចំនួនតួលេខ តែងប្រែប្រួលនៅពេលខ្លះ ។

និងនិមិត្តសញ្ញានៃអភិបាលខែត្រនោះៗ ប៉ុណ្ណោះ, រាជធានី ត្រូវបានគេរៀបចំអោយមានសណ្ឋានជារូបភាព « ពិតប្រាកដ » នៃសកលលោកធាតុ, ដ៏ជាខុទ្ទកលោកធាតុតូចមួយ នៅក្នុងមហន្តលោកធាតុនោះ, ពោលគឺ ព្រះរាជាណាចក្រនោះឯង ។ សំណល់ភស្តុតាងនៃទីក្រុងបុរាណខ្លះៗ បញ្ជាក់យ៉ាងច្បាស់ នូវគំនិតលោកធាតុវិទ្យាដែលបានជ្រួតជ្រាបចូលជ្រៅទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋទាំងមូល ។ ជាសំណាងល្អ, មាននៅសល់សិលាចារឹកមួយចំនួន និងអត្ថបទខ្លះៗ នៅក្នុងកាលប្បវត្តិក្នុងស្រុក អាចជួយយើងក្នុងការបកស្រាយភស្តុតាងបុរាណវត្ថុ ។

ដោយហេតុថា លោកធាតុ យោងតាមមតិរបស់សាសនាព្រាហ្មណ៍ និងពុទ្ធសាសនា ប្រមូលផ្តុំជុំវិញភ្នំមេរុ, ដូច្នេះ លោកធាតុតូចៗ ពោលគឺអាណាចក្រ ក៏ត្រូវតែមានភ្នំមេរុមួយនៅកណ្តាល នៃធានីរបស់អាណាចក្រនោះដែរ ដែលអាចជាមជ្ឈមណ្ឌលភូមិសាស្ត្ររបស់ប្រទេស, ឬប្រសិនបើមិនមែនជាមជ្ឈមណ្ឌលភូមិ-សាស្ត្រទេ យ៉ាងហោចណាស់ក៏ជាមជ្ឈមណ្ឌលមន្តអាគមរបស់ប្រទេសដែរ ។ ប្រហែលជានៅសម័យដើម, ភ្នំធម្មជាតិតូចៗ ត្រូវបានគេពេញចិត្តជ្រើសរើសធ្វើជាតំណាងភ្នំឋានសួគ៌ ។ នេះគឺជាករណីមួយនៅក្នុងប្រទេសខ្មែរ នាសតវត្សទី ៩ នៃគ្រិស្តសករាជ ។ យសោធរបុរ ដ៏ជាក្រុងទីមួយរបស់អង្គរ ត្រូវបានស្ថាបនាឡើងរហូតមកដល់ឆ្នាំ ៩០០ នៃគ្រិស្តសករាជ, បង្កើតបានជាផ្ទៃបួនជ្រុងមួយ ដ៏ធំសម្បើមប្រហែលប្រវែងពីរម៉ែល៍* កន្លះ នៅជ្រុងម្ខាងៗ ដោយមានជ្រុងនីមួយៗបែរមុខទៅរកទិសធំ និងដោយកំណត់យកភ្នំបាខែង ជាកូនភ្នំមានថ្មធ្វើជាផ្ចិត ( មណ្ឌលកណ្តាល ) ។ សិលាចារឹកមួយ ប្រាប់អោយយើងដឹងថា ភ្នំនេះតាំងនៅកណ្តាលរាជធានី ដោយមានប្រាសាទតាំងនៅលើកំពូល ហើយ " មានសោភណភាព ប្រៀប

* មួយម៉ែល៍ ស្មើ ១.៦០៩,៣៣ ម ។

ស្មើនឹងរាជបពិត " ពោលគឺ ភ្នំមេរុ [១] ។ ប្រាសាទលើភ្នំបាខែង មានលិង្គមួយ ដ៏ជានិមិត្តរូបនៃលិង្គរបស់ព្រះសិវៈ តាងទេវរាជ ពោលគឺ គុណធម៌ពិសិដ្ឋនៃរាជសម្បត្តិដែលសណ្ឋិតនៅក្នុងតួអង្គព្រះរាជាបច្ចុប្បន្ន ។ ជាញឹកញយណាស់ ភ្នំតាំងនៅចំណុចកណ្តាល គឺជាការច្នៃប្រឌិតសុទ្ធសាធ ដែលគេយកប្រាសាទមួយប៉ុណ្ណោះ ធ្វើជាតំណាង ។ គំនិតនេះសមស្របទៅនឹងគំនិតកំពុងកើតមាន នាពេលបច្ចុប្បន្ន ។ ជាការជាក់ស្តែង, ប្រាសាទ ឬវិហារ និមួយៗ នៅក្នុងទ្វីបអាស៊ីអាគ្នេយ៍ ទោះបីជាប្រាសាទវិហារហិណ្ឌូ ឬពុទ្ធសាសនា ក៏ដោយ, ទោះបីជាកសាងអំពីថ្ម, ឥដ្ឋ ឬឈើ ក៏ដោយ, ក៏គង់ត្រូវបានគេចាត់ទុកជារូបភាពនៃភ្នំមេរុជាទូទៅ ដោយគ្មានការប្រែប្រួលជាធំដុំឡើយ ។ នៅក្នុងប្រទេសខ្មែរបុរាណ, ប្រាសាទ / វិហារមួយ ត្រូវបានគេសន្មតតាមធម្មតាថា " គិរី " គឺភ្នំ, ហើយប្រាសាទ / វិហារ មានជាន់ច្រើន នៅបាលី (ឥណ្ឌូណេស៊ី) ក៏គេនៅហៅថា មេរុ ដែរ ។ សិលាចារឹកខ្មែរ បានបង្ហាញយ៉ាងច្បាស់ណាស់ ចំពោះការធ្វើអត្តសញ្ញាណកម្មបែបនេះ ។ ដូច្នេះ ដើម្បីបង្ហាញជា ឧទាហរណ៍ មានសិលាចារឹកមួយបាននិយាយថា ព្រះបាទឧទយាទិត្យវរ្ម័នទី II ( សតវត្សទី ១១ ) « ដោយទ្រង់យល់ឃើញថា ជម្ពូទ្វីប មានភ្នំមាសមួយ នៅត្រង់ផ្ចិត ( មណ្ឌលកណ្តាល ) របស់ខ្លួន, ព្រះអង្គក៏បានបង្គាប់អោយកសាងភ្នំមាសមួយ នៅផ្ចិតខាងក្នុងរាជធានីរបស់ព្រះអង្គដែរ ។ នៅពីលើកំពូលភ្នំមាសនេះ, ក្នុងវិមានទិព្វមួយ ភ្លឺចិញ្ចាចដោយមាស ព្រះអង្គបានអោយកសាងសិវលិង្គមួយ » ។

---

(១) ថ្វីបើ លោកធាតុវិទ្យារបស់ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា តាមធម្មតា សន្មតពិភព-លោកថា មានសណ្ឋានមូលក៏ដោយ, ក៏ទីក្រុង " លោកធាតុ " ទាំងឡាយ នៅក្នុងទ្វីបអាស៊ីអាគ្នេយ៍, លើកលែងករណីកម្រខ្លះចេញ, នៅតែប្រកាន់យកទ្រង់ទ្រាយបួនជ្រុងស្មើ ។ យើងត្រូវការពេលច្រើនដើម្បីពន្យល់រឿងនេះ, ប៉ុន្តែភាពផ្សេងពីគ្នាមិនសំខាន់ណាស់ណាទេ ។

# ការរៀបចំប្លង់អង្គរធំ

សំណង់បាក់បែកបច្ចុប្បន្ន នៃអង្គរធំ គឺជាសំណល់ នៃទីក្រុងចុងក្រោយបង្អស់នៃកន្លែងនេះ ដែលព្រះបាទជយវរ្ម័នទី ៧ បានកសាងក្នុងពាក់កណ្ដាលទីពីរនៃសតវត្សទី ១២ ។ ដោយព្រះបាទជយវរ្ម័ន ជាក្សត្រកាន់ពុទ្ធសាសនាមហាយាន, ក្នុងករណីនេះ ភ្នំតាំងនៅមណ្ឌលកណ្ដាល គឺជាវិហារពុទ្ធសាសនា ដែលមានព្រះរូបបដិមាធំតាងព្រះពុទ្ធអមិតាភៈ, ចំណែកព្រះភ័ក្ត្របួន តាងព្រះពោធិសត្វ លោកេស្វរៈ ( ព្រះជាម្ចាស់នៃលោក ) បានភ្ជាប់ជាលំអកំពូលប្រាសាទដ៏ច្រើន ។ ទីក្រុងត្រូវបានហ៊ុមព័ទ្ធដោយជញ្ជាំង និងគូជុំវិញ បង្កើតបានជាផ្ទៃបួនជ្រុងស្មើ ដែលមានប្រវែងជ្រុងនិមួយៗ ជិតពីរម៉ៃល៍ ហើយជ្រុងទាំងអស់បែរទៅរកទិសធំទាំងបួន ។ មានទ្វារចេញ - ចូល នៅកណ្ដាលជ្រុងនិមួយៗ ហើយទ្វារចេញ - ចូល ទីប្រាំ នៅទិសខាងកើត នាំទៅកាន់ទ្វារចូលព្រះរាជវាំង ។ កំពូលប្រាសាទនៅលើខ្លោងទ្វារ ក៏ត្រូវបំពាក់រូបមុខបួន នៃលោកេស្វរៈ ដូចរូបមុខបួននៃប្រាសាទកណ្ដាលដែរ ។ ដូច្នេះ, ពិភពលោកដ៏តូចនោះ គឺទីក្រុងអង្គរ ហើយតាមរយៈមធ្យោបាយនៃពិភពលោកតូចនេះ អាណាចក្រខ្មែរទាំងមូល រួមនឹងទីក្រុងអង្គរទាំងពីរនេះ ត្រូវឋិតនៅក្រោមកិច្ចការពារនៃ " ព្រះជាម្ចាស់នៃសកលចក្រវាល " ។ អត្ថន័យលោកធាតុនៃទីក្រុង ត្រូវបានគេផ្ដោតការយកចិត្តទុកដាក់វែងឆ្ងាយទៀត ដោយឧបមាវិធីមួយដ៏គួរចាប់អារម្មណ៍ ។ បង្កាន់ដៃស្ពាននៃផ្លូវចូលឆ្លងកាត់គូ ទៅកាន់ទ្វារទីក្រុង ត្រូវបានធ្វើឡើងដោយរូបថ្មធំៗពីរជួរ, ពាក់កណ្ដាលជួរជាពួកទេពតា, ពាក់កណ្ដាលជួរជាពួកយក្សឈរកាន់ពស់ដ៏ធំសម្បើមមួយមានក្បាលប្រាំពីរ ។ ដោយប្រការនេះ ទីក្រុងទាំងមូលបានក្លាយទៅជាការបង្ហាញការកួរសមុទ្រទឹកដោះយកទឹកអម្រឹត ដោយពពួកទេពតា និងយក្ស ដោយគេបានប្រើនាគរាជ ឈ្មោះ វាសុកី ធ្វើជាខ្សែពួរ ហើយយកភ្នំមេរុធ្វើ

ជាដំបងកូរ [១] ។ ការបង្ហាញនេះ សំដៅបញ្ជាក់ន័យថា គូជុំវិញ មានន័យជានិមិត្តរូប តំណាងមហាសាគរ ហើយបាយ័នជាប្រាសាទស្ថិតចំកណ្ដាលទីក្រុង គឺជាចំណុច ដែលជួរទេពតា និងយក្ស ទាញខ្សែព្រួរកូរសមុទ្រទឹកដោះសំដៅទៅរក គឺជាភ្នំមេរុ នោះឯង ។

## ធានីនៃប្រទេសភូមា

កាលប្បវត្តិភូមា និយាយថា ស្រីក្សេត្រ ( ទីក្រុងប្រូមបុរាណ ) ឋិតនៅលើដងទន្លេឥរាវឌ្ឌីភាគខាងក្រោម គឺជារាជធានី នៃព្រះរាជាណាចក្របុរាណរបស់ជនជាតិព្យុ ។ ស្រីក្សេត្រ ត្រូវបានពពួកទេពតា, ដោយមានព្រះឥន្ទ្រាធិរាជ ជាប្រមុខ, កសាងឡើង គឺកសាងតាមរូបភាពទីក្រុងឈ្មោះ សុទស្សិនៈ របស់ព្រះឥន្ទ្រ ដែលឋិតនៅលើកំពូលភ្នំមេរុ, ដោយមានទ្វារធំសាមសិបពីរ និងមានវិមានមាសនៅចំកណ្ដាលទីក្រុង ។ សំណល់បាក់បែកនៃទីក្រុង បង្ហាញយ៉ាងជាក់ស្ដែង នូវការប៉ុនប៉ងយ៉ាងមោះមុត ដើម្បីរៀបចំប្លង់ទីក្រុងជាមណ្ឌលមូល ថ្វីបើភាពជាក់លាក់ពេញលេញមិនទាន់ធ្វើបានអោយសំរេចក៏ដោយ ។ វាហាក់ដូចជាមានទំនៀមទម្លាប់ចាស់ទុំមួយនៅក្នុងប្រទេសភូមាថា ទ្វារនិមួយៗរបស់រាជធានី ត្រូវអោយស្របទៅនឹងខេត្រនិមួយៗ របស់ព្រះរាជាណាចក្រ ឬស្របទៅនឹងរដ្ឋសាមន្តរាជ ( រដ្ឋចំណុះ ) ។ ប្រទេសរាជ ( ស្ដេចចំណុះគេ ) ឬប្រមុខខេត្រទាំងសាមសិបពីរ រួមនឹងព្រះមហាក្សត្រ ជាគម្រប់ទីសាមសិបបី គង់នៅជាស្នូលកណ្ដាល សមស្របយ៉ាងពិតប្រាកដ ទៅនឹងទេពតាទាំងសាមសិបបីអង្គ ដែលគង់នៅលើកំពូលភ្នំមេរុ ហើយក្នុង

(១) នៅក្នុងទេវកថាច្បាប់ដើម, គេបានយកភ្នំមន្ទរៈ ធ្វើជាដំបងកូរសមុទ្រទឹកដោះ ។ នៅក្នុងទេវកថាប្លែកៗគ្នា នៃទ្វីបអាស៊ីអាគ្នេយ៍, គឺភ្នំមេរុ ដើរតួជាដំបងកូរសមុទ្រទឹកដោះ ។

ចំណោមទេពតាទាំងនោះ ព្រះឥន្ទ្រគឺជាទេវរាជ ។ ដូច្នេះ មិនគ្រាន់តែរាជធានីប៉ុណ្ណោះទេ សូម្បីតែអាណាចក្រទាំងមូលរបស់ ព្យុ ក៏ត្រូវរៀបចំចាត់តាំងអោយដូចជារូបភាពរបស់ទេវាណាចក្រ នៃព្រះឥន្ទ្រដែរ ។

នៅក្នុងធានីទាំងឡាយក្រោយៗមកទៀត របស់ប្រទេសភូមា, សណ្ឋានបួនជ្រុងស្មើ ត្រូវបានជំនួសសណ្ឋានមណ្ឌលមូលវិញ ថ្វីបើគោលការណ៍លោកធាតុវិទ្យាបែបនោះ (មណ្ឌលមូល) នៅតែត្រូវបានគេរក្សាទុកក៏ដោយ ។ យើងនឹងត្រូវនិយាយពាក្យពីរបីមាត់អំពីទីក្រុងមណ្ឌលេ, ដ៏ជាធានីក្រោយមកនៃប្រទេសភូមាឯករាជ, កសាងឡើងដោយព្រះបាទមិនដូន (King Mindon) ក្នុងគ.ស ១៨៥៧ ។ ទីក្រុងខាងក្នុងព័ទ្ធជុំវិញដោយកំពែងមួយ ហើយនិងគូ បង្កើតទៅជាផ្ទៃបួនជ្រុងស្មើដែលមានជ្រុងនិមួយៗប្រវែងជាងមួយម៉ៃល៍ ហើយជ្រុងទាំងអស់បែរទៅរកទិសធំ។ ព្រះរាជវាំងដែលតាំងនៅកណ្ដាលក្រុង, ហើយជាពិសេសបំផុត ឆត្រត្រួតប្រាំពីរជាន់ត្បូរនៅពីលើរាជបល្លង្កក្នុងមហាសាលសម្រាប់សវនាការ ត្រូវបានគេកំណត់សម្គាល់ថាជាភ្នំមេរុ ។ ទ្វារទាំងបីនៃជ្រុងនិមួយៗ នៃទីក្រុង រួមទាំងអស់ មានទ្វារដប់ពីរ, ហើយទ្វារទាំងអស់នេះមានឆ្លាក់សញ្ញារាសីចក្រ (the zodiac), តាមរយៈសញ្ញានេះ ចង្អុលប្រាប់ថា ទីក្រុងមានអត្ថន័យជារូបភាពនៃស្ថានសួគ៌ ដោយមានហ្វូងតារាអណ្ដែតព្រោងព្រាតជុំវិញទេវបពិត នៅកណ្ដាលទីក្រុង ។

## តួនាទីលោកធាតុនៃព្រះរាជា, វាំង និងរដ្ឋាភិបាល

ឥឡូវ, យើងចាប់ផ្ដើមដំណាក់សិក្សាពីតួនាទីលោកធាតុរបស់ស្ដេច, វាំង និងរដ្ឋាភិបាល ។ យើងជ្រើសយកប្រទេសភូមាជាឧទាហរណ៍ ។ នៅទីនោះ, ស្ដេចមានមហេសីថ្នាក់ឯក បួនអង្គ និងមហេសីថ្នាក់ទោ បួនអង្គទៀត ដែលមានគោរម្យងារថា «មហេសីប្រាសាទឧត្តរទិស», «មហេសីប្រាសាទបស្ចិមទិស», «មហេសី

ប្រាសាទទក្ខិណទិស», . ល . ។ គោរម្យងារទាំងនោះ បង្ហាញថា មហេសី ទាំងនោះ តាមប្រភពដើម ត្រូវស្របទៅតាមទិសធំទាំងបួន និងអនុទិសទាំងបួន ។ មានសេចក្តីបញ្ជាក់ទៀតថា នៅសម័យពីដើម បន្ទប់របស់មហេសីទាំងឡាយនោះ តាមការណ៍ពិតគឺ ឋិតនៅជារង្វង់មូលជុំវិញដំណាក់របស់ស្តេច, តាមរយៈនេះ គេសង្កត់លើសារៈសំខាន់របស់តួនាទីស្តេច ទុកជាស្នូលនៃសកលលោកធាតុ និងជាតំណាងព្រះឥន្ទ ដ៏ជាទេវរាជក្នុងស្ថានសួគ៌ លើកំពូលភ្នំមេរុ ។ ការសង្កេតរបស់លោក ជេម ហ្សក ស្កុត (Sir James George Scott) ថា បរាជ័យរបស់ស្តេចធីបាវ (King Thibaw) ជាព្រះរាជាចុងក្រោយរបស់ប្រទេសភូមា ដើម្បីផ្តល់អោយព្រះអង្គឯងផ្ទាល់ នូវចំនួនមហេសីស្របតាមការចាត់តាំង បានបណ្តាលអោយកើតមានសេចក្តីព្រួយបារម្ភដល់ប្រជាពលរដ្ឋ ដែលគោរពច្បាប់ត្រឹមត្រូវច្រើនជាងការសម្លាប់រង្គាលមកលើព្រះញាតិវង្សរបស់ព្រះអង្គទៅទៀត ។ ព្រឹត្តិការណ៍នេះបញ្ជាក់ថា ការកំណត់របស់លោកធាតុ នេះ ល្មមអោយគេយល់បានថាមានសារសំខាន់យ៉ាងណានោះហើយ[(១)] ។ មានរដ្ឋមន្ត្រីជាអធិបតីបួនរូប ; រដ្ឋមន្ត្រីជាអធិបតីមួយរូប១, បន្ថែមពីលើមុខងារជារដ្ឋមន្ត្រីរបស់ប្រទេស, កាលដើមឡើយ ត្រូវទទួលបន្ទុកមើលការខុសត្រូវលើតំបន់ផ្ទៃដីមួយភាគបួនរបស់រាជធានី និងរបស់អាណាចក្រ ថែមទៀត ។ រដ្ឋមន្ត្រីទាំងបួនរូប ស្របគ្នាយ៉ាងច្បាស់ក្រឡែតទៅនឹងមហារាជ ឬលោកបាលទាំងបួន (ចតុលោកៈបាល) ជាទេពតាឆ្មាំប្រចាំទិសធំទាំងបួន នៅក្នុងលទ្ធិពុទ្ធសាសនា ។ ប៉ុន្តែថា ភារកិច្ចជំនួសចតុលោកបាល ត្រូវបានផ្ទេរទៅអោយសេនាពិសេស ៤ រូប ដែលម្នាក់១ ត្រូវថែរក្សាការពារជ្រុង ឬចំហៀងមួយនៃវាំង និងរាជធានី, មន្ត្រីពិសេសទាំងនោះ មាន

(១) ដូចគ្នានេះដែរ, លោក H.G. Quaritch Wales បានអធិប្បាយអំពីដំណឹតស្មាមដ៏អាក្រក់ដែលបានកើតមានក្នុងចណ្តាប្រជាពលរដ្ឋ ព្រោះការលុបចោលប្រព័ន្ធស្រីស្នំ ដោយស្តេចរាមា ទី VII នៃប្រទេសសៀម ។

ទង់ប្រកបដោយព័ណ៌ស្របទៅតាមជ្រុងនៃភ្នំ មេរុ, មន្ត្រីមួយរូប តាងព្រះបាទធតរដ្ឋ ជាលោកបាលរក្សាទិសខាងកើត មានទង់ពណ៌ស, មន្ត្រីតាងព្រះបាទកុបេរៈ (កុវេរៈ) ជាលោកបាលរក្សាទិសខាងជើង មានទង់ពណ៌លឿង, ... ល ។ គោលការណ៍លោកធាតុ ត្រូវបានគេប្រើចុះមកដល់មន្ត្រីថ្នាក់ក្រោម តាមរយៈឋានានុក្រមនៃមន្ត្រី ដូចឃើញមានប្រើសម្រាប់មន្ត្រីបំរើការក្នុងក្រសួងមួយចំនួន ។ តួយ៉ាង, អនុរដ្ឋលេខាធិការមាន ៤ រូប, លេខាធិការជំនួយ ប្រាំបីរូប, រាជទូត (Heralds) បួនរូប, អ្នកនាំព្រះរាជសារ បួនរូប, ... ល ។

មានអង្គការចាត់តាំងដូចគ្នាយ៉ាងច្រើន នៅក្នុងប្រទេសសៀម, ប្រទេសខ្មែរ និងប្រទេសជ្វា ។ ជាញឹកញាយ យើងឃើញមានប្រើចំនួនតួលេខសម្រាប់ស្នងឯកបួនរូប និងរដ្ឋមន្ត្រីជាអធិបតីបួនរូប ( សេនាបតី ) " ចតុស្តម្ភ " ដូចដែលគេអោយឈ្មោះនៅក្នុងប្រទេសខ្មែរ ។ នៅក្នុងប្រទេសសៀម និងប្រទេសភូមា, រដ្ឋមន្ត្រី ( សេនាបតី ) ទាំងនោះ កាលដើមឡើយបានគ្រប់គ្រងភាគទាំងបួន នៃផ្ទៃព្រះរាជាណាចក្រដែលលាតសន្ធឹងឆ្ពោះទៅរកទិសធំទាំងបួន ។

មានសេចក្តីចង្អុលប្រាប់ថា នៅក្នុងសម័យបុរាណ រចនាសម្ពន្ធលោកធាតុនៃរដ្ឋ ត្រូវបានអនុវត្តវែងឆ្ងាយជាងនេះទៀត ។ ខ្ញុំបាននិយាយរួចហើយអំពីការប្រមាណថា ព្រះរាជាណាចក្របុរាណរបស់ព្យុ នៅក្នុងប្រទេសភូមា មានខេត្រ ឬរដ្ឋសាមន្តរាជសាមសិបពីរ, អភិបាលខេត្រ ឬស្តេចប្រទេសរាជទាំងសាមសិបពីរ រួមជាមួយនឹងព្រះមហាក្សត្រ មានចំនួនស្របទៅនឹងចំនួនទេពតាទាំងសាមសិបបីអង្គ គង់នៅឋានសួគ៌លើកំពូលភ្នំមេរុ ។ ដូចគ្នានេះដែរ ព្រះរាជាណាចក្រនៃជនជាតិ*ប៉េគុ* (Pegu) ក្នុងសតវត្សទី ១៤ ក៏មានខេត្រសាមសិបពីរ ។ ក្សត្រប្រទេស (the principality) របស់ជនជាតិ*កេងទុង* (Keng Tung) ជារដ្ឋមួយដ៏ធំទូលាយរបស់ជនជាតិ*សាន់* (Shan) ក្នុងចំណោមរដ្ឋធំៗរបស់*សាន់* ត្រូវបានគេអោយ

ឈ្មោះប្រកបដោយអត្ថន័យថា " ក្រុងសាមសិបពីរ របស់ជនជាតិ *ឃុន* (the khün) ", ជនជាតិ*ឃុន* ជាពួកកុលសម្ពន្ធគ្រប់គ្រងគេ នៅក្នុងរដ្ឋ ។ មានវគ្គមួយនៅក្នុងសៀវភៅឈ្មោះ " ប្រវត្តិសាស្ត្រថ្មី នៃ សន្តតិវង្សតាំង " (the New History of the T'ang Dynasty) ចង្អុលប្រាប់ថា រាជាណាចក្រជ្វា ក្នុងសត-វត្សទី ៩ បានចែកចេញជា ២៨ ខេត្រ, លោកអភិបាលរបស់ខេត្រទាំង ២៨ រួមជាមួយរដ្ឋមន្ត្រី (សេនាបតី) ទាំងបួន ត្រូវបានជាចំនួនមន្ត្រីជាន់ខ្ពស់សាមសិបពីររូប ។ នេះអាចជាទម្រង់ដ៏ចាស់ទុំមួយរបស់ប្រព័ន្ធដដែល, ដែលនៅក្នុងនេះ ខេត្រទាំងឡាយស្របទៅនឹងក្រុមផ្កាយ « វិមានចន្ទ »ម្ភៃប្រាំបី (the twenty eight "Houses of Moon"), ហើយរដ្ឋមន្ត្រី (សេនាបតី) ទាំងបួន ស្របទៅនឹងទេពតាឆ្នាំទិសធំទាំងបួន ។ វាជាការច្បាស់ណាស់ថា នៅក្នុងករណីទាំងអស់នេះអាណាចក្រត្រូវបានប្រឌិតឡើង ទុកដូចជារូបភាពទេវលោករបស់តារានិករ និងពពួកទេពតា ។

នៅទូទាំងព្រះរាជាណាចក្រទាំងឡាយឯនាយប្រទេសឥណ្ឌា, ប្រព័ន្ធដែលផ្អែកលើទស្សនៈផ្ចិតរាបមូល ( មណ្ឌល ) ត្រូវបានបំពេញបន្ថែម និងកែសម្រួលយ៉ាងទូលំទូលាយ ដោយការបែងចែកទៅជាក្រសួងដៃស្ដាំ និងក្រសួងដៃឆ្វេង, ខាងស្ដាំនិងខាងឆ្វេង ; ក្នុងករណីនេះ គេយោងទៅរកអាសនៈក្បែរស្ដេច តម្រូវទៅតាមសារសំខាន់នៃអ្នកកាន់កាប់ក្រសួងរៀងៗខ្លួន ក្នុងឱកាសពិធីនានា ។ ចំណែកស្ដេចវិញ, កាលណាគង់លើបល្លង្ក, ព្រះអង្គតែងបែរព្រះភ័ក្ត្រទៅទិសខាងកើតជានិច្ច, ខាងស្ដាំស្របនឹងទិសខាងត្បូង ហើយខាងឆ្វេងស្របនឹងទិសខាងជើង ។ ជាឧទាហរណ៍ នៅក្នុងប្រទេសថៃ, មានមហេសីឯក គង់ខាងស្ដាំ, មហេសីបន្ទាប់បន្សំគង់ខាងឆ្វេង, នាយទាហានកងទ័ព អង្គុយខាងស្ដាំ នៃស្ដេច ពោលគឺ " ក្នុងទិសខាងត្បូង ", ពិព្រោះ ផ្កាយព្រះគ្រោះ អង្គារ, ដែលទាក់ទងនឹងសង្គ្រាម, ត្រូវបានគេ

ចាត់ទុកជាផ្កាយព្រះគ្រោះទិសខាងត្បូង ។ តាមពិត, ប្រជានុរាស្ត្រប្រទេសសៀម ត្រូវបានបែងចែកជាពីរវណ្ណៈ គឺខាងស្តាំ (ខាងត្បូង) និងខាងឆ្វេង (ខាងជើង) ។ វណ្ណៈស្តាំ ត្រូវចូលបំរើកងទ័ព ហើយឆ្វេង បំរើការងារជាស៊ីវិល ។

## ឥទ្ធិពលលើពិធីអភិសេក

តួនាទីលោកធាតុ និងទេវលោករបស់ស្តេច តាំងតែពីព្រេងនាយរហូតដល់សព្វថ្ងៃ ត្រូវបានគេអោយតម្លៃយ៉ាងពិសេស នៅក្នុងពិធីអភិសេក ។ ក្នុងប្រទេសភូមា, សំណង់សាងឡើងសម្រាប់គោលបំណងនេះ ត្រូវបានគេអោយឈ្មោះប្រកបដោយអត្ថន័យថា " វិមានរបស់ព្រះឥន្ទ " ( Thagya-(១) nan ) ។ សូម្បីតែនៅក្នុងរាជាណាចក្រកាន់ពុទ្ធសាសនាទាំងឡាយឯនាយប្រទេសឥណ្ឌា ការធ្វើពិធីត្រូវបានពួកព្រាហ្មណ៍ជាអ្នកដឹកនាំធ្វើ ។ ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពធំៗ គឺស្តេចគង់លើបល្ល័ង្កដែលតាងភ្នំមេរុ ហើយព្រះអង្គព័ទ្ធជុំវិញដោយព្រាហ្មណ៍ប្រាំបីនាក់ជាតំណាងលោកបាលទាំងប្រាំបី, ដ៏ជាទេពតាឆ្មាំរក្សាទិសទាំងប្រាំបី នៅក្នុងទ្រឹស្តីលោកធាតុរបស់សាសនាព្រហ្មញ្ញ ។ បន្ថែមលើនេះទៀត, នារីក្រមុំកិត្តិយសបួននាក់ តាងទិសធំទាំងបួន ថ្វាយគារវកិច្ចចំពោះព្រះមហាក្សត្រ ។

ឯកសារផ្លូវការបោះពុម្ពផ្សាយ ក្នុងឱកាសអភិសេកព្រះបាទស៊ីសុវត្ថិ នៃប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩០៦ បានផ្តល់សេចក្តីពន្យល់ផ្សេងគ្នាបន្តិចបន្តួច អំពីតួនាទីលោកធាតុរបស់ព្រះរាជា ។ យោងតាមឯកសារនេះ ព្រះរាជាភ្ជាប់ព្រះកាយពលព្រះអង្គឯងជាមួយភ្នំមេរុ ព្រះនេត្រស្តាំរបស់ព្រះអង្គ តាងព្រះអាទិត្យ, ព្រះនេត្រឆ្វេង

---

(១) Thagya គឺជា ទម្រង់ស័ព្ទសំស្ក្រឹតភូមា ក្លាយមកពីពាក្យ sakra ( បាលី : សក្កៈ ) មានន័យសំគាល់ថា ព្រះឥន្ទ ។

របស់ព្រះអង្គ តាងព្រះច័ន្ទ, ព្រះហស្ត និងព្រះបាទា តាងទិសធំទាំងបួន ឆត្រត្រួតប្រាំមួយជាន់ខាងលើព្រះកេសព្រះអង្គ តាងស្ថានសួគ៌ជាន់ទាបប្រាំមួយជាន់, កំពូលស្រួចនៃមកុដ តាងកំពូលប្រាសាទព្រះឥន្ទ ដែលឋិតនៅកំពូលភ្នំមេរុ ហើយសុពណ៌បាទរបស់ព្រះអង្គ តាងព្រះធរណី ។ នេះមានន័យថា ព្រះរាជាត្រូវបានកំណត់ទុកព្រះកាយព្រះអង្គឯង ( ការធ្វើអត្តសញ្ញាណកម្ម ) ជាស្នូលនៃសកលចក្រវាល ។ គំនិតដដែលនេះ ហាក់ដូចជាត្រូវបានគេបង្ហាញតាមរយៈគោរមងារ " Paku Buwono " " ដែកគោលនៃពិភពលោក " នៃជនជាតិ *ស៊ីស៊ីហ៊ុណាន* នៃកោះស្វាឡ្វ ក្នុងប្រទេសជ្វា ។ ប៉ុន្តែថា ការធ្វើអត្តសញ្ញាណកម្មព្រះរាជាជាមួយភ្នំមេរុ មិនមានវិសមិតភាព ( incompatible ) ជាមួយនឹងការធ្វើអត្តសញ្ញាណកម្មជាមួយព្រះឥន្ទនោះទេ ពហុនិមិត្តរូបនិយមមានជាញឹកញយណាស់ នៅក្នុងប្រទេសកាន់ពុទ្ធសាសនាឯនាយប្រទេសឥណ្ឌា ។ តួយ៉ាងនៅក្នុងប្រទេសភូមា, ព្រះរាជាមានគេតនភណ្ឌទាំងអស់របស់ព្រះឥន្ទ, ព្រះរាជាត្រូវបានគេធ្វើអត្តសញ្ញាណកម្ម ជាមួយវិស្វកម្មទេវបុត្រ ដែលជាទេពតាស្ថាបត្យករ និងជាអ្នកកសាងពិភពលោក ។ លើសនេះទៀត, មានភស្តុតាងយ៉ាងច្បាស់ប្រាប់ពីព្រះរាជា ត្រូវបានគេធ្វើអត្តសញ្ញាណកម្មជាមួយព្រះអាទិត្យ ។

## រដ្ឋលោកធាតុ និង ទេវរាជ

រដ្ឋលោកធាតុ ដូចដែលបានកើតមាននៅក្នុងទ្វីបអាស៊ីអាគ្នេយ៍, ត្រូវបានគេភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងមតិ ស្តីពីទេវរាជសម្បត្តិ ។ ទេវភាពរបស់ព្រះរាជាត្រូវបានគេប្រឌិតឡើងតាមមធ្យោបាយជាច្រើន យោងតាមសាសនាដែលប្រជាជនរាប់អានជាងគេ ។ កន្លែងណាមានសាសនាហិណ្ឌូ គ្របដណ្តប់លើសាសនាឯទៀត, ព្រះរាជាក៏ត្រូវបានគេសន្មតថា ព្រះអង្គជាអវតាររបស់ទេពតា (អាទិទេព), ឬជាទេព-

ច្យុតិ, ឬមួយជាទេវាវតារផង ជាទេពច្យុតិផង ។ ជាទូទៅ គឺព្រះសិវៈដែលត្រូវបាន គេជឿថា បានបែងភាគ (អវតារ) មកយកកំណើតជាស្តេច ឬបានចុះមកបន្តសន្តតិ-វង្ស ។ ដូចជា នៅក្នុងសិលាចារឹកចាម នៃសតវត្សទី ៩ ព្រះបាទ *ឩរោជ*, ជាស្ថាបនិក នៃរាជវង្ស, ត្រូវបានគេនិយាយថា គឺជារាជបុត្ររបស់សិវៈ ។ កំណាព្យរបស់ជ្វា ឈ្មោះ *នាគរក្ឫតាគម* (សតវត្សទី ១៤) គ្រាន់តែបាននិយាយរៀបរាប់អំពីព្រះបាទ *រាជសនគរៈ* នៃអាណាចក្រ *មជបហិត* ( ១៣៥០ - ១៣៨៩ នៃ គ.ស. ), ដូចគេ បានបញ្ជាក់តាមទំនាយផ្សេងៗ ដែលបានកើតមាននៅពេលព្រះអង្គប្រសូត, ក្នុង បណ្តាព្រឹត្តិការណ៍ឯទៀតៗ មានព្រឹត្តិការណ៍ផ្ទុះភ្នំភ្លើងជាអាទិ៍, ថាព្រះអង្គ គឺជា អវតារ នៃ *ភតារៈ គិរិនាថ*, ពោលគឺ ព្រះសិវៈ ដ៏ជា" ម្ចាស់ភ្នំ" ។ នៅក្នុងកាលប្បវត្តិ *បារាភាតុន* របស់ជ្វា ព្រះបាទ*ក្ឫតជយ* នៃអាណាចក្រ *កាទិរី* (សតវត្សទី ១៣) នៅឱកាសមួយនោះ បានបង្ហាញព្រះអង្គឯងក្នុងរូបកាយជាអធិមនុស្សរបស់ព្រះសិវៈ មានព្រះហស្តបួន និងមានព្រះនេត្រទីបី នៅចំកណ្តាលថ្ងាស ហើយអណ្តែតឡើង ក្នុងអាកាស ។ នៅក្នុងប្រទេសខ្មែរ និងប្រទេសចាម្ប៉ាបុរាណ ព្រះមហាក្សត្រ ត្រូវ បានភ្ជាប់ព្រះកាយព្រះអង្គយ៉ាងជិតស្និទ្ធជាមួយនឹងការបូជាលិង្គ ដែលគេចាត់ទុកជា អាសនៈ ឬជាទីតាំងសារជាតិទិព្វ (the seat of the devine essence) នៃ រាជសម្បត្តិ ។ ដូចយើងបានឃើញស្រាប់, នៅក្នុងប្រទេសខ្មែរ លិង្គនេះគឺជាតំណាង ទេវរាជ (the God King), ដែលត្រូវបានគេគោរពបូជា នៅក្នុងប្រាសាទកណ្តាល ទីក្រុង ។ ស្តេចបច្ចុប្បន្ន ត្រូវបានគេទុកជាបាតុភាពនៃទេវានុភាពរបស់ទេវរាជ, ហើយដោយហេតុតែទេវរាជមានរូបកាយមើលឃើញនោះ លិង្គសំដៅដល់ព្រះសិវៈ ដោយផ្ទាល់តែម្តង ។

ប៉ុន្តែថា, ព្រះសិវៈ ពុំមែនជាអាទិទេពតែមួយអង្គប៉ុណ្ណោះទេ ដែលបាន អវតារ ឬបែងភាគព្រះអង្គឯងមកកើតជាស្តេច ។ ស្តេច*អៃរលង្គៈ* ( King

Airlangaga ) នៃប្រទេសជ្វា (សតវត្សទី ១១) បានសន្មតព្រះអង្គឯងជាអវតារព្រះវិស្ណុ ។ វិមានអនុស្សាវរីយ៍របស់ព្រះអង្គ បង្ហាញព្រះអង្គក្នុងរូបរាងជាព្រះវិស្ណុទ្រង់គង់លើសត្វគ្រុឌ ។ ឧទាហរណ៍ដ៏គួរកត់សំគាល់មួយទៀត នៃអវតាររបស់ព្រះវិស្ណុ គឺ ស្តេចសូរ្យវរ្ម័នទី២ នៃប្រទេសខ្មែរ (សតវត្សទី ១២) ដែលទ្រង់បានកសាងវិមានអនុស្សាវរីយ៍របស់ព្រះអង្គដោយផ្ទាល់ ទុកជាប្រាសាទព្រះវិស្ណុ ដ៏ធំសម្បើមមួយ ៖ ប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ។ យើងរកឃើញវែងឆ្ងាយទៀត នូវគំនិតពហុអវតារ, ដែលគេបានដឹងផងដែរពីប្រទេសឥណ្ឌា ។ ដូចជាកាលប្បវត្តិ បាបារាតុនបានប្រាប់យើងថា *អង្គ្រោក* (សតវត្សទី១៣), ជាស្ថាបនិកនៃសន្តតិវង្ស *សិង្គសរី* និងជាបុព្វបុរសនៃព្រះរាជាទាំងឡាយ នៃអាណាចក្រ *មជបហិត* គឺជាអវតារមួយអង្គរបស់ព្រះវិស្ណុ ដែលព្រះព្រហ្មបានបង្កើតឡើងអំពីស្ត្រីលោកីយម្នាក់, ហើយនៅពេលជាមួយគ្នា បុត្ររបស់ព្រះសិវៈ គឺ *ស្តេចក្ឫតរាជសៈ* ( សោយទីវង្គត ឆ្នាំ ១៣១៦ នៃ គ.ស. ), ជាស្ថាបនិកនៃអាណាចក្រ *មជបហិត* ត្រូវបានគេកសាងរូបបដិមាមួយតាងព្រះអង្គជា *ហារិហារៈ,* គឺជាការផ្សំព្រះវិស្ណុ និងព្រះសិវៈ ។ សូម្បីតែអវតារដំណាលគ្នារបស់ពពួកទេពតាហិណ្ឌូ និងពុទ្ធសាសនាមហាយាន ក៏កើតមានដែរ ។ តួយ៉ាង . សុំលើកយកឧទាហរណ៍តែមួយ . ស្តេចជ្វា ព្រះនាម *ក្ឫតនាគរៈ* ( ត្រូវគេធ្វើគត់ ឆ្នាំ១២៩២ នៃ គ.ស ) ក៏ត្រូវបានគេចាត់ទុកជាអវតារមួយរបស់ព្រះសិវៈក៏ដូចជាអវតាររបស់*ធ្យានិពុទ្ធ អក្សោភ្យៈ* ។ យោងតាមន័យនេះ ព្រះអង្គបានត្រូវគេស្គាល់នៅក្នុងប្រពៃណីជ្វា ក្រោមព្រះនាម *សិវៈពុទ្ធ* ។

គេអាចបន្ថែមថា ទ្រឹស្តីទេវាវតារ ត្រូវបានគេប្រើ មិនមែនទុកជាមធ្យោបាយ ដើម្បីលើកតម្កើងឋានៈរបស់ស្តេចស្របច្បាប់ប៉ុណ្ណោះទេ, ប៉ុន្តែ ទុកជាមធ្យោបាយកែតម្រូវដល់ការដណ្តើមយករាជបល្ល័ង្កដូចគ្នាផងដែរ ។ តួយ៉ាងស្តេច *អង្គ្រោក* ដែលបាននិយាយពីខាងដើម, ជាស្ថាបនិកនៃរាជាណាចក្រសិង្គសរី, គឺជា

អ្នកដណ្តើមរាជ្យ ប្រកបមុខរបរឧក្រិដ្ឋជាយូរឆ្នាំ ធ្វើជាអ្នកឆបោក, ជាចោរលួចប្លន់, និងជាអ្នកសម្លាប់មនុស្ស ។ ប៉ុន្តែថា ទោះបីអតីតកាលដ៏ឧក្រិដ្ឋរបស់មនុស្សនោះយ៉ាងណាក៏ដោយ, ក៏គេនៅតែក្លាយទៅជាស្តេច, បើយោងតាមកាលប្បវត្តិបាបារាតុន, ពិព្រោះគេជាអវតាររបស់ទេពតា ( ឬទេពតាចុះមកចាប់កំណើត ) ។

ទ្រឹស្តីទេវាវតារ ដូចដែលបានឃើញមាននៅក្នុងលទ្ធិហិណ្ឌូ និងពុទ្ធសាសនាមហាយាន មានវិសមិតភាព (ភាពមិនត្រូវគ្នា) ជាមួយនឹងលទ្ធិនៃពុទ្ធសាសនាហីនយាន ( ឬថេរវាទ ) ។ ភាពផ្សេងពីគ្នានៅក្នុងគោលការណ៍សំខាន់ៗនៃលទ្ធិនេះ ត្រូវបានសំដែងចេញអោយឃើញច្បាស់ សូម្បីនៅក្នុងការរៀបចំធានីរបស់ប្រទេសក៏ផ្សេងគ្នាដែរ ។ នៅក្នុងប្រទេសខ្មែរសម័យបុរាណ, មានប្រាសាទមួយបង្កើតបានជាមណ្ឌលកណ្តាល (ឬជាស្នូល) នៃធានី ហើយដោយប្រការនេះ ដើរតួជាភ្នំមេរុ នៃទីក្រុង និងអាណាចក្រ ។ នៅក្នុងប្រទេសភូមា ចំណុចកណ្តាលនៃធានី គឺជាទីតាំងនៅនៃព្រះរាជវាំង ដោយគ្មានការប្រែប្រួល, ហើយគឺរាជវាំងនេះហើយ ដែលត្រូវបានកំណត់ថាជាភ្នំមេរុ ។ នៅក្នុងប្រទេសខ្មែរសម័យបុរាណ ឬមួយព្រះសិវៈក្នុងរូបភាពព្រះអង្គជាទេវរាជ, ដ៏ជាសារជាតិអមតៈនៃរាជសម្បត្តិ, ឬមួយព្រះពោធិសត្វលោកេស្វរៈ, ដ៏ជា " ស្តេចចក្រវាល " គង់នៅលើ " ភ្នំកណ្តាល " ហើយចាប់ពីទីនេះ ផ្ទៃអាណាចក្របានលាតសន្ធឹងចេញទៅ ។ ពុទ្ធសាសនាហីនយាន (ថេរវាទ) មិនទទួលស្គាល់ទេវភាពអមតៈទេ ។ ព្រះឥន្ទ្រ គឺគ្រាន់តែជាស្តេចមួយអង្គនៃឋានសួគ៌ជាន់ទាបមួយប៉ុណ្ណោះ, ដែលជាជាន់ទីពីរ បន្ទាប់ពីផែនដី ។ ព្រះឥន្ទ្រ មានឱកាសតិចតួចណាស់ ដើម្បីរួចខ្លួនពីមរណភាព និងពីការកើតជាថ្មីទៀត ដូចមនុស្សលោកដែរនោះ, លើកលែងតែជន្មាយុរបស់ព្រះឥន្ទ្រឋិតថេរបានយូរចេញ ។ ដូចគ្នានេះដែរ គេបាននិយាយអំពីពួកទេពតា ដែលឋិតនៅឋានសួគ៌ថ្នាក់ខ្ពស់ ។ ពួក «អាទិទេព» ទាំងអស់នោះ នៅក្នុងពុទ្ធសាសនា ហីនយាន ត្រូវបាន

គេហៅ ត្រឹមតែទេពតា យ៉ាងសមស្របបំផុត ។ ពួកទេពតាទាំងនេះ គ្មានប្រាសាទ និងគ្មានការគោរពបូជា (Cults) ទេ ។ ដូច្នេះ វាជាការងាយយល់ណាស់ថា ហេតុអ្វីនៅក្នុងប្រទេសភូមា គ្មានប្រាសាទ (Temple) ណាមួយ ត្រូវបានស្ថាបនាឡើងនៅមណ្ឌលកណ្ដាលនៃធានី ។ ការប្រកាន់យកគោលការណ៍លោកធាតុវិទ្យា និងការធ្វើព្រះរាជាអោយទៅជាទេពតា ឬអាទិទេពនៅក្នុងទីនេះ ត្រូវបានគេប៉ុនប៉ងធ្វើដោយមធ្យោបាយទាំងឡាយផ្សេងវិញ ។ ដោយការសង់វាំងនៅចំកណ្ដាលទីក្រុង និងដោយការកំណត់សម្គាល់វាំងនោះថាជាភ្នំមេរុ, ម្ចាស់វាំង ពោលគឺព្រះរាជា បានក្លាយជាស្វ័យប្រវត្តិ ជាអ្នកតំណាងព្រះឥន្ទ ។ យើងអាចរហូតដល់និយាយបានថា ព្រះរាជាគឺជា " ព្រះឥន្ទ " នៃចក្រវាលដ៏តូចនេះ, គឺអាណាចក្រភូមា, ប៉ុន្តែព្រះរាជាគ្រប់គ្រងប្រាសាទរបស់ព្រះអង្គ តាមមន្តអាគមស្របនិយម (the magic of parallelism) ប៉ុណ្ណោះ ហើយព្រះអង្គមិនមែនជាអវតារនៃព្រះឥន្ទមែនទែន ដូចជាស្ដេចជ្វា និងស្ដេចខ្មែរបុរាណ ត្រូវបានអវតារមកពីសិវៈ និងវិស្ណុនោះឡើយ(១) ។ មានផែនការពន្យល់ពីពិសិដ្ឋភាពដ៏ខ្ពង់ខ្ពស់ ដែលនៅក្នុងពិសិដ្ឋភាពនេះ ព្រះរាជវាំង ត្រូវបានគេគោរពនៅក្នុងអាណាចក្រកាន់ពុទ្ធសាសនា ឯនាយប្រទេសឥណ្ឌា ។ វាំងគឺ ជានិមិត្តរូបនៃភ្នំកៃលាស (ភ្នំឋានសួគ៌), មិនមែនតែប៉ុណ្ណោះ, លើសជាងនិមិត្តរូបសុទ្ធសាធទៅទៀត ៖ គឺជា " ភ្នំមេរុ " របស់ប្រទេសភូមា , ឬប្រទេសសៀម, ឬប្រទេសខ្មែរ ដែលជាខុទ្ទកលោកធាតុ ។ បុគ្គលណាម្នាក់ចូលទៅជិតវាំង ត្រូវសំដែងការគោរពរបស់គេ ដោយការចុះពីលើខ្នងសេះ ដោយការដំឡោះឆត្រ ដោយការលំឱនក្បាលចំពោះកំពូលប្រាសាទវាំងឬរហូតដល់លុតជង្គង់គោរព ។ ការប៉ុនប៉ងដើម្បីអោយមាន

---

(១) ប៉ុន្តែ, នៅមានស្លាកស្នាមជំនឿយ៉ាងខ្លាំងដែលថាព្រះសិវៈ និងព្រះវិស្ណុ បានបែងភាគ (អវតារ) ខ្លួនព្រះអង្គមកកើតជាស្ដេច ឃើញនៅសល់ក្នុងការរៀបចំពិធីអភិសេក ក្នុងប្រទេសសៀម និងប្រទេសខ្មែរ ។

ការសំដែងសេចក្ដីគោរពអំពីបេសកជនអង់គ្លេស បាននាំអោយមានការចរចា និងការប៉ះទង្គិចមិនចេះចប់ មិនចេះហើយ ដោយសារតែបេសកជនអង់គ្លេស មិនព្រមប្រតិបត្តិតាមសំណូមពរ ដែលគេយល់ថាជាការបន្ទុះបង្អាប់មើលងាយ ។ «ស្ដេចវាំងមាស» គឺជាគោរម្យងារមួយ ក្នុងចំណោមគោរម្យងារដ៏សំខាន់បំផុត នៃក្សត្រភូមា ។ ប៉ុន្តែ, ហេតុពិតដែលថា ព្រះរាជាគឺជាព្រះឥន្ទ ហើយដោយ ហេតុនេះជាអ្នកគ្រប់គ្រងប្រទេស ទុកដូចជាម្ចាស់នៃអាណាចក្រភ្នំមេរុ ពោលគឺ វាំងតែប៉ុណ្ណោះ, ហេតុការណ៍នេះប្រកបដោយគ្រោះថ្នាក់ពេកណាស់ ។ វាតែងបង្កអោយមាននូវការប៉ុនប៉ងជាប្រចាំ សម្រាប់ពួកអ្នកចង់ដណ្ដើមអំណាច, ទោះចេញមកពីស្រទាប់ព្រះញាតិវង្សក្ដី ឬពីអ្នកខាងក្រៅក្ដី, ក៏ដូចជាការចង់កាន់កាប់ព្រះរាជវាំងដែលអាចសំរេចឡើងដោយការវាយប្រហារ ឆ្មក់ តាមការប្រើកងកំឡាំងតូចតាចហើយតាមធម្មតា សំដៅដណ្ដើមយកអាណាចក្រទាំងមូល ។ ដោយហេតុនេះ, ស្ដេចភូមា និងស្ដេចសៀម ជាច្រើនអង្គ បាក់ដូចជាអ្នកទោស នៅជាប់ឃុំក្នុងវាំងរបស់ខ្លួន ដែលក្សត្រទាំងនោះមិនហ៊ានយាងចេញទៅឆ្ងាយ ដោយខ្លាចអ្នកដណ្ដើមរាជ្យចូលមកកាន់កាប់យករាជវាំង ។ ស្ដេចភូមាចុងក្រោយគេ ព្រះនាម *ធីបាវ* (Thibaw), សព្វព្រះទ័យរហូតដល់អោយគេរៀបចំពិធីអភិសេកដ៏អឹកធឹក ហែប្រទក្សិណជុំវិញរាជធានី ប្រគល់ទៅអោយព្រះញាតិណាមួយ នូវឱកាសដើម្បីធ្វើអោយព្រះញាតិនោះក្លាយទៅជាម្ចាស់នៃវាំង ក្នុងពេលដែលព្រះអង្គ (ធីបាវ) ទ្រង់យាងទៅឆ្ងាយ ។

ក្នុងលទ្ធិពុទ្ធសាសនាហីនយាន, គំនិតស្ដីពីទេវាវតារ ទុកជាការកែតម្រូវសម្រាប់គ្រងរាជសម្បត្តិ ត្រូវបានជំនួសដោយគំនិត ស្ដីពីការកើតទៀត និងស្ដីពីកុសលកម្មខាងសាសនា ។ គឺអំពើល្អរបស់គេ, បុញ្ញកម្មខាងសាសនា ដែលបានសន្សំក្នុងជាតិមុន បានធ្វើអោយមនុស្សម្នាក់កើតទៅជាស្ដេច ឬធ្វើអោយគេបានទទួលរាជ-

សម្បត្តិ នៅក្នុងជីវភាពរបស់គេ, ទោះបីបានដោយការបះបោរ និងការធ្វើឃាតក៏ដោយ ។ ឧទាហរណ៍ជាគំរូមួយគឺ ឧទាហរណ៍ ស្តេច *ញៀង-អ៊ូ សាវ៉ាហាន* (Nyaung-u Sawrahan) (សតវត្សទី ១០), តាមការរៀបរាប់នៅក្នុងកាលប្បវត្តិវាំងកែវរបស់ស្តេចភូមា (the Glass Palace Chronicle of the Kings of Burma) ញៀង-អ៊ូ សាវ៉ាហាន, ជាកសិករម្នាក់, បានធ្វើគត់ស្តេចដែលបានលួចចូលមកក្នុងច្បារដំណាំរបស់គាត់ ហើយដែលគាត់មិនបានស្គាល់ ។ ភ្លាមនោះ គាត់ត្រូវបានគេលើកឡើងធ្វើជាស្តេចដោយមិនដឹងខ្លួនផង ។ បុញ្ញកម្មរបស់គាត់មានអានុភាពខ្លាំងពេកណាស់, នៅពេលដែលរដ្ឋមន្ត្រីមួយរូប ក្នុងបណ្តារដ្ឋមន្ត្រីទាំងឡាយ បានប្រឆាំងនឹងការលើកគាត់តាំងជាស្តេច, រូបបដិមាថ្មនៃទេពតាឆ្មាំទ្វារវាំង បានក្លាយទៅជាមានជីវិត ហើយសម្លាប់រដ្ឋមន្ត្រីនោះចោល ។ សេចក្តីអធិប្បាយរបស់កាលប្បវត្តិ មានអត្ថន័យថា : " ទោះបីតាមការណ៍ពិត សាវ៉ាហានគួរតែត្រូវទទួលសេចក្តីវិនាសយ៉ាងទាន់ហន់ ដោយសារការធ្វើគត់ព្រះរាជា ក្នុងពេលលោកនៅជាកសិករនៅឡើយ, (ប៉ុន្តែ ផ្ទុយទៅវិញ) សាវ៉ាហាន បានសំរេចរហូតដល់ទទួលរាជសម្បត្តិយ៉ាងងាយ ដោយសារកំឡាំងនៃកុសលកម្ម ដែលបានកសាងក្នុងអតីតកាល ។ " ប៉ុន្តែ នៅខណៈដែលកម្មជាអំពើល្អរបស់លោក ក្នុងអតីតកាលត្រូវរីងហួតអស់, រូបបដិមាថ្មដដែលនោះ ដែលពីមុនបានសម្លាប់សត្រូវរបស់លោកក្លាយជាមានជីវិតជាថ្មីទៀត ហើយចាប់គ្រវែងលោកអោយចេញផុតអំពីទីលានប្រាសាទ ។

គ្មានបុណ្យឯណាប្រសើរលើសបុណ្យ បានមកពីការបំរើព្រះពុទ្ធអង្គផ្ទាល់ទេ ។ តួយ៉ាងកាលប្បវត្តិវាំងកែវ ប្រាប់អោយយើងដឹងថា មានយក្សឆ្មាំភ្នំមួយ ដែលបានបាំងព្រះពុទ្ធមិនអោយត្រូវកំដៅថ្ងៃ ដោយស្លឹកឈើបីសន្លឹក, បានទទួលអំពីព្រះពុទ្ធ នូវពុទ្ធទំនាយថា គេនឹងបានធ្វើស្តេចប្រទេសភូមាបីដង ។ នៅក្នុងសតវត្សទី ១០

គេបានកើតជាថ្មី នៅក្នុងតំបន់ទំនាប មានឈ្មោះ *សាឡេះ ងះក្វេ* ( Saleh Ngahkwe ), ដែលក្រោយមកក្លាយជាស្តេច ដោយការធ្វើគត់ស្តេច ដែលសោយរាជ្យមុន ។ " ដោយសារកើតចេញពីត្រកូលយក្ស, សាឡេះ ងះក្វេ គឺជាមនុស្សឆាប់ក្រោធខឹង និងមានមានះក្រអឺតក្រអោងហួសហេតុ " រួមទាំងការល្មោភស៊ី និងឃាតកម្មស្រែកឈាមព្រៃផ្សៃផង, រហូតដល់ទីបញ្ចប់ ត្រូវបានសេនាបតី ( រដ្ឋ-មន្ត្រី ) របស់ខ្លួនផ្ទាល់សម្លាប់បង់ ។ គេគប្បីយល់ថា កុសលកម្មកើតមកពីការបាំងថ្ងៃ ផ្តល់ម្លប់ដល់ព្រះពុទ្ធត្រូវបានរឹងហួតអស់ ដោយសារតែជីវិតពោរពេញដោយឧក្រិដ្ឋកម្ម ។ ប៉ុន្តែថា, យោងតាមកាលប្បវត្តិភូមា, ដំណើររឿងនេះ មិនដូច្នោះទេ ។ បីសាចភ្នំពីមុន ត្រូវបានកើតឡើងវិញ ក្នុងសតវត្សទី ១២ ជាព្រះអង្គម្ចាស់ *នរថុ* ( Narathu ) ដែលបានក្លាយជាស្តេចដោយការធ្វើគត់ព្រះបិតា និងព្រះជេដ្ឋារបស់ព្រះអង្គ ហើយនៅក្នុងរាជ្យរបស់ព្រះអង្គ, ក្សត្រអង្គនេះពូកែខាងប្រព្រឹត្តអំពើបង្ហូរឈាម ។ លុះដល់មកក្នុងសតវត្សទី ១៣ បីសាចភ្នំនោះ បានមកកើតឡើងវិញជាព្រះអង្គម្ចាស់ *នរថិហបតេ* ( Narathihapate ) ។ ដំណើររឿងនេះ នាំយើងមកដល់ទស្សនៈមួយ ស្តីពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដ៏ជាគំរូបំផុត ដែលផ្អែកលើសារសំខាន់ដ៏ធំសម្បើមតាមទំនាយ និងនិមិត្តសញ្ញា ។ តាមពិត, គេអាចនិយាយបានថា, ជាពិសេស ទាក់ទងនឹងពុទ្ធទំនាយ, នៅក្នុងទស្សនៈយល់ឃើញរបស់អ្នកប្រវត្តិ-សាស្ត្រភូមា, ព្រឹត្តិការណ៍ទាំងឡាយមិនកើតមកពីការទស្សន៍ទាយទេ ពិព្រោះ ព្រឹត្តិ-ការណ៍ទាំងនោះនឹងកើតមាន, ប៉ុន្តែវាកើតមាន ពិព្រោះវាត្រូវបានគេទស្សន៍ទាយ ។ « ការរកឃើញ » របស់ទំនាយបុរាណ និង « ការសង្កេត » របស់និមិត្តសញ្ញាសហសម័យ គឺជាមធ្យោបាយសម្រេចគោលបំណងមួយដែលគេប្រើជាទូទៅក្នុងវិជ្ជានយោបាយភូមា ហើយនៅតែបង្កបានជាកត្តាដ៏មានឥទ្ធិពលមួយ នៅក្នុងអ្វីដែលយើងអាចហៅថា ប្រពៃណី និងវប្បធម៌នយោបាយក្នុងស្រុក (political folk-

lore) ។

គំនិតទាំងមូល និងទម្រង់ខាងក្រៅនៃរាជសម្បត្តិ (Kingship) ក្នុងទ្វីបអាស៊ីអាគ្នេយ៍, ហើយជាពិសេស ក្នុងព្រះរាជាណាចក្រទាំងឡាយកាន់ពុទ្ធសាសនាឯនាយប្រទេសឥណ្ឌា, តាមពិតទៅ គឺឋិតលើទស្សនៈនៃស្តេចចក្រពត្តិ (the Universal Monarch) ។ ឥឡូវនេះ គេយល់ថា ស្តេចចក្រពត្តិមួយអង្គ គឺជាព្រះពោធិសត្វត្រៀមមួយអង្គ នៅក្នុងលោកនេះ ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអនាគត ។ ឋិតក្រោមកាលៈទេសៈបែបនេះ, ទ្រឹស្តីនៃការកើតទៀត និងទ្រឹស្តី កម្មៈ ត្រូវបានគេភ្ជាប់ជាមួយគ្នា ដើម្បីផ្តល់ឥទ្ធិពលទៅដល់ព្រះរាជាទាំងឡាយ តាមរយៈគំនិតឧត្តុង្គឧត្តមមួយ ស្តីពីកុសលកម្មក្នុងសាសនារបស់ព្រះរាជា ដើម្បីចាត់ទុកព្រះរាជាជាពោធិសត្វ ។ តួយ៉ាង, *អ៊ុង ហ្សាយ៉ា* (Oung Zaya), ជាស្ថាបនិក នៃរាជវង្សចុងក្រោយរបស់ប្រទេសភូមា ឡើងគ្រងរាជ្យជាស្តេច យកព្រះនាមថា *អាឡុងប៉ាយ៉ា* (Aloungpaya) ដែលសំគាល់ព្រះអង្គថាជាព្រះពុទ្ធង្កូរ (an Embryo Buddha ) ។ បុត្ររបស់ព្រះអង្គ គឺស្តេច *ពោទាយប៉ាយ៉ា* (Bodawpaya) (១៧៨២-១៨១៩) ប្រកាសជាចំហថាព្រះអង្គជាព្រះពោធិសត្វម៉ៃត្រេយៈ ។ ប៉ុន្តែ សេចក្តីប្រកាសរបស់ព្រះអង្គ ត្រូវបានព្រះសង្ឃបដិសេធ ហើយព្រះអង្គ ក៏បានបោះបង់ចោលឈ្មោះនោះទៅ ។ សេចក្តីប្រកាសដូចគ្នានេះ ក៏ត្រូវបានធ្វើឡើងដោយស្តេច *តាក់ស៊ីន* (King Taksin) នៃប្រទេសសៀមដែរ (១៧៦៧-១៧៨២) ។

ទ្រឹស្តី និយាយពីឧបនិស្ស័យជាស្តេចឡើងគ្រងរាជ្យ (The theory of vocation to Kingship) ដែលផ្អែកលើមូលដ្ឋាន ទេវរាជ ដូចជានៅប្រទេសជ្វា និងប្រទេសខ្មែរបុរាណ, ឬផ្អែកលើមូលដ្ឋានកម្មៈ ដែលបានកសាងក្នុងជាតិមុន ដូចជានៅក្នុងប្រទេសភូមា, ប្រទេសសៀម និងប្រទេសខ្មែរសម័យថ្មី ក៏មិនបានបោះបង់ចោលខ្លឹមសារនៃទ្រឹស្តីបន្តមតិក នៃសិទ្ធិឡើងសោយរាជ្យដែរ ។ ជាញឹក

ញយ ពួកអ្នកដណ្តើមរាជ្យបានខិតខំធ្វើអោយមានភាពស្របច្បាប់ ដោយបកស្រាយពង្សាវលិ (ខ្សែស្រឡាយត្រកូល) ភ្ជាប់ពួកគេទៅនឹងសន្តតិវង្ស ( the dynasty ) ដែលពួកគេបានទម្លាក់ ឬទៅនឹងសន្តតិវង្សដែលបានគ្រប់គ្រងប្រទេស កាលពីសម័យដើម ។ ម្តងម្កាលផងដែរ, ពង្សាវលីដ៏ចម្លែក ត្រូវបានគេរៀបចំឡើង ដោយចាត់ទុកសន្តតិវង្សក្នុងស្រុក នៅអាស៊ីអាគ្នេយ៍ ថាចុះមកពីសន្តតិវង្សល្បីឈ្មោះណាមួយរបស់ប្រទេសឥណ្ឌាបុរាណ ។ ករណីដែលស្គាល់ជាងគេបំផុត គឺករណីស្តេចថ្មីៗនៃប្រទេសខ្មែរ ដែលប្រកាសខ្លួនថាជាប់ខ្សែវង្សត្រកូលពីព្រះរាជាបុរាណ នៃប្រទេសឥន្ទប្រស្ថ (Delhi) ។ សន្តតិវង្សភូមាចុងក្រោយដែលស្ថាបនាឡើងដោយមេភូមិម្នាក់ ក្នុងសតវត្សទី ១៨, បានប្រកាសថាជាអ្នកបន្តវង្ស ចុះមកពីព្រះរាជ-សក្យវង្សនៃក្រុងកបិលវត្ថុ, ជាសេចក្តីប្រកាសទាមទារដែលបានធ្វើអោយខ្លួនគេមានខ្សែលោហិតជាប់ជាមួយព្រះពុទ្ធផ្ទាល់ ។ ប្រភេទមួយនៃពង្សាវលី ប្រឌិតបែបនេះ, គេត្រូវតែយកចិត្តទុកដាក់ជាពិសេស ពិព្រោះ វាមានអត្ថន័យជ្រាលជ្រៅ លើសជាងការប្រើសម្រាប់លើកកិត្តិយសរបស់សន្តតិវង្សដោយសុទ្ធសាធ ។ ព្រះរាជានៃនគរហ្វូណាន ( សតវត្សទី ៣ ដល់សតវត្សទី ៧ នៃ គ.ស ) និងព្រះរាជានៃប្រទេសខ្មែរបុរាណ ត្រូវបានគេនិយាយថាជាតំណពូជចុះមកពីព្រាហ្មណ៍ម្នាក់ ដែលបានមកពីប្រទេសឥណ្ឌា និងចុះមកពីធីតាមួយអង្គរបស់ស្តេចភុជង្គនាគ ជាម្ចាស់ប្រទេស ។ រឿងព្រេងនៅតែត្រូវបានគេនិយាយនៅឡើយ ក្នុងប្រទេសខ្មែរ, ព្រាហ្មណ៍ត្រូវបានគេដាក់ជំនួសដោយព្រះអង្គម្ចាស់មួយអង្គ មកពីអាស៊ីអាគ្នេយ៍ នៅក្នុងរឿងសម័យថ្មី ។ អត្ថន័យមានច្បាស់លាស់ ។ នាគ ឬភុជង្គនាគ គឺជាម្ចាស់ដើមនៃផែនដី ។ ដោយមានតំណពូជចុះមកពីធីតានៃស្តេចនាគ, ព្រះរាជាបានទាមទារភាពស្របច្បាប់ចំពោះផែនដីនៃព្រះរាជាណាចក្ររបស់ព្រះអង្គ យ៉ាងហោចណាស់ ក៏នៅក្នុងទ្រឹស្តីដែរ, ដែលតាមរយៈទ្រឹស្តីនេះ ផែនដីនៃព្រះរាជាណាចក្រ បានក្លាយជាកម្មសិទ្ធិផ្ទាល់

របស់ព្រះអង្គ ។ សេចក្ដីរាយការណ៍មួយរបស់ចិន បានប្រាប់យើងអោយដឹងថា នៅក្នុងសតវត្សទី ១៣ ប្រជាជនខ្មែរបានជឿថាស្ដេច នៅពេលយប់បានទៅរួមរក្សជាមួយនាងនាគី នៃម្ចាស់ផែនដី ដែលតែងតែមករកព្រះអង្គដល់ក្នុងប្រាសាទ ក្នុងរូបរាងជាមនុស្ស ។ តាមការជាក់ស្ដែង គេគិតថា ព្រះរាជាតែងរឹតបន្ដឹងសម្ពន្ធភាពរវាងព្រះអង្គផ្ទាល់ និងផែនដីនៃព្រះរាជាណាចក្រ តាមរយៈនេះ ។ ដូច្នេះ ព្រះរាជានៅក្នុងប្រទេសខ្មែរបុរាណ, ក្នុងឋានៈជាអវតារនៃទេវរាជផង និងក្នុងឋានៈជាអ្នកតំណត្រកូលផង, ហើយជាមួយគ្នានេះ ជាព្រះស្វាមីរបស់ទេពធីតានៃម្ចាស់ផែនដី ថែមទៀតផង, ព្រះអង្គបង្កើតបាននូវមណ្ឌលមន្ដអាគមដ៏ពិតប្រាកដមួយ ភ្ជាប់អាណាចក្រទៅនឹងអានុភាពទេវះក្នុងឋានសួគ៌ ក៏ដូចជាទៅនឹងអានុភាពទេវៈ នៅលើផែនដីដែរ ។

កំណាត់ហេតុណាមួយ ស្ដីពីមតិបញ្ញត្តិ អំពីរដ្ឋ និងរាជសម្បត្តិ នៅទ្វីបអាស៊ីអាគ្នេយ៍ អាចនឹងមិនគ្រប់គ្រាន់បានទេ ប្រសិនបើគេមិនបាននិយាយអំពីសារសំខាន់ដ៏ធំធេងនៃរាជកកុធភណ្ឌ (the regalia) ផងទេ ។ រាជភណ្ឌខ្លះ ដូចជាស្វេតច្ឆត្រ និងមកុដ មានអត្ថន័យជាលោកធាតុវិទ្យា ដូចបាននិយាយខាងដើម ។ ជាងនេះទៀត, ស្វេតច្ឆត្រត្រូវបានគេគិតថា ជាអាសនៈរបស់ទេពារក្ស ដែលតែងផ្ដល់ដំបូន្មានដល់មហាក្សត្រ ហើយនៅក្នុងពេលមានអាសន្ន អាចធ្វើអន្ដរាគមន៍យ៉ាងសកម្ម ដើម្បីសង្គ្រោះសន្ដតិវង្ស ទៀតផង ។ រាជភណ្ឌខ្លះទៀត ត្រូវបានគេយល់ថាមានបង្កប់កំឡាំងមន្ដអាគម, ដូចជាព្រះខ័នរាជ្យរបស់ប្រទេសខ្មែរ ដែលគេជឿថាកាលណាព្រះខ័ននោះដកចេញពីស្រោម ដោយមិនបានរៀបចំសែនព្រេនត្រឹមត្រូវទេអាចនាំអោយមានមហន្ដរាយធ្លាក់មកលើប្រទេស ។ លក្ខណៈមន្ដអាគមរបស់រាជកកុធភណ្ឌ កាន់តែឃើញមានច្បាស់នៅក្នុងឧបទ្វីបម៉ាឡេ និងក្នុងប្រទេសឥណ្ឌូណេស៊ី ។ លក្ខណៈនេះ ឡើងដល់ចំណុចកំពូល នៅក្នុងមតិបញ្ញត្តិ ដ៏ចម្លែកដែលគួរ

យកចិត្តទុកដាក់ក្នុងចំណោមជនជាតិ *ប៊ូគីស និងម៉ាកស្សារ៉េស* (the Bugis and Makassarese) នៃកោះសេឡេប ។ យោងតាមមតិបញ្ញត្តិនេះ, គឺរាជក-កុធភណ្ឌទេ ដែលគ្រងរាជ្យដោយពិតប្រាកដនោះ, រីឯព្រះអង្គម្ចាស់ គ្រាន់តែជាអ្នកគ្រប់គ្រងរដ្ឋ ក្នុងនាមរបស់រាជកកុធភណ្ឌ ប៉ុណ្ណោះ ។

ការតម្កើងស្តេចអោយស្មើទេពតា ទន្ទឹមនឹងលើកព្រះអង្គអោយមានឋានៈមួយខ្ពស់ហួសស្ទើរជឿពុំបាននៅចំពោះមុខបរិពាររបស់ព្រះអង្គ, ពុំបានសម្រេចជោគជ័យដោយប្រការណាមួយទេ ក្នុងការធ្វើអោយរដ្ឋាភិបាលមានស្ថិរភាព, ប៉ុន្តែគឺទៅជាបានផលផ្ទុយទៅវិញ ។ ដូចបានពន្យល់ពីខាងដើមរួចហើយ, ទ្រឹស្តីទេវរាជ, ហើយសូម្បីតែទ្រឹស្តីចែងពីការកើតឡើងវិញ និងទ្រឹស្តីកម្មៈ បានផ្តល់ឧបាយកលដោះខ្លួនយ៉ាងស្រួលអោយពួកដណ្តើមរាជ្យ ។ ហេតុពិតដែលថា វាមានការងាយស្រួលយ៉ាងបង្គួរ ដើម្បីដណ្តើមកាន់កាប់វាំង, ដូចជានៅក្នុងប្រទេសភូមា, និងប្រទេសសៀម, ឬដើម្បីដណ្តើមកាន់កាប់រាជកកុធភណ្ឌ, ដូចជានៅក្នុងផ្នែកខ្លះ នៃប្រទេសឥណ្ឌូណេស៊ី, ជាញឹកញយ ដោយគ្រាន់តែមានប្រជាជាតិទាំងមូលទទួលស្គាល់ថាជាស្តេច ។ ហេតុពិតនេះ គឺបានឈានទៅដល់ការធ្វើសកម្មភាព ដូចជាការអុជអាលអោយមានការបះបោរបន្ថែមទៀត ម្យ៉ាងវិញទៀត, អំណាចដ៏ធំសម្បើមដោយគ្មានកំណត់ព្រំដែន ដែលស្តេចមានក្នុងដៃ បានអូសទាញអោយមានអំពើរំលោភ ដែលនៅទីបំផុតធ្វើអោយស្តេចត្រូវបានបរិវាររបស់ព្រះអង្គស្អប់ ហើយក៏ជំរុញអោយព្រះអង្គរលំរលាយ ។ មកដល់ចំណុចនេះ, ភាពមិនច្បាស់លាស់ ស្តីពីគោលការណ៍ជ្រើសរើសស្តេចបន្តរាជ្យ ក៏កើតមានឡើង ។ ជួនកាល ពួកសេនាបតីឬរដ្ឋមន្ត្រី ចង្អុលតែងតាំងព្រះអង្គម្ចាស់មួយអង្គ អោយឡើងជាស្តេច ។ បន្ទាប់មកក៏មានព្រះមហេសីទាំងឡាយ, ពិតមែនតែមិនផ្លូវការ ប៉ុន្តែមានប្រសិទ្ធភាពខ្ពស់, បានប្រើឥទ្ធិពលរបស់ខ្លួនគាំទ្រព្រះអង្គម្ចាស់ណាមួយ ដែលគាប់ព្រះទ័យ ។ ជាញឹកញយ

មុខរាជ្យតែងធ្លាក់ទៅលើព្រះអង្គម្ចាស់ណា ដែលដណ្តើមកាន់កាប់រាំងបានរហ័សបំផុត ហើយធ្វើគត់បងប្អូនរបស់ខ្លួនចោល ។ ឋិតក្រោមកាលៈទេសៈបែបនេះ វាគ្មានរឿងអ្វីនាំអោយឆ្ងល់ទេថា អាណាចក្រទាំងឡាយរបស់ទ្វីបអាស៊ីអាគ្នេយ៍ ចាប់តាំងពីដើមទីរៀងមក តែងត្រូវបានហែកហួរជាញឹកញយដោយឧទ្ទាមកម្ម ហើយជាញឹកញយចេញជាលទ្ធផល គឺផ្តួលរំលំស្តេច ឬរហូតដល់ផ្តួលរំលំសន្តតិវង្ស ។ សេចក្តីរាយការណ៍ពីដំបូងៗដែលយើងទទួលបាន គឺសេចក្តីរាយការណ៍ចេញមកពីប្រភពចិនស្តីពីព្រះរាជាណាចក្រហ្វូណន ។ សេចក្តីរាយការណ៍បានប្រាប់អោយដឹងថា លក្ខខ័ណ្ឌទាំងឡាយបែបនេះ បានកើតមានឡើងតាំងតែពីដើមសតវត្សទី៣ នៃគ.ស ម្ល៉េះ ។ ប្រសិនបើមានសម័យកាលដ៏វែងនៃអំពើជិះជាន់ និងអសន្តិសុខ, នោះក៏ព្រោះតែមានឧទ្ទាមកម្ម និងផលវិបាករបស់វា, ចោរកម្មអាចក្លាយទៅជាប្រពៃណីប្រជាប្រិយតាមធម្មតាទៅហើយ ដែលគេពិបាកនឹងលុបបំបាត់ ។ ជាឧទាហរណ៍, ករណីបែបនេះកើតមាននៅក្នុងប្រទេសភូមា ក្នុងអំឡុងសតវត្សទី ១៨ និងទី ១៩, ហើយគឺនៅក្រោមពន្លឺនៃរឿងអតីតបែបនេះហើយ ដែលព្រឹត្តិការណ៍ថ្មីៗនៅក្នុងប្រទេសនោះ ត្រូវតែគេមើលអោយឃើញ ។

## ការរស់រាននៃប្រពៃណី

ដើម្បីដឹងច្បាស់ថា តើប្រជាជនទាំងឡាយ នៃប្រទេសឯនាយឥណ្ឌា បានទទួលរងផលវិបាកយ៉ាងធ្ងន់ធ្ងរដូចម្តេចខ្លះ ដោយសាររចនាសម្ព័ន្ធលោកធាតុវិទ្យារៀបចំរដ្ឋ, នោះគេត្រូវការគ្រាន់តែគិតអំពីការបែងចែកប្រជាជនសៀម ទៅជាថ្នាក់ឆ្វេង និងថ្នាក់ស្តាំប៉ុណ្ណោះ, ដែលមិនជាយូរប៉ុន្មានផង បានកំណត់សេវាកម្មអោយមនុស្សម្នាក់ៗ ត្រូវមានកាតព្វកិច្ចបំពេញជូនរដ្ឋ ។ ជាងនេះទៀត, គេមិនត្រូវភ្លេចទេថា គោលការណ៍លោកធាតុ - មន្តអាគម ដែលបានអនុវត្តរៀបចំរដ្ឋ តាមពិត បង្កើត

បានជាផ្នែកនៃទស្សនៈមួយដ៏សាំញ៉ាំយ៉ាងខ្លាំង ហើយដែលជាលទ្ធផលចេញមកពីមតិបញ្ញត្តិនៃចក្រវាល និងអត្ថិភាពមនុស្ស ដែលបានត្រួតត្រា និងកំពុងត្រួតត្រា នៅឡើយ នូវជីវភាពឯកជនរបស់បុគ្គលម្នាក់ៗផងដែរ ។ ចំណែកនៅក្នុងប្រទេសសៀម និងប្រទេសខ្មែរ មនុស្សស្លៀកពាក់មានពណ៌ផ្សេងៗ ទៅតាមថ្ងៃខុសៗគ្នានៃសប្តាហ៍ យោងទៅតាមពណ៌ដែលគេផ្តល់អោយផ្កាយព្រះគ្រោះ មានឈ្មោះប្រចាំថ្ងៃ, ឬនៅក្នុងប្រទេសភូមាវិញ មុននឹងធ្វើការងារអ្វីមួយដ៏សំខាន់ គេត្រូវមើលក្បួននក្ខត្តឫក្ស និងថ្ងៃមានលាភ ឬឥតលាភជាមុនសិន, ឬក៏កាលណាគេលុតជង្គង់សូត្រធម៌នៅជ្រុងនោះៗ នៃព្រះវិហារ ដែលនៅក្នុងប្រព័ន្ធលោកធាតុវិទ្យា ស្របទៅនឹងផ្កាយព្រះគ្រោះនៃថ្ងៃក្នុងសប្តាហ៍ ដែលគេកើត, គេធ្វើការងារតាមគោលការណ៍ដដែល ដែលបានគ្រប់គ្រងរចនាសម្ពន្ធនៃអាណាចក្ររបស់គេ, នៃគំនិតស្តីពីរាជសម្បត្តិ និងពិធីរបស់ព្រះរាជវាំង ។ ដូច្នេះ, គេឃើញច្បាស់ណាស់ថា គំនិតលោកធាតុ - មន្តអាគម, រហូតមកដល់ពេលកន្លងទៅថ្មីៗនេះ, បានផ្តិតជាប់នៅក្នុងសន្តានចិត្តប្រជាជនរឹងមាំណាស់ ។

តើទាំងអស់នេះ ជារចនាសម្ពន្ធមួយកំពុងរលំរលាយ ចុះចាញ់ ក្រោមឥទ្ធិពលអារ្យធម៌ទំនើបឬទេ, ឬក៏វាអាចជះឥទ្ធិពលនៅឡើយ ទៅលើសកម្មភាពនយោបាយរបស់ប្រជាជនពាក់ព័ន្ធ ? ទោះជាយ៉ាងណាក៏ដោយ យើងទទួលបានសញ្ញាចង្អុលប្រាប់តិចតួចណាស់ ។

តាមសេចក្តីអះអាងរបស់លោក ក្វារិច វេល (H.G. Quaritch Wales), យើងបានដឹងថា ប្រជាជនសៀម ក្នុងរង្វង់ឆ្នាំ ១៩៣០ នៅតែរៀបចំបុណ្យជាតិតាមប្រពៃណីបុរាណក្នុងកិរិតតម្កើងខ្ពស់នៅឡើយ, បុណ្យប្រពៃណីទាំងនោះ បើនិយាយជារួម នៅតែត្រូវបានគ្របដណ្តប់ដោយទស្សនៈលោកធាតុវិទ្យា ។ គេអាចដណ្តឹងសួរខ្លួនគេថា តើមានប្រពៃណីចាស់ទុំនេះច្រើនកិរិតណា ដែលមិតនៅ

ពីក្រោមរាជឧទ្ទាមកម្ម ឆ្នាំ ១៩៣៣ ។

នៅក្នុងប្រទេសភូមា ករណីទាំងឡាយដូចតទៅនេះ អាចត្រូវបានគេចាត់ទុកជាករណីដ៏មានអត្ថន័យសំខាន់ ។ ក្នុងឆ្នាំ ១៨៨៧ ដល់ពីរឆ្នាំក្រោយ ពួកអាណានិគមអង់គ្លេស បានបញ្ចូលភូមាខាងលើ (Upper Burma) ជាឧបសម្ពន្ធរួចហើយ, មានភិក្ខុពុទ្ធសាសនិកមួយរូប ឈ្មោះ *អ៊ូ កេលាថា* (U kelatha) បានជាប់ជំពាក់ចិត្តស្នេហាជាមួយម្ចាស់ក្សត្រីមួយអង្គរបស់សន្តតិវង្ស ដែលគេទម្លាក់ពីរាជបល្លង្ក ។ ម្ចាស់ក្សត្រីបានសន្យាថា នឹងរៀបមង្គលការជាមួយ *អ៊ូ កេលាថា* ប្រសិនបើគេក្លាយជាស្តេចនៃប្រទេសភូមា ។ ក្រោយមក ក៏កើតមានសុបិន ឬឧត្តមនិមិត្តដែលប្រាប់អោយ *អ៊ូ កេលាថា* ដឹងថា នៅក្នុងជាតិមុន គាត់ធ្លាប់បានកើតជាព្រះអង្គម្ចាស់ភូមាមួយអង្គ ហើយសំខាន់ជាងនេះទៀត សុបិននោះបានប្រាប់ថា គាត់នឹងបានជាស្តេច នៅពេលណាគាត់បានអង្គុយនៅលើបល្លង្កក្នុងវាំង នៅមណ្ឌលេ ។ ដោយមានអ្នកដើរតាមគាំទ្រដប់ប្រាំបីនាក់ ដែលទាំងអស់គ្នាមានអាវុធត្រឹមតែដាវប៉ុណ្ណោះ, គាត់បានសំរុកចូលតាមទ្វារទីក្រុង ហើយប៉ុនប៉ងចូលទៅកាន់ព្រះរាជវាំង, ដែលនៅពេលនោះ ជាទីស្នាក់ការនៃក្លិបរបស់អង់គ្លេស ។ នាយទាហានអង់គ្លេសមួយចំនួន ប្រដាប់ដោយកាំភ្លើងបរបាញ់សត្វ បានបញ្ចប់ការប៉ុនប៉ងរបស់គាត់ទៅ ។ ព្រឹត្តិការណ៍នេះ បញ្ជាក់នូវភាពរស់រវើកដ៏អស្ចារ្យ នៃគំនិតលោកធាតុ - មន្តអាគម នៅចុងសតវត្សទី ១៩ ។ ដូចជាយើងបានឃើញហើយ, អ្នកណាមួយបានកាន់កាប់ព្រះរាជវាំង, ដ៏ជាភ្នំមេរុនៃអាណាចក្រភូមា, ដោយហេតុនេះ អ្នកនោះនឹងបានក្លាយជាតំណាងព្រះឥន្ទ្រ ហើយគឺជាស្តេច ។ នេះគឺវាស្របគ្នាទាំងស្រុង ជាមួយមួយនឹងបែបបទគិតគូរលោកធាតុ - មន្តអាគម ដែល *អ៊ូ កេលាថា* ហើយនិងមិត្រភ័ក្តិរបស់គេបានជឿថា ការគ្រាន់តែបានអង្គុយហើយកាន់កាប់បល្លង្ក នឹងបានធ្វើអោយគេក្លាយជាម្ចាស់ នៃអាណាចក្រទាំងមូល ដោយស្វ័យប្រវត្តិ ។

ដោយសេចក្ដីសោកស្ដាយ, មានពតិមានពិតប្រាកដតិចតួចណាស់ ស្ដីពី ឧទ្ទាមកម្មភូមា ឆ្នាំ ១៩៣០ - ៣១ ។ ប៉ុន្តែ, មានពតិមានលំអិតដូចតទៅនេះ ដែលត្រូវបានសារពតិមាន នាសម័យនោះចេញផ្សាយ គឺជាពតិមានសំខាន់ ។ សកម្មភាពមួយក្នុងបណ្ដាសកម្មភាពពីដំបូងៗ របស់លោក *សាយ៉ា សាន* (Saya San) មេដឹកនាំឧទ្ទាមកម្ម គឺត្រូវកសាង " វាំង " មួយ, តាមការជាក់ស្ដែង គឺគ្រាន់តែជាខ្ទមធ្វើពីឫស្សី សង់នៅកន្លែងណាមួយក្នុងព្រៃស្រោង, ដោយមានសរសេរអក្សរសម្គាល់វាំងនោះថា " វាំងរបស់ព្រះរាជាពុទ្ធសាសនិក " ។ តាមពិតទៅ គេងាយនឹងសើចចំអកចំពោះការប៉ុនប៉ងហួសមាឌបែបនោះ, ប៉ុន្តែ វាមានសារសំខាន់ដើម្បីយល់នូវការប៉ុនប៉ងនោះដែរ ។ យើងបានឃើញហើយថា ស្ដេច និងវាំង មិនអាចបំបែកចេញពីគ្នាបានទេ បើយោងតាមគំនិតភូមា ។ គ្មានព្រះរាជាណាចក្រណាអាចកើតមាន ដោយគ្មានវាំងមួយតាងភ្នំមេរុ ហើយកផ្ដុំជាមណ្ឌលមន្តអាគមរបស់វា, និងគ្មានស្ដេចបានទេ, " ម្ចាស់វាំងមាស " គឺជាស្ដេចក្នុងខ្សែស្រឡាយទីមួយ ដោយព្រះអង្គមានកម្មសិទ្ធិវាំង ។ អំពើរបស់ *សាយ៉ា សាន* ក្នុងការសង់វាំង, ជាមណ្ឌលមន្តអាគម សម្រាប់អាណាចក្រកំពុងកកើត, ដោយប្រការនេះ ស្របគ្នាយ៉ាងជិតស្និទ្ធទៅនឹងអំពើរបស់ *អ៊ូ កេលាថា* នៅពេលគាត់ចង់តម្កល់ខ្លួនគាត់នៅលើបល្ល័ង្កនៃវាំង ក្នុងទីក្រុងមណ្ឌលេ ។

រឿងរបស់ឧទ្ទាមកម្ម ម្យីនមុ ឆ្នាំ ១៩១០ (the Myinmu rebellion of 1910), ដូចលោក ប៉ូល អេដម៉ុង (Paul Edmonds) បាននិយាយនៅក្នុងសៀវភៅរបស់គាត់ ឈ្មោះ *ក្ងោក និងវត្ត* (Peacocks and Pagodas), ប្រសិនបើរឿងនេះមិនបានផ្ដល់ចំណេះដឹងដល់យើង អំពីគំនិតលោកធាតុ-មន្តអាគមក៏ដោយ, ក៏យ៉ាងហោចណាស់ បានផ្ដល់ឧទាហរណ៍ដ៏សំខាន់ អំពីឥទ្ធិពលនៃជំនឿក្នុងការកើតទៀត, ក្នុងទំនាយ, និងក្នុងប្រផ្នូលដែរ ។ យុវបុរសម្នាក់ អាយុ

ដប់ប្រាំបីឆ្នាំ ឈ្មោះ *មោង ថាន* (Maung Than) កំពុងដើរត្រឡប់ទៅផ្ទះ ពីកន្លែងធ្វើការនៅក្នុងស្រែដោយជក់បារីផង ។ មនុស្សមួយចំនួន ដែលបានដើរមកជួបគាត់ហួសទៅ គិតថា ខ្លួនគេបានឃើញផ្សែងហុយចេញពីដៃរបស់គាត់ ។ មនុស្សទាំងនោះ ក៏នាំគ្នានិយាយអំពីរឿងនេះនៅក្នុងភូមិ ហើយពាក្យចចាមអារាមបានឮដល់ចាស់ៗ ដែលធ្លាប់ចងចាំប្រពៃណីចាស់ទុំមួយ ។ យោងតាមប្រពៃណីនោះថា, មានស្តេចភូមាពីដើម ព្រះនាម *ចាន់យ៉េកថា* (Chanyeik tha) អាចនឹងកើតឡើងវិញ ក្នុងរូបកាយជាយុវជនម្នាក់ដែលមានមហិទ្ធិឫទ្ធិ ធ្វើអោយផ្សែងហុយចេញពីដៃ ។ សញ្ញា និងប្រផ្នូលទាំងឡាយផ្សេងទៀត ត្រូវបានគេស្វែងរក ។ មិនចាំបាច់រង់ចាំយូរផង, សញ្ញា និងប្រផ្នូលទាំងនោះ ក៏បានមកដល់ ។ រូបសត្វគ្រីហ្វិន (the griffins)* ថិតនៅខឿនព្រះវិហារចាស់មួយ ត្រូវបានគេឃើញញ័រ ; គ្រាប់ភ្លៀងមាសបានធ្លាក់មកលើព្រះវិហារមួយទៀត ; ហើយមានប្រផ្នូលគ្រប់ទិសទីបានកើតច្រើនឡើង ដែលចង្អុលមករកយុវជន *មោង ថាន* ថាជាអវតារជាថ្មី នៃស្តេច *ចាន់យ៉េកថា* (Chanyeik tha) ដែលគេបាននិយាយមកយូរហើយ ។ *មោង ថាន* បានបាក់ចូលទៅក្នុងវង់ល្បែង ហើយបានប្រកាសអួតអាងតាមទម្លាប់ថា ខ្លួនគាត់មានសាច់គង់ កាប់មិនមុត ហើយមានសិល្ប៍ ចេះបំបាំងខ្លួនមើលមិនឃើញ ។ ជាមួយនឹងហ្វូងមនុស្សប្រមាណមួយពាន់នាក់ ប្រដាប់ដោយដាវ និងលំពែង, *មោង ថាន* បានបើកការវាយប្រហារទៅលើប៉ុស្តិ៍ប៉ូលិស នៅម្យិនមុ (Myinmu), ប៉ុន្តែ ត្រូវបានរុញអោយថយក្រោយ, រួចក្រោយមក ក៏ត្រូវចាប់ខ្លួនបាន ។

គេអាចចោទសួរ ថាតើមានលទ្ធភាពឯណាមួយស្តីពីមតិបញ្ញត្តិដដែលនេះអាចប្រែក្លាយជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍន៍ស្ថាបនា នាពេលអនាគតបានឬទេ ?

---

* សត្វគ្រីហ្វិន : សត្វក្នុងរឿងល្បើក មានខ្លួនជាសឹង្ហ, ក្បាល និងស្លាប ជាសត្វឥន្ទ្រី, ត្រចៀកសេះ និងមានសិរ មានព្រុយដូចត្រី ។

សំណួរនេះ គឺពិបាកឆ្លើយ ។ ពួកអ្នកបូព៌ាប្រទេស ដែលបានទទួលការអប់រំពីលោកខាងលិច, ហើយសំខាន់បំផុត គឺពួកអ្នកដឹកនាំចលនាជាតិនិយម, មានទំនោរមើលស្រាល និងមើលងាយ " អប្បិយជំនឿ " (superstitions) ដែលគ្រប់គ្រង ដឹកនាំប្រជាជាតិរបស់គេក្នុងអតីតកាល ។ ប៉ុន្តែថា, វាមានមហាជន ជាមនុស្សសាមញ្ញច្រើនណាស់ដែលបានធំធាត់ដុះដាលឡើង នៅក្នុងប្រពៃណីចាស់ទុំនេះ ។ គំនិត និងលទ្ធិប្រជាធិបតេយ្យសម័យថ្មី ហើយនិងរដ្ឋាភិបាលតំណាង មានអត្ថន័យតិចតួចណាស់ ឬគ្មានអត្ថន័យអ្វីសោះឡើយ ចំពោះមនុស្សទាំងឡាយនោះ ។ ពួកគេមិនអាចទទួលការអប់រំក្នុងពេលដ៏ខ្លីបានទេ ។ ការផ្តាច់ទាំងស្រុងនូវប្រពៃណីវប្បធម៌ បានបង្ហាញអោយឃើញស្ទើរតែទូទៅហើយ នូវមហន្តរាយចំពោះអភិសមាចារ (ethics) ជាតិ និងបុគ្គល និងចំពោះស្មារតីទាំងស្រុងរបស់ប្រជាជន ដែលទទួលរងការប៉ះពាល់ ។ ដោយហេតុនេះ, ការសម្របសម្រួលមួយរវាងមតិបញ្ញត្តិចាស់ និងថ្មីហាក់ដូចជាត្រូវបានគេសំដែងស្វាគមន៍ ។ យ៉ាងហោចណាស់, ពាក្យពេចន៍ខាងក្រៅជាច្រើនរបស់មតិបុរាណ អាចត្រូវបានរក្សាទុកដដែលយ៉ាងស្រួល ហើយត្រូវបានបំពេញបន្តិចម្តងៗ ដោយន័យថ្មី ដោយមិនបង្អួចវឌ្ឍនភាពអប់រំ និងសម្ភារៈបន្តិចណាសោះឡើយ ។ ទោះជាដូចម្តេចក្តី, ករណីប្រទេសជប៉ុនបង្ហាញថា មានគំនិតមួយបុរាណឆ្ងាយជាងគំនិត ស្តីពីរដ្ឋលោកធាតុទៅទៀត ហើយសម្របសម្រួលបានតិចតួចទៅនឹងការបកស្រាយអភិសមាចារ ជាងគំនិតខាងក្រោយនេះ (គឺគំនិតរដ្ឋ-លោកធាតុ) ទៅទៀត, នោះគឺជំនឿក្នុងបច្ឆាជនរបស់រាជវង្ស *មីកាដូ* (the Mika-do) ថាចុះមកពីសុរិយទេពធីតា (the Sun Goddess) ( ឬយ៉ាងហោចណាស់ការប្រឌិតឡើងនូវជំនឿបែបនេះ) ។ ជំនឿនេះ អាចរស់រានមានជីវិត ហើយធ្វើសហវិដ្ឋមានបានយ៉ាងស្រួល ជាមួយនឹងការអភិវឌ្ឍន៍ដ៏ឈ្លាសវៃទាំងអស់ នៃវិទ្យា-សាស្ត្រ និងបច្ចេកទេសសម័យថ្មី ។ បញ្ហាបច្ចុប្បន្ន របស់ទ្វីបអាស៊ីអាគ្នេយ៍ ចាប់ពី

ពីពេលនេះតទៅ ត្រូវបានគេពិភាក្សាស្ទើរតែផ្តាច់មុខទៅហើយចេញពីទស្សនវិស័យសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយ ។ វាអាចជាកំហុសធំមួយ បើគេមិនយកចិត្តទុកដាក់ចំពោះសារសំខាន់របស់វប្បធម៌ និងប្រពៃណីក្នុងស្រុក សម្រាប់ការរៀបចំតំបន់នោះអោយទៅជាទីពេញចិត្ត នាពេលអនាគតនោះទេ ។

* * *

## វប្បធម៌ជាតិ

| | |
|---|---|
| បាន *ថ្មី* កុំចោល *ចាស់* | ខ្មែរត្រូវច្បាស់គិតការពារ |
| *ចាស់* កើតមានយូរយារ | ខ្មែរគ្រប់គ្នាធ្លាប់ពិសោធ ។ |
| *ថ្មី* កើតចេញពី *ចាស់* | ខ្មែរច្រើនណាស់នៅល្ងង់ឆោត |
| *ចាស់-ថ្មី* ផ្សំ *ពិសោធន៍* | ខ្មែរត្រូវផ្ដោតចិត្តអភិវឌ្ឍ ។ |

ឈន អៀម

# ពុទ្ធិដីកំពូល
# ព្រះធម៌ជាអនន្តសច្ចៈនៃសកលលោក(*)

ខ្ញុំព្រះករុណា អាត្មាភាព គិយ៉ូសេ អែនស៊ិនជោស នៃនិកាយ ណោនប៊ុតស៊ឹ របស់ប្រទេសជប៉ុន សូមសំដែងនូវអំណរគុណដោយស្មោះ ចំពោះសម្ដេចព្រះសង្ឃរាជ ព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងអស់លោកអ្នកទាំងអស់ ដែលបានយាងនិមន្ត និងអញ្ជើញមកពីគ្រប់ទិសទីនៃប្រទេសកម្ពុជា យ៉ាងច្រើនកុះករ ដើម្បីធ្វើបដិសណ្ឋារកិច្ចស្វាគមន៍ ចំពោះខ្ញុំព្រះករុណា អាត្មាភាព និងគណៈប្រតិភូ ។

យើងទាំងអស់គ្នាជាពុទ្ធសាសនិក ដែលជឿលើពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ យើងទាំងអស់គ្នាបានកើតមកក្នុងជីវិតនេះ គឺជាផលនៃកម្មដែលទាក់ទងជាមួយឪពុកម្ដាយយើង ហើយមានភព្វសំណាងបានរស់រានមានជីវិត ដោយសារមហាករុណាទិគុណរបស់ព្រះពុទ្ធ ។ ហេតុអ្វីបានជាយើងកើតមក ? ដើម្បីគោលបំណងអ្វី ដែលយើងរស់នៅនោះ ? ហើយតើអ្វីទៅដែលយើងគប្បីធ្វើក្នុងនាមជាពុទ្ធសាសនិកម្នាក់ នាពេលឥឡូវនេះ ?

ព្រះសិទ្ធត្ថគោតម, ព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រសូតនៅតំបន់មួយ នាជើង

---

(*) អត្ថបទនេះ ជាសុន្ទរកថារបស់ព្រះតេជព្រះគុណ គិយ៉ូសេ អែនស៊ិនជោស ថ្លែងក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតសង្ឃ នៅក្នុងបរិវេណអង្គរធំ នៅថ្ងៃ ១៩ ខែកុម្ភៈ ១៩៩៧ ។ ព្រះតេជព្រះគុណ គិយ៉ូសេ អែនស៊ិនជោស ជាស្ថាបនិកនៃនិកាយ ណោនប៊ុតស៊ឹ របស់ប្រទេសជប៉ុន និងជាអនុប្រធាននៃអង្គការមហាពោធិ របស់ឥណ្ឌា ។

ភ្នំហិមាល័យ ពីរពាន់ប្រាំរយឆ្នាំ កន្លងមកហើយ ។ នៅពេលព្រះពុទ្ធជាម្ចាស់មានព្រះជន្ម ម្ភៃប្រាំបួនវស្សា ព្រះអង្គបានចាប់អារម្មណ៍ចំពោះសច្ចៈនៅក្នុងសេចក្តីទុក្ខនៃជីវិត " រួចព្រះអង្គបានបោះបង់ចោលជីវិតលោកិយនេះ ដើម្បីស្វែងរក " ដំណោះស្រាយនៃការកើតនិងស្លាប់ " ដែលជាវត្ថុបំណងនៃជីវិតមនុស្សលោក ។ ក្រោយពីបានធ្វើតបធមិតាមបែបឥសី អស់រយៈពេលប្រាំមួយឆ្នាំ ព្រះពុទ្ធជាម្ចាស់បានបោះបង់វាចោល ដោយមកពីព្រះអង្គរកឃើញថា ការធ្វើតបៈតាមបែបឥសីនោះ មិនបាននាំព្រះអង្គឱ្យរកឃើញនូវមាគ៌ា នៃដំណោះស្រាយឡើយ ។ ក្រោយមក នៅថ្ងៃទី ៨ ខែធ្នូ នៅក្រោមម្លប់ពោធិព្រឹក្ស និងរស្មី ដ៏ចាំងចែងនៃពន្លឺផ្កាយ នាពេលព្រលឹម នៅតំបន់ពុទ្ធគយា ព្រះអង្គក៏បានរកឃើញសម្មាសម្ពោធិញ្ញាណ និងបានត្រាស់ដឹងជាព្រះពុទ្ធ នាពេលនោះ ។ សម្មាសម្ពោធិញ្ញាណ ដែលព្រះពុទ្ធសម្រេចបាននោះ គឺជាការត្រាស់ដឹងដោយព្រះអង្គឯងនូវអនន្តសច្ចៈ ដែលជា " ព្រះធមិ " នោះឯង ។ ដោយសារបានសម្រេចនូវព្រះធមិ ឬអនន្តសច្ចៈនោះឯង ដែលព្រះសិទ្ធត្ថគោតម បានក្លាយជាព្រះពុទ្ធ ។ ព្រះពុទ្ធជាម្ចាស់តែងសំដែងជារឿយៗថា " ពេលណា អ្នកមើលឃើញព្រះធមិ ពេលនោះអ្នកឃើញតថាគត ។ ពេលណា អ្នកឃើញតថាគត ពេលនោះអ្នកឃើញព្រះធមិ " ។ ពេលណា យើងមានជំនឿស៊ប់ទៅលើព្រះធមិហើយ គឺថាជឿលើអនន្តសច្ចៈហើយ ។ ហើយពេលបានដឹងច្បាស់អំពីព្រះធមិហើយ នៅពេលនោះឯង យើងក៏អាចក្លាយជា " ពុទ្ធ " ដូចព្រះពុទ្ធជាម្ចាស់ដែរ ។ ព្រះពុទ្ធសាសនាបានប្រៀនប្រដៅថា មនុស្សទាំងអស់នៅក្នុងលោកនេះ អាចក្លាយជាព្រះពុទ្ធមួយអង្គបាន ។ និយាយមួយបែបទៀតថា ព្រះពុទ្ធសាសនា ជាសាសនាដែលនាំឱ្យក្លាយជាព្រះពុទ្ធ ។

ព្រះពុទ្ធជាម្ចាស់រមែងប្រដៅថា " ចូរអ្នកមើលវត្ថុទៅតាមរូបភាពពិតរបស់វា " ។ នៅពេលដែលយើងមើលអ្វីៗទាំងអស់ក្នុងលោកនេះ តាមរបៀបនេះ

ពេលនោះយើងឃើញថា ៖

« អ្វីៗទាំងអស់ សុទ្ធតែមិនទៀង »

« អ្វីៗដែលកើតមក សុទ្ធតែគ្មានសារសំខាន់ »

« អ្វីៗទាំងអស់ សុទ្ធតែជាទុក្ខវេទនា »

នៅពេលព្រះពុទ្ធជាម្ចាស់ចូល " និព្វាន " នៅក្រោមម្លប់ដើមសាលព្រឹក្សទាំងគូ នៅដែនកុសិនារា ដោយផ្ទឹព្រះកេសបែរទៅទិសខាងជើង ព្រះភក្ត្របែរទៅទិសខាងលិច ព្រះអង្គទ្រង់ត្រាស់ថា " អ្វីៗទាំងអស់សុទ្ធតែអនិច្ចៈ ។ អ្វីៗទាំងអស់សុទ្ធតែប្រែប្រួលឥតឈប់ឈរ ដូច្នេះ សូមកុំប្រហែសក្នុងការប្រតិបត្តិ " " វត្ថុទាំងឡាយសុទ្ធតែស្ថិតក្នុងស្ថានភាពប្រែប្រួលឥតមានទីបញ្ចប់ ហើយវត្ថុទាំងអស់នោះ ប្រែប្រួលពីរូបមួយទៅរូបមួយទៀត នៅក្នុងវដ្តសង្សារ " ។

ផ្កាយបញ្ចេញពន្លឺនៅលើមេឃ, រួចដើមឈើ និងរុក្ខជាតិនានានៅលើភ្នំកំពុងប្រែប្រួលឥតឈប់ឈររៀងរាល់ថ្ងៃ មួយឆ្នាំ ពេញមួយឆ្នាំ ។ ដើមឈើ និងរុក្ខជាតិនានាដុះឫស ចេញពន្លក ចេញផ្កា រួចចេញផ្លែ ។ នៅគ្រប់ពេល អ្វីៗសុទ្ធតែប្រែប្រួលនៅក្នុងធម្មជាតិ ក៏ដូចជានៅក្នុងមរណភព នៅក្នុងនាម និងនៅក្នុងរូប ។

គ្មានអ្វីដែលស្ថិតស្ថេរជានិរន្តរ៍ ឬមិនប្រែប្រួលដាច់ខាតនោះទេ នៅក្នុងលោកនេះ ។ ហេតុដូច្នោះហើយបានជា អ្វីៗដែលកើតឡើង សុទ្ធតែជាវត្ថុឥតសារៈ និងមិនពិត ។ ប៉ុន្តែ មនុស្សខំព្យាយាមចាត់ទុករបស់ឥតសារៈនោះថា ជារបស់មានសារៈ និងពិត រួចក៏ធ្លាក់ទៅក្នុងកាមទោស ដោយសារការប៉ុនប៉ងយករបស់មិនពិតឥតសារៈ ធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។ នោះហើយជាដើមហេតុនៃសេចក្តីទុក្ខវេទនាទាំងឡាយ ។ នៅពេលដែលវត្ថុទាំងឡាយកំពុងប្រែប្រួលឥតឈប់ឈរ មនុស្សក្បាលរឹង ចចេសប៉ុនប៉ងឃាត់វត្ថុទាំងឡាយនោះ កុំឱ្យប្រែប្រួលទៅវិញ ។ នោះហើយជាប្រភពនៃសេចក្តីទុក្ខ ។

" អ្វីៗទាំងអស់ សុទ្ធតែទុក្ខវេទនា " នោះជាហេតុផលមូលដ្ឋាន ដែលធ្វើឱ្យព្រះពុទ្ធជាម្ចាស់ បោះបង់ចោលលោកិយនេះ ។ " ជីវិតជាហេតុនាំមកនូវការឈឺចាប់ និងសេចក្តីទុក្ខសោក សម្រាប់អ្នកមានជីវិតរស់នៅទាំងអស់គ្នា " ។ ពេលនេះពុទ្ធកាលកន្លងទៅបានពីរពាន់ប្រាំរយឆ្នាំហើយ ប៉ុន្តែ សច្ចធម៌នេះនៅតែស្ថិតស្ថេរ ឥតប្រែប្រួល ។

ទុក្ខវេទនាទាំងឡាយ កើតមកពី " តណ្ហាលោកិយ " ។ មូលហេតុនៃតណ្ហារបស់មនុស្សនេះ មានប្រភពចេញពីការស្រឡាញ់ខ្លួនឯងហួសហេតុ ដែលនាំមនុស្សទៅរកការប្រកាន់យកវត្ថុដែលឥតសារៈ ថាជាវត្ថុមានសារៈ រួចនាំទៅរកការយល់ច្រឡំដោយប៉ុនប៉ងបង្កើត ភាពមិនប្រែប្រួលចេញពីអ្វីដែលកំពុងប្រែប្រួល ។

ដើម្បីបើកផ្លូវឆ្ពោះទៅរកការពិត យើងត្រូវតែដណ្តើមជ័យជំនះពីលើតណ្ហាលោកិយ ដែលមាននៅក្នុងចិត្តរបស់យើង ព្រោះវាជាប្រភពនៃសេចក្តីទុក្ខវេទនាគ្រប់យ៉ាង ។ មានតែនៅក្នុងឱកាសនោះទេ ទើបយើងសម្រេចបាននូវសេចក្តីស្ងប់ខាងផ្លូវចិត្ត ។ សេចក្តីស្ងប់ដ៏វិសុទ្ធនោះ គឺជាសេចក្តីប្រាថ្នាដ៏កំពូលរបស់ពុទ្ធសាសនា ដែលគេហៅថា " សេចក្តីស្ងប់នៃនិព្វាន " ។ ការសម្រេចបាននូវស្ថានភាពនៃសេចក្តីស្ងប់ ដ៏កំពូលនោះ គឺជាវត្ថុបំណងនៃព្រះពុទ្ធសាសនា ។

ព្រះពុទ្ធសាសនា ឬថាសេចក្តីប្រៀនប្រដៅជាមូលដ្ឋានរបស់ព្រះពុទ្ធជាម្ចាស់ គឺជាសាសនានាំឱ្យក្លាយជាព្រះពុទ្ធ ដោយរៀនសូត្រអំពីសច្ចៈ ដែលព្រះពុទ្ធជាម្ចាស់បានរកឃើញរួចហើយ បានសេចក្តីថា គឺសម្រេចឱ្យបាននូវ " សេចក្តីស្ងប់នៃនិព្វាន " ។ ការសិក្សាអំពីព្រះពុទ្ធសាសនា គឺការប្រតិបត្តិតាមមាគ៌ារបស់ព្រះពុទ្ធ ។ ចុះយើងអាចប្រតិបត្តិតាមពុទ្ធមាគ៌ានោះយ៉ាងដូចម្តេច ? យើងមានវិធីប្រតិបត្តិជាប្រពៃណីបីយ៉ាង មួយគឺ ប្រព្រឹត្តតែអំពើល្អ, ពីរគឺ ការប្រមូលផ្តុំអារម្មណ៍ឱ្យមូល, និងបីគឺ ការរកឱ្យឃើញនូវអរិយសច្ចៈ ។ គេនិយាយថា បើនរណាម្នាក់ស្ទាត់ជំនាញ

ក្នុងការប្រើវិធីទាំងបីបែបនេះ អ្នកនោះនឹងអាចក្លាយទៅជាព្រះពុទ្ធមួយអង្គបាន ។ ពាក្យទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ត្រូវបានគេប្រមូលផ្តុំមកក្នុង " ចតុរារិយសច្ច និង អដ្ឋង្គិកមគ្គ " ។

យើងបានឃើញភាពច្របូកច្របល់ និងឥតសណ្តាប់ធ្នាប់នៅក្នុងពិភពលោកបច្ចុប្បន្ននេះ ។ គេមិនឃើញមានការបែងចែកខាងសីលធម៌រវាងត្រូវ និងខុស ហើយគេឃើញតែការវេចរិល និងកង្វល់ខាងផ្លូវចិត្ត ។ អារម្មណ៍របស់យើងកំពុងស្រេកឃ្លាននូវសេចក្តីស្ងប់ដ៏បរិសុទ្ធ ។ សង្គ្រាម និងទំនាស់ បន្តកើតមាននៅជុំវិញពិភពលោក ។ ការបង្កើនចំនួនអាវុធនុយក្លេអ៊ែរ មានទំហំធំធេង ដែលគេមិនអាចត្រួតពិនិត្យបាន ធ្វើឱ្យផែនដីស្ថិតក្នុងគ្រោះថ្នាក់វិនាសសូន្យសុង ដោយគ្រាន់តែចុចគន្លឹះមួយ ដែលជាលទ្ធផលនៃការប៉ះទង្គិចគ្នានៃតណ្ហារបស់មនុស្ស ។ មនុស្សជាតិកំពុងប្រឈមមុខនឹងគ្រោះបាត់បង់ជីវិតរបស់ខ្លួនឯង ។ បច្ចុប្បន្ននេះ យើងកំពុងស្ថិតនៅក្នុងយុគមួយ ដែលព្រះពុទ្ធជាម្ចាស់ហៅថា " ព្រះធម៌ចុងក្រោយបំផុត " ។ តើយើងអាចសម្រេច " សេចក្តីស្ងប់នៃនិព្វាន " នៅក្នុងលោកបែបនេះ បានដែរឬទេ ? ។

នៅពេលមានពាក្យទូន្មានប្រៀនប្រដៅ ព្រមទាំងមានវិធីប្រតិបត្តិនូវពាក្យទូន្មានទាំងនោះផង តើមានមនុស្សប៉ុន្មាននាក់ទៅ ដែលអាចអនុវត្តតាមបានពិតប្រាកដនោះ ? ហើយតើអ្វីទៅដែលហៅថា ព្រះធម៌ពិត ឬសច្ចៈពិត ដែលព្រះពុទ្ធជាម្ចាស់ បានសម្រេចរួចហើយនោះ ?

ព្រះពុទ្ធជាម្ចាស់បានក្លាយជាព្រះពុទ្ធ ដោយសារតែព្រះអង្គរកឃើញនូវអរិយសច្ចៈ ។ ដូច្នេះ អរិយសច្ចៈនៃសកលលោក គឺដូចជាព្រះធម៌ ដែលព្រះពុទ្ធទ្រង់បានរកឃើញ ។ ព្រះធម៌ ឬអរិយសច្ចៈ ត្រូវបានគេហៅថា " ចិត្ត ឬធាតុ " ។ តាមគម្ពីរសូត្រៈរបស់ព្រះពុទ្ធ " ចិត្តនៃព្រះពុទ្ធគ្មានអ្វីក្រៅពីមហាមេត្តាធម៌នោះទេ " ។

បុគ្គលណាដែលបានសម្រេចនូវមហាមេត្តាធម៌របស់ព្រះពុទ្ធហើយ បុគ្គលនោះគេហៅថា ជាអ្នកបានសម្រេចផលហើយ ឬជា " ពុទ្ធ " ហើយ ។ អរិយសច្ចៈមានពាសពេញសកលលោកយ៉ាងបរិបូណ៌ ហើយវាមិនលើស ឬមិនខ្វះឡើយ ។ វាហាក់ដូចជារង្វង់មូលយ៉ាងពេញលេញដូច្នោះដែរ ។ ពិភពលោកទាំងមូលខ្លួនឯង ក៏មានសណ្ឋានដូចជារង្វង់មូលដែរ ។ អ្វីៗទាំងអស់ រាប់តាំងពីព្រះអាទិត្យ ព្រះចន្ទ ហ្វូងតារា មនុស្សជាតិ សត្វតិរច្ឆាន សត្វល្អិត មច្ឆជាតិ រហូតដល់រុក្ខជាតិទាំងឡាយ នៅក្នុងពិភពលោកនេះ ដោយឥតគិតអំពីទំហំរបស់វា សុទ្ធតែមានរាងមូលទាំងអស់ ។ តាមរបៀបដូចគ្នានេះ វត្ថុទាំងឡាយនៅក្នុងពិភពលោក គ្មានអ្វីដែលគេមិនអាចវាស់បាន ឬមានលក្ខណៈអស្ចារ្យ ដោយគ្មានដើម ឬចុង ឬក៏គ្មានប្រភពដើម ឬទីបញ្ចប់នោះទេ ។ ដូច្នេះហើយបានជា ព្រះពុទ្ធជាម្ចាស់ទ្រង់មានបន្ទូលនៅក្នុងគម្ពីរសូត្រៈថា «សត្វលោកទាំងឡាយ មានធម្មជាតិរបស់ព្រះពុទ្ធនៅជាមួយ ។ ( សត្វមានជីវិត មានធម្មជាតិជាមូលដ្ឋានដូចព្រះពុទ្ធ និងដោយហេតុនោះ ក៏អាចក្លាយជាព្រះពុទ្ធបាន )» ។ មានន័យថា សត្វលោកទាំងឡាយនោះ សុទ្ធតែជារបស់ពិត ។

សច្ចៈមិនអាចកើតមានឆ្ងាយពីខ្លួនយើងទេ ប៉ុន្តែ វាជាទស្សនៈឡូស៊ិច ដ៏បរិសុទ្ធ និងស្អាត ដែលគ្របដណ្តប់ពីលើពិភពលោកទាំងមូល ។ សេចក្តីពិតនោះ វាមិនលើស ហើយក៏មិនខ្វះដែរ ទាំងវាមិនកើត ហើយក៏មិនស្លាប់ដែរ ហើយក៏មិនមកដល់ ឬមិនចេញទៅវិញដែរ ។ វាមានឧបមាដូចជា រង្វង់មូល ដែលមាន ៣៦០ អង្សា ។ នៅក្នុងរូបវិទ្យា គេហៅថា " ក្រឹត្យក្រមនៃការថែរក្សាមាឌ " ហើយត្រូវបានគេយកមកប្រើនៅក្នុងបច្ចេកវិទ្យា ក្នុងទូរទស្សន៍ និងវិទ្យុ ។ អ្វីៗនៅក្នុងពិភពលោកនេះ គឺជាការបង្ហាញឱ្យឃើញនូវសច្ចៈ ដែលគម្ពីរសូត្រៈបានយោងទៅដល់គាថាមួយថា " ពុទ្ធារម្មណ៍ គឺគ្មានអ្វីក្រៅពីមហាមេត្តានោះទេ " ឬថាអ្វីៗទាំងអស់ សុទ្ធតែស្ថិតនៅក្នុងមហាមេត្តារបស់ព្រះពុទ្ធ ។ ដោយហេតុថា គ្មានអ្វីដែលកើត និងគ្មានអ្វីដែល

ស្លាប់ អ្វីៗដែលមានជីវិត គ្រាន់តែផ្លាស់ប្តូរភាពជានិច្ចនៅក្នុងសច្ចៈ រួចបង្កើតជាពិភពមួយ ដែលកសាងឡើងដោយសារផលនៃអំពើរបស់ខ្លួនផ្ទាល់ ។ រួចអ្វីដែលគេអាចមើលឃើញនោះ គ្រាន់តែជាទិដ្ឋភាពផ្សេងៗ នៃពិភពលោកនោះតែប៉ុណ្ណោះ ។ ពិភពលោក និងអត្តនៃបុគ្គល គឺតែមួយ ហើយថែមទាំងមិនអាចផ្តាច់ពីគ្នាបានទៀតផង ។ ប៉ុន្តែ វិធីពិចារណារបស់លោកខាងលិច ក្នុងការស្វែងរកសច្ចៈ បានចែកសច្ចៈនេះជាពីរគឺ ប្រធាន និងកម្មវត្ថុ ។

តាមរបៀបនេះ, សច្ចៈហាក់ដូចជាត្រូវបានគេរកឃើញតាមរយៈយថាលោក នៅក្រៅពីអត្តនោម័តិរបស់ខ្លួន ។ ប៉ុន្តែ ដោយការស្រាវជ្រាវបែបវិទ្យាសាស្ត្រគាំទ្រទស្សនៈយកកម្មវត្ថុជាគោលតែមួយគត់នោះ មនុស្សយើងបានជាប់ជំពាក់កាន់តែខ្លាំងឡើង ទៅលើសារសំខាន់នៃខ្លួនឯង និងទៅលើការយកបុគ្គលទុកជាប្រធានទៅវិញ ។ ដោយឱ្យតម្លៃខ្លាំងហួសហេតុទៅលើបុគ្គល វិធីនេះបានបង្កើតឱ្យមានការបែងចែកជាពីរ រវាងខ្លួនឯង និងអ្នកដទៃ ដែលនាំទៅរកការប្រកាន់ ឬការបែងចែកនៃពិភពលោកយើងនេះ ។ ជាលទ្ធផល វាធ្លាក់ទៅក្នុងអន្ទាក់នៃលទ្ធិផ្តាច់មុខ ប្រកាន់ថាខ្លួនឯងត្រូវមិនចេះខុស និងការនិយមលទ្ធិឧត្តមភាពខាងសម្ភារៈរបស់បុគ្គល ។

ទស្សនៈរបស់លោកខាងលិចបន្តថា នាមនិងរូបរបស់មនុស្ស ជាធាតុពីរដាច់ពីគ្នា ។ រូបកាយកើតពីឪពុកម្តាយ ចំណែកនាមវិញ ជាធម្មតាកើតក្រៅពីរូបកាយ ។ គេថា រូបកាយកើតឡើងដោយសារជាតិប្រូតេអ៊ីន, គេថា អង្គភាពមូលដ្ឋាននៃសារធាតុ គឺជាចំណែកដ៏តូចល្អិតបំផុត រួចគេថា ពិភពលោកនេះមានទំហំប្រហែលម្ភៃពាន់លានឆ្នាំ នៃពន្លឺ ។

ប៉ុន្តែ ពីរពាន់ប្រាំរយឆ្នាំមុននេះ ព្រះពុទ្ធជាម្ចាស់បានរកឃើញរួចស្រេចទៅហើយ នូវអត្ថិភាពនៃម៉ាក្រូលោកធាតុ និងមីក្រូលោកធាតុ ទាំងបានបញ្ជាក់ថា វត្ថុធាតុទាំងឡាយ វាតែមួយ ដូចដែលវាត្រូវបានបង្ហាញឱ្យឃើញដោយសច្ចៈ ។

នៅក្នុងទស្សនៈខាងបូព៌ាវិញ យើងមិនបានបែងចែកប្រធាន និងកម្មវត្ថុជាពីរទេ ដូចជាយើងចាត់ទុក នាមនិងរូប ថាជាធាតុតែមួយ ។ ទាំងនាម ទាំងរូប សុទ្ធតែមានសារសំខាន់ដូចគ្នា ហើយស្ថិតនៅជាមួយគ្នាជានិច្ច ឥតដែលនៅដោយឡែកពីគ្នាសោះឡើយ ។ ជាភស្តុតាង គឺយើងអាចសំដែងនូវអារម្មណ៍របស់យើង ទាំងតាមនាម ទាំងតាមរូប ។ ពេលណាគេឱ្យយើងផ្លាស់ប្តូរពីកន្លែងមួយ ទៅកន្លែងមួយទៀត បេះដូងយើងរំជើបរំជួល រួចយើងយំ ។ ពេលភ័យខ្លាច ឬខឹង បេះដូងយើងញាប់ញ័រ ហើយយើងបែកញើស ។

ការបំបែកវត្ថុតែមួយឱ្យទៅជាប្រធាន និងកម្មវត្ថុ មិនខុសគ្នាពីការសង្កេតមើលវត្ថុមានជីវិតពីជ្រុងមួយ គឺរស់ ដោយសប្បាយ ឬស្លាប់ ដោយទុក្ខព្រួយ ។ ប៉ុន្តែតាមពិត អ្វីៗទាំងអស់នៅលើលោកនេះ សុទ្ធតែស្ថិតក្នុងស្ថានភាពប្រែប្រួលជានិច្ច ដែលជាលទ្ធផលនៃសកម្មភាពរបស់មេត្តាធមិ៍ពិត ។ ពីរស់ទៅស្លាប់ គឺជាដំណើរយ៉ាងទៀងទាត់នៃវលកជីវិត និងជាសច្ចធមិ ។ ប្រសិនបើសត្វមានជីវិតកើតហើយសត្វនោះប្រាកដជាស្លាប់ទៅវិញ ។ ឯរស់និងស្លាប់ វាតែមួយ ។ ការបំបែកសច្ចៈនេះជាពីរគឺ ប្រធាននិងវត្ថុ នាមនិងរូប សម្ភារៈនិងស្មារតី មិនត្រឹមត្រូវទេ ។ វាដូចជាគេប្រកែកគ្នាអំពី សើចនិងយំ ឬក៏ ចុងនិងគល់ នៃដំបងមួយ ថាខុសគ្នា តែតាមពិតវាតែមួយ ។ តាមពិត វាជាវត្ថុតែមួយដែលយើងនាំគ្នាចែកជាពីរ ហើយយើងជជែកគ្នាយកតែឈ្នះរៀងខ្លួន ។ មានពាក្យកាព្យបុរាណមួយឃ្លាថា « ខ្ញុំឆ្ងល់ថា តើជួងវាឮ ឬក៏អន្លូងវាឮ ។ តាមពិត ទាំងជួង ទាំងអន្លូង ទើបវាមានសំឡេង » ។

នៅពេលអន្លូងវាយទៅលើជួង ពេលនោះជួងក៏បន្លឺសំឡេងឡើង ។ ប៉ុន្តែមនុស្សមិនយល់ទេ ថាហេតុអ្វីបានជាគាត់ឮសូរ ដោយសារគាត់គិតថា សូរសំឡេងនិងខ្លួនគាត់ ជាវត្ថុពីរនៅដាច់ពីគ្នា ដែលជាការយល់ខុសសោះ ។ អារម្មណ៍របស់មនុស្សទុកដូចជាជួង ហើយគាត់បានឮសូរស្នូរជួងយ៉ាងរហ័ស ដោយគាត់មិនបាន

ប្រុងស្តាប់សួរនោះទេ ។ បែបនេះ គេហៅថាការភ្ជាប់អារម្មណ៍របស់ព្រះពុទ្ធ ។ សច្ចៈមានតែមួយគត់ ។ **វត្ថុ** គឺដួង ឬអន្លង់ និង **ប្រធាន** គឺអារម្មណ៍របស់មនុស្សបានចងភ្ជាប់គ្នាតែមួយ ហើយមនុស្សក៏មានអារម្មណ៍ ដែលអាចយល់អំពីពិភពលោកបាន ។ ហេតុនេះហើយបានជា មនុស្សអាចឮសួរដោយមិនចាំបាច់រៀបចំមុនឡើយ ។ ប៉ុន្តែ អ្នកស្រាវជ្រាវសម័យទំនើប កំពុងសាកល្បងធ្វើការបែងចែករវាងពុទ្ធិប្រធាន និងពុទ្ធិវត្ថុ និងរកវិធីដោះស្រាយបញ្ហានោះដោយឡែកពីគ្នា តាមចំណេះដឹងរបស់មនុស្សដែលខ្លួនមាន ។

លោកយើងនេះ ជាលោកដែលគ្មានអ្វីស្ថិតស្ថេរ ហើយប្រែប្រួលឥតឈប់ឈរ ។ ដូច្នេះ ដាច់ខាតមិនអាចរកឃើញសច្ចៈនៃការមិនប្រែប្រួល នៅក្នុងសច្ចៈនៃការប្រែប្រួលជានិរន្តរ៍នោះបានទេ ។ វាមានឧបមាដូចជា គេមិនអាចឡើងដើមឈើ ដើម្បីស្វែងរកចាប់ត្រីដូច្នេះដែរ ។ តាមពិត សច្ចៈមិនមែនជាអ្វីដែលនៅឆ្ងាយនោះទេ ។ ប្រសិនបើយើងគ្រាន់តែអាចយល់អំពីនាមពិត និងរូបពិត របស់យើងផ្ទាល់ នោះយើងអាចមើលឃើញសច្ចៈហើយ ។ វិធីបែបលោកខាងកើត ក្នុងការស្វែងរកសច្ចៈ ធ្វើឱ្យអាចសម្រេចបាន ដូចដែលព្រះពុទ្ធជាម្ចាស់លោកបានបង្ហាញឱ្យឃើញរួចហើយ ។

អរិយសច្ចៈដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានរកឃើញហើយនោះ ជាសច្ចៈដ៏ពេញលេញ និងជាសច្ចៈដែលឥតមានចំណុះឥទ្ធិពលរបស់អាទិទេព ឬ រិទ្ធិអំណាច ឬឆន្ទៈណាដទៃឡើយ ។ ព្រះពុទ្ធជាម្ចាស់បានរកឃើញសច្ចៈនេះ តាមរយៈបញ្ញាញាណ និងរូបកាយរបស់ព្រះអង្គ គឺនាម និងរូប ដែលត្រូវបានបង្ហាញឱ្យឃើញដោយសច្ចៈ ។ នោះគឺ ជីវិតដែលជាប្រធានបទនៃការរាវរករបស់ព្រះពុទ្ធជាម្ចាស់ តាំងពីបាតក្រោមនៃបញ្ញាញាណរបស់ព្រះអង្គ ។ នោះគឺ ជីវិត ឬឆន្ទៈ នៃធម្មជាតិ ដែលមានតាំងពីមុនពេលមានការពិសោធន៍ ឬចំណេះដឹងទៅទៀត ហើយត្រូវបានគេហៅថា ពុទ្ធភាព

ពុទ្ធញ្ញាណ ឬប្រភពកំណើតនៃការសច្ចារបស់ព្រះអមិតៈ ឬសច្ចភាព ។ នៅពេលឆន្ទៈដ៏បរិសុទ្ធ ដែលស្ថិតនៅជាមួយសត្វមានជីវិតនេះបានដឹករូបយើង ហើយខ្លួនយើងត្រូវបានប្រមូលផ្តុំគ្នាជាមួយនឹងសារសំខាន់ដែលកំពុងត្រួតត្រាពិភពលោក យើងអាចឈានទៅដល់ការយល់ដឹងមួយដែលថា ពិភពលោក គឺយើង ហើយគ្មានអ្វីក្រៅពីយើងដែលនៅក្នុងពិភពលោកនេះទេ ។ មកដល់ចំណុចនេះ យើងអាចដឹងបានអំពីឆន្ទៈពិតប្រាកដ ហើយបានក្លាយទៅជាធាតុមួយ នៅជាមួយពិភពលោក និងជាមួយមនុស្សជាតិទាំងឡាយ ដោយឥតមានរបាំងបែងចែកឡើយ ។ ពាហិរលោកនេះ នឹងអាចក្លាយទៅជាពិភពលោករបស់លោកអ្នក ហើយលោកអ្នកអាចទទួលស្គាល់ថាខ្លួនលោកអ្នកជាម្ចាស់នៃពិភពលោកនេះ ។ រួចលោកអ្នកនឹងមានថាមពលនៃឆន្ទៈដ៏ខ្លាំងក្លា ក្នុងការប្រឈមមុខនឹងសត្រូវរាប់សិបលាន ។ នៅពេលដែលឆន្ទៈដ៏បរិសុទ្ធនិងពាហិរវត្ថុបានបង្រួមបញ្ចូលគ្នាយ៉ាងល្អឥតខ្ចោះ ជាវត្ថុតែមួយហើយ ពេលនោះសច្ចៈក៏កើតឡើងដែរ ។ មនុស្សអាចដឹងនូវអ្វីៗទាំងអស់ ហើយភ្លេចខ្លួនឯងទៅវិញ។ នៅពេលនោះ អ្វីៗទាំងអស់ក្លាយទៅជាតែមួយ ហើយតែមួយនោះគឺអ្វីៗទាំងអស់ ហើយព្រះធម៌អាចនឹងបញ្ជាក់ឱ្យឃើញច្បាស់នូវអត្តភាពនោះ ។ ពេលមនុស្សទទួលអារម្មណ៍ដឹងថាខ្លួន និងធម៌ ទាំងប្រធាន ទាំងវត្ថុ សុទ្ធតែមានសារសំខាន់ដូចគ្នា ពេលនោះ មនុស្សបានឈានទៅដល់ពិភពនៃការត្រាស់ដឹងហើយ ។ នៅពេលដែលវិញ្ញាណមិនអាចនឹងដឹងអំពីវិញ្ញាណខ្លួនឯង ពេលនោះ ព្រះអាទិត្យដែលកំពុងបញ្ចេញរស្មី និងបក្សាបក្សីដែលកំពុងស្រែកច្រៀង អាចនឹងបញ្ជាក់បាននូវធម្មភាពនោះ ។ ដូច្នេះ ព្រះធម៌បញ្ជាក់ដោយព្រះធម៌ខ្លួនឯង ។ ដោយសារពិភពលោក និងមនុស្សវាតែមួយ មនុស្សអាចទទួលស្គាល់នូវមេត្តា និងសេចក្តីស្រឡាញ់ដោយខ្លួនឯង ។ នៅពេលនោះ មនុស្សអាចនឹងយល់អំពីពុទ្ធវចនៈដូចតទៅនេះ ថាជារបស់ខ្លួន « តថាគតមិនអាចសម្រេចសម្មាសម្ពោធិញ្ញាណពិតប្រាកដបាន ដោយមិនបានរំដោះសត្វ ឱ្យ

ផុតពីជាបកម្មបានឡើយ » ។ ពេលមនុស្សបានដឹងអំពីពុទ្ធវចនៈនេះ មនុស្សនោះអាច នឹងរកឃើញនូវសច្ចភាពរបស់ខ្លួនជាមនុស្សជាតិ ហើយគ្មានអ្វីក្រៅអំពីចំណេះដឹងនៃភាពខាងក្នុងបំផុតនៃវិញ្ញាណរបស់ខ្លួនឡើយ ។ យើងត្រូវទទួលស្គាល់ភាពបរិសុទ្ធនៃស្មារតី និងត្រូវគិតអំពីមហាមេត្តាដែលយើងត្រូវបានអនុញ្ញាតឱ្យរស់រានមានជីវិត និងត្រូវដឹងថា នោះហើយជាមូលដ្ឋាននៃជំនឿ ឬជីវិត ។

នោះហើយដែលគេហៅថា បានឃើញសច្ចភាពរបស់មនុស្ស ឬបានឃើញព្រះពុទ្ធ ។ ពេលមនុស្សបានដឹងថា អ្វីៗទាំងអស់នៅក្នុងពិភពលោកនេះ គឺខ្លួនគេផ្ទាល់នោះ គេនឹងយល់ថាពិភពលោករីកចំរើនដោយសារមហាមេត្តា ហើយខ្លួនគេផ្ទាល់ ក៏មិនមែនវត្ថុផ្សេងដាច់ដោយឡែកដែរ ។ គេគឺជាវត្ថុធាតុមួយនៃពុទ្ធវិញ្ញាណ និងអាចផ្តល់នូវមេត្តាទៅដល់សត្វមានជីវិតទាំងអស់ ។ ពេលនោះ មនុស្សអាចដឹងអំពីនាម និងរូប នៃខ្លួនឯងផ្ទាល់ ។ នាម និងរូប ជាវត្ថុធាតុតែមួយតាំងពីកំណើតមកដូច្នេះ ប្រធាន និងវត្ថុ ក៏អាចជាវត្ថុធាតុតែមួយដែរ ។ ប៉ុន្តែ នៅពេលមនុស្សបានជ្រួតជ្រាបយ៉ាងជោគជាំទៅដោយការសិក្សាបែបលោកខាងលិច មនុស្សបានធ្វើការបែងចែកប្រធានដោយឡែកពីកម្មវត្ថុ ។ ក្រោយពីទទួលស្គាល់ទស្សនៈខាងក្រោយនេះរួចហើយ មនុស្សក៏តាំងព្យាយាមស្វែងរកសច្ចៈនៅក្នុងកម្មវត្ថុ ។ ជាលទ្ធផល ទស្សនៈនានាដែលកើតចេញពីការសិក្សាបែបនេះ គឺជាទស្សនៈខុសឆ្គងទាំងស្រុង ។ ដោយសារការប្រកាន់នូវទស្សនៈបែបនេះ មនុស្សអាចចាត់ទុកខ្លួនឯងថាត្រូវ ឯគេឯទៀតសុទ្ធតែខុស ។ ជាលទ្ធផល មនុស្សបានក្លាយទៅជាគិតតែពីប្រយោជន៍ខ្លួន ហើយត្រឡប់ទៅជាអត្តទត្តបុគ្គល ។

សត្វមានជីវិតទាំងអស់ សុទ្ធតែកើតមកពីឪពុកម្តាយ ។ ប៉ុន្តែ ឪពុកម្តាយដែលបានរស់នៅដប់ពាន់ឆ្នាំ ឬមួយលានឆ្នាំកន្លងទៅហើយ ឬក៏តាំងពីពេលកកើតនោះ មិនទាន់មានឈ្មោះ ឬរូបរាងនៅឡើយ ។ វាដូចជាស្ថិតក្នុងសុញ្ញ ភាព ដែលគេ

មិនអាចយល់បាន ឬក៏ជាលំហអវកាសទទេ ហួសពីការស្រមៃរបស់មនុស្ស ។ អ្វីៗទាំងអស់កើតចេញពីលំហអវកាសដ៏ល្អល្ហែវ ដែលគេមិនអាចប៉ាន់ស្មាននោះឯង ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ដឹងថា ភពទទេនោះអាចនឹងពិបាកយល់បានណាស់ ដូច្នេះព្រះអង្គទ្រង់ឱ្យឈ្មោះថា អមិតាយុ គឺជីវិតដែលគ្មានព្រំដែន ។ ព្រះអង្គទ្រង់ឱ្យឈ្មោះពន្លឺដែលចេញពីខាងក្នុងភាពទទេរបស់ពេលវេលានៃពិភពនេះថា អមិតាភៈ ឬថា ពន្លឺឥតព្រំដែន ។ ពន្លឺនោះជាមូលដ្ឋាននៃវត្ថុធាតុ និងបាតុភូតទាំងឡាយក្នុងពិភពលោក ។ អ្វីៗទាំងអស់ រាប់តាំងពីព្រះអាទិត្យ ព្រះចន្ទ ហ្វូងតារា សត្វធាតុ មនុស្សជាតិ រហូតដល់រុក្ខជាតិ សុទ្ធតែកើតឡើងដោយសារពន្លឺនៃអមិតាភៈ ដោយឆ្លងកាត់កាលាយុទាំងមូលនៃអមិតាយុ ឬភាពទទេ ដែលស្ថិតនៅក្រៅវិមិតិ និងគំនិតទាំងឡាយ ។ កាលនិងអាកាសនៃអមិតាយុ និងពន្លឺនៃអមិតាភៈ វាដូចជាចុងសងខាងនៃវត្ថុតែមួយ ។ ពិភពលោកពោរពេញទៅដោយមេត្តាធម៌ និងព្រហ្មវិហារធម៌ ហើយកំណាព្យ **ហៃគុ** ដ៏បរមបុរាណរបស់ជប៉ុន សរសេរថា «រៀងរាល់ឆ្នាំ ពន្លកផ្កាសិរី នៅលើភ្នំយុសិណូ តែងប្រជែងគ្នាបំបែកដើម និងរកប្រភពដើម្បីចេញផ្កាឱ្យរីកស្គុសស្គាយ»។ តាមពិត វាគ្មានប្រភពនៃពន្លកផ្កានៅក្នុងដើមឈើទេ ។ ប៉ុន្តែ ខ្យល់ជំនោរនៃនិទាឃ-រដូវ ដែលជាកម្មទាក់ទងនឹងការចេញផ្កា គឺជាហេតុដែលនាំឱ្យផ្ការីក ។ ដូច្នេះកាលណាហេតុនិងកម្ម ជាបច្ច័យមកដល់ព្រមគ្នា ពេលនោះ បុប្ផាដ៏ល្អស្រស់ ក៏រីកឡើង ។ នេះក៏ដូចជាអមិតាភៈ ឬពន្លឺឥតព្រំដែន ដែលបានបំភ្លឺលោកទាំងមូលនេះដែរ ។ អមិតាភៈមិនបានកើតឯងៗនោះទេ ។ វាមិនបានភ្លឺឡើងដោយខ្លួនឯងទេ ឬក៏រលត់ទៅវិញដោយឯងៗដែរ ។ វាដូចជា កាលណាមានកម្មជាបច្ច័យនៅក្នុងពេលដែលរង្គុំថ្មទង្គិចទៅលើដែកមួយដុំ វានឹងបង្កើតបានជាភ្លើងដូច្នេះដែរ ឬក៏ដូចជា កាលណា**ឪជភ**ជាឪពុករួមរស់ជាមួយ**ជុំថា**ជាម្ដាយ កូនរបស់គេដែលជាភ្លើងនោះ ក៏ប្រសូតចេញមក ។ តាមរបៀបដូចគ្នានេះដែរ កាលណាព្រះអាទិត្យ និងព្រះច័ន្ទ ធាតុ

អវិជ្ជមាន និងវិជ្ជមាន ឬធាតុឈ្មោលនិងញី ឬក៏ឪពុកនិងម្តាយ រួមរស់ជាមួយគ្នា ដោយកម្មជាបច្ច័យ ដូចជាការកើតឡើងនៃអគ្គីនោះ អ្វីៗនៅក្នុងពេលនោះ រាប់ទាំងខ្លួនយើងដែលជាមនុស្សជាតិ ក៏កើតឡើង ។ ភ្លើងឆាបឆេះឡើង ពេលណាវាលទៅប៉ះអុស ។ ប៉ុន្តែ ភ្លើងវាវលត់ទៅវិញ កាលណាវាឆេះអស់អុស ដែលជាកម្មបច្ច័យ ។ ដូចគ្នានេះដែរ ឪពុកម្តាយយើងនិងខ្លួនយើង អាចស្លាប់ទៅវិញជាយថាហេតុ ។ ប៉ុន្តែ អមិតាភៈដែលជាប្រភពនៃអគ្គី មាននៅក្នុងអ្វីៗទាំងអស់នៃលោកដោយឥតមានលើស ឬខ្វះឡើយ ។ ពន្លឺនេះស្ថិតនៅក្នុងអមិតាយុ ចាប់តាំងពីយូរលង់មកហើយ ហើយនឹងស្ថិតនៅក្នុងនោះជាអនន្តកាលតទៅ ។ ដូចគ្នានេះដែរ សច្ចៈ ឬសារជាតិនៃព្រះធមិ គឺជាកាលនិងអាកាសទាំងមូល ។ ដូច្នេះ បានជាគេហៅអមិតាពុទ្ធ ថាជាព្រះពុទ្ធជាម្ចាស់ ។ យោលទៅតាមគម្ពីរសូត្រៈ ព្រះពុទ្ធជាម្ចាស់មានបន្ទូលដោយសេចក្តីស្ងប់ទៅកាន់សារីបុត្រថា : « ម្នាលសារីបុត្រ តើដោយហេតុអ្វីបានជាគេហៅព្រះពុទ្ធថា អមិតាភៈ ? ម្នាលសារីបុត្រ ពន្លឺរបស់ព្រះពុទ្ធបានចាំងចែងដោយឥតព្រំដែន និងគ្មានលាក់លៀមទៅគ្រប់ទិសទាំងដប់នៃពិភពលោកនេះ ។ ម្នាលសារីបុត្រ ជីវិតរបស់ព្រះពុទ្ធ និងមនុស្សលើផែនដីនេះ ចេះតែបន្តយ៉ាងយូររាប់កប្បដែលមិនអាចរាប់បាន មិនអាចកំណត់បាន មិនអាចគណនាបាន ។ ព្រោះហេតុនោះហើយ ទើបគេហៅព្រះពុទ្ធថា អមិតាយុ ។ ម្នាលសារីបុត្រ ដប់កប្បបានកន្លងទៅហើយ ចាប់តាំងពីព្រះពុទ្ធអមិតៈបានត្រាស់ដឹង ។

សារធាតុនៃមហាមេត្តា គឺជាកាល និងអាកាសទាំងមូល ។ ដប់គឺជាចំនួនខ្ពស់បំផុត ដូចនេះដប់កប្បមានន័យថា រយៈពេលច្រើនកប្បដែលមិនអាចរាប់បាន ។ ព្រះពុទ្ធជាម្ចាស់ទ្រង់មានបន្ទូលនៅក្នុងគម្ពីរសូត្រៈថា : « ពុទ្ធញ្ញាណ គ្មានអ្វីក្រៅពីមហាមេត្តាទេ » បានសេចក្តីថា កាលនិងអាកាសទាំងមូលនេះឯង ជាមហាមេត្តា ។

ពេលព្រះពុទ្ធទ្រង់បានត្រាស់នៅក្រោមដើមពោធិព្រឹក្ស ក្រោមពន្លឺផ្កាយ

ពេលទៀបភ្លឺ នៃថ្ងៃទី ៨ ខែធ្នូ កាលពីពីរពាន់ប្រាំរយឆ្នាំកន្លងទៅ ព្រះអង្គបានប្រកាសថា : « ជាការអស្ចារ្យណាស់ ដែលសត្វលោកមានគតិបណ្ឌិត និងគុណធម៌ របស់តថាគត » ។

គតិបណ្ឌិតបានន័យថា « នាម » ហើយគុណធម៌បានន័យថា « រូប » ។ ទាំងនេះចង់និយាយថា ដោយការរកឃើញនូវនាមនិងរូបរបស់ព្រះអង្គ ព្រះពុទ្ធជាម្ចាស់ ក៏បានរកឃើញនូវអ្វីៗទាំងអស់ដែរ ។ នៅក្នុងសច្ចៈឥតមានទំហំ ឬកំរាស់ទេ ។ មានវិធីច្រើនរាប់មិនអស់ក្នុងការសិក្សាអំពីសច្ចៈ ឬធម៌ ។ ហេតុនោះ មនុស្សមានច្រកទ្វារច្រើនរាប់មិនអស់ ដើម្បីចូលទៅរៀនធម៌របស់ព្រះពុទ្ធ ។ ប្រភេទនៃចំណេះដឹង ដូចជាវិទ្យាសាស្ត្រ ទស្សនវិជ្ជា សិល្បៈ អក្សរសិល្ប៍ ។ ល ។ សុទ្ធតែអាចរកឃើញនៅក្នុងពុទ្ធោវាទដែលបានពន្យល់អំពីសច្ចៈ ឯសាសនាវិញ គ្រាន់តែជាចំណែកមួយនៃពុទ្ធោវាទនោះ ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទូលំទូលាយណាស់ ហើយជ្រាលជ្រៅមិនអាចវាស់ប្រមាណបានផងនោះ ត្រូវបានបន្សល់ទុកនៅក្នុងគម្ពីរសូត្រៈជាច្រើនពាន់ក្បាល ។ ប៉ុន្តែ ពាក្យទូន្មាននោះមានលក្ខណៈវែងអន្លាយ ដែលមិនងាយចាប់បាននូវចំណុចជាគន្លឹះបានដោយងាយៗនោះទេ ។ ដោយសារមនុស្សមានសេរីភាពគ្រប់គ្រាន់ក្នុងការជ្រើសរើស នូវអ្វីដែលគេប្រាថ្នាចង់បានក្នុងការសិក្សាអំពីសច្ចៈនោះ មនុស្សអាចសិក្សាពាក្យទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ពីជ្រុងនានាផ្សេងៗពីគ្នា ។ នៅប្រទេសជប៉ុន តាមរយៈមាគ៌ានៃគតិបណ្ឌិត ចិត្តវេគ ឬឆន្ទៈការដាក់ឈ្មោះផ្សេងៗគ្នា ហើយនិកាយនានារបស់ពុទ្ធសាសនា ត្រូវបានគេបង្កើតឡើង ។ ជាអកុសល នាបច្ចុប្បន្នកាលនេះ អ្នកទាំងឡាយនោះ ភាគច្រើនបានភ្លេចអស់នូវមូលដ្ឋានគ្រឹះនៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ រួចពួកគេជាប់រវល់តែអំពីទស្សនៈរាយរងតែប៉ុណ្ណោះ ។ មនុស្សអាចសម្រេចនូវសច្ចៈតែមួយគត់បានដោយសារតែផ្លូវតាមមាគ៌ាទាំងឡាយនៃការសិក្សាអំពីពុទ្ធោវាទតែមួយគត់ និងគ្មាន

ផ្លូវណាផ្សេងទេ ។ ប៉ុន្តែ វាជាការពិបាកណាស់ ក្នុងការស្វែងរកសន្តិភាពក្នុងចិត្ត នៅក្នុងពិភពមួយដែលកំពុងជាប់រវល់ជានិច្ច និងពោរពេញដោយរោងចក្រឧស្សាហកម្ម ដូចសព្វថ្ងៃនេះ ។

ព្រះពុទ្ធជាម្ចាស់បានទស្សន៍ទាយទុកមកហើយថា យុគនៃការចុះដុនដាបនេះ នឹងឈានមកដល់ ។ នៅក្នុងគម្ពីរឈ្មោះ « សមាធិអំពីព្រះពុទ្ធនៃជីវិតអមតៈ » សរសេរថា ដើម្បីស្រោចស្រង់សត្វលោកដែលអាចទទួលអារម្មណ៍បាននៃយុគសម័យនេះ ព្រះពុទ្ធជាម្ចាស់បានឈប់ទេសនាអំពីគម្ពីរ « បុណ្ឌរីកសូត្រ » ដើម្បីប្រោសមហាក្សត្រី វៃទេហិ ដែលជាព្រះអគ្គមហេសីរបស់ស្ដេចពិម្ពិសារ ។ នៅក្នុងគម្ពីរ « ព្រះពុទ្ធនៃជីវិតអមតៈ » ព្រះអានន្ទត្រូវបានបង្រៀនឱ្យដឹងអំពីវិធីយ៉ាងងាយដើម្បីសម្រេចឱ្យបាននូវសច្ចធម៌ នៃព្រះពុទ្ធសាសនា ។ នៅក្នុងជំពូកចុងបំផុត នៃ « គម្ពីរអមិតៈ » មានបញ្ជាក់ថា ព្រះពុទ្ធជាម្ចាស់ព្រះអង្គឯងទ្រង់បានសម្រេចនូវសម្មាសម្ពោធិញ្ញាណ នៅក្នុងកលិយុគនៃបាបធម៌ទាំង ៥ ។ ការប្រៀនប្រដៅអំពីឆន្ទៈមានតាំងពីសម័យបុរាណនៃប្រទេសឥណ្ឌា រហូតដល់សម័យចិនបុរាណ រួចបានសាយភាយទៅដល់ប្រទេសជប៉ុន និងដែលខ្ញុំព្រះករុណា អាត្មាភាព មានកិត្តិយសបានទទួលនូវពាក្យប្រៀនប្រដៅទាំងនោះ ។ ឥឡូវ ខ្ញុំព្រះករុណា អាត្មាភាព បានរស់ដោយរីករាយក្នុងសច្ចធម៌ នៃព្រះពុទ្ធសាសនា ។

ពីមុន មានកវី និងអ្នកនិពន្ធរឿងសម្រាប់កុមារជប៉ុន ដ៏ល្បីល្បាញម្នាក់ឈ្មោះ « កេនជិមីយ៉ាហ្សាវ៉ា » ដែលជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនម្នាក់ ហើយបានគោរពជាពិសេសចំពោះគម្ពីរ « បុណ្ឌរីកសូត្រ » ។ គាត់បានសរសេរអំពីស្មារតីនៃគម្ពីរ « បុណ្ឌរីកសូត្រ » ដូចតទៅ :

« ទោះបីមនុស្សទាំងអស់នៃពិភពនេះ សម្រេចនូវសុភមង្គល តែវាគ្មានសុភមង្គលពិតទេ » ។

សព្វថ្ងៃ គ្មានទីណានៅលើផែនដីដែលយើងអាចរក « សន្តិភាពពិត និងសុភមង្គលពិត » ដែលមនុស្សជាតិប្រាថ្នាចង់បានជាយូរមកហើយ និងមិនដែលឈប់សម្រាកក្នុងការស្វែងរកក្នុងប្រវត្តិនៃជីវិតរបស់ខ្លួនទេ ។ ដល់ពេលហើយ ដែលមនុស្សម្នាក់ ឬយើងទាំងអស់គ្នា គប្បីភ្ញាក់រឭកដល់សេចក្ដីពិតដ៏ធ្ងន់ធ្ងរនេះ ព្រមទាំងគប្បីចាប់ផ្ដើមយកចិត្តទុកដាក់ឱ្យបានខ្លាំងជាងនេះចំពោះអនាគតរបស់យើង ដោយទទួលស្គាល់ថា « ពិភពលោករបស់យើងនេះ តាមពិត ជាពិភពមានជីវិតដ៏ល្អប្រណីតមួយ ហើយយើងទាំងអស់គ្នា និងសត្វមានជីវិត ជាភពតែមួយដែលចងភ្ជាប់គ្នាដោយជោគវាសនារួមគ្នា ។ យើងអាចកុំយកចិត្តទុកដាក់ដល់ព្រំដែនប្រទេស ជាតិសាសន៍ និងសាសនា និងសម្លឹងមើលឱ្យឆ្ងាយពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់យើង ។ ចូរយើងបំពាក់ក្នុងអារម្មណ៍ថា គ្មាននរណាម្នាក់ក្នុងចំណោមយើងទាំងអស់គ្នានេះ ដែលកើតឡើងដោយខ្លួនឯង និងអាចបន្តការរស់រានមានជីវិតដោយពឹងលើកម្លាំងខ្លួនតែម្នាក់ឯងបានទេ ។ យើងរស់នៅ ឬគួរថាត្រូវបានអនុញ្ញាតឱ្យរស់នៅបាន ក៏ព្រោះមានការឧបត្ថម្ភគាំទ្រពីមនុស្សគ្រប់ប្រភេទដទៃទៀត និងទាំងជីវិតនៃសត្វលោកជាច្រើនទៀតផង ។ យើងមានឪពុកម្ដាយរបស់យើង ។ ឪពុកម្ដាយយើងមានមាតាបិតារបស់គាត់ ។ រួចអ្នកទាំងអស់ ក៏មានឪពុកម្ដាយតទៅទៀតដែរ ។ ប្រសិនបើយើងក្រឡេកទៅមើលប្រភពដើម យើងនឹងអាចដឹងបានថា ឈាមដែលយើងបានទទួលនៅពេលនោះ បានហូរកាត់ជីវិតរាប់លានមុនយើង ។ សាមសិបបីជំនាន់នៃបងប្អូនយើង បូកថែមចំនួនមួយ ស្មើនឹងចំនួននៃមនុស្សទាំងមូល ។ មួយរយជំនាន់ បូកនឹងចំនួនសត្វមានជីវិតទាំងអស់នៅលើផែនដី ក៏មានន័យដូចនេះដែរ ។ សត្វលោកទាំងអស់ សុទ្ធតែមានទំនាក់ទំនងជាបងប្អូននឹងគ្នា ឬមានទំនាក់ទំនងជាមួយគ្នា តាមបែបនេះ ឬបែបនោះ នៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគត-កាល ។ ដោយយើងនៅតែបន្តកើតស្លាប់ យើងមិនដឹងថា កើតពេលណា ឬក៏កន្លែង

ណា ដែលយើងត្រូវកើតនៅជាតិខាងមុខនោះទេ ។

មានកំណាព្យដ៏ពិរោះ និងចាស់បុរាណរបស់ជប៉ុនមួយឃ្លាយ៉ាងខ្លីថា ៖

« ស្ដាប់ឮសូរចម្រៀងបក្សីលើភ្នំយំពិរោះ ខ្ញុំសង្ស័យហាក់ដូចជាសូរសំឡេងរបស់ខ្មោចឪពុក ឬខ្មោចម្ដាយខ្ញុំ » ។ តាមពិត សត្វមានជីវិតទាំងអស់ សុទ្ធតែជាបងប្អូននឹងគ្នា ជាបងប្អូនបង្កើត ឬជាញាតិព័ន្ធទេវិញទៅមក ។ គ្មាននរណាម្នាក់កើតតែម្នាក់ឯងគត់ ឬក៏គ្មាននរណា អាចរក « សន្តិភាពពិតប្រាកដ » បាន ឬក៏ « សុភមង្គលពិត » បានសំរាប់យើង ដ៏រាបណាមនុស្សជាតិទាំងមូល មិនត្រូវបានគេសង្គ្រោះឱ្យផុតពីគ្រោះមហន្តរាយ ។ ដូច្នេះ ដើម្បីសេចក្ដីសុខរបស់មនុស្សជាតិយើងត្រូវតែប្រព្រឹត្តតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដែលតែងតម្កល់នូវព្រហ្មវិហារធម៌ និងសន្តិភាពទុកជាធំ ។

តាំងតែពីសម័យបុរាណមក ប្រទេសឥណ្ឌា ដែលត្រូវបានជប៉ុន ហៅថា « តេជីគុ » ជាកន្លែងគោរពរបស់អ្នកកាន់ពុទ្ធសាសនា និងជាទឹកដីដ៏ល្អពិសិដ្ឋរបស់ព្រះពុទ្ធជាម្ចាស់ ។ ពួកគេមានប្រាថ្នាទៅទស្សនាទីនោះ ហាក់ដូចជាចង់ទៅជួបផ្ទាល់ជាមួយពាក្យប្រៀនប្រដៅពិតរបស់ព្រះពុទ្ធជាម្ចាស់ ។

ប៉ុន្តែ ព្រះពុទ្ធសាសនាបានស្រុតចុះយ៉ាងលឿន ។ ចំនួនពុទ្ធបរិស័ទបានថយចុះ ។ សំណល់ និងបុរាណដ្ឋាន នៃវប្បធម៌ពុទ្ធសាសនាសម័យមុនៗ បានរេចរិល និងបាត់បង់ទៅ ។ ទាំងនៅក្នុងប្រទេសអ្នកកាន់ពុទ្ធសាសនា ដូចជាប្រទេសជប៉ុន ក៏ប្រជាជនមានទំនោរទៅរកតែទស្សនៈរាយរងសើៗ ដែលឆ្ងាយពីចរន្តពិតនៃជំនឿ ។ គេផ្ដោតការគោរពយ៉ាងជ្រាលជ្រៅរបស់គេតែទៅលើស្ថាបនិក នៃនិកាយរបស់ខ្លួន ដោយយកចិត្តទុកដាក់យ៉ាងស្ដួចស្ដើងចំពោះព្រះពុទ្ធជាម្ចាស់ ដែលបានបង្កើតពុទ្ធសាសនាមុនគេទេវិញ ។ ការតម្កល់ទុកជាកំណប់ទ្រព្យមានតម្លៃ និងការថែរក្សាទុកនូវទីកន្លែងដ៏ពិសិដ្ឋរបស់ព្រះពុទ្ធជាម្ចាស់ ទុកជាកេរមរតកនៃពិភពលោក សម្រាប់

មនុស្សជំនាន់ក្រោយ គឺជាភារកិច្ចដ៏ឧត្តុង្គឧត្តមរបស់យើង ដែលយើងមិនត្រូវបោះបង់យ៉ាងងាយទាល់តែសោះ ។ ប៉ុន្តែ ឥឡូវនេះ នៅក្នុងសម័យដែលពិភពលោកយើង កំពុងតែច្របូកច្របល់ហួសហេតុយ៉ាងនេះ ខ្ញុំព្រះករុណា អាត្មាភាព មានជំនឿយ៉ាងមុតមាំថា ជាពេលដែលពុទ្ធបរិស័ទទាំងអស់នៃពិភពលោក ត្រូវប្រមូលផ្តុំកម្លាំងពួតដៃគ្នា និងត្រឡប់ទៅរកពាក្យប្រៀនប្រដៅដើមដំបូងរបស់ព្រះពុទ្ធជាម្ចាស់ និងបន្លឺសំឡេងឱ្យខ្លាំង ដូចសូរសីហនាទ ដើម្បីប្រកាសអំពីពុទ្ធោវាទឱ្យបានឮពាសពេញពិភពលោក ។ នេះជាពេលដែលយើងទាំងអស់គ្នា ត្រូវក្រោកឈរឡើង ដើម្បីដណ្តើមយកជ័យ គឺ « ការរក្សាសន្តិភាពដ៏យូរអង្វែង និងសុភមង្គលពិត សម្រាប់មនុស្សជាតិទាំងមូល » មិនមែនសម្រាប់តែសេចក្តីសុខរបស់បុគ្គលទេ តែដើម្បីសម្រេចបាននូវបំណងប្រាថ្នា និងឧត្តមគតិរបស់យើង គឺ :

« ការផ្សព្វផ្សាយនូវពុទ្ធសាសនាទូទាំងពិភពលោក និងការជួយមនុស្សគ្រប់រូបក្នុងលោកឱ្យបានក្លាយទៅជាពុទ្ធបរិស័ទ » ។

ខ្ញុំព្រះករុណា អាត្មាភាព សូមអធិដ្ឋានចំពោះមនុស្សទាំងអស់ សូមឱ្យវិលត្រឡប់ទៅរកពាក្យទូន្មានជាមូលដ្ឋានរបស់ព្រះពុទ្ធជាម្ចាស់ ។ ជារួម យើងគប្បីបូជាខ្លួនយើងទៅលើ « ការផ្សាយរបស់ព្រះពុទ្ធសាសនា ការចែកចាយព្រះពុទ្ធសាសនាទៅគ្រប់ទិសទី » ។ លោក ម៉ាត្សុអូបាសូ កវីដ៏ជាទីគោរពយ៉ាងជ្រាលជ្រៅរបស់ជប៉ុននាសម័យ ហៃគុ និយាយថា :

« ថ្ងៃនិងខែ ជាអ្នកដង្ហោយហៅ បានឆ្លងកាត់មួយរយជំនាន់ ។ ឆ្នាំដែលមកដល់ នឹងចេញទៅវិញ គ្រាន់តែជាអ្នកធ្វើដំណើរឥតឈប់ឈរតែប៉ុណ្ណោះ » ។

យើងជាវត្ថុមានជីវិត គ្មានអ្វីខុសពីអ្នកធ្វើដំណើរ ដែលចេះតែធ្វើដំណើរកាត់ចរន្តពេលវេលាដែលហូរមិនចេះចប់ ។ យើងម្នាក់ៗ បានកើតមកក្នុងពិភពលោកនេះ ហើយម្នាក់ៗរស់ក្នុងបរិដ្ឋានមួយរបស់ខ្លួន ។ យើងបានជួប « មនុស្ស » ដូចជា

យើងមានវាសនា ហើយយើងជួបនឹងពាក្យទូន្មានរបស់ព្រះពុទ្ធ ក៏ដូចជាយើងមានភព្វវាសនាដែរ ។ រួចតមក យើងលាគ្នាទៅវិញ ហើយស្លាប់លាចាកមរណលោកនេះទៅ ។ បញ្ហាសំខាន់នៅពេលនេះ គឺថា « តើយើងបានបន្សល់ទុកនូវអ្វីខ្លះ ក្រោយពេលយើងស្លាប់ទៅ ?

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងចំណាយពេលវេលាចុងក្រោយ នៃជីវិតរបស់ខ្ញុំព្រះករុណា អាត្មាភាព ទុកជាស្ពានចម្លងរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន តាមរយៈពុទ្ធសាសនា ដូចជាមនុស្សនៅភូមិភាគបូព៌ា ដូច្នេះដែរ ។

ទៅទីបញ្ចប់ ខ្ញុំព្រះករុណា អាត្មាភាព សូមអធិដ្ឋាននូវសេចក្ដីប្ដេជ្ញា របស់ខ្ញុំព្រះករុណា អាត្មាភាពថា « ខ្ញុំព្រះករុណា អាត្មាភាព សូមបូជាខ្លួនខ្ញុំផ្ទាល់ ចំពោះការផ្សព្វផ្សាយនូវពាក្យទូន្មានរបស់ព្រះពុទ្ធជាម្ចាស់ ដើម្បីជាគុណប្រយោជន៍ដល់មនុស្សជាតិទាំងមូល ដរាបណាសេចក្ដីទុក្ខនៅតែមាននៅលើលោកនេះ ។ ខ្ញុំព្រះករុណា អាត្មាភាព សូមបួងសួងសុំឱ្យសត្វឃុំនៅលើលំហមេឃ ឱ្យបុប្ផារីកស្រស់ស្គុសស្គាយគ្របដណ្ដប់លើផែនដីគ្រប់ទិសទី ។ សូមឱ្យមនុស្សទាំងអស់ទទួលបាននូវសន្តិភាព និងសុភមង្គល ។

អង្គរ, ថ្ងៃទី ១៩ កុម្ភៈ ១៩៩៧
គិយូសេ អែនសិនជោស

> « ជនដែលមិនបានធ្វើអំពើបាប មិនទទួលផលបាបទេ ក៏ដូចគ្នានឹងមនុស្ស ដែលដៃគ្មានរបួស មិនដែលពុលនឹងថ្នាំពុលដែលខ្លួនកាន់ទេ » ។
>
> ធម្មបទ . ១២៤

# ប្រាសាទបឹងមាលា

( បទពាក្យប្រាំពីរ )

ធ្វើដំណើរឆ្ងាយចូលព្រៃក្រាស់ ដើរលើផ្លូវចាស់កៀរជើងភ្នំ
ខ្យល់បក់ត្រសៀកឮសត្វយំ ដូចភ្លេងរងំបំពេចិត្ត ។
កូនឈើល្វតខ្ពស់វែងលវៃ ឈើធំត្រឈៃឈរល្វិរបរិត
ស្លឹកជ្រុះក្រាលដីដើរមិនស្និទ្ធ អារម្មណ៍ហាក់ស្ថិតក្នុងយុគមួយ ។
ដូចទេពអប្សរមានសក់ដាញ់ សក់វែងក្រញាញ់អង្គុយព្រួយ
ឃុំក្នុងព្រៃជ្រៅគ្មានអ្នកជួយ អប្សរសែនព្រួយក្នុងចិន្តា ។
មើលចុះវល្លិត្រៀលធ្លាក់ដូចទោង ស្មៅដុះរយោងលើសិលា
ដើមបេងធំៗបញ្ចេញផ្កា មើលទៅបក្សាសប្បាយក្រៃ ។
ប្រាសាទផ្កាបេង (១) បឹងមាលា រស់រងវេទនាឥតតម្លៃ
ទ្រុឌទ្រោមគ្រាំគ្រារៀងរាល់ថ្ងៃ កម្មកាចចង្រៃគ្មានមេត្តា ។
ក្បាច់ផ្តែរត្រូវស្លែដុះរុំជិត ចម្លាក់ប្រណីតដួលពិការ
កំពូលរលំសែនខ្លោចផ្សា ជញ្ជាំងដួលផ្ការកាច់សរសរ ។
ទោះបីអាយុបងអង្គរ (២) ចរិតនឹងនចិត្តស្មោះស
សុភាពទន់ភ្លន់ស្រស់បវរ នេះគឺជាថ្មមានវិញ្ញាណ ។
មាលាប្រាសាទជាខ្មាតច្បាស់ ខ្មែរប្រសប់ណាស់ធ្វើអោយមាន
សិល្បៈពិតមួយបានរស់រាន អត្តសញ្ញាណច្បាស់ប្រាកដ ។

---

(១) ប្រាសាទបឹងមាលា អ្នកខ្លះថា ប្រាសាទបេងមាលា ( គ្មានការអះអាងច្បាស់លាស់ ) ។

(២) ប្រាសាទបឹងមាលា កសាងឡើងមុនអង្គរវត្ត ក្នុងសតវត្សទី ១២ រចនាបថអង្គរវត្ត ។

ស្នាដៃកែច្នៃប្លែកៗគ្នា កុំពួលវង្សាមានអំណត់
និស្ស័យសិល្បៈមិនខ្សោយខ្សត់ ឥឡូវខ្មែរអត់អស់លំនឹង ។
គេផ្ដួលឈើធំរលំលើ គេច្រៀកយកឈើពីលើហ្នឹង
គេដាប់យករូបល្អច្រឡឹង គេហាក់មិនដឹងថាខ្លួនខុស ។
យើងខ្មែរយុគនេះសែនខ្មាសអៀន មិនគួរបើហ៊ានសាងកំហុស
បំផ្លាញទ្រព្យខ្លួនយសធ្លាក់ចុះ សុំលាងកំហុសជូនខ្មែរក្រោយ ។
មិនគួរលើកដៃសាងបន្ត ត្រូវមើលឃើញថ្មស្រែកដង្ហោយ
ហៅយើងរាល់គ្នាអោយងាកក្រោយ កុំទៅមុខដោយភ្លេចសាវតារ ។
មើលចុះសម្រស់គួរគយគន់ ទោះបីឈើធ្ងន់ស្រុតយ៉ាងណា
ស្នាដៃមានន័យសែនអស្ចារ្យ មនុស្សលើលោកាកោតសរសើរ ។

ដោយ **ខៀវ បញ្ញាវុឌ្ឍ**

ភាសិត

*ចូរយកដើមព្រៃងជាច្បាប់ប្រាណ វាយោបក់ប្រានមិនរលំ*
*រុក្ខជាតិដូចយ៉ាងដើមសុក្រំ ខ្យល់ធំបក់ធំគង់រលើង ។*

# ទំនួញត្បាល់កិន

( បទកាកគតិ )

បុរាណបានថ្មៃ យកឈើឫស្សី ដីដំបូកបិទ
ធ្វើជាឧបករណ៍ ប្រើប្រាស់ទាន់ចិត្ត កិនស្រូវបែកល្អិត
សំរូបអង្ករ ។

ទើបយកទៅបុក អង្រែងទង្គក ត្បាល់ក្បៀងបន្ត
សម្រាំងសម្រិត ប្រឹងស្រិតអោយស ចង្អេរអបអរ
អុំយកស្រូវចេញ ។

កញ្រ្ចែងវែងធ្លេច កន្ទក់កំទេច ជម្រុះបណ្តេញ
យកអង្ករដើម ថ្ងៃឆ្នើមស្អាតឆេញ ដាំបាយមែនមិញ
ឆ្ងាញ់ឈ្ងុយពិសារ ។

មានប្រយោជន៍ណាស់ ជំនាន់ជាន់ចាស់ គេតែងត្រូវការ
ជាច្រើនសតវត្ស សង្គមខេមរា ពឹងពាក់ដោយសារ
ត្បាល់កិនស្រុកស្រែ ។

យុគសម័យថ្មី ហេតុការណ៍អ្វីៗ ក្រឡៃប្រាស់ប្រែ
បោះបង់ទំនៀម ទម្លាប់ស្រុកស្រែ គេនាំគ្នាកែ
មកស៊ីវិល័យ ។

ជឿនលឿនខ្លាំងណាស់ ដោយវិទ្យាសាស្ត្រ ប្រឌិតកែច្នៃ
ផ្លាស់ចាស់ចោលចេញ ដេញតាមសម័យ ប្រកាន់ស្មារតី

យកថ្មីនិយម ។

ស្រណោះស្រណោក យោបំយំសោក វិយោគក្តៅងំ
ត្បាល់កិនមួយតួ សែនកើតទុក្ខធំ ព្រោះត្បិតសង្គម
គេលែងត្រូវការ ។

គេបោះបង់ចោល ទុកនៅក្បែរក្រោល ក្តៅក្តួលខ្លោចផ្សា
ត្រូវថ្ងៃត្រូវភ្លៀង ខ្ទបប្រាំងវស្សា ខ្ទិចខាតមេ្តចម្តា
គេពុំរវល់ ។

កាលដើមនោះណា មនុស្សគ្រប់អាត្មា ត្រូវការរចល់
កិនស្រូវឥតស្រាក រីងរៃកអំពល់ ញាតិផ្សេងមកដល់
សុំកិនបន្ត ។

ត្បាល់កិនល្បីឈ្មោះ លេចឮកិត្តិយស ព្រោះកិនអង្ករ
មនុស្សម្នាពឹងពាក់ ស្មោះស្ម័គ្រអបអរ ទាក់ទងសាទរ
គាំទ្រតម្កើង ។

មិត្តភក្តិញាតិផៅ ត្បាល់ដៃល្បីពៅ កេរ្តិ៍ឈ្មោះខ្ពស់ឡើង
ចង្អេរកំព្រូង រីតរៃងថ្កុំថ្កើង វាសនាត្រចើង
ឡើងឫក្សរាសី ។

គេប្រើគេប្រាស់ រាប់រកខ្លាំងណាស់ ពុំមានសំចៃ
រាល់ល្ងាចយប់ព្រឹក កិនបុកវែងស្ទៃ គ្មានទំនេរដៃ
រងៀឥតអាក់ ។

ទេសកាលប្តូរផ្លាស់ ត្បាល់កិនកម្សត់ក្រាស់ យីអ៊ុនស្រុតធ្លាក់
គេប្រើម៉ាស៊ីន គេមានរោងចក្រ កិនរំរងទទាក់
សុទ្ធស្វ័យប្រវត្តិ ។

អង្រៃត្បាល់ក្បៀង ត្បាល់ដៃទ្វញឡើង ពេបស៊ែប្បបវៀចមាត់
បងអើយវាសនា ចារជាក់កំណត់ អោយផុតរលត់
នាទីយើងហោង ។

កញ្ជើកព្រៀង អង្រែងដងវែង ចង្អេរអុំផង
សោយសោកសង្រេង ក្ដែង១ជាម្ដង យំយែកកន្លង
ឥតក់កាយា ។

វាយរាប់ទំនុក ខំផ្ដុំផ្ដាំទុក អស់ជាតិខេមរា
សូមនឹកយើងផង សម័យដូនតា យើងយកអាសារ
ខេមរាជានិច្ច ។

អស់ពួកយើងខ្ញុំ ទោះបីតូចធំ បុរាណម្ដាមេ្ដច
តែយើងតស៊ូ ស្មារតីប្ដូរផ្ដាច់ បំរើភារកិច្ច
គ្រប់តម្រូវការ ។

សូមខ្មែរចាំចង ចារឹកយើងផង ទុកក្នុងសាវតារ
ថាពួកយើងខ្ញុំ ជួយបម្រើការ អោយជាតិខេមរា
រស់រានជីវិត ។

យើងស្លាប់តែកាយ ព្រលឹងឆើតឆាយ នៅតែរស់ពិត
រស់ក្នុងសុបិន រស់ក្នុងនិមិត្ត យើងនៅនែបនិត្យ
ជិតខ្មែរជានិច្ច ។

ដោយ **ម៉ៀច ប៉ុណ្ណ**

នៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ

# ត្រានិងផ្លិតមន្ត្រីសង្ឃ

ព្រះសង្ឃនាយក ឬសម្តេចព្រះសង្ឃនាយក, សម្តេចព្រះសង្ឃរាជ, និង មន្ត្រីសង្ឃទីរាជាគណៈ, ឋានានុក្រមគ្រប់ថ្នាក់ មានត្រានិងផ្លិតជាគ្រឿងសំគាល់ ដូចខាងក្រោមនេះ ៖

## ត្រាសម្តេចព្រះសង្ឃរាជ



ត្រូវធ្វើមានរូបប្រាសាទ នៅចំកណ្តាល ខាងស្តាំមានរូបផ្លិតស្រួច ខាងឆ្វេងមានថូទឹកកណ្តី មានក្បាច់ភ្ញីភ្លើងខាងៗ នៅគែមរឿជុំវិញមានក្បាច់ត្របកឈូក ។

## ត្រាព្រះរាជាគណៈ គ្រប់ថ្នាក់



ត្រូវធ្វើរូបផ្លិតស្រួច នៅចំកណ្តាល មានក្បាច់ភ្ញីភ្លើងខាងៗ នៅគែមរឿជុំវិញ មានក្បាច់ត្របកឈូក ។

# ត្រាមេគណ




ត្រូវធ្វើទំហំ 0,0៥៥ម ត្រូវធ្វើជាក្បាច់រូបផ្ចិតស្រួច មានក្បាច់ភ្ញីភ្លើងខាង១ នៅគែមរឿជុំវិញត្រូវធ្វើក្បាច់ត្របកឈូក នៅក្រោមរូបផ្ចិតត្រូវមានឆ្លាក់អក្សរខ្មែរសំគាល់ថាជា មេគណ ។

# ត្រាអនុគណ




ត្រូវធ្វើទំហំ 0,0៥៣ម ត្រូវធ្វើក្បាច់ជាផ្ចិតរូបឆែកជុំវិញ មានក្បាច់ភ្ញីភ្លើងខាង១ នៅគែមរឿជុំ-វិញ ត្រូវធ្វើក្បាច់ត្របកឈូក នៅក្រោមរូបផ្ចិតត្រូវមានឆ្លាក់អក្សរខ្មែរសំគាល់ថាជា អនុគណ ។

# ត្រាឋានានុក្រម

## ព្រះគ្រូ និងព្រះបាឡាត់

## ព្រះវិន័យធរ និងព្រះវិន័យធម្ម ឬព្រះធម្មធរ



ត្រូវធ្វើផ្ចិតមូលផែកជុំវិញចំកណ្តាល មានក្បាច់ភ្ញីភ្លើងខាង១ នៅគែមវៀជុំវិញ មានក្បាច់ត្របកឈូក ។ ។

# ត្រាព្រះសមុហ៍



ត្រូវធ្វើផ្ចិតមុខព្រហ្មចំកណ្តាល មានក្បាច់ភ្ញីភ្លើងខាង១ នៅគែមវៀជុំវិញ មានក្បាច់ត្របកឈូក ។

# ត្រាព្រះបាឡាត់គណ
# ព្រះវិន័យធរគណ និង ព្រះវិន័យធរអនុគណ

ត្រូវធ្វើទំហំ ០,០៥០ម ត្រូវធ្វើក្បាច់ជារូបផ្ចិតមូលនៃកជុំវិញ មានក្បាច់ភ្ញីភ្លើងខាងៗ នៅគែមរឿជុំវិញត្រូវធ្វើក្បាច់ត្របកឈូក នៅក្រោមរូបផ្ចិតត្រូវមានឆ្លាក់អក្សរខ្មែរ សំគាល់ថាជា បាឡាត់គណ វិន័យធរគណ ឬ វិន័យធរអនុគណ ។









## ត្រាព្រះសមុហ៍គណ និង ព្រះសមុហ៍អនុគណ

ត្រូវធ្វើទំហំ ០,០៤០ម ត្រូវធ្វើក្បាច់ជារូបផ្តិតមុខព្រហ្ម ដូចផ្តិតសម្រាប់សមុហ៍ របស់ព្រះរាជាគណៈទាំង ៤ ថ្នាក់ មានក្បាច់ភ្ញីភ្លើងខាងៗ នៅគែមវៀជុំវិញត្រូវមានក្បាច់ត្របកឈូក នៅក្រោមរូបផ្តិតត្រូវមានឆ្លាក់អក្សរខ្មែរសំគាល់ថាជា សមុហ៍គណ ឬ សមុហ៍អនុគណ ។







## ត្រាលេខាធិការគណ និង អនុលេខាធិការអនុគណ

ត្រូវធ្វើទំហំ ០,០៤០ម ត្រូវធ្វើក្បាច់ជារូបសីមា មានក្បាច់ភ្ញីភ្លើងខាងៗ នៅគែមវៀជុំវិញត្រូវធ្វើក្បាច់ត្របកឈូក នៅក្រោមរូបសីមាត្រូវមានឆ្លាក់អក្សរខ្មែរសំគាល់ថាជាលេខាធិការគណ និង អនុលេខាធិការអនុគណ ។






# ត្រាចៅអធិការ

ត្រូវធ្វើទំហំ ០,០៥០ម ត្រូវធ្វើក្បាច់ជាផ្លិតមុខព្រហ្ម " ផ្លិតរង " មានក្បាច់ភ្ញីភ្លើង ខាង១ នៅគែមវៀជុំវិញត្រូវធ្វើក្បាច់ត្របកឈូក នៅក្រោមរូបផ្លិតត្រូវមានឆ្លាក់អក្សរខ្មែរសំគាល់ថាជា ចៅអធិការ នាមវត្ត ឈ្មោះឃុំ ស្រុក និងខេត្ត ។






ផ្លិតសម្តេចព្រះសង្ឃរាជ
ពណ៌លឿង



## ផ្លិតព្រះរាជាគណៈ

- ថ្នាក់ឯក : ពណ៌ក្រហម
- ថ្នាក់ទោ : ពណ៌បៃតង
- ថ្នាក់ត្រី : ពណ៌ស្វាយ
- ថ្នាក់ចត្វា : ពណ៌ខៀវ





## ផ្លិតឋានានុក្រម

ព្រះគ្រូ ព្រះបាឡាត់ ព្រះវិន័យធរ ព្រះវិន័យធម្ម ឬព្រះធម្មធរ ត្រូវប្រើផ្លិតមូលនែកជុំវិញ ។ ឯព្រះសមុហ៍ ត្រូវប្រើផ្លិតមុខព្រហ្ម ។ ចំពោះពណ៌ ត្រូវធ្វើតាមថ្នាក់ព្រះរាជាគណៈដែលបានតែងតាំង ។

របៀបប្រើ : របៀបប្រើប្រាស់គ្រានិងផ្លិតយ៉ាងណាៗនោះ ខ្ញុំព្រះករុណា ខ្ញុំ ពុំអាចរៀបរាប់ក្នុងទីនេះបានទេ, ទុកឱកាសថ្វាយ ប្រគេន ជូន សម្តេចព្រះសង្ឃរាជ ឬមន្ត្រីសង្ឃជាន់ខ្ពស់ ឬក៏មន្ត្រីព្រះបរមរាជវាំង ដែលធ្លាប់ចាត់ចែងព្រះ

រាជពិធីការកន្លងមក រំលែណនាំផងចុះ ។

នៅទីនេះ, ខ្ញុំព្រះករុណា ខ្ញុំ សូមសរសេរតែពីរបៀបថ្វាយព្រះពរព្រះករុណាជាម្ចាស់ជីវិតតម្កល់លើត្បូង ក្នុងពេលចប់ពិធីចំរើនព្រះបរិត្ត ឬចប់ពិធីសត្ត-ប្បករណាភិធម្ម មានយ៉ាងនេះ :

ក្នុងពេលថ្វាយព្រះបរិត្ត ឬថ្វាយសត្តប្បករណាភិធម្ម, ព្រះសង្ឃពុំមានលើកផ្លិតបាំងទេ គឺព្រះហស្តគ្រប់អង្គត្រូវសំពះ ។ លុះចប់ហើយ ទើបមន្ត្រីសង្ឃជាន់ខ្ពស់មួយអង្គលើកផ្លិតឡើង មន្ត្រីសង្ឃឯទៀតៗ ក៏លើកផ្លិតឡើងតាមលំដាប់លំដោយ, ព្រះមហាថេរមួយអង្គខាត់ *យថា វារិវហា បូរា ... ។ ល ។ មណីជោតិ-រសោ យថា* មន្ត្រីសង្ឃទាំងអស់ទទួល *សព្វីតិយោ វិវជ្ជន្តុ ... អាយុ វណ្ណោ សុខំ ពលំ* (បីចប់), - រួចហើយ ព្រះមហាថេរដើមអាសន៍សូធ្យតែមួយអង្គឯងថា :

*អតិរេកវស្សសតំ ជីវតុ, អតិរេកវស្សសតំ ជីវតុ, អតិរេកវស្សសតំ ជីវតុ, ទីឃាយុកោ ហោតុ, អរោគោ ហោតុ, សុខិតោ ហោតុ មហារាជា ;*

*សិទ្ធិកិច្ចំ, សិទ្ធិកម្មំ, សិទ្ធិលាភោ ជយោ និច្ចំ បរមមហារាជវរស្ស ភវតុ សព្វទា សូមថ្វាយព្រះពរ !*

ព្រះសង្ឃទាំងអស់ទទួលសូធ្យ : *ភវតុ សព្វមង្គលំ ...* បីចប់ រួចហើយព្រះមហាថេរដដែលថ្វាយព្រះពរថា :

សូមថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័នឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរត្ន និករោត្តម ធម្មិកមហារាជាធិរាជ បរម-នាថ បរមបពិត្រ ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាម្ចាស់ជីវិត (*) សូមថ្វាយព្រះពរ ! សូមថ្វាយព្រះពរលា !

***

---

(*) ព្រះសង្ឃប្រើពាក្យថា « ជាម្ចាស់ជីវិត » មិនប្រើពាក្យថា « តម្កល់លើត្បូង » ទេ ។

# ពិធីប្រគល់និងទទួលសៀវភៅ អំណោយរបស់អង្គការ WCRP




សម្តេចព្រះមង្គលទេពាចារ្យ អ៊ុំ ស៊ុម ទទួលសៀវភៅពីគណៈប្រតិភូ WCRP

ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ១៩៩៨ វេលាម៉ោង ៨ ព្រឹក ក្រសួងធម្មការ និងសាសនា បានរៀបចំពិធីប្រគល់ និងទទួលសៀវភៅបោះពុម្ព ឆ្នាំ១៩៩៧ អំណោយរបស់ក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនានិងសន្តិភាព (WCRP) ។

ចូលរួមជាអធិបតីក្នុងឱកាសនោះ ខាងជប៉ុន មានព្រះតេជព្រះគុណ យ៉ាម៉ាដា ប្រធានគណៈប្រតិភូ WCRP លោក តេហ៊្សុយកា កូជី នាយកអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ប្រចាំក្រុងភ្នំពេញ, ខាងកម្ពុជា មានសម្តេចព្រះមង្គលទេពាចារ្យ អ៊ុំ ស៊ុម អគ្គាធិការនៃពុទ្ធិកសិក្សា, ឯកឧត្តម ហៀន វណ្ណារ័ត្ន រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា, ឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការ, លោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការនិងសាសនា ។ ក្រៅពីនេះ គេឃើញមានសមណ-

សិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងមន្ត្រីរាការក្នុងក្រសួងធម្មការ និងសាសនា និមន្ត-អញ្ជើញចូលរួមយ៉ាងកុះករ ។

មានមតិក្នុងឱកាសនោះ, លោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ បានរៀបរាប់អោយដឹងថា ៖

- សៀវភៅជាអំណោយរបស់អង្គការ WCRP ឆ្នាំ ១៩៩៧ ដែលនឹងត្រូវប្រគល់ជានិមិត្តរូប នាឱកាសនេះ រួមមានសៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅ ១០ ចំណងជើង ចំនួន ២៨.៥០០ ច្បាប់ និងទស្សនាវដ្ដីកម្ពុជសុរិយា ៤ លេខ ចំនួន ១២.០០០ ច្បាប់ ។

- អង្គការដែលបានចូលមកជួយពុទ្ធសាសនបណ្ឌិត្យមុនគេ ចាប់តាំងពីវិជ្ជាស្ថាននេះ ត្រូវបានរៀបចំអោយដំណើរការឡើងវិញ នៅក្នុងឆ្នាំ ១៩៩២ គឺមានអង្គការជំនួយសូត្តស៊ូជប៉ុន (JSRC), ក្រុមប្រឹក្សាពិភពលោកដើម្បីសាសនា និងសន្តិភាព (WCRP), និងអង្គការ រិស្សូ កូសី-កៃ (RKK) ជាពិសេស WCRP បានជួយបោះពុម្ពសៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅ ៣៦ ចំណងជើង មានចំនួន ២២.០៥០០ ច្បាប់ និងទស្សនាវដ្ដីកម្ពុជសុរិយា ចេញផ្សាយប្រចាំត្រីមាស ពីឆ្នាំ១៩៩៤ មានចំនួន ៦៤.០០០ ច្បាប់ ។ ក្រៅពីនេះ WCRP បានជួយម៉ាស៊ីនកុំព្យូទ័រ, ព្រិនធើរ ឡេស៊ើរ, ម៉ាស៊ីនភ្លើង, និងរថយន្ត ។

ថ្លែងស្វាគមន៍ក្នុងឱកាសនោះ ឯកឧត្តម ហៀន វណ្ណារ័ត្ន បានធ្វើការកត់សំគាល់ថា សៀវភៅដែលបានបោះពុម្ពរួចហើយ ពិតមែនតែពុំទាន់គ្រប់គ្រាន់តាមសេចក្ដីត្រូវការ ប៉ុន្ដែ បានរួមវិភាគទានយ៉ាងធំធេងដល់ការស្រោចស្រង់អោយរស់ឡើងវិញនូវវប្បធម៌ពុទ្ធសាសនា និងវប្បធម៌ខ្មែរ នៅកម្ពុជា និងបានរួមចំណែកជាពិសេសដល់ការកសាងធន់ធានមនុស្ស តាមរយៈពុទ្ធសាសនា ។ ឯកឧត្ដមបានថ្លែងអំណរគុណ និងដឹងគុណដ៏ជ្រាលជ្រៅ ដោយពុំមានថ្ងៃភ្លេច ចំពោះអង្គការជំនួយ

ស្មាលពីមន្ត្រីសង្ឃខេត្ត ស្រុក, ពីមន្ត្រីរាជការក្នុងមន្ទីរធម្មការខេត្ត ស្រុក និង ពុទ្ធបរិស័ទដ៏ច្រើនកុះករ ។



គណៈប្រតិភូ WCRP ប្រគេនសៀវភៅចំពោះព្រះសង្ឃ



គណៈប្រតិភូ WCRP ទស្សនាសាខាបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ នៅក្នុងបរិវេណវត្តសីហរតនារាម ក្រុងតាកែវ ដែលនៅទីនោះ គណៈប្រតិភូបានសំដែងការសប្បាយរីករាយ ដោយឃើញការរៀបចំទុកដាក់សៀវភៅបានល្អ ។

# សេចក្តីកែតម្រូវ :

អត្ថបទកំណាព្យ « បទថយក្រោយ » ដែលបានចុះផ្សាយក្នុងទស្សនាវដ្តី «កម្ពុជសុរិយា» លេខ ៤ ឆ្នាំ ១៩៩៧ ទំព័រ ៨២ មានការភ័ន្តច្រឡំត្រង់គំនូសសញ្ញានៃបទថយក្រោយទី២ , សូមមេត្តាកែតម្រូវ ។

គំនូសសញ្ញាលេខ និងអក្សរ បទថយក្រោយទី១ រៀងគ្នាដូចនេះ គឺ :

1 2 3 4 5 6 7 ក ខ គ ឃ ង ច ឆ

0 0 0 0 0 0 0 0 0 0 0 0 0 0

គំនូសសញ្ញាអក្សរ និងលេខ បទថយក្រោយទី២

1 2 3 4 5 6 7 ក ខ គ ឃ ង ច ឆ

0 0 0 0 0 0 0 0 0 0 0 0 0 0

សូមកែតម្រូវដូចខាងក្រោមនេះវិញ គឺ :

ឆ ច ង ឃ គ ខ ក 7 6 5 4 3 2 1

0 0 0 0 0 0 0 0 0 0 0 0 0 0

*សូមអរគុណ,*

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ទិដ្ឋភាពនៃអគារថ្មីរបស់ពុទ្ធសាសនបណ្ឌិត្យ ( សូមអានអត្ថបទ នៅទំព័រ ៩៥ )

ឆ្នាំទី ៥២ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស ២៥៤១ គ.ស ១៩៩៨

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ


ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ណរក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました

この本が、日本の宗教者とカンボジアの人々との友情のきずなとなりカンボジアの宗教と文化の発展に貢献できれば幸いです

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន ( JSRC ) ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាព រវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្ប-ធមិ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## Acknowledgement

The *Kambuja Suriya Magazine* is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

I. អក្សរសិល្ប៍ពុទ្ធសាសនា
- ធម៌គ្រឹះនៃពុទ្ធសាសនា - ត ( ឈិន អៀម ) ........ ១
- ព្រះពុទ្ធសាសនា គឺជាគ្រឹះនៃការប្រតិបត្តិ សំរាប់ការរស់នៅទាំងអស់គ្នា ( សម្ដេចព្រះមហាឃោសានន្ទ ) ........ ២៦

II. អក្សរសាស្ត្រទូទៅ
- វចនស័ព្ទវិទ្យានៃភាសាខ្មែរបច្ចុប្បន្ន - ត (បណ្ឌិត ឡុង សៀម) ........ ៣១
- សិលាចារឹកខ្មែរ ( ហាម ឆាយលី ) ........ ៤៩
- ព្រះពុទ្ធសាសនា និងសង្គមខ្មែរ ( សុខ សេង ) ........ ៦២
- អំពីធ្លះ ( មៀច ប៉ុណ្ណ ) ........ ៦៩
- សេវនាសេវនតា ការគួរសេពគប់និងមិនគួរសេពគប់ ........ ៧២
- បទគោព័ទ្ធស្ទឹង ( ធន់ ហ៊ិន ) ........ ៧៦
- រឿងចៅល្ងង់សព្វជាតិ ( ធន់ ហ៊ិន ) ........ ៧៨
- មើលបន្ទាយស្រី ( ខៀវបញ្ញា វុឌ្ឍ ) ........ ៨២
- អំពីក្រ ៥ យ៉ាង ( សម្ដេចព្រះសង្ឃរាជ ជួន ណាត ) ........ ៨៤
- អបាយមុខ ( សម្ដេចព្រះសង្ឃរាជ ជួន ណាត ) ........ ៨៧

III. កំណត់ និង ប្រវត្តិការណ៍
- ពិធីសម្ពោធអគារពុទ្ធសាសនបណ្ឌិត្យ ........ ៨៩
- សំណង់អគារពុទ្ធសាសនបណ្ឌិត្យ ........ ៩៥
- ត្រូវកសាងអោយបាននូវសាមគ្គីភាពក្នុងជួរពុទ្ធសាសនិក ........ ៩៨
- សេចក្ដីអំពាវនាវរបស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៧ .... ១០២
- មន្ត្រីសង្ឃទីរាជាគណៈ នៃគណៈមហានិកាយ ........ ១០៦

# ធម៌គ្រឹះ នៃ ពុទ្ធសាសនា (ត)

ដោយ លោក ភីទ័រ ដ. សន្តិនា
( By Peter D. Santina )
បកប្រែដោយ : **ឈន អៀម**

## ( VI )

## សមាធិ

( ការធ្វើចិត្តអោយរីកចំរើន )

ប្រធានបទរបស់យើងថ្ងៃនេះ គឺស្តីពីការធ្វើចិត្តអោយរីកចំរើន ។ យើងនឹងពិនិត្យមើលជំហានទាំងឡាយ នៃអរិយដ្ឋង្គិកមគ្គ ដែលបានចែកចេញជាក្រុមដោយមានឈ្មោះថា សមាធិ ឬការធ្វើអោយចិត្តរីកចំរើន ។ យើងបាននិយាយរួចហើយថា តើជំហានទាំងឡាយនៃមាគ៌ា (មគ្គៈ) មានអន្តរសម្ព័ន្ធគ្នាយ៉ាងណា, ហើយនៅក្នុងបរិបទនេះ វាមានអត្ថប្រយោជន៍សំខាន់យ៉ាងណា ដើម្បីយល់នូវទីតាំងនៃការអភិវឌ្ឍន៍ចិត្ត (សមាធិ) ពីព្រោះ វាឋិតនៅកណ្តាលរវាងសីល និងបញ្ញា ដូចនេះ, សមាធិ មានទំនាក់ទំនង និងមានសារសំខាន់សម្រាប់សីលផង សម្រាប់បញ្ញាផង ។ លោកអ្នកអាចសួរថា ព្រោះហេតុអ្វីបានជាយ៉ាងនេះ ។ តាមពិត មានពេលខ្លះ គេបាននិយាយប្រាប់ខ្ញុំអំពីសេចក្តីត្រូវការដើម្បីធ្វើសមាធិ ។ ដោយហេតុថា បើគេគ្រាន់តែប្រតិបត្តិតាមសីល សិក្ខាបទទាំងឡាយ, តើប៉ុណ្ណឹងគ្រប់គ្រាន់ដើម្បីដឹកនាំជីវិតអោយឋិតក្នុងសីលបានឬទេ ?

ខ្ញុំគិតថាមានចម្លើយច្រើនចំពោះសំនួរនេះ ។ ដំបូងបំផុត, នៅក្នុងពុទ្ធ-សាសនា មិនមែនមានតែគោលដៅមួយប៉ុណ្ណោះទេ ។ ក្រៅពីគោលដៅចង់បានសេចក្តីសុខ និងសំណាងល្អ, នៅមានគោលដៅចង់បានសេរីភាពផងដែរ ។ ប្រសិនបើគេចង់បានសំរេចគោលដៅនៃសេរីភាព, មាគ៌ាតែមួយដែលអាចសំរេចបានគឺតាមរយៈបញ្ញា ។ ហើយដើម្បីអោយសំរេចបាននូវបញ្ញា គេត្រូវធ្វើចិត្តអោយបរិសុទ្ធ ធ្វើចិត្តអោយរីកចំរើនតាមរយៈសមាធិ ។ សូម្បីតែការប្រតិបត្តិសីល, សម្រាប់ការរក្សាសីល សិក្ខាបទទាំងឡាយ ក៏អាចធ្វើចិត្តអោយរីកចំរើនជាការចាំបាច់ដែរ ។ ព្រោះហេតុអ្វី ? ពិព្រោះ វាមានការងាយស្រួលជាង ដើម្បីប្រព្រឹត្តតាមសិក្ខាបទទាំងឡាយនៃសីល កាលណាអ្វីៗទាំងអស់ប្រព្រឹត្តទៅល្អ ។ ប្រសិនបើយើងមានការងារល្អ, ប្រសិនបើយើងរស់នៅក្នុងសង្គមមួយមានស្ថិរភាព, ប្រសិនបើយើងមានប្រាក់គ្រប់គ្រាន់ ដើម្បីចិញ្ចឹមខ្លួនយើង និងគ្រួសារយើង, វាមានការងាយស្រួលជាងដើម្បីកាន់តាមសិក្ខាបទទាំងឡាយ ។ ប៉ុន្តែ កាលណាយើងធ្លាក់ទៅក្នុងកាលៈទេសៈព្រួយកង្វល់, អសន្តិសុខ, យកជាឧទាហរណ៍ កាលណាយើងបាត់ការងារធ្វើ, កាលណាយើងធ្លាក់ខ្លួនក្នុងស្ថានភាពដែលអំពើព្រៃផ្សៃ ឥតច្បាប់ទម្លាប់គ្រប់ដណ្តប់, នេះគឺជាចំណុចដែលការប្រព្រឹត្តកាន់សីល ឋិតក្រោមការគំរាមកំហែង ។ នៅក្នុងកាលៈទេសៈបែបនេះ, ប្រការតែមួយគត់ ដែលអាចរក្សាការប្រតិបត្តិសីល របស់យើងបាន គឺការអភិវឌ្ឍន៍ចិត្ត, ការពង្រឹងចិត្ត និងការគ្រប់គ្រងចិត្តអោយបាន ។ តាមគន្លងនេះ, ការអភិវឌ្ឍន៍ចិត្ត (សមាធិ) មួយផ្នែក ប្រើសម្រាប់ការថែរក្សា ប្រតិ-បត្តិសីលរបស់យើង, មួយផ្នែកទៀត ប្រើសម្រាប់រៀបចំចិត្តអោយមើលឃើញហេតុការណ៍ទាំងឡាយជាយថាភូត, រៀបចំចិត្តអោយចាប់យកបញ្ញា ដែលនឹងបើកទ្វារទៅរកសេរីភាព, ទៅរកការត្រាស់ដឹង ។ ដោយហេតុនេះ ការអភិវឌ្ឍន៍ចិត្ត ឬសមាធិ មានតួនាទីសំខាន់យ៉ាងក្រៃលែង ក្នុងការប្រតិបត្តិតាមអរិយដ្ឋង្គិកមគ្គ ។

ការផ្តល់តម្លៃទៅលើការអភិវឌ្ឍន៍ចិត្ត ឬសមាធិ មិនមែនជាការចម្លែកទេ បើយើងរំលឹកឡើងវិញនូវសារសំខាន់នៃតួនាទីរបស់ចិត្តនៅក្នុងការពិសោធន៍ក្នុងពុទ្ធសាសនា ។ ខ្ញុំនឹកឃើញកាលពីពីរសប្តាហ៍កន្លងទៅ មានមនុស្សម្នាក់នៅក្នុងអង្គប្រជុំបាននិយាយថា ចិត្តហាក់ដូចជាសភាវធម៌មួយដ៏សំខាន់បំផុត ចំពោះជំហានទាំងឡាយរបស់អរិយដ្ឋង្គិកមគ្គ ។ ខ្ញុំបានកត់សម្គាល់ថា នេះជាការសន្និដ្ឋានមួយមានអត្ថន័យពេកណាស់ ហើយត្រឹមត្រូវទៀត ។ យើងរកឃើញយ៉ាងច្បាស់លាស់ណាស់នូវសេចក្តីសន្និដ្ឋាននេះនៅក្នុងពុទ្ធវចនៈ ។ ព្រះពុទ្ធទ្រង់បានសំដែងថា ចិត្តគឺជាប្រភពនៃសភាវធម៌ទាំងអស់, សភាវធម៌ទាំងអស់កើតចេញពីចិត្ត ។ គេនិយាយផងដែរថា ចិត្តគឺជាប្រភពនៃគុណធម៌ទាំងអស់, នៃគុណសម្បត្តិទាំងអស់ ។ ដើម្បីអោយសំរេចបានគុណធម៌ទាំងនោះ, គេត្រូវធ្វើចិត្តអោយស្ថិតក្នុងវិន័យ ។ ចិត្តគឺជាកូនសោរសម្រាប់កែប្រែធម្មជាតិ (ចរិត) នៃបទពិសោធន៍របស់យើង ។ មានម្តងនោះ គេនិយាយថា ប្រសិនបើយើងក្រាលគ្របផ្ទៃផែនដីទាំងមូល ដើម្បីការពារជើងរបស់យើងកុំអោយដាច់រលាត់ដោយសារដង្គត់ និងថ្ម, ប្រសិនបើយើងត្រូវក្រាលគ្របផ្ទៃផែនដីទាំងមូលដោយស្បែក, នេះគឺជាការងារមួយដ៏លំបាកលំបិនក្រៃលែង ។ ប៉ុន្តែបើគ្រាន់តែគ្របត្រឹមតែផ្ទៃបាតជើងយើងដោយស្បែកប៉ុណ្ណោះ, វាហាក់ដូចជាផ្ទៃផែនដីទាំងមូល ត្រូវបានក្រាលគ្របដោយស្បែកដែរ ។ តាមគន្លងដដែលនេះ ប្រសិនបើយើងត្រូវសំអាតលោកធាតុទាំងមូលអោយអស់លោភៈ, ទោសៈ និងមោហៈ, វាជាការងារមួយដ៏លំបាកពេកណាស់ ។ វាងាយបំផុត បើគ្រាន់តែសំអាតចិត្តរបស់យើងផ្ទាល់អោយប្រាសចាកលោភៈ, ទោសៈ និងមោហៈ, វាហាក់ដូចជាលោកធាតុទាំងមូល ត្រូវបានជម្រះអោយបរិសុទ្ធចាកកិលេសជាគ្រឿងសៅហ្មងទាំងនោះទៅហើយ ។ ព្រោះហេតុនោះហើយបានជា នៅក្នុងពុទ្ធសាសនា យើងផ្តោតការយកចិត្តទុកដាក់លើចិត្ត ទុកចិត្តដូចជាគន្លឹះដើម្បីសម្រេចអោយបាន នូវការប្រែប្រួលមួយ

នៅក្នុងមាគ៌ាដែលយើងពិសោធការរស់នៅ, នៅក្នុងមាគ៌ាដែលយើងមានទំនាក់ទំនងជាមួយមនុស្សដទៃទៀត ។

ថ្មីៗនេះ សារសំខាន់នៃចិត្ត ត្រូវបានអ្នកវិទ្យាសាស្ត្រ, ចិត្តវិទូ, និងវេជ្ជបណ្ឌិតទទួលស្គាល់ ។ ក្នុងចំណោមអស់លោក គង់មានលោកអ្នកខ្លះ អាចដឹងពីបច្ចេកទេសខ្លះៗ ដែលវេជ្ជបណ្ឌិតក្នុងប្រទេសខាងលិចកំពុងប្រើប្រាស់ ។ វេជ្ជបណ្ឌិតមួយចំនួន បានប្រើប្រកបដោយជោគជ័យនូវបច្ចេកទេស ដូចគ្នានឹងបច្ចេកទេសធ្វើសមាធិ ដើម្បីជួយអ្នកជំងឺអោយជំនះបានលើជំងឺ និងវិបត្តិរ៉ាំរ៉ៃ ។ នេះគឺជាហេតុការណ៍ ដែលគេទទួលស្គាល់សព្វថ្ងៃនៅក្នុងរង្វង់វិជ្ជាជីវៈពេទ្យ ។ ពេលកន្លងទៅមិនយូរប៉ុន្មាន, គេបាននិយាយប្រាប់ខ្ញុំអំពីករណីមួយ ទាក់ទងនឹងភរិយារបស់លោកសាស្ត្រាចារ្យម្នាក់ ។ គ្រូពេទ្យប្រចាំគ្រួសាររបស់គេ បានចាប់ផ្តើមប្រើបច្ចេកទេសធ្វើសមាធិ ដើម្បីព្យាបាលអ្នកជំងឺដែលរងការឈឺចាប់បែបណាមួយនោះ ។ គេបានប្រាប់ស្ត្រីនោះថា គាត់ត្រូវទទួលការវះកាត់ដើម្បីព្យាបាលជងឺនោះ ។ ជាជំនួសការវះកាត់ គេបានស្នើអោយគាត់អនុវត្តបច្ចេកទេសសមាធិនេះវិញមួយថ្ងៃពីរដង អស់រយៈពេលពីរខែ ។ ដោយបានអនុវត្តបច្ចេកទេសនេះ គេបានឃើញថា គាត់ពុំចាំបាច់ទទួលការវះកាត់ទេ ។ យើងអាចយល់បានទាំងអស់គ្នាហើយ នូវអានុភាពនៃចិត្តមកលើអាកប្បកិរិយារបស់យើង ដោយប្រមើលមើលនូវបទពិសោធន៍ផ្ទាល់របស់យើង ។ យើងដឹងថាម្តងម្កាល យើងមានអារម្មណ៍រីករាយ ហើយមានអាកប្បកិរិយាវិជ្ជមានចំពោះសកម្មភាពរបស់យើងយ៉ាងណា, ហើយកាលណាអារម្មណ៍បែបនេះកើតមានឡើង យើងមានថាមពលខ្លាំងក្លា, យើងឆ្លើយតប និងមានសមត្ថភាពបំពេញសកម្មភាពក្នុងបែបបទយ៉ាងល្អប្រសើរ ។ នៅឱកាសខ្លះវិញ កាលណាចិត្តរបស់យើងចង្អៀតចង្អល់ និងមានទុក្ខព្រួយ យើងឃើញថា យើងមិនអាចសូម្បីធ្វើការងារដ៏សាមញ្ញមួយអោយបានសម្រេចផង ។ តាមគន្លងនេះ យើងអាចឃើញ

ថា តើចិត្តមានសារសំខាន់យ៉ាងណានៅក្នុងគ្រប់វិស័យនៃសកម្មភាព ។

មានជំហានបីយ៉ាងរបស់អរិយដ្ឋង្គិកមគ្គ ត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមសមាធិនេះ, ហើយជំហានទាំងបីនោះគឺ សម្មាវាយាមៈ, សម្មាសតិ និងសម្មាសមាធិ។ ជំហានទាំងបីនេះរួមគ្នាជំរុញ និងជួយធ្វើអោយគេមានទំនុកចិត្តលើខ្លួនគេ, អោយចេះប្រុងប្រយ័ត្ន និងស្ងប់ស្ងាត់ ។ ដំបូងបង្អស់, ក្នុងន័យទូទៅបំផុត សម្មាវាយាមៈមានន័យថា ការបណ្តុះអាកប្បកិរិយាវិជ្ជមាន ចំពោះសកម្មភាពទាំងឡាយរបស់យើង ។ យើងអាចហៅសម្មាវាយាមៈថា សម្រេចចិត្តខ្លាំងក្លាក៏បាន ។ វាមានន័យថា ការធ្វើការងាររបស់យើងប្រកបដោយថាមពល, ប្រកបដោយឆន្ទៈ ដើម្បីធ្វើអោយការងារនោះៗបានសម្រេច ។ គេបានថែងនៅក្នុងអត្ថបទមួយថា យើងត្រូវចាប់ផ្តើមការងាររបស់យើងតាមលំនាំដីរី ដែលចុះទៅក្នុងបឹងមួយត្រជាក់ ក្នុងអំឡុងពេលកំដៅថ្ងៃត្រង់ ។ ដោយមានការខិតខំបែបនេះ, ពេលនោះ យើងអាចសំរេចជោគជ័យបាន នៅក្នុងការងារអ្វីក៏ដោយ ដែលយើងដាក់ផែនការធ្វើ, ទោះជាក្នុងមុខរបររបស់យើង ក្នុងការសិក្សារបស់យើង ឬក្នុងការប្រតិបត្តិធម៌ ។ ក្នុងន័យនេះ, ការខិតខំមានទាក់ទងទៅនឹងទំនុកចិត្តផងដែរ ។ វាជាការអនុវត្តជាក់ស្តែងនៃទំនុកចិត្ត ។ ប្រសិនបើយើងអាក់ខាន មិនបានដាក់ការខិតខំទៅក្នុងការងារអ្វីមួយដែលយើងធ្វើទេ យើងមិនអាចសង្ឃឹមទទួលបានជោគជ័យទេ ។ ប៉ុន្តែ ការខិតខំត្រូវឋិតក្រោមការត្រួតពិនិត្យ, ត្រូវមានតុល្យភាព, ហើយក្នុងទីនេះ យើងអាចរំលឹកឡើងវិញ នូវអ្វីដែលយើងបាននិយាយទាក់ទងនឹងមជ្ឈិមបដិបទា ឬមជ្ឈិមមាគ៌, ទាក់ទងនឹងខ្សែពិណ គឺខ្សែរឹតតឹងពេក និងខ្សែរឹតធូរពេក ។ ដូច្នេះ ការខិតខំ មិនគប្បីក្លាយទៅជាតឹងហួសជ្រុលពេក, ហើយដូចគ្នាដែរ ការខិតខំ មិនត្រូវក្លាយជាធូររលុងពេក, មិនត្រូវបានគេបោះបង់ចោលឡើយ ។ នេះគឺអ្វីដែលយើងសំដៅដល់ សម្មាវាយាមៈពោលគឺ ការតាំងចិត្តមួយដែលស្ថិតក្រោមការត្រួតពិនិត្យ, ដែលមានឋិតថេរ ជាប់

លាប់, ដែលប្រកបដោយសម្រើបចិត្តខ្លាំងក្លា ហើយរីករាយ ។

សម្មាវាយាមៈ ត្រូវបានគេកំណត់ន័យថា មានបួនយ៉ាង ។ សម្មាវាយាមៈ គឺជាការខិតខំរារាំងគំនិតអកុសល កុំអោយកើតឡើង ។ សម្មាវាយាមៈ គឺជាការខិតខំកំចាត់ចោលគំនិតអកុសល ពេលណាវាបានកើតឡើងហើយ ។ សម្មាវាយាមៈ គឺជាការខិតខំបណ្តុះគំនិតជាកុសលអោយកើតមានឡើង ។ សម្មាវាយាមៈ គឺជាការខិតខំទ្រទ្រង់គំនិតជាកុសលអោយនៅឋិតថេរ ។ និយមន័យចុងក្រោយនេះមានសារៈសំខាន់ ជាពិសេស ពិព្រោះ វាមានករណីបែបនេះជាញឹកញយដែលបង្ហាញថា សូម្បីយើងបានសំរេចជោគជ័យក្នុងការបណ្តុះបណ្តាលអាកប្បកិរិយាជាកុសល អោយកើតឡើងហើយក៏ដោយ, ក៏អាកប្បកិរិយាទាំងនោះ ច្រើនតែមានអាយុខ្លី ។ រវាងគ្នានិងគ្នា, ទិដ្ឋភាពទាំងបួនយ៉ាងនេះរបស់សម្មាវាយាមៈជះឥទ្ធិពលរបស់ខ្លួន មកលើសភាវធម៌ផ្លូវចិត្ត ដោយធ្វើយ៉ាងណា កាត់បន្ថយអោយបាន និងលុបបំបាត់ជាយថាហេតុ នូវសភាវធម៌ផ្លូវចិត្តជាអកុសលមួយចំនួន ដែលយើងបានទ្រទ្រង់ទុកនៅក្នុងចិត្តរបស់យើង និងដើម្បីបង្កើន ហើយស្ថាបនាអោយរឹងមាំ នូវគំនិតជាកុសលទាំងឡាយ ទុកដូចជាផ្នែករួមពីធម្មជាតិ នៃសភាវធម៌ផ្លូវចិត្តរបស់យើង ។

ជំហានទីពីរ របស់អរិយដ្ឋង្គិកមគ្គ ដែលត្រូវបានបញ្ចូលក្នុងក្រុមសមាធិ (ការអភិវឌ្ឍន៍ចិត្ត) គឺសម្មាសតិ ។ សម្មាសតិ មានសារវន្តណាស់, សូម្បីនៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើងក៏ដោយ ។ ពាក្យប្រៀនប្រដៅរបស់ពុទ្ធសាសនានេះ, តាមការណ៍ពិត ខ្ញុំហ៊ាននិយាយថា ពាក្យទូន្មានប្រៀនប្រដៅទាំងអស់ របស់ពុទ្ធសាសនាអាចពន្យល់បាន, អាចលើកជាឧទាហរណ៍ភ្ជាប់ទៅនឹងស្ថានភាពទាំងឡាយដែលមាននៅក្នុងជីវភាពរាល់ថ្ងៃ, ដែលយើងទាំងអស់គ្នាធ្លាប់ដឹង ធ្លាប់ស្គាល់ ។ ជាការណ៍ជាក់ស្តែង ប្រសិនបើលោកអ្នកពិនិត្យមើលពាក្យប្រៀនប្រដៅផ្ទាល់ របស់ព្រះពុទ្ធ, លោកអ្នកនឹងឃើញថា ព្រះអង្គតែងប្រើឧទាហរណ៍ជាដរាប, ជាឧទាហរណ៍

ដែលសវនិកជនរបស់ព្រះអង្គ (his audience) ធ្លាប់ស្គាល់ ធ្លាប់ដឹង នៅពេលណាព្រះអង្គបង្រៀនព្រះធម៌ ។ ដូច្នេះ នៅក្នុងទីនេះដែរ ចំពោះសតិ, យើងអាចធ្វើបានល្អ ដោយពិនិត្យមើលសារសំខាន់នៃសតិ នៅក្នុងសកម្មភាពលោកីយធម្មតារបស់យើង ។ សតិ គឺជាការភ្ញាក់រលឹក ឬការប្រុងប្រយ័ត្ន, ចៀសវាងសភាវៈនៃចិត្តរាយមាយ និងសាំញ៉ាំ ។ វាអាចនឹងមានគ្រោះថ្នាក់តិចតួច ប្រសិនបើមនុស្សគ្រប់រូបមានសតិប្រុងប្រយ័ត្ន ។ ដូច្នេះ បើទោះជាគេកំពុងបើកបររថយន្ត, ឬកំពុងដើរឆ្លងកាត់ផ្លូវមានចរាចរណ៍មមាញឹក, ឬកំពុងគិតគូរបញ្ជីគណនេយ្យ, អ្វីក៏ដោយ ដែលគេកំពុងធ្វើ, ការងារនោះនឹងត្រូវបានធ្វើទៅប្រកបដោយប្រសិទ្ធភាព ប្រសិនបើគេមានសតិប្រុងប្រយ័ត្ន និងភ្ញាក់រលឹក ។ វានឹងជួយបង្កើនឋាមភាព, ផលិតភាពរបស់គេ, ហើយដូចគ្នានេះដែរ វានឹងកាត់បន្ថយគ្រោះថ្នាក់មួយចំនួន ដែលកើតឡើងបណ្ដាលមកពីខ្វះការប្រុងប្រយ័ត្ន, ពោលគឺ បណ្ដាលមកពីការខ្វះសតិភ្ញាក់រលឹក ។

និយាយដោយឡែក, ចំពោះការប្រតិបត្តិព្រះធម៌ សតិដើរតួដូចជាខ្សែបង្ហៀរត្រួតមើលចិត្តរបស់យើង ។ ក្នុងន័យនេះ ប្រសិនបើយើងពិចារណា ថាតើចិត្តរបស់យើងតាមធម្មតាប្រព្រឹត្តទៅយ៉ាងដូម្ដេច, យើងអាចឃើញនូវការចាំបាច់អោយមានខ្សែបង្ហៀរ ពោលគឺ ការត្រួតពិនិត្យមកលើចិត្តរបស់យើង ។ មួយរយៈពេលកន្លងទៅ, មានខ្យល់បក់ខ្លាំងមួយរឹង បណ្ដាលអោយបង្អួចមួយខាងនេះនៅខាងស្ដាំខ្ញុំ បោកឮផាំង ។ ខ្ញុំជឿថា ភាគច្រើននៃចិត្តរបស់យើងភ្លាមនោះ ផ្ដោតទៅលើសូរនោះ ។ ដូចគ្នានេះដែរ នៅស្ទើរតែគ្រប់ខណៈនៃជីវិតរបស់យើង, ចិត្តរបស់យើង កំពុងតែរត់តាមកម្មវត្ថុទាំងឡាយនៃវិញ្ញាណ ។ ចិត្តរបស់យើងមិនដែលបានតម្រង់ឆ្ពោះតែវត្ថុមួយ ឬនៅស្ងៀមទេ ។ កម្មវត្ថុទាំងឡាយនៃវិញ្ញាណ អាចជាសូរសំឡេង ឬអាចជារូបភាពមើលឃើញ ។ នៅពេលលោកអ្នកបើកបរតាមផ្លូវថ្នល់, ភ្នែករបស់លោកអ្នក អាចត្រូវបានផ្ដោតជាប់ទៅលើរូបភាពផ្សាយពាណិជ្ជកម្ម

ដ៏ជាទីទាក់ទាញអារម្មណ៍, ចិត្តរបស់លោកអ្នកនឹងត្រូវបានទាក់ទាញទៅរករូបភាពផ្សាយពាណិជ្ជកម្មនោះ ។ កាលណាលោក អ្នកធុំក្លិនទឹកអប់របស់អ្នកណាម្នាក់, ចិត្តរបស់លោកអ្នក នឹងក្លាយជាចិត្តជាប់ជំពាក់ក្នុងកម្មវត្ថុនោះ ។ ទាំងអស់នេះ គឺជាហេតុទាំងឡាយនៃសេចក្តីរាយមាយ ។ ដូច្នេះ ដើម្បីត្រួតត្រា បន្ថយអោយតិចចុះជាអប្បបរមា នូវសេចក្តីរាយមាយនេះ, យើងត្រូវការអោយមានឆ្នាំបែបណាមួយដែលអាចឃុំគ្រងចិត្តរបស់យើង កុំអោយក្លាយទៅជាជំពាក់វាក់វ័ណ្ឌជាមួយកម្មវត្ថុនៃវិញ្ញាណ, គឺកុំអោយក្លាយទៅជាជំពាក់វាក់វ័ណ្ឌនៅក្នុងគំនិតជាអកុសល ។ ឆ្នាំនេះគឺសតិ ។ មានពេលមួយនោះ ព្រះពុទ្ធទ្រង់បាននិទានរឿងព្រេងមួយ ស្តីពីអ្នកលេងសៀកពីរនាក់ - គ្រូ និងសិស្ស ។ នាឱកាសមួយនោះ គ្រូបាននិយាយទៅកាន់សិស្សថា « ឯងជួយការពារអញ, ហើយអញនឹងជួយការពារឯងវិញ ។ តាមដំណើរនេះ, យើងនឹងសំដែងល្បិចរបស់យើង ហើយចុះមកក្រោមវិញដោយសុវត្ថិភាព » ។ ប៉ុន្តែសិស្សបាននិយាយថា « ទេ, លោកគ្រូ, នេះមិនកើតទេ ។ ខ្ញុំត្រូវការពារខ្លួនខ្ញុំ ហើយលោកគ្រូត្រូវការពារខ្លួនរបស់លោកគ្រូ » ។ តាមគន្លងនេះដូចគ្នា, យើងត្រូវរក្សាចិត្តរបស់យើងផ្ទាល់ ។ មនុស្សខ្លះអាចនិយាយថា នេះគឺអត្តទត្ថះពេកហើយ ។ តើការងារជាក្រុមយ៉ាងដូចម្តេចទៅវិញ ? ប៉ុន្តែ ខ្ញុំគិតថា នេះគឺជាការយល់ខុសជាមូលដ្ឋានមួយ ។ ច្រវាក់មួយខ្សែ ជាប់មាំត្រឹមតំណកងដ៏ខ្សោយបំផុតរបស់វាប៉ុណ្ណោះ ។ ក្រុមមួយមានសមត្ថភាពស្មើនឹងសមាជិកទាំងឡាយរបស់ខ្លួនមានសមត្ថភាពប៉ុណ្ណោះ ។ មនុស្សរាយមាយមួយក្រុម ដែលមិនអាចបំពេញភារកិច្ចផ្ទាល់របស់ខ្លួនបាន គឺជាក្រុមមួយគ្មានសមត្ថភាព ។ ដូចគ្នានេះដែរ, ដើម្បីអោយយើងអាចបំពេញតួនាទីប្រកបដោយប្រសិទ្ធភាពក្នុងទំនាក់ទំនងចំពោះមនុស្សជាមិត្រភក្តិរបស់យើងបាន, យើងត្រូវរក្សាគ្រប់គ្រងចិត្តរបស់យើងជាមុន ។ ចូរសន្មតថា លោកអ្នកមានរថយន្តមួយយ៉ាងស្អាត ។ លោកយកចិត្តទុកដាក់ចតរថយន្ត នៅក្នុងកន្លែងណាមួយ ដើម្បី

កុំអោយអ្នកបើកបរម៉្យូតូណាម្នាក់មកប៉ះទង្គិចវា ។ សូម្បីនៅកន្លែងធ្វើការ ឬនៅផ្ទះ, លោកអ្នកតែងតែអើតមើលតាមបង្អួចមួងម្កាល ដើម្បីបញ្ជាក់ថាតើរថយន្តនៅត្រឹមត្រូវឬទេ ។ លោកអ្នកច្បាស់ជាយករថយន្តទៅអោយយន្តការី (ជាងម៉ាស៊ីន) ត្រួតមើលយ៉ាងទៀងទាត់ ។ តាមទំនងនេះដូចគ្នា, យើងទាំងអស់គ្នាតែងមានវត្ថុមួយដែលមានតម្លៃខ្ពស់ណាស់ជាងទ្រព្យសម្បត្តិដទៃឯទៀត ។ វត្ថុមួយនោះ គឺចិត្តរបស់យើង ។

ដោយទទួលស្គាល់តម្លៃនៃចិត្តរបស់យើង, យើងត្រូវថែរក្សាចិត្តនោះ ។ នេះគឺជាការភ្ញាក់រលឹក ។ នេះគឺជាទិដ្ឋភាពមួយនៃសមាធិ (ការអភិវឌ្ឍន៍ចិត្ត) ដែលយើងអាចហាត់ធ្វើនៅពេលណា និងក្នុងកន្លែងណាក៏បាន ។ ជួនកាលខ្ញុំឃើញមនុស្សខ្លះនិយាយមកកាន់ខ្ញុំថា វាមានសេចក្តីលំបាកក្រៃលែង ដើម្បីហាត់ធ្វើភាវនា, ហើយជាញឹកញយ មនុស្សតែងមានសេចក្តីញញើតបែបណាមួយ ដើម្បីហាត់ធ្វើភាវនា ។ និយាយជារួម, មនុស្សតែងនឹកគិតអំពីសមាធិភាវនា ឬអង្គុយភាវនា ។ ប៉ុន្តែ បើទោះជាគេមិនបានត្រៀមខ្លួនហាត់ធ្វើសមាធិភាវនាក្តី, តាមពិតទៅ គេអាចហាត់ធ្វើសម្មាវាយាមៈ និងសម្មាសតិបាន ដោយគ្មានខ្លាចអំពីផលវិបាកមិនល្អណាមួយឡើយ ។ វាគ្រាន់តែតម្រូវអោយលោកអ្នកមានការភ្ញាក់រលឹក និងការប្រុងប្រយ័ត្ន, ឃ្លាំមើលចិត្តរបស់លោកអ្នកអោយដឹង ថាតើចិត្តនោះកំពុងត្រាច់ទៅទីណា, អោយដឹង ថាតើចិត្តនោះកំពុងធ្វើអ្វី ។ បីដូចជាពេលខ្ញុំកំពុងនិយាយទៅកាន់លោកអ្នកឥឡូវនេះ, ដោយប្រើជ្រុងម្ខាងនៃចិត្តរបស់ខ្ញុំ, ខ្ញុំអាចឃ្លាំមើលចិត្តរបស់ខ្ញុំ, តាមដានចិត្តរបស់ខ្ញុំ ។ តើខ្ញុំកំពុងគិតពីអ្វី ? តើចិត្តរបស់ខ្ញុំនៅជាមួយនឹងអ្វី ដែលខ្ញុំកំពុងនិយាយទៅកាន់លោកអ្នកឬទេ, ឬខ្ញុំកំពុងតែគិតអំពីអ្វី ដែលបានកើតឡើងកាលពីព្រឹកមិញ, ឬកាលពីសប្តាហ៍មុន, ឬក៏ខ្ញុំកំពុងគិតពីអ្វីដែលខ្ញុំនឹងធ្វើនៅថ្ងៃស្អែក ។ ម្តងនោះខ្ញុំបានឮគ្រូបង្រៀនម្នាក់និយាយថា បើអ្នកឯងកំពុងឆុងតែមួយពែង ពុទ្ធសាសនា

មានន័យថា កំពុងឆុងតែមួយពែងដែរ, ដោយផ្តោតអារម្មណ៍ ផ្ចង់ចិត្តទៅលើអ្វី ដែលគេកំពុងធ្វើ ។ នេះគឺជាការណ៍ពិត មិនថាជាអ្វីដែលគេកំពុងធ្វើនោះទេ : ជូតផ្ទះ, ដើរទៅសាលារៀន, ឬដាំស្ល ។ អ្វីក៏ដោយដែលគេកំពុងធ្វើ, គេអាចហ្វឹកហាត់ សតិបាន ពោលគឺ ការហ្វឹកហាត់ឃ្លាំមើលចិត្ត, តាមដានចិត្ត ។

តាមទម្លាប់ ការហ្វឹកហាត់សតិ បានដើរតួសំខាន់ណាស់ នៅក្នុងពុទ្ធសាសនា ។ នៅពេលមួយនោះ ព្រះពុទ្ធទ្រង់បានត្រាស់ហៅការហ្វឹកហាត់សតិថា ជាមាគ៌ាមួយ ដើម្បីសំរេចបាននូវការបញ្ចប់ទុក្ខ ។ និយាយដោយចំទៅ, ការហ្វឹកហាត់សតិ ត្រូវបានធ្វើអោយរីកចំរើន ដើម្បីបញ្ចូលទៅក្នុងការអនុវត្តន៍ដោយឡែកបួនយ៉ាង ។ នោះគឺ ការអនុវត្តសតិចំពោះអង្គកាយ - ការភ្ញាក់រលឹក (ដឹង) ពីទីតាំងនៃអវយវៈរបស់ខ្លួនជាដើម ; សតិចំពោះវេទនារម្មណ៍-រីករាយ, ទោមនស្ស ឬអព្យាក្រឹត ; សតិចំពោះខណៈនៃមនសិការ ; និងនៅទីបំផុត សតិចំពោះកម្មវត្ថុទាំងឡាយ (នៃវិញ្ញាណ) ។ ទីតាំងទាំងបួននៃសតិនេះ បានបន្តដើរតួដ៏សំខាន់ នៅក្នុងការហ្វឹកហាត់ធ្វើភាវនាតាមបែបពុទ្ធសាសនា ។

ចូរយើងបន្តពិចារណាជំហានទីបី គឺសមាធិ ឬជួនកាលគេហៅថាភាវនា ឬសមថៈ ។ លោកអ្នកនឹងនឹកឃើញថា យើងបាននិយាយអំពីប្រភពដើមនៃសមាធិ តាមដំណើរសព្វគ្រប់ទៅដល់អរិយធម៌ជ្រលងទន្លេឥណ្ឌុស ។ សមាធិ គ្មានទាក់ទងនឹងអ្វីជាមួយនឹងការរត់ (ការភ្លុតម្តងៗ), ឬការស្រយុតស្រយង់, ឬក៏ការភ្ញាក់រលឹកពាក់កណ្តាលនោះទេ ។ សមាធិ គឺជាការផ្ចង់តម្រង់ចិត្តយ៉ាងមុតស្រួចទៅលើកម្មវត្ថុនៃអារម្មណ៍តែមួយ ។ កម្មវត្ថុអាចជាវត្ថុមានរូប ឬជាធម្មារម្មណ៍ ។ កាលណាចិត្តមូលស្លួងទាំងស្រុងទៅលើកម្មវត្ថុតែមួយបានសំរេចហើយតាមរយៈសមាធិ, ចិត្តនោះត្រូវបានស្រូបទាំងស្រុងទៅក្នុងកម្មវត្ថុនោះ ដោយផ្តាច់ចេញពីការគិតពីអារម្មណ៍រីករាយរំភើបញាប់ញ័រ ឬការងោកងុយទាំងអស់ ។ នេះគឺជាកម្មវត្ថុនៃការហ្វឹកហាត់ធ្វើសម្មា

សមាធិ ដើម្បីផ្តោតចិត្តយ៉ាងមុតស្រួចទៅលើកម្មវត្ថុតែមួយ ។ ភាគច្រើននៃយើងទាំងអស់គ្នា បានដឹងច្បាស់ហើយអំពីស្ថានភាពទាំងឡាយបែបនេះ ។ មានពេលខ្លះចិត្តចូលស្ងួងបានកើតឡើងឯងៗ កាលណាគេស្តាប់បទភ្លេងណាមួយដែលគេចូលចិត្ត ឬកាលណាគេសម្លឹងមើលសមុទ្រ ឬមើលមេឃ ។ គេអាចពិសោធអំពីខណៈដែលចិត្តឋិតលើកម្មវត្ថុនោះ, សំឡេងនោះ ឬរូបភាពនោះ យ៉ាងមូលស្ងួងឥតរាយមាយ ។

គេអាចហ្វឹកហាត់ធ្វើសមាធិ តាមបែបបទមួយចំនួន ។ កម្មវត្ថុនៃសមាធិអាចជាចក្ខុវិស័យ ដូចជាអណ្តាតភ្លើង, រូបភាព ឬផ្កា ឬក៏ជាមតិ ជាវត្ថុគ្មានរូប ដូចជាអាកាស ដូចជាមេត្តាធម៌ ។ កាលណាគេហ្វឹកហាត់ធ្វើសមាធិ គេផ្តោតចិត្តជាញឹកញយទៅលើកម្មវត្ថុ ។ អំពើយ៉ាងនេះបាននាំបន្តិចម្តងៗជាលំដាប់ទៅកាន់សមត្ថភាពដើម្បីតម្កល់ចិត្តអោយនៅនឹងលើកម្មវត្ថុ ដោយឥតមានសេចក្តីរាយមាយ ។ កាលណាសកម្មភាពនេះអាចសំរេចបាន អស់រយៈពេលដ៏វែងណាមួយហើយ, ពេលនោះគេបានសំរេចឯកគតាចិត្ត (single pointedness of mind) ។ វាមានសារៈសំខាន់ណាស់ដើម្បីកត់សំគាល់ថា ទិដ្ឋភាពនៃការអភិវឌ្ឍន៍ចិត្តនេះ ត្រូវហ្វឹកហាត់ដោយមានការណែនាំពីគ្រូអាចារ្យដ៏មានបទពិសោធន៍ ។ បានជាដូច្នេះ ពិព្រោះ វាមានកត្តាបច្ចេកទេសមួយចំនួន ដែលនាំអោយបានសំរេចជោគជ័យ ឬនាំអោយបរាជ័យ ហើយកត្តាបច្ចេកទេសទាំងនោះ រួមមាន របៀបអង្គុយ, អាកប្បកិរិយា និងឱកាសហ្វឹកហាត់ ។ ហើយគេមានការពិបាក ដើម្បីប្រតិបត្តិតាមកត្តាបច្ចេកទេសទាំងនេះអោយបានត្រឹមត្រូវទាំងអស់ដោយគ្រាន់តែអានសៀវភៅ ។ ប៉ុន្តែថា គេពុំចាំបាច់បួសជាសង្ឃ ដើម្បីហ្វឹកហាត់ភាវនា ឬសមាធិបែបនេះទេ, គេពុំចាំបាច់រស់នៅក្នុងព្រៃទេ, ហើយគេក៏ពុំចាំបាច់បោះបង់ចោលសកម្មភាពប្រចាំថ្ងៃរបស់ខ្លួនដែរ ។ គេអាចចាប់ផ្តើមដោយរយៈកាលខ្លីៗ, ដូចជារយៈពេលខ្លីប្រមាណពីដប់ ទៅដប់ប្រាំ

នាទី ក្នុងមួយថ្ងៃ ។

កាលណាសមត្ថភាពរបស់គេនៅក្នុងសមាធិ ឬភាវនាបែបនេះបានរីកចំរើនហើយ, សមត្ថភាពនេះមានអត្ថប្រយោជន៍សំខាន់ពីរយ៉ាង ។ ទីមួយ, វានាំអោយមានសុខុមាលភាព, ផាសុកភាព, សេចក្តីសប្បាយ, សេចក្តីស្ងប់, ភាពសុខសាន្តខាងផ្លូវចិត្ត និងខាងផ្លូវកាយ ។ ទីពីរ, វាធ្វើអោយចិត្តប្រែទៅជាឧបករណ៍មួយមានសមត្ថភាពមើលឃើញវត្ថុទាំងឡាយតាមយថាភូត ។ សមត្ថភាពនេះ រៀបចំចិត្តអោយឈោងចាប់យកបញ្ញា ។ កាលណាយើងនិយាយអំពីការមើលឃើញវត្ថុទាំងឡាយជាយថាភូត, យើងប្រដូចការអភិវឌ្ឍន៍ឆ្ពោះទៅរកសមត្ថភាពនេះ ទៅនឹងការអភិវឌ្ឍន៍ឧបករណ៍ជំនាញនៅក្នុងវិទ្យាសាស្ត្រ តាមរយៈនេះ យើងអាចពិនិត្យមើលចុណ្ណភាគអាតូមិក ជាដើម ។ ប្រសិនបើគ្មានការអភិវឌ្ឍន៍ឧបករណ៍ទទួលវិទ្យុទេ, នោះក៏យើងមិនអាចដឹងពីរលកវិទ្យុដែរ ។ ដូចគ្នានេះដែរ ប្រសិនបើយើងមិនអភិ-វឌ្ឍចិត្តរបស់យើងតាមរយៈការបណ្តុះបណ្តាលសម្មាវាយាមៈ និងសម្មាសតិ ហើយជាពិសេស បណ្តុះឯកគ្គតាចិត្តទេ, ការយល់ដឹងរបស់យើងអំពីសភាពពិតនៃវត្ថុ, អំពីសច្ចៈ នឹងនៅតែជាចំណេះដឹងខាងបញ្ញា ។ ដើម្បីប្រែក្លាយចំណេះដឹងខាងបញ្ញា អំពីអរិយសច្ចៈបួន អោយចាកអំពីចំណេះដឹងតែក្នុងសៀវភៅ ទៅជាការពិសោធន៍ផ្ទាល់ យើងត្រូវសំរេចអោយបាននូវឯកគ្គតាចិត្ត ។ គឺនៅចំណុចនេះហើយ ដែលការអភិវឌ្ឍន៍ចិត្ត ត្រៀមប្រែក្លាយការយកចិត្តទុកដាក់របស់ខ្លួនទៅចាប់យកបញ្ញា ។ គឺនៅចំណុចនេះ ដែលយើងមើលឃើញតួនាទីសមាធិនៅក្នុងពុទ្ធសាសនា ។ ខ្ញុំបាននិយាយរឿងនេះយ៉ាងសង្ខេបខ្លី នៅពេលខ្ញុំនិយាយពីការសំរេចព្រះទ័យរបស់ព្រះពុទ្ធដើម្បីចាកចោលគ្រូអាចារ្យពីររូបគឺ អាឡារកាលាមៈ និងឧទករាមបុត្រ, ហើយនិងបាននិយាយអំពីការផ្សំផ្គុំរវាងសមាធិ ឬភាវនាជាមួយនឹងវិបស្សនាដ៏មុតធ្លុះ នៅរាត្រីនៃការត្រាស់ដឹងសម្មាសម្ពោធិញាណ ។ ដូច្នេះ នៅក្នុងទីនេះដែរ ឯកគ្គតាចិត្តតែឯង

មិនទាន់គ្រប់គ្រាន់ទេ ។ វាដូចគ្នានឹងការសម្រួចខ្មៅដៃដើម្បីសរសេរ ឬសំលៀងពូថៅដែលប្រើដើម្បីកាត់ផ្តាច់ឫសគល់នៃលោភៈ ទោសៈ និងមោហៈ ។ កាលណាយើងសំរេចបានឯកគតានៃចិត្តហើយ, ពេលនេះ យើងត្រៀមភ្ជាប់ខ្លួនទៅនឹងសេចក្តីសុខសាន្ត រួមជាមួយទស្សនៈយល់ដឹងដ៏មុតស្រួច, គឺសមាធិប្រកបដោយបញ្ញា ។

***

## ( VII )
## បញ្ញា

ថ្ងៃនេះ យើងនឹងបង្ហើយការពិនិត្យមើលរបស់យើងពីអរិយដ្ឋង្គិកមគ្គៈ ។ ក្នុងពេលពីរសប្តាហ៍កន្លងទៅ, យើងបានពិនិត្យមើលសីល (សុចរិយា) និងសមាធិ (ការអភិវឌ្ឍន៍ចិត្ត) ។ ថ្ងៃនេះ យើងលើកយកក្រុមទីបី មកពិនិត្យមើល, ហើយក្រុមទីបីនោះ គឺក្រុមបញ្ញា ។ ក្នុងទីនេះ យើងមានស្ថានភាពមួយដ៏គួរអោយជាប់ចិត្ត ដែលយើងបានលើកឡើងរួចហើយនាពេលកន្លងទៅ ក្នុងគ្រាដែលយើងបានពិភាក្សាអំពីអរិយសច្ចៈបួន ។ កាលណាគេមើលអរិយដ្ឋង្គិកមគ្គៈ រៀបរាប់តាមលំដាប់លំដោយ គេតែងចាប់ផ្តើមពីសម្មាទិដ្ឋិ ហើយនៅក្នុងបរិបទ នៃការបែងចែកជាបីយ៉ាង នៃសីល សមាធិ និងបញ្ញា នេះទៀត, បញ្ញា ត្រូវបានរាប់នៅក្នុងចុងគេ ។ គេបានសាក

ល្បងពន្យល់ហេតុផលនេះដោយប្រើការប្រៀបប្រដូចទៅនឹងការឡើងភ្នំ ។ កាលណាគេចាប់ផ្តើមឡើងភ្នំ, គេត្រូវសម្លឹងមើលកំពូលភ្នំ ហើយការមើលឃើញកំពូលភ្នំនេះហើយ ដែលផ្តល់ការតម្រង់ទិសដល់ផ្លូវដើររបស់យើង ។ ក្នុងន័យនេះ សូម្បីពេលណាគេចាប់ផ្តើមឡើងភ្នំ, គេមានភ្នែកក្រឡេកមើលទៅកំពូល ។ ដូចគ្នានេះដែរ សម្មាទិដ្ឋិ គឺជាជំហានចាំបាច់ តាំងតែពីការចាប់ផ្តើមដើរតាមមាគ៌ាម្លេះ ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង គេត្រូវឡើងពីថ្នាក់ទាប, ឈានទៅជាន់កាំថ្នាក់កណ្តាល មុននឹងគេឡើងដល់កំពូល, ពោលគឺ ការសំរេចបាននូវបញ្ញា ។ ដោយហេតុនេះ ក្នុងពាក្យពេចន៍ជាក់ស្តែង, បញ្ញាត្រូវដាក់នៅខាងចុងគេ សម្រាប់ការហ្វឹកហាត់អំពីមាគ៌ារបស់គេ ។

បញ្ញាត្រូវបានពិពណ៌នាថាជាការយល់ដឹង នូវអរិយសច្ចៈទាំងបួន ឬការយល់ដឹងអំពីបដិច្ចសមុប្បាទធម៌ជាអាទិ៍ ។ អ្វីដែលជាអត្ថន័យនៃពាក្យពោលនេះ គឺថា កាលណាយើងនិយាយអំពីការសំរេចបាននូវបញ្ញា, យើងជាប់ពាក់ព័ន្ធជាមួយនឹងការប្រែក្លាយប្រការទាំងឡាយនេះនៃវាទៈ ឬពាក្យប្រៀនប្រដៅពីហេតុការណ៍សាមញ្ញទៅជាហេតុការណ៍ពិតផ្ទាល់ខ្លួន ។ យើងបានជាប់ចិត្តក្នុងការកែប្រែចំណេះដឹងនេះពីការរៀនតាមសៀវភៅសុទ្ធសាធ ទៅជាបទពិសោធន៍ពិតនៃជីវិត ។ ឯមាគ៌ាដែលត្រូវប្រកាន់យក គឺតាមរយៈការបណ្តុះបណ្តាលចរិយា (សីល) ហើយបើនិយាយអោយចំ គឺតាមរយៈការបណ្តុះបណ្តាល ការធ្វើអោយចិត្តរីកចំរើន (សមាធិ) ។ ម្យ៉ាងទៀត អ្នកណាក៏អាចអានសេចក្តីពន្យល់អំពីចតុរារិយសច្ចៈជាអាទិ៍ នៅក្នុងសៀវភៅបានដែរ, ប៉ុន្តែថា នេះមិនដូចគ្នានឹងការបានសំរេចបញ្ញានោះទេ ។ ដូចព្រះពុទ្ធអង្គទ្រង់បានទូន្មានថា គឺការខកខានមិនបានយល់ចតុរារិយសច្ចៈ និងបដិច្ចសមុប្បាទៈ ទើបយើងទាំងអស់គ្នាត្រូវអន្ទោលក្នុងវដ្តសង្សារនៃការកើត និងស្លាប់ ។ ជាក់ស្តែង កាលណាព្រះអង្គមានបន្ទូលបែបនេះ, ព្រះអង្គបានសំដៅយកអ្វីមួយ ដែល

មានគម្ពីរភាពជាងការខកខានដ៏សាមញ្ញដើម្បីយល់ដឹងតាមបញ្ញាស្មារតី នូវប្រការទាំងឡាយនេះនៃវាទះ ។ ការយល់ដឹងក្នុងទីនេះ ត្រូវយល់ក្នុងន័យនៃសម្មាទិដ្ឋិ គឺការយល់ដឹងដោយផ្ទាល់ក្នុងន័យមើលឃើញ ។ ប្រហែលមកពីហេតុនេះហើយ ទើបបានជាញឹកញយណាស់ ភាសានៃការមើលឃើញ ត្រូវបានប្រើសម្រាប់ពិពណ៌នាការសំរេចបានបញ្ញា ។ យើងនិយាយក្នុងន័យមើលឃើញសច្ចះ មើលឃើញវត្ថុទាំងឡាយ តាមយថាភូត (តាមការពិតជាក់ស្តែង) ។ ពិព្រោះ ការសំរេចបានបញ្ញា មិនមែនជាលំហាត់ខាងបញ្ញា ឬលំហាត់ខាងការសិក្សា នៅសាលារៀនទេ ។ គឺជាការមើលឃើញ, ការយល់ដឹងនូវសច្ចះទាំងឡាយនេះដោយផ្ទាល់ ។ កាលណាមានការយល់ដឹងសច្ចះបែបនេះសំរេចបានហើយ, គុណធម៌នេះមានកំរិតស្មើនឹងការចាប់បាន នូវការត្រាស់ដឹង ។ គុណធម៌នេះ បើកទ្វារទៅកាន់សេរីភាព គឺសេរីភាពរួចផុតពីទុក្ខ ហើយទៅកាន់ព្រះនិព្វាន ។ បញ្ញា គឺជាគុណធម៌គន្លឹះនៅក្នុងពុទ្ធសាសនា ។ នៅក្នុងសាសនាទាំងឡាយខ្លះ យើងឃើញថា ជំនឿដើរតួសំខាន់ ។ នៅក្នុងសាសនា ទាំងឡាយផ្សេងទៀត, យើងឃើញថា ការស្មឹងស្មាធិ៍ គឺជាគុណធម៌ដ៏ឧត្តម ដូចជាគំរូនៅក្នុងយោគះ ។ នៅក្នុងពុទ្ធសាសនា ជំនឿ ឬសទ្ធា គឺជាគុណធម៌ដំបូង, សមាធិ គឺជាឧបករណ៍ ។ ស្នូលពិតប្រាកដរបស់ពុទ្ធសាសនា គឺបញ្ញា ។

ជំហានពីរ របស់អរិយដ្ឋង្គិកមគ្គ ដែលរួមបញ្ចូលនៅក្នុងបញ្ញា គឺសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ។ សម្មាទិដ្ឋិ អាចនិយាយបានថា គឺជាការមើលឃើញអ្វីៗ ដូចដែលវាមានពិតជាក់ស្តែង (យថាភូត) ។ ការយល់ដឹងនូវសច្ចះអំពីអ្វីៗទាំងឡាយ ប្រសើរជាងការមើលឃើញអ្វីៗទាំងឡាយនោះ តាមដូចដែលវាលេចចេញឡើង ។ អ្វីដែលចង់សំដៅដល់ គឺវិបស្សនាញាណ, ការយល់ដឹងមុតធ្លុះ, ការមើលឃើញហួសពីផ្ទៃក្រៅនៃអ្វីៗទាំងអស់ ។ បើយើងចង់ពន្យល់សភាវធម៌នេះជាវោហារវាទ (doctrinal terms), យើងនឹងត្រូវនិយាយអំពីចតុរារិយសច្ចះ, បដិច្ចសមុប្បាទះ, អនិច្ចះ,

អនត្តៈ និងធម៌ឯទៀត ។ ប៉ុន្តែ សម្រាប់ពេលនេះ, ចូរយើងនិយាយតែអំពីមធ្យោបាយសម្រេចអោយបានសម្មាទិដ្ឋិបានហើយ ។ ក្នុងទីនេះ យើងអាចពិនិត្យមើលម្តងទៀត នូវអាកប្បកិរិយាវិទ្យាសាស្ត្រ នៃពាក្យប្រៀនប្រដៅ (ព្រះធម៌) របស់ព្រះពុទ្ធ ។ ពិព្រោះតែកាលណាយើងត្រូវពិនិត្យមើលមធ្យោបាយ ដើម្បីសម្រេចបានសម្មាទិដ្ឋិ, យើងមើលឃើញថា យើងចាប់ផ្តើមដោយការសង្កេត ជាបរានុម័តិអំពីទីតាំង និងអំពីខ្លួនយើង ។ យើងភ្ជាប់ការសង្កេតជាមួយនឹងការអង្កេត, ការពិនិត្យ, និងការពិចារណា ។

ក្នុងការចាប់យកបានសម្មាទិដ្ឋិ យើងឃើញថា មានការយល់ដឹងពីរបែប ។ មួយគឺ ការយល់ដឹងដែលយើងចាប់យកបានដោយខ្លួនយើង ។ មួយទៀតគឺ ការយល់ដឹងដែលយើងបានតាមរយៈអ្នកដទៃ, ពោលគឺ ការយល់ដឹងដែលអ្នកដទៃប្រាប់ដល់យើង ។ នៅទីបំផុត ការយល់ដឹងទាំងពីរបែបនេះ រលាយចូលគ្នា ពិព្រោះ នៅដំណាក់កាលចុងក្រោយ ការយល់ដឹងពិតអំពីសម្មាទិដ្ឋិ ត្រូវបានជារបស់យើងផ្ទាល់ ។ ប៉ុន្តែនៅចន្លោះពេលនេះ, គេអាចពិនិត្យឃើញភាពផ្សេងគ្នា រវាងសម្មាទិដ្ឋិ ដែលយើងសំរេចបានតាមរយៈការសង្កេតមើលបរិដ្ឋាន (ទីជុំវិញ) និងសម្មាទិដ្ឋិ ដែលយើងសំរេចបាន តាមរយៈការសិក្សាព្រះធម៌ជាពាក្យប្រៀនប្រដៅ ។ ដូចជាអ្វីពាក់ព័ន្ធទៅនឹងទីតាំងរបស់យើង, គេសុំអោយយើងសង្កេតជាបរានុម័តិ នូវអ្វីដែលយើងឃើញ, អ្វីដែលយើងពិសោធ ហើយបន្ទាប់មក ពិនិត្យនិងពិចារណានូវសារសំខាន់របស់វា, ដូច្នេះ កាលណាយើងចាប់ផ្តើមសិក្សាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, គេសុំអោយសិក្សាពាក្យប្រៀនប្រដៅនោះ, ស្តាប់ពាក្យប្រៀនប្រដៅនោះ ហើយបន្ទាប់មក ពិចារណាពាក្យប្រៀនប្រដៅនោះ, ពិនិត្យពាក្យប្រៀនប្រដៅនោះ ។ បើទោះបីយើងនិយាយក្នុងន័យនៃការសង្កេត និងការអង្កេត, ឬទោះបីយើងនិយាយដល់ការសិក្សាពីវាទៈ ហើយយើងនិយាយក្នុងន័យនៃការអាន, ឬការស្តាប់

និងការពិចារណា, ជំហានទីបី ក្នុងដំណើរចាប់យកបានការយល់ដឹងនេះ គឺសមាធិ ។ គឺនៅក្នុងជំហានទីបី នៃដំណើរចាប់យកបានសម្មាទិដ្ឋិនេះហើយ ដែលការយល់ដឹងទាំងពីរបែបរលាយចូលគ្នា ។ រួមសេចក្តីមក, មធ្យោបាយចាប់យកបានសម្មាទិដ្ឋិគឺមាន ដូចតទៅ - ក្នុងជំហានទីមួយ, គេត្រូវសង្កេត សិក្សា និងអាន ។ នៅជំហានទីពីរ គេត្រូវពិនិត្យប្រកបដោយបញ្ញា នូវអ្វីដែលគេបានសង្កេត បានសិក្សា និងបានអាន ។ នៅជំហានទីបី គេត្រូវត្រិះរិះថ្លឹងថ្លែងលើអ្វីដែលគេបានពិនិត្យ, បានពិចារណា និងបានវិនិច្ឆ័យ ។ ចូរយើងលើកយកឧទាហរណ៍ជាក់ស្តែងមួយ ។ ចូរយើងគិតថា យើងមានបំណងធ្វើដំណើរទៅកាន់គោលដៅណាមួយ ។ ដើម្បីធ្វើដូច្នោះ យើងត្រូវមានផែនទីផ្លូវ ដែលបង្ហាញផ្លូវនាំទៅកាន់ទីនោះ ។ ដំបូង យើងក្រឡេកមើលផែនទីដើម្បីអោយដឹងទិស ។ បន្ទាប់មក យើងត្រូវពិនិត្យឡើងវិញ នូវអ្វីដែលយើងបានឃើញ, មើលផែនទីឡើងវិញ ពិនិត្យផែនទីដើម្បីបញ្ជាក់ថា យើងយល់នូវការណែនាំបានហើយ ។ គឺនៅពេលនោះហើយ ទើបយើងធ្វើដំណើរទៅកាន់ទីដៅ របស់យើង ដោយទៀងទាត់បាន ។ នេះគឺដូចគ្នានឹងការធ្វើសមាធិ ។ ម្យ៉ាងទៀត សន្មត់ថា យើងបានទិញឧបករណ៍ថ្មីមួយគ្រឿង ។ គ្រាន់តែអានសេចក្តីណែនាំ មិនទាន់គ្រប់គ្រាន់ទេ ។ យើងត្រូវអានឡើងវិញ នូវសេចក្តីណែនាំ, ពិនិត្យសេចក្តីណែនាំនោះៗ ដើម្បីបញ្ជាក់ថា តើយើងយល់សេចក្តីណែនាំនោះៗ ច្បាស់លាស់ហើយនៅ ។ កាលណា យើងប្រាកដថា យើងបានធ្វើអោយការយល់ដឹងប្រកបដោយបញ្ញារបស់យើងបានច្បាស់លាស់ហើយ បន្ទាប់មក យើងអាចចាប់ផ្តើមធ្វើអោយឧបករណ៍ថ្មីមួយគ្រឿងនេះ ដំណើរការដោយត្រឹមត្រូវបាន ។ នេះដូចគ្នានឹងសមាធិ, ដូចគ្នានឹងការត្រិះរិះ ថ្លឹងថ្លែង លើអ្វីដែលយើងសំរេចបានតាមរយៈការសង្កេត, ការសិក្សា, ការពិចារណា និងការពិនិត្យ ។ នៅជំហានទីបី តាមរយៈសមាធិ, ហេតុការណ៍ទាំងឡាយនេះ ក្លាយទៅជាចំណែកនៃជីវិតសោធន៍របស់យើង ។

ប្រហែលយើងអាចចំណាយពេលបន្តិច ពិភាក្សាពីអាកប្បកិរិយា ដែលគេអាចធ្វើអោយបានល្អ ដើម្បីបណ្តុះបណ្តាលអាកប្បកិរិយា ក្នុងការសិក្សាព្រះធម៌ (ពាក្យប្រៀនប្រដៅ) របស់ព្រះពុទ្ធ ។ គេតែងនិយាយថា អ្នកដែលចូលទៅជិតព្រះធម៌ ត្រូវខិតខំបញ្ចៀសកំហុសបីយ៉ាងនៅក្នុងអាកប្បកិរិយារបស់គេ ហើយកំហុសទាំងបីយ៉ាងនោះ ត្រូវបានលើកយកមកបង្ហាញដោយភ្ជាប់ជាមួយឧទាហរណ៍អំពីភាជន៍មួយ ។ នៅក្នុងបរិបទនេះ, យើងគឺជាតួភាជន៍ ព្រះធម៌ គឺជាអ្វីដែលត្រូវចាក់បំពេញទៅក្នុងភាជន៍ ។ ចូរសន្មត់ថា ភាជន៍មានគ្របបិទជិត, យើងនឹងពុំមានជោគជ័យចាក់អ្វីបំពេញភាជន៍បានទេ, យកជាឧទាហរណ៍ដូចជាទឹកដោះគោ ។ នេះដូចគ្នាទៅនឹងមនុស្សណាមួយដែលស្តាប់ព្រះធម៌ដោយមានចិត្តបិទជិត ពោលគឺ ចិត្តដែលបានតាំងរួចហើយ ។ ព្រះធម៌មិនអាចចូលទៅបំពេញភាជន៍បានទេ ។ ចូរសន្មត់មួយទៀតថា យើងមានភាជន៍មួយដែលមានបាតធ្លុះ ។ ប្រសិនបើយើងបំពេញភាជន៍ដោយទឹកដោះគោ, ទឹកដោះគោនឹងហូរចេញតាមរន្ធធ្លុះ ។ នេះដូចគ្នានឹងមនុស្សទាំងឡាយខ្លះក្នុងចំណោមយើងនេះ ដែលឃើញថាអ្វីដែលយើងឮ មិនបិតនៅជាមួយយើងទេ ។ ហើយនៅទីអវសាន វាមានករណីនិយាយពីភាជន៍ ដែលនៅក្នុងភាជន៍នេះ មានវត្ថុសៅហ្មង ។ ចូរយើងសន្មតថា យើងបំពេញភាជន៍ដោយទឹកដោះគោមុនពេលយើងបានសំអាតភាជន៍នោះ ។ ចូរសន្មតថា វាមានទឹកដោះគោខូចគុណភាពសល់នៅក្នុងភាជន៍ ។ ទឹកដោះគោស្រស់ថ្មី ដែលយើងចាក់ទៅក្នុងភាជន៍ នឹងត្រូវខូច ។ ដូចគ្នានេះដែរ ប្រសិនបើយើងស្តាប់ព្រះធម៌ដោយចិត្តមិនបរិសុទ្ធ, ដោយអាកប្បកិរិយាមិនបរិសុទ្ធ, យកជាឧទាហរណ៍ ពីព្រោះ យើងចង់សំរេចអោយបានកិត្តិយស ឬកិត្តិស័ព្ទកិរិតណាមួយ, ជាមួយអាកប្បកិរិយាអត្តទត្តភាព ឬចំណង់បែបនេះ យើងប្រៀបដូចជាភាជន៍មួយប្រឡាក់ដោយពណ៌សៅហ្មង ។ យើងត្រូវជៀសវាងកំហុសទាំងអស់ ទៅក្នុងអាកប្បកិរិយារបស់យើង ចំពោះការស្តាប់ពាក្យប្រៀន

ប្រដៅរបស់ព្រះពុទ្ធ, ចំពោះការសិក្សាព្រះធម៌ ។ ជាជំនួសអោកប្បកិរិយានេះ គេនិយាយថា គេអាចស្តាប់ព្រះធម៌ តាមបែបអ្នកជំងឺស្តាប់ការណែនាំរបស់គ្រូពេទ្យ ។ នៅក្នុងបរិបទនេះ, ព្រះពុទ្ធ ទុកជាគ្រូពេទ្យ, ព្រះធម៌ គឺជាឱសថ, យើងទាំងអស់គ្នា គឺជាអ្នកជំងឺ ហើយការប្រតិបត្តិព្រះធម៌ គឺជាមធ្យោបាយមួយ ដែលតាមមធ្យោបាយនេះ យើងអាចព្យាបាលអោយសះស្បើយពីជំងឺ, ឯជំងឺ គឺគ្រឿងសៅហ្មង (កិ-លេស) -លោភៈ, ទោសៈ, និងមោហៈ ដែលបង្កើតឡើងនូវទុក្ខ ។ យើងនឹងច្បាស់ជាសំរេចបានសម្មាទិដ្ឋិ ក្នុងកិរិតណាមួយ, ប្រសិនបើយើងរៀបចំការសិក្សាព្រះធម៌ ដោយមានចិត្តដក់ជាប់នូវសញ្ញាណនេះ ។

ជាញឹកញយ យើងបែងចែកសម្មាទិដ្ឋិចេញជាពីរទិដ្ឋភាព ។ ទិដ្ឋភាពទីមួយ ទាក់ទងកិរិតធម្មតា ចំណែកទិដ្ឋភាពទីពីរ ទាក់ទងកិរិតជ្រាលជ្រៅជាង ។ មួយរយៈពេលកន្លងទៅហើយ, យើងបាននិយាយអំពីគោលដៅ ដែលពុទ្ធសាសនាផ្តល់អោយ, ក្នុងន័យនៃកិរិតគោលដៅពីរយ៉ាង - សុភមង្គល និងភ័ព្វសំណាងល្អ នៅក្នុងជាតិនេះ និងជាតិក្រោយ, ហើយនឹងការរំដោះទុក្ខចុងក្រោយបង្អស់ ។ ទិដ្ឋភាពទីមួយ នៃសម្មាទិដ្ឋ គឺការយល់ដឹងពីទំនាក់ទំនងរវាងហេតុនិងផល នៅក្នុងរង្វង់នៃការទទួលខុសត្រូវ ផ្លូវសីលធម៌ចំពោះអំពើ និងចរិយារបស់យើង ។ សេចក្តីបញ្ជាក់ដោយសង្ខេបនេះ ចង់និយាយថា យើងនឹងទទួលសោយនូវផលនៃអំពើរបស់យើង ។ ប្រសិនបើយើងធ្វើល្អ, ប្រសិនបើយើងប្រព្រឹត្តកាន់តាមសិក្ខាបទ ចេះគោរពជីវិតសត្វ, មិនលួចទ្រព្យសម្បត្តិគេ, និយាយពាក្យពិតត្រង់ជាអាទិ៍ ប្រសិនបើយើងប្រព្រឹត្តបាននៅក្នុងគន្លងកុសលទាំងនេះ យើងនឹងទទួលសោយ (ពិសោធ) ផលល្អនៃអំពើរបស់យើង ។ យើងនឹងទទួលសោយសុភមង្គល និងទទួលបានឋានៈខ្ពង់ខ្ពស់ធូរធានៅក្នុងជាតិនេះ និងជាតិក្រោយ ។ ផ្ទុយទៅវិញ ប្រសិនបើយើងប្រព្រឹត្តអាក្រក់, យើងទទួលសោយនូវទុក្ខទោស, លំបាកវេទនា និងខ្សត់យសសក្តិ ទ្រព្យ

សម្បត្តិ នៅក្នុងជាតិនេះ និងជាតិក្រោយ ។

ស្តីពីកិរិតនៃការយល់ដឹង ដូចដែលមានទាក់ទងនឹងគោលដៅចុងក្រោយនៃព្រះធម៌របស់ព្រះពុទ្ធ យើងមានការពាក់ព័ន្ធជាមួយនឹងសម្មាទិដ្ឋិ ក្នុងន័យមើលឃើញអ្វីៗទាំងអស់តាមយថាភូត ។ កាលណាយើងនិយាយថា មើលឃើញអ្វីៗទាំងអស់តាមយថាភូត, តើយើងចង់និយាយសំដៅន័យអ្វី ? ជាថ្មីម្តងទៀត គេអាចទទួលបាននូវចម្លើយជាវាទៈចំពោះសំនួរនេះ ។ វាអាចមានន័យថា មើលឃើញអ្វីៗទាំងអស់ជាអនិច្ចៈ, ជាបដិច្ចសមុប្បាទៈ, ជាអនត្តៈ, ដូចជាមើលឃើញអរិយសច្ចៈបួនដូច្នេះ ។ ចម្លើយទាំងអស់នេះ គឺត្រឹមត្រូវ ។ ចម្លើយទាំងអស់នេះ ប្រាប់នូវអ្វីមួយអំពីការមើលឃើញអ្វីៗទាំងអស់ ដូចដែលវាមានពិតមែន (យថាភូត) ការមើលឃើញធម្ម-ភាពនៃអ្វីៗទាំងអស់ ។ ដើម្បីឈានមកដល់ការយល់ដឹងទិដ្ឋភាពទីមួយនេះ និងក្នុងន័យជាជំហានចុងក្រោយនៃអរិយដ្ឋង្គិមគ្គ, យើងត្រូវស្វែងរកអ្វីមួយដែលពាក្យពេចន៍ទាំងអស់នេះ ស្តីពីសម្មាទិដ្ឋិមានរួមគ្នា ។ កាលណាយើងពណ៌នាអំពីសម្មាទិដ្ឋិនៅក្នុងបែបបទផ្សេងៗទាំងអស់នេះ, ការពណ៌នាទាំងអស់នោះ គឺផ្ទុយទៅនឹងអវិជ្ជា, ផ្ទុយទៅនឹងបំណង, ផ្ទុយទៅនឹងការជាប់ជំពាក់ក្នុងវដ្តសង្សារនៃការកើត-ស្លាប់ ។ កាលដែលព្រះពុទ្ធទ្រង់បានត្រាស់ដឹង, បទពិសោធន៍របស់ព្រះអង្គ គឺជាសំខាន់បំផុតនោះ បទពិសោធន៍បំផ្លាញអវិជ្ជា ។ ព្រះពុទ្ធអង្គបានសំដែងរៀបរាប់បទពិសោធន៍នេះដោយព្រះអង្គឯងផ្ទាល់ ជាញឹកញយបំផុតក្នុងពាក្យពេចន៍ស្តីពីការយល់ដឹងអរិយសច្ចៈបួន និងការយល់ដឹងបដិច្ចសមុប្បាទ ។ ទាំងអរិយសច្ចៈបួន ទាំងបដិច្ច-សមុប្បាទ សុទ្ធតែពាក់ព័ន្ធទៅនឹងការបំផ្លាញអវិជ្ជា ។ ក្នុងន័យនេះ អវិជ្ជា គឺជាបញ្ហាស្នូល, គំនិតស្នូល ទាំងនៅក្នុងរូបមន្តនៃអរិយសច្ចៈបួន ទាំងនៅក្នុងរូបមន្តបដិច្ច-សមុប្បាទ ។

ឥឡូវ ចូរយើងក្រឡេកមើលអរិយសច្ចៈបួនម្តងទៀត មួយភ្លែតសិន ។

គន្លឹះដើម្បីប្រែក្លាយបទពិសោធន៍របស់បុគ្គល ពីបទពិសោធន៍នៃទុក្ខ មកបទពិសោធន៍នៃការបញ្ចប់ទុក្ខ គឺជាការយល់ដឹងនូវអរិយសច្ចៈទីពីរ ពោលគឺ សច្ចៈនៃសមុទយទុក្ខ ។ ពេលណាយើងយល់ដឹងសមុទយទុក្ខហើយ, បន្ទាប់មក យើងអាចប្រព្រឹត្តដើម្បីសំរេចនូវការបញ្ចប់ទុក្ខបាន ។ អរិយសច្ចៈបួន ដូចដែលយើងបានពិភាក្សាចែកចេញជាពីរក្រុមគឺ ពីរប្រការត្រូវបោះបង់ចោល និងពីរប្រការទៀត ត្រូវសំរេចអោយបាន . ទុក្ខសច្ចៈ និងសមុទយសច្ចៈ ត្រូវបោះបង់ចោល, ហើយនិរោធ-សច្ចៈ និងមគ្គសច្ចៈ ត្រូវសំរេចអោយបាន ។ ការយល់ដឹងនូវហេតុនៃទុក្ខ (សមុទយ-សច្ចៈ) ធ្វើអោយគេអាចបំពេញកិច្ចការនេះបាន ។ យើងអាចមើលឃើញបញ្ហានេះដោយច្បាស់លាស់បាននៅក្នុងការពណ៌នារបស់ព្រះពុទ្ធ អំពីបទពិសោធន៍របស់ព្រះអង្គ ក្នុងរាត្រីនៃការត្រាស់ដឹងរបស់ព្រះអង្គ ។ ពេលដែលព្រះអង្គបានរកឃើញហេតុនៃទុក្ខហើយ, ពេលដែលព្រះអង្គទ្រង់បានឈ្វេងយល់ថា រាគៈ, ទោសៈ និងអវិជ្ជា គឺជាហេតុនៃទុក្ខហើយ, ទស្សនញ្ញាណនេះបានបើកទ្វារអោយព្រះអង្គសំរេចការត្រាស់ដឹង ។ អវិជ្ជា, រាគៈ និងទោសៈ គឺជាហេតុនៃទុក្ខ ។ បើយើងចង់បន្ថយការត្រួតពិនិត្យរបស់យើងឈានទៅរកគំនិតដ៏មានសារសំខាន់បំផុត, យើងត្រូវផ្តោតលើអវិជ្ជាពិព្រោះតែអវិជ្ជា ទើបរាគៈ និងទោសៈ កើតឡើងបាន ។

ជាសារវន្ត, អវិជ្ជា គឺជាមតិស្តីពីអត្តៈ (អាត្មា) ជាអចិន្ត្រៃយ៍, ឯករាជមួយ ។ នេះគឺជាមតិបញ្ញត្តិអំពី «អាត្មា» (អញ) ដែលផ្ទុយ និងដែលដាច់ចេញពីមនុស្ស និងវត្ថុទាំងឡាយនៅជុំវិញយើង ។ ពេលណាយើងមានការយល់ដឹងពី «អាត្មា» (អញ) ហើយ, យើងមានទំនោរចិត្តផ្តល់ការអនុគ្រោះដល់អ្វីៗទាំងអស់នោះដែលជួយទ្រទ្រង់ «អាត្មា» នេះ, ហើយមានទំនោរចិត្តស្អប់ខ្ពើមអ្វីៗទាំងអស់នោះ, ដែលយើងយល់ថា គំរាមកំហែង «អាត្មា» នេះ ។ គឺមតិបញ្ញត្តិអំពីអត្តៈនេះហើយដែលជាមូលហេតុនៃទុក្ខ, ជាឫសគល់នៃចិត្តវេគ (emotions) . រាគៈ, កោធៈ,

ទោសៈ, ឥច្ឆា, តណ្ហា និងច្រណែនឈ្នានីស ។ គឺភាពល្ងង់ខ្លៅ មិនដឹងហេតុពិត ដែលថា « អាត្មា », អត្តៈ ដែលគេហៅដូច្នេះ គឺគ្រាន់តែជាឈ្មោះស្រួលសំគាល់ ចង្អោមកត្តាប្រែប្រួល, ពឹងផ្អែក, ផ្សេងព្រេង ប៉ុណ្ណោះ ។ តើវាមានព្រៃក្រៅពីដើម ឈើកើតឬទេ ? អត្តៈ គឺគ្រាន់តែជាឈ្មោះសម្រួលសម្រាប់សំគាល់ចង្អោមអភិក្រម ទាំងឡាយ ។ អត្តៈ គឺជាហេតុនៃទុក្ខ និងភ័យ ។ នៅក្នុងបរិបទនេះ អត្តៈ គឺប្រដូច ទៅនឹងការច្រឡំខ្សែព្រួរ ថាជាពស់ក្នុងពេលងងឹត, យើងអាចនឹងស្មានថា ខ្សែព្រួរគឺជា ពស់មែនទែន ហើយការស្មាននេះ គឺជាហេតុនាំអោយមានភ័យ ។ ដូចគ្នានេះដែរ, នៅ ក្នុងអវិជ្ជា យើងគិតថា អភិក្រមអនត្តៈ, អនិច្ចៈនៃវេទនារម្មណ៍, ការយល់ដឹងដោយ វិញ្ញាណ (perceptions) ជាដើម .... គឺជាអត្តៈ, ហើយ លទ្ធផល, យើងមាន ប្រតិកម្មចំពោះស្ថានភាពទាំងឡាយ ដោយសេចក្តីសង្ឃឹម និងភ័យ ។ យើងចង់បាន វត្ថុណានិមួយ ហើយយើងស្អប់វត្ថុឯទៀត ។ យើងចូលចិត្តមនុស្សខ្លះ យើងស្អប់ មនុស្សខ្លះទៀត ។ ដូច្នេះ អវិជ្ជា ក្នុងន័យនេះ គឺជាសញ្ញាណ (សេចក្តីយល់ដឹង) ភ័ន្ត ច្រឡំអំពីអាត្មាមួយថិតថេរ, អំពីអាត្មាមួយពិតប្រាកដ ។ ការប្រៀនប្រដៅអំពីអនត្តៈ នេះ មិនផ្ទុយនឹងក្រឹត្យក្រមអំពីការទទួលខុសត្រូវខាងសីលធម៌, ក្រឹត្យក្រមអំពីកម្ម ទេ ។ តាមពិត លោកអ្នកនឹងនឹកឃើញថា យើងបានរៀបរាប់ពីសម្មាទិដ្ឋិ ក្នុងន័យមាន ពីរទិដ្ឋិភាព, គឺការយល់ដឹងក្រឹត្យក្រមកម្ម ហើយក្នុងទីនេះ គឺជាការមើលឃើញអ្វីៗ ទាំងអស់ ដូចដែលវាមានពិតមែន (ជាយថាភូត), ការយល់ដឹងធម្មជាតិនៃជីវិត ។ ពេលណាមួយ អត្តទិដ្ឋិ (egoism) ត្រូវបានកំចាត់, ពេលណាមួយ សញ្ញាណភ័ន្ត ច្រឡំអំពីអត្តៈ ត្រូវបានបំបាត់ដោយសម្មាទិដ្ឋិ, ពេលនោះ តណ្ហា, ទោសៈ និងបាបធម៌ ឯទៀត មិនកើតមានទេ ។ កាលណាអត្តទិដ្ឋិនេះបញ្ឈប់បាន, ការបញ្ចប់នៃទុក្ខ ក៏សំរេចបាន ។ ខ្ញុំមិនសង្ឃឹមថា អត្តទិដ្ឋិនេះត្រូវបានមនុស្សគ្រប់រូបយល់ច្បាស់លាស់ ភ្លាមៗទេ ។ យើងត្រូវចំណាយពេលប្រជុំច្រើនដងទៀត នៅក្នុងសប្តាហ៍ក្រោយៗ

ទៀត សិក្សាស៊ីជម្រៅ និងពង្រីកការពិនិត្យពិចារណាអំពីធម្មជាតិនៃអវិជ្ជា ។

ចូរយើងបន្តសិក្សាផ្នែកបន្ទាប់នៃមាគ៌ា ( មគ្គ: ) ដែលឋិតនៅក្នុងក្រុមបញ្ញា ហើយផ្នែកនោះគឺ សម្មាសង្កប្បៈ ។ ក្នុងទីនេះ យើងចាប់ផ្តើមពិចារណាការបញ្ចូលជាថ្មី, ការអនុវត្តជាថ្មី នៃក្រុមបញ្ញាទៅក្នុងវិស័យនៃសុចរិយា (សីល) ពិព្រោះសង្កប្បៈ (ការត្រិះរិះ ឬការគិត) មានឥទ្ធិពលសម្បើមណាស់ទៅលើចរិយា ឬការប្រព្រឹត្ត ។ ព្រះពុទ្ធទ្រង់មានបន្ទូលថា ប្រសិនបើបុគ្គលប្រព្រឹត្ត ឬនិយាយប្រកបដោយចិត្តបរិសុទ្ធ, បន្ទាប់មក សេចក្តីសុខ (សុភមង្គល) រមែងដើរតាម បីដូចស្រមោលរបស់គេ ដែលមិនឃ្លាតចេញសោះឡើយ ។ ហើយប្រសិនបើគេនិយាយ និងប្រព្រឹត្តប្រកបដោយចិត្តប្រទូស្ត, បន្ទាប់មក សេចក្តីទុក្ខរមែងទៅតាម បីដូចជាកង់តែងវិលទៅតាមជើងគោ ដូច្នោះ ។ សង្កប្បៈ មានឥទ្ធិពលយ៉ាងធំសម្បើមទៅលើចរិយាមារយាទរបស់បុគ្គល ។ សម្មាសង្កប្បៈ មានន័យថា ការជៀសវាងរាគៈ និងទោសៈ ។ ដូច្នេះ លោកអ្នកអាចមើលឃើញ ថាតើបញ្ញាមានសារសំខាន់យ៉ាងណា ពិព្រោះហេតុនៃសេចក្តីទុក្ខ ត្រូវបានគេអោយឈ្មោះថា : រាគៈ, ទោសៈ និងអវិជ្ជា ។ សម្មាទិដ្ឋិ កំចាត់ចោលនូវអវិជ្ជា ។ សម្មាសង្កប្បៈ កំចាត់ចោលនូវរាគៈ និងទោសៈ ។ ដូច្នេះ សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ កំចាត់ចោលនូវហេតុ និងទុក្ខ ។

ដើម្បីកំចាត់បង់នូវរាគៈ និងលោភៈ, យើងចាំបាច់ត្រូវបណ្តុះអភិនិ-ស្រ្កមណ៍ (ការចេញសាងផ្នួស) ឬការផ្តាច់ចំណង់ចិត្តជាប់ជំពាក់ ។ ដើម្បីកំចាត់បង់នូវទោសៈ យើងត្រូវបណ្តុះមេត្តា និងករុណា ។ តើត្រូវបណ្តុះអាកប្បកិរិយា នៃអភិនិស្រ្កមណ៍, មេត្តា និងករុណាយ៉ាងណា ដែលនឹងទុកជាឱសថរំងាប់ពិសរាគៈ និងទោសៈបាន ? ជាបឋម, អភិនិស្រ្កមណ៍ត្រូវបានបណ្តុះឡើងតាមការត្រិះរិះពិចារណាលើធម្មជាតិពោរពេញដោយទុក្ខនៃជីវិត, ជាពិសេស គឺទុក្ខទោមនស្ស កើតចេញពីកាមសុខ ។ យើងប្រៀបប្រដូចកាមសុខ ទៅនឹងទឹកអំបិល (ទឹកប្រៃ) ។

មនុស្សស្រេកទឹក ដែលផឹកទឹកប្រៃ កាន់តែបង្កើនសម្រេករបស់គេខ្លាំងទៀតប៉ុណ្ណោះ ។ មនុស្សនោះ មិនអាចបំបាត់ការស្រេកបានទេ ។ ម្យ៉ាងទៀត ព្រះពុទ្ធទ្រង់បានប្រដូចកាមសុខ ទៅនឹងផ្លែឈើដែលគេហៅថា ផ្លែកិម្ព ។ គឺជាផ្លែឈើមួយដែលមានរូបភាពគួរជាទីពេញចិត្ត ។ វាមានសំបករលោង ។ វាមានក្លិនក្រអូប និងមានរស់ជាតិឆ្ងាញ់ ។ ប៉ុន្តែ វាបណ្តាលអោយមានគ្រោះថ្នាក់ ពិព្រោះ វាមានជាតិពុលកាលណាគេបរិភោគវា ។ ដូចគ្នានេះដែរ, កាមសុខ (សេចក្តីសប្បាយរីករាយតាមផ្លូវវិញ្ញាណ) គឺជាសភាវៈទាក់ទាញចិត្ត, សប្បាយរីករាយ, ប៉ុន្តែថា វាបង្កអោយកើតមានមហន្តរាយ ។ ដូច្នេះ ដើម្បីបណ្តុះចិត្តឥតជាប់ជំពាក់ (Detachment), បុគ្គលត្រូវពិចារណាអំពីផលវិបាកដ៏អប្រិយ៍នៃកាមសុខ ។ បន្ថែមលើនេះទៀត, បុគ្គលត្រូវជញ្ជឹងគិតមើល, ត្រូវយល់ថា ធម្មជាតិ (ឬចរិត) នៃសង្ខារៈ គឺទុក្ខៈ ។ គឺថាទោះបីជាបុគ្គលអាចកើតនៅក្នុងទីកន្លែងណាក៏ដោយ អោយតែនៅក្នុងព្រំដែននៃខួប (វដ្ត) កើត និងស្លាប់, ស្ថានភាពនោះ នៅតែគ្របដណ្តប់ដោយទុក្ខ ។ ធម្មជាតិនៃសង្ខារៈ គឺទុក្ខ បីដូចជាធម្មជាតិនៃភ្លើង គឺកម្តៅ ។ តាមរយៈការយល់ដឹងនូវធម្មជាតិ មិនជាទីពេញចិត្តនៃជីវិត, និងតាមរយៈការដឹងច្បាស់នូវផលវិបាក មិនគួរចង់បាននៃកាមសុខ គេអាចបណ្តុះបាននូវចិត្តឥតជាប់ជំពាក់ ។

គេអាចបណ្តុះមេត្តា និងករុណា តាមរយៈការទទួលស្គាល់សមភាព ជាសារវន្តនៃសព្វសត្វមានជីវិត ។ សត្វទាំងអស់ខ្លាចសេចក្តីស្លាប់, សត្វទាំងអស់ភ័យរន្ធត់ចំពោះទណ្ឌកម្ម ។ ទទួលស្គាល់សភាវធម៌នេះ, គេមិនគប្បីសម្លាប់ ឬញ៉ាំងអោយគេសម្លាប់អ្នកដទៃឡើយ ។ សត្វទាំងអស់ចង់បានសេចក្តីសុខ, សត្វទាំងអស់ខ្លាចការឈឺចាប់ ។ នៅក្នុងស្ថានភាពនេះ, យើងទាំងអស់គ្នា គឺដូចពៃគ្នា ។ សព្វសត្វមានជីវិត គឺដូចគ្នា ។ ទទួលស្គាល់សភាវធម៌នេះ គេមិនគប្បីមិនតម្កើងខ្លួនឯងអោយខ្ពស់លើសអ្នកដទៃឡើយ, គេមិនគប្បីចាត់ទុកខ្លួនឯងផ្សេងពីបែបបទ ដែលខ្លួនត្រូវ

ចាត់ទុកអ្នកដទៃឡើយ ។ ការទទួលស្គាល់សមភាព ជាមូលដ្ឋានរបស់សត្វមានជីវិតទាំងអស់ គឺជាគ្រឹះសម្រាប់បណ្តុះមេត្តា និងករុណា ។ សត្វទាំងអស់ប្រាថ្នាសេចក្តីសុខ ក៏ដូចជាអាត្មាអញប្រាថ្នាសេចក្តីសុខដែរ ។ យល់ដឹងបាននូវសភាវធម៌នេះ គេត្រូវចាត់ទុកសត្វមានជីវិតទាំងអស់ប្រកបដោយក្តីមេត្តា និងករុណា ។ គេត្រូវបណ្តុះបំណងប្រាថ្នានេះ ថាសត្វមានជីវិតទាំងអស់ សូមបានសេចក្តីសុខ ។ បីដូចជាអាត្មាអញខ្លាចសេចក្តីទុក្ខ និងការឈឺចាប់, ហើយប្រាថ្នាជៀសវាងផុតពីនេះ, ឯសត្វមានជីវិតទាំងអស់ ក៏ខ្លាចសេចក្តីទុក្ខ និងការឈឺចាប់ដូច្នេះដែរ, ហើយគេចេញអោយផុតពីនេះ ។ យល់ដឹងសភាវធម៌នេះ គេត្រូវអភិវឌ្ឍ និងបណ្តុះអាកប្បកិរិយាមួយដែលចង់ឃើញសត្វមានជីវិតទាំងអស់រួចចាកផុតពីទុក្ខ ។

នៅក្នុងបែបនេះ យើងអាចអភិវឌ្ឍ និងបណ្តុះអាកប្បកិរិយាអភិនិស្រ្កមណ៍, មេត្តា និងករុណា ដែលជះប្រតិកម្មរវាងគ្នានិងគ្នា ហើយលុបបំបាត់ជាយថាហេតុ នូវលោភៈ និងទោសៈបាន ។ ជាអវសាន, តាមរយៈបញ្ញា, ក្រោយបានលុបបំបាត់អវិជ្ជា, លោភៈ និងទោសៈហើយ, ក្រោយបានសំអាតខ្លួនយើងអោយបរិសុទ្ធចាកកិលេសទាំងបីយ៉ាងនោះហើយ, យើងអាចចាប់បាននូវសេរីភាព ដ៏ជាគោលដៅចុងក្រោយ ដែលជាគោលបំណងនៃអរិយដ្ឋង្គិកមគ្គ, ដ៏ជាបរមសុខនៃនិព្វាន ។

*( នៅមាន ត )*

# ព្រះពុទ្ធសាសនា គឺជាគ្រឹះនៃការប្រតិបត្តិ សំរាប់ការរស់នៅផាំងអស់គ្នា(*)

សត្វលោកដែលត្រូវអវិជ្ជាបិទបាំង មានសេចក្ដីត្រេកត្រអាល (នន្ទិរាគៈ) ជាគ្រឿងចងទុក មានការរិះគិត (វិតក្កស្ស វិចារណា) ជាគ្រឿងបញ្ជាទៅ រមែងក្ដៅផ្សាដោយភ្លើងទុក្ខនិងភ្លើងកិលេស ហើយអន្ទោលទៅក្នុងសង្សារវដ្ដ គ្មានទីបញ្ចប់ ។

ធម្មជាតិទាំងឡាយណា មានកិរិយាកើតឡើងជាធម្មតា ធម្មជាតិទាំងនោះ ក៏រីកល្វតលាស់នាំទៅរកសេចក្ដីវិនាសអន្តរធានសាបសូន្យទៅជាធម្មតា, មិនបានទៀងនៅជាអមតៈទេ, សូម្បីតែដំណើរនៃលោកដែលមានការកើតជាខាងដើម និងការវិនាសទៅជាខាងចុង ក៏មានការវិលទៅមុខជានិច្ច ឥតឈប់ឈរ ដូចជាកង់ចក្រ ហើយក៏គ្មានអ្នកណាជាអ្នកបង្កើតក្រៅតែពីហេតុបច្ច័យ ប៉ុណ្ណោះ ល្អីកណាបើគ្មានហេតុបច្ច័យទេ ក៏មិនអាចកើតឡើងបានដែរ ។

ក្នុងដំណើរនៃលោកដែលវិវត្តមកដល់សម័យកាលនៃវិទ្យាសាស្ត្រកាន់តែរីកចំរើនឥតឈប់ឈរនេះ, អាវុធប្រល័យជីវិតក៏កាន់តែទំនើប និងមានប្រសិទ្ធភាពខ្ពស់ ចំណែកគ្រោះថ្នាក់នៃបាតុភូតដ៏អាក្រក់នៃធម្មជាតិ ក៏កាន់តែកើតមានឡើងប្លែកៗ ហើយជម្លោះនៃសង្គ្រាមសេដ្ឋកិច្ច សង្គ្រាមឈ្លានពាន សង្គ្រាមសាសនា សង្គ្រាមស៊ីវិល សង្គ្រាមដណ្ដើមអំណាចនៃលទ្ធិនយោបាយ ការវាយប្រហារដោយសង្គ្រាមពាក្យសំដី អំពើហិង្សាជាដើម ជាទូទៅ ក៏បន្តកើតមាននៅឡើយ ទោះបីជាមានច្បាប់ និងទណ្ឌកម្មក៏ដោយ ទាំងនេះក៏ព្រោះតែមានហេតុរបស់វាដែរ គឺការថយចុះនៃគុណធម៌ សីលធម៌ មនុស្សធម៌ និងព្រហ្មវិហារធម៌ជាដើមនោះឯង និងការរីកដុះដាលឡើងនៃអកុសលធម៌ អមនុស្សធម៌ មហិច្ឆតាលោភលន់ ការចងគំនុំគុំគួន

(*) ធម្មទេសនារបស់សម្ដេចព្រះមហាឃោសានន្ទ ក្នុងពិធីប្រកាសទទួលរង្វាន់ នីវ៉ាណូ

មិច្ឆាទិដ្ឋិ ការប្រកាន់មានះរើសអើង ការមិនចេះអនុគ្រោះ ការបំផ្លាញបរិដ្ឋាន សេចក្តីកំណាញ់ សេចក្តីនិន្ទាឈ្នានីស ជាដើមនោះឯង ។

ចំណែកឯព្រះពុទ្ធ បានណែនាំអោយលះបង់នូវលោភៈ ទោសៈ មោហៈ ដែលជាហេតុនៃរឿងរ៉ាវដ៏អាស្រូវទាំងនោះ ចេះរស់នៅដោយសុខស្ងប់ផ្លូវកាយ និងសន្តិភាពផ្លូវចិត្តក្នុងអហិង្សាធម៌ ដោយមិនបៀតបៀនខ្លួនឯង ជាងមិនបៀតបៀនអ្នកដទៃផង ពោលគឺ អោយចេះអនុគ្រោះគ្នាក្នុងការរស់នៅប្រកបដោយធម៌ ៤ យ៉ាងគឺ : ការមានចិត្តទូលាយ ចេះចែកចាយធ្វើទាន ១, ពោលពាក្យគួរជាទីស្រលាញ់ ១, ប្រព្រឹត្តជាប្រយោជន៍ដល់គ្នាទៅវិញទៅមក ១, តម្កល់ខ្លួនស្មើក្នុងព្រះធម៌ ១ ; ទាំងបានមានពុទ្ធដីកាថា *« ការស្រុះស្រួលសាមគ្គីគ្នា រមែងបានសេចក្តីសុខ » « សេចក្តីសន្តោសព្រមត្រេកអររបស់តាមមានតាមបាន ជាទ្រព្យដ៏ប្រសើរ របស់បុគ្គល »* តែមិនមែនមានន័យថាអោយខ្ជិលទេ គឺថា ការស្វែងរកប្រយោជន៍បច្ចុប្បន្នត្រូវប្រកបដោយអង្គ ៤ៈ មានការប្រឹងប្រែងព្យាយាម ១, ការចេះរក្សាទុកដាក់ ១, ការចិញ្ចឹមជីវិតអោយស្មើតាមព្រះធម៌ ១, ការសេពគប់មនុស្សបានត្រឹមត្រូវ ១ ។ ម្យ៉ាងទៀត ក៏បានអោយចៀសវាងនូវហេតុ នូវសេចក្តីវិនាស ចង្រៃឧត្បាត ដែលមាន ១២ ជំពូក ក្នុងបរាភវសូត្រ ដូចជាការពេញចិត្តនឹងធម៌របស់អសប្បុរស, ការប្រាកដតែខាងខឹងក្រេវក្រោធ ការមានទ្រព្យសម្បត្តិច្រើន ហើយមិនចិញ្ចឹមមាតាបិតា ជាដើម និងអោយស្វែងរកនូវសុភមង្គលសិរីសួស្តី ដែលមាន ៣៨ ប្រការក្នុងមង្គលសូត្រ ដូចជាការមិនសេពគប់បុគ្គលពាល ការនៅក្នុងស្រុកទេសដ៏សមគួរ ភាពជាអ្នកចេះដឹងច្រើន ការតម្កល់ខ្លួនអោយល្អ ការប្រព្រឹត្តបន្ទាបខ្លួន ការធ្វើការងារអោយពិតប្រាកដ មិនច្របូកច្របល់ ការចេះព្រមត្រេកអររបស់តាមមានតាមបាន ការបរិច្ចាគទានចែកចាយ សេចក្តីអត់ធ្មត់ ការអោយចេះអនុគ្រោះគ្នាតាមសង្គហធម៌ក្នុងសង្គមគ្រួសារ ការពោលវាចាអោយបានត្រឹមត្រូវជាដើម ។ ទាំងនេះគ្រាន់តែជា

ចំណែកដ៏តូចមួយនៃព្រះធម៌ ដែលមាន ៨៤.០០០ ធម្មក្ខន្ធ ប៉ុណ្ណោះ តែទោះយ៉ាងដូច្នោះក៏ដោយ បើបំពេញអោយខ្លី នៅត្រង់ឱវាទ ៣ ម៉ាត់គឺ : ការមិនអោយធ្វើអំពើអាក្រក់គ្រប់យ៉ាង, ការធ្វើតែអំពើល្អ, ការសំអាតចិត្តអោយបរិសុទ្ធចាកមន្ទិល មានលោភៈ ទោសៈ មោហៈ ជាដើម ។

វាចាំបាច់ដែរ សម្រាប់យើងរាល់គ្នា ក្នុងការដុសខាត់កិលេស មានលោភៈ ទោសៈ មោហៈ ជាដើម ព្រោះថា កាលបើកិលេសនេះក្លៀវក្លាឡើងហើយ ធ្វើអោយមនុស្សចេះភូតកុហក បោកប្រាស ការកាប់សម្លាប់ អំពើហិង្សា និងអំពើដ៏លាមកដទៃទៀត ។

លោភៈ បើគ្របសង្កត់បុគ្គលណាហើយ ធ្វើអោយបុគ្គលនោះវង្វេងមិនឃើញធម៌អនិច្ចំ គ្មានសេចក្តីខ្មាស គ្មានធម៌សន្តោស ( ត្រេកអរតាមមានតាមបាន ) ក្រាស់ដោយមហិច្ឆតា ទោះបីជាមានទ្រព្យ អំណាចច្រើនហើយក៏ដោយ ក៏មិនបានសុខស្ងប់ចិត្ត ពោលគឺ តែងតែអន្ទះសាក្តៅក្រហាយ រហូតដល់ធ្វើនូវអំពើដែលមិនប្រកបតាមគន្លងធម៌បានកាន់តែច្រើន សេចក្តីខ្វះខាតកាន់តែធំធេង ដូចពុទ្ធភាសិតថា *អ្នកបរិភោគកាម សុទ្ធតែជាអ្នកខ្វះខាតរហូតដល់លះបង់រាងកាយទៅ* ។

ទោសៈ កាលបើគ្របសង្កត់ជនណាហើយ ជននោះគឺជាមនុស្សគ្មានមេត្តាធម៌ មនុស្សវង្វេងបាំងទុក្ខ និងប្រព្រឹត្តទុច្ចរិតផ្សេងៗ ដូចជាការបង្កជម្លោះ ការចង់កំចាត់នូវពៀរដោយតាមសងសឹក ចង់ឈ្នះកោធជនដោយការខឹងក្រេវក្រោធតបតដែលមិនខុសអ្វីអំពីការចង់ឈ្នះអគ្គីកំពុងឆេះ ដោយការយកឥន្ធនៈមកជះពន្លត់ដូច្នេះឯង ហើយទីបំផុត គឺសុទ្ធតែជាអ្នកចាញ់ គឺចាញ់កិលេសបាបក្នុងខ្លួនឯង ច្រើនតែបង្កវេរាគ្មានទីបញ្ចប់ ។

ដូច្នេះ យើងគួរតែយកជ័យជំនះលើខ្លួនឯង ដោយអប់រំចំរើនព្រហ្មវិហារធម៌ដល់បុគ្គលទូទៅ ទោះជាមិនជាទីស្រឡាញ់ ទោះបីជាយ៉ាងណា, ចំពោះបុគ្គលមិន

ជាទីស្រឡាញ់ យើងចំរើនមេត្តាសម្លឹងតែត្រង់ចំណុចល្អរបស់ជននោះ ដូចបុគ្គលណាដើរផ្លូវឆ្ងាយស្រេកទឹកហើយបានជួបស្រះ គួរតែវែកចកនិងសារាយចេញ ហើយក្រេបផឹកតែត្រង់ទឹកថ្លាប៉ុណ្ណោះ ។ ដូច្នេះ យើងមិនត្រូវក្រោធខឹងនឹងមនុស្សឆ្កួតទេ តែយើងគ្រាន់តែធ្វើយ៉ាងណា កុំអោយមនុស្សឆ្កួតនោះបៀតបៀនបាន និងធ្វើអោយចិត្តរបស់យើងបានរួចផុតពីកណ្តាប់ដៃនៃកិលេសមារដ៏លាមក និងបានជ័យជំនះលើខ្លួនឯងតែប៉ុណ្ណោះ ។ ទោះបីបុគ្គលឈ្នះក្នុងសង្គ្រាមមួយពាន់ គុណនឹងមួយពាន់ដងក៏ដោយ ក៏ព្រះពុទ្ធមិនទាន់អោយឈ្មោះថាជាអ្នកមានជ័យជំនះដែរ ចំណែកឯបុគ្គលណាដែលឈ្នះខ្លួនឯងតែម្នាក់គត់បាន ទើបមានឈ្មោះថាជាអ្នកមានជ័យជំនះដ៏ប្រសើរឯក ព្រោះគ្មានបុគ្គលណាមួយ សូម្បីមនុស្ស ទេវតា ក៏មិនអាចធ្វើអោយបរាជ័យបានដែរ ម្យ៉ាងទៀត បុគ្គលណារក្សាខ្លួនបានខាងក្រៅរបស់អ្នកនោះ ឈ្មោះថា ខ្លួនបានរក្សាល្អហើយ ។

មុននឹងស្វែងរកកល្យាណមិត្តល្អខាងក្រៅ គួរតែធ្វើខ្លួនឯងអោយជាមិត្តល្អសិន ក៏ដូចជាមុននឹងស្វែងរកសុខសន្តិភាពជូនសង្គមជាតិ គួរតែធ្វើខ្លួនឯងអោយមានសន្តិភាព និងគុណធម៌ជាមុនសិន ព្រោះថា ចំណេះវិជ្ជា ទ្រព្យសម្បត្តិ អំណាចបើធ្លាក់ដល់កណ្តាប់ដៃបុគ្គលគ្មានគុណធម៌ហើយ វាតែងបង្កអោយមានគ្រោះថ្នាក់ដល់អ្នកដទៃ និងបំផ្លាញនូវកុសលធម៌របស់ខ្លួនឯងតែប៉ុណ្ណោះ ។

នរជនណារស់នៅបានតែមួយថ្ងៃ ក៏ដាច់ខ្យល់ស្លាប់ទៅវិញ តែជាបុគ្គលមានគុណធម៌ ដូចជាសីល ទាន បញ្ញា ឬ ការបានឃើញព្រះធម៌ជាដើម គង់ប្រសើរវិសេសជាងបុគ្គលរស់នៅបានរាប់រយឆ្នាំ ដែលគ្មានគុណធម៌ ដូច្នេះ បើយើងចង់អោយជីវិតមានន័យខ្លឹមសារ និងឈ្មោះជាអ្នកស្រឡាញ់ខ្លួន និងសន្តិភាពពិតប្រាកដនោះ គួរតែរកសន្តិភាអោយខ្លួន កុំអោយជាមនុស្សចង្អៀតលោក និងរក្សាខ្លួនរឿយៗ ដោយកុំដុតខ្លួនឯងឡើយ ព្រោះថា បុគ្គលល្ងង់ មានខ្លួនឯងជាសត្រូវចំពោះ

ខ្លួនឯង ដូចច្រេះកើតអំពីដែក រមែងស៊ីនូវដែកនោះវិញ ។

បុគ្គលដែលមានការទូន្មានដោយព្រះធម៌នៃព្រះពុទ្ធសាសនាបានល្អហើយនោះ ឈ្មោះថាបាននូវទីពឹងដែលគេបានដោយកម្រ និងរស់នៅដោយសុខសន្តិភាព ដូច្នេះ ព្រះពុទ្ធសាសនាដើរតួនាទីសំខាន់ណាស់ក្នុងការទប់ស្កាត់ និងលុបបំបាត់នូវអំពើហិង្សា ការលួច ឆក់ ប្លន់ ការកាប់សម្លាប់ ការបង្កសង្គ្រាម អំពើពុករលួយ ការរំលោភច្បាប់ អំពើលាមករាប់រយជំពូកដទៃទៀត ។

ព្រះពុទ្ធសាសនា គឺជាគ្រឹះកំពូលនៃប្រព័ន្ធសីលធម៌ ប្រសើរលើសច្បាប់ និងសីលធម៌ធម្មតា និងក៏ជាទ្រឹស្តីនៃវិទ្យាសាស្ត្រ ដែលភ្ជាប់ហេតុពិតទៅនឹងផល ដូចជាបដិច្ចសមុប្បាទ ចតុរារិយសច្ចៈជាដើម លើសពីនេះទៅទៀត ព្រះធម៌ ៨.២០០ ធម្មក្ខន្ធក្នុងអភិធម្មបិដក មានអត្ថន័យទស្សនវិជ្ជាជ្រាលជ្រៅហួសនិស្ស័យនៃគំនិតរបស់មនុស្សលោកសាមញ្ញ ដែលប្រឹងគិតរាវរកអោយឃើញបានដោយខ្លួនឯង និងដោយគ្មានព្រះពុទ្ធត្រាស់ដឹងឡើងទេនោះ ។

ព្រះពុទ្ធមិនមែនជាអ្នកបង្កើតធម៌ទេ តែព្រះអង្គគ្រាន់តែរកធម៌ឃើញប៉ុណ្ណោះ ដោយប្រើពេលកសាងសន្សំអភិនីហារបារមី ដើម្បីត្រាស់ដឹង អស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប ។ ធម៌នេះក៏មិនមែនជាកម្មសិទ្ធិផ្ទាល់មុខរបស់បុគ្គល ឬជនជាតិណាមួយឡើយ ព្រោះថា បុគ្គលណាក៏ដោយអោយតែប្រព្រឹត្តតាមព្រះធម៌បានត្រឹមត្រូវហើយ ព្រះធម៌តែងនាំសេចក្តីសុខអោយដល់ជនទាំងអស់នោះ « *ធម្មោ សុចិណ្ណោ សុខមាវហាតិ* » ដូច្នេះ ព្រះពុទ្ធសាសនា គឺជាច្បាប់សកល និងជាគ្រឹះសំរាប់យើងទាំងអស់គ្នា ក្នុងពិភពលោកគោរពប្រតិបត្តិ ដើម្បីបានសុខសន្តិភាព ស្ថិរភាព សុភមង្គល ការបានប្រយោជន៍ខ្លួនឯងផង ប្រយោជន៍អ្នកដទៃផង ប្រយោជន៍ក្នុងការរស់នៅក្នុងបច្ចុប្បន្នផង ប្រយោជន៍បរលោកផង និងប្រយោជន៍ ដ៏ក្រៃលែង គឺព្រះនិព្វានជាទីបំផុត នៃការអន្ទោលទៅក្នុងសង្សារវដ្តផងដែរ ៕

# វចនស័ព្ទវិទ្យា
# នៃភាសាខ្មែរបច្ចុប្បន្ន (ត)
# Lexicologie du Khmer Moderne

## បម្រែបម្រួលសេម៉ង់ទិក

ក្នុងចំណោមភាសាមន-ខ្មែរទាំងអស់ ភាសាខ្មែរមានបម្រែបម្រួលស្វរស័ព្ទ រូបស័ព្ទ និងសេម៉ង់ទិកច្រើនជាងគេ ។ អំពីបាតុភូតទាំងពីរនេះ គេអាចពន្យល់បាន ដោយសារមូលហេតុពីរយ៉ាង ៖

- ទីតាំងភូមិសាស្ត្រនៃប្រទេសកម្ពុជា ស្ថិតនៅចំទីប្រជុំផ្លូវកាត់គ្នា ដែលនាំមកនូវអារ្យធមិបរទេសនានា ដូចជា ឥណ្ឌា, ចិន, លោកខាងលិច ... ។

- នៅក្នុងប្រវត្តិសាស្ត្រកន្លងមក ភាសាខ្មែរមានទំនាក់ទំនងឥតឈប់ឈរជាមួយភាសាដទៃទៀត ដូចជាភាសាសំស្ក្រឹត បាលី ចាម ម៉ាលេស៊ី ចិន យួន ថៃ បារាំង ។ ល ។

ក៏ដូចជាភាសាដទៃទៀតដែរ សមាសភាពវចនស័ព្ទនៃភាសាខ្មែរ មានការរីកចំរើនឥតឈប់ឈរ ។ ក្នុងសម័យកាលប្រវត្តិសាស្ត្រនីមួយៗ ពាក្យថ្មីៗមួយចំនួនបានកកើតឡើង និងពាក្យមួយចំនួនស្ថិតនៅខាងក្រៅនៃការប្រើប្រាស់ ។ កំណកំណើតពាក្យថ្មី មានទំនាក់ទំនងទៅនឹងការរីកចំរើនផ្នែកសេដ្ឋកិច្ច នយោបាយ និងវប្បធមិ របស់ប្រជាជន ។ ការបាត់បង់ពាក្យមួយចំនួនចេញពីភាសា ជាបឋម គឺជាផលវិបាកនៃការបាត់បង់វត្ថុមួយចំនួន ឬស្ថាប័ននយោបាយមួយចំនួន ។

នៅក្នុងភាសាខ្មែរ គេសង្កេតឃើញបម្រែបម្រួលនិយមន័យរបស់ពាក្យមានច្រើនបែបច្រើនយ៉ាងណាស់ ប៉ុន្តែ គេអាចបែងចែកគោលការណ៍ទាំងនេះជាពីរក្រុមសំខាន់ៗ គឺ គោលការណ៍ក្នុងភាសាវិទ្យា និងគោលការណ៍ក្រៅភាសាវិទ្យា ។

• គោលការណ៍ក្នុងភាសាវិទ្យា គឺត្រូវកំណត់ដោយបម្រែបម្រួលរបៀបរបបនៃរូបស័ព្ទ សូរស័ព្ទ និងសម្ពន្ធ ឬនិយាយម្យ៉ាងទៀតថា ត្រូវកំណត់ដោយកត្តាផ្ទាល់នានាក្នុងភាសា ។

• គោលការណ៍ក្រៅភាសាវិទ្យា កើតឡើងដោយបម្រែបម្រួលនៃសង្គមវប្បធម៌ សេដ្ឋកិច្ច និងបច្ចេកទេស ឬមួយលក្ខណៈចម្រុះ ដែលគេហៅថា « លំហសង្គមនៃពាក្យ » ដែលបង្កើតឡើងដោយសំនួនវោហារភាសាឯកទេសនីយកម្ម ឬការពង្រីកន័យ និងនិន្នាការឆ្ពោះទៅរកភាពពង្រីកបន្ថុកវចីកោសល្យ ( élo-quence ) និងន័យទាក់ទងនឹងសញ្ចេតនារបស់ពាក្យនីមួយៗ ។

ទន្ទឹមនឹងការយកចិត្តទុកដាក់ទៅលើសារសំខាន់នៃការសិក្សាពីបម្រែបម្រួលន័យរបស់ពាក្យ នៅក្នុងការស្រាវជ្រាវអំពីសមាសភាពវចនស័ព្ទនៃភាសាយើងនឹងធ្វើការវិភាគពីរ ដែលតាមទស្សនៈយើង គឺវាមានលក្ខណៈសំខាន់ និងជាទិដ្ឋភាពយថាប្រភេទ នៃបម្រែបម្រួលសេម៉ង់ទិករបស់ពាក្យ ក្នុងភាសាខ្មែរគឺ :

- បម្រែបម្រួលសូរស័ព្ទ ដែលនាំទៅរកបម្រែបម្រួលន័យ
- ការប្រៀបធៀបន័យ (métaphore) និងហេតុបានពីការប្រៀបធៀបន័យ ឬ រូបារម្មណ៍នីយកម្ម (motivation métaphorique) ។

## I. បម្រែបម្រួលសូរស័ព្ទ ដែលនាំទៅរកបម្រែបម្រួលន័យ

បម្រែបម្រួលសូរស័ព្ទ មិនទាន់អាចនាំទៅរកការបាត់បង់ពាក្យឬសចេញពីភាសាទេ ។ បម្រែបម្រួលដែលយើងនិយាយនៅពេលនេះ មានលក្ខណៈអថេរ

ហើយប្រព្រឹត្តទៅក្នុងដំណើរអភិវឌ្ឍន៍ ដ៏យូរលង់ និងដ៏ឥតឈប់ឈរនៃភាសា ។ ហេតុនេះហើយ គេសង្កេតឃើញវត្តមានពាក្យនានា ដែលរក្សាន័យស្រដៀងនឹងន័យរបស់ពាក្យដើម (mots primaires) ។ យើងហៅពាក្យទាំងនេះថាជាពាក្យភ្លោះ (mots doublés) ។ ដើម្បីជាឧទាហរណ៍ យើងសូមលើកយកពាក្យ « មេ », « មិ » និង « ម៉ែ » មកធ្វើការវិភាគ :

ពាក្យ « មេ » មានន័យថា ម្តាយ, អ្នកដឹកនាំ, ជាធំ, ( ភេទញី ) ។ លោក ហ្វ. ម៉ាទីនី (F. Matini) ចាត់ទុកថាជាសំណល់នៃស៊ុបស្ត្រា អូស្ត្រូអាស៊ីយាទិក (Substrat Austroasiatique) ។

ពាក្យ « មី » តាមការពន្យល់របស់លោក ជីវ តាក្វាន់ មានន័យថា លោកស្រី, ( មេផ្ទះ ), មីង ។ នៅក្នុងសម័យបច្ចុប្បន្ន ពាក្យ « មី » នេះ មានន័យបែបអវិជ្ជមាន និងប្រើសំរាប់ហៅសត្វភេទញី ។

ពាក្យ « ម៉ែ » មានន័យថា « ម្តាយ » កើតចេញពីពាក្យ « មេ » នៅក្នុងមធ្យមសម័យ ដោយសារការក្លាយស្រះ «អេ » /e:/ ទៅជាស្រះផ្សំ (diph-tongue) « អែ » /ae/ ។

ប្រសិនបើយើងធ្វើគំនូសបំព្រួញការវិវត្តន៍នៃពាក្យ «មី» និង «ម៉ែ» នោះយើងឃើញថា ការវិវត្តន៍នេះប្រព្រឹត្តទៅមិនតាមបន្ទាត់ត្រង់នោះទេ គឺថា ពាក្យទាំងពីរនេះកើតចេញពីពាក្យ « មេ » តែមួយគត់ ប៉ុន្តែ នៅពេលនិយាយ មានការខុសគ្នា ។ តាមសិលាចារឹកអង្គរ ពាក្យ អេ្ម មានន័យថា ម្តាយ ។

មេ : សម័យបុរាណយូរលង់



មី : សម័យបុរាណ

ម៉ែ : មធ្យមសម័យ

យើងនឹងលើកឧទាហរណ៍មួយផ្សេងទៀត ចេញពីភាសាខ្មែរបុរាណ ដើម្បីបង្ហាញអំពីជាតុភូតបម្រែបម្រួលន័យរបស់ពាក្យគឺ : មុះ វ្នំ គោល (ច្រមុះ ភ្នំ គោល) ដែលក្នុងសម័យបច្ចុប្បន្ននេះ មានទម្រង់ជា គោល ច្រមុះ ភ្នំ ។ ពេលយើងប្រៀបធៀបទម្រង់ទាំងពីរគឺ « ចាស់ និង ថ្មី » យើងសង្កេតឃើញបម្រែបម្រួលសូរស័ព្ទនៅក្នុងគ្រប់ពាក្យ : មុះ → ច្រមុះ, វ្នំ → ភ្នំ, គោល → គោល ។

ព្យញ្ជនៈ « វ » ប្តូរជា « ព » រីឯស្រះ « a » ក្លាយទៅជា « o » ។ នៅក្នុងពាក្យទីព ស្រះ « អូ » ប្តូរជាស្រះផ្សំ « អោ » រីឯព្យញ្ជនៈបំពង់ក និងព្យញ្ជនៈ ឮ « sonores » /g/ ក្លាយទៅជាព្យញ្ជនៈថ្លង់ « sourdes » /k/ ។

## បម្រែបម្រួលស្រះ

A. Haudricourt et A. Martinet បានសរសេរថា នៅក្នុងពេលដែលភាសាថៃ ចាប់ផ្តើមកើតមានតុង ឬស្នៀង (ton) នៅក្នុងភាសាខ្មែរ ចំនួនស្រះគឺកើនឡើងទ្វេ និងបើគិតអំពីកម្រិតសំបូរបែបនៃប្រព័ន្ធស្រះវិញ ភាសាខ្មែរ គឺជាភាសាមួយ ក្នុងចំណោមភាសាដែលគេចាត់ទុកថា ជាភាសាសំបូរបែបខាងសំនួរស្រះក្នុងលោក ។ ប្រសិនបើការអះអាងនេះ ជាការត្រឹមត្រូវនោះ គេអាចធ្វើការសន្និដ្ឋានថា ភាពសំបូរបែបនៃស្រះខ្មែរ គឺស្ថិតនៅត្រង់ថា វាមានក្រុមពីរ គឺក្រុមបិទនិងក្រុមបើក ។ ជាញឹកញាប់ណាស់ ស្រះទាំងពីរក្រុមនេះ មានទំនាក់ទំនងខាងសំនួរនិងន័យរវាងគ្នានឹងគ្នា នៅក្នុងពាក្យខ្មែរ ។ មានពាក្យមួយចំនួនដែលខុសគ្នា ដោយសារគុណភាពស្រះ និងមានន័យស្រដៀងគ្នា ហើយដែលគេសន្និដ្ឋានថា ចេញពីឫសតែមួយ ។

កំណាកំណើតពាក្យខ្មែរមួយចំនួនធំ បានប្រព្រឹត្តឡើងតាមការផ្លាស់ប្តូរសំនួរ ឬតាមវិធីបន្លាស់ប្តូរសំនួរ (modification phonétique) ។

| | |
|---|---|
| តន់ | ទន់ |
| ចប់ | ឈប់ |
| ប៉ោង | ពង់, ពង |
| តួង | ទួង |
| ចាប់ | ជាប់ |
| មាត់ | ម៉ាត់ |
| ចុក | ជុក |
| តិច | ទិច |
| តួច | ទួច |
| តោង | ទោង ។ល។ |

តាមឧទាហរណ៍នៃពាក្យទាំងពីរបែបនេះ យើងអាចសន្និដ្ឋានអំពីវត្តមាននៃទំនាក់ទំនងសេម៉ងទិក ដែលបង្កើតឡើងដោយទំនាក់ទំនងរវាងស្រះទាំងឡាយនេះគឺ : អ - អ៊, អា - អ៊ា, អិ - អ៊ិ, អូ - អ៊ូ, អុ - អ៊ុ, អោ - អ៊ោ ។

ក្នុងបច្ចុប្បន្នកាលនេះ ដោយសារអវត្តមាននៃសូរវិទ្យាប្រវត្តិសាស្ត្រ នៃភាសាខ្មែរ គេមិនអាចអះអាងបានទេ អំពីមតិមួយចំនួនដែលថា ស្រះបើកបង្កើតស្រះបិទ ព្រោះថា តាមការសិក្សាប្រៀបធៀបពាក្យខ្មែរបុរាណ និងពាក្យខ្មែរសម័យថ្មី អាចអោយគេរកឃើញដំណើរវិវត្តន៍ច្រាសមកវិញដែរ ។

ឧទាហរណ៍ ពាក្យខ្មែរបុរាណ « វ្រោះ » (vroh) ពាក្យខ្មែរសម័យថ្មី « ព្រោះ » ។

មួយវិញទៀត ការសិក្សាប្រៀបធៀប អាចអោយគេរកឃើញបម្រែបម្រួល ដែលមានលក្ខណៈស្រដៀងគ្នានៃស្រះខ្មែរបុរាណ « អេ » ទៅជាស្រះផ្សំ « អើ » « អឿ » និង « អែ » ។

# បម្រែបម្រួលព្យញ្ជនៈ

យើងបានសង្កេតឃើញរួចមកហើយថា បម្រែបម្រួល គឺមានមិនត្រឹមតែស្រៈប៉ុណ្ណោះទេ តែក៏មានចំពោះព្យញ្ជនៈដែរ ។

១. ការជំនួសព្យញ្ជនៈក្រអូម " ច " ដោយព្យញ្ជនៈបង្ហួរ " ស "

បម្រែបម្រួលនេះ គេសង្កេតឃើញនៅក្នុងពាក្យមួយចំនួន ដូចខាងក្រោមនេះ :

ពាក្យខ្មែរបុរាណ « ឝី » ពាក្យខ្មែរសម័យ « ស៊ី »

ពាក្យខ្មែរបុរាណ « ចាយ » ពាក្យខ្មែរសម័យ « សាយ »

ពាក្យខ្មែរបុរាណ « ច្ទឹង » ពាក្យខ្មែរសម័យ « ស្ទឹង » ។

បម្រែបម្រួលបែបនេះ សាយភាយនៅពេលដែល « រ » បានចូលក្នុងក្រុមព្យញ្ជនៈ ហើយគេអាចសង្កេតឃើញនៅក្នុងពាក្យជាច្រើន ក្នុងភាសាទំនើប ។

ឧទាហរណ៍ :

ច្រូង ស្រោង

ជ្រាវ ស្រាវ

ច្រូច ស្រោច

ច្រាញ ស្រាញ ។

ទំនាក់ទំនងរវាងព្យញ្ជនៈខ្យល់ «ច» និង «ស» បានត្រូវរក្សាទុកនៅក្នុងភាសាខ្មែរនៅតំបន់ខ្លះនៃខេត្តតាកែវ ដែលនៅទីនោះមានរាជធានីចាស់ អង្គរបូរី ។

២. ការជំនួសព្យញ្ជនៈ " ច " ដោយពាក់កណ្ដាលស្រៈ " យ "

បម្រែបម្រួលនេះ អាចរកឃើញដោយវិធីសិក្សាប្រៀបធៀបពាក្យឫស

ដែលចាប់ផ្ដើមឡើងដោយព្យញ្ជនៈក្រអូម « ច » នៅក្នុងភាសាបាឌ្នារ ក្យល-ក្យល ខ្យល់ ឯភាសាខ្មែរគឺ ពាក្យ ខ្ចោលខ្ចោល និងពាក្យ ខ្យល់ ។ នៅក្នុងភាសាខ្មែរ «ខ្ចោល» មានកំណើតចេញពីពាក្យ « យោល » ដោយផ្សំជាមួយផ្នត់ដើម « ក » ដែលផ្ដល់ន័យបន្ថែម « ចលនាសកម្ម » ។

៣- បម្រែបម្រួលព្យញ្ជនៈ " ម " ទៅជា " ង "

បម្រែបម្រួលបែបនេះ ច្រើនកើតឡើងនៅក្នុងវិធីសម្របសម្រួលពាក្យកម្ចីពីសំស្ក្រឹត ឬពីបាលី មកភាសាខ្មែរ ជាពិសេសគឺ មានចំពោះព្យញ្ជនៈចុងព្យាង្គនៃពាក្យទ្វេព្យាង្គ ។ ឧទាហរណ៍ ៖

ពាក្យសំស្ក្រឹត hamsa នៅក្នុងភាសាខ្មែរក្លាយជា « ហង្ស » ។

នៅក្នុងទេវកថា ភាសាសំស្ក្រឹត vamsa នៅក្នុងភាសាខ្មែរ « វង្ស » ហើយពាក្យ « ភ្នំ » ផ្ដល់កំណើតដល់ពាក្យ « ភ្នង » ~ « ម្នង » ។

៤- ការជំនួសគ្នាទៅវិញទៅមករវាងព្យញ្ជនៈ " ញ " និង " ង "

យើងលើកពាក្យ « វឹង » និងពាក្យ « វិញ » មកពិនិត្យ

ពាក្យ « វឹង » អាចចាត់ទុកថាជាពាក្យដំបូង (ពាក្យដើម ពាក្យឫស) ពីព្រោះ គេជួបប្រទះពាក្យទាំងនេះតាំងពីយូរយារណាស់មកហើយ នៅក្នុងអត្ថបទប្រៀនប្រដៅ (អប់រំ) ខ្មែរ ក្នុងសម័យបុរាណ ។

ឧទាហរណ៍ នៅក្នុងល្បះមួយថា « រក្សាទៅមកវឹង » = « ចូរជួយគ្នាទៅវិញទៅមក » ។ នៅក្នុងបច្ចុប្បន្នកាលនេះ « វឹង » មានន័យថា « មួយរំពេច » ឬ « មួយភ្លែត » វឹងពាក្យ « វិញ » មានន័យថា « (សកម្មភាព) ទៅមក « ជូន » ។

ប៉ុន្តែ យើងអាចសន្និដ្ឋានថា ពាក្យ «ខ្លោញ» និងពាក្យ «ក្លោង» មានដំណើរច្រាសមកវិញ គឺព្យញ្ជនៈ «ញ» ក្លាយមកជា «ង» វិញ ។ ពាក្យ «ខ្លោញ» មានជាតឹកតាងនៅក្នុងសិលាចារឹក ហើយមានន័យថា « ប្រធាន » « មេ » សម្រាប់ហៅរាជមន្ត្រី ។ ពាក្យកម្លាយចេញពីពាក្យ « ខ្លោញ » នេះ គឺជាពាក្យ « ក្លោង » រក្សាន័យបុរាណរបស់ខ្លួននៅក្នុងពាក្យ « មេក្លោង » ប៉ុន្តែម៉្យាងវិញទៀត គេប្រើពាក្យក្លោងនៅក្នុងសមាសភាពនៃពាក្យ « ក្លោងទ្វារ » ដែលមានន័យតែនៅក្នុងការហៅផ្នែកខាងលើនៃរោងថែវទទឹងទ្វារប៉ុណ្ណោះ ។

ចំពោះភាសាខ្មែរបច្ចុប្បន្ន មានលក្ខណៈពិសេស ដូចតទៅ ៖

ប្រសិនបើព្យញ្ជនៈប្រកប «ង» នៅខាងក្រោយស្រៈ «អ៊ិ» ឬ «អេ» វានឹងក្លាយទៅជា «ញ» វិញ ។ ឧទាហរណ៍ រឹង, មឹង, របេង, គេង, លេង ។ ល ។

៥. ការឆ្លងកាត់ព្យញ្ជនៈ " វ " ទៅជា " ព "

បម្រែបម្រួលនេះ គេសង្កេតឃើញសឹងតែទូទៅ នៅក្នុងពាក្យខ្មែរបុរាណ ដែលក្លាយមកជាពាក្យខ្មែរសម័យបច្ចុប្បន្ន ៖

| ភាសាខ្មែរសម័យបុរាណ | ភាសាខ្មែរសម័យបច្ចុប្បន្ន |
|---|---|
| អវិល | អំពិល |
| វ្រៃ | ព្រៃ |
| វ្រះ | ព្រះ |
| វ្នៅ | រពៅ |
| វ្នែក | ភ្នែក |
| វ្លាស | ផ្លាស់ |
| វ្នូវ | ផ្លូវ |

រីឯពាក្យកម្ចីពីភាសាសំស្ក្រឹត ក៏មានបម្រែបម្រួលដូចគ្នានេះដែរ

| សំស្ក្រឹត | ភាសាខ្មែរសម័យបច្ចុប្បន្ន |
|---|---|
| កម្វុជ kamvuja | កម្ពុជា |
| វណ៌ varna | ពណ៌ |
| វាក្យ vakya | ពាក្យ |
| វិធិ vidhi | ពិធី |
| វេលៈ vela | ពេល |
| វ្យាករណៈ vyakarana | ព្យាករណ៍, វេយ្យាករណ៍ |
| វ្យាយាមៈ vyayama | ព្យាយាម |

## បម្រែបម្រួលព្យញ្ជនៈឮស្អុះ ទៅជាព្យញ្ជនៈថ្លង់

នៅក្នុងភាសាខ្មែរ គេសង្កេតឃើញមានបម្រែបម្រួលព្យញ្ជនៈ ឮស្អុះ ទៅជាព្យញ្ជនៈថ្លង់ ។ បម្រែបម្រួលនោះ មានឥទ្ធិពលខ្លាំងទៅលើប្រព័ន្ធហ្វូណែមខ្មែរទាំងមូល ។ បញ្ហានេះ ត្រូវលោក A. Haudricourt និងលោក A. Martinet ពិនិត្យយ៉ាងហ្មត់ចត់ នៅក្នុងអត្ថបទឈ្មោះ " Propagation Phonétique ou évolution phonétique ? - Assourdissement et sonorisation d'occlusives dans l'Asie du Sud-est " ។ អ្នកនិពន្ធអត្ថបទទាំងពីររូបនេះបានធ្វើការកត់សំគាល់ថា : នៅក្នុងភាសាខ្មែរ និងភាសាមន បម្រែបម្រួលព្យញ្ជនៈស្អុះឃោសៈ ទៅជាព្យញ្ជនៈអឃោសៈ គឺជាឥទ្ធិពលស្វ័យរិទ្យាទៅវិញទៅមក នៃបម្រែបម្រួលប្រព័ន្ធព្យញ្ជនៈជាទូទៅ ។ នៅក្នុងភាសាថៃ ដែលក្នុងនោះ ដំណើរនេះប្រព្រឹត្តទៅដោយឆ្លងកាត់ការបញ្ចេញខ្យល់បំនិត (aspiration) ។

ឧទាហរណ៍ : ប → ផ → ព ។ នៅក្នុងភាសាបាខ្នារ (ភាសាមន-ខ្មែរ)

ដែលនៅដាច់តែឯងនៅលើភ្នំអណ្ណាម ផ្នែកខាងត្បូង បម្រែបម្រួលនេះគ្មានឡើយ ។

នៅក្នុងការវិភាគបាតុភូតបែបនេះ នៅក្នុងភាសាខ្មែរ គួរកត់សំគាល់លក្ខណៈពិសេសសំខាន់ៗមួយចំនួន ដូចតទៅ ៖

បម្រែបម្រួលព្យញ្ជនៈឃោសៈ ( ឮស្ទះ ) បុរាណ នាំអោយកើតមានការរក្សាចំនួនព្យញ្ជនៈ ដូចមានតទៅ ៖

គ /g/ → ក /k/

ជ /j/ → ជ /c/

ទ /d/ → ទ /t/

ព /b/ → ព /p/

វ /v/ → ព /b/

កំណកំណើតស្រះបិទ ក៏ដូចជាស្រះបើក ។ នៅតាមឯកសារសិលាចារឹកសតវត្សទី ១៣ គេមិនអាចសង្កេតឃើញបាតុភូតនៃបម្រែបម្រួលរបស់ព្យញ្ជនៈឮស្ទះណាមួយ ប្រែប្រួលទៅជាព្យញ្ជនៈថ្លង់ទេ ។ ឧទាហរណ៍ ៖

« គឹរ » មានទម្រង់ដើម ( គឺសម័យនគរភ្នំ ) ជា « វេរ », « គោ » /go/ ជា « គោ », « អង្គរ » ជា « នគរ » /nagara/ ។

បម្រែបម្រួលព្យញ្ជនៈ ឮស្ទះ ទៅជាថ្លង់ បានប្រព្រឹត្តនៅក្នុងអំឡុងច្រើនសតវត្ស ហើយទើបតែបញ្ចប់ពេញលេញ នៅសតវត្សទី ១៩ ។ ឧទាហរណ៍ ៖

គេ /ge/ → កេ /ke:/

គី /gi/ → គី /kit:/

គង /gang/→ គង់ /kûn/

គាប /gap/→ គៀប /kiəp/

គរោប /garop/→ ក្រប /crɔ:p/

គតិ /gati/→ កតិ, ក្តី /kd..i/

គណៈ /gana/→ គណៈ, គ្នា /k...ate/ ; /kd...i/

ជា /ja/ → ជា /ciə/

ជាតិ /jati → ជាត /ciɔt/

ជីវា /jiva/→ ជ្វា /cviə/

ដារ /dar/→ ទារ /tiə/

ទេវៈ /deva/→ ទេវៈ, ទេព

វោល /vol/→ ពោល

វវេ /vave→ ពពៃ

វល្វេល /valvel/→ ពពិល, ពពេល

វេល /vela/ វេលា, ពេល

បំរែបម្រួលព្យញ្ជនៈឃោសៈ (ឮស្អិះ) នាំអោយមានការបាត់បង់ហ្វូណែម (ព្យញ្ជនៈ) មួយចំនួនធំ ។ រីឯការបាត់បង់ហ្វូណែមនេះ ក៏នាំទៅរកការបាត់បង់ពាក្យដំបូងៗមួយចំនួន ហើយការស្តារ និងស្ថាបនាពាក្យទាំងនេះ អាចធ្វើទៅបានតាមវិធីប្រៀបធៀបនឹងភាសាជិតខាង និងភាសាដែលនៅក្នុងអំបូរតែមួយ គឺភាសាក្នុងអំបូរមន-ខ្មែរ ។

ការប្រៀបធៀបពាក្យនៅក្នុងភាសាខ្មែរបច្ចុប្បន្ន អាចអោយគេរកឃើញនៅក្នុងឧទាហរណ៍ ពាក្យ « ភ្លោះ » ថាបំរែបម្រួលនេះជះឥទ្ធិពលដល់ការបង្កើតពាក្យថ្មី ។ ពាក្យផ្តើមដោយព្យញ្ជនៈ « ដ » និង « ត » ។

ដល់ ទល់

ដង ទង

ដាក់ ទាក់

| | |
|---|---|
| ដាប | ទាប |
| ដុំ | តុំ |
| ដី | ទី |
| ដោក | តោក |
| ដៅ | ទៅ |

ពាក្យផ្ដើមដោយព្យញ្ជនៈ « ប » និង « ព » « ប៉ »

| | |
|---|---|
| បត់ | ពត់ |
| បា | ប៉ា |
| បិច | ប៉ិច |
| បុះ | ពុះ |
| បូក | ពូក |
| បូត | ពូត |
| បើ | ពើ |
| ប៉ែក | ប៉ែក |
| បោ | ពោ (វ) |
| បាំង | ពាំង ។ |

ការសិក្សាពាក្យតាមវិធីប្រៀបធៀបសូរស័ព្ទ និងន័យរបស់វា ដើម្បីរកពាក្យភ្លោះនៅក្នុងភាសាបច្ចុប្បន្ន អាចប្រព្រឹត្តទៅបាន ព្រោះថា ព្យញ្ជនៈ ឲ្យស្ទះ និងថ្លង់ស្ទះ នៅតែកើតមានតទៅទៀត ។ ឧទាហរណ៍ « ដ » និង « ត » « ប់ » និង « ព » « ប៉ » ។ ហេតុដូច្នេះ ការស្រាវជ្រាវពាក្យដែលផ្ដើមដោយព្យញ្ជនៈស្ទះ ព្យញ្ជនៈបំពង់ក « ក » និងព្យញ្ជនៈ « ច » អាចប្រព្រឹត្តទៅបានដោយជោគជ័យ លុះត្រាតែគេធ្វើការប្រៀបធៀបពាក្យខ្មែរ ជាមួយនឹងពាក្យនៅក្នុងភាសាមន និងភាសាបាឌ្នារ

ព្រោះថា នៅក្នុងភាសាខ្មែរបច្ចុប្បន្ន គ្មានគូព្យញ្ជនៈឆ្លើយគ្នាដូចនេះទេ (គេអាចប្រៀបធៀបបានតែគូដែលមានស្រះ ក្រុមផ្សេងៗ ប៉ុណ្ណោះ) ។

## វិធីសង្កត់សំឡេង (ACCENTUATION)

វិធីសង្កត់សំឡេង មានតួនាទីកំណត់មួយនៅក្នុងការផ្លាស់ប្តូរសមាសភាពវចនស័ព្ទនៃភាសាខ្មែរ ព្រោះថាវិធីសង្កត់សំឡេងមានទំនាក់ទំនងទៅនឹងការផ្លាស់ប្តូររូបភាពខាងក្រៅរបស់ពាក្យ ។

អ្នកឯកទេសបានបញ្ជាក់ថា វិធីសង្កត់សំឡេងនៅក្នុងភាសាខ្មែរ ជាទូទៅស្ថិតនៅលើព្យាង្គទី២ នៃពាក្យទ្វេព្យាង្គ ។

លោក G. Coedès បានហៅវិធីសង្កត់សំឡេងនេះថា ជាវិធីសង្កត់សំឡេងឱណាមិក ហើយយោងទៅតាមទ្រឹស្តីរបស់ ប្រង់ ស្តែទែរ អំពីភាសាឥណ្ឌូនេស៊ី ។ រីឯលោក Martini វិញ អោយឈ្មោះថា « បន្ទោយស្រះព្យាង្គទី១ » ។

ការសង្កេតអំពីឥទ្ធិពលនៃវិធីសង្កត់សំឡេង ទៅលើរចនាសម្ពន្ធសូរស័ព្ទនៃពាក្យ ធ្វើទៅបានដោយការវិភាគការដាក់ផ្នត់ ។ ដូចជាដំណើរនៃការដាក់ផ្នត់ «លើកទី២» គឺស្ថិតនៅលើការអោយន័យថ្មី ឬមួយន័យបន្ថែម ដែលសំដែងពីសញ្ចេតនាដល់ពាក្យឯកព្យាង្គ ឬពាក្យចាស់មួយហួសសម័យ ឬពាក្យកម្លាយចាស់មានពីរព្យាង្គ ។ ក្នុងនោះ ហេតុការណ៍នេះ ត្រូវបានអះអាងថា វិធីសង្កត់សំឡេងលើព្យាង្គទី២ នៃពាក្យកម្លាយ បន្ទោយព្យាង្គទី១ បន្តិចម្តងៗ នៅក្នុងពាក្យទ្វេព្យាង្គ ។ ឧទាហរណ៍ ៖ ចេញពីកិរិយាស័ព្ទ «វាស់» បង្កើតបានជានាម «រង្វាស់» ដោយប្រើផ្នត់ដើម «អង់» ប៉ុន្តែ ដោយការប្រើប្រាស់ពាក្យជារៀងរាល់ថ្ងៃ ព្យាង្គទី១ របស់ពាក្យមានបម្រែបម្រួលជាពិសេស ទៅលើស្រះ « អ » នៅដើមព្យាង្គ ដោយមានការបញ្ចេញសំឡេងនៅបំពង់ក ។ ពាក្យ « អង្វាស់ » ដោយបម្រែបម្រួលសូរស័ព្ទក្លាយ

ទៅជា « រង្វាស់ » ជាពាក្យឯកព្យាង្គ ។ បន្ទាប់មកទៀតគឺ មានការដាក់ផ្នត់លើក ទី២ គឺការថែមផ្នត់ដើម « រង់ » ក្លាយជា «រង្វាស់» គឺការបន្ថែមកម្លាំងព្យាង្គទី១ :

វាស់ → អង្វាស់ → រង្វាស់

នៅក្នុងពាក្យកម្លាយដែលមានពីរព្យាង្គ ក្នុងនោះព្យាង្គទីមួយ គឺជាផ្នត់ដើម បានសេចក្តីថា ជាធាតុមានន័យមិនពេញលេញរបស់ពាក្យនោះ ពាក្យទី២ គឺជាពាក្យឫស ។ នៅក្នុងភាសានិយាយ វិធីសង្កត់សំឡេងជាទូទៅ បានធ្លាក់ទៅលើព្យាង្គទី២ គឺធ្លាក់ទៅធាតុរបស់ពាក្យដែលមានន័យពេញលេញ ។ ជាលទ្ធផលចុងក្រោយ ពាក្យឫសខុសប្លែកពីផ្នត់ដើមក្នុងករណីភាគច្រើន គឺវារក្សារចនាសម្ព័ន្ធរបស់ខ្លួន ។ របៀបដូចគ្នានេះដែរ គឺប្រព្រឹត្តទៅក្នុងពាក្យសមាសមួយចំនួន ដែលក្នុងនោះ មានធាតុមួយមានស្វរខ្សោយជាង ។

ពេលនេះ យើងនឹងលើកយកករណីមួយចំនួន ដែលចាត់ទុកថាជាផលវិបាកនៃឥទ្ធិពលនៃការសង្កត់សំឡេងទៅលើទម្រង់ខាងក្រៅនៃពាក្យ មកពិនិត្យ ។ យើងចែកផលវិបាកនៃឥទ្ធិពលនេះជាពីរជំពូកគឺ : ផលវិបាកអវិជ្ជមាន និងផលវិបាកវិជ្ជមាន ។

*១. ផលអវិជ្ជមាន*

ការសង្កត់សំឡេងក្នុងរយៈកាលជាច្រើនសតវត្ស បានធ្វើអោយផលវិបាករចនាសម្ព័ន្ធបុរាណរបស់ពាក្យ មានបម្រែបម្រួល ។ យើងបានរកឃើញថា ពាក្យខ្មែរបុរាណ អាចជាពាក្យឯកព្យាង្គ និងជាពាក្យទ្វេព្យាង្គ ។ ពាក្យទ្វេព្យាង្គ ជាធម្មតា ច្រើនតែចាប់ផ្តើមពីព្យញ្ជនៈទោល (គ្មានក្រុមព្យញ្ជនៈនៅខាងដើម) ។ នៅទីតាំងខាងដើម អាចមានស្វរស្ទះនៅបំពង់សំឡេង ដែលក្រោមឥទ្ធិពលនៃការសង្កត់សំឡេង ក៏បាត់បង់ទៅ ទាំងនេះគឺនាំទៅរកការបាត់បង់ព្យាង្គទាំងមូល ។

| ភាសាបាខ្មារ | | ភាសាខ្មែរ |
|---|---|---|
| អដា | ada: | ទា |
| | aka | ក |
| | akom | កុំ |
| | apon | ប៉ោង |
| | atap | តប់ |
| | acèp | ចិប |
| | anih | នេះ |

ពាក្យទ្វេព្យាង្គមួយចំនួនក្នុងភាសាខ្មែរបុរាណ ក្រោមឥទ្ធិពលនៃការសង្កត់សំឡេងលើព្យាង្គ បានក្លាយទៅពាក្យឯកព្យាង្គ :

| ពាក្យខ្មែរបុរាណ | ភាសាខ្មែរបច្ចុប្បន្ន |
|---|---|
| anak | អ្នក |
| aseh | សេះ |
| ame | មេ ( ម៉ែ ) |
| ata | តា |
| amlo | ម្លូ |
| patau | ផ្ដៅ |
| vinau | ភ្នៅ |
| kurun | ក្រុង |
| padah | ផ្ទះ |
| karol | ក្រោល |
| garop | គ្រប |

karom ក្រោម

paren ប្រេង

tannot ត្នោត

ក្នុងសម័យបច្ចុប្បន្ននេះ វិបាកអវិជ្ជមានដែលកើតឡើងដោយសារវិធីសង្កត់សំឡេងកាន់តែរីកចំរើនធំឡើងៗ ជាពិសេស ក្រោមឥទ្ធិពលរបស់ក្រុមជនបរទេស ( ចិន, វៀតណាម ) ដែលនៅតែរក្សាបន្លឺតាមរបៀបចាស់ ជាទម្លាប់របស់ខ្លួន ។ ដោយឡែកគឺ គេសង្កេតឃើញមាននិន្នាការមិនបន្លឺព្យញ្ជនៈទីពីរក្នុងបន្សំព្យញ្ជនៈ ជាពិសេស ព្យញ្ជនៈ « រ » នៅក្នុងក្រុមព្យញ្ជនៈ ក្រ គ្រ ច្រ ជ្រ ត្រ ទ្រ ប្រ ព្រ ស្រ ។ ឧទាហរណ៍ : ផ្សារ → សារ, ភ្នំពេញ → អំពេញ, ស្បែកជើង → បែកជើង ជាដើម ក៏ជាផលវិបាកអាក្រក់នៅក្នុងការអភិវឌ្ឍន៍ នៃភាសាខ្មែរទៅអនាគត ។

ឥទ្ធិពលនេះ នឹងកាន់តែរីកខ្លាំងឡើងៗ ប្រសិនបើនិន្នាការនេះរីកដុះដាលបន្តទៅទៀត បណ្តាលមកពីអាពាហ៍ពិពាហ៍ល្បាយជាតិសាសន៍ និងសកម្មភាព នៃ « ច្បាប់សន្សំសំចៃនៃការខំប្រឹងប្រែងអាន » និង « ម៉ូដ » នៅក្នុងតំបន់ដែលមានប្រជាជនច្រើន ។

*២. ផលវិជ្ជមាន*

យើងអាចនិយាយបានថា វិធីសង្កត់សំឡេង ឌីណាមិក អាចបង្កើតពាក្យថ្មី ព្រមទាំងធ្វើអោយមានករណីម្យ៉ាង ដែលពាក្យបុរាណនៅតែរស់រានមានជីវិតទន្ទឹមនឹងពាក្យដែលកើតថ្មីពីពាក្យបុរាណនេះ ដោយវិធីសង្កត់សំឡេង ។

ឧទាហរណ៍ នៅក្នុងភាសាខ្មែរបុរាណ ពាក្យ « acah អ្ចះ » បង្កើតបានជាពាក្យកម្លាយ « អម្ចាស់ » ដោយប្រើផ្នត់ជែក « ម » / -m- / ។ ប៉ុន្តែ ការសង្កត់សំឡេងបានបន្សោយព្យាង្គទី១ ។ ទីបំផុត កើតមានពាក្យ « ម្ចាស់ » ទន្ទឹមនឹងពាក្យ « acah » ។ នៅក្នុងភាសាខ្មែរបច្ចុប្បន្ន ពាក្យទាំងពីរនេះ នៅមានវត្តមានទន្ទឹម

គ្នា ។ ប៉ុន្តែ ក្នុងការផ្លាស់ប្តូរន័យពីពាក្យចាស់ទៅពាក្យថ្មី មានបម្រែបម្រួលសេម៉ង់-ទិក : ប្រៀបធៀបពាក្យ «អម្ចាស់»(ដោយសារការលើកកំពស់ពាក្យ «acah» និង «ម្ចាស់» ។ កំណកំណើតពាក្យបែបនេះ អាចតាងដោយគំនូសបំព្រួញ ដូចតទៅ :

ពាក្យបុរាណ « អ្ចះ » acah → ចាស់ (តាមវិធីសង្កត់សំឡេង)
→ ម្ចាស់
អម្ចាស់

ពាក្យដទៃទៀត ក៏បង្កើតឡើងតាមវិធីដូចគ្នានេះដែរ ។ ប៉ុន្តែ ញឹកញាប់ជាងគេ វិធីសង្កត់សំឡេងមានឥទ្ធិពលទៅលើពាក្យឯកព្យាង្គ និងលើព្យាង្គដែលមាន [រ] និង [ម] ។ យើងបានរកឃើញក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត មានកាឡារូប (variante) អក្ខរាវិរុទ្ធពីរនៃពាក្យតែមួយ : « រងើរងើ » ឬ « ល្ងើល្ងើ » ។ ពាក្យ « ល្ងើល្ងើ » ជាពាក្យឱបនៃពាក្យ « រងើរងើ » ដោយសារការផ្លាស់ប្តូរពី [រ] មក [ល] ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងសម័យបច្ចុប្បន្ន ពាក្យទាំងពីរនេះជាពាក្យផ្សេងពីគ្នា ព្រោះវាមានន័យទីទៃពីគ្នា គឺ : « រងើរងើ » មានន័យថា « ឈឺក្បាល » រីឯពាក្យ « ល្ងើល្ងើ » មានន័យថា « ភ្លើ » ។ ឧទាហរណ៍នេះ គឺមិនមែនមានតែមួយនោះទេ ឧទាហរណ៍នេះ ឆ្លុះបញ្ចាំងទំនាស់រវាងភាសា អក្សរសាស្ត្រ និងភាសានិយាយ ។ ពេលដែលទំនាស់នេះកាន់តែធំឡើងៗ ពេលនោះ សេម៉ង់ទិកនៃពាក្យឫស និងពាក្យឱប បែកខ្ញែកពីគ្នា ហើយពាក្យទាំងពីរក្លាយជាពាក្យទីទៃពីគ្នា ។

វិធីសង្កត់សំឡេង ក៏ជះឥទ្ធិពលទៅលើស្រៈ ក្នុងព្យាង្គដែលផ្តើមដោយព្យញ្ជនៈ [ម] ។ ឧទាហរណ៍ « មួយ » ក្លាយទៅជា « ម » ហើយចូលផ្សំទៅក្នុងពាក្យដែលនៅពីក្រោយពាក្យ « មួយ » ។

នៅក្នុងកន្សោមពាក្យដែលមានទំនាក់ទំនង attributive ( ពាក្យមួយកំណត់បញ្ជាក់ន័យពាក្យមួយទៀត ) ។ ឧទាហរណ៍ :

| | |
|---|---|
| មួយថ្ងៃ | ម៉្ងៃ |
| មួយដង | ម្តង |
| មួយយ៉ាង | ម្យ៉ាង |
| មួយកាល | ម្កាល (ម្តងម្កាល) |
| មួយដុំ | ម្ដុំ |
| មួយនាក់ | ម្នាក់ ( ដែលប្រើជាពាក្យសំរាប់រាប់មនុស្ស ) |

នៅចុងបញ្ចប់នៃផ្នែកនេះ យើងអាចធ្វើកំណត់សំគាល់ ដូចតទៅ :

- បម្រែបម្រួលស្វរស័ព្ទ នាំទៅរកបម្រែបម្រួលន័យ ។ បម្រែបម្រួលនេះនាំទៅរកការបាត់បង់ពាក្យមួយចំនួន និងផ្ទុយទៅវិញ នាំទៅរកការកកើតពាក្យភ្លោះ។
- ករណីបម្រែបម្រួលស្វរស័ព្ទនិមួយៗ តែងមានទំនាក់ទំនងរវាងគ្នានឹងគ្នា និងជាលទ្ធផលកើតបានជាប្រព័ន្ធទំនាក់ទំនងទៅវិញទៅមក ដែលជាការវិវត្តន៍នៃភាសា មានលក្ខណៈជារចនាសម្ព័ន្ធ ក្នុងរយៈកាលប្រវត្តិសាស្ត្រនិមួយៗ ។

*( នៅមានត )*

# សិលាចារឹកខ្មែរ

ដោយ **ហម ឆាយលី**

## លំនាំដើម

នៅសម័យ " អង្គរ " នរណាក៏អាចដឹងដែរថា ជាសម័យថ្កុំថ្កើងរុងរឿង ជាសម័យដែលប្រកបដោយមហិទ្ធិពលគ្របវិស័យ ៖ វិស័យគ្រប់គ្រងប្រទេស វិស័យការពារប្រទេស ផ្នែកវិទ្យាសាស្ត្រគ្រប់ប្រភេទ ផ្នែកស្ថាបត្យកម្ម និងវិស័យអក្សរ-សាស្ត្រជាអាទិ៍ ។ បើយើងនិយាយអំពីវិស័យផ្សេងៗទៀត យើងអាចយល់បានយ៉ាងងាយ ដោយយើងឃើញការលួតលាស់ ឬសំណង់ផ្សេងៗយ៉ាងប្រត្យក្ស ។ បើនឹងនិយាយអំពីការរីកចំរើន និងភាពឧត្តុង្គឧត្តមផ្នែកអក្សរសាស្ត្រវិញ យើងខ្វះឯកសារជាទីបំផុត ពុំមានអ្វីអោយឃើញជារូបរាងមែន ។ ប៉ុន្តែអ្នកប្រាជ្ញចំណានៗខាងភាសាសាស្ត្រ ( Linguiste ) និងចារឹកសាស្ត្រ ( Epigraphiste ) ទើបយល់បានភ្លាមថា ការរីកចំរើនក្នុងវិស័យអក្សរសាស្ត្រ ត្រូវតែមានការរីកចំរើនទន្ទឹមគ្នានឹងវិស័យផ្សេងៗឯទៀតដែរ ។ បានជាយើងហ៊ានអះអាងដូច្នោះ ព្រោះយើងបានឃើញហើយថា តាំងតែអំពីសម័យមុនអង្គរ ( សតវត្សទី ៦ ) រហូតដល់សម័យក្រោយអង្គរ ( សតវត្សទី ១៥ ) អ្នកប្រាជ្ញទាំងពីរផ្នែកខាងលើនេះ បានសិក្សាសិលាចារឹកជាច្រើនដែលរកឃើញតាមភូមិ តាមមាត់ស្ទឹង លើភ្នំ ក្នុងរូងភ្នំ តាមព្រៃស្ដុក នៅតាមវត្តនិងជាពិសេស នៅតាមប្រាសាទនានាសព្វពាសពេញផ្ទៃប្រទេសកម្ពុជាទាំងមូលព្រមទាំងមានរហូតដល់ប្រទេសជិតខាងយើងទៀតផង [1] ។ ទាំងអស់នេះហើយដែលបញ្ជាក់អោយឃើញថា ការរីកចំរើន និងការផ្សព្វផ្សាយនៃអក្សរសាស្ត្រខ្មែរមានតាំងអំពីដើម ។ បានន័យថា អក្សរសាស្ត្រខ្មែរបានឡើងខ្ពស់ត្រដែតត្រដឹម ដល់កំរិត ដែលអាចចាត់ទុកប្រទេសកម្ពុជា ជាអរិយប្រទេសបាន នាសម័យនោះ ។

ម្យ៉ាងទៀត តាមរយៈសិលាចារឹកនេះហើយ ដែលយើងគ្រប់រូបបានឃើញ និងឮព្រះបន្ទូលនៃអតីតមហាក្សត្រខ្មែរ ផ្តែផ្តាំទុកអោយក្សត្រាក្សត្រីជំនាន់ក្រោយៗ និងប្រជារាស្ត្ររបស់ព្រះអង្គទាំងអស់លើផែនដីកម្ពុជា គោរព និងប្រតិបត្តិតាម [2] ។ ព្រះបន្ទូលដែលស្ថិតនៅលើផ្ទាំងថ្មទាំងនេះ បើគិតទៅមានអាយុជាងមួយពាន់ឆ្នាំហើយ ថ្វីដ្បិតតែថ្មស្ទើរតែរបេះដាច់ដាចផុយហើយក្តី តែអត្ថន័យ និងខ្លឹមសារនៃឱវាទរបស់ព្រះអង្គនៅរឹងជាងថ្មនេះទៅទៀត ហើយមានតេជះខ្លាំងក្លាចិញ្ចាចចិញ្ចែង ធ្វើអោយឱវាទទាំងនេះក្លាយទៅជាអមតៈ ពុំអាចរលត់រលាយបានឡើយ ។

យើងទាំងអស់គ្នាទន្ទេញមិនភ្លេចពីមាត់សោះទេថា នៅសម័យមហានគរឬយសោធបុរៈ ប្រទេសយើងមានឥទ្ធិពលខ្លាំងពូកែ ជាប្រទេសមួយដែលមានវឌ្ឍនភាពគ្រប់វិស័យ ព្រមទាំងចាំក្នុងអារម្មណ៍ទៀតផងថា ដោយសារមហាក្សត្រខ្មែរសម័យនោះ មានលក្ខណៈគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនគរ គឺទ្រង់បរិបូណ៌ដោយចំណេះវិជ្ជា, មានឧត្តមគតិជាតិនិយម, ប្រកបដោយសច្ចធម៌, កាន់ទសពិធរាជធម៌ ។ មិនតែប៉ុណ្ណោះសោត ទ្រង់បានសិក្សា និងហាត់ហ្វឹកហ្វឺនផ្នែកយុទ្ធសាស្ត្រ យ៉ាងជំនាញ ( បើតាមសម័យថ្មីវិញ គឺសាលាយោធា និងជាមេបញ្ជាការសឹក ) និងប្រកបដោយសេចក្តីក្លាហានជាទីបំផុត ក្នុងពេលមានសឹកសង្គ្រាមដើម្បីការពារជាតិ ។ ដូច្នេះហើយបានជា រាជាណាចក្រកម្ពុជា លាតសន្ធឹងយ៉ាងធំធេង នាកាលសម័យនោះ [3] ។

បន្ទាប់ទៅនេះ តាមរយៈការសិក្សាស្រាវជ្រាវរបស់អ្នកប្រាជ្ញបារាំង និងខ្មែរជាច្រើនរូប ដែលមានជាអាទិ៍ លោក អេត្យេន អេម៉ូនីញេ ( Etienne Aymonier ), ល្វី ហ្វីណូ ( Louis Finot ), ស្ហ្សក សឺដែស ( George Coedès ) និងលោកស្រី សាវរស ពៅ ( Saveros Pou ) ដែលលោកបាន

បកប្រែសិលាចារឹកជាភាសាសំស្ក្រឹត ឬខ្មែរទៅជាភាសាបារាំង ។ ដូច្នេះ តាមរយៈអត្ថបទទាំងនោះហើយ ដែលអោយលោកអ្នកទាំងឡាយបានយល់អំពីវប្បធម៌អារ្យធម៌ខ្មែរ ព្រមទាំងឱវាទដ៏មានខ្លឹមសាររបស់ក្សត្រសម័យអង្គរ និងអោយយើងបានធ្វើការសិក្សាអំពីចំណេះវិជ្ជារបស់ទ្រង់ លើការចាត់ចែង, ក្នុងកិច្ចការរដ្ឋ, រដ្ឋប្បវេណី ទំនៀមទម្លាប់របស់រាជក្សត្រ, សេចក្តីក្លាហានរបស់ទ្រង់, ក្នុងកិច្ចការពារជាតិ ព្រមទាំងកង្វល់របស់ទ្រង់ចំពោះ « កម្ពុជទេស » ទៅអនាគត និងសេចក្តីបួងសួងរបស់ព្រះអង្គ ដល់ទេព, ព្រះឥន្ទ្រ, ព្រះព្រហ្ម, ទេពតាសព្វ អោយជួយទ្រទ្រង់ " កម្ពុជទេស " អោយបានសុខក្សេមក្សាន្តតរៀងទៅ លុះអនន្តកប្ប ។ ល ។

ពាក្យ " សិលាចារឹក " ផ្សំមកពីពាក្យ " សិលា " និង " ចារឹក " ។ សិលា បានន័យថា ថ្ម ។ ចារឹក បានន័យថា ចំណារទាំងឡាយដែលចារ ឬសរសេរឡើងដោយអ្នកនិពន្ធនានា ។ រួមសេចក្តីទៅបានន័យថា ការចារ ឬសរសេរនៅលើផ្ទាំងថ្មទាំងឡាយ ចាប់តាំងអំពីសម័យដើម រហូតដល់សតវត្សយើងនេះ ។

ចារិកសាស្ត្រ គឺការសិក្សានូវសិលាចារឹកចាស់ៗទាំងឡាយ ។ សិលាចារឹកដែលចាស់ជាងគេ គឺសិលាចារឹកដែលគេរកឃើញនៅ វ៉ូកាញ់ ( Stèle de Vo-canh ) ចារនៅសតវត្សទី ៥ ជាភាសាសំស្ក្រឹត [4] ។ ឯសិលាចារឹកដែលសរសេរជាភាសាខ្មែរបុរាណនោះ ចារឡើងនៅដើមសតវត្សទី ៧ គឺសិលាចារឹកអង្គរបុរី ។ ការស្រាវជ្រាវចេះតែធ្វើបន្តទៅទៀត ហើយអ្នកប្រាជ្ញនានាខាងមុខវិជ្ជានេះ បានចុះលេខក្នុងបញ្ជី នៃសិលាចារឹកខ្មែរ ក្រោយពីបានបង្កើតសាលាបារាំង ផ្នែកបូព៌ាទិស ( Ecole Française d'Extrême Orient : EFEO ) នៅឆ្នាំ ១៨៩៨ ដែលមានទីស្នាក់ការនៅហាណូយ ។ គេបានរកឃើញសិលាចារឹកទាំងអស់ ចំនួនប្រហែល ១.៥០០ ។ ក្រោយពីពេលនោះមកទៀត គេបានរកឃើញបន្តបន្ទាប់ ហើយគេក៏បានចុះលេខបន្តៗដែរ ។ ប៉ុន្តែ នៅមានសិលាចារឹកដែលគេរកឃើញថ្មីៗទៀត ពុំទាន់បាន

ចុះលេខនោះ ក៏នៅមានសន្ទឹកសន្ធាប់ណាស់ដែរ ។

សព្វថ្ងៃនេះ ទាំងទេសចរបរទេស ទាំងខ្មែរខ្លួនឯង ដែលបានទស្សនាអង្គរ ឬប្រាសាទឯទៀត បានចាប់អារម្មណ៍តែក្បាច់រចនា សិល្បៈ តែប៉ុណ្ណោះទេ ។ រីឯសិលាចារឹកដែលមានចារនៅតាមជញ្ជាំង គៀនកោះយ៉ាងច្រើន គេពុំសូវចាប់អារម្មណ៍ផងទេ ។ តើសិលាចារឹកទាំងនេះហើយដែលមានបង្កប់នូវប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ភាសា សាសនា និងរចនាសម្ពន្ធ និងការរស់នៅនៃសង្គមខ្មែរ នាសម័យដើម ជាឯកសារដែលពាល់បាន ដែលបានបន្សល់យ៉ាងសន្ទឹកសន្ធាប់ ទុកជាកេរមរតក អោយកុលបុត្តកុលធីតានៃកម្ពុជាសព្វថ្ងៃ ។

*១. តើសិលាចារឹកទាំងនោះមានភាសាអ្វីខ្លះ ?*

ខ្ញុំគួរតែបញ្ជាក់អោយបានច្បាស់បន្តិចជាមុនសិន អំពី " ភាសា " និង " អក្សរ " ។ " ភាសា " គឺការបញ្ចេញដោយសូរស័ព្ទ ក្នុងការប្រទាក់ប្រទងគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ឬទៅកាន់សង្គម ។ " ភាសា " របស់ខ្មែរយើង តាមអ្នកប្រាជ្ញខាងភាសាសាស្ត្រ គេកត់បញ្ចូលទៅក្នុងក្រុមអំបូរភាសា មន - ខ្មែរ ។ រីឯ " អក្សរ " គឺអ្វីៗដែលចារ ឬសរសេរ ការកត់ត្រាទុកលើថ្ម ស្លឹក ក្រដាស ឈើ ស្បែក ... ។ ល ។ ដែលមនុស្សប្រើសម្រាប់ប្រទាក់ប្រទងគ្នាដែរនៅក្នុងសង្គម ។ " អក្សរ " ខ្មែរយើង ត្រូវបានខ្ចីអំពីក្លឹង្គ នៅតំបន់ភូមិភាគខាងត្បូង ដែលមានឈ្មោះថា ចល្លុក្យៈ ( Calukya ) និងបាល្លវៈ ( Pallava ) ។ ក្រោយមក ខ្មែរយើងបានកែប្រែច្នៃលំអបន្តិចម្តងៗ អោយក្លាយទៅជាអក្សរខ្មែរពិតប្រាកដ ។ ទើបនៅសម័យសតវត្សទី ៩ក្សត្រអង្គព្រះបាទយសោវរ្ម័នទី ១ បានប្រតិស្ឋនាមថា «កម្ពុជអក្សរ» គឺថាជាអក្សររបស់កម្ពុជា ។

អក្សរដែលខ្មែរយើងប្រើប្រាស់ក្នុងសិលាចារឹកនោះ គឺ អក្សរខ្មែរដែល

យើងហៅថា " អក្សរខ្មែរបុរាណ " នោះ ។ ដោយយោងទៅតាមលក្ខណៈអក្សរ និងវេយ្យាករណ៍នោះហើយ ដែលអ្នកប្រាជ្ញបានចែងជាសម័យសម្រាប់ភាសាបាន ។ ការសិក្សាលើអត្ថបទសិលាចារឹកនេះ មានការលំបាកសន្ធឹកសន្ធាប់ខ្លាំងណាស់ ពីព្រោះយើងត្រឡប់ទៅមើលអក្សរ និងស្តាប់ភាសារបស់យើងកាលអំពីអំឡុង ១.០០០ ឆ្នាំមុន គឺ ១០ សតវត្សមុន ។

១.១ សិលាចារឹកជាភាសាសំស្រ្កឹត :

ភាសានេះមានប្រភពដើមនៅប្រទេសក្លិង្គ ក្នុងកំឡុងសតវត្សទី ១០ មុនគ្រិស្តសករាជ ។ អ្នកប្រាជ្ញ និងអ្នកឯកទេសផ្នែកភាសានេះ បានពាក់តែងរៀបចំអោយមានជាក្បួនខ្នាត ជាវេយ្យាករណ៍ត្រឹមត្រូវប្រាកដឡើង សម្រាប់អ្នកអក្សរ-សាស្រ្តក្លិង្គទាំងអស់គោរពក្បួន និងវេយ្យាករណ៍ក្នុងការនិពន្ធ : ធមិ ច្បាប់ រឿងព្រេងធំៗ ជាកាព្យទាំងអស់ ។

គេចាត់ទុកភាសានេះជាភាសាប្រសើរបំផុត គឺសម្រាប់ក្រុមទេព ឬព្រះ ( ទេវភាសា ) ស្តេច, ព្រាហ្មណ៍, អ្នកប្រាជ្ញធំៗ និងអ្នកដែលមានត្រកូលខ្ពស់ ។

ភាសានេះក៏បានត្រូវយកមកប្រើនៅក្នុងស្រុកខ្មែរ តាំងតែអំពីដើមប្រវត្តិសាស្រ្តម្ល៉េះ តាមរយៈអ្នកប្រាជ្ញក្លិង្គ ព្រាហ្មណ៍ អ្នកជំនាញធំៗ [5] ។ ល ។

ភាសាសំស្រ្កឹតនេះ បានប្រើប្រាស់ក្នុងអក្សរសាស្រ្តខ្មែរយើង តាំងតែអំពីសតវត្សទី ៥ រហូតដល់សតវត្សទី ១៤ ។ អ្នកប្រាជ្ញទាំងនោះ បានចាត់ជាផ្នែកធំៗ ក្នុងការនិពន្ធជាភាសាសំស្រ្កឹតនៅក្នុងស្រុកយើង ដូចតទៅ : ផ្នែកសាសនា ផ្នែកទស្សន-វិជ្ជាផ្សេងៗ ផ្នែកតុលាការ ផ្នែកប្រវត្តិសាស្រ្ត ផ្នែកបច្ចេកទេស សំណង់ ជលសាស្រ្ត សិល្បសាស្រ្ត និងក្បួនខ្នាតសំខាន់ៗ ... ។ ខ្មែរយើងចារជាភាសាសំស្រ្កឹត ជា " កាព្យ " ។ ឯថ្វីដៃនៃអ្នកចារអក្សរ មានលក្ខណៈល្អលើសអំពីសិលាចារឹក នៅស្រុក

ក្លឹង្គ និងនៅស្រុកជ្វា ( ឥណ្ឌូណេស៊ី ) ទៅទៀត នេះគឺជាការកត់សំគាល់ និងបានទទួលការសរសើរអំពីអ្នកប្រាជ្ញខាងអារ្យធមិក្លឹង្គ និងអ្នកចារិកសាស្ត្រ ជាជនជាតិហុល្លង់, បារាំង និងក្លឹង្គ ទាំងអត្ថបទ ទាំងអក្សរ ។ ទោះបីជាក្សត្រខ្មែរសម័យអង្គរខ្លះនិយមគោរពព្រហ្មញ្ញសាសនាក្តី ព្រះពុទ្ធសាសនាហីនយានក្តី មហាយានក្តី ទ្រង់តែងតែប្រើប្រាស់ភាសាសំស្ក្រឹតនេះជាដរាបក្នុងការនិពន្ធផ្សេងៗ តាំងអំពីដើមប្រវត្តិសាស្ត្រនៃប្រទេសយើង រហូតដល់សតវត្សទី ១៤ ។ ដូច្នេះ ភាសាទាំងពីរ ( ភាសាខ្មែរ និងភាសាសំស្ក្រឹត ) នេះ បាននៅរួមរស់ជុំជិតនឹងគ្នាអស់រយៈ ១៤ សតវត្ស ។ ម្យ៉ាងទៀត ជាមួយនឹងភាសាបូរាណ ភាសានេះក៏មានប្រើលាយឡំជាមួយគ្នា តាំងតែអំពីដើមប្រវត្តិសាស្ត្រ រហូតដល់សព្វថ្ងៃនេះដែរ [6] ។

## ១.២ សិលាចារឹកជាភាសាខ្មែរ ( ខ្មែរបូរាណ : អង្គរបុរី ) [7]

វីសិលាចារឹកជាភាសាខ្មែរដែលគេបានរកឃើញ មានច្រើនសន្ធឹកសន្ធាប់ណាស់ គេមិនចារជាកំណាព្យទេ គឺគេចារជាពាក្យរាយ ( Prose ) កត់ត្រាអំពីបុណ្យ និងរៀបរាប់អំពីរឿងហេតុដែលកើតមានឡើងរៀងរាល់ថ្ងៃ ។

## ១.៣ សិលាចារឹកជាភាសាបាលី

ម្យ៉ាងទៀត ខ្ញុំគួរតែរំលឹកថា មានភាសាបាលីដែលចាប់ផ្តើមប្រើប្រាស់នៅស្រុកយើង ជាមួយនឹងពុទ្ធសាសនាថេរវាទ នៅចុងសតវត្សទី ១៣ ក្រោយភាសាសំស្ក្រឹតទេ ។ ព្រោះភាសានេះ ជាភាសាយានរបស់ពុទ្ធសាសនាថេរវាទ ។ គេបានរកឃើញសិលាចារឹកជាភាសាបាលីដែលចាស់ជាងគេ នៅសតវត្សទី ១៣ [8] តែមានចំនួនតិចតួចណាស់ ។ ចាប់តាំងអំពីពេលនោះមក ភាសាបាលីត្រូវយកប្រើជំនួសភាសាសំស្ក្រឹតវិញខាងវិស័យសាសនា ។

*២. តើសិលាចារឹកគេសរសេរនៅទីណាខ្លះ ?*

ខ្មែរយើងជាអ្នកចារ ឬសរសេរយ៉ាងចំណាន ។ យើងចារតាំងតែពី សត-វត្សទី ៥ រហូតដល់សតវត្សទី ២០ យើងនេះ ( ឧទាហរណ៍ សិលាចារឹក K 771, ឆ្នាំ ១៩១៦ . ១៧ ) [9] ។

២.១ នៅលើជញ្ជាំងប្រាសាទតែម្តង ឬក្លោងទ្វារ នៅលើមេទ្វារទាំងសងខាង ( Pié-droits ) នៅលើផ្តែរ ( មេទ្វារពីខាងលើ : Linteaux ) ។

២.២ លើផ្ទាំង ឬផែនថ្ម, សីមា ( Stèles ) រាងសំប៉ែត ដូចសីមាវត្តដែលយើងធ្លាប់ឃើញទាំងអស់គ្នា ។ គេសរសេរខាងបន្ទារទាំងសងខាង ចួនកាលខាងទោលទាំងសងខាងដែរ ក៏មាន ។ គេចារនៅលើសរសរស្តម្ភ នៅតាមគ្រប់ជ្រុងទាំងបួន តែមានជ្រុងខ្លះពុំបានសរសេរ ក៏មាន ។ ឯផ្ទាំងថ្មទាំងនេះវិញ មនុស្សអាចលើកផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតបាន ចួនកាលមិនពិតប្រាកដថាជាកន្លែងចាស់របស់សិលាចារឹកនោះទេ ។ ភាគច្រើនគឺ ព្រះសង្ឃដែលបានយកសិលាចារឹកនោះមកតម្កល់ទុកនៅក្នុងវត្តដែលបានសាងថ្មី ។ ចួនកាលមានសិលាចារឹកខ្លះ គេបានចាររួចតាំងតែពីសម័យចាស់ តែលុះសតវត្សក្រោយៗ គេក៏ទៅចារលើផ្ទាំងសិលាចារឹកនោះដដែលបន្ថែមជាមួយគ្នាទៀត ។

ខ្មែរចារលើថ្ម លើស្លឹករឹត លើស្លឹកមាស ប្រាក់ ចងជា " កំពី " ( ពាក្យខ្មែរចាស់ : កំរី ) សរសេរនៅលើក្រដាសក្រាស់បត់ជាផ្នត់ ដែលយើងសព្វថ្ងៃ ហៅថាក្រាំង ។ ការចារនេះ ខ្មែរយើងប្រាថ្នាកត់អំពីបុណ្យកុសល ពុំមែនធ្វើលេងនោះទេ ហើយបង្គាប់អោយអ្នកផងដទៃគោរព និងរក្សាចំណារនេះ ល្មិតណានៅមានព្រះអា-ទិត្យ និងព្រះចន្ទរហូតតទៅ ។ តែដូចយើងទាំងអស់គ្នាបានជ្រាបហើយថា កង្វះការថែរក្សា ធាតុអាកាស សំណើម សង្គ្រាម និងដៃមនុស្សអាក្រក់ បានបំផ្លិចបំផ្លាញសម្បត្តិដ៏មានតម្លៃទាំងនេះមិនចេះឈប់ឈរ ។ រីឯអ្នកដែលពុំបានបំផ្លិចបំផ្លាញវិញ

នោះ គេបានដឹកជញ្ជូនសម្បត្តិអក្សរសាស្ត្រខ្លះចេញអស់អំពីស្រុកយើង មករក្សាទុកក្នុងស្រុកគេ ប្រៀបដូចគេរក្សាសត្វអោយនៅក្នុងសួនសត្វដើម្បីកុំអោយបាត់ពូជវា។

*៣. តើអ្នកណាខ្លះដែលបានស្រាវជ្រាវអំពីសិលាចារឹកនេះ ?*

កម្ពុជាយើងសម័យអតីតកាល មានចារសិលាចារឹកយ៉ាងសន្ធឹកសន្ធាប់ណាស់ ដែលជាប្រភពសំខាន់ដើម្បីសិក្សាប្រវត្តិសាស្ត្រជាតិ ( សិលាចារឹក និងអត្ថ-បទចាស់ៗទាំងនោះ ពុំមែនអធិប្បាយអំពីប្រវត្តិសាស្ត្រទេ តែតាមរយៈអត្ថបទទាំងនោះ អ្នកឯកទេសផ្នែកប្រវត្តិសាស្ត្រ អាចច្បិចយកវត្ថុសំខាន់ៗ ចងក្រងជាប្រវត្តិ-សាស្ត្របាន ) ។

នៅឆ្នាំ ១៨៧៩ លោក ហេនទ្រិក កៀន ( Hendrik Kern ) បានយកសិលាចារឹក ដែលលោក ស៊ុល អារម៉ង់ ( Julle Armand ) បានធ្វើជាប្រដាប់ ( Estampages ) ផ្ញើមក ដើម្បីសិក្សានៅអឺរុប ។ លោក ហេនទ្រិក កៀន បានបោះពុម្ពជាភាសាហុល្លង់ ផ្សព្វផ្សាយសិលាចារឹកជាភាសាសំស្ក្រឹតទាំងនោះ ។ លោក កៀន មិនមានការលំបាកសោះទេ ក្នុងការបកប្រែភាសាទាំងនោះ ព្រោះលោកជាអ្នកឯកទេសខាងភាសាសំស្ក្រឹតស្រាប់ ។ បន្ទាប់មក អត្ថបទរបស់គាត់ត្រូវគេយកមកបកប្រែជាភាសាបារាំង ហើយបោះពុម្ពផ្សព្វផ្សាយនៅប្រទេសបារាំងទៀត ។ ការបោះពុម្ពផ្សព្វផ្សាយនេះ ធ្វើអោយរញ្ជួយដល់អ្នកប្រាជ្ញបារាំងផ្នែកភាសាសំស្ក្រឹត ។

បន្ទាប់មកទៀត ទើបលោក អូហ្គុស បាថ ( Auguste Barth ) លោក អាបែល បែកហ្កេញ ( Abel Bergaigne ) បានផ្ដើមធ្វើការសិក្សា និងស្រាវជ្រាវអំពីសិលាចារឹកជាភាសាសំស្ក្រឹតសុទ្ធ ។

ទើបក្រោយមក នៅឆ្នាំ ១៨៨២ ដល់ ១៨៨៥ ក្រោមការដឹកនាំនៃលោក អេ ត្យែន អេម៉ូនីញេ ( Etienne Aymonier ) បានរកឃើញសិលាចារឹកជាង

៣០០ ក្នុងចំណោមនេះ គេឃើញមានចារជាភាសាសំស្ក្រឹតជាងពាក់កណ្តាលទៅហើយ ទើបគាត់បានរៀបចំបោះពុម្ពផ្សព្វផ្សាយសិលាចារឹកជាភាសាសំស្ក្រឹត ដែលថែងអំពីរបាក្យត្រូសម័យអង្គរ ។ រីសិលាចារឹកជាភាសាខ្មែរវិញ លោក អេម៉ូនីញ៉េ បានធ្វើការសិក្សាយ៉ាងច្រើនលើភាសាខ្មែរចាស់ ( សតវត្សទី ៦ ដល់ទី ១៤ ) និងភាសាខ្មែរសម័យកណ្តាល (សតវត្សទី ១៦ ដល់ទី ១៨) [10] ។ បន្ទាប់មក ដោយមានការសិក្សារបស់គាត់លើភាសាខ្មែរបូរាណផង លើភាសាខ្មែរទំនើបផង និងតាមការត្រិះរិះរបស់គាត់ផ្ទាល់ដល់អត្ថរសនៃសិលាចារឹក ទើបគាត់បានចងក្រងជាសៀវ-ភៅបីក្បាលយ៉ាងសម្បើម ដែលមានឈ្មោះថា " LE CAMBODGE កម្ពុជា " ហើយដែលមានអត្ថន័យយ៉ាងសំខាន់ផ្នែកសង្គមខ្មែរ និងជាអាទិ៍ ប្រវត្តិសាស្ត្រ ភូមិ-សាស្ត្រខ្មែរ បោះពុម្ពនៅឆ្នាំ ១៩០០ - ១៩០៤ ។

ចំពោះលោក ស៊្លក សឺដែស ( George Coedès ) ជាឯកទេសផ្នែកចារិកសាស្ត្រផងនោះ លោកបានបន្សល់ទុកស្នាដៃរបស់លោកយ៉ាងច្រើនអំពីសិលាចារឹកខ្មែរយើងនេះ តែជាភាសាបារាំងដែរ ព្រមទាំងអត្ថបទផ្សេងៗទៀត ដែលទាក់ទងនឹងប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី អក្សរសាស្ត្រ និងសង្គមខ្មែរ [11] ។

មួយចំណែកទៀត ក្នុងរង្វង់អ្នកសិក្សាស្រាវជ្រាវខ្មែរយើងវិញ មានលោកមហាពិទូក្រសេម បានចម្លងសិលាចារឹកសម័យកណ្តាល រួចបានធ្វើបទានុ-ក្រម ភ្ជាប់ពីខាងក្រោមផង [12] ។

តាំងតែអំពីឆ្នាំ ១៩៦០ រហូតមកដល់ឥឡូវនេះ ដោយក្តីសទ្ធារបស់លោកស្រីបណ្ឌិត សាវរស ពៅ លោកស្រីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងច្រើនអំពីសិលាចារឹក : ទាំងភាសាចាស់ ( សតវត្សទី ៦ ដល់ទី ១៤ ) និងទាំងភាសាខ្មែរសម័យកណ្តាល ( សតវត្សទី ១៤ ដល់ទី ១៨ ) ។ ស្នាដៃរបស់លោកស្រី អំពីសិលាចារឹកសម័យកណ្តាលនេះ ត្រូវបានបោះពុម្ពផ្សាយឡើងតាំងពីឆ្នាំ ១៩៧២ ម្ល៉េះ [13] ។

មិនតែប៉ុណ្ណោះ លោកស្រីបានធ្វើពលិកម្មយ៉ាងសម្បើមអំពីភាសាខ្មែរបូរាណ ហើយស្នាដៃដ៏ប្រណីត និងដ៏ស្មុគស្មាញ ដោយបានចងក្រង " វចនានុក្រមខ្មែរចាស់ បារាំង - អង់គ្លេស " ដោយបានសម្ពោធឆ្លង នៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៩២ [14] ។

ថ្វីដ្បិតតែការខិតខំរបស់អស់លោកអ្នកប្រាជ្ញមួយចំនួនទាំងនោះក៏ដោយ ក៏សិលាចារឹកក្នុងប្រទេសយើង នៅមានសេសសល់ច្រើនសន្ធឹកសន្ធាប់ទៀត ដែលខ្មែរយើងពុំបានរកឃើញនៅឡើយ ។

*៤- គោលដៅអំណឹះតទៅអនាគត*

ការសិក្សាលើសិលាចារឹកនៃលោកអ្នកប្រាជ្ញទាំងពីរ មានវិធីពីរបែបផ្សេងអំពីគ្នា ៖

<u>វិធីទី</u> ១ ៖ លោក ស្តីក សីដែស វិធីរបស់គាត់ គឺច្បិចឡើងនូវលក្ខណៈទាំងឡាយដែលទាក់ទងតែនឹងប្រវត្តិសាស្ត្រ និងសិល្បៈ ហើយនិងលាតត្រដាងប្រព័ន្ធសង្គមខ្មែរចាស់ ដែលបានបន្សល់ទុកមកក្នុងសិលាចារឹកចាស់ ។

<u>វិធីទី</u> ២ ៖ លោកស្រី សាវរស ពៅ វិធីរបស់គាត់ គឺលាតត្រដាងអ្វីៗទាំងអស់ដែលទាក់ទងនឹងភាសាសាស្ត្រ គឺស័ព្ទ, ន័យ និងវេយ្យាករណ៍ក្នុងភាសាខ្មែរចាស់ ដោយឆ្លៀតទាញយករចនាសម្ព័ន្ធវិទ្យាសាស្ត្រ ដែលមានដ៏ទូលំទូលាយ ដើម្បីធ្វើការសិក្សាអោយបានដល់ជម្រៅនៃអត្ថបទទាំងអស់ រួចពិនិត្យពិច័យអោយអស់ដែលសិលាចារឹកបានបន្សល់អាថ៌កំបាំងទុកនៅក្នុងនោះ សម្រាប់ជាផ្លូវដ៏ទូលំទូលាយដល់អ្នកសិក្សាក្រោយៗ ។ ពិតមែនហើយ វិធីទាំងពីរបែបរបស់លោកទាំងពីរខាងលើមានគោលបំណងតែមួយគត់គឺ បំផុសអោយឃើញ ៖ រពាក្យត្រអង្គរ រចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋផ្សេងៗ សង្គមព្រាហ្មណ៍ ឬអ្នកកាន់សាសនាផ្សេងៗ ជំនឿសាសនាអំពីភូមិស្រុក ប្រវត្តិផ្នែកសេដ្ឋកិច្ចនៃសង្គមខ្មែរចាស់ រឿងប្រឌិតផ្នែកសាសនា

(ប្រភេទអច្ឆរិយៈ) ផ្នែកភ្លេង របាំ ។ ល ។

ដូច្នេះហើយទើបប្រធានទាំងនោះ គេអាចចម្រាញ់ទាញយកមកសិក្សាធ្វើជាប្រវត្តិសាស្ត្រនៃកម្ពុជា ដែលមានប្រធានចម្បងពីរ គឺ :

១. អំពីសង្គមខ្មែរចាស់,

២. អំពីសេដ្ឋកិច្ចនៃប្រទេសកម្ពុជា សម័យចាស់ និងសម័យកណ្តាល ( សតវត្សទី ១៤ ដល់ ១៨ ) ។ ព្រោះថា សិលាចារឹកនេះហើយដែលជាប្រភពសំខាន់បំផុតនៃការសិក្សា ស្រាវជ្រាវលើកម្ពុជា ។ ប្រសិនជាការសិក្សាស្រាវជ្រាវលើប្រវត្តិសាស្ត្រ និងការស្រាវជ្រាវលើភាសាសាស្ត្រមានប្រព័ន្ធជាផ្លូវមួយនោះ គេអាចចម្រាញ់ យកគុណប្រយោជន៍អំពីស្នាដៃលោក ស្ទក សីដែស ដែលជាអណ្តូងរ៉ែមួយសម្រាប់ជីករកត្បូងពុំចេះរីងខ្សោះសោះឡើយ ដើម្បីយកមកប្រើប្រាស់ និងភ្ជាប់កម្ពុជាចាស់ មកសម័យថ្មីបានដោយប្រពៃទៅអនាគត [15] ។ និងម្យ៉ាងទៀតតាមមធ្យោបាយនៃការផ្សព្វផ្សាយទំនើប គឺការបោះពុម្ពផ្សាយតាមលក្ខណៈវិទ្យាសាស្ត្រ ដែលសិលាចារឹកបានបន្សល់ទុកអោយ ។

***

---

*កំណត់ឯកសារ :*

[1] Cf. Auguste Barth, " Note de lecture sur le Cambodge " , BEFEO, t.II, 1902 : 75-85;
Etienne Aymonier, Le Cambodge, volume I. E. Leroux, Paris 1900;
George Coedès, Recueil des inscriptions du Siam, Vol. I, Bangkok 1924 :
Louis Finot, Notes d'épigraphie indochinoise, EFEO, Hanoï 1916,

[2] " Le supérieur du Monastère paré de toutes règles de la Bonne

conduite, doit aller à la rencontre de tous les maîtres et les honorer suivant ses moyens ", ( Cf. George Coedès, Insriptions du Cambodge, t VI, EFEO 1954 : 195 : Stèle de Vat Sithor, Xème S. stance LXXXIII ).

[3] Cf . Henri Parmentier, " Carte de l'empire khmer d'après la situation des Inscriptions datées ", EFEO, t. XVI, n° 3, 1916.

[4] Abel Bergaigne, Inscriptions sanskrites au Champa et du Cambodge, Imprimerie Nationale, 1893 : 191

[5] Saveros Pou, " Les noms des monuments khmers ", BEFEO, Tome LXXVIII, 1990 : 204.

[6] Saveros Pou, Dictionnaire Vieux Khmer-Français, Paris 1992; Kamaleswar Bhattacharya, Resherches sur le Vocabulaire des inscriptions sanskrites du Cambodge, EFEO. Paris 1991.

[7] G. Coedès, Insriptions du Cambodge, Tome II, Paris 1942 : 21 ; E. Aymonier, Cambodge I, Paris 1900 : 162 ; E. Lunet Lajonquière, Inventaire descriptif des Monuments du Cambodge, Tome I, Paris 1902 : 3.

[8] G. Coedès, " Etudes cambodgeiennes " (XXXII), La plus ancienne inscription en Pali du Cambodge, BEFEO., Tome XXXVI, Fasc. 1, 1936 : 14-21.

[9] Abel Bergaigne, Inscriptions Sanskrites du Champa et du Cambodge, Imprimerie Nationale, 1893.

[10] Etienne Aymonier, " Les inscriptions modernes d'Angkor Vat, Preah Pean, Bakon et la grande Inscription ", Jourmal Asiatique, Nov-Déc, 1899 ;

Le Cambodge, E. Leroux, Paris, 3 tomes, 1900-1904.

[11] G. Coedès, Jayavarmman VII, Imprimerie de la Bibliothèque Royale, Phnom Penh, 1935 ;

Les peuples de la péninsule indochinoise, Dunod Paris, 1962 ;

Les Etats hindouisés et d'Indochine, De Boccard Paris, 1964.

Inscriptions du cambodge, EFEO. 8 volumes, Hanoï-Paris 1937 1966.

" Etudes cambodgiennes ", BEFEO. 1911-1936.

ត្រូវតែកុលបុត្តកុលធីតាយើងទាំងអស់ ស្រាវជ្រាវមករក្សាទុកវិញ នូវស្នាដៃទាំងនេះ ព្រោះវាជាសម្បត្តិវប្បធម៌របស់ជាតិយើង និងម្យ៉ាងទៀត ត្រូវខិតខំសិក្សា សំរាប់សង្គមជាតិយើងតាមរយៈស្នាដៃរបស់គាត់ ព្រោះសព្វថ្ងៃ យើងមិនមានសេសសល់អ្វី ដែលមានតម្លៃដូចសម្បត្តិទាំងនោះទេ ។ បើសិនណាហើយ សម្បត្តិទាំងនោះបាត់បង់ ប្រទេសខ្មែរ ប្រជាជាតិខ្មែរ មនុស្សខ្មែរទាំងនោះឯង ក៏នឹងត្រូវបាត់បង់ដែរ ។

កម្ពុជាយើងសព្វថ្ងៃ ប្រៀបដូចជាសំពៅដែលត្រូវព្យុះបោកបក់លិចលង់ក្នុងលំហមហាសាគរ ។ ដូច្នេះ ត្រូវតែកុលបុត្តកុលធីតាខិតខំតោងពំនាក់តួសំពៅ ឬ បំណែកសំពៅ ទើបយើងអាចគេចផុតពីមហន្តរាយ ហើយយើងអាចរស់រានមានជីវិតបាន ។ បើសិនជាកុលបុត្តកុលធីតាណាមួយហើយ ពុំព្រមខិតខំតោងសំពៅនោះទេ ហើយបែរទៅជាលះបង់សំពៅនោះវិញ អ្នកនឹងត្រូវអន្តរាយជីវិតដោយភាពល្ហើយកម្លាំង ឬដោយមហាព្យុះព្យោមា ដ៏សាហាវក្នុងមហាសាគរជាពុំខាន ។ បានន័យថា យើងត្រូវតែឱបក្រសោបថែរក្សាវប្បធម៌ប្រពៃណីរបស់ជាតិយើងរោយបានប្រាកដប្រជា និងខ្ជាប់ខ្ជួន ទើបយើងអាចរស់រានបាននៅក្នុងពិភពលោកដ៏ចង្អៀតចង្អល់នេះ ដោយក្តីថ្លៃថ្នូរបាន ។

[12] Moha Bidur Krassem, Inscriptions Modernes d'Angkor ( Nouvelle préface de Saveros Pou ), Réimpression par Cedoreck Paris 1984.

[13] Saveros Lewitz, " Les inscriptions modernes d'Angkor Vat ", Journ al Asiatique, Paris 1972 ; Nouvelle Inscription du Cambodge I, EFEO., XVII, Paris 1989 ; Nouvelle Inscription du Cambodge II, EFEO 1996.

[14] Saveros Pou, Dictionnaire Vieux Khmer-Français-Anglais, Cedoreck, Paris 1992.

[15] Saveros Pou, " Angkor et dix siècles d'Art khmer ", Réunion des musées nationaux, Paris 1997 : 53-61.

***

# ព្រះពុទ្ធសាសនា និង សង្គមខ្មែរ

យើងចង់ដឹងថា តាំងពីអតីតកាល រហូតមកដល់បច្ចុប្បន្នកាលនេះ តើព្រះពុទ្ធសាសនា បានជួយអភិវឌ្ឍសង្គមខ្មែរដែរឬទេ ? សំនួរនេះ តម្រូវអោយយើងឆ្លើយ និងដោះស្រាយបំភ្លឺ ដោយប្រើការសិក្សាស្រាវជ្រាវ តាមសម័យកាលនីមួយៗដូចតទៅ :

• *សម័យនគរភ្នំ (ព.ស. ៥៤៣ - ១០៩៣, គ.ស. ទី១ - ៥៥០)*

ខាងចុងគ្រីស្តសតវត្សទី ៥ និងដើមគ្រីស្តសតវត្សទី ៦ ព្រះបាទកៅណ្ឌិន្យជយវរ្ម័ន ព្រះចៅនគរភ្នំ បានបញ្ជូនអ្នកប្រាជ្ញពីរអង្គ គឺព្រះសង្ឃបាលត្ថេរ និងព្រះមន្ទ្រសេនត្ថេរ ដែលចេះភាសាច្រើន អោយទៅជួយប្រែព្រះត្រៃបិដកជូនប្រទេសចិន តាមសេចក្តីសុំពីព្រះចៅក្រុងចិន ព្រះនាម វូ ក្នុងរាជវង្សលាង ។ ព្រះថេរៈទាំងពីរអង្គនេះក៏ទទួលព្រះរាជានុញ្ញាតអោយទៅបំពេញប្រេសិតកម្មនេះ តាមសំណើរបស់ព្រះចៅក្រុងចិន នៅ " ហួណន-ក្វាង " ប្រែថា ការិយាល័យនៃប្រទេសនគរភ្នំ ។ នេះជាប្រេសិតកម្មដ៏ខ្ពង់ខ្ពស់ ដែលព្រះថេរៈទាំងពីរអង្គ បានបំពេញជាផ្លូវរដ្ឋជូនប្រទេសទាំងពីរ ដែលបង្កើតបានជាមិត្តភាពមួយ ចងភ្ជាប់ប្រទេសទាំងពីរ អោយស្រឡាញ់រាប់អានគ្នា ។ ចំណងមិត្តភាពនេះ បានបន្តដល់ព្រះមហាក្សត្រក្រោយៗទៀតផង ។

សេចក្តីប្រែព្រះត្រៃបិដក ជាស្នាព្រះហស្តនៃព្រះថេរៈទាំងពីរអង្គនេះ មានចារជាប់ព្រះនាមក្នុងព្រះត្រៃបិដកចិន រហូតមកដល់សព្វថ្ងៃនេះ ។ កាលសម្តេចព្រះឧបយុវរាជ សីហនុ វរ្ម័ន យាងទៅប្រទេសចិន ក្នុងឆ្នាំ ១៩៥៦ អធិបតីនៃសមាគម

ពុទ្ធសាសនាចិន បានយកស្នាព្រះហស្តនោះមកថ្វាយសម្តេចទត ទុកជាសក្ខីភាពនៃមិត្តភាពខ្មែរ-ចិន ដែលមានអាយុ ១៥០០ ឆ្នាំ មកហើយ ។

នៅ ព.ស. ១០២៧, គ.ស. ៤៨៤ ព្រះបាទកៅណ្ឌិន្យជយវរ្ម័នដដែល បានបញ្ជូនព្រះសាក្យនាគសេនត្ថេរ ជាប្រេសិតទៅកាន់ព្រះចៅក្រុងចិន ព្រះនាម វុ-ទី ។ ប្រេសិតកម្មរបស់ព្រះថេរះអង្គនេះ មានលក្ខណៈជាការទូត ពីព្រោះភារកិច្ចនេះជាទំនាក់ទំនងការងាររបស់ប្រទេសជាតិទាំងពីរ ។ នេះជាការបញ្ជាក់បានថា ភិក្ខុសង្ឃនៃព្រះពុទ្ធសាសនា មានមុខងារសំខាន់ណាស់ក្នុងសង្គម ។

- *សម័យចេនឡា (ព.ស. ១០៩៣-១៣៤៥, គ.ស. ៥៥០-៨០២)*

ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១ វត្តព្រៃវៀរ ជាវត្តមួយគួរអោយចាប់អារម្មណ៍ខ្លាំងណាស់ បំភ្លេចចោលមិនបាន ។ វត្តនេះស្ថិតនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជាវត្តបរមបុរាណមួយជាប់ឋិតថេរចិរកាល តាំងពីកានោះមក រហូតមកដល់សព្វថ្ងៃនេះ ។ ទៅដល់វត្តនេះភ្លាម យើងឃើញសម្បត្តិវប្បធម៌ខ្មែរពីបុរាណគួរអោយរំភើបចិត្តខ្លាំងណាស់ រំភើបដោយនឹកដល់បុព្វបុរសយើង គឺពិតជាបុព្វការីជន គួរជាទីគោរពសក្ការះរបស់យើងជំនាន់ក្រោយ ។ និយាយនេះ ហាក់ដូចជាមានតែវត្តព្រៃវៀរមួយនេះ ដែលមានតួនាទីថែរក្សាសម្បត្តិវប្បធម៌របស់ជាតិ ។ តាមពិត អោយតែវត្តអារាមរបស់ព្រះពុទ្ធសាសនា គឺជាជង្រុកវប្បធម៌របស់ខ្មែរទោះក្នុងសម័យកាលណាក៏ដោយ ។ ប៉ុន្តែ ចំណុចដែលគួរអោយចាប់អារម្មណ៍នោះ គឺ វត្តនេះកើតឡើងតាំងពី គ.ស. ៦៦៤ ហើយឋិតថេរ រហូតមកដល់សព្វថ្ងៃនេះ ពុំមានរលុបរលាយទៅណា ហើយបានរក្សាទុកនូវវប្បធម៌របស់ជាតិអោយយើង រហូតដល់សព្វថ្ងៃនេះ ទៀតផង ។

• *សម័យមហានគរ (ព.ស. ១៣៤៥-១៩៧៥, គ.ស. ៨០២-១ ៤៣២)*

លោក ចូវ តាក្វន ព្រះរាជទូតព្រះចៅក្រុងចិន ប្រចាំប្រទេសមហានគរ បានសរសេរក្នុងឆ្នាំ ១២៩៦ ថា « ព្រះរាជា ពិគ្រោះកិច្ចការធំៗជាមួយនឹងព្រះភិក្ខុសង្ឃ » ។

ឯលោក សីដែស ប្រវត្តិវិទូបារាំង បានសរសេរក្នុងកាលានុប្បវត្តិលាវ និយាយថា ព្រះរាជកុមារ ហ្វា-ង៉ូម បានទៅសិក្សាចំណេះវិជ្ជានៅប្រទេសខ្មែរ ក្នុងរជ្ជកាលព្រះបាទជយវិមបរមេស្វរៈ ។ ព្រះរាជកុមារនេះ បំពេញការសិក្សាក្នុងសំណាក់ព្រះមហាថេរខ្មែរមួយអង្គ មានឋានៈខ្ពង់ខ្ពស់ ព្រះនាម " មហា ផះ សម៉នចៅ " (មហាព្រះសមណៈ) ។ លុះព្រះជន្មបាន ១៦ ព្រះវស្សា ព្រះមហាក្សត្រខ្មែរសព្វព្រះទ័យណាស់ ទ្រង់ព្រះមេត្តាប្រោសលើកព្រះរាជធីតា ព្រះនាម " កែវ ឬ យ៉តកែវ " អភិសេកប្រទានជាអគ្គជាយា ។ លុះដល់ គ.ស. ១៣៥៣ ព្រះរាជាកុមារ ហ្វា-ង៉ូម បានអភិសេកជាព្រះមហាក្សត្រលាវ ព្រះនាម " ព្រះយ៉ា ហ្វា - ង៉ូម " ហើយទ្រង់ដាក់នាមរាជធានីលាវថា " ល៉ានឆាង " ។ កាលណោះ នៅមិនទាន់មាននាមថា " ល្វងព្រះបាង" នៅឡើយទេ ។ រួចហើយ ព្រះយ៉ា ហ្វា - ង៉ូម បានសុំព្រះរាជានុញ្ញាតពីព្រះមហាក្សត្រខ្មែរ និមន្តមហាព្រះសមណៈជាគ្រូរបស់ព្រះអង្គ គណៈសង្ឃខ្មែរ និងសិល្បករខ្មែរច្រើននាក់ ព្រមទាំងគម្ពីរដីកា យកទៅប្រតិស្ឋាននៅប្រទេសលាវ ។ ដើម្បីអោយកើតមានសិរីសួស្តីជ័យមង្គលដល់ប្រទេស និងប្រជាជន របស់ព្រះអង្គ ទ្រង់ក៏សុំព្រះរាជានុញ្ញាតពីព្រះមហាក្សត្រខ្មែរ និមន្តពុទ្ធបដិមា(*) សក្តិសិទ្ធិមួយអង្គទៀត ដែលមានកិត្តិនាមល្បីល្បាញ យកទៅប្រតិស្ឋានទុកជាមង្គល ឬជាកិត្តិយស

(*) ពុទ្ធបដិមាអង្គនេះ ប្រហែលព្រះពុទ្ធរូបព្រះនាម « ជយពុទ្ធមហានាថ » ពីព្រោះ ពុទ្ធរូប នាមជយពុទ្ធមហានាថ ទាំង ២៥ អង្គ មានកិត្តិនាមល្បីល្បាញខ្លាំងណាស់ដល់ប្រទេសនានា ។

ដល់ព្រះរាជធានីយ៉ានឆាង ។ លុះបានទៅប្រតិស្ឋាននៅព្រះរាជធានីយ៉ានឆាងហើយ ព្រះពុទ្ធរូបអង្គនេះ ត្រូវបានថ្វាយនាមថា «ព្រះបាង» ។ រាជធានីយ៉ានឆាង តាំងពីបានព្រះបាងទៅប្រតិស្ឋានទុកជាជយមង្គលហើយ ក៏បាននាមាភិធេយ្យថ្មីថា « រាជធានីលួងព្រះបាង » តាំងពីពេលនោះមក រហូតដល់សព្វថ្ងៃនេះ ។

សេចក្ដីរៀបរាប់ខាងលើនេះ យើងឃើញថា បេសិតមួយក្រុមធំ ដែលព្រះមហាក្សត្រខ្មែរបញ្ជូនទៅនោះ មានទ្រង់ទ្រាយជាផែនការមួយ រៀបចំឡើងដើម្បីជួយអភិវឌ្ឍប្រទេសលាវ ក្រោមការដឹកនាំរបស់មហាព្រះសមណៈ និងព្រះយ៉ាហ្វា-ង្ញូម ។ ព្រោះហេតុនេះ សេចក្ដីរុងរឿងនៃព្រះពុទ្ធសាសនា និងសិល្បវិជ្ជាការនានា នៅប្រទេសលាវ អាចកើតចេញពីឥទ្ធិពលនៃវប្បធម៌ខ្មែរពីបុរាណទាំងអស់ ។

នេះជាការអភិវឌ្ឍន៍ដ៏ធំមួយ ដែលព្រះពុទ្ធសាសនាបានជួយបំពេញថ្វាយព្រះមហាក្សត្រខ្មែរ ក៏ដូចជាសង្គមខ្មែរ បង្កើតបានជាមិត្តភាពមួយយ៉ាងជិតស្និទ្ធ រវាងប្រទេសទាំងពីរ ។ ពង្សាវតារខ្មែរបានឆ្លាក់ប្រវត្តិនេះ ទុកជាកិត្តិយសដ៏ខ្ពង់ខ្ពស់ នៃព្រះមហាក្សត្រខ្មែរ គណៈសង្ឃខ្មែរ ប្រជាជនខ្មែរ ។ និស្សិតលាវ ជាបព្វជិតក្ដី គ្រហស្ថក្ដី តែងមកសិក្សានៅប្រទេសខ្មែរ ក្រោមការឧបត្ថម្ភពីព្រះមហាក្សត្រខ្មែរ ។

• *សម័យអាណានិគមនិយមបារាំង (គ.ស. ១៨៦៣ - ១៩៥៣)*

ក្នុងសម័យនេះ បារាំងបានប៉ុនប៉ងលុបបំបាត់អក្សរខ្មែរ ។ នៅតាមសាលារៀន បារាំងអោយរៀនអក្សរឡាតាំងជំនួសអក្សរខ្មែរ ។ នេះជាព្រឹត្តិការណ៍ ដ៏រំជួលមួយក្នុងសង្គមខ្មែរ ប៉ុន្តែ ពុំមានខ្មែរណាហ៊ានតវ៉ាឡើយ ។ រឿងនេះ បារាំងខំព្យាយាមខ្លាំងណាស់ ប៉ុន្តែ ពេលក្រោយមក ស្រាប់តែបារាំងអោយរៀនអក្សរខ្មែរឡើងវិញ ។ តើមូលហេតុអ្វីបានជាបារាំងលះបង់គំនិតលុបបំបាត់អក្សរខ្មែរ ។

ការដោះស្រាយបញ្ហាខាងលើ ទៅតាមសម័យកាលនីមួយៗ ធ្វើអោយ

យើងដឹងច្បាស់ដោយខ្លួនឯងថា វត្តអារាមជាជង្រុកវប្បធម៌ ជាមជ្ឈមណ្ឌលផ្សព្វផ្សាយពុទ្ធិ និងថែរក្សាសម្បត្តិវប្បធម៌ជាតិ តាំងពីអតីតកាលដ៏យូរលង់មកហើយ ។ ឯព្រឹត្តិការណ៍លុបបំបាត់អក្សរជាតិ ដែលជាព្រឹត្តិការណ៍ដ៏គួរអោយរន្ធត់នោះ ត្រូវបានវត្តអារាមប្រឈមមុខតទល់ទៀត ។ ភិក្ខុ-សាមណេរគ្រប់វត្តអារាម នៅតែសរសេរចារជាអក្សរខ្មែរដដែល សូត្រធម៌ បង្រៀនធម៌ ជាអក្សរខ្មែរ ។ បង្រៀនអក្សរខ្មែរដល់កូនចៅដែលទៅនៅវត្ត ។ គម្ពីរដីកា សាស្ត្រាស្លឹករឹត ក្បួនតម្រាទាំងឡាយ ត្រូវភិក្ខុ-សាមណេរគ្រប់វត្ត ថែរក្សាទុកយ៉ាងម៉ត់ចត់ ។ ការប្រឈមមុខតទល់នឹងបារាំងរបស់វត្តអារាមនេះ ធ្វើអោយបារាំងទាល់ច្រក ពីព្រោះបារាំងមិនហ៊ានរំលោភលើវត្តអារាម ។ មនុស្សខ្មែរនាពេលនោះ មានការរួមគំនិតគ្នាខ្លាំងណាស់ ។ ពុទ្ធបរិស័ទគ្រប់វត្ត មានគំនិតប្រឆាំងបារាំងដូចៗគ្នា ប៉ុន្តែ វត្តអារាម (ភិក្ខុ-សាមណេរ) ជាអ្នកចេញមុខ ។ ឥទ្ធិពលនេះ ធ្វើអោយសាលារៀនអក្សរឡាតាំងរបស់បារាំងចុះខ្សោយ ជាលំដាប់ ។ ទីបំផុត បារាំងអោយរៀនអក្សរខ្មែរដដែល ។ ប្រសិនបើ គ្មានវត្តអារាមទេនោះ អក្សរជាតិរបស់យើង ត្រូវរលុបរលាយបាត់អស់តាំងពីពេលនោះឯង ។

• *សម័យសង្គមរាស្ត្រនិយម (១៩៥៣ - ១៩៧០)*

ក្នុងសម័យសង្គមរាស្ត្រនិយម រដ្ឋាភិបាល និងវត្តអារាម មានការជិតដិតគ្នាល្អណាស់ ។ គំនិតនេះ ពិតជាមានការជិតជាមជាប់ឥទ្ធិពលពីមហាក្សត្រមុនៗ ដូចជាព្រះបាទជ័យវរ្ម័នទី ២ រហូតដល់ជ័យវរ្ម័នទី ៧ ជាដើម ។ ព្រះបាទជ័យវរ្ម័នទី ២ ដែលតាំងរាជធានី នៅលើភ្នំគូលេន ហៅ « មហេន្ទ្របព៌ត » ព្រះអង្គបានរៀបចំពិធីសំខាន់ៗពីរគឺ ពិធី «ទេវរាជ» និងពិធី «ពុទ្ធរាជ» ។ ពិធីទាំងពីរនេះហើយ ដែលធ្វើអោយយើងយល់ថា ព្រះអង្គឱបសាសនាទាំងពីរគឺ ព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ។

តាមពិត កំណើតសាសនារបស់ព្រះអង្គគឺ ព្រហ្មញ្ញសាសនា តែក្រោយមក ដោយពុទ្ធ-សាសនារីកចំរើន ព្រះអង្គក៏បែរមកកាន់ពុទ្ធសាសនាទៀត ។ នេះជាការបញ្ជាក់យ៉ាងច្បាស់ថា ព្រះបាទជ័យវ្ម័នទ ២ ជាបុព្វការីរបស់ព្រះបាទជ័យវ្ម័នទ ៧ ។ ឯសម័យសង្គមរាស្ត្រនិយម ក៏ដូច្នោះដែរ ។ យើងសង្កេតឃើញថា ស្ទើរតែគ្រប់វត្តអារាមបានសាងសង់សាលារៀនសំរាប់កុមារា កុមារី ក្នុងចំណុះជើងវត្ត ។ កាលនោះ ការសាងសង់ទាំងឡាយ មានសាលាបឋមសិក្សា រហូតដល់អនុវិទ្យាល័យ វិទ្យាល័យច្រើនតែព្រះសង្ឃជាប្រធាននៃការសាងសង់ ។ មានវត្តជាច្រើនបានជួយផ្តល់ការងាយស្រួលដល់គ្រូបង្រៀន ដោយផ្តល់ទីកន្លែងស្នាក់នៅក្នុងវត្ត និងផ្គត់ផ្គង់ភោជនា-ហារទៀតផង ។

នៅឯក្រុងភ្នំពេញវិញ វត្តនីមួយៗ ផ្ទុកដោយសិស្ស និងនិស្សិត ស្នាក់នៅរៀនសូត្រ ។ វត្តខ្លះ ភិក្ខុ-សាមណេរមានតិចជាងសិស្ស និស្សិត ។ គ្រាន់តែវត្តឧណ្ណាលោមមួយ ឆ្នាំខ្លះ ភិក្ខុ-សាមណេរមានត្រឹម ៤០០ អង្គ ឯសិស្ស និស្សិត មានដល់ទៅជាង ៥០០ នាក់ ក៏មាន ។ សិស្ស និស្សិត ទាំងនេះមានការស្រឡាញ់ស្និទ្ធស្នាលជាមួយភិក្ខុ-សាមណេរណាស់ ។ សាស្ត្រាចារ្យខ្លះ បន្តស្នាក់នៅក្នុងវត្ត រហូតដល់មានគូស្រករ ទើបចេញពីវត្ត ដោយនាំយកនូវស្លាកស្នាមស្រឡាញ់វត្ត និងភិក្ខុ-សាមណេរទៅជាមួយផង ។ មានសកម្មភាពវប្បធម៌ច្រើនទៀត ដែលវត្តអារាម និងព្រះសង្ឃពុទ្ធសាសនិកយើង បានរួមចំណែកលើកស្ទួយសង្គមជាតិ ។

តាមការសិក្សាដោយសង្ខេបរបស់យើង, យើងឃើញថា តាំងពីបុរាណរៀងមក ព្រះពុទ្ធសាសនាបានដើរតួនាទីជាប្រវត្តិសាស្ត្រ ដោយបានរួមចំណែកដល់ភាពថ្កុំថ្កើងរុងរឿង និងកិត្យានុភាពនៃមាតុភូមិអង្គរ ដោយបានថែរក្សា លើកតម្កើងអត្តសញ្ញាណជាតិកម្ពុជា ភាសា អក្សរសាស្ត្រ វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរដ៏ល្អបវរ ព្រមទាំងបានបង្ហាញផ្លូវរស់នៅ ដ៏សុខសាន្តដល់ខេមរជនគ្រប់រូប

អោយដើរឆ្ពោះទៅកាន់សន្តិភាព វិបុលភាព និងសុភមង្គល ដោយចៀសវាងអំពើហឹង្សា អកុសលកម្ម បាបកម្មផ្សេងៗ ។

នាដំណាក់កាលបច្ចុប្បន្ននេះ ព្រះពុទ្ធសាសនា ដែលស្ទើរតែផុតរលត់សូន្យសុងក្នុងកម្លុងឆ្នាំ ១៩៧៥ - ១៩៧៩ បានរីកចំរើនឡើងវិញ ក្នុងសន្ទុះមួយថ្មី ដោយបានទទួលការឧបត្ថម្ភពីពុទ្ធសាសនិកជនដ៏សប្បុរសក្នុងប្រទេស និងក្រៅប្រទេស ។ ជាមួយនឹងការរីកចំរើននេះ ទោះបីបញ្ហាថ្មីៗ បានកើតមានឡើងនៅក្នុងសាសនមណ្ឌល ក៏មន្ត្រីសង្ឃ និងមន្ត្រីធម្មការខេត្ត ក្រុងរបស់យើង បានរិះរកវិធី និងវិធីសាស្ត្រដោះស្រាយមួយដ៏សមហេតុផល សំដៅពង្រឹងតួនាទីព្រះពុទ្ធសាសនា នៅក្នុងសង្គមឡើងវិញ តាមរយៈតួនាទីរបស់វត្តអារាម, របស់ព្រះសង្ឃ និងការអប់រំឃោសនាផ្សព្វផ្សាយអំពីព្រះធម៌ ពុទ្ធឱវាទ សីលធម៌ ចរិយាធម៌ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ពុទ្ធសាសនិកជនទៅលើព្រះពុទ្ធសាសនា និងតម្រង់ទិសសង្គម និងយុវវ័យជំនាន់ក្រោយៗ អោយបន្តគោរពចំពោះព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនៃយើង ។ សកម្មភាពដែលមន្ត្រីសង្ឃ និងមន្ត្រីធម្មការខេត្ត ក្រុង របស់យើង យកព្រះទ័យយកចិត្តទុកដាក់ជាពិសេសនោះគឺ ការបន្តផ្តល់ការគាំទ្រដល់ការងារមនុស្សធម៌ និងសង្គមកិច្ច ដូចជាកសាងវត្តអារាម កសាងបណ្ណាល័យ កសាងសាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ ការទំនុកបំរុងដល់ចាស់ព្រឹទ្ធាចារ្យគ្មានកូនចៅ កុមារកំព្រា និងប្រជារាស្ត្រជួបគ្រោះភ័យដោយប្រការផ្សេងៗ ជាដើម ព្រោះយើងមានជំនឿជាក់ថា កិច្ចការទាំងអស់នេះ ទោះធំឬតូច, ច្រើនឬតិចក្តី សុទ្ធតែមានឥទ្ធិពលចូលជ្រៅក្នុងជីវភាពសង្គម ដែលញ៉ាំងអោយតួនាទីព្រះពុទ្ធសាសនា កាន់តែរីកចំរើនរឹងមាំទៅអនាគត ៕

**សុខ សេខ**

កែសំរួល : **ឌិម ខែម**

# អំពីផ្លូះ

អ្នកផងតែងតែបានសង្កេតឃើញកសិករខ្មែរទាំងប្រុសទាំងស្រី និយម ប្រើប្រាស់សម្លៀកបំពាក់ពណ៌ខ្មៅ ជាងពណ៌ដទៃទៀត ពីព្រោះ ពណ៌នេះធន់នឹង ការប្រឡាក់ប្រឡូសភក់ជ្រាំ ញើសក្អែល ទោះបីគេមិនបានបោកគក់រាល់ថ្ងៃ ក៏មិន ចោទជាបញ្ហាអ្វីប៉ុន្មានដែរ ។ ពណ៌នេះគេហៅថា ផ្លូះ ។

ផ្លូះគឺជាទឹកជ្រលក់មានពណ៌ខៀវ ធ្វើពីមរលាយនឹងទឹកដាក់កំបោរ-ស គឺ ភក់ដែលកើតពីទឹកត្រាំដើមត្រុំ ស្លឹកត្រុំស្រស់ លាយផ្សំទៅតាមទម្លាប់ដែលបានចេះ បានដឹង និងបានធ្វើតៗគ្នាមកជាច្រើនជំនាន់មកហើយ ។

១ / អំពីត្រុំ

ត្រុំជារុក្ខជាតិម្យ៉ាង ដែលគេយកមកច្នៃធ្វើផ្លូះ ។ កាលពីជាងកន្លះសតវត្ស មុន នៅទីជនបទស្រុកស្រែចំការ គេឃើញត្រុំដុះយ៉ាងច្រើននៅតាមដីទួល ដែលគេ ទុកចោលឥតដាំដំណាំ ។ អ្នកធ្វើផ្លូះ មិនចាំបាច់ដាំត្រុំដែលជាវត្ថុធាតុដើមចាំបាច់បំផុត សំរាប់ធ្វើផ្លូះនោះទេ ព្រោះត្រុំដុះដោយឯងៗ អាចផ្គត់ផ្គង់តម្រូវការនៃអ្នកធ្វើផ្លូះ ឥតមានខ្វះឡើយ ។ ត្រុំជារុក្ខជាតិប្រភេទតិណជាតិ មានកំពស់ពី ៧០ សង្ទីម៉ែត្រ ទៅ ១ ម៉ែត្រ ។ ស្លឹកវារាងមូលទ្រវែងបន្តិច ។ នៅរដូវវស្សា ត្រុំដុះលូតលាស់ល្អ មានស្លឹក ទន់ពណ៌បៃតងចាស់ ។ គឺនៅពេលនោះហើយ ដែលគេកាប់ ឬកាច់ត្រុំយកមកត្រាំ អោយរលួយ ដោយរើសយកតែមែកណាដែលមានស្លឹកច្រើន ។

២ / អំពីការធ្វើផ្លូះ

គេយករម្ងូរស្លឹកត្រុំទៅត្រាំក្នុងខាប់ ដែលដាក់ទឹកពេញ ។ ក្នុងរយៈពេល បីយប់ គេស្រង់ដើមត្រុំ និងស្លឹក ដែលរលួយអស់យកទៅបោះចោល ។ ត្រុំរលួយ

នេះធុំក្លិនស្អុយខ្លះដែរ ប៉ុន្តែមិនមែនស្អុយខ្លាំងរហូតដល់ចូលជិតមិនបាននោះឡើយ ។ ពេលនោះ គេយកកំបោរហុយ ( ពណ៌ស ) ចំនួនបីត្រឡោកទៅចាក់ក្នុងខាប់ ឬពាង ដែលត្រាំត្រំនោះ រួចហើយគេកូរទឹកនោះនឹងកំណាត់ឈើមួយ អស់រយៈពេលប្រ-ហែលកន្លះម៉ោងទើបផ្អាក ។ ថ្ងៃបន្តបន្ទាប់មក គេតែងយកឈើមកកូរវិតវិរក់ទឹកត្រំ រលួយក្នុងខាប់នោះក្នុងមួយលើក១រយៈពេលកន្លះម៉ោង រហូតដល់គម្រប់មួយសប្តាហ៍ ទើបទឹកដែលផ្សំដោយវត្ថុធាតុទាំងពីរនេះឡើងពណ៌ខៀវក្រមៅ ។ ពេលនោះ គេសន្មតថាផ្លូះឡើងពណ៌ពេញលេញ ល្មមអាចជ្រលក់បានហើយ ។

៣ / អំពីការជ្រលក់ផ្លះ

ជាទូទៅ គេតែងយកសំពត់ក្រណាត់ ខោ អាវ អំបោះ សូត្រ ពណ៌ស ដែលគេចង់បានពណ៌ក្រមៅនេះយកទៅជ្រលក់ផ្លះ ។ គេយកវត្ថុទាំងនោះទៅជ្រលក់ក្នុងខាប់ផ្លះដោយកូរត្រឡប់អោយជិតសព្វ ទើបគេពូតច្របាច់សម្រក់ទឹកផ្លះចេញ រួចយកទៅហាលថ្ងៃអោយស្ងួត ហើយយកមកជ្រលក់ហាលបី ឬបួនដង រហូតទាល់តែវត្ថុដែលជ្រលក់នោះជិតពណ៌ខ្មៅពេញលេញទើបឈប់ ។ កាលណាផ្លះនោះជ្រលក់លែងជិតខ្មៅ គេយកកំបោរសមួយ ឬពីរត្រឡោក ទៅចាក់បន្ថែមក្នុងទឹកផ្លះចាស់នោះ ហើយកូរវិតដូចមុន ដរាបទាល់តែផ្លះឡើងពណ៌ ទើបគេទុកអោយរងទឹកផ្លះ ហើយសម្រិតទឹកល្បាយថ្មីនោះ ផ្ទេរទៅដាក់លាយជាមួយខាប់ផ្លះផ្សេងទៀត ។ កាកផ្លះដែលកកនៅបាតពាង ឬខាប់ ត្រូវបានគេបារកៀរយកចេញ ដើម្បីរៀបចំធ្វើផ្លះសាជាថ្មីទៀត តាមរបៀបដូចពោលខាងលើ ។

៤ / អំពីមរ

មរ គឺជាមេនៃផ្លះ ( ភក់កើតពីទឹកត្រាំដើមត្រំ និងស្លឹកត្រំ ) ។ អ្នកធ្វើផ្លះខិតខំរក្សាទុកដើម្បីបង្កបង្កើតផ្លះអោយបានឆាប់រហ័សទាន់តម្រូវការ ដោយមិនចាំបាច់វិលទៅអនុវត្តរបៀបដូចបានជម្រាបខាងដើមនោះឡើយ ។ ដើម្បីធ្វើមរ

គេត្រូវក្លួរធ្លះដែលបានថែមកំបោរពីរ ឬបីដងហើយនោះអោយបានសព្វល្អ ។ មួយសន្ទុះក្រោយមក ទឹកធ្លះខះកកនៅផ្នែកស្រទាប់ក្រោមមានសភាពខាប់ប៊ុកៗ ដូចទឹកម្សៅសាគូ ។ គេសម្រិតទឹករាវខាងលើចេញ ទុកតែវត្ថុធាតុខាប់ដែលកកនៅបាតខាប់ ។ គឺវត្ថុនេះហើយដែលគេនិយមហៅថា « មរ » នោះ ។ គេទុកមរសំរាប់លាយនឹងទឹកធ្លះធម្មតា ដែលទើបផ្សំធ្វើអោយឡើងពណ៌ខ្មៅភ្លាម អាចបំរើការជ្រលក់បាន ដោយមិនចាំបាច់រង់ចាំរហូតដល់មួយសប្តាហ៍នោះឡើយ ។

៥ / អំពីប្រយោជន៍នៃធ្លះ

ដូចបានជ្រាបខាងលើស្រាប់ កសិករខ្មែរសម័យមុន ធ្លាប់បានចាត់ទុកធ្លះជាពណ៌ជ្រលក់មួយយ៉ាងសំខាន់បំផុត ។ ក្រៅពីជ្រលក់សម្លៀកបំពាក់សំរាប់ធ្វើការងារកសិកម្មភ្ជួររាស់ ដកស្ទូង ច្រូតកាត់ គេប្រើធ្លះសំរាប់ជ្រលក់សូត្រធ្វើជាថាន ( សរសៃអន្ទង ) ត្បាញសំពត់ហូល ផាមួង រនាំង ពិដានផ្សេងៗ ។ នៅរដូវប្រញឹកការងារទាំងពីរលើក ( ដកស្ទូង និងច្រូតកាត់ ) អ្នកធ្វើធ្លះមានការមមាញឹកខ្លាំងណាស់ដើម្បីបំរើសំណូមពររបស់កសិករក្នុងសហគមន៍ ។ ដូច្នេះហើយបានជា អ្នកជ្រលក់ត្រូវបង្កើនបរិមាណធ្លះរបស់ខ្លួនរហូតដល់ដប់ ឬដប់ប្រាំខាប់ ( ពាង ) ។ ធ្លះមានលក្ខណៈពិសេសមួយ គឺពណ៌វាជិតជាប់ស្ថិតស្ថេរបានយូរជាងល័ក្តវិទ្យាសាស្ត្រ ។

បច្ចុប្បន្ននេះ ធ្លះបានបាត់បង់តួនាទីជាពណ៌ជ្រលក់នៅកម្ពុជាយើងទៅហើយ ។ ល័ក្តវិទ្យាសាស្ត្រពណ៌ខ្មៅ បានចូលខ្លួនមកបំរើសង្គមខ្មែរជំនួសវិញ ។

ដោយ **មៀច ប៉ុណ្ណ** មន្ត្រីចូលនិវត្តន៍
នៅពុទ្ធសាសនបណ្ឌិត្យ

(១) ផាមួងអន្ទងខ្មៅចាក់លឿង ហៅថា ផាមួងអង្កាច់មាស ។

# សេវនាសេវនកា
# ការគួរសេពគប់ និង មិនគួរសេពគប់

--------

## ព្រះបរមពុទ្ធោវាទ

អសេវនា ច ពាលានំ កុំសេពគប់ពួកជនពាល, បណ្ឌិតានញ្ច សេវនា គួរសេពគប់ពួកជនជាបណ្ឌិត ។ ពាក្យថា ពាល នេះ មានប្រភពដើមថា ទ្វិ «ពីរ» និង លុ «កាត់» ផ្លាស់ ទ្វិ ជា ពា, ផ្លាស់ លុ ជា ល ផ្សំជា ពាល ប្រែថា «អ្នកកាត់ប្រយោជន៍ពីរ គឺប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃ, ឬប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍បរលោក» ។ ពាល បើជាគុណបទ ប្រែថា «ក្មេង ; ទន់ ; ល្ងង់» ។ ពាក្យថា បណ្ឌិត មានប្រភពដើមថា បឌិ ចេញមកជា បណ្ឌា ប្រែថា «ប្រាជ្ញារក្សាខ្លួនឱ្យគេចចៀសវាងផុតចាកទុច្ចរិត» ផ្សំជាមួយនឹង ឥត (បច្ច័យ) សម្រេចរូបជា បណ្ឌិត ប្រែថា «អ្នកមានប្រាជ្ញារក្សាខ្លួនឱ្យគេចចៀសវាងផុតចាកទុច្ចរិត គឺអ្នកកាន់សុចរិតខ្ជាប់ខ្ជួន», ប្រែឱ្យខ្លីថា «អ្នកប្រាជ្ញ គឺអ្នកមានគំនិតប្រាជ្ញាយល់ខុសត្រូវ ព្រមទាំងប្រព្រឹត្តកាន់សុចរិតយុត្តិធម៌ខ្ជាប់ខ្ជួនផង» ។ ផ្ទុយគ្នានឹងពាក្យថា ពាល ។ បណ្ដាពាក្យទាំងពីរនេះ, បុព្វបុរសពុទ្ធសាសនិកខ្មែរយើងនិយមប្រើពាក្យ ពាល ថាអ្នកល្ងង់ខ្លៅ, ប្រើពាក្យ បណ្ឌិត ថាអ្នកចេះដឹង ; ដោយហេតុនេះបានជា បព្វជិតពុទ្ធសាសនិកដែលលាចាកផ្នួស ទើបនឹងសឹកថ្មីៗ គេហៅថា បណ្ឌិត ហៅឃ្លាតមកថា អន្ទិត (ស្រដៀងនឹងសម្ដីប្រាក្រិតនៅប្រទេសឥណ្ឌា), បានជាគេហៅយ៉ាងនេះ ព្រោះគេយល់ថា « អ្នកត្រឹមត្រូវ, អ្នកចេះដឹង, អ្នកហ្មត់ចត់ ដ្បិតទើប

នឹងលាចេញមកពីវត្តអារាម ដែលជាកន្លែងហ្មត់ចត់ ទាំងកំពុងប្រព្រឹត្តសុចរិតខ្ជាប់ខ្ជួនផង » (ពិតឬពុំពិតដូចគេហៅនោះ ជានាទីរបស់អ្នកទើបនឹងសឹកនោះឯង ; គួរណាស់តែប្រព្រឹត្តធម៌ កាន់សីលឱ្យបានហ្មត់ចត់ខ្ជាប់ខ្ជួនតរៀងទៅ កុំឱ្យអ្នកដទៃគេរិះគន់និន្ទាខ្លួនបាន, កុំឱ្យចុះក្នុងតម្រាថា « *អន្ទិតគោលោត ឱ្យស្រីបញ្ឆោតអស់ពោតមួយចង្ការ* » ដែលមានរឿងតំណាលថា សឹកមកដាំពោត, មានស្រីម្នាក់បញ្ឆោតទិញពោតជឿ, តមក, ឥតបានសងថ្លៃពោតទាល់តែសោះ, កើតទុក្ខសឹកកុកសម្កុល ខ្មាសគេសន្ធឹក ) ។

ពាក្យកាព្យឱ្យងាយចាំ

ពាក្យ ៧

*គប់ពាលវែងរាលទៅរកខុស គប់ប្រាជ្ញស្រីប្រុសវែងបានត្រូវ*
*គប់មិត្រអបលក្ខណ៍វែងអាស្រូវ ខុសត្រូវមានព្រោះការសេពគប់ ។*
*គួរជ្រើសរើសរកជនប្រុសស្រី តើមានធម៌អ្វីជាប្រភព*
*បើឃើញច្បាស់ហើយសឹមសេពគប់ ឬត្រូវតែឈប់កុំរវល់ ។*
*បើតាមឱវាទព្រះសម្ពុទ្ធ វិសុទ្ធទ្រង់ធម៌និរមល*
*គួរដឹងថាបើឃើញបុគ្គល យល់ខុសពុំគួរសេពគប់ឡើយ ។*
*សូវនៅម្នាក់ឯងប្រសើរជាង ត្រូវតែចៀសវាងជនពោះតើយ*
*មិនកាន់តាមធម៌ជាកោះត្រើយ ព្រងើយដោយយល់ថាខ្លួនត្រូវ ។*
*មកពីច្រឡំភ័ន្តគំនិត ភ្លាត់គិតបែរយល់ព្រៃថាផ្លូវ*
*យកធម៌សុចរិតជាសត្រូវ ក្រឡូវតំកើងឯទុច្ចរិត ។*

ផ្ទុយទេខុសទេគួរបោះបង់ គួរខំផ្ចិតផ្ចង់កាន់សុចរិត
កុំអាងថាស្រេចតែនឹងចិត្ត គួរតែអាណិតខ្លួនទើបសម ។
ព្រោះការសេពគប់នេះសំខាន់ ប្រយ័ត្នកុំភ័ន្តកុំច្រឡំ
គប់ពាលបានពាលមិនបាច់ខំ ដូចគេវាយដំឱ្យសន្លប់ ។
គប់មិត្របណ្ឌិតបានបណ្ឌិត គំនិតត្រឹមត្រង់អាចបញ្ចប់
ឧបទ្រពចង្រៃឱ្យរម្ងាប់ សុខស្ងប់អាចកើតមានឯងៗ ។
ព្រះសព្វញ្ញូទ្រង់ត្រាស់ថា ជនណាជាមនុស្សពាលដាក់ស្តែង
ស្រាប់តែភ្ញាក់ខ្លួនថាអញឯង ជាពាលក្រែលែងទៅហើយតើ ។
ជននោះបានឈ្មោះថាបណ្ឌិត ព្រោះភ្ញាក់គំនិតដោយអើពើ
នឹងអាចញ៉ាំងខ្លួនឱ្យបានរើ- គំនិតសើរ៉ើឱ្យឃ្លាតឆ្ងាយ ។
ផ្ទុយគ្នាស្រឡះពីជនពាល ពង្រីកពង្រាលផ្លូវអបាយ
ប្រមុខនៃទុក្ខភយន្តរាយ កម្ចាយសុខស្ងប់ឱ្យសាបសូន្យ ។
ឥតភ្ញាក់ខ្លួនសោះរឹតតែរឹត ឥតគិតអាណិតប្រពន្ធកូន
ទោះបីមិត្រភក្តិនិងបងប្អូន ទូន្មានរំលឹកក៏លែងកើត ។
ជននោះឈ្មោះថាមហាពាល ពេញសិប់ជាពាលតួឯកឆើត
គួរសាធុជនកុំឈមអើត មិនកើតទេគុណក្លាយជាទោស ។
គួរចៀសដូចចៀសផ្លូវរផល ខ្ចិចខ្ចិលយ៉ាងណាដោយសន្តោស
កុំឈ្លោះប្រកាន់ឱ្យរឱស ក្រែងទោសនឹងមានព្រោះធ្វើគុណ ។
អហំ ជ.ណ. ជោតញ្ញាណ មានក្តីគោរពព្រះមានបុណ្យ
ពេលដែលខ្លួនកាន់តែចាស់ស៊ុន ជីពជន្មគម្រប់ប៉ែតសិបប្រាំ ។
ភ្ញកនឹកដល់ពុទ្ធភាសិត ថារូបយើងពិតជាមិនទ្រាំ
ដល់រយឆ្នាំទេវែងខ្លេចខ្លាំ ពុំទ្រាំរស់នៅតាមចង់ឡើយ ។

រូបបាត់សូន្យទៅនាមគង់នៅ ដោយសារចិត្តដៅពុំគោះគើយ
ប្រឹងកសាងកេរ្តិ៍ពុំព្រងើយ ខ្លួនបាត់ទៅហើយកេរ្តិ៍គង់នៅ ។
ហេតុនេះអហាំវែងខំប្រឹង ទោះខ្លួនចាស់ម្ដឹងមិនសៅដៅ
ធ្វើនេះរួចធ្វើនោះទៀតទៅ មិននៅយកស្រួលដោយទម្រន់ ។
មិនព្រមទម្រើសខ្លួនឱ្យធ្លាប់ តាំងចិត្តមាំខ្ជាប់ដោយគិតគណាន៍(*)
ឃើញថាករណីយ៍ទោះស្រាលធ្ងន់ កម្រពេកពន់ក៏ត្រូវប្រឹង ។
មានពាក្យភាសិតថែងប្រាប់ថា រូបតែងជរាមិនរឹងប៉ឹង
ប៉ុន្តែរូបកុំដេកសម្លឹង រង់ចាំតែពេលអស់ជីវិត ។
កិច្ចការខ្លះធ្វើបានដោយកាយ ខ្លះដោយវាចានិងចិត្តគិត
ទោះខ្លួនចាស់ត្រូវប្រឹងប្រព្រឹត្ត កុំគិតដេកចាំតែពេលស្លាប់ ។
ធ្វើទៅស្ដីទៅគិតឱ្យសព្វ ការអ្វីគួរគាប់ត្រូវកាន់កាប់
ប្រយ័ត្នកុំឱ្យតែខុសច្បាប់ បើច្បាប់បើកផ្លូវត្រូវប្រឹងធ្វើ ។
ប្រយ័ត្នមួយយ៉ាងកុំឱ្យប៉ះ ប្រទះត្រូវចំលើអំពើ
ជាកម្មអកុសលកុំខ្វល់ធ្វើ ព្រោះកាលបើធ្វើវែងបានទុក្ខ ។
កុំឃើញត្រឹមតែបច្ចុប្បន្ន ប្រយ័ត្នក្រែងភ័ន្តទៅខាងមុខ
កុំយល់ថាចេះតែបានសុខ ស្រណុកស្រណានគ្មានទុក្ខឡើយ ។
បានសុខត្រូវនឹកដល់ទុក្ខផង គិតឱ្យហ្មត់ហ្មងកុំគោះគើយ
សុខទុក្ខក្រវែលគ្មាតឥតស្បើយ ល្ហើយត្រឹមប៉ុណ្ណឹងចុះចប់ហោង ៕

***

(*) គណាន៍ អានថា គន់

# បទគោព័ទ្ធស្ទឹង

*វាចារំឭក :*

អត្ថបទកំណាព្យដែលលោកអ្នកនាង នឹងត្រូវបានអាននៅក្នុងទំព័រជាបន្តទៅនេះ មានឈ្មោះថា បទគោព័ទ្ធស្ទឹង ។ បទនេះត្រូវបានលោកកវីនិពន្ធ អៀង សាយ ចងក្រងឡើងនៅក្នុងសៀវភៅរបស់លោកឈ្មោះ «មេកាព្យ» ។ ខ្ញុំបានអានកំណាព្យនេះនៅក្នុងទសវត្សទី៦០ រួចហើយក៏នៅចាំបទនេះរត់មាត់រហូតមកដល់សព្វថ្ងៃ ។

ដើម្បីរក្សាស្នាដៃដ៏មានតម្លៃនេះទុកកុំអោយបាត់បង់ ខ្ញុំសូមចម្លងកំ-ណាព្យបទគោព័ទ្ធស្ទឹងរបស់លោក អៀង សាយ ទុកក្នុងទស្សនាវដ្ដីកម្ពុជសុរិយាលេខនេះ គ្រាន់ជាគំរូនៃបទ និងគ្រាន់ជាការអានកំសាន្ត សម្រាប់ជនានុជនស្នេហាវប្បធម៌ និងអក្សរសាស្ត្រជាតិ ។ ជាអកុសល ក្នុងចំណោមអត្ថបទកំណាព្យរបស់លោកជាគំរូទាំងពីរបទ ខ្ញុំនៅចាំបានតែមួយប៉ុណ្ណោះ ។ ប៉ុន្តែ បានតាក់តែងអត្ថបទមួយទៀត ជូនបន្ថែមជាគម្រប់ពីរ ។

បទគោព័ទ្ធស្ទឹង គឺជាបទកំណាព្យពាក្យ ៧ ដែលមានចែកចេញជា ៤ ឃ្លា ហើយពាក្យចុងក្រោយនៃឃ្លានីមួយៗ ត្រូវយកទៅធ្វើជាពាក្យផ្ដើមនៃឃ្លាបន្ទាប់ ពោលគឺ ពាក្យទី៧ នៃឃ្លាទី១ ត្រូវធ្វើជាពាក្យទី១ នៃឃ្លាទី២ ឯពាក្យទី៧ នៃឃ្លាទី២ ត្រូវធ្វើជាពាក្យទី១ នៃឃ្លាទី៣ តែយ៉ាងនេះជារៀងរហូតទៅ ។

ព្រមជាមួយនឹងបទកំណាព្យនេះ ខ្ញុំក៏សូមចម្លងទុកផងដែរ នូវរឿងនិទានខ្លីមួយ ដែលខ្ញុំបានអាននៅក្នុងសៀវភៅរបស់លោក អៀង សាយ ក្នុងអំឡុងពេលជាមួយគ្នា ។ រឿងនេះមានឈ្មោះថា « រឿងចៅល្ងង់សព្វជាតិ » ។

## បទគោពំទូស្លីខ ទី ១

ទឹកមាត់ដែលនៅក្នុងមាត់ខ្លួន ខ្លួនលិទ្ធលេបផ្ទួនឥតខ្ពើមទេ
ទេបើជូនជាទឹកមាត់គេ គេខាកខំរេរិះខ្ពើមពិត ៗ
ពិតហើយគំនិតរបស់ខ្លួន ខ្លួនចេះតែសួនមិនមានគិត
គិតឯលទ្ធិគេឆ្ងាយជិត ជិតជួបពិនិត្យថាគេខុស ៗ

## បទគោពំទូស្លីខ ទី ២

ទាស់តិចតួចកុំផ្ដួចផ្ដើមផ្សំ ផ្សំទៅជាធំធ្មឹជាភ្លើង
ភ្លើងកំហឹងបើឆាបឆេះឡើង ឡើងក្ដៅជាងភ្លើងទប់មិនបាន ៗ
បានជាលោកថាអោយខំអត់ អត់ធ្មត់បំផុតទើបបានក្សាន្ត
ក្សាន្តមកពីចិត្តចេះទប់ខាន ខានខឹងព្រោះបានធម៌អត់ឱន ៗ



***

# រឿងចៅល្ងង់សព្វជាតិ

មានរឿងមួយដំណាលថា មានចៅម្នាក់កើតមកនៅក្នុងត្រកូលអ្នកធុនល្មមមួយនៅទីជនបទ ។ ចៅនោះជាក្មេងល្ងង់ហួសពេកណាស់ ខាងផ្នែកបញ្ញាស្មារតី សូម្បីតែអ្វីៗដែលសាមញ្ញ ងាយស្រួលបំផុតក្តី ក៏វាមិនអាចគិតឃើញ ឬយល់បានដែរ ។ បើមានគេប្រាប់ពន្យល់អ្វីបន្តិចបន្តួច ចៅនេះចាប់បានតែមួយភ្លែតប៉ុណ្ណោះ រួចភ្លេចទៅវិញភ្លាម ។ ព្រោះហេតុដូច្នោះហើយ ទើបបានជាគេតែងហៅចៅនោះថា « អាល្ងង់សព្វជាតិ » ។ លុះចៅនោះមានវ័យវឌ្ឍនា-ការធំពេញរូបរាងកន្លងបានយូរទៅហើយកាលណាក្តី ក៏គេគ្មានឃើញអ្វីថាជាការរីកចំរើនដុះដាលខាងប្រាជ្ញាសោះ។ នៅក្នុងដំណាក់កាលនោះ ចៅល្ងង់សព្វជាតិ ស្រាប់តែកើតចិត្តប្រតិព័ទ្ធលើស្រីៗ រហូតដល់សុំអោយម្តាយឪពុកទៅស្តីដណ្តឹងកូនគេអោយ ។ ដោយលុះក្នុងក្តីអាណិតអាសូរកូន ហើយមានគំនិតថា ទោះបីម្តេចម្តា ក៏ថ្ងៃមុខថ្ងៃក្រោយទៅ គេ ត្រូវតែទុកដាក់កូនចៅអោយមានគូស្រករ ទើបស្វាមីភរិយាទាំងពីរអង្គាសម្រេចគ្នាថា ត្រូវតែព្រមព្រៀងតាមបំណងរបស់កូន ។

ក្រោយពីនោះបន្តិចមក ម្តាយឪពុកចៅល្ងង់សព្វជាតិ ក៏ទៅមើលកូនគេម្នាក់ នៅមិនឆ្ងាយប៉ុន្មានពីស្រុកភូមិរបស់ខ្លួនទេ ។ ចៅនោះក៏ទៅជាមួយផងដែរ ។ ការចូលចែចូវ ក៏ទៅជាត្រូវរ៉ូវគ្នានាពេលនោះតែម្តង ។ ទាំងសងខាងបានព្រមព្រៀងគ្នាថា ៣ ខែទៀត នឹងភ្ជាប់ពាក្យ ទាំងលើកជំនូនមកជាមួយផង ហើយ ៣ ខែក្រោយមកទៀត នឹងរៀបការ ។ កម្មវិធីនោះ ត្រូវបានអនុវត្ត ដូច

បានគ្រោងទុក ។ ពិធីរៀបអាពាហ៍ពិពាហ៍បានប្រព្រឹត្តទៅអស់ ៣ ថ្ងៃ ៣ យប់ រួចហើយ កូនប្រុសក៏នៅផ្ទះខាងស្រី ។

លុះចូលខែជាគម្រប់ទី ៣ បន្ទាប់ពីរៀបការមក ប្រពន្ធចៅល្ងង់សព្វជាតិ ក៏ឆ្លងទន្លេបានកូនមួយ ។ ចៅនោះសប្បាយចិត្តណាស់ ។ ចៅប្រឹងខំថែទាំបំរើប្រពន្ធសព្វបែបសព្វយ៉ាង រហូតដល់ប្រពន្ធអាំងភ្លើងរួចរាល់ស្រាច់បាច់អស់ មិនអោយមានខ្វះចន្លោះត្រង់ណាបន្តិចសោះឡើយ ។

បានប៉ុន្មានថ្ងៃក្រោយមក ចៅល្ងង់សព្វជាតិ ជួនជាជួបសម្លាញ់គេម្នាក់ ។ សម្លាញ់នោះ ដែលបានដឹងថាមិត្តរបស់គេ ទើបតែរៀបការបានបីខែហើយស្រាប់តែមានកូនដូច្នេះ ក៏ពន្យល់ថា :

« នែ៎ សម្លាញ់ ! អញអាណិតឯងណាស់ ។ អញសុំប្រាប់ឯងអោយត្រង់ទៅចុះថា កូនហ្នឹងមិនមែនជាកូនរបស់ឯងទេ ព្រោះឯងទើបតែប្រសព្វគ្នាបាន ៣ ខែប៉ុណ្ណោះ ។ បើវាជាកូនរបស់ឯងនោះ លុះត្រាតែឯង និងប្រពន្ធរបស់ឯងបានគ្នាជាប្ដីប្រពន្ធយ៉ាងតិចណាស់ក៏ ៩ ខែដែរ ។ អញ្ចឹង មានតែប្រពន្ធឯងគេមានប្រុសមានសហាយមុនគេរៀបការជាមួយឯង » ។

កាលបើបានឮសម្លាញ់របស់ខ្លួននិយាយយ៉ាងនេះហើយ ចៅល្ងង់សព្វជាតិ ប្រឹងសួររឿងនេះបញ្ជាក់ម្ដងហើយម្ដងទៀត ។ លុះជឿជាក់ថាពិតជាដូច្នេះមែន ចៅនោះក៏អះអាងប្រាប់សម្លាញ់ថា :

« ចាំមើលទៅផ្ទះវិញ អញរករឿងប្រពន្ធអញអោយណាណីម្ដង ។ ច្បាស់ជាពិតអញ្ចឹងមែនហើយ ។ ចាំមើលណា៎ ! អញនឹងលែងវាចោល » ។

បន្ទាប់មក ចៅល្ងង់សព្វជាតិ ក៏ដើររហាំងរលះទៅកាន់ផ្ទះរបស់ខ្លួនវិញ ។ ទៅដល់ហើយ ចៅមិនបង្អង់អោយយូរឡើយ ក៏ប្រញាប់លើកមូលហេតុដែលថាទើបនឹងបានគ្នាជាប្ដីប្រពន្ធតែ ៣ ខែ មិនទាន់បាន ៩ ខែផង ស្រាប់តែ

មានកូននោះមកបង្កជារឿងអោយកើតជាជម្លោះនឹងអាលលែងលះគ្នា ។ រីឯនាងភរិយា គេជាស្រីឆ្លាត លុះឮអ្នកបាទជាប្ដីនិយាយត្រូវចំចំណុចខ្សោយរបស់ខ្លួន ហេតុតែនាងស្គាល់ចរិតរបស់ប្ដីច្បាស់ នាងក៏ប្រើកិរិយាម៉្មឹកម៉្មក់ប្រញាប់និយាយល្បួងប្ដី ទាំងប្រើល្បិចផ្សំផងថា :

« ឪវាឯង កុំអាលជឿគេអោយហួសហេតុណា៎ ។ មនុស្សយើង មិនមែនសុទ្ធតែល្អជាមួយយើងទាំងអស់គ្នាទេ ។ មានមនុស្សខ្លះនិយាយចាក់រុកអោយយើងឈ្លោះគ្នា អោយយើងបែកបាក់គ្នា ។ មនុស្សខ្លះទៀត គេចេះជួយយកអាសារយើង ចង់អោយយើងរស់នៅជួបជុំគ្នាបានល្អ គេនោះទើបជាមនុស្សល្អ ។ យើងត្រូវសេពគប់តែជាមួយមនុស្សល្អទើបបានល្អ ។ ចំណែកឯរឿងដែលឪវាឯងលើកឡើងថា យើងភពប្រសព្វនៅជាមួយគ្នាជាប្ដីប្រពន្ធមិនទាន់បាន ៩ ខែនោះ វាមិនមែនជាការពិតទេណា៎ ! ។ ឥឡូវ ឪវាឯងចាំមើលណា៎ ចាំខ្ញុំរំឭកប្រាប់ឡើងវិញ តាំងពីដើមមក ។ ឪវាឯងមិនមកដណ្ដឹងខ្ញុំបាន ៣ ខែ ទើបលើកជំនួន ? ហ៏ ! រាប់ម្រាមដៃខ្ញុំអោយគ្រប់ ៣ មើល៍ ! « ចៅល្ងង់សព្វជាតិ ក៏នឹកឃើញឡើងវិញថាពិតជាអញ្ចឹងមែន ។ ចៅក៏ចាប់រាប់ម្រាមដៃប្រពន្ធម្ដងមួយៗ រហូតដល់គ្រប់ ៣ រួចចំណាំទុក ។ នាងប្រពន្ធក៏បន្តទៅទៀតថា " លុះលើកជំនួនរួចហើយបាន ៣ ខែទៀត ទើបយើងរៀបការ មែនឬទេ ? បើមែន ហ៏ ! រាប់ម្រាមដៃខ្ញុំថែម ៣ ទៀតមក » ។ ចៅល្ងង់នឹកឃើញរឿងនោះថាពិតដូច្នោះមែន ក៏រាប់ម្រាមដៃប្រពន្ធថែម ៣ ទៀត រួចកាន់ជាប់ទុកជាចំណាំ ។ ជាចុងក្រោយបង្អស់ នាងប្រពន្ធក៏ប្រាប់ទៅទៀតថា : « ក្រោយពីយើងរៀបការមកបាន ៣ ខែថែមទៀតណា៎ ទើបយើងបានកូន ។ នេះរាប់ម្រាមដៃខ្ញុំថែម ៣ ទៀតមក » ។ ចៅល្ងង់យើងក៏រាប់ដូចលើកមុន ។ ពេលនោះ នាងប្រពន្ធបានឱកាសហើយ ក៏និយាយទៅកាន់ប្ដីថា « ឥឡូវនេះ ឪវាឯងរាប់ម្រាមដៃខ្ញុំឡើង

*វិញមើល តើឃើញគ្រប់ ៩ ឬអត់ទេ ? » ។*

*ចៅល្ងង់សព្វជាតិ ក៏រាប់ម្រាមដៃប្រពន្ធតាំងពី ១ រហូតដល់ ៩ ឃើញគ្រប់ចំនួនជាប្រាកដមែន ទើបចៅនោះនឹកខឹងនឹងសម្លាញ់ថា មិនគួរអីមកនិយាយផ្ដេសផ្ដាសលេងអញ្ចឹងសោះ ។ ចៅនោះមិនចងពៀរអ្វីនឹងសម្លាញ់ទេ គ្រាន់តែទៅស្ដី បន្ទោសអោយបន្តិចបន្តួច ដោយប្រការផ្សេងៗតែប៉ុណ្ណោះ ។*

***

ហេតុនិងផលជាគូគ្នា សំរាប់ធីរាត្រូតពិនិត្យ
បើហេតុនិងផលសមគ្នាពិត ជឿចុះកុំភិតភ័យខ្លាចខុស ។

សម្ដេចព្រះធម្មលិខិត ល្វី ឯម




ប្រាសាទបន្ទាយស្រី កសាងក្នុងសតវត្សទី ១០ ក្នុងឆ្នាំ ៩៦៧ ដោយព្រះរាជគ្រូ យជ្ញវរាហៈ

បទពាក្យប្រាំពីរ

*មើលរៃកណ្ដឹងប្រឹងបំពេរ គ្មានពេលទំនេរលើព្រឹក្សា*

*ស្ដាប់ត្នោរំភើបក្នុងឱរា ពាមផ្ដោតនេត្រារកសំឡេង ។*

ឧទ្យានធម្មជាតិល្អប្រណីត ឈើទាលប្រកិតនឹងដើមបេង
វល្លិ៍ត្រៀលអង្គញ់ប្រពោងលេង ដើមស្លង់គិតផ្សេងដុះតែឯង ។
ចង្រិតស្រែកយំពីក្រោមថ្ម តបនឹងឪឡឹយំកណ្តែង
សេកសោមសារិកាច្រៀងប្រឡែង ហ្វូងស្វាកំប្លែងលោតច្របល់ ។
ទីស្ថានមនោរមសែនសុខសាន្ត ទីធ្លាប់ធ្មើងថ្កានបានបន្សល់
មានបន្ទាយស្រីទុកតម្កល់ សក្ការបូជាដល់សព្វថ្ងៃ ។
ទេសចរជាច្រើនដើរសម្លឹង មានខ្លះឈរធ្មឹងនឹកស្រមៃ
គិតដល់អ្នកឆ្លាក់មានទឹកដៃ ក្បាច់ផុសល្អក្រៃស្នាដៃខ្មែរ ។
ឧស្សាហ៍ព្យាយាមនិងអំណត់ បញ្ចាក់ប្រាកដលើនោះដែរ
ពីទេពកោសល្យឥតប្រួលប្រែ មានន័យថាខ្មែរពុទ្ធិខ្ពស់ ។
មើលស្រីគ្រប់លក្ខណ៍ឈរសែនសម រាងនាងមូលក្លំសមនឹងយស
ញញឹមមានលក្ខណ៍វង់ភ័ក្ត្ររស់ ចិត្តអនុគ្រោះដូចវល្លភា[១] ។
ខ្លួនតូចច្រឡឹងល្អឥតខ្ចោះ សមសួនទាំងអស់ឥតគណនា
ដក់ជាប់ជិតដាមក្នុងនេត្រា ឱ ! ជុំសិលាបន្ទាយស្រី ។
ស្រីខ្មែរឥឡូវនាងស្គាល់ទេ រូបសំណាកកេរជាសាក្សី
ស្រីខ្មែរមានសព្វឥតខ្វះអ្វី មានទាំងសេរី និងក្តីស្មោះ ។
ផ្តល់ក្តីស្រឡាញ់ពេញក្នុងលោក បើមានទុក្ខសោករលាយអស់
កូនខ្មែរម្ចាស់កេរសែនស្រណោះ មិនអាចបង់បោះមរតកខ្លួន ។

ខៀវ បញ្ញាចុន្ន

---

(១) វល្លភា ៖ ភរិយាដែលស្វាមីស្រឡាញ់ ទុកចិត្តឥតរង្កៀស ។

# អំពីក្រ ៥ យ៉ាង

## ក្រកិច្ច, ក្រកល, ក្រដឹង, ក្រយល់, ក្រវៃឆ្នៃទាស់

ក្រទាំង ៥ យ៉ាងនេះ មានអត្ថន័យថា : ១. ក្រកិច្ច គឺការអ្វីៗដែលគេត្រូវធ្វើ ហៅថាកិច្ច ; កិច្ចនេះក្រពុំងាយយល់ទេ ។ ២. ក្រកល គឺឧបាយកម្វាយហេតុការណ៍ណាមួយ ហៅថាកល ; កលនេះក៏ក្រ ។ ៣. ក្រដឹង គឺការដឹងរឿងហេតុអ្វីៗក៏ក្រ ព្រោះពុំងាយបានដឹងជាក់ប្រាកដទេ ច្រើនតែដឹងលាំៗ ស្រោលៗ ។ ៤. ក្រយល់ ការយល់នេះក៏ក្រ ព្រោះច្រើនតែបានដឹង ប៉ុន្តែពុំយល់, ដូចគេសួរថា អ្នកឯងបានដឹងរឿងនឹងទេ ? - ឆ្លើយថាដឹង, ចុះយល់ទេតើរឿងហ្នឹងយ៉ាងម៉េច ? - ខ្ញុំពុំយល់ទេ ។ ៥.ក្រវៃឆ្នៃទាស់ ការទទឹងទាស់ឱ្យគេទាស់គាំងភ្លាម ត្រូវតាមការណ៍ពិត ឬត្រូវត្រង់តាមផ្លូវច្បាប់ ញ៉ាំងគេឱ្យស្លូវសប ឬតវ៉ាថាម៉េចទៅទៀតពុំកើត ហៅថា វៃឆ្នៃទាស់ ; វៃឆ្នៃទាស់នេះ ក៏ក្រណាស់ជាងក្រទាំង ៤ ខាងលើទៅទៀត ដោយហេតុនេះបានជា បុរាណភាសិតថា ក្រ ។

# ពាក្យកាព្យឱ្យងាយចាំ

## បទកាកគតិ

*ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រវៃឆ្នៃទាស់*
*ទាំង៥នេះសុទ្ធ- តែក្រទាំងអស់ ប្រាជ្ញាស្រួចស្រស់*
*ទើបក្រឃ្លាតបាន ។*

*ខ្វះការអប់រំ រមែងច្រឡំ ខ្លះៗពុំខាន*
*បើលុះតែខំ អប់រំឱ្យមាន ការថ្មីកទើបបាន*
*រួចផុតចាកក្រ ។*

*កុំយល់ថាងាយ ទោះការសម្វាយ សុទ្ធតែកម្រ*
*លុះតែបានរៀន បានស្តាប់តៗ ទើបបានការក្រ*

ក្លាយជាងាយខ្លះ ។

ទោះកិច្ចតូចទេ ខ្វះការរិះរេ ធ្វើទៅតែងខ្វះ
ទោះធ្វើទៅកើត ក៏មិនស្អាតជ្រះ ព្រោះពាក្យថាខ្វះ
ផ្ទុយនឹងគ្រប់គ្រាន់ ។

ចំណែកខាងកល ឧបាយក្រយល់ ក៏ច្រើនតែភ័ន្ត
ជួនកាលគំនិត វង្វេងវង្វាន់ ជួនកាលស្មោស្មន់
យល់ខុសទទេ ។

បើប្រើតាមកល ដែលគិតពុំយល់ ខ្វះការរិះរេ
ចេះតែស្មានៗ បំពានធ្វេសធ្វេ ឬតាមតែគេ
នាំខុសជាត្រូវ ។

រីឯការដឹង បើគ្មានដំណឹង ក៏ឥតមានផ្លូវ
ណាប្រាប់ឱ្យដឹង មិនមាំស្រេខ្លូវ ការខុសឬត្រូវ
ក៏ឥតបានដឹង ។

ការដឹងក៏ក្រ បើគ្មានតំណ តជាដំណឹង
ឥតមានគំនិត ងងឹតស្ងួនឡូឈឹង ហេតុនោះការដឹង
ក៏ឈ្មោះថាក្រ ។

ចំណែកខាងយល់ ជាការអំពល់ មួយដ៏កម្រ
បើគ្រាន់តែដឹង ដោយឮតៗ ប៉ុន្តែខ្លួនស
ប្រាប់ថាពុំយល់ ។

ដូចគេសួរថា តើអ្នករាល់គ្នា យល់ឬពុំយល់
រឿងដែលខ្លួនដឹង ដំណឹងសល់វ៉ល់ ខ្លួនថាពុំយល់
ខ្ញុំគ្រាន់តែដឹង ។

ហេតុនេះការយល់ លុះតែអំពល់ គិតពេញទំហឹង
បើឥតគំនិត រិះរេសញ្ញឹង ក៏គ្រាន់តែដឹង
កម្របានយល់ ។

ឯវៃថ្ងៃទាស់ ក្រជាងទាំងអស់ ព្រោះច្រើនកើតកល
នៅតាំងជ្រងោ ដោយគិតមិនដល់ ក៏នៅស្រងល់
ដោះស្រាយពុំរួច ។

នៅពេលជំនុំ ឬគេមកជុំ គេតាំងផ្តើមផ្តួច
គេសួរបញ្ហា ណាមួយក្របួច ឯងឆ្លើយពុំរួច
នៅថ្មឹងតែម្តង ។

បើមានប្រាជ្ញា រហ័សក្លៀវក្លា គំនិតហ្មត់ហ្មង
ឆ្លើយបានភ្លាមភ្លែត ត្រដែតកន្លង អ្នកសួរឥតសង
សួរសបរិញទៀត ។

ហេតុនោះបានជា ចាស់លោកពោលថា ការណ៍នេះចង្អៀត
កម្រមានអ្នក ឈ្លាសវៃឆ្លាក់ឆ្លៀត គេសួរថែមទៀត
ពុំអាចឆ្លើយឆ្លង ។

បើរឿងនោះធំ អាចនឹងរលំ ខូចការតែម្តង
ហេតុនោះបានជា ព្រឹទ្ធាចារ្យផង អ្នកចេះហ្មត់ហ្មង
ពោលទុកថាក្រ ។

ក្រវៃថ្ងៃទាស់ លើសក្រទាំងអស់ ហៅពេញជាក្រ
លុះតែរៀនគិត ឱ្យបានល្អិតល្អ នោះទើបក្តីក្រ
នេះឃ្លាតចេញឆ្ងាយ ។

សម្តេចព្រះសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ)

# អបាយមុខ (*)

*ភភន* : យើងនឹកស្តាយ ដោយយល់ថាពុំគួរខាន ក៏បានស្រង់យកពាក្យកាព្យ ជាព្រះរាជនិពន្ធនៃសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ព្រះសង្ឃរាជគណៈមហានិកាយ ដែលទ្រង់និពន្ធក្នុងព.ស ២៥១២ គ.ស ១៩៦៨ កាលព្រះអង្គមានព្រះជន្មគម្រប់ ៨៥ វស្សា មកចុះផ្សាយទុកជាព្រះកេរ្តិ៍ក្នុងទស្សនាវដ្តីនេះ ។ កំណាព្យនេះថ្លែងពីអបាយមុខ ដែលកុបុត្ត កុលធីតាត្រូវចៀសវាង ។

អ្នកមានព្យាយាម, បើពេញចិត្តចំពោះព្រះរាជនិពន្ធនេះ, គួរទន្ទេញអោយចាំមាត់ ឬបង្គាប់អោយកូនចៅតូចៗ អោយទន្ទេញចាំមាត់ស្ទាត់ ហើយអោយនាំគ្នាសូត្ររឿយៗ ដើម្បីរំលឹកគ្នាក្នុងគ្រួសារ ក៏ជាការប្រពៃណាស់, មិនវែងណាស់ណាទេ, ដូចតទៅនេះ :

« អបាយមុខ ប្រែថា ហេតុជាប្រធាននៃសេចក្តីវិនាស ។ ព្រះពុទ្ធសាសនាប្រាប់ថា អបាយមុខ, ដោយសង្ខេបមាន ៤ យ៉ាង គឺ : ១. ឥត្ថីធុត្ត ការលេងស្រី, ២. សុរាធុត្ត ការលេងស្រា, ៣. អក្ខធុត្ត ការលេង ល្បែងភ្នាល់ ឬល្បែងស៊ីសង, ៤. បាបមិត្ត មានជនប្រព្រឹត្តអាក្រក់ជាមិត្ត ។ ទាំង ៤ យ៉ាងនេះ ជាប្រមុខនៃការហិនហោច ឬសេចក្តីវិនាស ។ បណ្តាអបាយមុខទាំង ៤ យ៉ាងនេះ បុគ្គលណាញៀនជាប់នោះត្រង់អបាយមុខណាក៏ដោយ បុគ្គលនោះ ក៏រមែងតែដល់នូវការហិនហោច ឬវិនាសទ្រព្យធន បើមិនច្រើនក៏តិច ពុំដែលខានឡើយ ។

## ពាក្យកាព្យបញ្ជាក់ឱ្យងាយចាំ

### ពាក្យ ៧

*អបាយមុខជង្រុកហិន សង្កិនឱ្យក្តៅដួងហឫទ័យ*
*ច្រើននាំអ្នកលេងឱ្យសន្ធៃ យប់ថ្ងៃដេកព្រួយនឹកស្តាយក្រោយ ។*

កំពុងប្រព្រឹត្តងងឹតឈឹង លុះដល់រំពឹងឃើញញឹកញយ
ទើបបានយល់ច្បាស់ថាខ្លួនធ្លោយ ជួនក៏បណ្តោយដេញជើងទៀត ។
ដេញជើងត្រាតែឃើញលិចលង់ រឹតតែល្ងិតល្ងង់ទ្រូងចង្អៀត
អ្នកខ្លះម៉្លឹងហើយនៅតែឆ្អៀត អង្រៀតនឹងស្លាប់ទើបថយក្រោយ ។
ទំពាំភ្ជាក់ខ្លួនជួនអស់ទ្រព្យ ជួនកាលធ្លាក់ជាប់ដល់រូបខ្សោយ
កើតរោគឈឺចាប់ស្លាប់បណ្តោយ គួរឱ្យព្រឺខ្លាចអបាយមុខ ។
ហេតុនេះយុវ័នយុវតី នាងអ្នកប្រុសស្រីគួរខ្លាចទុក
ឱ្យហើយពីក្មេងទាន់មានសុខ ត្រូវខំសម្រុកប្រឹងរៀនសូត្រ ។
នាងអ្នកចូររៀនកុំផុញទ្រាន់ ទាន់វ័យនៅក្មេងត្រូវខំស្រូត
ស្រូតរៀនឱ្យទាល់តែរហូត បានដល់កោះត្រើយសឹមសម្រាក ។
វិទ្យាជាទ្រព្យដ៏ចម្បង កន្លងលើសលែងឥតទ្រព្យសាក
ជាទ្រព្យស្រាលផងមិនលំបាក វេចជាបង្វេចស្ពាយពុនរែក ។
ទោះមកយកជាប់ទៅជាមួយ វិទ្យាអាចជួយឃើញទាន់ភ្នែក
ចង់បានអ្វីៗវិទ្យាស្រែក ហៅទ្រព្យប្លែកៗឱ្យចូលមក ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃចន្ទ្រ ទី ២២ កក្កដា
សម្តេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ
ប.អ.ស. _ អ.ម. រ.(**)

(*) អបាយមុខ < អប « ប្រាស, ឃ្លាតចាក », អាយ « សេចក្តីចំរើន », មុខ « ប្រមុខ, ប្រធាន, ប្រភព » រួមគ្នាជា អបាយមុខ ប្រែថា ហេតុជាប្រធាននៃសេចក្តី វិនាស ។ ( ជ.ណ. ) ។

(**) ប.អ.ស = បណ្ឌិតអក្សរសាស្ត្រ ; អ.ម.រ = អភិធជមហារដ្ឋគុរុ (សញ្ញាប័ត្រជាន់ខ្ពស់ នៃប្រទេសភូមា)។

# ពិធីសម្ពោធ អគារពុទ្ធសាសនបណ្ឌិត្យ



សម្តេច ជា ស៊ីម ក្នុងពិធីសម្ពោធអគារពុទ្ធសាសនបណ្ឌិត្យ (រូបថត : ពុទ្ធសាសនបណ្ឌិត្យ)

នៅថ្ងៃទី ២៨ ឧសភា ១៩៩៨ វេលាម៉ោង ៨ ព្រឹក ពិធីសម្ពោធអគារពុទ្ធសាសនបណ្ឌិត្យ អំណោយរបស់ រីស្សូ កូសី-កៃ នៅលើផ្ទៃដីជាប់ឧទ្យានសម្តេច ហ៊ុន សែន មាត់ទន្លេបាសាក់ ត្រូវបានប្រារព្ធឡើងក្នុងបរិយាកាសរីករាយយ៉ាងក្រៃលែង ក្រោមអធិបតីភាព សម្តេច ជា ស៊ីម ប្រធានរដ្ឋសភា ព្រះរាជតំណាង ដ៏ខ្ពង់ខ្ពស់នៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ។ ក្នុងឱកាសនោះ គេសង្កេតឃើញ

មានការចូលរួមជាកិត្តិយសនៃភ្ញៀវជាតិ និងអន្តរជាតិ មន្ត្រីរាជការ សិស្សានុសិស្ស ព្រមទាំងពុទ្ធបរិស័ទ ជាច្រើនកុះករ ។

ថ្លែងសុន្ទរកថាស្វាគមន៍ក្នុងឱកាសនោះ, ឯកឧត្តម ហៀន វណ្ណារ័ត្ន រដ្ឋ-លេខាធិការក្រសួងធម្មការ និងសាសនា បានរំលឹកថា : ខេមរបណ្ណាល័យដែលត្រូវបានបង្កើតឡើងដោយព្រះករុណាព្រះបាទស៊ីសុវត្ថិ នៅក្នុងឆ្នាំ ១៩២១ ក្រោយមក នៅក្នុងឆ្នាំ ១៩២៥ បានប្តូរឈ្មោះថា ព្រះរាជបណ្ណាល័យកម្ពុជា ហើយចុងក្រោយបំផុត ត្រូវបានរៀបចំឡើងវិញអោយទៅជា វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ នៅក្នុងឆ្នាំ ១៩៣០ គឺជាមជ្ឈមណ្ឌលស្រាវជ្រាវ និងជាមជ្ឈមណ្ឌលអប់រំតែមួយគត់ របស់កម្ពុជា ដែលមានបណ្ណាល័យឯកទេសរបស់ខ្លួន មានសារមន្ទីរផ្នែកនរវិទ្យា ដែលមានដាក់តាំងវត្ថុជាច្រើន ទាក់ទងនឹងជំនឿសាសនា ទំនៀមទម្លាប់ ប្រពៃណី និងជីវភាពរស់នៅរបស់ជនជាតិ ។ មានក្រុមជំនុំស្រាវជ្រាវពីរទៀតគឺ ក្រុមជំនុំព្រះត្រៃបិដក ( បង្កើតឡើងក្នុងឆ្នាំ១៩២៩ ) និងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ( បង្កើតឡើងក្នុងឆ្នាំ ១៩៣៤ ) ព្រមទាំងបានបោះពុម្ពផ្សាយទស្សនាវដ្តីមួយឈ្មោះ កម្ពុជសុរិយា ដែលបាន ចេញផ្សាយជាលើកដំបូង ក្នុងឆ្នាំ ១៩២៦ ។

នៅមុនឆ្នាំ ១៩៧៥, សកម្មភាពស្រាវជ្រាវ និងសកម្មភាពបោះពុម្ពផ្សាយ បានរួមវិភាគទានដល់កិច្ចអភិវឌ្ឍន៍វប្បធម៌នៃប្រជាជនខ្មែរ ។ បណ្ណាល័យរបស់ពុទ្ធសាសនបណ្ឌិត្យ មានសៀវភៅប្រមាណ ៤០.០០០ ក្បាល ជាភាសាខ្មែរ បារាំង អង់គ្លេស ថៃ សិហឡ: ភូមា និងភាសាឯទៀត ស្តីពី និរុត្តិវិទ្យា, សាសនា, ប្រវត្តិ-វិទ្យា, បុរាណវិទ្យា ․ ល ․ ។ បណ្ណាល័យបានរក្សាកំណប់ដ៏សំខាន់មួយគឺ សាស្ត្រាស្លឹករឹត សរសេរជាភាសាបាលី និងភាសាខ្មែរ ស្តីពីធម៌អាថ៌, រឿងព្រេងប្រជាប្រិយ៍, ប្រពៃណី, វប្បធម៌, អារ្យធម៌ខ្មែរ, ប្រវត្តិសាស្ត្រ, សិល្ប:, របាំ, ចម្រៀង, ... ។ បណ្ណាល័យបានទទួល និងរក្សាទុកជូនសាធារណជនអាន សិក្សា នូវកាសែត ទស្សនា-

វត្តី ព្រឹត្តិប័ត្រ ជាភាសាខ្មែរ បារាំង អង់គ្លេស ដែលផ្ដុំជាប្រភពឯកសារសមោធាន និង ពតិមានមួយ ដ៏សំខាន់បំផុត បើកជូន សាធារណជនចូលអាន សិក្សា ស្រាវជ្រាវ រៀង រាល់ថ្ងៃ ។

បណ្ណាល័យដែលមានសម្បត្តិធនធាន ដ៏មានតម្លៃ កាលនោះ បានតាំងនៅ ក្នុងអគារភាគខាងក្រោម របស់ ក្រសួងការបរទេសបច្ចុប្បន្ននេះ ។ លុះមកដល់ សម័យកាល ដែលក្រុមខ្មែរក្រហមឡើងកាន់អំណាច ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩, សម្បត្តិធនធានទាំងប៉ុន្មាន របស់ ពុទ្ធសាសនបណ្ឌិត្យ ក៏ត្រូវបានបំផ្លាញគ្មានសេស សល់ បាត់បង់ទាំងរូប បាត់បង់ទាំងឈ្មោះ បាត់បង់ទាំងសកម្មភាពបណ្តុះបណ្តាល បញ្ញាស្មារតី ។

ទើបតែនៅដើមឆ្នាំ ១៩៩២, ក្រសួងធម្មការ ត្រូវបានបង្កើតឡើងវិញ ដោយរដ្ឋសភា នៃរដ្ឋកម្ពុជា ។ ឯពុទ្ធសាសនបណ្ឌិត្យ ដែលជាស្ថាប័នមួយ ក្រោមឱវាទក្រសួងធម្មការ ក៏ត្រូវបានរៀបចំ ហើយដំណើរការងារ ឡើងវិញ ដោយបានទទួលព្រះរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ អំពីសម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជ គណៈមហានិកាយ ដើម្បីប្រើប្រាស់កុដិពីរ នៅក្នុងវត្តឧណ្ណាលោម ធ្វើជាកន្លែងធ្វើការបណ្តោះអាសន្ន ។

ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៩២ រៀងមក ដោយបានទទួលការ ឧបត្ថម្ភពីរដ្ឋាភិបាល, ពីអង្គការជំនួយ សូតូស៊ូជប៉ុន (JSRC) ពីអង្គការ រីស្សូ កូសិ-កៃ (RKK) និងពីមូលនិធិហេនរិសប៊ីល (HBF) អាល្លឺម៉ង់ វិជ្ជាថានពុទ្ធសាសន-បណ្ឌិត្យ បានខិតខំស្តារសមត្ថភាព និងលទ្ធភាពរបស់ខ្លួនឡើងវិញ ដោយបានរៀបចំ រចនាសម្ព័ន្ធស្ថាប័នជាថ្មី និងចាប់ផ្តើមសកម្មភាពធ្វើការស្រាវជ្រាវ និងបោះពុម្ពផ្សាយ ភ្លាមដែរ ។

ចំពោះភារកិច្ចបច្ចុប្បន្ន របស់ពុទ្ធសាសនបណ្ឌិត្យ គឺទទួលបន្ត និង រក្សាតួ

នាទីពីមុនរបស់វិជ្ជាស្ថាន ដ៏ជា មជ្ឈមណ្ឌលមួយរបស់ជាតិ ដើម្បីការសិក្សា ស្រាវជ្រាវ ប្រមូលចងក្រងឯកសារ និងការចែកផ្សាយចំណេះដឹង ក៏ដូចជាកន្លែងសំរាប់ធ្វើការ ជួបជុំគ្នា រវាងអ្នកស្រាវជ្រាវជាតិ តំបន់ និងអន្តរជាតិ ដើម្បីធ្វើការជជែក ការពិភាក្សា ផ្លាស់ប្តូរចំណេះដឹង មតិយោបល់ ក្នុងចំណោមអ្នកស្រាវជ្រាវ អំពីពុទ្ធសាសនា និង វប្បធម៌ខ្មែរ ។ល។

ព្រះតេជព្រះគុណ ហ្សិនដូ ម៉ាត្សូណាហ្គា ( Zendo Matsunaga ) ប្រធានអង្គការជំនួយសូត្វស៊ូជប៉ុន ( JSRC ) ក៏ដូចជាព្រះតេជព្រះគុណ យ៉ូស៊ីណូប៊ូ មីណាមី ( Yoshinobu Minami ) ប្រធានមូលនិធិដើម្បី សន្តិភាពនៃអង្គការ រីស្សូ កូសី-កៃ ( RKK ) បានថ្លែងថា ទំនាក់ទំនងជាមិត្តភាពជាមួយពុទ្ធសាសន-បណ្ឌិត្យរបស់កម្ពុជា ចាប់ផ្តើមឡើងតាំងពីឆ្នាំ ១៩៨៧ មក នៅពេលដែលគណៈកម្មាធិការជប៉ុន នៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព និងអង្គការ រីស្សូ កូសេក-កៃ បានចាប់ផ្តើមឧបត្ថម្ភការបោះពុម្ពសៀវភៅធម៌ និងសៀវភៅវប្ប-ធម៌ទូទៅ ។ យើងមានជំនឿដោយស្មោះថា ពុទ្ធសាសនបណ្ឌិត្យនេះ ពិតជានឹងក្លាយទៅជាឧបករណ៍ប្រកបដោយថាមពលមួយ នៅក្នុងការស្តារឡើងវិញនូវមូលដ្ឋានគ្រឹះ ដែលអាចនាំប្រជាពលរដ្ឋកម្ពុជា ទៅរកមាគ៌ារបស់ព្រះពុទ្ធ ។

ព្រះតេជព្រះគុណ មីណាមី បានបញ្ជាក់ថា សមាជិករបស់អង្គការ រីស្សូ កូសី-កៃ ចំនួន ៦ លានកន្លះ បានអត់អាហារចំនួន ៣ ពេល ក្នុងមួយខែ ហើយបានធ្វើអំណោយជាប្រាក់ស្មើនឹងថ្លៃអាហារទាំង ៣ ពេលនោះ ទៅជូនមូលនិធិដើម្បីសន្តិ-ភាព របស់អង្គការ រីស្សូ កូសី-កៃ ។ ប្រការដែលមានសារសំខាន់ជាងគេនោះគឺ យើងបានខិតខំប្រឹងប្រែងក្នុងការចែករំលែកអោយដឹងអំពីន័យនៃការអត់ឃ្លាន និងការស្វាធ្យាយធម៌របស់យើង ដើម្បីសេចក្តីសុខនៃមនុស្សដែលកំពុងមានទុក្ខ ជាជាងដោយគ្រាន់តែអោយទានជាប្រាក់ ។ តាមរយៈយុទ្ធនាការ « ធ្វើអំណោយអាហារមួយ

ពេល » សមាជិក សមាជិកានៃអង្គការ រីស្សូ កូសី-កៃ ទាំងអស់ បានដឹងកាន់តែជ្រាលជ្រៅ អំពីសេចក្ដីថ្លៃថ្នូរ និងភាពរួមតែមួយនៃរូបភាពទាំងអស់ របស់ជីវិត ។ យើងពិតជាមានកិត្តិយសមែន ដោយសារអំណោយរបស់យើង ត្រូវបានគេប្រើប្រាស់ដើម្បីគម្រោងការដ៏ធំ និងមានសារសំខាន់នៃការសាងសង់ឡើងវិញ នូវពុទ្ធ-សាសនបណ្ឌិត្យនេះ ។

សម្ដេច ជា ស៊ីម ប្រធានរដ្ឋសភា និងជាព្រះរាជតំណាងនៃព្រះមហាក្សត្រ បានចាត់ទុកអគារដ៏ស្កឹមស្កៃនេះថា គឺជាអំណោយកាត់ថ្លៃពុំបានរបស់អង្គការសាសនា រីស្សូ កូសី-កៃ ពីប្រទេសជប៉ុន និងជានិមិត្តរូបនៃការប្រកាសបើកសករាជថ្មី ឆ្ពោះទៅកាន់ការអភិវឌ្ឍន៍បញ្ញាស្មារតី ក្រោមពន្លឺនៃព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ និងឆ្ពោះទៅកាន់សុខសន្តិភាពក្នុងចិត្ត ក្នុងកាយជានិរន្តរ៍ សំរាប់ប្រជារាស្ត្រ និងប្រទេសកម្ពុជាទាំងមូល ។

សម្ដេចប្រធានរដ្ឋសភាបានចាត់ទុកថា អំណោយអគារនេះបានឆ្លុះបញ្ចាំងអោយឃើញ នូវទឹកចិត្តស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ និងស្មោះសរបស់ពុទ្ធសាសនិកជនជប៉ុន និកាយរីស្សូ កូសី-កៃ ចំពោះពុទ្ធសាសនិកជនកម្ពុជា និកាយថេរវាទ ដែលជួបលំបាក ហើយក្រក្សត់ ។ អំណោយអគារនេះ នឹងបានប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ចាត់ទុកជាចំណងតភ្ជាប់យ៉ាងជិតស្និទ្ធនៃភាតរភាព និងមិត្តភាពជាអមតៈ រវាងប្រជារាស្ត្រ និងប្រទេសទាំងពីរ គឺកម្ពុជា-ជប៉ុន ។

បន្ទាប់ពីបំពាក់មេដាយស្ថាបនាជាតិ ជូនម្ចាស់អំណោយ និងមេដាយការងារ ជូនមន្ត្រី ៤ រូប នៅក្រសួងធម្មការរួចមក សម្ដេច ជា ស៊ីម អមដំណើរដោយព្រះតេជព្រះគុណ ហ្សិនជួ ម៉ាត្សូណាហ្គា, ព្រះតេជព្រះគុណ យ៉ូស៊ីណូប៊ូ មីណាមី និងសមាជិកសភា សមាជិករាជរដ្ឋាភិបាល អង្គទូត អញ្ជើញកាត់ខ្សែបូ ជានិមិត្តរូប

បើកអោយប្រើប្រាស់អគារថ្មី របស់ពុទ្ធសាសនបណ្ឌិត្យ និងអញ្ជើញទស្សនាទិដ្ឋភាព ផ្នែកខ្លះនៃអគារ និងចុះហត្ថលេខាលើសៀវភៅក្រាំងមាសទុកជាអនុស្សាវរីយ៍ផង ។




សម្តេច ជា ស៊ីម ប្រធានរដ្ឋសភា ចុះហត្ថលេខាលើសៀវភៅក្រាំងមាសទុកជាអនុស្សាវរីយ៍



លោក យូស៊ីណូប៊ូ មីណាមី ប្រធានគណៈប្រតិភូ រិស្សូ កូសី-កៃ ចុះហត្ថលេខាលើសៀវភៅក្រាំងមាស

# សំណង់អគារពុទ្ធសាសនបណ្ឌិត្យ



អគារថ្មីនៃពុទ្ធសាសនបណ្ឌិត្យ សង់អំពីបេតុង អារម៉េ ប្រក់ក្បឿង និងមានកំពូលស្រួចនៅចំកណ្តាល តាមបែបសំណង់សិល្បៈខ្មែរ ដែលផុសត្រដែតនៅលើផ្ទៃដី ជាប់សួនឧទ្យានសម្តេច ហ៊ុន សែន មាត់ទន្លេបាសាក់ ត្រូវបានសម្ពោធបើកអោយប្រើប្រាស់ ចាប់ពីថ្ងៃទី ២៨ ឧសភា ១៩៩៨ តទៅ បន្ទាប់ពីការសាងសង់ អស់រយៈពេលពីរឆ្នាំ ដោយចំណាយប្រាក់អស់ចំនួន ៤៩២.៥៣២ ដុល្លារអាមេរិក ។

លោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា បានថ្លែងរៀបរាប់អំពីកាលប្បវត្តិ នៃការសាងសង់អគារថ្មី របស់ពុទ្ធសាសនបណ្ឌិត្យ ដូចតទៅ :

នៅឆ្នាំ ១៩៩៣ អង្គការពុទ្ធសាសនាជប៉ុន វីស្ស៊ូ កូសី-កៃ តាមរយៈអង្គការជំនួយសូតូស៊ូជប៉ុន ប្រចាំក្រុងភ្នំពេញ បានជួយស្តារ និងកសាងពុទ្ធសាសនា នៅកម្ពុជាឡើងវិញ ជាពិសេស ជួយបោះពុម្ពឡើងវិញ នូវសៀវភៅធម៌អាថ៌ របស់ពុទ្ធសាសបណ្ឌិត្យ ដែលត្រូវបំផ្លិចបំផ្លាញក្នុងសម័យឆ្នាំ ១៩៧៥ - ១៩៧៨ ។ ទន្ទឹមនឹងការជួយឧបត្ថម្ភនេះ ពុទ្ធសាសនបណ្ឌិត្យកម្ពុជា ក៏ធ្វើសំណើតាមរយៈអង្គការជំនួយ

សូត្តស៊ូជប៉ុន ទៅអង្គការ វីស្សូ កូសី-កៃ ដើម្បីអោយអង្គការដ៏សប្បុរសនេះ ជួយសង់អគារមួយខ្នង ធ្វើជាទីស្នាក់ការ ពីព្រោះ ពុទ្ធសាសនបណ្ឌិត្យ ពេលនោះ បានខ្ចីកុដិពីរ ក្នុងវត្តឧណ្ណាលោម ដើម្បីធ្វើជាកន្លែងធ្វើការបណ្ដោះអាសន្ន ។

នៅឆ្នាំ ១៩៩៤ អង្គការនេះបានយល់ព្រមជាគោលការណ៍ ថានឹងជួយផ្ដល់ថវិកាសំរាប់សាងសង់អគារថ្មី តែសុំអោយពុទ្ធសាសនបណ្ឌិត្យ រកទីកន្លែងសាងសង់អោយបានសិន ។

ការស្វែងរកដីសំរាប់សាងសង់ បានចាប់ផ្ដើមពីខែ ឧសភា ឆ្នាំ១៩៩៤ ។ ទាំងក្រសួងធម្មការ និងសាសនា ទាំងប្រតិភូនៃរាជរដ្ឋាភិបាល ប្រចាំក្រុងភ្នំពេញរហូតដល់ព្រះរាជរដ្ឋាភិបាល និងព្រះករុណាជាអម្ចាស់ជីវិត សុទ្ធតែបានរួមវិភាគទានយ៉ាងសកម្ម ក្នុងការស្វែងរកដី សំរាប់សាងសង់អគារថ្មីនេះ ។ បន្ទាប់ពីការផ្លាស់ប្ដូរទីតាំងជាច្រើនលើកមក ចុងបំផុត នៅថ្ងៃ ០៤ ខែមីនា ឆ្នាំ ១៩៩៥ គណៈរដ្ឋមន្ត្រីជាពិសេស សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២ ក៏បានសំរេចប្រគល់ដី នៅទីនេះចំនួន ៩៤៥០ ម២ ទៅក្រសួងធម្មការ និងសាសនា ដើម្បីសាងសង់អគារពុទ្ធសាសនបណ្ឌិត្យថ្មី ។

នៅថ្ងៃទី ២១ ខែកក្កដា ១៩៩៥ អង្គការ វីស្សូ កូសី-កៃ បានសំរេចផ្ដល់ជំនួយ គិតជាទឹកប្រាក់ស្មើនឹង 492.532 $ សំរាប់តែសាងសង់អគារ និងផ្គត់ផ្គង់សម្ភារៈឧបករណ៍ប្រើប្រាស់មួយផ្នែក អោយពុទ្ធសាសនបណ្ឌិត្យ ប៉ុណ្ណោះ ។

ប៉ុន្តែ ដោយសារទីតាំងសំរាប់សាងសង់ ត្រូវបានប្ដូរមកកន្លែងថ្មី ដែលជាមជ្ឈមណ្ឌលវប្បធម៌ និងទេសចរណ៍ផងនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរោបនីយកម្ម និងសំណង់ វណ្ណ ម៉ូលីវណ្ណ បានសុំអោយក្រសួងធម្មការ និងសាសនា គូរប្លង់ឡើងវិញ ដើម្បីអោយសមស្របទៅនឹងទីតាំងថ្មី ។

ពុទ្ធសាសនបណ្ឌិត្យ និងអង្គការជំនួយស្វ៊ីតស៊ុយជប៉ុន ពេលនោះ បានសុំទៅលោក លី ជិនទង ដែលជាស្ថាបត្យករខ្មែរម្នាក់ ធ្លាប់រៀនសូត្រនៅប្រទេសបារាំង អោយជួយគូរប្លង់អគារឡើងវិញ ជាថ្មី ។

ប្លង់អគារ ត្រូវបានគូរចប់សព្វគ្រប់ នៅខែមករា ឆ្នាំ ១៩៩៦ ។ នៅខែមីនា ឆ្នាំ ១៩៩៦ ឯកឧត្តម វណ្ណ ម៉ូលីវណ្ណ បានជួយពិនិត្យគំរូប្លង់ថ្មីម្តងទៀត និងបានយល់ព្រមអោយសាងសង់ ដោយកែសំរួលផ្នែកបច្ចេកទេស និងសោភណភាពបន្តិចបន្តួច ។

នៅថ្ងៃ ០៣ មេសា ១៩៩៦ សាលាក្រុងភ្នំពេញ បានចេញច្បាប់អនុញ្ញាតអោយសាងសង់ ។ ការសាងសង់ បានចាប់ផ្តើមធ្វើនៅថ្ងៃ ១០ ខែមេសា ១៩៩៦ ។

អគារថ្មី នៃពុទ្ធសាសនបណ្ឌិត្យ ដែលមានបណ្តោយ ប្រវែង ៥៤ ម៉ែត្រ ទទឹងត្រង់កន្លែងធំបំផុត ប្រវែង ២០ ម៉ែត្រ កំពស់ ៣២ ម៉ែត្រ ៥០ នេះ សង់លើចន្លល់ខ្ពស់ពីដី និងមានពីរជាន់ នៅត្រង់កណ្តាលអគារ ។ នៅជាន់ផ្ទាល់ដី មានបន្ទប់មួយ ទំហំ ៩២ ម$^{២}$ ធ្វើជាឃ្លាំង និងមានផ្ទៃដីក្រាលស៊ីម៉ង់ចំនួន ១៣០០ ម$^{២}$ ។ ជាន់ទីមួយនៃអគារ ចែកជាបីផ្នែកគឺ ផ្នែកស្លាបខាងស្តាំ ជាសាលប្រជុំ មានទំហំ ១៧២ ម$^{២}$ ស្លាបខាងឆ្វេង ជាបណ្ណាល័យ មានទំហំ ១៧២ ម$^{២}$ ។ ឯផ្នែកកណ្តាលមានការិយាល័យផ្សេងៗ ចំនួន ៨ បន្ទប់ និងបន្ទប់អនាម័យ ៣ បន្ទប់ ។ សរុបផ្ទៃក្រឡាទាំងអស់ នៃជាន់ទី១ មានទំហំ ៦២៣ ម$^{២}$ ។ នៅជាន់ទី២ មានបន្ទប់ធ្វើការចំនួន ៨ និងបន្ទបអនាម័យ ២ ដែលមានទំហំសរុបចំនួន ២៦៥ ម$^{២}$ ។ សរុបផ្ទៃក្រឡារបស់អគារទាំងមូល មាន ២២៧៩ ម$^{២}$ ។ គេអាចឡើងទៅកាន់ជាន់ទី ១ នៃអគារបានដោយរថយន្ត និងតាមជណ្តើរចំនួន ៣ គឺ មួយពីខាងមុខ មួយពីខាងក្រោយ និងមួយទៀត នៅចំកណ្តាលអគារ ។

ពុទ្ធសាសនបណ្ឌិត្យ

## ត្រូវរកសាងអោយបាន នូវ សាមគ្គីភាពក្នុងជួរពុទ្ធសាសនិក

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៧ ត្រូវបានប្រារព្ធឡើងយ៉ាងមហោឡារិក នៅរសៀលថ្ងៃទី ២៥ មិថុនា ១៩៩៨ នាសាលសន្និសីទ ចតុមុខ ក្រោមអធិបតីភាពសម្ដេច ជា ស៊ីម ប្រធានរដ្ឋសភា ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសម្ដេចព្រះសង្ឃរាជ និងមន្ត្រីសង្ឃទាំងពីរគណៈ, មន្ត្រីធម្មការពីគ្រប់ខេត្តក្រុង, ចៅក្រសួង មន្ត្រីក្រសួងធម្មការ និងឥស្សរជនក្នុងជួររដ្ឋាភិបាល - រដ្ឋសភា ព្រមទាំងពុទ្ធបរិស័ទ ចូលរួមប្រមាណ ៧០០ នាក់ ។

ថ្លែងសុន្ទរកថាក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ នាឱកាសនោះ សម្ដេច ជា ស៊ីម ប្រធានរដ្ឋសភា បានសំដែងក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះរាជអគ្គមហេសី ជាទីសក្ការៈ នូវកតញ្ញូតាធម៌ ដ៏ខ្ពង់ខ្ពស់បំផុត ថ្វាយសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ និងជូនក្រសួងធម្មការ និងសាសនា ដែលបានរៀបចំកម្មវិធីដ៏ឧត្តុង្គឧត្តមនេះឡើង ដើម្បីលើកតម្កើងព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋយើង អោយបានស្ថិតស្ថេរជារៀងរហូតទៅ និងសូមប្រគនពរ និងជូនពរបវរមហាប្រសើរ សូមអោយអង្គមហាសន្និបាតសំរេចបានជោគជ័យដ៏ត្រចះត្រចង់ តាមរបៀបវារៈ និងកម្មវិធីដែលបានគ្រោងទុក ។

បន្ទាប់មក សម្ដេចបានមានប្រសាសន៍ថា ៖ « ក៏ដូចជាប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស ដែលជាពុទ្ធសាសនិកជន ខ្ញុំព្រះករុណា ខ្ញុំ មានក្ដីសោមនស្សរីករាយស្វាគមន៍ ចំពោះអង្គមហាសន្និបាត និងមានជំនឿយ៉ាងមុតមាំថា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ នឹងយកព្រះទ័យទុកដាក់ដ៏ខ្ពង់ខ្ពស់ ដើម្បីដោះស្រាយបញ្ហាផងទាំងឡាយ

ដែលជាការលំបាក ឬជាឧបសគ្គរារាំងដល់ដំណើរជាប្រក្រតីនៃព្រះពុទ្ធសាសនា នៅពេលបច្ចុប្បន្នផង និងរកវិធីដ៏សក្តិសិទ្ធិ សំដៅទ្រទ្រង់ដំណើរទៅមុខនៃព្រះពុទ្ធ-សាសនានៃយើង តទៅអនាគតផង ។

សម្តេចបានរំលឹកថា ៖ តាំងពីបុរាណកាលរៀងមក ព្រះពុទ្ធសាសនាបានដើរតួនាទីជាប្រវត្តិសាស្ត្រ ដោយបានរួមចំណែកដល់ភាពថ្កុំថ្កើងរុងរឿង និងកិត្យានុ-ភាពនៃមាតុភូមិអង្គរ ដោយបានថែរក្សាលើកតម្កើងអត្តសញ្ញាណជាតិកម្ពុជា ភាសាអក្សរសាស្ត្រ វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរដ៏ល្អបវរ ព្រមទាំងបង្ហាញផ្លូវរស់នៅ ដ៏សុខសាន្តដល់ខេមរជនគ្រប់រូប អោយដើរឆ្ពោះទៅកាន់សន្តិភាព វិបុលភាព និងសុភមង្គល ដោយចៀសវាងអំពើហឹង្សា អកុសលកម្ម បាបកម្មផងទាំងឡាយ ។

ក្នុងដំណើរវែងឆ្ងាយបត់បែនក្នុងប្រវត្តិសាស្ត្រជាតិយើង ទីវត្តអារាម ព្រះសង្ឃ គម្ពីរ ដីកា ក្បួនច្បាប់ និងពុទ្ធសាសនិកជន បានស្មោះស្ម័គ្របូរផ្លាស់ទ្រទ្រង់ព្រះពុទ្ធសាសនាអោយបានរីកចំរើន សមស្របនឹងតថភាពសង្គមជាតិ ហើយមានដំណើរទៅមុខ ទន្ទឹមគ្នានឹងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ ។ ទាំងនេះបានបង្កើតឡើងនូវមោទនភាព និងមានឥទ្ធិពលស៊ីជម្រៅ ជ្រួតជ្រាប ក្នុងដួងចិត្តនៃជនកម្ពុជាគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ គ្រប់ទិសទី រហូតដល់មានការទទួលស្គាល់ជាផ្លូវការ ជាសាសនារបស់រដ្ឋ ។

នាដំណាក់កាលបច្ចុប្បន្ននេះ ព្រះពុទ្ធសាសនាដែលស្ទើរតែផុតរលត់សូន្យសុង ក្នុងកម្លុងឆ្នាំ ១៩៧៥ - ១៩៧៩ បានរីកចំរើនឡើងវិញ ក្នុងសន្ទុះថ្មី ដោយបានទទួលការឧបត្ថម្ភពីពុទ្ធសាសនិកជនដ៏សប្បុរស ទាំងក្នុង និងក្រៅប្រទេស ។

ជាការពិតហើយ ជាមួយនឹងការរីកចំរើននេះ បញ្ហាថ្មីៗបានកើតឡើង ដែលទាមទារនូវការដោះស្រាយមួយដ៏សមហេតុផល ។

ខ្ញុំព្រះករុណា ខ្ញុំ សូមរួមចំណែកទាក់ទាញអារម្មណ៍អង្គសន្និបាត អោយចាប់អារម្មណ៍អំពីការពង្រឹងតួនាទីព្រះពុទ្ធសាសនាក្នុងសង្គម តាមរយៈតួនាទីរបស់វត្តអារាម, ព្រះសង្ឃ និងការអប់រំឃោសនាផ្សព្វផ្សាយអំពីព្រះធម៌ ពុទ្ធឱវាទ សីល-ធម៌ ចរិយាធម៌ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ពុទ្ធសាសនិកជន ទៅលើព្រះពុទ្ធសាសនា និងតម្រង់ទិសសង្គម និងយុវវ័យជំនាន់ក្រោយ អោយបន្តគោរពចំពោះព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនៃយើង ។ ដើម្បីសំរេចការងារនេះ ទាមទារនូវការពង្រឹងឡើងវិញនូវ ប្រព័ន្ធពុទ្ធិកសិក្សាអោយបានសុក្រឹតត្រឹមត្រូវ និងមានគុណភាពពិតប្រាកដ ព្រមជាមួយនឹងការបង្កើនសមត្ថភាពរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងការបោះពុម្ព ចងក្រង ផ្សព្វផ្សាយអោយបានទូលំទូលាយនូវ គម្ពីរ ដីកា ក្បួនច្បាប់ និងឯកសារផ្សេងៗទៀត ។

សំខាន់ជាងគេមុនអ្វីៗទាំងអស់គឺ ត្រូវកសាងអោយបាននូវសាមគ្គីភាពក្នុងជួរពុទ្ធសាសនិកជន ជាពិសេស ក្នុងជួរព្រះសង្ឃទាំងពីរគណៈ ដែលត្រូវដើរជាគំរូដល់ប្រជារាស្ត្រយើង ។ ព្រះសង្ឃត្រូវដើរតួនាទីអោយបានសមស្របទៅនឹងការលើកតម្កើងដ៏ខ្ពង់ខ្ពស់ជាសាសនារបស់រដ្ឋ ។ ការប្រកាន់និកាយធម្មយុត្ត ឬ មហា-និកាយ គឺចំណុះលើជំនឿរបស់ពុទ្ធសាសនិកជន ។

អាស្រ័យដោយលទ្ធភាពរបស់រដ្ឋយើងនៅមានកំណត់ ហើយជីវភាពប្រជារាស្ត្រយើងនៅជនបទ ក៏នៅជួបការលំបាកជាច្រើនប្រការ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវដល់ព្រះតេជព្រះគុណព្រះមេគណ ព្រះអនុគណ ព្រះចៅអធិការគ្រប់វត្ត សូមព្រះមេត្តាយកព្រះទ័យទុកដាក់បន្តទៀត ចំពោះការកសាងសមិទ្ធិជាប្រ-យោជន៍សាធារណៈ ដែលមិនផ្ទុយនឹងគន្លងនៃព្រះពុទ្ធសាសនា ។ រួមជាមួយនោះ សូមព្រះអង្គមេត្តាបន្តផ្តល់ការគាំទ្រដល់ការងារមនុស្សធម៌ និងសង្គមកិច្ច ដូចជាការទំនុកបំរុងដល់ចាស់ព្រឹទ្ធាចារ្យគ្មានកូនចៅ ថែទាំកុមារកំព្រា និងប្រជារាស្ត្រជួប

គ្រោះភ័យ ដោយប្រការផ្សេងៗ ។

កិច្ចការទាំងនេះ ទោះធំ ឬតូច, ច្រើន ឬតិចក្តី សុទ្ធតែមានឥទ្ធិពលចូលជ្រៅក្នុងជីវភាពសង្គម ដែលញុំាងអោយតួនាទីនៃព្រះពុទ្ធសាសនា កាន់តែរីកចំរើនរឹងមាំទៅអនាគត ។

ដោយថ្ងៃនេះ ជាថ្ងៃគាប់ជួនគ្នានឹងថ្ងៃចាប់ផ្តើមនៃយុទ្ធនាការបោះឆ្នោត ខ្ញុំព្រះករុណា ខ្ញុំ សូមឆ្លៀតឱកាសនេះ សូមអំពាវនាវដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ នៅទូទាំងប្រទេស សូមព្រះមេត្តាផ្តល់ដំបូន្មាន និងការអប់រំទូលំទូលាយដល់ប្រជា-រាស្ត្រយើងជាពុទ្ធសាសនិកជន និងជាអ្នកបោះឆ្នោតនៅគ្រប់ទីកន្លែង អោយប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ យកធម៌ព្រះពុទ្ធជាពន្លឺ ដើម្បីលើកតម្កើងនូវការឃោគយល់សន្តោសប្រណី អធ្យាស្រ័យគ្នា និងរំងាប់នូវអំពើគំរាមកំហែង ការគាបសង្កត់ អំពើហឹង្សា ឬសកម្មភាពមិនប្រក្រតីណាមួយ ដែលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ពលរដ្ឋដទៃ ក្នុងការសំដែងមតិតាមសន្លឹកឆ្នោតសំងាត់ ក្នុងក្របខ័ណ្ឌនៃការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

ខ្ញុំព្រះករុណា ខ្ញុំ មានជំនឿយ៉ាងមុតមាំថា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គនឹងមេត្តាចូលរួមវិភាគទានដ៏ថ្លៃថ្លា ក្នុងការពន្យល់ណែនាំដល់ប្រជារាស្ត្រយើងអោយបានយល់ដឹង និងប្រកាន់ជំហរ ទស្សនៈត្រឹមត្រូវ ក្នុងកម្លុងពេលនៃយុទ្ធនាការឃោសនាបោះឆ្នោត និងការបោះឆ្នោត នាពេលខាងមុខនេះ ។ ម្យ៉ាងទៀត កិច្ចការពារសិទ្ធិមនុស្ស និងការលើកតម្កើងលទ្ធិប្រជាធិបតេយ្យ ពុំទាស់ខុសអ្វីនឹងពុទ្ធឱវាទនៃព្រះសម្មាសម្ពុទ្ធនៃយើងឡើយ » ។

***

# សេចក្តីអំពាវនាវ
# របស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៧

ថ្ងៃទី ២៥ - ២៦ - ២៧ ខែមិថុនា ឆ្នាំ ១៩៩៨

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៧ ដោយមានសម្តេចព្រះសង្ឃរាជ និងមន្ត្រីសង្ឃទាំងពីរគណៈចូលរួម ត្រូវបានប្រារព្ធឡើង យ៉ាងមហោឡារិក នៅវេលារសៀល ថ្ងៃទី ២៥ ខែមិថុនា ១៩៩៨ នាសាល សន្និសីទ ចតុមុខ ក្រោមអធិបតីភាព សម្តេច ជា ស៊ីម ប្រធានរដ្ឋសភា ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងឱកាសនោះ បន្ទាប់ពីសុន្ទរកថាស្វាគមន៍ របស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្តីពីសកម្មភាពរបស់ព្រះសង្ឃចំពោះពុទ្ធសាសនា និងសង្គម រួចមក, សម្តេច ជា ស៊ីម បានថ្លែងសុន្ទរកថាបើកមហាសន្និបាតមន្ត្រីសង្ឃប្រកបដោយខ្លឹមសារជ្រាលជ្រៅ ស្តីពីបច្ចុប្បន្នភាពនៃពុទ្ធសាសនា ដោយភ្ជាប់ទៅនឹងបច្ចុប្បន្នភាពនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងធ្វើយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។ល។ និង ។ល។

ចាប់ពីពេលព្រឹក នៃថ្ងៃទី ២៦ - ២៧ ខែមិថុនា អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៧ ខាងគណៈមហានិកាយ ត្រូវបានបើកប្រជុំពេញអង្គ នៅក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្រោមព្រះអធិបតីភាព ព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ដោយមានមន្ត្រីសង្ឃពីគ្រប់ខេត្ត ក្រុង ចូលរួម ចំនួន ១៥០ អង្គ និងមន្ត្រីធម្មការខេត្ត ក្រុង ចំនួន ២៧ រូប ព្រមទាំងចៅ

ក្រសួង និងមន្ត្រីក្រសួងធម្មការ មួយចំនួន ក៏បានចូលរួមផងដែរ ។ ខាងគណៈធម្មយុត្តិកនិកាយ ត្រូវបានបើកប្រជុំពេញអង្គ នៅក្នុងវត្តបទុមវតី ក្រុងភ្នំពេញ ក្រោមព្រះអធិបតីភាព សម្តេចព្រះសុគន្ធាធិបតី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ដោយមានមន្ត្រីសង្ឃខេត្ត ក្រុង ចូលរួម និងមន្ត្រីធម្មការខេត្ត ក្រុង ព្រមទាំងចៅក្រសួង និងមន្ត្រីក្រសួងធម្មការមួយចំនួន បានចូលរួមផងដែរ ។

អនុសំវច្ឆរមហាសន្និបាត បានស្តាប់សេចក្តីរាយការណ៍របស់ព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយ អំពីសកម្មភាពទាំងក្នុង និងក្រៅប្រទេស របស់សម្តេច ក្នុងឆ្នាំ ១៩៩៧ ក្នុងបុព្វហេតុជាតិ សាសនាព្រះមហាក្សត្រ ។

អនុសំវច្ឆរមហាសន្និបាតបានស្តាប់យោបល់មួយចំនួន របស់ឯកឧត្តម ប្រាក់ ជិន អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្តីពីពុទ្ធសាសនា និងវប្បធម៌ខ្មែរ ។

អនុសំវច្ឆរមហាសន្និបាតបានស្តាប់បទអន្តរាគមន៍ របស់ឯកឧត្តម យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា ស្តីពី ពុទ្ធសាសនានៅកម្ពុជា ។

អនុសំវច្ឆរមហាសន្និបាត បានស្តាប់សេចក្តីរាយការណ៍ របស់ មន្ត្រីសង្ឃ មន្ត្រីធម្មការខេត្ត ក្រុង ស្តីពីបច្ចុប្បន្ននៃពុទ្ធសាសនា, ចំណុចខ្វះខាត និងចំណុចរីកចំរើននៅក្នុងការប្រតិបត្តិធម៌វិន័យ និងការរៀនសូត្រព្រះបរិយត្តិធម៌ នៅតាមខេត្តក្រុងនីមួយៗ ។

អនុសំវច្ឆរមហាសន្និបាត បានស្តាប់យោបល់របស់មន្ត្រីនៃវេទិកាផ្សាយមេត្តាធម៌ ដើម្បីសន្តិភាព ( អង្គការក្រៅរដ្ឋាភិបាល ) ស្តីពីអហឹង្សា ។

អនុសំវច្ឆរមហាសន្និបាត មានអំណរសាទរយ៉ាងជ្រាលជ្រៅ ខ្ពង់ខ្ពស់បំផុត ដោយបានឃើញផ្ទាល់នឹងចក្ខុ ស្តាប់ឮដោយសោតៈរៀងៗខ្លួន នូវព្រះកាយ

វិការនៃសម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គ មានទំនាក់ទំនងគ្នាដោយរាក់ទាក់បំផុត នៅក្នុងអង្គអនុសំវច្ឆរមហាសន្និបាត ដោយគ្មានការប្រកាន់អស្មិមានះសោះឡើយ ។

អនុសំវច្ឆរមហាសន្និបាត បានស្ដាប់សេចក្ដីរាយការណ៍សង្ខេប របស់លោក ឱម ខែម នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ស្ដីពីសកម្មភាពរបស់ពុទ្ធ-សាសនបណ្ឌិត្យបច្ចុប្បន្ន និងសំណូមពរការងារអនាគត ។

អនុសំវច្ឆរមហាសន្និបាត បានស្ដាប់មតិរបស់ឯកឧត្ដម ដោក ណារិន អនុ-រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្ដីពីការអភិវឌ្ឍន៍ វិស័យពុទ្ធិកសិក្សា ។

អនុសំវច្ឆរមហាសន្និបាត បានស្ដាប់និងអនុម័តសេចក្ដីអំពាវនាវ របស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៧ ដែលមានខ្លឹមសារ ដូចខាងក្រោម ៖

១. មន្ត្រីសង្ឃគ្រប់ថ្នាក់ ត្រូវយកព្រះទ័យទុកដាក់បន្ដដោះស្រាយ និងបំបាត់រាល់បាតុភាពអសកម្ម ដែលជះឥទ្ធិពលមិនល្អដល់ពុទ្ធសាសនា ដូចជា រាល់បាតុ-ភាពវិវរអង្គាសមិនសមហេតុផល, ការបង្កអោយមានអធិករណ៍ក្នុងជួរសាសនា, ការប្រព្រឹត្តឃ្លៀងឃ្លាតអភិសមាចារ និងកិច្ចវត្តផ្សេងៗ, ការត្រាច់ចរដោយបំពាន ទៅកាន់ទីអគោចរ និងភាពអលជ្ជីនៃបព្វជិត ត្រូវតែខិតខំលុបបំបាត់ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២. ខិតខំប្រើប្រាស់អោយអស់លទ្ធភាព និងមធ្យោបាយដែលមាន ដើម្បីបន្ដជំរុញសាលាពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យ ដែលជាគ្រឹះមូលដ្ឋាននៃការពង្រឹងពង្រីកពុទ្ធិកមធ្យមសិក្សា និងពុទ្ធិកឧត្ដមសិក្សា ដែលជាប្រភពនៃភាពបិតថេររបស់ពុទ្ធសាសនា ក៏ដូចជាប្រភពនៃការរីកចំរើនខាងបញ្ញាញាណជាតិដែរ ។

ជាមួយនេះដែរ បន្ដសកម្មភាពបើកវគ្គសិក្សាផ្នែកវិប្បនាធុរៈ ការសិក្សាបរមត្ថធម៌ ដើម្បីប្រតិបត្តិអោយសុក្រិត្យ តទៅ ។

អំពីការសិក្សាបាតិមោក្ខបាលី ក៏ត្រូវតែជំរុញអោយភិក្ខុ-សាមណេរ យក

ហាប្ញទ័យទុកដាក់រៀនសូធ្យ អោយចាំមាត់ ហើយប្រឡងយកសញ្ញាប័ត្រផងដែរ ។

៣. មន្ត្រីសង្ឃគ្រប់ថ្នាក់ ត្រូវខិតខំណែនាំ និងជំរុញអោយវត្តនីមួយៗមានបណ្ណាល័យ ហើយត្រូវជួយជាវសៀវភៅធម៌ និងសៀវភៅអក្សរសាស្ត្រ ដែលបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ យកទៅតម្កល់ទុកនៅក្នុងបណ្ណាល័យរបស់វត្ត ។

៤. មន្ត្រីសង្ឃគ្រប់ថ្នាក់ ត្រូវបង្កើនការិតគ្រប់គ្រងវត្តអារាម, គរុភណ្ឌ វត្ថុសិល្បៈ និងភិក្ខុ-សាមណេរ ដើម្បីធានាបានគង់វង្ស និងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន និងរួមចំណែកលើកស្ទួយកិត្យានុភាព និងឥទ្ធិពល នៃព្រះពុទ្ធសាសនា ។

៥. ស្នើសុំអោយក្រសួងធម្មការ និងសាសនា មានកម្មវិធីបូកសរុបការងារប្រចាំឆ្នាំនីមួយៗ អោយបានមុនការប្រព្រឹត្តទៅ នៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ រៀងរាល់ឆ្នាំ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៨

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខា និងត្រា ៖ ហៀន វណ្ណារដ្ឋ

បានឃើញ និង ឯកភាព

ភ្នំពេញ, ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៨

ព្រះមហាសុមេធាធិបតី

សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ

ព្រះហស្តលេខា និងត្រា

**ទេព វង្ស ( ឧបេក្ខាសម្មោជ្ឈង្គិកោ )**

# មន្ត្រីសង្ឃធិរាជាគណៈ នៃ គណៈមហានិកាយ

**I.** រាជាគណៈថ្នាក់ឯក :

| | | |
|---|---|---|
| ១. ព្រះពោធិវង្ស នន់ ង៉ែត | វត្តបទុមវតី | រាជធានី ភ្នំពេញ |
| ២. ព្រះធម្មលិខិត ឈាស់ ឡាយ | វត្តសន្សំកុសល | រាជធានី ភ្នំពេញ |
| ៣. ព្រះវន្ន័រត ស មៀង | វត្តឧណ្ណាលោម | រាជធានី ភ្នំពេញ |

**II.** រាជាគណៈថ្នាក់ទោ :

| | | |
|---|---|---|
| ១. ព្រះមហាវិមលធម្ម ពិន សែម | វត្តរាជបូណ៌ | ខេត្តសៀមរាប |
| ២. ព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ | វត្តព្រះពុទ្ធមានបុណ្យ | ភ្នំពេញ |
| ៣. ព្រះធម្មឃោសាចារ្យ អ៊ុក រ៉ន | វត្តទួលទំពូង | រាជធានី ភ្នំពេញ |
| ៤. ព្រះឃោសធម្ម ឡុង យន់ | វត្តកណ្ឌរាម តាខ្មៅ | ខេត្តកណ្តាល |
| ៥. ព្រះសាសនមុនី ជេត ឌិន | វត្តជម្ពូព្រឹក្សា | ខេត្តស្វាយរៀង |
| ៦. ព្រះមុនីកោសល ហ៊ុល សុវណ្ណ | វត្តទួលសង្កែ | រាជធានី ភ្នំពេញ |

**III.** រាជាគណៈថ្នាក់ត្រី :

| | | |
|---|---|---|
| ១. ព្រះសិរីសម្មតិវង្ស យឿង យ៉ាត | វត្តជ្រោយអំពិល | ខេត្តកណ្តាល |
| ២. ព្រះពុទ្ធវង្ស ឡាយ លឿង | វត្តស្លាកែត | ខេត្តបាត់ដំបង |
| ៣. ព្រះសក្យវង្ស ប៉ាន សួស | វត្តព្រៃល្វា | ខេត្តតាកែវ |
| ៤. ព្រះឧបាលិវង្ស ងួន យី | វត្តចាក់អង្រែក្រោម | ខេត្តកណ្តាល |
| ៥. ព្រះញាណវង្ស យ៉ង់ សុខ | វត្តសុទស្សនារាម ជ្រោយថ្ម | កំពង់ចាម |
| ៦. ព្រះសុមេធវង្ស កែ យីន | វត្តកំពង់ពពិល | ខេត្តព្រៃវែង |

**IV.** រាជាគណៈថ្នាក់ចត្វា ៖

| | | |
|---|---|---|
| ១. ព្រះធម្មវិបស្សនា សំ ប៊ុនធឿន | វត្តនន្ទមុនី | រាជធានី ភ្នំពេញ |
| ២. ព្រះសមាធិធម្ម ស៊ិន ស៊ីម | វត្តបទុមរតនៈ (ដីដុះ) | ខេត្តកំពង់ចាម |
| ៣. ព្រះញាណកោសល ខៀវ ណើយ | វត្តរាជបូណ៌ | ខេត្តសៀមរាប |
| ៤. ព្រះសិរីសង្គ្រាមមុនី ហ៊ី ហេង | វត្តកោះ | រាជធានី ភ្នំពេញ |
| ៥. ព្រះសិរីវិសុទ្ធិ ប៊ុ ផាង | វត្តឧណ្ណាលោម | រាជធានី ភ្នំពេញ |
| ៦. ព្រះធម្មវង្សា ស៊ិន ឃីម | វត្តលង្កា | រាជធានី ភ្នំពេញ |
| ៧. ព្រះញាណសំវរ ស្រី ធីម | វត្តនិរោធរង្សី | រាជធានី ភ្នំពេញ |
| ៨. ព្រះវិន័យសំវរ ប៉ុក សំអាន | វត្តសន្សំកុសល | រាជធានី ភ្នំពេញ |
| ៩. ព្រះឥន្ទមុនី ចាន់ ថន | នៅប្រទេសបារាំង | |
| ១០. ព្រះទេពមុនី ឡុង សាខន | នៅប្រទេសអូស្ត្រាលី | |
| ១១. ព្រះអរិយមគ្គញ្ញាណ អន ហ៊ីម | វត្តក្រពើហា | ខេត្តកណ្ដាល |
| ១២. ព្រះវិភទ្ធញ្ញាណ ព្រហ្ម ខៀន | នៅសហរដ្ឋអាមេរិក | |
| ១៣. ព្រះបវរសត្ថា អឿ សំអាន | វត្តជម្ពូវ័ន | ខេត្តកណ្ដាល |
| ១៤. ព្រះញាណវិសុទ្ធិវង្ស សូ ហ៊ុល | វត្តចមសុទ្ធាវាស | ខេត្តបន្ទាយមានជ័យ |
| ១៥. ព្រះធម្មវិសុទ្ធិវង្ស ឯម ភឿង | វត្តជុំក្រៀល | ខេត្តកំពត |
| ១៦. ព្រះសីលសំវរ កើត គាំ | វត្តសិរីមង្គល | ខេត្តកណ្ដាល |
| ១៧. ព្រះគម្ពីរត្ថេរ ប៉ាល ហ៊ាល | វត្តមង្គលវ័ន | រាជធានី ភ្នំពេញ |
| ១៨. ព្រះវិន័យមុនី ពេជ្រ ពឿន | វត្តឧណ្ណាលោម | រាជធានី ភ្នំពេញ |
| ១៩. ព្រះទេពសត្ថា ស៊ង់ សារី | វត្តឧណ្ណាលោម | រាជធានី ភ្នំពេញ |

ភ្នំពេញ, ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៩៨

ទេព វង្ស សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ក្បួនដង្ហែរបស់សម្ដេចព្រះមហាឃោសានន្ទ ក្នុងឱកាសទិវាប្រកាសប្រគេនរង្វាន់សន្តិភាព របស់មូលនិធិ ដើម្បីសន្តិភាព នៃអង្គការ រីស្សូ កូសី-កៃ, ថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៩៨ ( រូបថត JSRC )

ឆ្នាំទី ៥២ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា

ព.ស ២៥៤២ គ.ស ១៩៩៨

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ឌារត្ន**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました

この本が、日本の宗教者とカンボジアの人々との友情のきずなとなりカンボジアの宗教と文化の発展に貢献できれば幸いです

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន ( JSRC ) ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាព រវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្ប-ធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## Acknowledgement

The *Kambuja Suriya Magazine* is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

**I. អត្ថបទរដ្ឋបាល**


- សេចក្ដីសំរេចស្ដីពីការបង្កើតគណៈកម្មការរៀបរៀង
  មាតិកានុក្រមព្រះតៃបិដក ........ ១


**I. អក្សរសិល្ប៍ពុទ្ធសាសនា**


- ធម៌ត្រឹះនៃពុទ្ធសាសនា - ត ( ឈេន អៀម ) ........ ៤
- ជំនួយស្មារតី : ពុទ្ធសាសនា និងការអប់រំសង្គម ( អាំ ឆន ) ........ ៣២


**II. អក្សរសាស្ត្រទូទៅ**


- វចនស័ព្ទវិទ្យានៃភាសាខ្មែរបច្ចុប្បន្ន - ត-ចប់ (បណ្ឌិត ឡុង សៀម) ........ ៣៧
- កតញ្ញូតា (ភារៈនៃអ្នកដឹងគុណ) ........ ៥៩
- ទេវទត្ត គឺអ្នកណា ? ........ ៦៣
- កិច្ចវត្តត្រង់អន្លើខ្លះចំពោះបព្វជិតពុទ្ធសាសនិក ........ ៦៦
- វិធីស្ដីការរបស់រាងកាយ ........ ៦៩
- ឯកសារ : កំណើតមនុស្សជាតិ ........ ៧៥
- រឿង ក្អែកនិងមៀម-ពស់និងស្កា-ខ្លាឃ្មុំនិងដើមពង្រ ........ ៨៦


**III. កំណត់ និង ប្រវត្តិការណ៍**

សុន្ទរកថារបស់សម្ដេចព្រះមហាឃោសានន្ទ :


- ក្នុងឱកាសទទួលរង្វាន់សន្តិភាព នៅទីក្រុងតូក្យូ ........ ៩៧
- ក្នុងឱកាសសាំប៉ូស៊ីយោម នៅទីក្រុងក្យូតូ ........ ១០៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ : ១៤៣ / ៩៨ ក.ធ.ស

# សេចក្តីសំរេច

ស្តីពីការបង្កើតគណៈកម្មការរៀបរៀងមាតិកានុក្រមព្រះត្រៃបិដក

-----

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣
- បានឃើញព្រះរាជក្រមស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមលេខ នស.រកម ០១៩៦.១៩ ចុះថ្ងៃទី ២៤ មេសា ១៩៩៦
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.មក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈនៃមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤
- យោងតាមការចាំបាច់របស់ក្រសួង

## សំរេច

ប្រការមួយ : បង្កើតគណៈកម្មការរៀបរៀងមាតិកានុក្រមព្រះត្រៃបិដក ដែលមាន

សមាសភាព ដូចតទៅ :

១. ព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ នាយកពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត អធិបតី

២. លោក ម៉ែន ប្រាង នាយករងពុទ្ធសាសនបណ្ឌិត្យ អធិបតីរង

៣. លោក អាំ ឆន បុគ្គលិកការិយាល័យព្រះត្រៃបិដក និងទំនៀមទម្លាប់ខ្មែរ សមាជិក

៤. លោក ម៉ី យ៉ាំ លេខាធិការសម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ សមាជិក

៥. លោក ឱម វីរៈ អនុប្រធានការិយាល័យបោះពុម្ព ការីកុំព្យូទ័រ

៦. លោក រត្ន ដែន បុគ្គលិកពុទ្ធសាសនបណ្ឌិត្យ លេខាធិការ

ប្រការ ២ : គណៈកម្មការនេះ ត្រូវកំណត់ពេលវេលាចាប់ផ្ដើមការងារ និងបញ្ចប់ការងារអោយបានជាក់លាក់ ដើម្បីអោយការរៀបរៀងមាតិកានុក្រមព្រះត្រៃបិដក ទទួលបានលទ្ធផលល្អប្រសើរ ។

ប្រការ ៣ : គណៈកម្មការរៀបរៀងមាតិកានុក្រមព្រះត្រៃបិដក ត្រូវជួបប្រជុំគ្នារៀងរាល់សប្ដាហ៍ ឬអឌ្ឍមាស តាមការអញ្ជើញរបស់អធិបតី ។ អធិបតីនៃគណៈកម្មការអាចនិមន្ត-អញ្ជើញ ព្រះសង្ឃ និងគ្រហស្ថ ជាបញ្ញវន្តជាតិ និងអន្តរជាតិដទៃទៀត ចូលរួមផ្ដល់យោបល់តាមការគួរ ។

ប្រការ ៤ : គណៈកម្មការរៀបរៀងមាតិកានុក្រមព្រះត្រៃបិដក ត្រូវរាយការណ៍ប្រចាំខែ ជូននាយកពុទ្ធសាសនបណ្ឌិត្យ អំពីលទ្ធផល និងដំណើរការងារ

របស់គណៈកម្មការ ។

ប្រការ ៥ : នាយកខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកពុទ្ធសាសនបណ្ឌិត្យ អធិការដ្ឋាននៃពុទ្ធិកសិក្សា និងអស់លោកដែលមានរាយនាមក្នុងប្រការមួយ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា : ហៀង វណ្ណរត្ន

ចម្លងផ្ញើជូន :

- សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ( ដើម្បីទ្រង់ជ្រាបជាពត៌មាន )
- នាយកដ្ឋានក្រោមឱវាទក្រសួង ( ដើម្បីជ្រាបជាពត៌មាន )
- ដូចក្នុងប្រការមួយ ( ដើម្បីអនុវត្ត )
- ឯកសារ កាលប្បវត្តិ

# ធម៌ត្រិះ នៃ ពុទ្ធសាសនា (ត)

ដោយ លោក ភីទ័រ ដ. សន្តិនា
( By Peter D. Santina )
បកប្រែដោយ : **ឈន អឿម**

## VIII
## កម្ម ( កម៌ )

ថ្ងៃនេះ យើងមកដល់មតិទាក់ទងគ្នាពីរ ដែលជាគំនិតធម្មតានៅក្នុងពុទ្ធសាសនា ។ គំនិតទាំងពីរនេះគឺ គំនិតស្តីពីកម្ម ( កម៌ ) និងការកើតទៀត ( បុនរុប្បត្តិ ) ។ គំនិតទាំងឡាយនេះ មានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ប៉ុន្តែ ដោយហេតុតែប្រធានបទមានវិសាលភាពជាបង្គួរផង, យើងនឹងចាប់ផ្តើមសិក្សាគំនិតនិយាយពីកម្ម ( កម៌ ) នៅថ្ងៃនេះ, ហើយសិក្សាគំនិតនិយាយពីការកើតជាថ្មី ( បុនរុប្បត្តិ ) នៅក្នុងឱកាសក្រោយទៀត ។

យើងដឹងថា អ្វីដែលធ្វើអោយយើងវង្វេងវិលវល់នៅក្នុងសង្សារៈ គឺកិលេស . កាមៈ, ព្យាបាទៈ, និងអវិជ្ជា ។ យើងបាននិយាយអំពីរឿងនេះរួចហើយ កាលដែលយើងនិយាយអំពី អរិយសច្ចៈ ទីពីរគឺ សច្ចៈ ស្តីពីហេតុនៃទុក្ខ ( សមុទយ-ទុក្ខ ) ។ កិលេសទាំងឡាយនេះ គឺជាសភាវធម៌ដែលសត្វលោកគ្រប់រូបតែងតែចែករំលែក ទោះបីយើងនិយាយតែពីមនុស្សឬសត្វពាឡម្រឹគ ឬសត្វដែលរស់នៅក្នុងភពឯទៀតៗដែលយើងមិនអាចមើលឃើញតាមធម្មតាក៏ដោយ ។ នៅក្នុងនេះ,

សត្វលោកទាំងអស់ គឺដូចគ្នា ហើយក្នុងចំណោមសត្វលោកទាំងអស់ដែលយើងអាចមើលឃើញពាបធម្មតា មានភាពផ្សេងៗគ្នាជាច្រើន ។ ឧទាហរណ៍ មានមនុស្សខ្លះមានទ្រព្យសម្បត្តិ, មនុស្សខ្លះមិនសូវមានទ្រព្យសម្បត្តិ, មនុស្សខ្លះមានកម្លាំងពលំ និងសុខភាពល្អ, អ្នកខ្លះទៀត ជាជនពិការ, ៎ល ៎ ។ មានភាពផ្សេងៗគ្នាច្រើនក្នុងចំណោមសត្វលោកទាំងឡាយ, ហើយកាន់តែមានភាពផ្សេងៗគ្នាច្រើនជាងទៀត រវាងសត្វពាឡម្រឹគ និងមនុស្ស ។ ភាពផ្សេងៗគ្នានេះ កើតមកពីកម្ម ។ អ្វីដែលយើងមានគ្រប់គ្នាគឺ ៎ កាមៈ ព្យាបាទៈ និងអវិជ្ជា គឺមានចំពោះសព្វសត្វលោក, ប៉ុន្តែវាមានស្ថានភាពដោយឡែក ដែលយើងបានរស់នៅនោះគឺ លទ្ធផលនៃកម្មដោយឡែករបស់យើង ដែលពាក់តែងស្ថានភាពសម្រាប់ការរស់នៅរបស់យើង, ជាស្ថានភាពដែលនៅក្នុងនេះ យើងអាចជាអ្នកមានទ្រព្យសម្បត្តិ, ជាអ្នកមានកម្លាំងមាំមួន, ជាអ្នកមានសុខភាពល្អ, ៎ល ៎ ។ ស្ថានភាពទាំងឡាយនេះ គឺបានកើតមានឡើងដោយកម្ម ។ គឺនៅក្នុងន័យនេះហើយ ដែលកម្មពន្យល់នូវពាក្យផ្សេងៗគ្នា ក្នុងចំណោមសត្វលោកទាំងឡាយ ។ កម្មពន្យល់ថា ហេតុអ្វីមនុស្សខ្លះមានសំណាងខ្ពស់ ចំណែកមនុស្សខ្លះទៀតវិញ មានភ័ព្វសំណាងតិច, អ្នកខ្លះមានសេចក្តីសុខច្រើន ឯអ្នកផ្សេងទៀត មានសេចក្តីសុខតិច ។ ព្រះពុទ្ធទ្រង់មានបន្ទូលដោយជាក់លាក់ថា កម្មបែងចែកអោយមានភាពផ្សេងៗគ្នា រវាងសត្វលោកទាំងឡាយ ។ លោកអ្នកអាចរំលឹកឡើងវិញផងដែរអំពីការយល់ដឹង ថាតើកម្មប៉ះពាល់ដល់កំណើតរបស់សត្វលោកទាំងឡាយនៅក្នុងកាលៈទេសៈប្រកបដោយសេចក្តីសុខ ឬប្រកបដោយសេចក្តីទុក្ខយ៉ាងណា, ហើយជាបដិលោមទៅវិញ វិវត្តពីស្ថានភាពប្រកបដោយទុក្ខទៅកាន់ស្ថានភាពប្រកបដោយសុខ ក៏ជាលទ្ធផលនៃកម្មរបស់គេយ៉ាងណា ៎ នេះគឺជាផ្នែកនៃបទពិសោធន៍របស់ព្រះពុទ្ធនៅក្នុងរាត្រីនៃការត្រាស់ដឹងរបស់ព្រះអង្គ ។ គឺកម្មដែលជាអ្នកបែងចែកស្ថានភាពទាំងឡាយដល់សត្វលោក ដើម្បីរស់នៅ ។

ក្រោយពីបាននិយាយយ៉ាងច្រើនអំពីដំណើរប្រព្រឹត្តទៅនៃកម្ម, ចូរយើងមើលអោយបានដិតដល់ជាងនេះទៀត នូវអ្វីដែលជាកម្ម។ ចូរយើងកំណត់និយមន័យអោយកម្ម ។ ប្រហែលជាយើងអាចកំណត់ន័យអោយកម្មបានប្រសើរ ដោយសំរេចជាដំបូង នូវអ្វីដែលមិនមែនជាកម្មសិន ។ ជាញឹកញយណាស់ វាមានករណីដែលយើងឃើញមនុស្សយល់ខុសនូវគំនិតអំពីកម្ម ។ នេះគឺជាការណ៍ពិតជាក់ស្តែង នៅក្នុងការប្រើពាក្យធម្មតារាល់ថ្ងៃ ។ យើងឃើញមនុស្សខ្លះនិយាយថា គេមិនអាចផ្លាស់ប្តូរស្ថានភាពរបស់គេបានទេ ដោយសារកម្មរបស់គេ ។ ក្នុងករណីកម្មក្លាយជាគ្រោះថ្នាក់មុយ៉ាងដែលគេខំរត់គេចអោយរួច កម្មប្រែក្លាយដូចជាព្រេងវាសនា ឬព្រហ្ម-លិខិត ។ នេះមិនមែនជាគំនិតយល់ដឹងត្រឹមត្រូវអំពីកម្មទេ ។ វាអាចជាមានការយល់ច្រឡំអំពីកម្មនេះ ដោយសារមានគំនិតប្រជាប្រិយ៍ ស្តីពីសំណាង និងព្រេងវាសនាទៅវិញ ។ ចំពោះហេតុផលនេះ, វាអាចមានមតិស្តីពីកម្ម ត្រូវបានគ្របដណ្តប់នៅក្នុងគំនិតមនុស្សដោយការយល់ដឹងអំពីបុព្វវាសនា ។ កម្មមិនមែនជា វាសនា ឬបុព្វ-វាសនាទេ ។

ប្រសិនបើកម្មមិនមែនជាវាសនា ឬជាបុព្វវាសនាទេ, ដូច្នោះ តើកម្មជាអ្វី ? ចូរយើងពិនិត្យមើលពាក្យនេះផ្ទាល់ ។ កម្ម មានន័យថា « អំពើ », មានន័យថា « ធ្វើ » ។ ភ្លាមនេះ យើងមានសេចក្តីចង្អុលប្រាប់ថា ន័យពិតរបស់កម្មមិនមែនជាន័យវាសនាទេ ពិព្រោះកម្ម គឺជា *អំពើ* ។ វាមាន *ថាមភាព* (dynamic) ។ ហើយវាលើសជាង*អំពើធម្មតា* ទៅទៀត ពិព្រោះកម្មមិនមែនជាអំពើមេកានិក ( mé-chanical action ) ទេ ។ កម្មមិនមែនជាអំពើឥតមនសិការ ឬអចេតនាទេ ។ កម្មគឺជាអំពើប្រកបដោយបំណង, មានមនសិការ, គិតទុកមុន, មានឆន្ទៈ ។ តើអំពើប្រកបដោយបំណង, ប្រកបដោយឆន្ទៈនេះតាក់តែង ឬកំណត់ស្ថានភាពរបស់យើងយ៉ាងណា ? នេះក៏ពិព្រោះតែអំពើនីមួយៗ ត្រូវមានប្រតិកម្ម, មានផល ។ សច្ចភាព

នេះ ត្រូវបានគេពន្យល់តាមរយៈ *រូបសកលលោកធាតុ* ( the physical Universe ) ដោយអ្នកប្រាជ្ញខាងរូបវិទ្យាដ៏ជំនាញម្នាក់ គឺលោក នូវតុន ( Newton ) ។ លោកបានចងក្រងជាក្រឹត្យក្រមដែលចែងថា អំពើនីមួយៗត្រូវមានប្រតិកម្មទប់តបវិញ ។ នៅក្នុងវិស័យសីលធម៌នៃអំពើមានមនសិការ, យើងក៏មានចំណែកដូចគ្នាចំពោះក្រឹត្យក្រមរូបវិជ្ជា ស្ដីពីអំពើ (កម្ម) និងប្រតិកម្មដែរ ពោលគឺ ក្រឹត្យក្រមដែលចែងថា រាល់អំពើប្រកបដោយបំណង និងឆន្ទៈ ត្រូវតែមានផលរបស់វា ។ ព្រោះហេតុនេះហើយ ទើបមានពេលខ្លះ យើងនិយាយពីកម្ម - វិបាក កម្មចេតសិក និងចំហាយទុំជោររបស់វា ឬនិយាយពីកម្ម - ផល, កម្មចេតសិក និងផល ( ផ្លែ ) របស់វា ។ ពេលណាយើងនិយាយពីអំពើប្រកបដោយបំណង រួមជាមួយនឹងចំហាយឬផល ពេលនោះគឺយើងនិយាយអំពីក្រឹត្យក្រមនៃកម្ម ។ ក្នុងន័យជាគ្រឹះបំផុត, ក្រឹត្យក្រមនៃកម្មនៅក្នុងវិស័យសីលធម៌ប្រៀនប្រដៅថា អំពើ ឬកម្មដូចគ្នា នឹងនាំមកនូវលទ្ធផលដូចគ្នា ។ ចូរយើងលើកយកឧទាហរណ៍មួយមកបញ្ជាក់ ។ ប្រសិនបើយើងបណ្ដុះគ្រាប់ស្វាយ, កូនឈើដែលដុះចេញមក នឹងជាដើមស្វាយ ហើយនៅពេលណាមួយ វានឹងផ្ដល់ចេញជាផ្លែស្វាយ ។ ជាជំនួសស្វាយវិញ ប្រសិនបើយើងបណ្ដុះគ្រាប់ខ្នុរ, កូនឈើដែលនឹងដុះចេញ នឹងជាដើមខ្នុរ ហើយផ្ដល់អោយផ្លែខ្នុរ ។ គេសាបព្រោះពូជបែបណា, គេច្រូតកាត់ផលបែបនោះ ។ អនុលោមទៅតាមអំពើរបស់គេ ដូច្នេះ គេនឹងទទួលផលនោះ ។ ដូចគ្នានេះដែរ ក្នុងក្រឹត្យក្រមនៃកម្ម, ប្រសិនបើយើងធ្វើអំពើកុសលនៅពេលណាមួយ យើងនឹងទទួលបានផលជាកុសល, ហើយបើយើងធ្វើអំពើអកុសលនៅពេលណាមួយ យើងនឹងបានលទ្ធផលអកុសល ពុំខាងប់ខ្លោចផ្សា ។ នេះគឺជាអ្វីដែលយើងចង់សំដៅដល់ កាលណាយើងនិយាយថា ហេតុតែងនាំមកនូវផលដែលដូចគ្នា ឬប្រហែលគ្នាទៅនឹងហេតុ ។ រឿងនេះ យើងនឹងឃើញកាន់តែច្បាស់ កាលណាយើងនិយាយដល់ឧទាហរណ៍ ស្ដីពីអំពើ

កុសល និងអំពើអកុសល ។

យើងអាចយល់បានតាមរយៈសេចក្ដីណែនាំទូទៅនេះ ដែលបង្ហាញថា កម្មអាចចែកចេញជាពីរយ៉ាង - គឺកម្មជាកុសល ឬកុសលកម្ម, និងកម្មជាអកុសល ឬអកុសលកម្ម ។ ដើម្បីកុំអោយយើងច្រឡំ នូវការពណ៌នាអំពីកម្ម, យើងត្រូវពិនិត្យមើលពាក្យដើមសិន ។ ក្នុងករណីនេះ កម្មគឺជាកុសលកម្ម ឬ អកុសលកម្ម, គឺកម្មជាកុសល ឬអកុសល ។ ដើម្បីអោយយើងយល់បាន ថាតើពាក្យទាំងនេះកំពុងត្រូវបានគេប្រើយ៉ាងដូចម្ដេច, ជាការសំខាន់ យើងត្រូវដឹងនូវន័យពិតនៃពាក្យកុសល និងអកុសល ។ កុសល មានន័យថាមានបញ្ញា ឬឈ្លាសវៃ ចំណែកឯអកុសល មានន័យថាឥតបញ្ញា, មិនឈ្លាសវៃ ។ នេះជួយអោយយើងយល់ថា តើពាក្យទាំងនេះកំពុងត្រូវបានគេប្រើយ៉ាងណា, មិនមែនក្នុងន័យល្អ និងអាក្រក់ទេ ប៉ុន្តែ ក្នុងន័យឈ្លាសវៃ និងមិនឈ្លាសវៃ, ក្នុងន័យមានបញ្ញា និងមិនមានបញ្ញា, ក្នុងន័យមានកុសល និងអកុសល ។ ឥឡូវ តើមានកុសលយ៉ាងណា ហើយតើអកុសលយ៉ាងណា ? មានកុសល នៅក្នុងន័យថា អំពើទាំងឡាយនោះមានប្រយោជន៍ដល់ខ្លួនឯងផង ដល់អ្នកដទៃផង, អំពើទាំងឡាយនោះមិនកើតចេញមកពីកាមៈ, ព្យាបាទៈ និងអវិជ្ជាទេ, ប៉ុន្តែចេញមកពីបរិច្ចាគ, ពីមេត្តា និងករុណា, ហើយនិងបញ្ញា ។

គេអាចចោទសួរថា តើគេអាចដឹងដូចម្ដេចបានថា អំពើមួយនេះប្រកបដោយកុសល ឬអកុសល ហើយបង្កើតឡើងនូវសេចក្ដីសុខ ឬសេចក្ដីទុក្ខ ។ ចម្លើយគឺថា ពេលវេលានឹងប្រាប់ ។ ព្រះពុទ្ធអង្គឯងទ្រង់បានឆ្លើយតបសំណួរនេះ ។ ព្រះអង្គបានពន្យល់ថា ដរាបណា អំពើអាក្រក់មិនទាន់បានផ្ដល់ផលនៃទុក្ខទេ, ដរាបនោះ មនុស្សកម្លៅនៅតែគិតថា អំពើនោះល្អ ។ ប៉ុន្តែ ពេលណាអំពើអាក្រក់នោះហុចផលនៃទុក្ខរបស់ខ្លួនអោយ គឺពេលនោះហើយដែលមនុស្សកម្លៅនោះដឹងថាអំពើនោះអាក្រក់ ។ ដូចគ្នានេះដែរ កាលណាអំពើមិនទាន់ហុចផលនៃ

សេចក្តីសុខអោយទេ, មនុស្សល្អអាចគិតថា អំពើនោះអាក្រក់ ។ ពេលណា អំពើល្អនោះហុចផលនៃសេចក្តីសុខអោយ, ពេលនោះហើយទើបគេដឹងថា អំពើនោះល្អ ។ ដូច្នេះ គេត្រូវការវិនិច្ឆ័យអំពើល្អ និងអំពើអាក្រក់ ចេញពីចំណុចទស្សនៈនៃផលក្នុងពេលវែង ។ និយាយអោយងាយយល់ គឺអំពើល្អ ផ្តល់លទ្ធផលជាសេចក្តីសុខសំរាប់ខ្លួនយើងផង សំរាប់អ្នកដទៃផង ។ ចំណែកអំពើអាក្រក់ មានលទ្ធផលផ្ទុយ, គឺផ្តល់លទ្ធផលជាទុក្ខដល់ខ្លួនឯងផង ដល់អ្នកដទៃផង ។

និយាយអោយចំទៅ, អំពើអាក្រក់ដែលត្រូវចៀសវាង គឺទាក់ទងទៅនឹងទ្វារបីយ៉ាង ឬមធ្យោបាយនៃអំពើបីយ៉ាង ។ នោះគឺ កាយ វាចា និងចិត្ត ។ មានអំពើអាក្រក់ដោយកាយបីយ៉ាង, អំពើអាក្រក់ដោយវាចាបួនយ៉ាង និងអំពើអាក្រក់ដោយចិត្តបីយ៉ាងដែលគេត្រូវចៀសវាង ។ អំពើអាក្រក់ដោយកាយបីយ៉ាងដែលត្រូវចៀសវាង គឺ ការសម្លាប់សត្វ, ការលួច និងការប្រព្រឹត្តខុសឆ្គងក្នុងការសេពកាម ។ អំពើអាក្រក់ដោយវាចាបួនយ៉ាងដែលត្រូវចៀសវាង គឺ ការនិយាយកុហក, ការនិយាយពាក្យមួលបង្កាច់, ការនិយាយពាក្យទ្រគោះបោះបោក, និងការនិយាយពាក្យខ្សិបខ្សៀវ អុជអាល ។ អំពើអាក្រក់តាមផ្លូវចិត្តបីយ៉ាងដែលត្រូវចៀសវាង គឺលោភៈ, ទោសៈ និងមោហៈ ។ ដោយចៀសវាងបានអំពើអាក្រក់ទាំងដប់យ៉ាងនេះ យើងនឹងចៀសវាងបាននូវផលវិបាកទាំងឡាយរបស់វា ។ អំពើអាក្រក់ មានសេចក្តីទុក្ខជាផល ។ ផលនៃអំពើអាក្រក់ អាចមានទ្រង់ទ្រាយផ្សេងៗ ។ ផលវិបាកនៃអំពើអាក្រក់ គឺមានការកើតជាថ្មីនៅក្នុងឋានក្រោម, នៅក្នុងទុគ្គតិភព - នរក ប្រេត និងសត្វតិរច្ឆាន (animals) ។ ប្រសិនបើអំពើអាក្រក់ទាំងនោះ មិនទាន់គ្រប់គ្រាន់នឹងផ្តល់ផលអោយកើតជាថ្មីនៅក្នុងឋានក្រោមទាំងនោះទេ, វានឹងផ្តល់ផលអោយជាទុក្ខទោមនស្សនៅក្នុងជាតិនេះ ក្នុងឋានៈជាមនុស្ស ។ ក្នុងទីនេះ យើងអាចឃើញគោលការណ៍នៃហេតុមួយដំណើរការដោយបង្កើតចេញជាផលដូចគ្នា ។ ឧទាហរណ៍

ការសម្លាប់ជីវិតជាទម្លាប់ ដែលកើតចេញពីព្យាបាទៈ និងកោធៈ និងដែលចេញជាលទ្ធផល គឺការផ្ដាច់ជីវិតសត្វដទៃ នឹងនាំអោយកើតជាថ្មី នៅក្នុងឋាននរក ។ នៅទីនេះ បទពិសោធន៍របស់គេ គឺស្អប់ស្អល់ទៅដោយកោធៈ និងព្យាបាទៈ ហើយនៅទីនោះ គេអាចត្រូវគេសម្លាប់ហើយសម្លាប់ទៀត មិនចេះចប់ ។ ប្រសិនបើការសម្លាប់ មិនទាន់គ្រប់គ្រាន់ក្លាយជាទម្លាប់ ឬធ្ងន់ធ្ងរហួតដល់ផ្ដល់កំណើតជាថ្មី នៅក្នុងឋាននរកទេ ការសម្លាប់នឹងហុចផលអោយជាជីវិតខ្លី ក្នុងឋានៈខ្លួនជាមនុស្ស, ជាការព្រាត់ប្រាស ពីមនុស្សទាំងឡាយជាទីស្រឡាញ់, ជាភ័យ ឬជាមនុស្សល្ងីល្ងើ ។ ក្នុងទីនេះដែរ យើងអាចមើលឃើញថា តើផលដូចគ្នាទៅនឹងហេតុយ៉ាងណា ។ ការសម្លាប់ បង្រួញអោយខ្លីនូវជីវិតនៃអ្នកដទៃ, ដកហូតពីអ្នកដទៃ នូវបុគ្គលទាំងឡាយជាទីស្រឡាញ់របស់គេ, . ល . ដោយហេតុនេះ ប្រសិនបើយើងសម្លាប់ យើងនឹងប្រឈម មុខទទួលនូវបទពិសោធន៍ នៃផលវិបាកទាំងឡាយនោះ ។ ដូចគ្នានេះដែរ ការលួច ដែលកើតចេញពីសេចក្ដីសៅហ្មងនៃកាមៈ ( ឬកាមកិលេស ) អាចនាំអោយកើតជាថ្មីជាប្រេត ស្រេក ឃ្លាន ដែលនៅក្នុងកំណើតនេះ គេខ្វះខាតទាំងស្រុងនូវវត្ថុដែលត្រូវការ ។ ប្រសិនបើវាមិនផ្ដល់ផលអោយកើតជាថ្មីទៀត ជាប្រេតបិសាចទេ, វានឹងផ្ដល់លទ្ធផលអោយជាមនុស្សក្រខ្សត់, ពឹងផ្អែកតែលើអ្នកដទៃដើម្បីរស់, . ល . ។ ការប្រព្រឹត្តខុសក្នុងការសេពកាម បង្កើតចេញនូវលទ្ធផលជាសេចក្ដីទុក្ខព្រួយរវាងប្ដី . ប្រពន្ធ ឬជាអាពាហ៍ពិពាហ៍ខ្វះសុភមង្គល ។

ចំណែកឯ អំពើអាក្រក់ បង្កើតអោយមានលទ្ធផលអាក្រក់ . គឺទុក្ខ, អំពើល្អ បង្កើតចេញជាលទ្ធផលល្អ . គឺសុខ ។ គេអាចបកស្រាយអំពើល្អជាពីរបែប ។ គេអាចគ្រាន់តែចាត់ទុកអំពើល្អ ជាការចៀសវាងអំពើអាក្រក់, ចៀសវាងការសម្លាប់, ការលួច, ការប្រព្រឹត្តខុសក្នុងផ្លូវភេទ និងបាបធម៌ឯទៀត ។ ឬគេអាចនិយាយអំពីអំពើល្អក្នុងពាក្យពេចន៍ជាវិជ្ជមាន ។ ក្នុងទីនេះ គេអាចយោងទៅរកបញ្ជី

អំពើល្អ ដែលរួមមាន ៖ សប្បុរសធម៌, ចរិយាល្អ, សមាធិ, ការគោរពបូជា, ការបំរើ, ការផ្ទេរបុណ្យកុសល, ការសប្បាយរីករាយចំពោះបុណ្យកុសលអ្នកដទៃ, ការស្តាប់ព្រះធម៌, ការបង្រៀនព្រះធម៌, និងការកែប្រែតម្រង់ទស្សនៈផ្ទាល់របស់ខ្លួន ។ ដូចគ្នានឹងអំពើអកុសលបង្កើតអោយមានទុក្ខ, អំពើកុសលទាំងឡាយនេះបង្កើតឡើងនូវអត្ថប្រយោជន៍ ។ ក្នុងទីនេះ ផលគឺដូចគ្នានឹងអំពើ ( កម្ម ) ដែរ ។ ជាឧទាហរណ៍, សប្បុរសធម៌នាំអោយកើតមានទ្រព្យសម្បត្តិ ។ ស្តាប់ព្រះធម៌នាំអោយកើតបញ្ញា ។ អំពើ ( កម្ម ) កុសល ផ្តល់ជាវិបាករបស់វា នូវផលល្អ ដូចគ្នានឹងអំពើ ( កម្ម ) អកុសល ផ្តល់ផលអាក្រក់ប្រហាក់ប្រហែលគ្នា ។

កម្មៈ, ទោះជាកុសលក្តី ជាអកុសលក្តី, តែងប្រែប្រួលទៅតាមលក្ខខ័ណ្ឌទាំងឡាយ ដែលនៅក្នុងនោះ អំពើទាំងឡាយត្រូវបានប្រព្រឹត្ត។ និយាយម្យ៉ាងទៀត, អំពើណាមួយ ជាកុសល ឬ អកុសល អាចពានផលវិបាកខ្លាំង ឬខ្សោយ ដោយផ្អែកលើលក្ខខ័ណ្ឌទាំងឡាយ ដែលនៅក្នុងនោះ អំពើនោះៗ ត្រូវបានធ្វើ ។ លក្ខខ័ណ្ឌទាំងឡាយដែលកំណត់ទម្ងន់ ឬកម្លាំងនៃកម្ម អាចចែកចេញទៅជាលក្ខខ័ណ្ឌទាំងឡាយនោះ ដែលទាក់ទងនឹងប្រធាន - គឺអ្នកធ្វើអំពើ, និងលក្ខខ័ណ្ឌទាំងឡាយនោះ ដែលទាក់ទងនឹងកម្មវត្ថុ - តួអង្គ ( the being ) ដែលរងអំពើ ។ ដូច្នេះ លក្ខខ័ណ្ឌទាំងឡាយដែលកំណត់ទម្ងន់នៃកម្ម អនុវត្តទៅលើប្រធាន និងកម្មវត្ថុ ។ និយាយអោយចំទៅ, ប្រសិនបើយើងលើកយកឧទាហរណ៍ ស្តីពីការសម្លាប់ ( បាណាតិបាត ), ដើម្បីអោយអំពើនៃការសម្លាប់ មានអានុភាពរបស់វាគ្រប់គ្រាន់ និងពេញលេញ, ត្រូវមានលក្ខខ័ណ្ឌទាំងឡាយ ( ឬអង្គ ) ប្រាំយ៉ាង - សត្វមានជីវិត, ការដឹងថាសត្វមានជីវិតកំពុងរស់រាន, មានព្យាយាមសម្លាប់សត្វមានជីវិត ការស្លាប់នៃសត្វមានជីវិតដោយសារការព្យាយាមនោះ ។ ក្នុងទីនេះដែរ យើងអាចមើលឃើញលក្ខខ័ណ្ឌទាំងឡាយជាអត្តានុម័តិ និងជាបរានុម័តិ ។ លក្ខខ័ណ្ឌអត្តានុម័តិ គឺការដឹងច្បាស់ថា

សត្វមានជីវិត, ការប៉ុនប៉ងសម្លាប់ និងអំពើសម្លាប់ ។ លក្ខខ័ណ្ឌបរានុម័តិ គឺវត្តមាននៃសត្វមានជីវិត និងការស្លាប់នៃសត្វមានជីវិត ក៏ជាផលវិបាកនៃការប៉ុនប៉ងនោះ ។ ដូចគ្នានេះដែរ, មានលក្ខខ័ណ្ឌទាំងឡាយប្រាំយ៉ាង ដែលកែប្រែទម្ងន់នៃកម្ម ហើយលក្ខខ័ណ្ឌទាំងប្រាំយ៉ាងនោះគឺ អំពើដែលមានព្យាយាមស្វិតស្វាញដដែលៗ អំពើកើតឡើងដោយមានបំណង និងការប្តេជ្ញាចិត្តមុតមាំ ; អំពើធ្វើហើយគ្មានវិប្បដិសារី ; អំពើប្រព្រឹត្តទៅលើបុគ្គលទាំងឡាយមានគុណធម៌ខ្ពង់ខ្ពស់អស្ចារ្យ, និងអំពើប្រព្រឹត្តទៅលើបុគ្គលទាំងឡាយដែលបានផ្តល់គុណប្រយោជន៍ដល់ខ្លួន ( អ្នកធ្វើ ) ក្នុងអតីតកាល ។ ក្នុងទីនេះដែរ ក៏មានលក្ខខ័ណ្ឌអត្តានុម័តិ និងបរានុម័តិ ។ លក្ខខ័ណ្ឌអត្តានុម័តិ គឺអំពើមានព្យាយាមស្វិតស្វាញ, អំពើធ្វើឡើងដោយមានបំណង និងអំពើធ្វើឡើងហើយគ្មានវិប្បដិសារី ។ ប្រសិនបើបុគ្គលធ្វើអំពើអកុសលដដែលៗ ដោយមានបំណង ( ដោយចេតនា ) ហើយគ្មានការសោកស្តាយក្រោយ ( វិប្បដិសារី ), ទម្ងន់នៃអំពើនឹងកើនឡើងខ្លាំង ។ លក្ខខ័ណ្ឌបរានុម័តិ គឺគុណសម្បត្តិរបស់កម្មវត្ថុដែលរងអំពើ និងចរិតនៃទំនាក់ទំនង ។ និយាយម្យ៉ាងទៀត, ប្រសិនបើបុគ្គលធ្វើអំពើជាកុសល ឬអកុសល ចំពោះសត្វមានជីវិតទាំងឡាយដែលមានគុណធម៌ ដ៏អស្ចារ្យដូចជាព្រះអរហន្ត ឬព្រះពុទ្ធ, អំពើជាកុសល ឬអកុសល ធ្វើឡើងហើយ នឹងមានទម្ងន់ធំធេងណាស់ ។ នៅទីអវសាន, អានុភាពនៃអំពើជាកុសល ឬជាអកុសល ធ្វើឡើងចំពោះបុគ្គលទាំងឡាយនោះ ដែលបានផ្តល់គុណប្រយោជន៍ដល់ខ្លួន ( អ្នកធ្វើអំពើ ) នៅក្នុងអតីតកាល, ដូចជា មាតាបិតា, គ្រូអាចារ្យ និងញាតិមិត្រទាំងឡាយ, អានុភាពនៃអំពើនោះ នឹងមានអានុភាពធំធេងណាស់ ។ លក្ខខ័ណ្ឌទាំងឡាយជាអត្តានុម័តិ និងបរានុម័តិរួមគ្នា កំណត់នូវទម្ងន់នៃកម្ម ។ នេះមានសារសំខាន់ណាស់ ពីព្រោះការយល់ដឹងនេះ នឹងជួយយើងអោយយល់ដឹងថា កម្មមិនមែនគ្រាន់តែជាបញ្ហាខ្មៅ និងស, ឬល្អ និងអាក្រក់ ដ៏សាមញ្ញនោះទេ ។ កម្ម គឺជាអំពើសីលធម៌ និង

ជាការទទួលខុសត្រូវសីលធម៌ ។ ប៉ុន្តែ ការប្រព្រឹត្តទៅនៃក្រឹត្យក្រមរបស់កម្ម មាន ចរិតកែតម្រូវ និងមានតុល្យភាពយ៉ាងល្អិតល្អន់ពេកណាស់ រហូតដល់ផលស៊ីគ្នានឹង ហេតុ, រហូតដល់ការគិតគូរពីលក្ខខ័ណ្ឌអត្តានុម័តិ និងបរានុម័តិ ដែលកំណត់ចរិត នៃអំពើ ។ នេះធ្វើអោយប្រាកដថា ផលនៃអំពើស្មើគ្នា និងដូចគ្នាទៅនឹងចរិតនៃ ហេតុ ។

ផលទាំងឡាយនៃកម្ម អាចកើតប្រាកដឡើងនៅក្នុងរយៈពេលខ្លី ឬក្នុង រយៈពេលវែង ។ តាមទម្លាប់ យើងចែកកម្មជាបីប្រភេទ ទាក់ទងនឹងទំហំពេលវេលា ដែលតម្រូវអោយផលនៃអំពើទាំងនោះ កើតមានប្រាកដឡើង ។ កម្មអាចផ្តល់ផល របស់ខ្លួនអោយ ឬមួយ នៅក្នុងជាតិនេះ ឬមួយ នៅក្នុងជាតិក្រោយបន្ទាប់ ឬមួយ ក្រោយជាតិជាច្រើនតែប៉ុណ្ណោះ ។ កាលណា កម្មអោយផលនៅក្នុងជាតិនេះ, យើង អាចមើលឃើញផ្លែផ្កានៃកម្ម នៅក្នុងរង្វង់ពេលវេលាមួយខ្លីតាមការប្រៀបធៀប ។ ប្រភេទនៃកម្មនេះ យើងងាយនឹងផ្ទៀងផ្ទាត់បាន ។ ឧទាហរណ៍, កាលណា អ្នកណា មួយ បណ្តែតបណ្តោយខ្លួនក្នុងការសប្បាយដ៏មានគ្រោះថ្នាក់ ដូចជា ផឹកស្រា ឬសេព គ្រឿងញៀនស្រវឹង, កាលណា អ្នកណាមួយចាប់ផ្តើមលួចទ្រព្យគេ ដើម្បីគាំទ្រ ទម្លាប់ដ៏មានគ្រោះថ្នាក់របស់ខ្លួន ; ផលទាំងឡាយនឹងឃើញជាក់ស្តែងនៅក្នុងរយៈ ពេលមួយខ្លី ។ ផលទាំងនោះ នឹងឃើញមានប្រាកដក្នុងការបាត់បង់អាជីព, និងមិត្ត-ភាព, បាត់បង់សុខភាព និងអ្វីៗដទៃទៀត ។ យើងមិនអាចមើលឃើញផលនៃកម្ម រយៈពេលវែងបានទេ, ប៉ុន្តែ ព្រះពុទ្ធ និងសាវ័កសំខាន់ៗរបស់ព្រះអង្គ ដែលបាន អភិវឌ្ឍចិត្តរបស់លោករួចហើយ អាចនឹងមើលឃើញដោយផ្ទាល់ នូវផលរយៈពេល វែងទាំងឡាយបាន ។ ជាឧទាហរណ៍, កាលព្រះមោគ្គល្លាន ត្រូវពួកចោរវាយសំពង អោយស្លុតត, ព្រះពុទ្ធទ្រង់មានពុទ្ធដីកាប្រាប់ថា ព្រឹត្តិការណ៍នេះ គឺជាផលនៃអំពើ មួយដែលមោគ្គល្លានបានប្រព្រឹត្តក្នុងជាតិមុន នៅពេលដែលលោកបាននាំមាតាបិតា

ចាស់ជរារបស់លោកចូលទៅក្នុងព្រៃ ហើយបានវាយសំពងលោកទាំងពីរនោះរហូតដល់ស្លាប់, រួចហើយលោកបានរៀបរាប់ប្រាប់គេថា ឪពុក-ម្តាយរបស់លោកត្រូវពួកចោរសម្លាប់ ។ ផលនៃអំពើអកុសលនោះបានប្រព្រឹត្ត ហើយកាលពីច្រើនជាតិពីមុន ទើបតែផ្តល់ផលអោយក្នុងជាតិចុងក្រោយបង្អស់របស់លោកប៉ុណ្ណោះ ។ នៅពេលមរណភាព, យើងត្រូវចាកចោលអ្វីៗទាំងអស់នៅខាងក្រោយ - ទ្រព្យសម្បត្តិរបស់យើង និងបុគ្គលជាទីស្រឡាញ់របស់យើង, ប៉ុន្តែ កម្មរបស់យើងរមែងទៅតាមយើង បីដូចជាស្រមោលអន្ទោលតាមប្រាណ ។ ព្រះពុទ្ធទ្រង់បានត្រាស់ថា គ្មានកន្លែងណាមួយនៅលើផែនដីនេះ ឬនៅក្នុងទេវលោកអាចអោយបុគ្គលគេចផុតពីកម្មរបស់គេបានឡើយ ។ ដូច្នេះ កាលណាលក្ខខ័ណ្ឌទាំងឡាយគ្រប់គ្រាន់ហើយ, ដោយផ្អែកលើចិត្ត និងកាយ, ផលនៃកម្ម រមែងកើតចេញប្រាកដឡើង បីដូចផ្លែស្វាយ ដោយផ្អែកលើលក្ខខ័ណ្ឌមួយចំនួនណានោះ រមែងកើតចេញប្រាកដឡើងនៅលើដើមស្វាយ ។ យើងអាចឃើញថា សូម្បីតែនៅក្នុងពិភពនៃធម្មជាតិ ផលទាំងឡាយខ្លះត្រូវការពេលវែងជាងផលទាំងឡាយឯទៀត ដើម្បីលេចខ្លួនឡើង ។ ឧទាហរណ៍ ប្រសិនបើយើងដាំកូនល្ហុង, យើងនឹងទទួលបានផលក្នុងរយៈពេលខ្លីជាងយើងដាំកូនធូរេន ។ ដូចគ្នានេះដែរ ផលនៃកម្មចេញប្រាកដឡើង ឬមួយនៅក្នុងរយៈពេលខ្លី ឬមួយក្នុងរយៈពេលវែង ។

ក្រៅពីប្រភេទនៃកម្មទាំងពីរគឺ កម្មជាអកុសល និងកម្មជាកុសល, យើងគប្បីនិយាយអំពីអព្យាកតកម្ម ឬនិប្ផលកម្ម (ineffective kamma) ។ អព្យាកត-កម្ម គឺជាកម្មដែលគ្មានវិបាកខាងសីលធម៌ ឬមួយ ពីព្រោះចរិតផ្ទាល់នៃអំពើមិនមានវិបាកខាងសីលធម៌ទេ, ឬមួយ ពីព្រោះអំពើនោះប្រព្រឹត្តឡើងដោយអចេតនា ឬ ឥតបំណង ។ ឧទាហរណ៍, ពេលដេកលក់, ពេលដើរ, ពេលដកដង្ហើម, ពេលបរិភោគ, ពេលធ្វើហត្ថកម្ម, - ល -, នៅក្នុងអំពើទាំងអស់នេះ មិនមានវិបាកខាងសីលធម៌

( សីលវិបាក ) ទេ ។ ដូចគ្នានេះដែរ, អចេតនាកម្ម គឺជា និប្ផលកម្ម ( កម្មមិនអោយផល ) ។ និយាយម្យ៉ាងទៀតថា ប្រសិនបើគេដើរជាន់លើសត្វល្អិតមួយដោយចៃដន្យ, ដោយមិនដឹងថាសត្វល្អិតនោះនៅទីហ្នឹង, អំពើនេះកត្តិជាអព្យាកតកម្មដែរ ពីព្រោះ គេគ្មានចេតនា . ធាតុប្រកបដោយចេតនា មិនមាននៅក្នុងទីនេះទេ ។

អត្ថប្រយោជន៍ នៃការយល់ដឹងនូវក្រឹត្យក្រមនៃកម្ម គឺថា ការយល់ដឹងនេះ បន្ថយទឹកចិត្ត ឬខាខាំងបុគ្គលមិនអោយធ្វើអំពើអកុសល ដែលមានតែសេចក្ដីទុក្ខជាផ្លែផ្ការបស់វា ។ ពេលណាយើងយល់ដឹងថា នៅក្នុងជីវិតផ្ទាល់របស់យើង រាល់អំពើ តែងមានប្រតិកម្មដូចគ្នា និងស្មើគ្នា, ពេលណាយើងដឹងថា យើងតែងទទួលរងនូវផលនៃអំពើនោះ ជាកុសល ឬអកុសល, យើងនឹងវៀរចាកអំពីអាកប្បកិរិយាអកុសល, មិនចង់ទទួលរងនូវផលនៃអំពើអកុសល ។ ដូចគ្នានេះដែរ ការយល់ដឹងថា អំពើកុសលមានសេចក្ដីសុខជាផ្លែផ្កា យើងរមែងបណ្ដុះនូវអំពើកុសលទាំងនោះ ។ ការត្រិះរិះពិចារណាលើក្រឹត្យក្រមនៃកម្ម, នៃអំពើ និងប្រតិកម្ម ក្នុងវិស័យសីលធម៌ ជំរុញអោយយើងបោះបង់អំពើអកុសល ហើយបណ្ដុះបណ្ដាលអំពើជាកុសល ។ យើងនឹងពិនិត្យមើលអោយជិតដល់ថែមទៀតនូវផលនៃកម្មដោយឡែក១ ក្នុងជាតិខាងមុខ ហើយតើកម្មពាក់ពៃង និងកំណត់ចរិតនៃកំណើតថ្មី យ៉ាងណា នៅក្នុងឧទ្ទេសកថារបស់យើង នាសប្ដាហ៍ក្រោយ ៕

***

## IX

## ការកើតទៀត

ថ្ងៃនេះ យើងនឹងបន្តប្រធានបទមួយទៀត ដែលយើងបានចាប់ផ្តើម កាលពីពីរសប្តាហ៍កន្លងទៅ នៅពេលដែលបាននិយាយដល់ការបង្រៀនអំពីកម្ម ។ យើងនឹងពិចារណាលទ្ធផលនៃកម្ម នៅក្នុងជីវិតបន្ទាប់, និយាយតាមបែបផ្សេងទៀត គឺនៅក្នុងការកើតជាថ្មី ។ ប៉ុន្តែ មុនពេលខ្ញុំចាប់ផ្តើមពិចារណាដោយជាក់លាក់ នូវពុទ្ធវចនៈទាក់ទងនឹងការកើតទៀត ខ្ញុំគិតថា យើងត្រូវការចំណាយពេលបន្តិច លើមតិបញ្ញត្តិ អំពីកំណើតថ្មីទៀតក្នុងន័យទូទៅ ។ នេះក៏ពីព្រោះតែ វាជាមតិបញ្ញត្តិមួយ ដែលមនុស្សជាច្រើនមានការលំបាកយល់, ជាពិសេស កាលពីពីរបីសតវត្សកន្លងទៅ នៅពេលដែលយើងកាន់តែបានក្លាយទៅជាមានលក្ខណសម្បត្តិ ដើម្បីពិចារណានៅក្នុងអ្វីដែលបានចូលទៅជាពាក្យ ( ស័ព្ទ ) វិទ្យាសាស្ត្រ, នៅក្នុងអ្វីដែលមនុស្សភាគច្រើនធ្លាប់តែជឿដោយក្តីល្ងង់ខ្លៅថាជាពាក្យវិទ្យាសាស្ត្រ ។ ការពិចារណានៅក្នុងបែបបទនេះ បានបណ្តាលអោយមនុស្សជាច្រើនបដិសេធគំនិតស្តីពីការកើតទៀតថាជាអ្វីមួយ ដែលផ្សេងទៅរកអប្បិយជំនឿ, ពោលគឺ ជាផ្នែកមួយនៃបែបបទចាស់ហួសសម័យ ដើម្បីយល់ដឹងពិភពលោក ។ ដូច្នេះ ខ្ញុំគិតថា យើងត្រូវការកែកុនតុល្យភាពនេះឡើងវិញ ហើយបង្កើតអោយមានភាពបើកចំហបែបណាមួយចំពោះមតិបញ្ញត្តិ ស្តីពីការកើតទៀតនេះ មុនពេលយើងសិក្សាដោយម៉ត់ចត់ នូវពុទ្ធវចនៈស្តីពីការកើតទៀត ឬ កំណើតថ្មីទៀត ។

មានវិធីសិក្សាមួយចំនួន ដែលយើងអាចលើកយកមកសិក្សា នូវអ្វីដែលយើងអាចហៅថា ការពណ៌នាដោយសង្ខេប នូវករណីស្តីពីតថភាពនៃការកើតទៀត ។ ចំណុចមួយដែលយើងអាចប្រកាន់យក គឺការរំលឹកឡើងវិញថា នៅក្នុង

វប្បធម៌សំខាន់ៗ ស្ទើរតែទាំងអស់នៃពិភពលោក, នៅពេលណាមួយនោះ វាបានកើតមានជំនឿយ៉ាងមុតមាំ នៅក្នុងតថភាពនៃការកើតទៀត ។ នេះជាការណ៍ពិតជាក់ស្តែងនៅក្នុងប្រទេសឥណ្ឌា ។ នៅក្នុងប្រទេសនេះ មតិស្តីពីការកើតទៀត ត្រូវបានគេស្រាវជ្រាវឃើញមានតាំងពីសម័យដើមបំផុតនៃអារ្យធម៌ឥណ្ឌា ដែលនៅក្នុងអារ្យធម៌នេះ សាសនាសំខាន់ៗទាំងអស់របស់ឥណ្ឌា, ទោះជាអាទិទេពនិយមក្តី ឬមិនមែនអាទិទេពនិយមក្តី, ទោះជាសាសនាហិណ្ឌូក្តី ឬមិនមែនលទ្ធិហិណ្ឌូក្តី ដូចជាសាសនាជេន ជាដើម គឺសុទ្ធតែជឿក្នុងការណ៍ពិត នៃការកើតជាថ្មី ។ ដូចគ្នានេះដែរ, នៅក្នុងវប្បធម៌ទាំងឡាយផ្សេងទៀត ក៏មានជំនឿក្នុងការកើតទៀត, ដូចមានឧទាហរណ៍ នៅក្នុងពិភពសមុទ្រមេឌីទែរ៉ាណេ, មានភស្តុតាងយ៉ាងច្រើនដែលបញ្ជាក់ថា ជំនឿក្នុងការកើតទៀត ត្រូវបានគេជឿជាទូទៅ មុនពេល និងក្នុងកំឡុងពេលពីរបីសតវត្សដំបូង នៃយុគសម័យរួម ។ ដូច្នេះ ជំនឿក្នុងការកើតទៀត បានក្លាយទៅជាផ្នែកមួយដ៏សំខាន់ នៃមាគ៌ាត្រិះរិះរបស់មនុស្ស អំពីស្ថានភាពរបស់ខ្លួន ។

និយាយដោយឡែក, នៅក្នុងរង្វង់ប្រពៃណីពុទ្ធសាសនា, យើងមានព្រះពុទ្ធជាសាក្សី ស្តីពីបញ្ហានៃការកើតទៀត ។ នៅក្នុងរាត្រីនៃការត្រាស់ដឹងរបស់ព្រះអង្គ, ព្រះពុទ្ធទ្រង់បានសំរេចញាណទាំងបីប្រភេទ, ហើយញាណទីមួយ ក្នុងបណ្តាញាណទាំងបីនោះគឺ ញាណ ( ការត្រាស់ដឹង ) ដ៏ទូលំទូលាយអំពីអតីតជាតិទាំងឡាយរបស់ព្រះអង្គ ( ពាលគឺ *បុព្វេនិវាសានុស្សតិញ្ញាណ* ) ។ ព្រះអង្គទ្រង់អាចរំលឹកឃើញនូវស្ថានភាពទាំងឡាយ, ដែលនៅក្នុងស្ថានភាពទាំងនោះ ព្រះអង្គបានចាប់បដិសន្ធិឡើងនៅក្នុងអតីតជាតិ ។ ព្រះអង្គអាចចងចាំថា ព្រះអង្គមាននាមឈ្មោះអ្វីខ្លះ, មានមុខរបរអ្វីខ្លះ . ល . និង . ល . ។ ក្រៅពីមានព្រះពុទ្ធជាសាក្សី, ក៏នៅមានសាវ័កសំខាន់ៗរបស់ព្រះអង្គ ដែលអាចរំលឹកឃើញអតីតជាតិទាំងឡាយដែរ ។ តួយ៉ាង ព្រះអានន្ទ បានសំរេចញាណសក្តិ រំលឹកឃើញអតីតជាតិរបស់លោកភ្លាម

បន្ទាប់ពីពេលលោកបានបួសរួច ។ ដូចគ្នាដែរ, នៅក្នុងអំឡុងកាលនៃប្រវត្តិរបស់ពុទ្ធសាសនា, ព្រះអរហន្ត, បណ្ឌិត និងអ្នកធ្វើសមាធិ អាចមានសមត្ថភាពរំលឹកឡើងវិញនូវអតីតជាតិរបស់លោកបាន ។

ប៉ុន្តែថា, ទទ្បីករណ៍ទាំងពីរនេះ ពុំមានទទ្បីករណ៍ណាមួយ គាំទ្រការកើតទៀត ត្រូវបានគេសង្ឃឹមថាអាចបញ្ចុះបញ្ចូលអោយគេជឿបានទាំងស្រុងនោះឡើយ នៅក្នុងបរិដ្ឋានវិទ្យាសាស្ត្រ និងវិចារណកម្ម ។ ដូចនេះ ប្រហែលយើងត្រូវការក្រឡេកមើលអោយជិតដល់បន្តិចនូវបញ្ហានេះ, ហើយក្នុងទីនេះ យើងទទួលបាននូវការឧបត្ថម្ភអំពីទិសមួយ ដែលមិនបានគិតទុកមុនសោះ ។ យើងភាគច្រើនអាចដឹងថា នៅក្នុងរយៈពេលម្ភៃឆ្នាំ ឬសាមសិបឆ្នាំកន្លងទៅ មានការខិតខំស្រាវជ្រាវយ៉ាងធំសម្បើមអំពីបញ្ហានៃការកើតទៀត ហើយការស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយចិត្តវិទូ និងបរចិត្តវិទូ(*) ( parapsychologists ) ។ បន្តិចម្តងៗ តាមរយៈការស្រាវជ្រាវនេះ, យើងបានចងក្រងឡើងនូវករណី ដ៏គួរអោយជឿយ៉ាងខ្លាំង ចំពោះការណ៍ពិតនៃការកើតទៀត, ជាករណីមួយដែលបានរីកចំរើនទៅតាមខ្សែបន្ទាត់វិទ្យាសាស្ត្រ ។ មានសៀវភៅជាច្រើនបានបោះពុម្ពផ្សាយ ដែលនៅក្នុងសៀវភៅទាំងនោះ ការស្រាវជ្រាវយ៉ាងល្អិតល្អន់ ត្រូវបានគេនិយាយរៀបរាប់ និងពិភាក្សា ។ អ្នក ប្រាជ្ញម្នាក់ដែលបានខ្នះខ្នែងយ៉ាងខ្លាំងក្នុងវិស័យនេះ ក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ គឺលោកសាស្ត្រាចារ្យ អៀន ស្តេវេនសុន ( Ian Stevenson ) នៃសាកលវិទ្យាល័យវៀរហ្ស៊ីនីញ៉ា, សហរដ្ឋអាមេរិក ។ លោកបានបោះពុម្ពផ្សាយការរកឃើញរបស់លោក ស្តីពីការកើតទៀត ជាងម្ភៃករណី ។ លោក-អ្នកខ្លះ ក្នុងចំណោមយើងនេះ អាចធ្លាប់ឮករណីរបស់ស្ត្រីម្នាក់ ដែលរំលឹកឃើញអតីតជាតិរបស់ខ្លួនបាន ជាងមួយ

(*) អ្នកប្រាជ្ញខាងចិត្តវិជ្ជា ដែលសិក្សាតាមបែបវិទ្យាសាស្ត្រ នូវសមត្ថភាព អាថ៌កំបាំងដែលមនុស្សខ្លះអះអាងថាមានដូចជា ការដឹងនូវអ្វីដែលនឹង កើតមានឡើង ... ។

វយឆ្នាំកន្លងទៅថា នាងមានឈ្មោះ ព្រិឌី មុរហ្វី ( Bridey Murphy ) រស់នៅក្នុងប្រទេសក្រៅ ដែលនាងមិនដែលស្គាល់សោះ នៅក្នុងជីវិតបច្ចុប្បន្ននេះ ។ ខ្ញុំមិននិយាយរៀបរាប់ពីករណីទាំងឡាយដោយឡែកៗ អោយបានល្អិតល្អន់ទេ ពីព្រោះ បើគេជាប់ចិត្តក្នុងភស្តុតាងវិទ្យាសាស្ត្រនេះ ស្តីពីការកើតទៀត គេអាចអានសៀវភៅស្តីពីរឿងនេះ ដោយខ្លួនឯងចុះ ។ ប៉ុន្តែ, ខ្ញុំគិតថា ឥឡូវនេះ យើងកំពុងឋិតនៅត្រង់ចំណុចមួយ ដែលសូម្បីតែអ្នកដែលមានសេចក្តីស្ទាក់ស្ទើរចិត្តបំផុត ក្នុងចំណោមយើងនេះ ក៏ត្រូវតែទទួលយល់ព្រមថា វាមានភស្តុតាងយ៉ាងល្អិតល្អន់ដ៏ច្រើន សំរាប់បញ្ជាក់ពីឥទ្ធភាពនៃការកើតទៀត ។

ប៉ុន្តែ នៅក្នុងការសិក្សាពីករណី ស្តីពីការកើតជាថ្មី, យើងអាចពិនិត្យមើលអោយកាន់តែជិតដល់ថែមទៀត នូវបទពិសោធន៍របស់យើងផ្ទាល់, ហើយនៅក្នុងទីនេះ យើងត្រូវការរំលឹកឡើងវិញ និងពិនិត្យបទពិសោធន៍នោះ តាមគន្លងពុទ្ធសាសនាសុទ្ធសាធ ដើម្បីមើលអោយឃើញថា អត្ថន័យអ្វីខ្លះដែលយើងអាចចម្រាញ់យកចេញពីបទពិសោធន៍របស់យើងផ្ទាល់ ។ យើងទាំងអស់គ្នានៅក្នុងបន្ទប់នេះ មានសមត្ថភាពដោយឡែកៗផ្ទាល់របស់ខ្លួន, មានចំណូលចិត្ត និងគ្មានចំណូលចិត្តផ្ទាល់របស់ខ្លួន, ហើយខ្ញុំគិតថា វាជាការត្រឹមត្រូវដើម្បីចោទសួរ ថាតើអ្វីៗទាំងអស់នេះ ជាលទ្ធផលនៃភាពចៃដន្យ ឬយ៉ាងណា ។ ជាឧទាហរណ៍, មានអ្នកខ្លះ ក្នុងចំណោមគ្នាយើងនេះ ពូកែខាងកីឡាលើសអ្នកឯទៀត, អ្នកខ្លះមានទេពកោសល្យខាងគណិតសាស្ត្រ, អ្នកខ្លះចូលចិត្តហែលទឹក, អ្នកខ្លះផ្សេងទៀតខ្លាចទឹក ។ តើភាពផ្សេងៗគ្នាទាំងអស់នេះ នៅក្នុងសមត្ថភាព និងឥរិយាបថរបស់យើង ជាលទ្ធផលនៃភាពចៃដន្យសុទ្ធសាធឬ ? មានលក្ខណៈពិសេសខ្លះស្ទើរជឿមិនបាន នៅក្នុងចរិតនៃបទពិសោធន៍របស់យើង ។ ខ្ញុំសូមលើកករណីរបស់ខ្ញុំផ្ទាល់ មកនិយាយ ។ ខ្ញុំបានកើតនៅក្នុងគ្រួសារអ្នកកាន់សាសនាកាតូលិករ៉ូម៉ាំង នៅសហរដ្ឋ

អាមេរិក ។ វាគ្មានអ្វីមួយសោះ នៅក្នុងចំណោះជាមូលដ្ឋានពីមុនៗរបស់ខ្ញុំ ដើម្បីបញ្ជាក់ថា នៅអាយុម្ភៃឆ្នាំ ខ្ញុំអាចបានធ្វើដំណើរមកកាន់ប្រទេសឥណ្ឌា, ហើយខ្ញុំនឹងចំណាយពេលដប់បួនឆ្នាំបន្ទាប់មកនៃជីវិតរបស់ខ្ញុំ ភាគច្រើននៅក្នុងទ្វីបអាស៊ី, ហើយខ្ញុំនឹងបានក្លាយជាអ្នកជាប់ជំពាក់យ៉ាងជ្រៅនៅក្នុងការសិក្សាពុទ្ធសាសនា ។

បន្ទាប់មកទៀត, មានស្ថានភាពទាំងឡាយនោះ ដែលនៅក្នុងស្ថានភាពនេះ ជួន កាលយើងមានអារម្មណ៍ដឹងមុនដ៏ខ្លាំងក្លាមួយថា យើងធ្លាប់បានរស់នៅក្នុងកន្លែងពិសេសណាមួយពីពេលមុន, ទោះបីយើងមិនបានឃើញកន្លែងនោះនៅក្នុងជីវិតបច្ចុប្បន្នរបស់យើងក៏ដោយ ។ ឬមួយ ជួនកាលយើងមានអារម្មណ៍ថា យើងធ្លាប់បានស្គាល់មនុស្សណាមួយពីមុន ។ ជួនកាលយើងជួបមនុស្សម្នាក់ ហើយនៅក្នុងរយៈពេលមួយដ៏ខ្លី យើងមានអារម្មណ៍ថា យើងបានស្គាល់មនុស្សនោះយ៉ាងច្បាស់លាស់ ។ ជាជំនួសទៅវិញ ជួ ន កាលយើងបានស្គាល់មនុស្សម្នាក់រាប់ឆ្នាំ ប៉ុន្តែយើងឥតជិតស្និទ្ធជាមួយមនុស្សនោះសោះ ។ បទពិសោធន៍នៃវេទនារម្មណ៍ ( feeling ) ទាំងនេះដែលមានចំពោះទីកន្លែងពីមុន ឬយើងបានស្គាល់មនុស្សណាម្នាក់ពីមុន គឺជាបទពិសោធន៍មានទូទៅ និងជាសាកលពេកណាស់ ទោះជានៅក្នុងវប្បធម៌មួយ ដែលស្ទើរតែមិនស្គាល់អ្វីសោះអំពីការកើតទៀតនោះផង ។ មានឃ្លាពិសេសមួយសំរាប់បញ្ជាក់បទពិសោធន៍នេះ, ពាក្យភាសាបារាំងថា « déja vù » ដែលមានន័យថា « បានឃើញ ឬបានទទួលពិសោធន៍រួចហើយ » ។ បើយើងមិនមែនជាអ្នកគម្ពីរនិយម ( dogmatic ), កាលណាយើងប្លុកចូលគ្នានូវភស្តុតាងទាំងអស់ស្តីពីការកើតទៀត . ជំនឿដ៏ជាប់លាប់ក្នុងការកើតទៀត នៅក្នុងវប្បធម៌ជាច្រើនក្នុងកាលវេលាខុសៗគ្នាជាច្រើន នៅក្នុងប្រវត្តិសាស្ត្រ, សក្ខីភាពផ្ទាល់របស់ព្រះពុទ្ធ, សក្ខីភាពរបស់សាវ័កទាំងឡាយសំខាន់ៗរបស់ព្រះពុទ្ធ, ភស្តុតាងលើកឡើងដោយការស្រាវជ្រាវ អង្កេតវិទ្យាសាស្ត្រ និងការប្រកាសផ្ទាល់ខ្លួនរបស់យើង ដែលយើងធ្លាប់មាន

ពីមុន, នោះយើងត្រូវទទួលស្គាល់ថា យ៉ាងហោចណាស់ ក៏មានលទ្ធភាពល្អមួយ ដែលអះអាងថា កំណើតថ្មីទៀត ឬ ការកើតទៀត គឺជាតថភាពមួយ ។

ក្នុងពុទ្ធសាសនា, កំណើតថ្មីទៀត គឺជាភាគនៃដំណើរផ្លាស់ប្តូរបន្ត ។ តាមពិត យើងមិនមែនគ្រាន់តែកើតឡើងវិញ នៅពេលយើងស្លាប់ហើយនោះទេ ។ យើងកើតហើយកើតទៀតនៅគ្រប់ខណៈ ។ ទស្សនៈនេះទៀត ក៏ដូចពុទ្ធវចនៈដទៃទៀតដ៏ច្រើន គឺងាយស្រួលពិនិត្យណាស់ ដោយយោងទៅរកការប្រៀនប្រដៅរបស់វិទ្យាសាស្ត្រ ។ ជាឧទាហរណ៍, ភាគច្រើននៃកោសិកានៅក្នុងខ្លួនមនុស្សដែលស្លាប់ហើយកើតជំនួសវិញជាច្រើនលើកច្រើនសា នៅក្នុងអំឡុងនៃជីវិតរស់នៅរបស់មនុស្សម្នាក់ៗ ។ សូម្បីតែកោសិកាមួយចំនួនតិចទាំងនោះ ដែលគង់វង្សនៅក្នុងជីវិតទាំងមូលរបស់មនុស្សនោះ ក៏គង់ទទួលរងនូវការប្រែប្រួលផ្ទៃក្នុងជាប្រចាំដែរ ។ នេះគឺជាភាគ ( ផ្នែក ) នៃដំណើរកើត, ស្លាប់, និងកើតឡើងវិញ ។ បើយើងក្រឡេកមើលទៅចិត្តវិញ, យើងឃើញថា សភាពនៃចិត្ត ទុក្ខព្រួយ, សប្បាយរីករាយ,. ល . និង . ល . កំពុងប្រែប្រួលគ្រប់ខណៈ ។ សភាពនៃចិត្តទាំងឡាយនោះ ស្លាប់ទៅហើយជំនួសវិញដោយភាពនៃចិត្តថ្មី ។ ដូច្នេះ ទោះបីយើងពិនិត្យមើលកាយ ឬ មើលចិត្ត, បទពិសោធន៍របស់យើង តែងប្រកបដោយលក្ខណៈ កើត, ស្លាប់ និងកើតឡើងវិញជាបន្តបន្ទាប់ ។

នៅក្នុងពុទ្ធសាសនា, គេប្រៀនប្រដៅថា មានឋាន, ភព ឬ វិសាលភាពនៃជីវិតប្លែកៗពីគ្នា ។ មានសាមសិបមួយភពនៃជីវិតដែលគេបានរាប់, ប៉ុន្តែ សំរាប់គោលបំណងរបស់យើង យើងនឹងប្រើប្រាស់ផែនការមួយយ៉ាងសាមញ្ញ ដែលរៀបរាប់តែប្រាំមួយភពនៃជីវិត ប៉ុណ្ណោះ ។ ជាទូទៅ ភពទាំងប្រាំមួយ អាចចែកចេញជាពីរក្រុម ។ ក្នុងបណ្តាក្រុមទាំងពីរ ក្រុមមួយមានសេចក្តីសុខជាងតាមការប្រៀបធៀប, ឯក្រុមមួយទៀត ជាក្រុមមានទុក្ខវេទនា ។ ក្រុមទីមួយ រួមមានបីភព

ហើយភពទាំងបី១នោះ គឺភពទេព្តា, ភពអសុរ និងភពមនុស្ស ។ ការកើតទៀត នៅក្នុងភពប្រកបដោយសេចក្តីសុខទាំងបីនេះ គឺជាលទ្ធផលនៃកុសលកម្ម ។ ក្រុមទីពីរ រួមមានបីភពដែលគេចាត់ទុកជាភពអភ័ព្វ តាមការប្រៀបធៀប ។ ភពទាំងបីនេះ ជូនកាលគេអោយឈ្មោះថា ទុគ្គតិភព ។ ភពទាំងនោះគឺ ភពតិរច្ឆាន, ភពប្រេត, និងភពនរក ។ ការកើតទៀតនៅក្នុងភពទាំងនេះ ( ទុគ្គតិភព ) គឺជាលទ្ធផលនៃអកុសលកម្ម ។

ចូរយើងពិនិត្យមើលភពទាំងនោះ ម្តងមួយ១ ហើយចាប់ផ្តើមពីភពក្រោមគេបង្អស់ ។ ចូរយើងពិនិត្យមើលភពនរក ( និរយៈ ) ។ មាននរកដោយឡែក១ នៅក្នុងពុទ្ធសាសនា ហើយនរកទាំងនោះ ជាគោលការណ៍ មាននរកក្តៅប្រាំបី និងនរកត្រជាក់ប្រាំបី ។ នៅក្នុងនរក សត្វទាំងឡាយរងការឈឺចាប់ឥតគណនា និងឥតរៀបរាប់ជាពាក្យសំដីបានឡើយ ។ គេតែងនិយាយថា ទុក្ខវេទនាដែលទទួលរងបណ្តាលមកពីបាបកម្ម ត្រូវគេចាក់ដោតដោយលំពែងបីរយក្នុងរយៈពេលមួយថ្ងៃ នៅក្នុងជីវិតនេះ គឺគ្រាន់តែជារយៈពេលមួយចម្រៀកនាទីនៃទុក្ខវេទនា ដែលទទួលរងនៅក្នុងនរកប៉ុណ្ណោះ ។ ហេតុនៃការកើតឡើងវិញនៅក្នុងនរក គឺបណ្តាលមកពីអំពើឃោរឃៅជាទម្លាប់បន្តបន្ទាប់ ការសម្លាប់សត្វជាទម្លាប់, អំពើកោងកាចជាដើម អំពើទាំងឡាយដែលកើតចេញពីការព្យាបាទ ។សត្វទាំងឡាយដែលកើតនៅក្នុងនរកទទួល រងនូវការឈឺចាប់ក្នុងនរក រហូតទាល់តែកម្មជាអកុសលរបស់គេរីងហួតអស់ ។ នេះមានសារសំខាន់ណាស់ ពីព្រោះយើងត្រូវកត់សំគាល់ថា នៅក្នុងពុទ្ធសាសនា គ្មានសត្វណាមួយទទួលរងការផ្តន្ទាទោសជានិរន្តរ៍នោះទេ ។ កាលណាកម្មអកុសលរបស់គេរីងហួតអស់ហើយ, សត្វទាំងឡាយក្នុងនរកត្រូវបានមកកើតជាថ្មី នៅក្នុងភពនៃជីវិតមានភ័ព្វល្អជាង ។

ភពបន្ទាប់ គឺភពប្រេត ។ សត្វទាំងឡាយនៅក្នុងភពនេះទ ទួលរងជា

ពិសេសនូវការស្រេកឃ្លាន និងការក្តៅក្រហាយ និងត្រជាក់ញាក់ញ័រ ។ សត្វទាំងនោះមិនមានអ្វីសោះ ដែលជាវត្ថុបំបាត់ការស្រេកឃ្លានរបស់គេ ។ គេនិយាយថា កាលណាពួកប្រេតស្រមៃឃើញភ្នំបាយ ឬទន្លេ ស្ទឹង ទឹកសាប, ហើយស្ទុះរត់សំដៅទៅរកការស្រមៃឃើញនោះ, ពួកគេតែងជួបប្រទះភ្នំបាយនោះ ជាគំនរគ្រួសប៉ុណ្ណោះ, ឯស្ទឹង-ទន្លេ ទឹកសាប គឺជាចម្រៀកផ្ទាំងថ្មពណ៌ ប៉ុណ្ណោះ ។ ដូចគ្នានេះដែរ, គេនិយាយថា នៅក្នុងរដូវក្តៅ សូម្បីតែព្រះចន្ទក៏ក្តៅដែរ, ចំណែកឯនៅក្នុងរដូវត្រជាក់វិញ សូម្បីតែព្រះអាទិត្យក៏ត្រជាក់ដែរ ចំពោះសត្វទាំងនោះ ។ ហេតុចម្បងបំផុតនាំអោយមកកើតជាថ្មីក្នុងកំណើតប្រេត គឺសេចក្តីកំណាញ់, ហើយភាពទុរគតក្រខ្សត់កើតចេញពីសេចក្តីលោភ ។ នៅក្នុងនរក, សត្វទាំងឡាយនៅក្នុងភពនេះ មិនត្រូវបានផ្តន្ទាទោសអោយមានជីវិតក្នុងរូបកាយជាប្រេតស្រេកឃ្លានរហូតនោះទេ, ពិព្រោះតែកាលណាកម្មអកុសលរីងហួតអស់ទៅ, សត្វទាំងឡាយនោះនឹងបានមកកើតជាថ្មីនៅក្នុងភពប្រសើរជាង ។

នៅក្នុងភពបន្ទាប់ ដែលជាភពតិរច្ឆាន, សត្វមានជីវិតទាំងឡាយរងទុក្ខមកពីកាលៈទេសៈអពមង្គលផ្សេងៗ ។ គេរងទុក្ខពីសេចក្តីភ័យខ្លាច និងសេចក្តីឈឺចាប់ ដែលជាលទ្ធផលនៃការសម្លាប់ និងស៊ីគ្នាទៅវិញទៅមកជាប្រចាំ ។ គេរងទុក្ខពីសេចក្តីអន្តរាយ បណ្តាលមកពីមនុស្សដែលសម្លាប់គេធ្វើជាអាហារ, សម្លាប់យកស្បែក ស្នែង ឬខ្នាយ ភ្លុក ។ សូម្បីតែមិនត្រូវបានគេសម្លាប់ក៏ដោយ ក៏សត្វស្រុកទាំងឡាយនោះគង់ត្រូវតែបង្ខំអោយធ្វើការបំរើមនុស្ស និងត្រូវគេបរទៅដោយចាក់នឹងជន្លួញ, កង្វេរ និងវាយដោយខ្សែតី, ទាំងអស់នេះគឺជាប្រភពនៃសេចក្តីទុក្ខ ។ ហេតុដ៏សំខាន់នាំអោយមានកំណើតជាថ្មី ជាសត្វតិរច្ឆានគឺអវិជ្ជា ។ និយាយម្យ៉ាងទៀត ការរត់តាមចំណង់របស់ខ្លួនដូចសត្វពន្លាត់ ដ៏ល្ងិតល្ងង់ ខ្វះសេចក្តីប្រុងប្រយ័ត្ន, ការជាប់ចិត្តតែនឹងការស៊ី, ការដេក និងកាមតណ្ហា, និងការប្រមាទ មិនខិតខំអភិវឌ្ឍន៍ចិត្ត

របស់ខ្លួន ហ្វឹកហាត់បង្កើតគុណធម៌មិជាដើមទេ នោះរមែងនាំអោយគេទៅកើតជាថ្មីក្នុងកំណើតសត្វតិរច្ឆាន ។ ឥឡូវនេះ កាលណាខ្ញុំលើកជាឧទាហរណ៍ថា ការសម្លាប់សត្វជាទម្លាប់ជាហេតុនាំអោយកើតក្នុងនរក ឬថាលោភៈជាហេតុនាំអោយកើតជាថ្មីក្នុងភពប្រេត ឬថាអវិជ្ជាជាហេតុនាំអោយមានកំណើតថ្មីក្នុងភពតិរច្ឆាន, នេះពុំមានន័យថា អំពើប្រកបដោយទោសៈ, លោភៈ ឬមោហៈដ៏ជាក់លាក់ណាមួយ នឹងផ្តល់ផលអោយកើតជាថ្មី ក្នុងចំណោមប្រភេទសត្វសមស្របក្នុងឋាននរក, ក្នុងភពប្រេត ឬភពតិរច្ឆាននោះទេ ។ អ្វីដែលសំដៅដល់នោះ គឺថា វាមានបច្ច័យ ( ទំនាក់ទំនង ) រវាងទោសៈ និងកំណើតជាថ្មីក្នុងឋាននរក, និងរវាងលោភៈ និងកំណើតជាថ្មីក្នុងភពប្រេត, ហើយនិងរវាងមោហៈ និងកំណើតជាថ្មី ក្នុងភពតិរច្ឆាន ។ បើគ្មានអ្វីរាំងទេ, បើគ្មានអ្វីទប់ដោយសារមានអំពើជាកុសលដទៃទៀតទេ, អំពើទាំងឡាយបែបនោះ ប្រសិនបើជាទម្លាប់ទៅហើយនោះ មុខជាផ្តល់អោយមានកំណើតជាថ្មី នៅក្នុងភពអបាយមុខទាំងបីនោះហើយ ។

ខ្ញុំនឹងលោតរំលងភពមនុស្សមួយខណៈសិន ហើយខ្ញុំបន្តទៅកាន់ភពអសុរ ។ ពួកអសុរជាពួកសត្វមានអានុភាពខ្លាំងក្លាខាងរូបកាយ និងមានប្រាជ្ញាឈ្លាសវៃខាងស្មារតីជាងមនុស្ស ។ ប៉ុន្តែ ពួកអសុរទាំងនោះរងទុក្ខដោយសារតែសេចក្តីច្រណែនឈ្នានីស និងជម្លោះទាស់ទែង ។ តាមដំណើររឿងទេវកថា គេនិយាយថា ពួកអសុរ និងពួកទេពតា តែងតែចែករំលែកដើមឈើទិព្វមួយដើមជាមួយគ្នា ។ នៅពេលដែលពួកទេពតាទទួលសោយផ្លែនៃដើមឈើទិព្វនោះ, ឯពួកអសុរ ជាអ្នកថែរក្សាការពារឫសនៃដើមឈើ ។ ពួកអសុរមានចិត្តច្រណែនចំពោះពួកទេពតា ហើយតែងប៉ុនប៉ងជានិច្ចកាលដណ្តើមយកផ្លែឈើអំពីពួកទេពតា ។ ជាលទ្ធផល ពួកអសុរតែងច្បាំងជាមួយពួកទេពតា ហើយតែងបរាជ័យ និងរងទុក្ខសោកយ៉ាងដំណំ ដោយសារផលវិបាកនេះ ។ ដោយសារមានសេចក្តីច្រណែន, ឈ្នានីស និង

ជម្លោះជាប់ជាប្រចាំនេះ, ទើបជីវិតនៅក្នុងចំណោមពួកអសុរប្រកបដោយទុក្ខព្រួយ និងទោមនស្ស ។ ដូចគ្នានឹងភពឯទៀតៗដែរ, វាមានហេតុបណ្តាលអោយកើតជាថ្មីនៅក្នុងចំណោមពួកអសុរ ។ លើផ្ទែករិជ្ជមាន, ហេតុគឺចិត្តសប្បុរសទូលំទូលាយ ។ លើផ្នែកអវិជ្ជមាន, ហេតុទាំងឡាយគឺកោធៈ, ឥច្ឆា និងឈ្នានីស ។

ភពទីប្រាំមួយ ដ៏ជាភពរបស់ទេពតា គឺជាភពសោយសុខបំផុត ក្នុងចំណោមភពទាំងប្រាំមួយ ។ ដោយសារអានិសង្សបានកសាងអំពើជាកុសល, បានប្រកាន់ខ្ជាប់សីល សិក្ខាបទ និងបានប្រព្រឹត្តធ្វើសមាធិ, សត្វលោកតែងបានកើតឡើងវិញក្នុងចំណោមពពួកទេពតា ដែលនៅទីនោះ គេបានសោយកាមសុខ ឬសុខខាងផ្លូវចិត្ត, ឬក៏សេចក្តីសុខក្សេមក្សាន្តទៅតាមកិរិតក្នុងទេវភព ដែលគេបានកើតឡើងវិញនោះ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ទេពតា ( ភពទេពតា ) មិនមែនជាភពគួរជាទីប្រាថ្នាទេ ពីព្រោះ សេចក្តីសុខរបស់ទេពតា មិនឋិតថេរជាអចិន្ត្រៃយ៍ទេ ។ ទោះបីជាសត្វលោកនោះ អាចសោយសុខក្នុងជីវិតរបស់គេជាទេពតាក៏ដោយ, តែកាលណាកម្លាំងនៃកម្មរបស់គេរីងហួតអស់ហើយ, កាលណាបុណ្យកុសលនៃការរក្សាសីល និងអានុភាពនៃបទពិសោធន៍ក្នុងសមាធិរីងស្ងួតអស់ហើយ, ទេពតាតែងច្យុតចាកឋានសួគ៌ ហើយទៅកើតជាថ្មីក្នុងភពមួយទៀត ។ នៅពេលនោះ, គឺនៅខណៈនៃការច្យុតិនោះ, គេនិយាយថា ទេពតាទាំងឡាយតែងរងទុក្ខក្រៀមក្រំខាងផ្លូវចិត្តខ្លាំងជាងការឈឺចាប់ខាងផ្លូវកាយ ដែលសត្វទាំងឡាយនៅក្នុងភពដទៃ បានទទួលរង ។ កត្តាអវិជ្ជមានជាប់ជាមួយនឹងកំណើតនៅក្នុងភពទេពតា គឺមានះ ។

ដូច្នេះ នៅក្នុងទីនេះ ដូចលោកអ្នកអាចមើលឃើញហើយថា យើងមានសេចក្តីទុក្ខព្រួយ ឬសេចក្តីសៅហ្មងជាប់មកជាមួយភពទាំងប្រាំ . សត្វក្នុងនរក, បីសាចស្រេកឃ្លាន, តិរច្ឆាន, អសុរ និងទេពតា ហើយភពទាំងនោះគឺព្យាបាទ, កាម, អវិជ្ជា, ឥច្ឆា និងមានះ ។ កំណើតនៅក្នុងភពណាមួយ ក្នុងបណ្តាភពទាំងប្រាំនេះ

គឺមិនជាទីប្រាថ្នាទេ ។ កំណើតនៅក្នុងភពជាន់ទាបបី មិនជាទីប្រាថ្នា ព្រោះមានហេតុផលជាក់ស្តែង គឺដោយសារមានទុក្ខធ្ងន់ធ្ងរ និងដោយសារអវិជ្ជាទាំងស្រុងនៃពពួកសត្វដែលរស់នៅក្នុងភពទាំងនោះ ។ សូម្បីតែកំណើតថ្មីនៅក្នុងភពអសុរ និងភពទេពតាក៏មិនជាទីប្រាថ្នាដែរ ។ នេះក៏ពីព្រោះតែជីវិតក្នុងចំណោមពួកអសុរ និងពពួកទេពតាមិនឋិតថេរជាអចិន្ត្រៃយ៍ ទោះបីជាគេបានទទួលសោយសេចក្តីសុខ និងបានទទួលពលានុភាព មានកិរិតណាមួយក្តី ។ ម្យ៉ាងទៀត, ដោយសារតែសេចក្តីសប្បាយរីករាយភ្លើតភ្លើននៅក្នុងភពទាំងនេះ, សត្វទាំងឡាយនៅក្នុងភពនោះៗមិនដែលនឹកគិតពីការស្វែងរកច្រកចេញអោយផុតពីវដ្តសង្សារនៃការកើត និងការស្លាប់ទេ ។ ព្រោះហេតុនោះហើយទើបគេនិយាយថា ក្នុងបណ្តាភពទាំងប្រាំមួយ, ភពដែលមានភ័ព្វ, មានសំណាង និងមានភាពអនុគ្រោះបំផុត គឺភពមនុស្ស ។ ព្រោះហេតុនេះ ទើបខ្ញុំបានទុកភពមនុស្សចុងក្រោយគេ ។

ភពមនុស្សគឺជាភពដ៏មានភាពអនុគ្រោះបំផុតក្នុងបណ្តាភពទាំងប្រាំមួយ ពីព្រោះក្នុងឋានៈជាមនុស្ស គេមានហេតុផល និងឱកាសដើម្បីប្រតិបត្តិព្រះធម៌ ហើយសំរេចការត្រាស់ដឹង ។ គេមានហេតុផល និងឱកាសនេះ ពីព្រោះលក្ខខ័ណ្ឌទាំងឡាយដឹកនាំទៅរកការប្រតិបត្តិតាមមាតិកាមានគ្រប់គ្រាន់ ។ នៅក្នុងភពមនុស្សគេបានទទួលពិសោធន៍ទាំងសេចក្តីសុខ ទាំងសេចក្តីទុក្ខ ។ សេចក្តីទុក្ខនៅក្នុងភពនេះទោះបីគួរអោយស្បើម, ក៏មិនខ្លាំងក្លាណាស់ណាជាងសេចក្តីទុក្ខនៅក្នុងទុគ្គតិភពទាំងបីដែរ ។ សេចក្តីសោមនស្ស និងសេចក្តីសុខ ដែលគេបានសោយនៅក្នុងភពមនុស្ស ក៏ពុំធំធេងណាស់ណាជាងសេចក្តីសោមនស្ស និងសេចក្តីសុខ ដែលគេបានសោយនៅក្នុងឋានសួគ៌ដែរ ។ ជាលទ្ធផល, មនុស្សមិនមានអន្តរាយភាពបិទបាំងដោយសេចក្តីសុខខ្លាំង ដែលគេបានសេពសោយនៅក្នុងឋានសួគ៌, ទាំងមិនមានសេចក្តីធ្វេសប្រហែសដោយសេចក្តីទុក្ខពិបាកទ្រាំទ្របាន ដែលសត្វនៅក្នុងនរកទទួលរង

នោះដែរ ។ ទាំងមិនដូចសត្វតិរច្ឆានដែរ, មនុស្សមានបញ្ញាគ្រប់គ្រាន់ដើម្បីស្គាល់ភាពចាំបាច់ស្វែងរកមធ្យោបាយបញ្ចប់នូវទុក្ខសោកទាំងស្រុង ។

កំណើតជាមនុស្សគឺជាលាភដ៏កម្រមួយ ដោយអាងលើទស្សនវិស័យមួយចំនួន ។ ដំបូងបង្អស់, វាជាការកម្រដើម្បីបានកើតជាមនុស្សដោយអាងលើទស្សន-វិស័យ ស្តីពីហេតុរបស់វា ។ ចរិយាល្អ គឺជាហេតុដំបូងបំផុតដើម្បីបានកំណើតជាមនុស្ស, ប៉ុន្តែចរិយាល្អដ៏ពិតប្រាកដ កម្រកើតមានពេកណាស់ ។ បន្ថែមលើនេះទៀត កំណើតជាមនុស្ស ពិបាកនឹងបានដោយអាងលើទស្សនវិស័យនៃចំនួន, ពីព្រោះមនុស្សជាតិ គឺគ្រាន់តែជាចំណែកដ៏តូចមួយនៃចំនួនសត្វលោកដែលរស់នៅក្នុងភពទាំងប្រាំមួយ ។ ជាងនេះទៀត វាមិនគ្រាន់តែបានកើតជាមនុស្ស ហើយគ្រប់គ្រាន់នោះទេ ពីព្រោះ នៅមានមនុស្សលោករាប់មិនអស់ ដែលមិនមានឱកាសដើម្បីប្រតិ-បត្តិព្រះធម៌ ។ ដោយហេតុនេះ វាមិនគ្រាន់តែមានការចាំបាច់បានកើតជាមនុស្សប៉ុណ្ណោះទេ, វាត្រូវតែមានការចាំបាច់ដើម្បីប្រតិបត្តិព្រះធម៌, ដើម្បីអភិវឌ្ឍគុណ-សម្បត្តិខាងសីល សមាធិ និងបញ្ញា របស់ខ្លួនផងដែរ ។

ព្រះពុទ្ធទ្រង់បានសំដែងអំពីភាពកម្រ និងចរិតវិសេសវិសាលនៃកំណើតដ៏គួរដល់កាលក្នុងចំណោមមនុស្សលោក ។ ព្រះអង្គបានប្រើការប្រៀបធៀបប្រដូចដើម្បីពន្យល់ចំណុចនេះ ។ ឧបមាថា ពិភពលោកទាំងមូល គឺជាមហាសាគរដ៏ធំល្វឹងល្វើយមួយ ហើយនៅលើផ្ទៃមហាសាគរនេះ មាននឹមមួយរសាត់អណ្តែតទៅនេះម្តង ទៅនោះម្តង ដោយត្រូវខ្យល់បោកបក់, ហើយឧបមាថា នៅបាតមហាសាគរមានអណ្តើកខ្វាក់មួយរស់នៅ ដែលតែងងើបលើផ្ទៃមហាសាគររៀងរាល់មួយរយឆ្នាំម្តង ។ ចំពោះអណ្តើកវាមានភាពកម្រពេកណាស់ ដើម្បីងើបឡើងដាក់ករបស់វាអោយត្រូវចំប្រហោងនឹមកំពុងរសាត់អណ្តែតនៅលើផ្ទៃមហាសាគរ, វាកម្រមានដូចគ្នា ចំពោះមនុស្សលោក ដើម្បីបានកំណើតដ៏គួរដល់កាលនោះ ។ ក្នុងទីផ្សេង

ទៀត លោកបានពោលប្រដូចថា បីដូចជាគេគ្រវែងគ្រាប់សណ្តែកស្ងួតមួយក្តាប់ទៅលើជញ្ជាំងថ្ម ហើយវាកម្រនឹងមានគ្រាប់សណ្តែកណាមួយកៀបជាប់ នៅក្នុងស្នាមប្រេះក្នុងជញ្ជាំង, ដូចគ្នាដែរ ដើម្បីកើតបានជាមនុស្សប្រកបដោយភ័ព្វសំណាងបានប្រតិបត្តិព្រះធម៌ គឺជាការកម្រដូចគ្នា ។

វាជាអំពើកម្លៅចំពោះការខ្ជះខ្ជាយជីវិតជាមនុស្សតាមគន្លងលក្ខខ័ណ្ឌជាអកុសល ដែលយើងបានទទួលនៅក្នុងសង្គមសេរី, ខ្ជះខ្ជាយឱកាសល្អ ដែលយើងត្រូវប្រតិបត្តិព្រះធម៌ ។ វាជាការសំខាន់ពេកណាស់ ដែលយើងមានឱកាសដ៏ល្អនេះហើយត្រូវតែប្រើអោយបាន ។ ប្រសិនបើយើងខកខានមិនបានប្រតិបត្តិព្រះធម៌នៅក្នុងជាតិនេះ, វាគ្មានផ្លូវណាមួយដើម្បីដឹងថា តើយើងនឹងទៅកើតទៀតនៅក្នុងភពណា ក្នុងបណ្តាភពទាំងប្រាំមួយ, ហើយតើដល់ពេលណា ទើបយើងនឹងមានភ័ព្វសំណាងបែបនេះម្តងទៀត ។ យើងត្រូវខិតខំរំដោះខ្លួនយើងចេញអោយផុតពីវដ្តសង្សារនៃការកើតទៀត ពិព្រោះការខកខានមិនបានធ្វើដូចនេះ មានន័យថា យើងនឹងបន្តវិលទៅវិលមក គ្មានទីបញ្ចប់ក្នុងការរស់នៅក្នុងបណ្តាភពទាំងប្រាំមួយ ។ កាលណា កម្មជាកុសល ឬអកុសល ដែលបណ្តាលអោយយើងកើតក្នុងភពណាមួយ ក្នុងបណ្តាភពទាំងប្រាំមួយត្រូវរីងហួតអស់ទៅ កំណើតថ្មីទៀតនឹងមកដល់ ហើយយើងនឹងឃើញថា ខ្លួនយើងរស់នៅក្នុងភពមួយទៀត ។ តាមពិត លោកបានពោលថា យើងទាំងអស់គ្នាបានវិលទៅវិលមក កើតនៅក្នុងភពទាំងប្រាំមួយនេះ មិនដឹងតាំងតែពីពេលណាមកទេ ហើយប្រសិនបើគ្រោងឆ្អឹងរាងកាយទាំងអស់របស់យើង នៅក្នុងជីវិតផ្សេងៗរបស់យើង ត្រូវគរជាគំនរវិញ នោះគំនរឆ្អឹងនោះអាចនឹងខ្ពស់ជាងភ្នំព្រះសុមេរុទៅទៀត ។ ប្រសិនបើទឹកដោះរបស់ម្តាយទាំងអស់ ដែលយើងបានបៅឆ្លងកាត់ជីវិតដ៏អនេក ( ច្រើនរាប់មិនអស់ ) របស់យើង ត្រូវបានប្រមូលផ្តុំវិញ ទំហំទឹកដោះនោះនឹងមានលើសទំហំទឹកក្នុងមហាសាគរទាំងអស់ ។ ឥឡូវនេះ យើង

មានឱកាសដ៏ល្អ ដើម្បីប្រតិបត្តិព្រះធម៌ហើយ យើងត្រូវតែធ្វើភ្លាមដោយគ្មានការបង្អែរបង្អង់ ។

ក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ មាននិន្នាការថ្មីមួយ ចង់បកស្រាយភពទាំងប្រាំមួយជាពាក្យពេចន៍ចិត្តវិជ្ជា ។ លោកគ្រូអាចារ្យខ្លះ បានស្នើយោបល់ថា បទពិសោធន៍ នៃភពទាំងប្រាំមួយ គឺមាននៅក្នុងជីវិតយើងសព្វថ្ងៃផ្ទាល់ ។ ដោយគ្មានការសង្ស័យឡើយ នេះជាការណ៍ពិតពាមដែលហេតុនេះកើតមាន ។ មនុស្សប្រុសស្រីទាំងនោះ ដែលកំពុងត្រូវគេឃុំឃាំងក្នុងពន្ធនាគារ ត្រូវគេធ្វើទារុណកម្ម ត្រូវគេសម្លាប់ . ល . និង . ល . គឺកំពុងតែត្រូវរងស្ថានភាពដូចគ្នាទៅនឹងស្ថានភាពនៃសត្វនៅក្នុងនរកដោយឥតសង្ស័យឡើយ ។ ដូចគ្នានេះដែរ មនុស្សប្រុសស្រីទាំងនោះ ដែលមានចិត្តកំណាញ់ស្វិត និងទ្រើស្តស្អូះ កំពុងត្រូវរងនូវស្ថានភាពចិត្តដូចគ្នានឹងស្ថានភាពចិត្តនៃប្រេត ។ ហើយមនុស្សប្រុសស្រីទាំងនោះ ដែលប្រព្រឹត្តដូចសត្វតិរច្ឆាន កំពុងទទួលរងនូវស្ថានភាពចិត្តដូចគ្នានឹងស្ថានភាពចិត្តនៃសត្វតិរច្ឆាន ។ មនុស្សប្រុសស្រីទាំងនោះ ដែលចូលចិត្តបង្កជម្លោះ អាងអំណាច និងមានចិត្តច្រណែនឈ្នានីស កំពុងទទួលរងស្ថានភាពចិត្តដូចគ្នានឹងស្ថានភាពចិត្តរបស់ពួកអសុរ ។ មនុស្សស្រីប្រុសទាំងនោះ ដែលមានចិត្តខ្ពស់ ស្ងប់ ក្សេមក្សាន្ត និងរីករាយ កំពុងទទួលរងស្ថានភាពចិត្តដូចគ្នានឹងស្ថានភាពចិត្តរបស់ទេពតា ។ ប៉ុន្តែថា នៅពេលស្ថានភាពនេះមានពិតដោយឥតសង្ស័យថា បទពិសោធន៍នៃភពទាំងប្រាំមួយកើតមាន នៅក្នុងកិរិតណាមួយ នៅក្នុងជីវិតមនុស្សក៏ដោយ ក៏ខ្ញុំនៅតែគិតថា វាអាចជាកំហុសមួយចំពោះការយល់ ឬការជឿថា ជីវិត ( អត្ថិភាព ) នៃភពទាំងប្រាំមួយ មិនមានការពិត ( តថភាព ) ទេ ដែលនេះជាការពិតជាក់ស្តែង ដូចគ្នានឹងបទពិសោធន៍របស់យើងជាមនុស្សដែរ ។ ភពនរក ភពប្រេត ភពតិរច្ឆាន ភពអសុរ ភពទេពតា គឺជាភពពិតដូចជាភពមនុស្សដែរ ។ យើងត្រូវរំលឹកឡើងវិញថា ចិត្តគឺជាអ្នកបង្កើតនៃសភាវធម៌

ផ្លូវចិត្តទាំងអស់ ។ អំពើទាំងឡាយធ្វើហើយប្រកបដោយចិត្តបរិសុទ្ធ ផ្អែកលើហេតុផល សប្បុរសធម៌ មេត្តា ~ ល ~ និង ~ ល ~ រមែងហុចផលអោយជាសេចក្តីសុខខាងផ្លូវចិត្ត ឬ ស្ថានភាពនៃជីវិត ដូចមាននៅក្នុងភពមនុស្ស និងភពទេពតា ។ ប៉ុន្តែ អំពើទាំងឡាយ ធ្វើហើយប្រកបដោយចិត្តមិនបរិសុទ្ធ ជាប់ជំពាក់ដោយលោភៈ ព្យាបាទៈ និងបាបធម៌ឯទៀត រមែងហុចផលអោយជាជីវិតអពមង្គល ដូចជាជីវិតរបស់ពពួកប្រេត និងពពួកសត្វនៅក្នុងនរក ។

នៅទីអវសាន ខ្ញុំសូមវែកញែកការកើតទៀតផ្តាច់ចេញពីវដ្តសង្សារ ។ លោកអ្នកអាចកត់សំគាល់ថា នៅក្នុងពុទ្ធសាសនាយើងតែងនិយាយដោយជាប់លាប់អំពីការកើតទៀត ហើយមិននិយាយអំពីវដ្តសង្សារទេ ។ នេះក៏ព្រោះតែនៅក្នុងពុទ្ធសាសនា យើងមិនជឿថាមានអង្គធាតុមួយមិនចេះប្រែប្រួល ហើយបន្តបិតផេរយូរអង្វែង, មិនជឿថាមានសារជាតិមួយដែលតែងអន្ទោលកើត ស្លាប់-កើត ស្លាប់ ។ យើងមិនជឿថា មានអត្តៈមួយ ឬព្រលឹងមួយដែលកើតឡើងវិញទេ ។ ព្រោះហេតុនោះហើយ កាលណាយើងពន្យល់អំពីការកើតទៀត យើងតែងប្រើឧទាហរណ៍ដែលមិនតម្រូវអោយមានដំណើរអន្ទោលកើត-ស្លាប់ នៃសារជាតិ ឬសារធាតុមួយនោះទេ ។ ជាឧទាហរណ៍ កាលណាមានពន្លកមួយដុះចេញពីគ្រាប់ពូជ, វាគ្មានសារជាតិណាមួយអន្ទោលទៅកើតទេ ។ គ្រាប់ពូជហើយនិងពន្លក មិនមែនជាវត្ថុដដែលទេ ។ ដូចគ្នានេះដែរ កាលណាយើងអុជទៀនមួយអំពីទៀនមួយទៀត, វាគ្មានសារជាតិណាមួយចេញពីទៀនមួយ ទៅទៀនមួយទៀតទេ, ហើយទៀនទីមួយគឺជាហេតុរបស់ទៀនទីពីរ ។ កាលណាគ្រាប់បាល់ប៊ីយា ទង្គិចគ្រាប់បាល់ប៊ីយាមួយទៀត វាមានភាពបន្តមួយ, ថាមពល និងទិសតម្រង់របស់បាល់ទីមួយ ត្រូវបានចែករំលែកទៅអោយបាល់ទីពីរ ។ វាជាហេតុរបស់បាល់ប៊ីយាទីពីរ កំពុងរមៀលទៅក្នុងទិសមួយដោយឡែក និងក្នុងល្បឿនមួយដោយឡែក ។ កាលណាយើងឈានជើងពីរ

ដងចុះទៅក្នុងស្ទឹងមួយ វាពុំមែនជាស្ទឹងដដែលទេ ប៉ុន្តែវាជានិរន្តរភាព, គឺនិរន្តរ-ភាពនៃហេតុ និងផល ។ ដូច្នេះ វាអាចកើតជាថ្មីទៀត ប៉ុន្តែ មិនមែនជាការអន្ទោលវិលកើត ស្លាប់ ទេ ។ វាមានការទទួលខុសត្រូវខាងផ្លូវសីលធម៌, ប៉ុន្តែ មិនមែនជាអត្តៈ ( ព្រលឹង ) មួយឯករាជជាអចិន្ត្រៃយ៍ទេ ។ វាមាននិរន្តរភាពនៃហេតុ និងផល ប៉ុន្តែ គ្មាននិច្ចភាពទេ ។ ខ្ញុំសូមបញ្ចប់ត្រឹមចំណុចនេះ ពីព្រោះ យើងនឹងពិចារណាឧទាហរណ៍ពីគ្រាប់ពូជ និងពន្លក និងឧទាហរណ៍ ពីអណ្តាតភ្លើង នៅក្នុចង្កៀងប្រេង សប្តាហ៍ក្រោយ នៅពេលយើងពិភាក្សាពីបដិច្ចសមុប្បាទធម៌ ។ ហើយដោយមានជំនួយពីបដិច្ចសមុប្បាទធម៌, យើងនឹងយល់ដឹងបានគ្រាន់បើ ថាតើបដិច្ចសមុប្បាទធម៌ធ្វើអោយមានការទទួលខុសត្រូវខាងផ្លូវសីលធម៌យ៉ាងណា ហើយមិនមែនធ្វើអោយអត្តៈ ( ព្រលឹង ) ស្រុះស្រួលគ្នាបាននោះទេ ។

*( នៅមានត )*

> **ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ**
> **ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។**
>
> បើគេស្វែងរកមិត្តរួមដំណើរ មិនបានអ្នកប្រសើរជាង ឬស្មើនឹងខ្លួនឯងទេ
> គេគប្បីទៅម្នាក់ឯង ល្អជាង ។ ចូរកុំយកមនុស្សពាលជាមិត្តអោយសោះ ។
>
> ធម្មបទ ពាលវគ្គ - ឈ. អ.

ជំនួយស្មារតី

# ពុទ្ធសាសនា និង ការអប់រំសង្គម

## I. ពុទ្ធសាសនា និង ជំនឿ :

ក្នុងព្រះពុទ្ធសាសនា ពុំបានណែនាំអោយជឿនូវជំនឿឥតហេតុផលទេ ; ជំនឿឥតហេតុផល ប្រាសចាកបញ្ញា ពុំមាននៅក្នុងព្រះពុទ្ធសាសនាឡើយ ។ ព្រះពុទ្ធទ្រង់បានទេសនាទុកក្នុងកាលាមសូត្រថា :

- កុំប្រកាន់ជឿអ្វីដែលឮតៗគ្នា មិនមានហេតុផល ( អនុស្សវា ),
- កុំប្រកាន់ជឿអ្វីដែលគេធ្វើមកតៗគ្នា ( បរម្បរា ),
- កុំប្រកាន់ជឿអ្វី ដោយអាងថា បានឮគេនិយាយមក ( ឥតិកិរ ),
- កុំប្រកាន់ជឿតាមក្បួនរបស់ខ្លួន ( បិដកសម្បទាន ),
- កុំប្រកាន់ជឿដោយអាងហេតុ ឬស្មានយក ( នយហេតុ ),
- កុំប្រកាន់ជឿអ្វី ដោយអាងលើការត្មេរត្មាន់ កាត់តម្រូវ ( តក្កហេតុ ),
- កុំប្រកាន់ជឿអ្វី ដោយអាងលើការត្រិះរិះតាមអាការៈដែលបានឃើញ ( អាការបរិវិតក្ក ),
- កុំប្រកាន់ជឿអ្វី ដោយអាងថា ខ្លួនពេញចិត្ត ( ទិដ្ឋិនិជ្ឈានក្ខន្ត ),
- កុំប្រកាន់ជឿថា អ្នកនេះជាបញ្ញវន្ត ល្មមជឿតាមបាន ( ភព្វរូបតា ),
- កុំប្រកាន់ជឿដោយអាងថា សមណៈនេះជាគ្រូរបស់អញ ( សមណោ នោ គរុ ។

## II. ព្រះពុទ្ធសាសនា និង សាមគ្គីភាព :

ព្រះពុទ្ធទ្រង់សម្តែងថា សាមគ្គីនាំមកនូវសេចក្តីសុខដ៏ក្រៃលែង ( *សាមគ្គី សមគ្គានំ តបោ សុខោ* ) កម្លាំងសាមគ្គីអាចឈ្នះអ្វីៗ ទាំងអស់ :

. សាមគ្គីគ្នាការពារភូមិ . ឃុំ អោយមានសុខសន្តិភាព,

. សាមគ្គីកសាងអណ្តូង ស្រះ ដើម្បីដោះស្រាយទឹក,

. សាមគ្គីកសាងសាលារៀន ដើម្បីបំបាត់អវិជ្ជា ។

ដើម្បីបង្កើតបាននូវសាមគ្គី ត្រូវមាន :

**ក / សង្គហធម៌** ៤ យ៉ាង :

• ទាន អោយរបស់ដែលគួរអោយដើម្បីចែកគ្នារស់ ឬអោយចំណេះចេះដឹងដល់គ្នានិងគ្នា ( ធម្មទាន ) ។

• បេយ្យវជ្ជ ពោលពាក្យសុភាពរាបសារកាន់គ្នាទៅវិញទៅមក, បើគេជាអ្នកផឹកស្រា កុំហៅគេថា អាប្រមឹក, បើគេពិការជើង កុំហៅគេថា អាកំបាក់, បើគេពិការភ្នែក កុំហៅគេថា អាកង្វាក់, ... ។

• អត្ថចរិយា ប្រព្រឹត្តធ្វើអំពើជាប្រយោជន៍ដល់មនុស្សច្រើនគ្នាផង ដល់ខ្លួនផ្ទាល់ផង ។

• សមានត្តតា រស់នៅយ៉ាងសាមញ្ញ គោរពរាប់អានអ្នកដទៃដោយស្មោះស្មើ មិនមានមានះដោយអាងទ្រព្យ អាងចំណេះ អាងត្រកូល ។

**ខ / សារាណិយធម៌** ៦ យ៉ាង :

• មេត្តាកាយកម្ម យោគយល់គ្នា ជួយគ្នាខាងផ្លូវកាយ,

• មេត្តាវចីកម្ម យោគយល់គ្នា ជួយគ្នាខាងផ្លូវវាចា,

• មេត្តាមនោកម្ម មានចិត្តស្មោះត្រង់នឹងគ្នា,

• លាភៈ ចែកលាភដែលបានមកដោយធម៌ ដល់អ្នកឯទៀតដែលត្រូវបាន មិនហួងហែង ឬត្បិតត្បៀត លាក់លៀមទុកតែម្នាក់ឯង,

• សីលៈ រក្សាខ្លួនអោយបានត្រឹមត្រូវតាមសីលធម៌, មិនប្រព្រឹត្តរំលោភបំពានលើជីវិត ទ្រព្យសម្បត្តិ ទីកន្លែង របស់អ្នកដទៃ,

• ទិដ្ឋិ គំនិតមិនមានអធិករណ៍ មិនឃើញអំពើរបស់គេសុទ្ធតែខុស, សុទ្ធតែមិនល្អ ។ ចេះសម្របសម្រួលគ្នា ( ប្រាជ្ញឯង រអែងប្រាជ្ញគេ ) ។

ធម៌ទាំង ៦ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសង្គ្រោះដល់គ្នានឹងគ្នា ដើម្បីមិនមានវិវាទគ្នា ដើម្បីព្រមព្រៀងគ្នា ។

## III. ពុទ្ធសាសនា និង សេដ្ឋកិច្ច :

ក / ព្រះពុទ្ធស្អប់ខ្ពើមភាពខ្ជិលច្រអូស ហើយទ្រង់បង្ហាញពីលេសបុគ្គលខ្ជិលច្រអូស ៦ យ៉ាង :

- អាងថា ព្រឹកពេក ( អតិបាតោ )
- អាងថា ល្ងាចពេក ( អតិសាយំ )
- អាងថា ក្តៅពេក ( អតិឧណ្ហំ )
- អាងថា ត្រជាក់ពេក ( អតិសីតំ )
- អាងថា ស្រេកពេក ( អតិបិបាសោ )
- អាងថា ឃ្លានពេក ( អតិឆាតោ )

ខ / ព្រះពុទ្ធប្រដៅមនុស្សអោយឧស្សាហ៍ : ដោយទ្រង់បញ្ជាក់ថា *វីរិយេន ទុក្ខមច្ចេតិ* សេចក្តីព្យាយាមនាំអោយរួចចាកទុក្ខ ។ ប្រយោជន៍ក្នុងបច្ចុប្បន្នក្តិ ក្នុងបរលោកក្តិ សុទ្ធតែសំរេចឡើងដោយព្យាយាម ពុំមែនកើតឡើងដោយការដេករង់ចាំព្រេងសំណាង ឬ ព្រះអាទិទេពប្រទានអោយនោះទេ ( *អត្តា ហិ អត្តនោ នាថោ* ខ្លួនទីពឹងខ្លួន, ខ្លួនស្វែងរកប្រយោជន៍សំរាប់ខ្លួន ) ។

ដើម្បីអោយសំរេចប្រយោជន៍បច្ចុប្បន្នគ្រប់យ៉ាងបាន ត្រូវបំពេញនូវសម្បទា ៤ យ៉ាង :

• ឧដ្ឋានសម្បទា ប្រកបដោយការភ្ញាក់រលឹក ស្ទុះស្ទាររៀនសូត្រ ស្វែង

រកទ្រព្យសម្បត្តិ ខិតខំបំពេញភារកិច្ចគ្រប់យ៉ាង ។

• អារក្ខសម្បទា ប្រកបដោយការយកចិត្តទុកដាក់ឃុំគ្រង ថែរក្សាអ្វីៗ ដែលខ្លួនខិតខំរកបានហើយនោះ កុំអោយបាត់បង់វិនាសទៅវិញ ។

• កល្យាណមិត្តតា ត្រូវសេពគប់តែនឹងមនុស្សល្អ - សប្បុរស ហើយ ជៀសវាងសេពគប់នឹងមនុស្សអាក្រក់ ពាលា ។ ធម៌ជាគ្រឿងសំគាល់របស់សប្បុរស មាន ៦ យ៉ាង :

១. ធម្មញ្ញុតា ភាពជាអ្នកដឹងធម៌ - ដឹងហេតុ ដឹងខុសត្រូវ,
២. អត្ថញ្ញុតា ភាពជាអ្នកដឹងអត្ថ ដឹងផល,
៣. មត្តញ្ញុតា ភាពជាអ្នកដឹងប្រមាណ,
៤. កាលញ្ញុតា ភាពជាអ្នកដឹងកាល,
៥. បរិសញ្ញុតា ភាពជាអ្នកដឹងទីប្រជុំ,
៦. បុគ្គលបរោបរញ្ញុតា ភាពជាអ្នកដឹងបុគ្គលខ្ពស់ - ទាប ។

• សមជីវិតា ប្រកបព្រមដោយការសន្សំសំចៃក្នុងការចាយវាយទ្រព្យ សម្បត្តិ លុយកាក់ដែលស្វែងរកបានមកអោយបានសមស្រប កុំខ្ជះខ្ជាយ ត្រូវចេះគិត មុខគិតក្រោយ ( ទ្រង់ណែនាំមនុស្សអោយបែងចែកទ្រព្យសម្បត្តិ ដែលរកបានមក ជា ៤ ចំណែក គឺ :

១. ដោះបំណុលចាស់ គឺ ចិញ្ចឹមមាតាបិតា បុព្វការី,
២. បុលបំណុលថ្មី គឺ ចិញ្ចឹមកូនចៅ,
៣. បោះក្នុងជ្រោះជ្រៅ គឺ ចិញ្ចឹមខ្លួនឯង,
៤. កប់ទុកជាកំណប់ព្រេង គឺ ធ្វើបុណ្យទានផ្សេងៗ ។

## IV. ពុទ្ធសាសនា និង សីលធម៌ :

ពុទ្ធសាសនា តែងអប់រំមនុស្សអោយប្រកាន់ខ្ជាប់នូវសីលធម៌ ។ អ្នកមាន

សីល ចាត់ទុកជាបុគ្គលទី ១ ដែលត្រូវបានទទួលនូវការគោរព ស្រលាញ់រាប់អាន និងទំនុកចិត្តអំពីមនុស្សដទៃក្នុងសង្គម ។ ពុទ្ធសាសនាអប់រំមនុស្សអោយស្អប់ខ្ពើមអំពើហិង្សា ចងពៀរវេរាគ្នា ហើយអោយមនុស្សចេះស្រឡាញ់គ្នា មានព្រហ្មវិហារចំពោះគ្នា ស្រឡាញ់សន្តិភាព ស្មោះត្រង់នឹងគ្នា ។ ឆ្លងតាមរយៈឥទ្ធិពលពុទ្ធសាសនានេះហើយបានជាគេពិនិត្យឃើញថា ជាតិខ្មែរ ជាជាតិមួយមានលក្ខណៈ អត្តចរិតស្លូតបូត ទន់ភ្លន់ មានសុជីវធម៌ រក្សាសីល ៥ ចាំសីល ៨ វៀរចាកអកុសលកម្មបថ ១០ គឺ :

ក)- កាយកម្ម បី :

១- សម្លាប់សត្វ

២- លួចទ្រព្យអ្នកដទៃ

៣- ប្រព្រឹត្តខុសក្នុងកាម

ខ)- វចីកម្ម បួន :

១- និយាយកុហក ភូតភរ

២- និយាយញុះញង់

៣- និយាយពាក្យអាក្រក់

៤- និយាយពាក្យឥតប្រយោជន៍

គ)- មនោកម្ម បី :

១- អភិជ្ឈា ច្រណែនឈ្នានីស

២- ព្យាបាទ ផ្គងចិត្ត ឬប៉ងនឹងធ្វើគេអោយវិនាស

៣- មិច្ឆាទិដ្ឋិ យល់ឃើញខុស គឺដំណើរយល់ខុសពីសេចក្តីពិត ។

ប្រសិនបើប្រជាជាតិនានាក្នុងលោកអនុវត្តបានត្រឹមត្រូវតាមមាគ៌ាពុទ្ធ-សាសនា នោះមនុស្សជាតិទាំងមូលពិតជាទទួលបាននូវការរីកចំរើន ទាំងខាងសម្ភារៈ ទាំងខាងស្មារតី ពុំខានឡើយ ។

អាំ ឆន

នៅពុទ្ធសាសនបណ្ឌិត្យ

# វចនសព្ទវិទ្យា នៃ ភាសាខ្មែរបច្ចុប្បន្ន ( ត - ចប់ )

## Lexicologie du Khmer Moderne

បណ្ឌិតសាស្ត្រាចារ្យ **ឡុង សៀម**

## រូបារម្មណ៍នីយកម្ម និង រូបារម្មណ៍

រូបារម្មណ៍នីយកម្មបានពីការប្រៀបធៀបន័យ គឺជាបែបផែនម្យ៉ាងនៃបំលែងន័យ គឺបានសេចក្ដីថា ន័យអរូបិយកើតឡើងដោយឈរលើមូលដ្ឋានន័យរូបិយ ដោយវិធីប្រដូចបញ្ញត្តិតាមដំណូច ឬវិធីជំនួស ។ និយមន័យនេះ ទាមទារការបញ្ជាក់មួយចំនួន ។

អ្នកភាសាវិទូខ្លះ ( មានលោក ប. ហ្សីរ៉ូ ) យល់ឃើញថា ហេតុកម្មបានពីការប្រៀបធៀបន័យ គឺជាបម្រែបម្រួលន័យ : វត្ថុមួយត្រូវគេយកឈ្មោះនៃវត្ថុផ្សេងទៀត ដាក់អោយទៅតាមបណ្ដុំលក្ខណៈនៃវត្ថុផ្សេងនោះ ។ រីឯបណ្ដុំលក្ខណៈនោះ ក៏អាចឈរលើមូលដ្ឋាននៃភាពដំណូច និងភាពត្រូវគ្នានៃវត្ថុទាំងពីរ ។ បណ្ដុំលក្ខណៈនោះ ក៏អាចឈរលើមូលដ្ឋាននៃភាពដំណូចផ្នែករូប, ផ្នែកមុខងារ ឬមួយយោលទៅតាមកាលៈទេសៈ ( ទីកន្លែង, កំណើត ) ។ បណ្ដុំលក្ខណៈនេះលេចឡើងនូវចន្លោះវត្ថុ ដែលគេត្រូវដាក់ឈ្មោះ (object evoque) និងវត្ថុដើម ( គម្រូ ) ( object repere ) សម្រាប់ប្រៀបធៀប ។

ការប្រៀបធៀបន័យ អាចឈរលើមូលដ្ឋាននៃពាក្យទោល ឬពាក្យផ្សំ ព្រមទាំងកន្សោមពាក្យ ឬសំនួនវោហារពាក្យ ( expression idiomatique ) ផងដែរ ។ ការប្រៀបធៀបន័យអាចប្រមូលផ្ដុំ ដោយឈរលើបណ្ដុំលក្ខណៈនៃវត្ថុពីរ ។ ឈ្មោះរបស់វត្ថុមួយ ក្នុងចំណោមវត្ថុទាំងពីរ ជាញឹកញាប់ មានតួនាទីជាអ្នកកំណត់ នៃវត្ថុមួយទៀត ។

តទៅនេះ យើងនឹងធ្វើការវិភាគឧទាហរណ៍ នៃការប្រៀបធៀបមួយចំនួន :

| | ន័យត្រង់ | ន័យបានពីការប្រៀបធៀប ឬ រូបារម្មណ៍ |
|---|---|---|
| ក). | ខ្លា ( សត្វ ) | ខ្លា ( នៅក្នុងគ្រឿងយន្ត ) |
| | ផ្កា ( រុក្ខជាតិ ) | ផ្កា ( បុណ្យផ្កា ) |
| | ក្រពើ ( សត្វ ) | ក្រពើ ( មនុស្សអាក្រក់ ) |
| | ស្វា ( សត្វ ) | ស្វា ( មនុស្សឡេមឡើម ) |
| | ស្វិត ( ជាប់បានយូរ ) | ស្វិត ( កំណាញ់ ) |
| | រឹង ( ឧ. ឈើរឹង ) | រឹង ( រឹងរូស ) |
| ខ). | កាំភ្លើង ( កាំរស្មី ) | កាំភ្លើង ( អាវុធ ) |
| | ចំពុះទុង ( ចំពុះទុងសត្វ ) | ចំពុះទុង ( កាំបិតនៅចុងកាំភ្លើង ) |
| | ឫសគល់ ( ឫសគល់ឈើ ) | ឫសគល់ ( មូលហេតុ ) |
| | ទឹកឃ្មុំ ( ទឹកផ្អែមបានពីឃ្មុំ ) | ទឹកឃ្មុំ ( ពិរោះ, ផ្អែមល្ហែម ) |
| | មែកធាង ( មែកធាងដើមឈើ ) | មែកធាង ( ផ្នែក, វិស័យ ) |
| គ). | ក្ដៅចិត្ត ( ចិត្តក្ដៅ ) | ខឹង |
| | ភ្លេចត្រចៀក | ភ្លេចភ្លាំង |
| | វង្វេងបឹង ( វង្វេងរកបឹងមិនឃើញ ) | ភ្លេចកំណើតខ្លួន |

ដោះស្រាយ ( ដោះស្រាយខ្សែ ) ដោះស្រាយ ( បញ្ហា )

ចងស្ពានមេត្រី (សង់ស្ពាន + មេត្រី) បង្កើតចំណងមិត្តភាព

ក្នុងឧទាហរណ៍ខាងលើ យើងអាចឃើញការប្រៀបធៀបន័យ ដែលជាលទ្ធផលនៃ :

ក. ការប្រដូចបណ្តុំលក្ខណៈ នៃវត្ថុរូបធាតុពីរ

ខ. ភាពដំណូចរវាងវត្ថុ រូបធាតុ និងវត្ថុមិនមែនរូបធាតុ

គ. ភាពដំណូចរវាងធាតុមិនមែនរូបធាតុពីរ ។

ពាក្យ « ស្វា » មានន័យប្រៀបធៀបពីរផ្សេងគ្នា ។ ទាំងនេះអាចពន្យល់បានថា ន័យន្លើយគ្នានីមួយៗ កើតឡើងពីប្រភពផ្សេងគ្នា ។ ដូចជាន័យថា « មនុស្សឡេមឡឺម ( រអែបរអប ) » កើតចេញពីបណ្តុំលក្ខណៈ នៃតួអង្គក្នុងរឿងរាមកេរ្តិ៍ « រាម-កេរ្តិ៍ » ឈ្មោះហនុមាន ជាស្តេចស្វាជំនិតរបស់ព្រះរាម ។

ពាក្យបានពីការប្រៀបធៀបន័យ ដែលបង្កើតឡើងដោយអ្នកនិពន្ធ និងកវី ហៅថាពាក្យប្រៀបធៀបន័យតាមរចនាបថ ។ ការប្រៀបធៀបនេះ ដំបូងឡើយ គឺជាលទ្ធផលនៃស្នាដៃរបស់បុគ្គលផ្ទាល់ប៉ុណ្ណោះ តែបន្ទាប់មក ត្រូវបានគេទទួលស្គាល់ជាទូទៅ ហើយក្លាយទៅជាពាក្យក្នុងភាសាទំនាក់ទំនងទូទៅ ។ ពេលដែលក្លាយជាពាក្យទំនាក់ទំនងទូទៅរួចហើយ ពាក្យប្រៀបធៀបទាំងនោះ ក្លាយទៅជាពាក្យប្រៀបធៀបន័យភាសាវិទ្យា ហើយដែលយើងនឹងយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវរបស់យើងនៅពេលនេះ ។

ក៏ដូចជាភាសាដទៃទៀត ដែលមានការរីកចំរើនដែរ ក្នុងភាសាខ្មែរ មានពាក្យជាច្រើនដែលមានន័យបែបប្រៀបធៀប ។ ទាំងនេះអាចបញ្ជាក់ដោយការសិក្សាពាក្យកម្លាយ និងពាក្យផ្សំ ។

តទៅនេះ យើងនឹងវិភាគទិដ្ឋភាពពិសេសមួយចំនួន នៃហេតុកម្មបានពី

ការប្រៀបធៀបន័យរបស់ពាក្យខ្លះ ដូចជាឈ្មោះនៃផ្នែកផ្សេងៗ របស់រាងកាយក្នុងការបង្កើតឈ្មោះវត្ថុ សំនួនវោហារ ឈ្មោះរុក្ខជាតិ ដោយផ្ដើមចេញ ដែលលោកស្រី S. Lewitz ហៅថា « ការហៅដោយឯកឯង » ។

តើ « ការហៅតាមសន្ទុះនៃអារម្មណ៍ » នោះជាអ្វីទៅ ?

នៅក្នុងលំនាំនៃការសិក្សាស្ថាននាមវិទ្យា លោកស្រី សវរស ពៅ បានបញ្ជាក់ថា ប្រជាជនចេះដាក់ឈ្មោះទីកន្លែង ដោយផ្អែកទៅតាម :

- ហេតុជាក់ស្ដែងក្នុងធម្មជាតិ ឬអ្វីមួយដែលធ្វើអោយម្ចាស់ភាសា មានមនោគតិ ( ហេតុជាក់ស្ដែងខាងភូមិសាស្ត្រ ឬផែនទី ) ។

ឧទាហរណ៍ : « ភ្នំដងរែក » ( ជួរភ្នំដែលស្ថិតនៅខាងជើង នៃប្រទេសកម្ពុជា វាមានឈ្មោះដូច្នេះ ព្រោះរូបរាងវាវែង ) ។ « ភ្នំបូកគោ ( នៅក្នុងជួរភ្នំកំចាយ ខេត្តកំពត ) វាមានឈ្មោះដូច្នេះ ព្រោះវាខ្ពស់ ហើយរាងដូចបូកគោ » ។

- បណ្ដុំអារម្មណ៍ស្របទៅតាមទំនៀមទម្លាប់បុរាណ ឬរឿងព្រេង ។

ឧទាហរណ៍ : « កំពង់លែង » ជាឈ្មោះស្រុកមួយ នៃប្រទេសកម្ពុជា ដែលយកដំណើររឿងព្រេងថា ឫទ្ធិសែនបានចាកចោលនាងកង្រី ធ្វើអោយនាងសម្លាប់ខ្លួននៅទីនោះ ។

ឧទាហរណ៍ នៃស្ថាននាមខ្មែរមួយចំនួនខាងលើនេះ អាចអោយយើងអះអាងថា មូលដ្ឋានសេម៉ង់ទិកនៃស្ថាននាម បើគិតតាមលក្ខណៈរបស់វា គឺដូចគ្នានឹងស្ថាននាមខ្មែរ ដែលមានបោតុកម្មដទៃទៀតដែរ គឺថា ពាក្យដែលកើតឡើងដោយសារបណ្ដុំអារម្មណ៍ទៅតាមអ្វីមួយ ហើយពាក្យនោះ គឺជាពាក្យយកចេញពីវចនស័ព្ទខ្មែរ ។

បើយើងវិភាគតទៅទៀតនោះ នឹងមានបញ្ហាមួយចោទឡើង ថាតើឈ្មោះទីកន្លែងដែលដាក់តាមនាម ខុសគ្នាយ៉ាងដូចម្ដេច ? ជាទូទៅ អ្វីដែលទាក់ទង

នឹងអសាធារណនាម អាចបញ្ជាក់បានថា ៖

. ជាពិស័ត្ថអសាធារណនាម ចេញពីពាក្យទោលក្នុងភាសាខ្មែរ ដែលមានន័យរូបិយ ។

. ឈ្មោះទីកន្លែង យកចេញពីពាក្យផ្សំ ហើយកំណើតរបស់វា គឺបានពន្យល់នៅខាងលើរួចមកហើយ ។

ដូច្នេះ យើងអាចធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ ៖ ឈ្មោះទីកន្លែង ឬឈ្មោះមនុស្ស នៅទីបំផុតកើតចេញពីពាក្យធម្មតារបស់វចនស័ព្ទក្នុងភាសាខ្មែរ ។ ហេតុនេះហើយ ការសិក្សាវចនស័ព្ទ គឺជាធាតុមួយដ៏សំខាន់នៃការស្រាវជ្រាវស្ថាននាម និងឈ្មោះដទៃទៀត ។ ផ្ទុយទៅវិញ ការស្រាវជ្រាវទាំងពីរជំពូកខាងលើ មិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានទំនាក់ទំនងជាមួយនឹងការសិក្សាស្រាវជ្រាវវចនស័ព្ទវិទ្យា ។

## ហេតុកម្មបានពីការប្រៀបធៀបន័យ នៅក្នុងឈ្មោះនៃផ្នែករបស់រាងកាយ និងសរីរាង្គរបស់មនុស្ស

ឈ្មោះសម្រាប់សំគាល់ផ្នែកផ្សេងៗ នៃរាងកាយមនុស្ស បានកើតឡើងក្នុងបុរាណកាលដ៏យូរលង់ ។ លើកលែងតែឈ្មោះនៃផ្នែកផ្សេៗ របស់រាងកាយដែលជាពាក្យទោល ឯកឮាង្គចេញ ភាគច្រើននៃឈ្មោះផ្នែករាងកាយ គឺជាពាក្យកម្លាយ និងពាក្យផ្សំ ។

ក្រុមពាក្យកម្លាយ គឺជាពាក្យដែលបានមកពីការដាក់ផ្នត់ដើម និងផ្នត់ចែកទៅអោយកិរិយាស័ព្ទបុរាណ ដែលមានន័យអនុលោមទៅតាមមុខងារនៃផ្នែកនីមួយៗ របស់រាងកាយ និងសរីរាង្គរបស់មនុស្ស ។

ឧទាហរណ៍ ៖ « ភ្នែក » ( វែក )

« ត្រគៀក » ( គៀក )

« ក្រលៀន » ( លៀន )

« ក្រពះ » ( ពះ " ឆី " )

« ទ្រូង » ( រូង )

« ខ្នង » ( កង . កោង )

« ថ្គាម » ( មកពីពាក្យបុរាណ " គាម . អង្គាម " )

ផ្នត់ដើម [ t ] នៃពាក្យ « ថ្គាម » ក៏ដូចជាក្នុងករណី នៃពាក្យច្រមុះ ដែលបានពណ៌នាខាងលើរួចមកហើយដែរ គឺចេញពីពាក្យ មន . ខ្មែរ « មុះ » គឺជាការបញ្ចេញស្វរស័ព្ទទៅលើពាក្យបុរាណ ហើយដែលគេដាក់ឈ្មោះ « ការផ្សាំនៅក្នុងភាសា » ( Greffe linguistique ) ។

ពាក្យ « ត្រចៀក » អាចកើតចេញពីពាក្យ « ច្រៀក » ។ វត្តមាននៃពាក្យផ្សាំនៅក្នុងភាសា ដែលក្នុងនោះមានពាក្យ « ត្រចៀក » ( ស្លឹកត្រចៀក , ទងត្រចៀក ) បញ្ជាក់អំពីដើមកំណើតសេម៉ង់ទិកនេះ ។

ដើម្បីហៅឈ្មោះផ្សេងៗទៀតនៃរាងកាយ និងសរីរាង្គ គេប្រើពាក្យផ្សំ ។ នៅក្នុងសមាសភាពនៃពាក្យធាតុផ្សំទីមួយ គឺជាឈ្មោះនៃវត្ថុដែលគេធ្វើបណ្តុំអារម្មណ៍ រីធាតុទីពីរ គឺជាឈ្មោះនៃវត្ថុដំបូង ( ដើម , មេ ) ។

ត្រង់នេះយើងនឹងពិនិត្យបែបផែនផ្សេងៗ នៃបណ្តុំអារម្មណ៍ គឺថា បែបផែនផ្សេងៗនៃហេតុកម្ម ។

ផ្នែកនៃភ្នែក : រង្វង់ភ្នែក, ក្រដាសភ្នែក, ប្រស្រីស, ប្រស្រីខ្មៅ ។ នៅក្នុងឧទាហរណ៍ចុងក្រោយគេនេះ យើងនឹងពិនិត្យន័យ នៃធាតុផ្សំទីមួយគឺ « ប្រ. ស្រី » ។ ពាក្យនេះ ប្រហែលជាកើតចេញពីពាក្យ « ស្រី » ដោយប្រើផ្នត់ដើម « ប្រ » ។ ឧទាហរណ៍ : « កូនក្រមុំ » ( ក្នុងភ្នែក ) ។

ផ្នែកនៃដៃ : ដើមដៃ, កែងដៃ, បាតដៃ, មេដៃ, ចង្អុលដៃ, នាងដៃ, កូនដៃ ។ រចនាសម្ពន្ធវេយ្យាករណ៍របស់ពាក្យ ដែលបានរៀបរាប់ខាងលើ គឺខុសៗគ្នា វត្ថុបណ្តុំអារម្មណ៍ ត្រូវសំគាល់ដោយថ្នាក់ពាក្យខុសៗគ្នា ។ គួរកត់សំគាល់ថា ពាក្យ « មេ, នាង, កូន » គឺជាពាក្យសំគាល់មនុស្ស ។

ផ្នែកផ្សេងៗទៀត នៃរាងកាយ និងសរីរាង្គមនុស្ស បានទទួលឈ្មោះតាមរបៀបដំណូចទៅនឹង :

ក. វត្ថុផ្សេងៗដែលនៅជុំវិញខ្លួនយើង : សន្ទះទ្រូង, សាច់ដុំ, ឆ្អឹងជងកាំបិត ។

ខ. ផ្នែកសំខាន់មួយនៃរាងកាយ : កដៃ, ក្បាលជង្គង់, ភ្នែកគោល, ជើងធ្មេញ ។

មានសរីរាង្គមនុស្សមួយចំនួនទៀត ដែលបានទទួលឈ្មោះដោយវិធីប្រៀបធៀបន័យ ដោយឈរលើគោលការណ៍ជំនួស ។

ឧទាហរណ៍ : អណ្តើក ជាសរីរាង្គដែលគេហៅតាមដំណូចជាមួយសត្វអណ្តើក បេះដូង ( បេះ - ដូង > « បេះដូង » ដូចដូង ) ។ តាមទស្សនៈហេតុកម្មបានពីការប្រៀបធៀបន័យ ការប្រដូចរូបរាងបេះដូងទៅនឹងផ្លែដូង គឺសមហេតុផលណាស់ ។ ប៉ុន្តែ តាមទស្សនៈរូបស័ព្ទវិទ្យាវិញ ទីតាំងនៃពាក្យ « បេះ » ដែលស្ថិតនៅខាងមុខពាក្យ « ដូង » គឺពិបាកពន្យល់ណាស់ ។ ប៉ុន្តែពាក្យ « បេះដូង » ជាពាក្យថ្មីជាងពាក្យ « ថ្លើម » ព្រោះពាក្យ « ថ្លើម » ជាពាក្យដើម ហើយបានបង្កបង្កើតសំនួនពាក្យមួយចំនួនធំ ។

នៅទីនេះ យើងមិនអាចធ្វើការពន្យល់ពាក្យដែលសំគាល់ផ្នែកនៃរាងកាយ ដែលទាក់ទងនឹងភេទរបស់បុរស ឬស្ត្រី ហើយកើតឡើងដោយហេតុកម្ម បានពីការប្រៀបធៀបន័យទេ ។ ប្រសិនបើការស្រាវជ្រាវបែបនេះ ប្រព្រឹត្តទៅបាន

នោះ ជាការពិតណាស់ ដែលវាអាចមានឥទ្ធិពលស៊ីជម្រៅនៅក្នុងការផ្តល់គំនិតអំពីវិធីបង្កើតពាក្យនៅក្នុងភាសា ព្រោះថា តាមពិត ភាសាមួយចំនួន ពាក្យទាំងនេះកើតចេញក្នុងរយៈកាលដំបូងនៃកំណកំណើតភាសា ។

## ការប្រៀបធៀបន័យអង់ត្រូប៉ូម័ហ្វ
## ( anthropomorphe)

ក្រោយពេលដែលការហៅឈ្មោះផ្នែកផ្សេងៗនៃរាងកាយ និងសរីរាង្គមនុស្ស បានធ្វើឡើងក្នុងកម្រិតមួយគ្រប់គ្រាន់ តាមហេតុកម្មបានពីការប្រៀបធៀបន័យហើយនោះ នៅក្នុងភាសា គេសង្កេតឃើញមានដំណៅទិសបញ្ច្រាសទៅវិញ នៅក្នុងការប្រើប្រាស់ឈ្មោះទាំងនោះ ដើម្បីបង្កើតពាក្យផ្សំសម្រាប់សំគាល់វត្ថុគ្មានជីវិត និងបាតុភូតធម្មជាតិ ។ ក្នុងឈ្មោះទាំងនោះ ឈ្មោះផ្នែកផ្សេងៗនៃរាងកាយ និងសរីរាង្គរបស់ តែងតែស្ថិតនៅខាងដើមនៃពាកផ្សំជានិច្ច និងមានតួនាទីជា « ពាក្យគ្រឹះ » និងផ្តល់ជាគំនិតរួមនៅក្នុងចំណាត់វត្ថុ ទៅតាមបណ្តុំលក្ខណៈនៃផ្នែកផ្សេងៗរបស់រាងកាយមនុស្ស ។

ពាក្យ « ក្បាល » នៅក្នុងសមាសភាពនៃពាក្យផ្សំ គឺមានន័យសំដៅទៅលើអ្វីដែលស្ថិតនៅខាងមុខ មានទ្រង់ទ្រាយមូល, អ្វីមួយដែលសំខាន់ ដែលនាំមុខគេ : ក្បាលទូក, ក្បាលម៉ាស៊ីន, ក្បាលពោះ, ក្បាលមាន់ ។

ពាក្យ « មុខ » សំដៅអ្វីដែលស្ថិតនៅខាងមុខ, អ្វីដែលកើតមានមុន : មុខផ្ទះ, មុខកាំបិត, មុខទឹក ។

ពាក្យ « មាត់ » សំដៅយកប្រហោង, ជាយ, ផ្នែកខាងមុខ : មាត់ទ្វារ,

មាត់ទន្លេ, មាត់ព្រៃ ។

ពាក្យ « ត្រចៀក » សំដៅយកអ្វីដែលភ្ជាប់ទៅនឹងវត្ថុសំខាន់ទាំងពីរផ្នែក : ត្រចៀកចាន, ត្រចៀកទ្វារ, ត្រចៀកត្រី ។

ពាក្យ « អណ្ដាត » សំដៅយកអ្វីដែលទន់ និងមានសណ្ឋានវែង : អណ្ដាតភ្លើង, អណ្ដាតស្រឡៃ, អណ្ដាតសមុទ្រ ។

ពាក្យ « ធ្មេញ » សំដៅយកអ្វីដែលមុត : ធ្មេញរណា, ធ្មេញកណ្ដុរ, ធ្មេញឈើ ។

ពាក្យ « ភ្នែក » សំដៅយកអ្វីដែលមានរាងមូល, តូច, មានទ្រង់ទ្រាយជាចំណុច : ភ្នែកជញ្ជីង, ភ្នែឫស្សី, ភ្នែកម្នាស់ ។

ពាក្យ « ជើង » សំដៅយកអ្វីដែលមានភាពឆ្ងាយនៅលើផ្ទៃរាប ឬក្នុងសភាពបញ្ឈរ : ជើងភ្នំ, ជើងមេឃ, ជើងព្រៃ, ជើងក្អែក, ជើងអក្សរ ។

ពាក្យ « ដៃ » សំដៅយកការសាយភាយ, ការលូតចេញ : ដៃកៅអី, ដៃអាវ, ដៃទន្លេ, ដៃជីរ, ដៃទ្វារ, ដៃខ្លា, ដៃចង្កូត ។

ពាក្យ « អាចម៍ » ( ពាក្យនេះ តាមវចនានុក្រមសម្ដេចសង្ឃ ជួន ណាត គេចាត់ទុកថា មានកំណើតសំស្ក្រឹត ) ។ រីឯយើងវិញចាត់ទុកថា ពាក្យនេះមានកំណើត មន-ខ្មែរ ។ ហេតុពិតនេះគឺថា ពាក្យ « អាចម៍ » នេះ គឺជាធាតុមួយសម្រាប់បង្កើតពាក្យផ្សំនឹងកន្សោមពាក្យជាច្រើន ដែលអាចបញ្ជាក់ថាជាពាក្យកើតនៅនឹងកន្លែង ។ អំពីការរិះគន់លើដើមកំណើតសំស្ក្រឹតរបស់ពាក្យមួយចំនួន ដែលជាពាក្យមន-ខ្មែរ ឬ ខ្មែរ នៅក្នុងអត្ថបទមួយចំនួន របស់លោកស្រី សវរស ៣៧ ។ ពាក្យនេះសំដៅយកស្នាមប្រឡាក់តូចៗ, កាកសំណល់ ។ គេប្រើវាក្នុងតួនាទីជាការប្រៀបធៀបន័យតាមដំណូចជាលក្ខណរូប : អាចម៍រណា, អាចម៍បំណះ, អាចម៍រុយ, អាចម៍លក្ខណ៍, អាចម៍ត្រចៀក, អាចម៍ភ្នែក, អាចម៍ដែក, អាចម៍ផ្កាយ, អាចម៍

ក្រពើ, អាចម៍ឆ្កែ ( ឈើក្បាលក្រពើ ), អាចម៍អណ្ដើក ។

ពាក្យ « ខ្នង » សំដៅយកផ្នែកខាងលើនៃវត្ថុអ្វីមួយ ៖ ខ្នងកង់, ខ្នងសំបុត្រ, ខ្នងភ្នំ ។

ឈ្មោះបែបប្រៀបធៀប ដែលសំគាល់បញ្ញត្តិភូមិសាស្ត្រ ដូចជា ៖ ទន្លេ, សមុទ្រ, ព្រៃ, ភ្នំ បង្ហាញថា កន្លែងទាំងនោះ ត្រូវគេចាត់ទុកថា មានបន្សុំជាមួយពាក្យដែលសំគាល់ជាមួយពាក្យផ្សេងៗ នៃខ្លួនមនុស្ស ៖ ដៃ, មាត់ ( ជាមួយទន្លេ, សមុទ្រ, ព្រៃ ) ជើង, ចង្កេះ, ច្រមុះ, ខ្នង ( ជាមួយភ្នំ ) ។

ហេតុពិតនៃបុគ្គលនិយកម្ម ការធ្វើអោយចលនាដល់វត្ថុគ្មានជីវិត ដោយវិធីប្រៀបធៀបន័យ អាចផ្ដល់នូវរូបភាពពិភពជុំវិញខ្លួន ក្នុងបញ្ញារបស់ប្រជាជនដែលជាម្ចាស់ភាសា ។

## ការឆ្លងកាត់បន្តិចម្ដងៗ ពីការប្រៀបធៀបន័យអង់ត្រូប៉ូម័រហ្វ ទៅជាសំនួនសំដីប្រៀបធៀបន័យ

ពាក្យអាចមានលក្ខណៈពហុន័យ ដោយការពង្រីកន័យដើមក្នុងលំនាំនៃហេតុកម្មប្រៀបធៀបន័យ ។

សរីរាង្គ និងផ្នែកផ្សេងៗ នៃរាងកាយមនុស្សដែលមានតួនាទីជាវត្ថុវិស័យក្នុងបណ្ដុំអារម្មណ៍ មានបំលែងសេម៉ង់ទិកបន្តិចម្ដងៗ ។ ពេលដែលបំលែងសេម៉ង់-ទិករបស់ន័យដើមឡើងដល់កម្រិតខ្ពស់ គឺបានសេចក្ដីថា ពេលដែលគម្លាតរវាងន័យរបស់វត្ថុវិស័យនៃបណ្ដុំអារម្មណ៍ និងពាក្យថ្មីដែលកើតឡើងពីហេតុកម្មនៃការប្រៀបធៀបន័យ មានកាន់តែខ្លាំង ពេលនោះ « បន្ទុះសេម៉ង់ទិក » កកើតឡើង ឬនិយាយបានម្យ៉ាងទៀតថា ន័យដើមនៃពាក្យរូបិយ ត្រូវគេបំភ្លេច ហើយនៅទី

បំផុតនៅសល់តែត្រឹមគំនិតរូបិយ ផ្នកដាននៃឈ្មោះសរីរាង្គផ្សេងៗនៃរាងកាយមនុស្សបន្តិចបន្តួចប៉ុណ្ណោះ ។ ចាប់ពីពេលនោះមក ឈ្មោះនៃសរីរាង្គ និងផ្នែកផ្សេងៗនៃរាងកាយនៃមនុស្សនីមួយៗ ក្លាយទៅជាធាតុនៃពាក្យផ្សំ និងសំនួនសំដីប្រៀបធៀបន័យ ហើយឈប់បន្ទុកន័យត្រង់ៗរបស់ខ្លួនទៀតហើយ ។

ឧទាហរណ៍ ៖ ដៃជើង, មុខមាត់, ភ្នែកច្រមុះ, ជើងឯក, ថ្លើមខ្មៅ, ថ្លើមធំ, ដៃដល់, មាត់រឹង, មុខក្រាស់, ត្រចៀកស្រាល, ចូលដៃ, លើកជើង, ពើងទ្រូង, ចំណាងជើង, គ្មានខួរ, ពោះវៀនមិនត្រង់ ... ។ ល ។

បន្ទាប់មកទៀត ពេលដែលន័យដើមរបស់ឈ្មោះសរីរាង្គ និងផ្នែកផ្សេងៗនៃរាងកាយ មានបម្រែបម្រួលក្នុងការប្រើប្រាស់ និងក្រោយមកទៀត ត្រូវគេបំភ្លេចទាំងស្រុង ពេលនោះ ពាក្យទាំងនោះក្លាយទៅជាពាក្យ « ប្រហោងក្នុង » ឬពាក្យអស់ន័យ ហើយតមក ក៏បានឆ្លងកាត់ពីក្រុមពាក្យដែលមានន័យពេញលេញទៅកាន់ក្រុម ម័រហ្វែម ឬក្រុមពាក្យរនាប់ ( mots classifications ) ។

ឧទាហរណ៍ ៖

ខ្លួន ៖ ១. មានន័យថា រាងកាយ

២. ជាម័រហ្វែម ដែលមានតួនាទីសំរាប់បង្កើតកិរិយាស័ព្ទឆ្លុះ ឬចម្លុះកម្ម ( reflechi ) ។ ឧទាហរណ៍ ៖ សម្លាប់ខ្លួន, ធ្វើទុក្ខខ្លួន ក្នុងកាលៈទេសៈខ្លះ ខ្លួន « អា » ចូលជាសមាសភាពជាមួយ « ឯ » ហើយកើតបានជា « ខ្លួនឯង » ។

ក្បាល ៖ ១. ក្បាល

២. ពាក្យរនាប់សំរាប់រាប់សត្វ

មុខ ៖ ១. មុខ

២. ពាក្យរនាប់សំរាប់រាប់មុខម្ហូប, វិញ្ញាសា ។

ឧទាហរណ៍ : មុខវិជ្ជា, ម្ហូបអាហារច្រើនមុខ ។

ខ្នង : ១. ខ្នង

២. ពាក្យរនាប់សំរាប់រាប់អគារ

ឧទាហរណ៍ : សាលាពីរខ្នង, អគារបួនខ្នង, ផ្ទះឈើបីខ្នង ។

## ហេតុកម្មបានពីការប្រៀបធៀបន័យ នៅក្នុងឈ្មោះសត្វ

នៅក្នុងផ្នែកដែលឧទ្ទិសចំពោះការដាក់ផ្នត់ ( alfixation ) យើងបានវិភាគលើការបង្កើតពាក្យដែលជាឈ្មោះសត្វ និងរុក្ខជាតិ ចេញពីកិរិយាស័ព្ទ និងពាក្យត្រាប់ ( onomatopée ) ។ ការបង្កើតពាក្យបែបនេះ អាចប្រព្រឹត្តទៅបានតាមវិធីពីរយ៉ាង :

. វិធីរូបស័ព្ទ

. វិធីសេម៉ង់ទិក

យើងនឹងវិភាគហេតុកម្មបានពីការប្រៀបធៀបន័យក្នុងការបង្កើតពាក្យដែលមានឈ្មោះសត្វមួយចំនួន :

កុក : នៅស្ងៀមដោយមិនឱនមុខចុះ

កុក : សត្វ ( ពាក្យបង្កើតឡើងតាមបណ្តុំអារម្មណ៍ ដោយប្រៀបធៀបទៅនឹងឥរិយាបថនៃសត្វកុកនេះ ដែលឈរទម្លាក់ចំពុះរង់ចាំចំណី ) ។

ប្រុក : ពាក្យត្រាប់តាមសូរ ដែលកើតឡើងដោយការរត់ចូលព្រៃ នៃសត្វតូចៗ ។

កំប្រុក : (ឈ្មោះសត្វ) ( ពាក្យដែលបង្កើតឡើងពាក្យត្រាប់ « ប្រុក »

ដោយដាកផ្ទត់ដើម « កំ » ។

កញ្ជ្រោង : « លោតសង្រ្កុប »

កញ្ជ្រោង : ( ឈ្មោះសត្វ ) ( ពាក្យដែលបង្កើតឡើងដោយបំលែងរូបស័ព្ទពីកិរិយាស័ព្ទ ទៅនាមស័ព្ទ តាមដំណូចចលនានៃកិរិយាស័ព្ទនេះ ) ។

ពាក្យឈ្មោះសត្វមួយចំនួន គឺជាពាក្យទោល ។ រចនាសម្ពន្ធរបស់ពាក្យទាំងនេះ ផ្តល់លទ្ធភាពអោយគេរកឃើញឈ្មោះអំបូរនៃប្រភេទនីមួយៗរបស់សត្វ ។ ពាក្យ « ត្រី » គឺសំដៅយកត្រីទូទៅ ហើយអាចចាត់ទុកថាជាឈ្មោះអំបូរ គឺបានសេចក្តីថា ក្នុងការសំគាល់ប្រភេទផ្សេងៗនៃត្រី ពាក្យ « ត្រី » មានតួនាទីជាពាក្យចំណាត់ថ្នាក់តាមឧទាហរណ៍នៅក្នុងពាក្យ « ត្រី » គេអាចបង្ហាញថា អំបូរសត្វនិមួយៗ ដូចជាបក្សី, សត្វល្អិត និងរុក្ខជាតិ តាងដោយពាក្យទោល រីឯប្រភេទនីមួយៗវិញ តាងដោយពាក្យផ្សំដែលមានពីរផ្នែក ។ ផ្នែកទីមួយ គឺជាឈ្មោះនៃអំបូរ រីឯទីពីរវិញ គឺជាឈ្មោះនៃប្រភេទ ។ វិភាគអំពីត្រីក្នុងឈ្មោះ « ត្រីក្អែក » ។ ផ្នែកទី ១ គឺសំគាល់អំបូរ « ត្រី » ផ្នែកទី ២ គឺសំគាល់ពាក្យ « ក្អែក » គេប្រើក្នុងការប្រដូចលក្ខណរូបរបស់សត្វក្អែក គឺសំបុរ « ខ្មៅ » ។ ហេតុកម្មនៃពាក្យត្រីក្អែកអាចតាងដោយគំនូសបំព្រួញ ដូចតទៅ :




វិភាគរូបារម្មណ៍នីយកម្មបានពីការប្រៀបធៀបន័យ ក្នុងការដាក់ឈ្មោះ

ប្រភេទសត្វខ្លះៗ :

១. ឈ្មោះសត្វដែលគេហៅទៅតាមដំណូច ក្នុងបែបផែនចំណី : ខ្លាឃ្មុំ, ខ្លាត្រី, ក្អែកកូនមាន់, ពស់កង្កែប ។

២. ឈ្មោះសត្វដែលគេហៅទៅតាមដំណូច ក្នុងបែបផែនជីវភាព : មាន់ទឹក, ជ្រូកព្រៃ, ឈ្លើងសមុទ្រ, ពស់វែករនាម ។

៣. ឈ្មោះសត្វដែលគេហៅទៅតាមដំណូចរូបរាងខាងក្រៅ : ឈ្លើងក្របី, ខ្យងដៃខ្លា ( ផ្កាយសមុទ្រ ), ស្វាព្រាហ្មណ៍ ។

យើងអាចធ្វើកំណត់សំគាល់ ដូចតទៅ :

. នៅក្នុងក្រុម ១ មានស័ព្ទដែលជាឈ្មោះសត្វតូចៗ ដូចជា ត្រី, សត្វល្អិតជាដើម គេប្រើជាធាតុផ្សំសំរាប់បង្កើតឈ្មោះសត្វដែលធំជាងគេ ។

. នៅក្នុងក្រុម ២ នាមស័ព្ទសំរាប់ហៅឈ្មោះធម្មជាតិ ( ព្រៃ, ទឹក, សមុទ្រ ) គេប្រើជាធាតុដំបូងសំរាប់បង្កើតឈ្មោះសត្វ ដែលខុសគ្នាតាមបែបផែនជីវភាព ហើយក្នុងករណីភាគច្រើន គេតែងជួបប្រទះនូវការប្រឈមរវាង :

« ព្រៃ » . « ព្រៃ » , « ព្រៃ » និង « ស្រុក »

ព្រៃ . ព្រៃឈើ, ព្រៃដែលគេមិនដាំ ឬ ចិញ្ចឹមក្នុងស្រុក, « ស្រុក » . ដែលគេដាំ ឬចិញ្ចឹមក្នុងស្រុក ។

ស្រុក . ដែលគេដាំ ឬ ចិញ្ចឹមក្នុងស្រុក (សំរាប់សត្វជើងបួន) សមុទ្រ . « សមុទ្រ » និង « ទន្លេ », « ទន្លេ » និង « ស្រែ » (សំរាប់សត្វ និងសប្បីសត្វ)

. នៅក្នុងក្រុម ៣ នាមស័ព្ទសំរាប់ហៅមនុស្ស ផ្នែកផ្សេងៗ នៃរាងកាយសត្វធំ ( ដំរី, ខ្លា ) គេប្រើជាធាតុផ្សំសំរាប់បង្កើតសត្វមានមាឌមធ្យម ឬតូច ។

ដូចនេះ បែបផែនចំណី បែបផែនជីវភាព ជាញឹកញាប់ណាស់ ត្រូវគេយកជាមូលដ្ឋានក្នុងការដាក់ឈ្មោះអោយវា ។

## បរូបារម្មណ៍ ឬការប្រៀបធៀបន័យ

## តាមលក្ខណៈរបស់សត្វ ( métaphores zoomorphique )

ការប្រៀបធៀបន័យតាមលក្ខណៈរបស់សត្វ កើតឡើងដោយវិធីប្រៀបប្រដូចសត្វមកជាមួយមនុស្ស ។ ដូចជាសត្វអាចអោយគេនឹកឃើញដល់មនុស្សដោយសារចរិត និងរូបរាងខាងក្រៅរបស់វា ។

តាមប្រភពរបស់វា ពាក្យប្រៀបធៀបន័យទាំងនេះ ចែកជាពីរក្រុម :

ក. យកពីរឿងព្រេងបុរាណ, ល្បើក :

- ក្ងោកមាស : ( ស្រីក្ងោកមាស ), ខ្លា ( មនុស្សខ្លាំងពូកែ ឬមនុស្សមានអំណាច តែប្រាជ្ញាអន់ )
- ទន្សាយ : ( អ្នកឆ្លាត )
- មេអំបៅ : ( ស្រីតែងខ្លួនហ៊ឺហា ឬអ្នកភ្លេចកំណើតខ្លួន )
- កង្កែប : ( អ្នកអួតអាង ឬអ្នកមិនចេះគិតវែងឆ្ងាយ )
- អកញ្ញី : ( ប្រពន្ធមានចិត្តស្មោះ ប្រៀបធៀបទៅតាម ដែលពេលណាដែលគេសម្លាប់អកឈ្មោលជាគូ អកញ្ញី ក៏សម្លាប់ខ្លួនដែរ ) ។

ខ. យកទៅតាមប្រភព ( ដើមកំណើត ) :

- ដំរី ( មនុស្សមានមាឌធំ មនុស្សមានមាឌមាំ )
- ជ្រូក : ( មនុស្សខ្ជិល និងកខ្វក់ )
- ក្របី : ( មនុស្សខ្លាំងក្លាដោយកម្លាំង )
- កុក : ( មនុស្សស្គម, ខ្ពស់ )
- ទា : ( មនុស្សពូជទាប )
- ស្វា : ( មនុស្សឡេបឡប )

. ក្អែក : ( មនុស្សចិត្តអាក្រក់ )

. មៀម : ( មនុស្សមានមុខអាក្រក់ )

. អំពិលអំពែក : ( មនុស្សចិត្តមិនទៀង មិនប្រាកដប្រជា )

. ចៃ : ( មនុស្សរស់នៅពឹងផ្អែកលើអ្នកដទៃ )

. ឈ្លើង : ( អ្នកជិះជាន់គេ មនុស្សបរាសិត )

. ក្អាត់ : ( មនុស្សអួតអាង )

សត្វធំៗ គេប្រៀបធៀបទៅនឹងមនុស្សមាឌធំ ឬមានឋានៈខ្ពស់ ។ រីឯសត្វតូចៗ គេប្រៀបធៀបទៅនឹងមនុស្សមាឌតូច ឬមានឋានៈទាប ។

នៅក្នុងករណីភាគច្រើន ការប្រៀបធៀបន័យតាមលក្ខណៈរបស់សត្វមានលក្ខណៈចំអក ឬអវិជ្ជមាន ។

ឧទាហរណ៍ : នៅក្នុងពាក្យប្រៀបធៀបនៅក្នុងរឿងព្រេង សត្វធំៗ គេប្រៀបធៀបទៅនឹងមនុស្សខ្លាំងពូកែ តែប្រាជ្ញអន់ ។

## រូបារម្មណ៍នីយកម្ម និង ប្រព័ន្ធហៅឈ្មោះរុក្ខជាតិ

រូបារម្មណ៍នីយកម្មបានពីការប្រៀបធៀបន័យក្នុងឈ្មោះរុក្ខជាតិ ក៏ឈរលើគោលការណ៍ ដូចគ្នានឹងករណីឈ្មោះសត្វដែរ ។ ប៉ុន្តែ យើងគ្រាន់តែចង់បញ្ជាក់ថា ក្នុងការបង្កើតឈ្មោះរុក្ខជាតិ រូបារម្មណ៍នៃហេតុកម្មបានពីការប្រៀបធៀបន័យមានច្រើនបែបយ៉ាងណាស់ : គឺវាពឹងផ្អែកលើភាពដំណូចតាមរូបរាងខាងក្រៅ ( ទម្រង់ សំបុរ ) តាមក្លិន, រសជាតិ, តួនាទី, គោលដៅ, លក្ខណៈ ( នៃការលូតលាស់ ) និងជាញឹកញាប់ ផ្សារភ្ជាប់ទៅនឹងជំនឿរបស់ប្រជាជន ។

១. ឈ្មោះរុក្ខជាតិកើតឡើងទៅតាមដំណូចរូបរាងខាងក្រៅ ( ទម្រង់,

សំបុរ ) :

សំរាប់ហេតុកម្មនេះ (motivation métaphorique) មានលក្ខណៈត្រង់ថាឈ្មោះផ្សេងៗ នៃរាងកាយសត្វ ជាទូទៅ គេប្រើជាពាក្យមូលដ្ឋាន ចំណាត់ថ្នាក់នៃវត្ថុវិស័យ « គោល » ។ ក្នុងតួនាទីជាពាក្យដំបូង គេប្រើជាញឹកញាប់នូវពាក្យដែលជាឈ្មោះ សំរាប់ចំណាត់ថ្នាក់ដូចតទៅ : ដើម, ស្មៅ, ផ្កា, ដំឡូង, វល្លិ៍ ។

នេះជាឧទាហរណ៍នៃឈ្មោះប្រៀបធៀបន័យរុក្ខជាតិ :

- ដើមស្វាយក្បាលដំរី : ( ប្រភេទមួយនៃរុក្ខជាតិ អំបូរស្វាយដែលអោយផ្លែ មានទំហំធំ និងមានទ្រង់ទ្រាយប្រហែលនឹងក្បាលដំរី ) ។
- ដើមចេកស្នែង : ( ប្រភេទមួយនៃរុក្ខជាតិចេកដែលអោយផ្លែ មានទ្រង់ទ្រាយប្រហែលស្នែងគោ ) ។
- ដំឡូងឈាមមាន់ : ( ប្រភេទដំឡូងម្យ៉ាង មានមើមពណ៌ក្រហមដូចជាឈាមមាន់ ) ។
- ដំឡូងដៃខ្លា : ( ប្រភេទដំឡូងម្យ៉ាងដុះក្នុងព្រៃ មានដើមសណ្ឋានដូចបាតដៃខ្លា ) ។
- ស្មៅអណ្តាតគោ : ( ស្មៅម្យ៉ាង មានស្លឹករឹងដូចអណ្តាតគោ ) ។

២. ឈ្មោះរុក្ខជាតិដែលកើតឡើងទៅតាមដំណួចក្លិន និងរសជាតិ :

- ដើមឈើផ្អែម : ( ឈើម្យ៉ាងដែលមើមរបស់វាមានរសជាតិផ្អែម albizzia myriophilla ) ។
- ដើមអាចម៍ត្អិះ ( រុក្ខជាតិម្យ៉ាងដែលគេយកទៅចម្រាញ់ធ្វើថ្នាំព្យាបាល, ពេលល្ងាច ផ្ការុក្ខជាតិនេះមានក្លិនស្អុយ ) ។
- ជីសង្កើច ( ជីម្យ៉ាងដែលគេប្រើប្រាស់សំរាប់បង់សម្លរ ) ។
- វល្លិ៍ផោម : ( វល្លិ៍ម្យ៉ាងមានក្លិនស្អុយ gentiana scendens) ។

៣. ឈ្មោះរុក្ខជាតិដែលកើតឡើងទៅតាមដំណូចមជ្ឈដ្ឋានជុំវិញ : ដំឡូងជ្វា, ដំឡូងបារាំង ។

ក្នុងហេតុកម្មដែលឈរលើដំណូចជាមួយមជ្ឈដ្ឋានជុំវិញ ចាំបាច់ត្រូវកត់សំគាល់ភាពឈមគ្នា រវាងពាក្យ « ស្រុក » ( ភូមិស្រុក ) និង « ស្រុក » ( ដាំ ឬដុះក្នុងស្រុក ) ពាក្យ « ព្រៃ » ( ព្រៃឈើ ) និង « ព្រៃ » ( ដុះនៅក្នុងព្រៃ ) :

- កន្ទួតស្រុក : ( phyllanthus acidus )
- កន្ទួតព្រៃ : ( phyllanthus emblica )

៤. ឈ្មោះរុក្ខជាតិដែលកើតឡើងទៅតាមដំណូចមុខងារ :

- វល្លិ៍ត្រី : ( វល្លិ៍ម្យ៉ាងសំរាប់ក្រងឧបករណ៍នេសាទ ) ។
- ប្រទាលពស់វែក : ( រុក្ខជាតិម្យ៉ាងសំរាប់ព្យាបាល ពេលពស់ចឹក ) ។

៥. ឈ្មោះរុក្ខជាតិដែលកើតឡើងទៅតាមជំនឿរបស់ប្រជាជន :

ក្នុងហេតុកម្មនេះ គេតែងប្រើពាក្យពីរគឺ « ព្រះ » និង « នាង » ។

ពាក្យ « ព្រះ » គេប្រើសំរាប់ហៅឈ្មោះរុក្ខជាតិ ដែលជាថ្នាំព្យាបាល ។ ការប្រើរបៀបនេះ អាចពន្យល់បានតាមជំនឿថា រុក្ខជាតិថ្នាំទាំងនេះ មានកម្លាំងដូចជាអាទិទេព ។

ឧទាហរណ៍ : ព្រះកម្ចាត់, ព្រះអង្គលំ, ព្រះថ្កោល ។

ពាក្យ « នាង » ប្រើសំរាប់ហៅឈ្មោះស្រូវប្រភេទផ្សេងៗ ។ ការពន្យល់អាចិកំបាំងនេះគឺដូច្នេះ : នៅប្រទេសកម្ពុជា ស្រូវ ( អង្ករ ) គឺជាស្បៀងសំរាប់ប្រជាជនកម្ពុជា ។ រីឯសាច់គឺជាអាហារបន្ទាប់បន្សំប៉ុណ្ណោះ ។ ប្រជាជនកម្ពុជា ចាត់ទុកថា ស្រូវ ( អង្ករ ) គឺជាជីវិតផ្ទាល់ ដូចជានៅក្នុងរឿងព្រេងខ្មែរបុរាណ គេប្រៀបធៀបស្រូវទៅនឹងម្តាយ « មេ » ។ អវតារស្រូវ គឺជាស្ត្រី ( ព្រះពៃស្រពណ៍ ) ។ នៅស្រុកស្រែ មានទំនៀមទម្លាប់មួយក្នុងការរំលឹកគុណព្រះពៃស្រពណ៍ គឺរៀងរាល់

ឆ្នាំ គេធ្វើពិធីបុណ្យមួយ ក្រោយពេលប្រមូលផល ។ ហេតុដូច្នេះហើយ ពាក្យ « នាង » ត្រូវបានជួបប្រទះក្នុងការប្រៀបធៀបន័យ របស់ឈ្មោះស្រូវ ព្រមទាំងការងារខ្លះ ដែលជាប់ទាក់ទងទៅនឹងការដាំដុះដំណាំស្រូវផងដែរ ។

នៅពេលស្រូវពេញជិតចេញផ្លែផ្កា មានសំនួនសំដីប្រៀបធៀបមួយចំនួន នៅតាមលក្ខណៈនៃទេវតាស្រូវ ឬ ស្ត្រី : ស្រូវធ្វើខ្លួន, ស្រូវពាក់ចិញ្ចៀន, ស្រូវផើម, ស្រូវដាក់ទឹកដោះ ។

តាមការស្រាវជ្រាវរបស់ E.P. Maspéro ស្រូវទាំងអស់មានចំនួន ៦៨ មុខ ។ ប្រភេទស្រូវនីមួយៗ ត្រូវមានឈ្មោះដោយការប្រៀបធៀប និង « លក្ខណៈរបស់ស្រូវ » ត្រូវបានគេរកឃើញនៅក្នុងឈ្មោះដ៏ច្រើនសន្ធឹកសន្ធាប់ ដែលនៅក្នុងនោះ មានពាក្យ « នាង » ។

ឧទាហរណ៍ : ស្រូវនាងមាស, ស្រូវនាងរាវ, ស្រូវនាងក្រូង, ស្រូវនាងឆ្មារ, ស្រូវនាងសក់ក្រអូប, ស្រូវនាងខ្មៅ, ... ។

បញ្ហាប្រភពនៃការប្រើប្រាស់ពាក្យ « នាង » ក្នុងពាក្យផ្សំផ្សេងទៀត ដែលមានន័យប្រៀបធៀបដែរ គឺថា ឈ្មោះរុក្ខជាតិផ្សេងទៀត ដូចជាឈើនាងនួន, ចេកនាងនួន, ជីរនាងវង មិនទាន់ដោះស្រាយនៅឡើយទេ ។

ឈរលើមូលដ្ឋាននៃពាក្យ « នាង » ដែលមានន័យដើម « ស្ត្រី » « នារី » គេឃើញវត្តមានឯកតាវចនស័ព្ទថ្មីៗជាច្រើន ដែលមានន័យរួម « អ្វីដែលល្អ » « សំខាន់ » « សោភ័ណ » « ចាំបាច់ » ។

ការសិក្សាពីហេតុកម្ម ដែលបានពីការប្រៀបធៀបន័យ ដែលរៀបរាប់មកខាងលើ គឺអំពីបញ្ហា :

- ការបង្កើតឈ្មោះសរីរាង្គ និងផ្នែកផ្សេងៗ នៃរាងកាយមនុស្ស ។
- ការប្រើប្រាស់ឈ្មោះផ្នែកផ្សេងៗ នៃរាងកាយមនុស្សដើម្បីដាក់ឈ្មោះ

វត្ថុ ។

- ការប្រើប្រាស់ឈ្មោះវត្ថុ ក្នុងការដាក់ឈ្មោះសត្វ ។

- ការប្រើប្រាស់ឈ្មោះផ្នែកផ្សេងៗនៃរាងកាយ ដើម្បីដាក់ឈ្មោះរុក្ខជាតិ

ការសិក្សាស្រាវជ្រាវអំពីការប្រៀបធៀប នៅមិនទាន់គ្រប់គ្រាន់ទេ គឺនៅរង់ចាំអ្នកសិក្សាស្រាវជ្រាវថ្មី ជួយបន្តការងារនេះ ។

កិច្ចការស្រាវជ្រាវនេះ ផ្តល់ត្រឹមតែគំនិតរួមអំពីលក្ខណៈពិសេស នៃការបង្កើតពាក្យខ្មែរមួយចំនួនប៉ុណ្ណោះ ។ វិធីដែលរៀបរាប់រួចមកហើយនេះ គឺមានជាយូរយារណាស់មកហើយ ប៉ុន្តែវិធីទាំងនេះ គេនៅតែប្រើប្រាស់រហូតដល់សព្វថ្ងៃ ។

ឧទាហរណ៍ ៖ ពាក្យ « ក្បាលមាន់ » ទើបកើតមានមិនជាយូរប៉ុន្មានទេ ។ មួយវិញទៀត មានបញ្ហាចោទឡើងថា តើឯកតាសេម៉ង់ទិកជាក់ស្តែងណាខ្លះ ដែលកើតឡើងដោយធាតុងាយដំបូងៗ សំរាប់ហៅឈ្មោះសរីរាង្គ និងផ្នែកផ្សេងៗនៃរាងកាយមនុស្ស នៅក្នុងការបង្កើតពាក្យសមាស ។

បញ្ហានេះ អាចដោះស្រាយបាន លុះត្រាតែគេសិក្សាស៊ីជម្រៅអំពីប្រព័ន្ធវចនស័ព្ទ និងសេម៉ង់ទិកក្នុងភាសាទាំងមូល ជាពិសេស អំពីបច្ចេកពាក្យសត្វវិទ្យា និងរុក្ខវិទ្យា ដែលគេប្រើយ៉ាងទូលំទូលាយក្នុងការដាក់ឈ្មោះវត្ថុ ឬជាតុភូតដែលនៅជុំវិញខ្លួនយើង ។

•••

## OREFERENCES

Coedès, G. 1924a, Recueil des Iscriptions du Siam, première partie :

Inscriptions de Sukhodaya, Bangkok.

Coedès, G. 1924b, " Etudes Cambodgiènnes, 17, L'épigraphie du temple de Bhimai " *BEFEO*, 24, 3-4 : 348

Coedès, G. Inscriptions du Cambodge, vol. 1 (1937), vol. 2 (1942), vol. 3 (1951), vol. 4 (1952), vol. 5 (1942), vol. 6 (1954), vol. 7 (1964) Hanoi, Paris.

Finot-Louis. *Inscriptions du Cambodge* publiées sous les auspices de l'Académie des Inscriptions et Belles-Lettre, tome I (1926), tome II (1926), tome III (1927), tome IV (1928), tome V (1931), tome VI (1937).

Gorgoniev, Y.A. 1939 *Recherches sur la grammaire de la langue Khmère* (en russe), thèse de doctorat ès sciences philologiques, institut des Etudes Orientals de l'Académie des Sciences de L'URSS, Moscou.

Hodson, C. 1913, " Notes on the numeral system of the Tibeto-Burmanese dialects ", *JRAS* 4.2 : 315-36.

Genner, Phillip N. 1969. *Affixation in Modern Khmer,* thèse doctorat, Department of Linguisstics, University of Hawaii.

Genner, Phillip N. 1974 " Les noms de nombre en Khmer, " JA, 262. 1-2 : 171-91

Long Seam. 1977. " A propos des anthroponymes dans les Inscriptions du Cambodge (VIème-XIIIèmes), " *peuples d'Asie et d'Affrique,* 3 : 111- 9 Mon-Khmer studies 20

Maspéro, H.1915. Grammaire de langue Khmère (Cambodgien) Paris.

Maspéro, H.1952. " Les langues mon-khmer ", les langues du monde, Paris.

Pinnow, H.-J. 1965. " Personal pronouns in the Astroasiatic languages : a historical study, " Lingua 14 : 3-42.

Sapir, E. [1925]. Le language, Paris, 1968.

Saveros Pou. 1978. " Inscriptions dite de Brai Svay [Bois des Manguiers de Sukhoday], *BEFEO,* 115 : 33-59.

Saveros Pou. 1979. " Une description de la phrase en vieux-khmer ", *MKS* 8 : 139-69.

Saveros Lewitz. 1971. " Inscriptions modernes d'Angkor 4, 5, 6 et 7 ", *BEFEO,* 58 : 105-23.

Schmidt, W. 1907-08. " Les peuples mon-khmers, trait-d'union entre les peuples de l'Asie centrale et de l'Austronésie ", *BEFEO,* 7 : 213-63, 8 : 1-35.

Shorto, H.L. 1956. " Notes on Mon Epigraphy ", *BSOAS,* 18. 2 : 344-52.

***

# កតញ្ញុតា

## ភាវៈនៃអ្នកដឹងគុណ

បទកាកគតិ

*កតញ្ញុតា មានន័យប្រាប់ថា ជនកតញ្ញូ ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះជាគ្រូ ប្រាប់ឱ្យតបគុណ ។ មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ ត្រូវតែសាបព្រោះ ។ បណ្តុះពូជបុណ្យ ក្នុងស្រែជាគុណ កុំឱ្យមានមោះ បុណ្យនឹងកើតកើន ចម្រើនឥតខ្ចោះ ត្រូវមានចិត្តស្មោះ កុំលុបគុណចោល ។ កុំគ្រាន់តែថា មាតាបិតា មានគុណជាគោល មាត់ថាត្រូវតប- គុណកុំច្បោល១ ធ្វើដែរស្រោល១ សោះតែគេថា ។ ជនអ្នកតបគុណ ព្រះពុទ្ធមានបុណ្យ ទ្រង់ត្រាស់ទេស្នា សរសើរញីកញយ មានក្នុងសាស្ត្រា គម្ពីរដីកា គួរយើងចងចាំ ។ ចេះចាំហើយធ្វើ ដោយចិត្តអើពើ ឱ្យស៊ប់ឱ្យស៊ាំ ឱ្យស្និទ្ធនឹងគុណ គុណតែងថែទាំ ពុំមែនខ្ចៃខ្ចាំ ព្រោះតបគុណទេ ។ ជនមានចិត្តខ្សោយ ច្រើនតែធ្វេសធ្លោយ រមិលគុណគេ អាងព្រេងសំណាង ពីក្នុងបុព្វេ ប្រហែសធ្វេសទ្វេ ព្រងើយកន្តើយ ។ អ្នកប្រាជ្ញប្រាប់ថា ជនប្រុសស្រីណា លុបគុណចោលហើយ ជនប្រុសស្រីនោះ ពុំមានសុខស្បើយ យូរប៉ុន្មានឡើយ វិវង់តែធ្លាក់ខ្លួន ។ កំពុងបានសុខ ស្រាប់តែមានទុក្ខ ចេញមុខផ្ទួន១ ឱ្យផលកំណាច ឃោរឃៅឥតសួន ទោសមកពីខ្លួន រមិលគុណគេ ។ ទេព្តាគេខឹង ព្រោះខ្លួនរឹងត្អឹង អាងបុណ្យបុព្វេ ទោសបច្ចុប្បន្ន ជិះជាន់ឥតល្ហែ ភ័ព្វព្រេងបុព្វេ បើមានក៏ផ្អាក ។ ទោសរមិលគុណ រារាំងមុខបុណ្យ- ព្រេងឱ្យសម្រាក បង្អង់ឃប់សិន ជាបថ្មីវិបាក ឱ្យផលឥតស្រាក ព្រោះ*

បានឱកាស ។ បុណ្យបាបចាស់ថ្មី តែងតែរំពៃ ពុំមែនផ្ដេសផ្ដាស ត្រូវពេលសស្រោស ហាក់ដូចប្រកាស ប្រាប់ថាត្រូវអញ ។ ចេញមុខផ្ដល់ផល សុខទុក្ខឱ្យដល់ជនដែល កកាញ់ កសាងបង្កើត កំណើតជាអញ អញជាសម្លាញ់ ត្រូវអញឱ្យផល ។ រីបុណ្យ ឬបាប ដែលមានសភាព ជាកម្មតែងផ្ដល់សុខទុក្ខឱ្យជនអ្នកធ្វើឱ្យដល់ នូវក្ដីសល់វល់ ឬក្ដីសុខសាន្ត ។ បាបតែងរារាំងបុណ្យឱ្យនៅតាំងផ្អាកសិនពុំបាន ចេញមុខឱ្យផល ជាសុខសម្រាន្ត អ្នកធ្វើតែងបានទទួលរងទុក្ខ ។ បុណ្យក៏រារាំង បាបឱ្យនៅតាំង ផ្អាកពុំចេញមុខ ព្រោះមានឱកាសបុណ្យផ្ដល់ក្ដីសុខ សុទ្ធតែមានមុខ ទីទៃពីគ្នា ។ ហេតុនោះគួរជន កុំនៅទម្រន់ក្នុងក្ដីខ្ជិលខ្ជាគួរកសាងបុណ្យ មានគុណមហិមា ទើបបានឈ្មោះថាអ្នកស្រឡាញ់ខ្លួន ៕

***

## អកតញ្ញូឥតគ្រប្រដៅកើត

អកតញ្ញុស្ស បោសស្ស និច្ចំ វិវរទស្សិនោ
សព្វញ្ចេ បឋវី ទជ្ជា នេវ នំ អភិរាធយេ ។

បើទុកជាគេលើកយកផែនដីទាំងមូលឱ្យដល់ជនអកតញ្ញូ ជាអ្នកឃើញនូវចន្លោះទោសជានិច្ចកាលក៏ដោយ គេក៏ពុំអាចញ៉ាំងវាឱ្យរីករាយបានឡើយ ( ពីព្រោះវាចេះតែរាវរករឿងទោស ហាក់ដូចជាតបស្នងសងគុណវិញជានិច្ចនិរន្តរ៍ ) ។

# ពាក្យកាព្យឱ្យងាយចាំ

ពាក្យ ៧

*អកតញ្ញូលុបលាងគុណ យោរយៅជ្រុលស៊ុនឥតដឹងអ្វី*
*ទោះបីគេលើកយកផែនដី រដ្ឋរាជបុរីឱ្យក៏ដោយ ។*
*វាក៏ឥតនឹកគុណតិចតួច វាចេះតែដួចរករឿងញយ*
*ព្យាបាទផ្គួនាពុំថយក្រោយ វាឱ្យទុក្ខព្រួយវិញតបគុណ ។*
*ព្រះពុទ្ធប្រាប់ថាជនចិត្តទ្រុស្ត វាកាន់ក្ដីខុសជ្រុលហួសស៊ុន*
*ឥតគ្រូប្រដៅឱ្យដឹងគុណ ទោះអ្នកមានបុណ្យក៏ទាល់ប្រាជ្ញ ។*
*ស្ដីថ្មីចម្ពោះជនល្ងង់ខ្លៅ ត្រូវពោលសំដៅជនអង់អាច*
*ដែលលើកវាឱ្យខ្ពស់ត្រដាច ក៏វាមិនខ្លាចតិចតួចឡើយ ។*

## សេចក្ដីបញ្ជាក់ថែម

កាលព្រះសក្យមុនីសម្ពុទ្ធព្រះអង្គចិតនៅជាពោធិសត្វ វិបត្តិកំណើតកើតជាដំរីព្រៃ មានភ្លុកទាំងពីរធំវែងទេរន្ទាំ ធន់ទ្រាំឱ្យព្រានព្រៃអារយកចុងភ្លុកទាំងពីរ ដោយខំប្រឹងធ្មេចភ្នែក ព្រានវាវែកយកចុងភ្លុកនោះទៅ . លុះគ្រាទីពីរ ដំរីក៏ទ្រាំឱ្យវាអារភ្លុកបន្ថែមកទៀត . ក្នុងគ្រាចុងក្រោយបំផុត, ព្រានអកតញ្ញូកំណាចចង្រៃនោះ វាវាយសំពងយកភ្លុកទាំងស្រុង ត្រាតែដំរីនោះស្រុត គឺផុតរលត់ក្ស័យជីវិតទៅ . ផ្ទៃផែនដី ដ៏ជ្រៅទ្រាំពុំបាន ក៏បែកសញ្ញែកហាស្រូបព្រានអកតញ្ញូយោរយៅនោះទៅ ។

ដោយហេតុនេះឯងបានជាព្រះសក្យមុនីសម្ពុទ្ធព្រះបរមសាស្ដាទ្រង់ត្រាស់ពន្យល់ថា *នេវ នំ អភិរាធយេ* ឥតអ្នកណាមួយអាចញ៉ាំងជនអកតញ្ញូនោះឱ្យរាវរីករាយ ( ចម្ពោះការទំនុកបម្រុងវានោះ ) បានឡើយ ។

## ពាក្យបរិយោសាន

*អកតញ្ញូ លុបលាងគុណគ្រូ មាតាបិតា ទោះបីវាទៅ នៅទ្វីងទីណា ឥតមានទេវតា ណាជួយវាឡើយ ។ ផលទោសអាក្រក់ យោយៅតក់ម៉ក់ តែង ផ្តល់បង្ហើយ ឱ្យវាលិចលង់ ភ័ន្តផុងឥតស្បើយ ឥតមានកោះត្រើយ ពឹងពួនជ្រក កោន ។ មានតែរងទុក្ខ គ្រប់បែបគ្រប់មុខ ខ្លួនវាក្រញោន ទុក្ខចាប់គ្រញិច ពត្រុន កំប្រោន ទីពឹងទីកោន នៃវាគឺទុក្ខ ។ គួរសាធុជន តាំងចិត្តឱ្យធ្ងន់ យកគុណជាសុខ កុំធ្វើលែនលន កុំស៊ីកគ្រលុក គុណជាជង្រុក នៃក្តីសុខសាន្ត ៕*

## មួយយ៉ាងថា

*អកតញ្ញូ ពុំនឹងគុណគ្រូ មាតាបិតា និងអ្នកមានគុណ ឯទៀតណាៗ ចិត្តវាហានក្លា រករឿងចាប់ទោស ។ ទោះអ្នកមានគុណ មានចិត្តជាបុណ្យ អត់ឱន សន្តោស សង្គ្រោះឱ្យវា រួចចាកទុក្ខទោស វានៅតែកោស- រូសរករឿងទៀត ។ ទោះលើកផែនដី ទាំមូលឱ្យក្តី វានៅតែឆ្លៀត រករឿងភាវិញ ដោយការជ្រែក ជ្រៀត នាំជនឯទៀត ឱ្យចូលដៃផង ។ នេះគឺជនពាល គំនិតរោលរាល អាក្រក់ កន្លង ទោះព្រះសមុទ្ទ វិសុទ្ធឥតហ្មង ក៏អាចចម្លង វាពុំបានឡើយ ៕*

វត្តឧណ្ណាលោម ក្រុងភំពេញ, ថ្ងៃពុធ ទី២៩ កក្កដា ២៥១២/១៩៦៨

សម្តេចព្រះសង្ឃរាជ ជ.ណ. (*) ជោតញ្ញាណោ

ប.អ.ស. - អ.ម.រ. (**)

(*) ជ.ណ. គឺ ជួន ណាត

(**) ប.អ.ស. គឺ បណ្ឌិតអក្សរសាស្ត្រ ; អ.ម.រ. គឺ អភិធជមហារដ្ឋគុរុ

# ទេវទត្ត គឺអ្នកណា ?

មានអ្នកប្រាជ្ញម្នាក់ បានធ្វើសេចក្តីពិនិត្យអំពីរឿងនេះ ហើយបានធ្វើសេចក្តីកត់ហេតុមួយដោយសង្ខេបដូច្នេះថា ៖

ព្រះទេវទត្តជាត្រកូលក្សត្រខត្តិយវង្ស រួមជាមួយនឹងព្រះពុទ្ធជាម្ចាស់ ។ លទ្ធិពុទ្ធសាសនាកើតឡើងបាន ២០ ឆ្នាំ ទើបលោកចូលបួសជាភិក្ខុ ។ លោកជាប់ជាព្រះញាតិនឹងព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់មិនបានហាមឃាត់ទេវទត្តដែលមានចិត្តគំនិតមិនពិតប្រាកដ មិនបរិបូណ៌ ដូចជាព្រះអង្គក្នុងការថែរក្សាវិនយបញ្ញត្តិ និងលទ្ធិសាសនា ។ ប៉ុន្តែ លោកមិនទាន់សំដែងអោយឃើញជាក់ស្តែងតាមគំនិតយោបល់ដែលប្លែកផ្សេងរបស់លោកទេ លុះ ១០ ឆ្នាំ មុនព្រះពុទ្ធបរិនិព្វាន ទើបលោកក្រាបទូលសុំព្រះបរមគ្រូ ដើម្បីកាន់ការត្រួតត្រាគណៈសង្ឃជំនួស តែរឿងនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ហាមឃាត់ ទើបលោកបង្កើតរបៀបសាសនាថ្មីមួយឡើង ។ ឯការសំខាន់ៗដែលគេបានឃើញស្នាមលំអានជាង ១.០០០ ឆ្នាំមកនោះ គ្រាន់តែមានពោលចេញឈ្មោះក្នុងរឿងរ៉ាវបុរាណនៃពុទ្ធសាសនា ។ គេមិនឃើញចេញឈ្មោះព្រះទេវទត្តក្នុងគម្ពីរសុត្តនិបាត ក្នុងគម្ពីរទីឃនិកាយក៏គ្មាន ។ ក្នុងបណ្ណាសកៈទាំង ៣ នៃសូត្រដទៃទៀត ក៏ចួនជាមានចេញឈ្មោះដល់ត្រង់ដែលនិយាយអំពីសា-កច្ឆាពីរបៀបសីលធម៌ ប៉ុន្តែ ក្នុងគម្ពីរវិន័យបាលីជាន់ចាស់ ដែលហៅថា វិភង្គវិន័យមានវគ្គ មួយនិយាយពីរឿងរ៉ាវព្រះទេវទត្តនៅចុងក្រោយបង្អស់ ។ ការពិនិត្យតាមមើលរឿងនេះ ចែកចេញជាបីផ្នែក គឺ ៖ តាមគម្ពីរវិន័យ, តាមរឿងរ៉ាវដែលប្រមូលពីក្នុងគម្ពីរចាស់ៗ, តាមសេចក្តីកត់ហេតុក្រោយៗមកទៀត ។

អំពីសេចក្តីប្រេះឆានៃគណៈ ដែលមានពោលទុកពិស្តារក្នុងខន្ធកៈ ១៨ នៃសុត្តវិភង្គនោះ មុនដំបូងនិយាយអំពីត្រកូលសក្យៈទាំង ៦ អង្គ ទ្រង់ចេញព្រះផ្នួស

ជាភិក្ខុ ដែលក្នុងចំនួននេះមានព្រះទេវទត្ត ១ អង្គផងដែរ ។ ឯក្សត្រទាំង ៥ អង្គ នោះ កាលទ្រង់ព្រះផ្នួសក្នុងព្រះសាសនាហើយ បំពេញព្យាយាមទៅ ក៏បានសំរេចគុណវិសេសក្នុងព្រះសាសនាទាំង ៥ អង្គ ឯព្រះទេវទត្តក៏បានសំរេចឫទ្ធិមួយយ៉ាងដែរ តែជាឈានលោកិយ ។

ក្នុងរឿងទី ១ និយាយថា ព្រះទេវទត្តរំពឹងពិចារណាស្វែងរកវិធីអោយបានផលប្រយោជន៍ និងកិត្តិយស ទើបលោកទៅបំភ័យព្រះរាជកុមារអជាតសត្រូវ ជាមកុដរាជកុមារនៃមគធរដ្ឋ ដោយអំណាចឫទ្ធិរបស់លោក ហើយព្រះរាជកុមារទទួលរាប់អាន ។ តែលោកនេះស្រវឹងនឹងលាភសក្ការៈដែលកើតឡើង ទើបរិះរកឧបាយចង់ធ្វើជាសាស្តាត្រួតត្រាគណៈសង្ឃ ព្រះពុទ្ធជាម្ចាស់ទ្រង់អោយព្រះមោគ្គល្លានត្ថេរចេញទៅក្រុងរាជគ្រឹះ ប្រាប់អោយទេវទត្តដឹងខ្លួនជាមុនអំពីលាភសក្ការៈរបស់ទេវទត្ត នាំអោយអន្តរាយដល់អាត្មា ។

ឯរឿងរ៉ាវទី ២ និយាយអំពីទេវទត្តក្រាបទូលសុំព្រះពុទ្ធជាម្ចាស់ អោយទ្រង់ប្រគល់គណៈសង្ឃមកខ្លួនត្រួតត្រា ព្រោះព្រះអង្គទ្រង់ជរាភាពណាស់ហើយ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់បដិសេធ ហើយទ្រង់ប្រកាសថា តាំងអំពីថ្ងៃនេះទៅ ទុកជាទេវ-ទត្តត្រូវការអ្វី ធ្វើអ្វី ស្រេចតែទេវទត្តចុះ គ្មានការរួបរួមជាមួយនឹងគណៈសង្ឃរបស់ព្រះអង្គទេ ។ តអំពីនោះមក ព្រះទេវទត្តពោលពន្យល់មកុដរាជកុមារអោយសម្លាប់ស្តេច ( បិតា ) រួចសឹមអោយជួយលោកសម្លាប់ព្រះពុទ្ធជាម្ចាស់ទៀតផង ។

តមកទៀត ព្រះទេវទត្តបានបញ្ញត្តច្បាប់យ៉ាងតឹងរ៉ឹងអំពីលំនៅ ( របស់ភិក្ខុ ) អំពីការទទួលនិមន្តន៍, អំពីអាហារភោជន ( ដែលមានត្រីសាច់ ) ព្រះពុទ្ធជាម្ចាស់ទ្រង់បដិសេធសេចក្តីបញ្ញត្តិរបស់ទេវទត្តទាំងអស់ ទើបទេវទត្តប្រកាសថា ព្រះបរមសាស្តា និងពួកសាវ័កប្រាថ្នាសេចក្តីសុខហ៊ឺហាណាស់ ហើយទេវទត្តបញ្ញត្តច្បាប់នេះឡើងតាមគំនិតរបស់ខ្លួន ហើយបបួលភិក្ខុក្មេងៗមួយពួកចំនួន ៥០០ រូប អោយ

(*) ក្សត្រទាំង ៦ អង្គគឺ : ភទ្ទិយ, អនុរុទ្ធ, ភគុ, កិម្ពិល, អានន្ទ, ទេវទត្ត ។

ប្រតិបត្តិតាម ។

ឯរឿងចុងបង្អស់និយាយថា ព្រះទេវទត្តចោមរោមដោយពួកសាវ័ក កំពុងសំដែងធម៌អោយពួកសាវ័កស្តាប់ ហើយបានអារាធនាព្រះសារីបុត្ត និងព្រះមោគ្គល្លាន អោយរួមទៅស្តាប់ធម៌ជាមួយនឹងគណៈសង្ឃនោះផង ។ សំដែងធម៌ដល់យប់ជ្រៅទៅ ក៏កាន់តែអស់កម្លាំងទៅ ទើបសុំអោយព្រះសារីបុត្តសំដែងធម៌ជំនួសខ្លួន ហើយសឹងលក់ទៅ ។ ព្រះសារីបុត្តបានចាត់ចែងធ្វើអោយភិក្ខុសង្ឃ ១ ភាគធំរបស់ព្រះទេវទត្តផ្លាស់ចិត្តគំនិត ត្រឡប់មកគាល់ព្រះពុទ្ធជាម្ចាស់វិញ ។

ក្នុងគម្ពីរមជ្ឈិមនិកាយ - សំយុត្តនិកាយ - អង្គុត្តរនិកាយ - ឧទាន - ឥតិវុត្តកៈ ក៏មានសេចក្តីនិយាយពីព្រះទេវទត្តដែរ នៅទីបំផុតក្នុងគម្ពីរក្រោយៗមកច្រើនមាននិយាយអំពីរឿងរ៉ាវព្រះទេវទត្ត កាន់តែញឹកញាប់ឡើង ជាប់នៅនឹងរឿងរ៉ាវផ្សេងៗ ជាច្រើន ។

ក្នុងគម្ពីរមហាវស្តុ និងគម្ពីរមហាវង្ស មានរឿងដំណាលប្លែកផ្សេងពីគ្នាអំពីពូជពង្សវង្សត្រកូលរបស់ទេវទត្ត ។ ក្នុងគម្ពីរមិលិន្ទបញ្ហា មានសេចក្តីដំណាលថាផែនដីស្រូបព្រះទេវទត្តចុះទៅ (នរក) ហើយក្នុងខណៈដែលនឹងស្លាប់នោះ ព្រះទេវ-ទត្តរលឹកដល់ព្រះពុទ្ធម្ចាស់ជាទីពឹង ។ កាលពី ព.ស ៩០០ មានអ្នកធុតង្គជាតិចិនម្នាក់ឈ្មោះ ហ្វា-ហៀន បានកត់ត្រាការដែលផែនដីស្រូបព្រះទេវទត្តនោះថា នៅមានរឿងនិយាយតៗគ្នាមកនៅឡើយក្នុងប្រទេសឥណ្ឌា ហើយក្នុងសម័យនោះសោតទៀត ក៏នៅមានពួកសាវ័ករបស់ព្រះទេវទត្ត ដែលគោរពនមស្សការព្រះពុទ្ធព្រះអង្គដែលកន្លងមកហើយ លើកលែងតែព្រះពុទ្ធគោតម ១ អង្គចេញ ។ ក្នុងព.ស ១១០០ មានអ្នកធុតង្គជាតិចិនម្នាក់ទៀត ទៅសំណាក់នៅក្នុងប្រទេសឥណ្ឌាដែរ ឈ្មោះ ហៀន ឆាង ក៏បានធ្វើសេចក្តីកត់ត្រាដូចគ្នានេះដែរ ។

( ពីកម្ពុជសុរិយា ឆ្នាំ ១៩៤១ ភាគទី ២៣ )

# សំដែងពីកិច្ចវត្ត គ្រប់អង្គខ្លះ ចំពោះបព្វជិតពុទ្ធសាសនិក

នៅតាមវត្តអារាមនីមួយៗ គេតែងសង្កេតមើលឃើញភិក្ខុទាំងឡាយ ធ្វើកិច្ចវត្តផ្សេងៗគ្នា អង្គខ្លះគក់បោកលាងស្បង់ចីពរ អង្គខ្លះជូតបាត្រ អង្គខ្លះកាត់ក្រចក អង្គខ្លះកោរព្រះកេសា អង្គខ្លះស្រង់ទឹកជម្រះរាងកាយ ជាដើម ។

កិច្ចវត្តអស់នេះ មានសេចក្តីពិស្តារក្នុងគម្ពីរចុឡវគ្គ វិន័យបិដកបាលិ-ខ្មែរ ភាគ ១០ និង ១១ ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពរួចហើយ ក្នុងទីនេះ យើងមិនបាច់ស្រង់យកសេចក្តីមកថ្លែងអោយសព្វគ្រប់ទេ គ្រាន់តែស្រង់យករឿងខ្លះ មកថ្លែងដើម្បីអោយយល់ដំណើរ និងហេតុផលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់បញ្ញត្តិ និងអនុញ្ញាត ដូចជា អនុញ្ញាតឈើស្ទន់ ហាមមិនអោយទុកសក់វែង និងក្រចកវែង ។

• ហេតុដែលទ្រង់អនុញ្ញាតឈើស្ទន់ (*)

ក្នុងសម័យនោះ ភិក្ខុទាំងឡាយមិនទំពាឈើស្ទន់ មាត់លោកក៏មានក្លិនស្អុយ ទើបនាំគ្នាក្រាបបង្គំទូលដំណើរនុ៎ះដល់ព្រះមានព្រះភាគ . ល . ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពាឈើស្ទន់នេះមាន ៥ ប្រការគឺ នាំអោយថយកម្លាំង ១ មាត់មានក្លិនស្អុយ ១ សរសៃសំរាបនាំអាហារមិនបរិសុទ្ធ ១ ប្រមាត់ និងស្លេស្មរួបរឹតបាយ ១ ភិក្ខុនោះឆាន់ចង្ហាន់មិនឆ្ងាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់មាន ៥ ប្រការគឺ នាំអោយមានកម្លាំងភ្នែក ១ មាត់មិនមានក្លិនស្អុយ ១ សរសៃសំរាប់នាំរសបរិសុទ្ធ ១ ប្រមាត់ និងស្លេស្មមិនរួបរឹត

(*) ប្រដាប់សំរាប់ដុសជម្រះធ្មេញ ។ ខ្មែរច្រើនប្រើវល្លិស្រស់ ឬមែកឈើស្រស់ ដែលមាន រសប្រហាត ឬស្វែងដូង ស្លាស្រស់ ក៏ប្រើ ។

បាយ ១ ភិក្ខុនោះឆាន់ចង្ហាន់ឆ្ងាញ់ ១ ( ហេតុនេះ ) ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឈើស្ទន់ ។

• ហេតុដែលទ្រង់ហាមមិនអោយទុកសក់វែង

ក្នុងសម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទុកសក់វែង មនុស្សទាំងឡាយបាន ឃើញ ក៏នាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុអស់នេះទុកសក់វែងដូច ពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលពាក្យតិះ ដៀលដូច្នោះ ក៏នាំគ្នាយកសេចក្តីនុ៎ះក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកសក់វែងទេ ភិក្ខុណាទុកសក់វែង ត្រូវ អាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអោយទុកសក់កំណត់កាលត្រឹម ពីរខែ ឬកំណាត់ត្រឹមពីរធ្នាប់ ។

តមក ពួកឆព្វគ្គិយភិក្ខុសិតសក់ដោយស្និត សិតសក់ដោយក្រាស ជ្រងសក់ ដោយម្រាមដៃ លាបសក់ដោយក្រមួន និងប្រេង ។ មនុស្សទាំងឡាយក៏ពោលទោស ដូចមុនទៀត ទើបភិក្ខុទាំងឡាយក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសិតសក់ដោយស្និត មិនត្រូវសិតសក់ដោយ ក្រាស មិនត្រូវជ្រងសក់ដោយដៃធ្វើជាក្រាស មិនត្រូវលាបដោយក្រមួន និងប្រេង ទេ ភិក្ខុណាសិត ( ឬលាប ) ត្រូវអាបត្តិទុក្កដ ។

• ហេតុដែលទ្រង់ហាមមិនអោយទុកក្រចកវែង

មានសេចក្តីដំណាលថា សម័យនោះឯង មានភិក្ខុ ១ រូប ទុកក្រចកវែង ដើរទៅបិណ្ឌបាត មានស្រីម្នាក់ឃើញលោកនោះហើយនិយាយដូច្នេះថា បពិត្រ លោកដ៏ចំរើន សូមលោកនិមន្តមកសេពមេថុនធម្មនឹងខ្ញុំចុះ ។ ភិក្ខុនោះពោលឃាត់

ថា នែនាង កុំឡើយ អំពើនេះមិនសមគួរទេ ។ ស្រីនោះនិយាយទៀតថា បពិត្រលោកដ៏ចំរើន បើលោកមិនសេពទេ ខ្ញុំនឹងខ្វាំក្រចៅខ្លួនខ្ញុំដោយក្រចករបស់ខ្ញុំ ហើយនឹងស្រែកថា ភិក្ខុនេះធ្វើវិប្បការដល់ខ្ញុំ ។ ភិក្ខុនោះក៏និយាយបណ្ដោយថា តាមចិត្តនាងចុះ ។ ទើបស្រីនោះខ្វាំក្រចៅរាងកាយខ្លួនដោយក្រចកខ្លួន ហើយស្រែកថា ភិក្ខុភិក្ខុនេះធ្វើវិប្បការដល់ខ្ញុំ ។ មនុស្សទាំងឡាយក៏ស្ទុះទៅចាប់ភិក្ខុនោះ ហើយបែរជាបានឃើញស្បែកឈាមជាប់នឹងក្រចកស្រីនោះវិញ ទើបយល់ច្បាស់ថា ភិក្ខុនេះមិនបានធ្វើកម្មនេះដល់ស្រីនោះទេ ហើយក៏លែងភិក្ខុនោះទៅ ។ ភិក្ខុនោះ លុះត្រឡប់ទៅអារាម ទើបប្រាប់ដំណើរនោះដល់ភិក្ខុផងគ្នា ។ ភិក្ខុទាំងឡាយក៏សួរថា ម្នាលអាវុសោ ចុះលោកទុកក្រចកវែងឬ ? ភិក្ខុនោះប្រាប់ថា អើអាវុសោ ។ ភិក្ខុអស់នោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុទុកក្រចកវែងសោះ ទើបនាំគ្នាក្រាបបង្គំទូលដំណើរនោះដល់ព្រះដ៏មានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទុកក្រចកវែងទេ ភិក្ខុណាទុក ត្រូវអាបត្តិទុក្កដ ៕

* * *

ដើម្បីយល់និងពិចារណា

# វិធីស្តីការរបស់រាងកាយ

លោកអ្នកដែលធ្វើការក្នុងក្រសួងរាជការ ក្នុងសមាគម ក្នុងក្រុមហ៊ុន ឬក្នុងអង្គការនីមួយៗ រមែងជ្រាបថា ចលនាសកម្មភាពក្នុងក្រសួង ក្នុងសមាគម ក្នុងក្រុមហ៊ុន និងក្នុងអង្គការនីមួយៗនោះ តើមានរបៀបយ៉ាងណា ? ពោលអោយខ្លីទៅគឺមានវិធីចែកមុខការគ្នាធ្វើតាមលំដាប់លំដោយ តាមជាន់ថ្នាក់ មានទំនងដូចវិធីស្តីការក្នុងរាងកាយរបស់យើងដែរ ប៉ុន្តែ បើពិនិត្យមើលដោយសព្វគ្រប់ទៅ នឹងយល់ថា វិធីស្តីការក្នុងរាងកាយយើង មានរបៀបរៀបរយល្អស្រួលជាងក្នុងក្រសួងនីមួយៗ ឬសមាគមនីមួយៗ ឬអង្គការនីមួយៗទៅទៀត ។ ឯវិធីស្តីការរបស់អវយវៈសំខាន់ៗក្នុងរាងកាយនេះគឺ : ១. ខួរក្បាល, ២. ខួរឆ្អឹងខ្នង, ៣. សរសៃប្រសាទ ។

## ១. ខួរក្បាល

ខួរក្បាល ជាសាច់ទន់ ប្រហែលនឹងសាច់ធួរេន មានទំហំតូចជាងក្បាលរបស់ម្ចាស់ខ្លួនបន្តិច មានទម្ងន់ប្រមាណ ១.៥០០ ក្រាម ។ ឯខ្នាតខួរក្បាលធំ ឬតូច ធ្ងន់ ឬស្រាល មិនមែនជាគ្រឿងវាស់សេចក្តីល្ងង់ខ្លៅ ឬឆ្លៀវឆ្លាតទេ ព្រោះមនុស្សមានក្បាលធំ មានខួរច្រើន តែជាមនុស្សល្ងង់ខ្លៅ ក៏មានគរគោក ឯសេចក្តីល្ងង់-ឆ្លាតនៅត្រង់សាច់របស់ខួរក្បាលដែលមានសណ្ឋានល្អ ឬអាក្រក់មកពីកំណើត ហេតុនេះ ទើបឃើញថា ខួរក្បាលល្អ មានទំនងដូចសំពត់សាច់ម៉ដ្ឋល្អប្រើជាប់បានយូរ ។ ឯខួរក្បាលអាក្រក់ ប្រៀបដូចសំពត់សាច់អាក្រក់ ប្រើមិនជាប់ ឆាប់ខូចខាតទៅវិញ ។ ខួរក្បាលនេះ ជាអវយវៈសំខាន់បំផុតរបស់រាងកាយ ជាអធិបតីស្តីការលើសរីរយន្តទាំងពួងក្នុងរាងកាយ មានទំនងដូចសេនាបតីស្តីការក្នុងក្រសួងនីមួយៗ ដូច្នោះ

ដែរ ប្រសិនបើខួរក្បាលពិការទៅ ឬអធិបតីនោះស្ដីការមិនត្រឹមត្រូវ មុខជាការងារទាំងពួងនឹងកើតវរវីកផ្ដេសផ្ដាសទៅតាមគ្នាទាំងអស់មិនខាន ។

ខួរក្បាលរបស់យើងមានពីរគឺ ខួរក្បាលធំ និងខួរក្បាលតូច ។ ឯខួរក្បាលធំ ចែកចេញជាពីរសង្កាត់គឺ សង្កាត់ខាងឆ្វេង និងសង្កាត់ខាងស្ដាំ ។ ខួរក្បាលសង្កាត់ខាងឆ្វេង មាននាទីត្រួតត្រានូវរាងកាយសង្កាត់ខាងស្ដាំ ហើយមានមុខក្រសួងដោយឡែក គឺធ្វើអោយចេះនិយាយ ចេះមើល ចេះសរសេរ ។ ឯខួរក្បាលសង្កាត់ខាងស្ដាំ មាននាទីត្រួតត្រានូវរាងកាយតែសង្កាត់ខាងឆ្វេងប៉ុណ្ណោះ មិនមាននាទីដទៃទៀត ហេតុនេះទើបឃើញថា ខួរក្បាលសង្កាត់ខាងឆ្វេង មានមុខក្រសួងចំណាប់ចំនួនជាងខួរសង្កាត់ខាងស្ដាំ បានជារាងកាយសង្កាត់ខាងស្ដាំរបស់យើងរឹងប៉ឹងខ្លាំងពូកែជាងរាងកាយសង្កាត់ខាងឆ្វេង ។

ខួរក្បាលធំ (ទាំងពីរផ្នែក) នៅមានចែកចេញជាចំណែកផ្សេង១ គឺ :

ក). ខួរក្បាលនៅចំណែកខាងមុខ សំរាប់ទទួលទុកនូវការចាំ ហេតុដូច្នេះបានជា កាលយើងនឹករកអ្វីមិនឃើញ ច្រើនតែយកដៃស្ទាបថ្ងាស ដើម្បីរំលឹកខួរក្បាលអោយនឹករាវរកឃើញឡើងវិញ ឬវេលាគិតគូរអ្វីច្រើនពេក ធ្វើអោយថ្ងាសក្ដៅដេកមិនលក់ ដោយហេតុ មានលោហិតឡើងមកខួរក្បាលសង្កាត់នេះច្រើន ។

ខ) ខួរក្បាលនៅចំណែកខាងក្រោយ សំរាប់អោយមើលអ្វី១ឃើញ ហេតុដូច្នេះបានជា ក្នុងខណៈដែលយើងដួលផ្ងារទៅក្រោយ ត្រូវត្រង់ខួរក្បាលសង្កាត់នេះ ដោយប៉ះនឹងដី ឬវត្ថុអ្វី ឬមួយត្រូវគេវាយចំកន្ទួតរង្វង់ ក៏ធ្វើអោយយើងងេងងោង ស្រវាំងភ្នែកមើលអ្វីមិនឃើញ ដោយហេតុរញ្ជួញដល់ខួរក្បាលសង្កាត់នេះ ។

គ). ខួរក្បាលនៅខាងចំហៀងនោះ សំរាប់ធ្វើអោយយើងឮសូរស័ព្ទនានាបាន ហេតុដូច្នោះបានជា កាលណាត្រូវគេទះតប់ពីខាងចំហៀង ឬចំពីមុខ ទើបធ្វើ

អោយយើងហ៊ឹងត្រចៀកស្ដាប់អ្វីមិនឮឡើយ ។

ឃ).- ខួរក្បាលនៅចំណែកខាងមុខរណ្ដៅប្រឡាយ សំរាប់ធ្វើអោយកម្រើក ហេតុនេះបានជា កាលណាត្រូវគេវាយក្បាលត្រង់ចំណែកនេះ ទើបធ្វើអោយរាងកាយយើងនេះទៅជាប្រកាច់ប្រកិន ប្រសិនបើអវយវៈសង្កាត់នេះខូចខាតពិការទៅ រាងកាយយើងក៏តាយសាក ( ដូចជារោគស្លាប់ជើង ស្លាប់ដៃ) ប្រើការមិនកើត ។

ង).- ខួរក្បាលនៅចំណែកខាងក្រោយរណ្ដៅប្រឡាយនេះ សំរាប់ធ្វើអោយដឹងសម្ផស្សផ្សេង១បាន បើអវយវៈសង្កាត់នេះខូចខាតពិរាពិការទៅ ធ្វើអោយបាត់ស្មារតីមិនដឹងខ្លួន កាលបើមិនដឹងខ្លួនហើយ រាងកាយក៏មិនកម្រើក ព្រោះខ្សែសរសៃសំរាប់អោយដឹងសម្ផស្សផ្សេង១នោះដាច់ចេញពីគ្នា ។

ច).- ខួរក្បាលនៅចំណែកខាង១ និងខាងចុងរណ្ដៅប្រឡាយសង្កាត់ខាងឆ្វេង សំរាប់ធ្វើអោយចេះនិយាយ.សរសេរ.មើល ។ កាលបើអវយវៈចំណែកនេះខូចខាតអន្តរាយទៅ ទើបធ្វើអោយនិយាយមិនកើត សរសេរមិនកើត ឯមនុស្សដែលគនិយាយមិនរួចនោះ គេច្រើននិយាយថាមនុស្សមានកន្ទើតខ្លីពេក តែសេចក្ដីពិត មិនមានទោសកើតមកពីកន្ទើតវែង ឬខ្លីឡើយ ។

ឆ).- ឯខួរក្បាលតូច១ នៅខាងក្រោម និងខាងក្រោយខួរក្បាលធំនោះ សំរាប់ធ្វើអោយរាងកាយតាំងនៅនឹងបានមិនទ្រេតទ្រោត នៅចំណែកខាងស្ដាំឃុំរក្សារាងកាយចំណែកខាងស្ដាំ, ចំណែកខាងឆ្វេងឃុំរក្សារាងកាយខាងឆ្វេង មិនប្ដូរមុខក្រសួងគ្នាដូចជាខួរក្បាលធំទេ ។ ( ប្រសិនបើទារកទើបសម្រាលថ្មី១ មានខួរក្បាលចំរើនប៉ុននឹងក្មេងធំតែម្ដង មុខតែនឹងធ្វើអោយទារកដែលទើបនឹងសម្រាលនោះចេះឈរ . អង្គុយ . ដើរបានមួយរំពេច ដូចជាសត្វតិរច្ឆានជំពូកខ្លះមិនខាន តែនឹងនាំអោយលំបាកដល់អ្នកអភិបាលក្មេង ព្រោះក្មេងនឹងដើរធ្លាក់ពីលើផ្ទះមិនខាន

ព្រោះក្មេងមិនទាន់មានសតិសម្បជញ្ញៈ ។ ហេតុនេះ ការដែលក្មេងក្រូបានចេះឈរ ដើរ អង្គុយខ្លួនឯង មានទំនងដូចសព្វថ្ងៃនេះ ជាការគាប់ប្រសើរណាស់ ) ។

## ២. ខួរឆ្អឹងខ្នង

ខួរឆ្អឹងខ្នងនេះ មានលក្ខណៈដូចជាខួរក្បាលដែរ មានបណ្តោយប្រមាណ ១៥ ធ្នាប់ ជាប់ជាមួយនឹងខួរក្បាល រលាយជាសាច់មួយចុះមកតាមចន្លោះឆ្អឹងខ្នង ផុតត្រឹមឆ្អឹងចង្កេះទី ១ ដើម្បីទទួលសេចក្តីរាយការណ៍ ដែលបញ្ជូនមកតាមសរសៃប្រសាទផ្សេងៗក្នុងរាងកាយបញ្ជូនមកដល់ខួរក្បាល ។ ឯចំណែកខាងក្រោមនៃខួរឆ្អឹងខ្នង ក៏ទទួលដឹងឮចំពោះរាងកាយជាចំណែកខាងក្រោមមានជើងជាដើម ហើយឡើងមកជាលំដាប់ រហូតដល់ចំណែកលើខ្លួននិងដើមដៃ សន្មតថា បើមានគ្រោះថ្នាក់ដល់ខួរឆ្អឹងខ្នង ត្រង់កណ្តាលខ្នង អវយវៈត្រង់ចំណែកនោះប្រើការមិនបាន សេចក្តីរាយកាណ៍ផ្សេងៗដែលត្រូវបញ្ជូនមកតាមប្រសាទនោះ តោងតែធ្វើដំណើរមកតាមខួរឆ្អឹងខ្នងទាំងអស់ ទើបខួរឆ្អឹងខ្នងនាំសេចក្តីរាយការណ៍អស់នោះទៅដល់ខួរក្បាលមួយជាន់ទៀតជាលំដាប់លំដោយ ដើម្បីមិនអោយប្រសាទតូចៗ នាំសេចក្តីរាយការណ៍ដើររំលងថ្នាក់ត្រង់សំដៅទៅខួរក្បាលតែម្តងទេ ។ រឿងនេះមានទំនងដូចក្រសួងរាជការ និងមន្ទីរធ្វើការធំៗ ដែលចាត់របៀបតាមថ្នាក់តូច ថ្នាក់ធំ មិនអោយធ្វើការរំលងថ្នាក់ ដែលជាហេតុធ្វើអោយកិច្ចការផ្សេងៗ កើតវឹកវរជាកោលាហលឡើង ។

## ៣. សរសៃប្រសាទ

មានលក្ខណៈ មានព័ណ៌សម្បុរសលាយលឿង ជាសរសៃតូចៗឆ្មារ ដូចជាសរសៃអំបោះរួមគ្នាជាបាច់ៗ ហើយក្នុងបាច់សរសៃអស់នោះ មានសរសៃប្រសាទសំរាប់ធ្វើអោយដឹងខ្លួន និងសរសៃប្រសាទដែលធ្វើអោយដុំសាច់រួមផ្តុំគ្នាបាន ញែកចេញជាសរសៃល្អិតៗ មករួមប្រជុំក្នុងដុំសាច់ និងសើស្បែកគ្រប់អន្លើ សរសៃប្រ-

សាទរស់នេះហើយដែលចេញមកអំពីខួរឆ្អឹងខ្នង មាន ៣១ គូ សំរាប់រក្សារាងកាយ មាន ១២ គូទៀត សំរាប់ឃុំរក្សានូវមុខនិងក្បាល ។ ការដែលមានសរសៃប្រសាទជំពូកខ្លះទទួលសេចក្តីរាយការណ៍សំដៅត្រង់ទៅដល់ខួរក្បាលតែម្តង មិនបាច់បញ្ជូនមកតាមខួរឆ្អឹងខ្នងនោះ ប្រយោជន៍នឹងអោយកិច្ចការប្រព្រឹត្តទៅបានស្រួល រហ័សរួសរាន់ មានទំនងដូចជាមេទាហានខ្លះក្នុងកងទ័ព អោយមានអំណាចស្នើការផ្ទាល់លោកមេទ័ពតែម្តងបាន មិនបាច់ស្នើការតាមលំដាប់ថ្នាក់ ដូចមេទាហានឯទៀតៗ ។

យ៉ាងណាមិញ :

១) សន្មតិថា ម្រាមជើងរបស់យើងប៉ះកំដៅភ្លើង ។ កំដៅនេះធ្វើអោយចុងសរសៃប្រសាទដឹងថាក្តៅ ហើយបញ្ជូនរាយការណ៍ទៅតាមសរសៃដែលជាប់ទាក់ទងគ្នានឹងខួរឆ្អឹងខ្នង ទើបខួរឆ្អឹងខ្នងនាំបញ្ជូនដំណឹងនេះទៅដល់ខួរខាងលើ ។ ចំណែកនេះក៏បកបញ្ជូនទៅដល់ខួរជាចំណែកនៅខាងមុខ ដែលមាននាទីទទួលទុកនូវការចាំគ្រប់ជំពូក ក៏នឹកឃើញចាំបានថា ធម្មជាតិភ្លើងក្តៅ បើមិនដក ឬទាញយកជើងចេញទេ មុខជាម្រាមជើងនឹងត្រូវភ្លើងឆេះមិនខាន ទើបបង្គាប់ទៅដល់សរសៃប្រសាទដែលនៅប្រចាំជើង អោយដកជើងចេញពីភ្លើងយ៉ាងប្រញាប់ ប៉ុន្តែ ការស្តីការ និងបង្គាប់ការ ទទួលប្រតិបត្តិការនោះ រហ័សរួសរាន់ណាស់ ដូចជាផ្លេកបន្ទោរ ទើបធ្វើអោយយើង មិនដឹងខ្លួន ហើយស្តីការយ៉ាងដាច់ស្រេចមិនបាច់រារង់ទេ ។ ប្រសិនបើអាល័យរារង់ ពិគ្រោះប្រឹក្សាថា ត្រូវផ្លុំភ្លើងអោយរលត់ទៅ ឬនឹងប្រើដៃចាប់ភ្លើងចេញដូច្នោះ មុខជាម្រាមជើងយើង នឹងរលាកភ្លើងមិនខាន ។

២) សន្មតិថា មូសវាមកទំខាំមុខយើង ដំងឹដែលកើតពីមូសខាំនោះ នឹងរត់សួរទៅតាមសរសៃប្រសាទប្រាប់ចៅនាទីផ្សេងៗ ដូចពោលមកហើយ តែសេចក្តីថ្មីករបស់យើង បង្គាប់អោយយកដៃទះមូសនោះ ដែលជាវិធីស្រួលជាងញាក់មុខ ឬអង្រួនក្បាលដេញមូស ទើបស្តីការបង្គាប់ទៅដៃអោយទះមូសដូច្នេះ ជាដើម ។

៣)- សន្មតិថា មានមនុស្សមកជេរយើងនៅចំពោះមុខ ពាក្យជេរនោះ ស្ទុះទៅចូលត្រចៀក ហើយជូនដំណឹងទៅដល់ខួរដែរ តែមុននឹងបង្គាប់អោយធ្វើតបតទៅវិញនោះលំបាកបន្តិច ពោងប្រើសេចក្ដីត្រិះរិះបន្តិចថា ត្រូវធ្វើដូចម្ដេចទើបស្រួល មានវិធីដែលត្រូវធ្វើតបតទៅវិញ ច្រើនយ៉ាង :

ក) ប្រសិនបើអ្នកដែលត្រូវគេជេរនោះជាមនុស្សចាស់ទុំ មានគំនិតគិតគូរច្រើន ដឹងខុសដឹងត្រូវ ក៏ធ្វើជាមិនដឹងមិនឮក៏មាន ឬចាត់ការតាមដែលឃើញថាជាសេចក្ដីគាប់គួរ ដូចជាបណ្ដេញអោយមនុស្សជេរដើរចេញ ឬប្ដឹងប៉ូលិសអោយចាប់ធ្វើទោសតាមច្បាប់ ក៏មាន ។

ខ) បើអ្នកដែលត្រូវជេរមានឋានៈស្មើគ្នានឹងអ្នកជេរ ខួរក្បាលបង្គាប់អោយជេរតបទៅវិញ កើតជាវិវាទទាស់ទែងគ្នាមិនដាច់ស្រេច ទាល់តែប៉ូលិសចាប់ទាំងពីរនាក់នាំទៅផ្ទះបក ក៏មាន ។

គ) បើអ្នកដែលត្រូវជេរជាមនុស្សទោសៈខ្លាំង អត់សង្កត់ចិត្តពុំបាន ខួរក្បាលក៏ប្រើដៃជើងអោយទាត់ធាក់អ្នកជេរមួយរំពេចទៅ ក៏មាន ។

តាមឧទាហរណ៍ ដែលពោលមកនេះ ដើម្បីសំដែងអោយឃើញថា រាងកាយរបស់យើងនេះ មានវិធីស្ដីការជារបៀបរៀបរយល្អណាស់ ទាំងរហ័ស ទាំងដាច់ស្រេច ប៉ុន្តែកិច្ចការដែលចាត់ចែងធ្វើទៅនោះ នឹងមានសេចក្ដីចំរើន ឬមិនចំរើន ស្រេចតែសេចក្ដីត្រិះរិះប៉ិនប្រសប់ឈ្លាសវៃនៃខួរក្បាល មានទំនងដូចចាងហ្វាងសាលា ឬអធិបតីនៃក្រសួងនីមួយៗ ដូច្នោះដែរ ។

មួយវិញទៀត គ្រឿងសម្ភស្សផ្សេងៗ ពោងប្រព្រឹត្តទៅមិនស្រួលជាដរាប បើមានខួរខូចខាតត្រង់កន្លែងណាមួយ ដូចជាខួរឆ្អឹងខ្នងពិការ រាងកាយដែលនៅក្រោមខួរឆ្អឹងខ្នង ក៏ប្រើការមិនកើត ។ រឿងនេះមានទំនងដូចខ្សែភ្លើងអគ្គិសនី បើខ្សែនៅក្រៅផ្ទះដាច់ ភ្លើងក្នុងផ្ទះក៏រលត់អស់មិនខាន ៕

ពីកម្ពុជសុរិយា លេខ១០ ឆ្នាំទី១២ . ១៩៤០

ឯកសារ

# អំពីកំណើតមនុស្សជាតិ

បណ្ដាមនុស្សជាតិដែលមាននៅលើផ្ទៃពិភពនេះ សឹងមានតំណែងនាទី និងឋានៈខុសប្លែកៗគ្នា ស្គាល់ខុស-ត្រូវ ល្អ-អាក្រក់ គ្រប់យ៉ាង ឬធ្វើការផ្សេងៗ ទាំងមានគុណប្រយោជន៍ ទាំងមានទោស ហើយមានចំរើន វិនាស តៗមក តាមយុគ តាមសម័យ ដរាបមកដល់ឥឡូវនេះ ។ វិជ្ជានិងសិល្បសាស្ត្រទាំងឡាយចំរើនឡើង ដើម្បីជាប្រយោជន៍តាមសេចក្ដីត្រូវការរបស់មនុស្ស ។ របស់ដែលអស្ចារ្យនិងស្ងាត់កំបាំងក៏បានស្រាវជ្រាវរាវរក ព្រមទាំងលក្ខឋាន នាំមកផ្សាយអោយឃើញប្រាកដច្បាស់ដល់ភ្នែកមនុស្សលោក តែរឿងដែលតាំងឈ្មោះខាងលើនេះ ដើម្បីចង្អុលប្រាប់អំពីកំណើតដើមរបស់មនុស្ស តើមនុស្សជាន់ដើម កើតមកអំពីអ្វី ?

ចំណោទនេះ នៅតែងងឹតងងល់ដល់ដលវិជ្ជាការទាំងឡាយក្នុងលោក ។ បណ្ដាអ្នកប្រាជ្ញទាំងឡាយតាំងអំពីបុរាណសម័យ រហូតមកដល់សម័យវិទ្យាសាស្ត្រក្នុងសព្វថ្ងៃនេះ បានព្យាយាមស្រាវជ្រាវរាវរកមូលហេតុមកច្រើនណាស់ហើយ មើលទៅហាក់ដូចជាមិនអាចដោះប្រស្នានេះអោយជ្រះស្រឡះបាន បើកាន់តែរាវរកទៅហើយកត់ត្រាមកសំរាប់អោយមនុស្សផងគ្នាពិចារណាមើល ក៏កាន់តែឃើញស្មុគស្មាញ់ វរវីក ហើយទាស់ទែងខ្វែងគំនិតគ្នាច្រើនឡើង ត្រាតែមិនអាចសន្និដ្ឋានអោយជាទីពិតប្រាកដបានថាយ៉ាងណា របស់អ្នកណាជាសេចក្ដីពិតល្មមប្រកាន់យកជាលក្ខឋានបាន ។

យើងនឹងប្រមូលយករឿងរ៉ាវរបស់អ្នកប្រាជ្ញ ឬគន្ថរចនាចារ្យ និងអ្នកប្រាជ្ញវិទ្យាសាស្ត្រដែលបានរៀបរៀងទុកនោះមកថ្លែង ដើម្បីជាទីសណ្ដាប់ ឬជាគ្រឿងពិនិត្យរកហេតុផល សំរាប់អ្នកត្រូវការចង់ជ្រាបរឿងនេះ តទៅ ។

កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ មានគណៈអ្នកស្រាវជ្រាវ ១ ក្រុម ហៅថា

« គ្រីក្ររី » បានគិតស្មានគ្មាន់គ្មេរអំពីកំណើតមនុស្សជាតិថា លោកដែលមនុស្សជាតិបានអាស្រ័យនៅនេះមានអាយុច្រើនលានឆ្នាំ ប្រហែល ១៨ លានឆ្នាំមកហើយ កំណត់វេលាជា ៨ យុគ គឺយុគទី ១ មនុស្សមានកំណើតជាសត្វត្រី ហែលនៅក្នុងទឹកជាដំបូង តែសត្វត្រីកើតមកពីអ្វី មិនមានសំដែងទុកអោយច្បាស់លាស់ ហើយថាក្បាលត្រីនេះឯង ដែលក្លាយមកជាក្បាលមនុស្ស ក្នុងវេលាក្រោយ ។ ក្នុងយុគទី២ ទី៣ សត្វត្រីនេះក្លាយមកជាសត្វគោក មានអាការកិរិយាជាសត្វលូន-វារ ។ ក្នុងយុគទី៤ ទី៥ អវយវៈរបស់សត្វលូន-វារនេះ ក៏មានជើងដុះថែមឡើងទៀត តាមចំណង់របស់ធម្មជាតិនៃសត្វគោក ។ ដល់មកក្នុងយុគទី៦ ទី៧ ក៏ប្រែត្រឡប់ក្លាយមកជាសត្វពានរ ត្រាច់រង្កាត់លើមែកឈើ ហេតុដែលក្លាយមកជាសត្វស្វាបាននេះ ដោយសេចក្តីអន្ទះអន្ទែងស្វែងរកអាហារ ដោយបានល្បងភ្លក់រសជាតិផ្លែឈើដើមទាប១ជាដំបូង ហើយព្យាយាមប្រពៃងប្រពោងមែកឈើ លុះអំណើះជាអង្វែងឆ្នាំទៅ រាងកាយក៏ក្លាយទៅជាពានរ ។ គ្រប់១យុគនៃការប្រែប្រួលនេះ ខួរក្បាលក៏កាន់តែត្រូវការប្រើអោយមានប្រយោជន៍ច្រើនឡើងជាលំដាប់ ទើបក្លាយភាពមកជាមនុស្សដោយបរិបូណ៌ ។ តាមសេចក្តីដែលពោលមកនេះ មានលក្ខឋានបានមកអំពីបុរាណវត្ថុ និងរាងឆ្អឹងសត្វសម័យព្រេងនាយដ៏យូរលង់ជាច្រើនជំពូក លក្ខឋានអស់នេះ មានប្រយោជន៍សំរាប់ជាគ្រឿងពិចារណាអំពីគ្រឿងបរិភោគរបស់មនុស្សដែលប្រែប្រួលទៅតាមយុគតាមសម័យអស់នោះ ។

ក្រៅអំពីគណៈ « គ្រីក្ររី » នៅមានគណៈស្រាជ្រាវឯទៀត១ ដែលនាំគ្នាត្រួតត្រា ពិនិត្យមើលរឿងនេះ ក៏បានពោលអាងថា ធ្លាប់ស្រាវជ្រាវពិនិត្យរឿងនេះជាច្រើនប្រទេសមកហើយនៅទ្វីបអាស៊ី បានប្រទះឃើញរាងឆ្អឹងសត្វជាច្រើនពួកដែលបាន សន្និដ្ឋានទុកថា ទ្វីបអាស៊ីជាទីប្រជុំកើតនៃកំណើតសត្វជំពូកផឹកទឹកដោះ និងសត្វ ជើង ៤ មុនទីដទៃ១ទាំងអស់ក្នុងលោក ។ សេចក្តីស្រាវជ្រាវដែលបានពោល

មកនេះគឺការរុករកក្នុងសម័យវិទ្យាសាស្ត្រ ដែលយោបល់ដោយសរុបថា មនុស្ស យើងកើតមកអំពីអាការប្រែប្រួលនៃសត្វ ។

យើងងាកបែរទៅពិចារណាមើលតាមយោបល់ក្នុងលទ្ធិសាសនាខ្លះល្បង មើល តែយើងនឹងពោលតាមលទ្ធិព្រាហ្មណ៍ជាមុន ព្រោះជាសាសនាចាស់ក្នុងលោក នេះ ដូចមានរឿងពោលទុកថា ហេតុដែលមានមនុស្សកើតឡើងនេះ ដោយអំណាច ឬទ្ធានុភាពរបស់ព្រះព្រហ្ម ក្នុងជាន់ដំបូងបង្អស់នោះ ព្រះព្រហ្មកើតឡើងក្នុងស៊ុត តែ គម្ពីរនេះមិនបានពោលល្អិតល្អន់ថា ហេតុអ្វីទើបព្រះព្រហ្មទៅនិម្មិតខ្លួនអោយស្ថិតនៅ ក្នុងស៊ុតដូច្នោះ ឬអ្នកណាមួយជាអ្នកនិម្មិតព្រះព្រហ្មឡើង ស៊ុតដែលព្រះព្រហ្មនិម្មិត ឡើងនេះ ជាស៊ុតវិសេស ទើបអាចអណ្តែតនៅឰដ៏កណ្តាលអាកាសបាន ១ ម៉ឺនកល្ប ព្រះព្រហ្មដែលទ្រង់ស្ថិតនៅតែក្នុងស៊ុតអស់វេលាយូរដល់ម្លេះ ទ្រង់មានសេចក្តី នឿយណាយរោយស្រពន់ ឬមួយមានព្រះទ័យរំខានធុញថប់តប់ប្រមល់ក្នុងការ ប្រថាប់នៅក្នុងទីតែមួយកន្លែងដូច្នេះតទៅទៀត ទើបទ្រង់បណ្តាលអោយស៊ុតនោះ ប្រេះបែកចេញជាពីរចំណែក ស៊ុតទាំងពីរចំណែកនេះធំសម្បើមមហិមា ផុតវិស័យ នឹងវាស់វែងកើត ទើបព្រះព្រហ្មទ្រង់កំណត់យកមួយចំហៀងខាងលើជាផ្ទៃមេឃ មួយចំហៀងខាងក្រោមជាផ្ទៃលោក ។ លុះតមក កើតភ្លើងឆេះកល្ប ឆេះអស់ទាំង លោកគ្មានសល់អ្វី តែអ្នកណាជាអ្នកបង្កាប់អោយដុតបំផ្លាញលោកនេះ មិនមាន សំដែងទុក លុះអំណើះតពីនោះមក ទើបមានព្រះឥសូរជាម្ចាស់មកសាងមនុស្សលោក ឡើងវិញទៀត មានដីរ ៤ និងសសរ ៩ ដើម សំរាប់រងទទួល ព្រះឥសូរជាម្ចាស់ទ្រង់ តាំងព្រះទ័យទំនុកបំរុងលោកនេះអោយកាន់តែរុងរឿងឡើងជាលំដាប់ ទើបទ្រង់ សែកព្រះសេទោ អោយហូរចេញក្លាយមកជាទឹក ទ្រង់សែកព្រះមេទោ អោយក្លាយ មកជាផែនដី ហើយទ្រង់ត្រិះរិះថា ស្ថានសួគ៌និងស្ថានមនុស្សលោកយើងនេះ មិន ទាន់មានជាន់ថ្នាក់ជាទីគួរពិតពិលរមិលមើល ទើបទ្រង់យកព្រះចូឡាមណី ជាគ្រឿង

អម្ពររបស់ទ្រង់ ១ បណ្ដាលអោយកើតជាភ្នំព្រះសុមេរុ តាំងនៅកណ្ដាលពិភពមនុស្សនេះ ហើយទ្រង់ចាប់យកព្រះសង្វាររមកសាងជាភ្នំព័ទ្ធជុំវិញភ្នំព្រះសុមេរុ ជា ៧ ជាន់ គឺ ភ្នំយុគន្ធរ ភ្នំឥសិន្ធរ ភ្នំករវិក ភ្នំសុទស្សន ភ្នំនេមិន្ធរ ភ្នំវិន្តក និងភ្នំអស្សកណ្ណ រួមជា ៧ ភ្នំ ហៅថាភ្នំសត្តបរិភណ្ឌ ជាភ្នំព័ទ្ធជុំវិញពិភពលោក តមកទើបទ្រង់សាងព្រះអាទិត្យ ព្រះចន្ទ និងបណ្ដាផ្កាយផ្សេងៗទុកសំរាប់ប្រដាប់លោក ហើយទ្រង់សាងព្រះឧមាភគវតី ព្រះនារាយណ៍ និងព្រះព្រហ្មធាតាឡើង ដើម្បីអោយជួយសាងសព្វសរពើដែលមិនទាន់បរិបូណ៌ ។ កាលបើកើតលោកឡើងហើយ វត្ថុនានាដែលមាននៅលើផ្ទៃផែនដីនេះ សុទ្ធតែជាទីរីករាយ គួរពិតពិលរមិលមើល ផ្ទៃផែនដីក៏មានក្លិនក្រអូប ឈ្ងុយឆ្ងាញ់ជាពន្លឹក ពួកព្រះព្រហ្មក៏មានចិត្តចង់សេពសោយឱជារសផែនដីដែលឆ្ងាញ់នោះ ទើបទ្រង់ហោះចុះមកពីស្ថានសួគ៌ ហើយទ្រង់សេពសោយដោយកំសាន្តព្រះទ័យ លុះយូរបន្តិចទៅក៏ភ្លេចស្ថានសួគ៌ ហើយអស់ឫទ្ធិនឹងហោះត្រឡប់ទៅកាន់ទីដើមវិញ ទើបនាំគ្នារួមភេទផ្សំដំណេកជាមួយគ្នា ជាដើមកំណើតនៃមនុស្សទាំងឡាយ តរៀងមក ។

ចំណែកឯគម្ពីររបស់គ្រិស្តសាសនាដែលចាស់ៗនោះ មាននិយាយថាមូលហេតុដែលនឹងកើតមានមនុស្សឡើងនេះ ព្រះដ៏ជាម្ចាស់សួគ៌អង្គមួយ ទ្រង់សាងមនុស្សឡើងមុនបង្អស់ ព្រះជាម្ចាស់សួគ៌នេះមានតែមួយអង្គប៉ុណ្ណោះ គ្រិស្តសាសនិកជនតែងហៅថា « ព្រះបិតា » ព្រះអង្គបានសាងលោកឡើងនេះ មានកំណត់ទុកជា ៧ គ្រា ក្នុង ១ គ្រាៗ អស់វេលាជាយូរអង្វែងកំណត់មិនបាន តែពោលទុកក្នុងគម្ពីរថា គ្រាទី ១ ទ្រង់សាងពន្លឺឡើង គ្រាទី ២ ទ្រង់សាងមេឃ ហើយញែកចេញមកជាផែនដីនិងទឹក គ្រាទី ៣ ទ្រង់សាងដីដោយឡែក ទឹកដោយឡែក ព្រឹក្សាជាតិដោយឡែក គ្រាទី ៤ បានទ្រង់សាងព្រះអាទិត្យ ព្រះចន្ទនិងដួងផ្កាយ ( នេះឃើញថាមានពន្លឺមុន ទើបមានដួងអាទិត្យជាក្រោយ ) គ្រាទី ៥ បានទ្រង់សាងសត្វ

ស្លាប និងមច្ឆជាតិ តមកក្នុងគ្រាទី ៦បានទ្រង់សាងសត្វចតុប្បាទ ទ្វេបាទ និងមនុស្ស ហើយទ្រង់សម្រាកព្រះអង្គ ដែលរាប់ថាជាគ្រាទី ៧ ។ ឯមនុស្សដែលទ្រង់សាងឡើង នេះ តាមគម្ពីរពោលថា មានរូបរាងប្រហែលនឹងព្រះអង្គដែរ តែរាងកាយរបស់ មនុស្សប្រកបដោយដីផង់ និងវិញ្ញាណ វិញ្ញាណនេះមិនមែនសាងឡើងដោយធាតុអ្វី ឡើយ គឺជាអភិនិហាររបស់ព្រះជាម្ចាស់សាងឡើងជាដំបូងនេះ ជាមនុស្សប្រុស ឈ្មោះថា អាដាំ ។ អាដាំនេះកើតមកក្នុងលោកតែម្នាក់ឯង តមកទ្រង់មានព្រះទ័យ គិតថា អាដាំកើតមកក្នុងលោកតែម្នាក់ឯង ហាក់ដូចជាស្រងេះស្រងោចពន់ពេក ទើបទ្រង់សណ្ដំអាដាំអោយលក់ទៅ ហើយទ្រង់កាត់យកឆ្អឹងជំនីខាងឆ្វេងផុតរបស់ អាដាំដោយឫទ្ធានុភាព យកតែឆ្អឹងជំនីមួយមកហើយ រុំស្រោបដោយមំសះធ្វើជារូប ស្ត្រីឡើង ប្រកបព្រមដោយវិញ្ញាណ អោយឈ្មោះថានាង អែវ ជាគូរួមសុខរួមទុក្ខ ជាមួយនឹងអាដាំរៀងមក ។ បុរសស្ត្រីគូនេះ តែងអាក្រាតកាយនៅក្នុងសួនស្ថានសួគ៌ ជាបរមសុខ ឥតមានធ្វើការអ្វីឡើយ មានផលានុផល និងចញ្ចហារសំរាប់បរិភោគ គ្រប់យ៉ាងមិនមានខ្វះខាត បណ្ដាសព្វសត្វក៏មូលមកជាមិត្ត មិនប្រទូសរ៉ាយដល់គ្នា ទៅវិញទៅមក ។ តមក ផលកម្មដែលជាអំពើអាក្រក់មកបណ្ដាលចិត្តរបស់អាដាំ និង នាងអែវ អោយទៅបរិភោគផ្លែឈើ ដែលព្រះជាម្ចាស់ទ្រង់ហាមផ្ដាច់នោះ ដោយ ផលបាបនេះហើយ ទើបព្រះជាម្ចាស់ទ្រង់បណ្ដេញអាដាំ និងនាងអែវ ចេញពីសួន ស្ថានសួគ៌ ដោយទោសល្មើសព្រះឱង្ការ ហើយទ្រង់ផ្ដាច់សេចក្ដីសុខទាំងពួង ដែល ធ្លាប់ទទួលមកពីខាងដើម ។ អាដាំនាងអែវ ក៏កាន់តែមានសេចក្ដីអៀនខ្មាស ដែលខ្លួន ជាមនុស្សអាក្រាតដូច្នោះ ទើបបេះស្លឹកឈើយកមកបិទបាំងរាងកាយ ហើយមាន ភារៈដូចជាមនុស្សធម្មតាក្នុងសម័យតមក គឺត្រូវធ្វើការចិញ្ចឹមជីវិត មានទុក្ខ មានសុខ មានឈឺ មានស្លាប់ ; ដោយអាដាំ និងនាងអែវនេះ ទើបមានកូនមានចៅតៗគ្នា រៀង មកដល់សព្វថ្ងៃនេះ ។

ចំណែកខាងគម្ពីរគូរ៉ាន របស់សាសនាឥស្លាម ឬមហាហ្មាត់ មានសេចក្ដីដំណាលប្រហែលគ្នាគ្រប់អន្លើ ពោលគឺ ព្រះអាឡា ឬ អាឡោះ បានទ្រង់សាងអាដាំនិងនាងហាវ៉ាឡើង ហើយទ្រង់ប្រទានឧទ្យានអល្ប្យាម៉ុតជាលំនៅ ។ ថ្ងៃមួយ នាងហាវ៉ាទៅបេះផ្លែឈើអម្រឹត ដែលព្រះជាម្ចាស់ទ្រង់ហាមផ្ដាច់មិនអោយបរិភោគនោះ សេចក្ដីនេះទ្រង់ជ្រាបដល់ព្រះអាឡាជាម្ចាស់ ទើបទ្រង់បណ្ដេញចេញពីឧទ្យានហើយត្រូវផ្ដាសាអោយរងទុក្ខវេទនាផ្សេងៗ ហើយព្រះអាឡាទ្រង់ប្រោសអោយទេវតាមកនៅថែរក្សាឧទ្យាននោះវិញ ។

ឯប្រវេណីនិយមរបស់ជនជាតិជប៉ុន មានសំដែងថា មុននឹងមានមនុស្សកើតឡើងក្នុងពិភពនេះ មានទេវបុត្តនិងទេវតាពីរអង្គទ្រង់ទតមើលឃើញខាងក្រោមទីប្រថាប់មានលក្ខណៈទន់ជាចាហួយ ទើបចុះមកពីស្ថានសួគ៌ទៅកាន់ទីនោះហើយទ្រង់កូរទឹកចាហួយនេះដោយអាវុធធ្នូន ខណៈដែលទ្រង់លើកធ្នូនឡើង ទឹកចាហួយដែលជាប់នៅចុងធ្នូននោះ ក៏ស្រក់ចុះមកជាដំណក់ៗ ។ ដំណក់ចាហួយនេះហើយ ដែលក្លាយមកជាផែនដី ហើយជាកោះផ្សេងៗ របស់ប្រទេសជប៉ុននៅសព្វថ្ងៃនេះ ។

តមក ទេវបុត្តទេវធីតាទាំងពីរអង្គនោះ ក៏គង់នៅលើកោះដែលសាងឡើងថ្មីនេះ ហើយទ្រង់កសាងសព្វសារពើទាំងពួង មានមេឃ រុក្ខជាតិ តិណជាតិ មនុស្សនិងភ្លើង ។ ធ្នូនជាភ្លើងដែលសាងឡើងដោយឫទ្ធានុភាពនោះបណ្ដាលនេះទេវធីតានោះស្លាប់ទៅ ទេវបុត្តមានចិត្តអាណោះអាល័យដល់នាងទេវធីតាពន់ពេកទើបស្ដេចទៅតាមនាងរហូតដល់ស្រុកមច្ចុ ឯនាងពោលថា ខ្លួននាងបានសេពរសជាតិរបស់មច្ចុហើយ មិនអាចត្រឡប់ប្រែជាសភាពដើមវិញបានទេ លុះថារួចហើយក៏បាត់រាងកាយចូលទៅក្នុងដែនមច្ចុនោះវិញ ។ ឯទេវបុត្តបានរង់ចាំនាងទេវធីតាអស់កាលយូរហួសកំណត់នឹងអត់ទ្រាំនៅចាំតទៅទៀតបាន ក៏ទ្រង់ដើរចូលទៅក្នុង

អាណាខេត្តរបស់មួត្យុ ពិភពនេះងងឹតពេកណាស់ ទើបទ្រង់កាច់ក្រាសសិតសក់ ១ ចំរៀករុជជាគប់ភ្លើង ក្នុងមួយរំពេចនុ៎ះឯង ពន្លឺភ្លើងឆ្លុះភ្លឺឡើងចាំងទៅត្រូវរាងកាយ នៃនាងទេវធិតាដែលកំពុងមានដង្កូវនៅពាសពេញទាំងខ្លួន ហើយមានពន្លឺព្រោងព្រាតដោយជុំវិញ ទេវបុត្តនោះក៏រត់ចេញពីទីនោះ ។ ការដែលស្វាមីនាងដើរកន្លងចូលទៅក្នុងដែននោះដូច្នោះ ធ្វើអោយទេវធិតានោះមានចិត្តក្រេវក្រោធជាពន្លឹក ទើបប្រើបម្រើស្រីជរាម្នាក់ ជារាជទូតអោយដេញចាប់ព្រះស្វាមីមកអោយបាន កាលស្រីមួត្យុដេញប្រកិតមកជិតទាន់ ទេវបុត្តក៏បោះសរសៃស្ងួតចោលទៅ ក្លាយទៅជាចំការទំពាំងជូរ ធ្វើអោយរាជទូតមួត្យុនោះភាន់ភ្លាំងភ្លេចស្មារតី គិតតែបេះផ្លែទំពាំងជូរបរិភោគយ៉ាងក្សេមក្សាន្ត លុះមានស្មារតីនឹករលឹកឃើញ ក៏ខំដេញតាមទៅទៀត ទេវបុត្តក៏កាច់ក្រាសរោយទៅជាទំពាំងឫស្សីខ្ចីៗ យ៉ាងឆ្ងាញ់ ស្រីមួត្យុក៏គិតតែសេពទំពាំងឫស្សីខ្ចីនោះ ដោយចិត្តល្មោភម្តងទៀត ។ ខណៈនោះ ទាហានមួត្យុក្នុងអាណាចក្រទាំងមូល ក៏លើកគ្នាដេញតាមមក ទេវបុត្តក៏ហូតព្រះខ័នពេជ្រចេញមកឥស្វឹផង រត់ផង រហូតដល់ដែនមនុស្សលោក ទើបទេវបុត្តសៃកផ្លឺផ្លែអម្ពូត ៣ បោះចោលទៅត្រូវទាហានមួត្យុ មានអន្តរាយចាលចាញ់រត់ខ្ចាត់ខ្ចាយអស់ទៅ ។ ក្នុងខណៈនោះ នាងទេវធិតាក៏ដេញតាមប្រកិតមកទៀត ប៉ងនឹងផ្តាច់ យកជីវិតអោយតែខាងបាន ។ ឯទេវបុត្តដល់មកខណៈនេះ ក៏អស់សេចក្តីស្នេហាអាល័យក្នុងខ្លួននាងធិតា ទើបទេវបុត្តដាក់ថ្ម ១ ដុំ ធ្វើជាព្រំប្រទល់ទុកត្រង់ចន្លោះនៃពិភពទាំងពីរ ហើយពោលបាមផ្តាច់ថា នាងឯងធ្លាប់ជាភរិយារបស់យើង តាំងអំពីថ្ងៃនេះទៅដាច់ស្រឡះពីស្វាមីភរិយាគ្នាចុះ ឯនាងទេវធីតាមានចិត្តខ្ញាញ់ ណាស់ ទើបពោលពាក្យព្យាបាទថា កាលបើខ្លួនយើងសម្លាប់អ្នកមិនបានទេ យើងនឹងសម្លាប់បរិវាររបស់អ្នកមួយថ្ងៃ ១.០០០ នាក់ ទេវបុត្តក៏ពោលពាក្យផ្ចាលតបទៅវិញថា យើងនឹងសាងបរិវារសងវិញមួយថ្ងៃ ១.៥០០ នាក់ ។ តាំងអំពីថ្ងៃនោះមក នាងទេវធីតា ដែលជាអ្នកគ្រប់គ្រង

ពិភពមនុស្ស ក៏គិតតែបំផ្លាញជីវិតមនុស្សមួយ ថ្ងៃ ១.០០០ នាក់ តាមប្រកាស ឯទេវបុត្ត ក៏ទ្រង់សាងមនុស្សឡើងមួយថ្ងៃ ១.៥០០ នាក់រាល់ថ្ងៃដែរ ដោយហេតុនេះ ប្រទេសជប៉ុន មានមនុស្សកើតច្រើនជាងស្លាប់ ហើយមានភ័យវិបត្តិធ្វើអោយប្រជាជនបង់ជីវិតក្នុងមួយគ្រាៗ ជាចំនួនច្រើន ដូចទឹកជោរជន់មកលិចស្រុក ភ្នំភ្លើងផ្ទុះ ផែនដីកម្រើក តាមពាក្យផ្ដាសារបស់ទេវធីតា ជាដើមកំណើតអង្គនោះ ។

ក្នុងតម្រាបុរាណរបស់ចិន ក៏មានរឿងនិទាលទុកថា មនុស្សដែលបានមកចាប់កំណើតឡើងក្នុងលោកនេះ ថាដើមដំបូងមានព្រះមួយអង្គនៅក្នុងលោកនេះទ្រង់ព្រះនាមថា សែកកៀម្វនីប៉ុត ទ្រង់ទតមើលលោកដែលមានទ្វីប ៤ គឺទ្វីបខាងកើត, ទ្វីបខាងលិច, ខាងជើង, ខាងត្បូង ទ្វីបខាងត្បូងមានឈ្មោះថាណាំជៀងប៉ូជីវ នៅមានពពកអ័ព្ទមីរងងឹត ព្រះសែកកៀម្វនីប៉ុត ប្រាថ្នានឹងធ្វើទៅជាមនុស្សលោក ទើបទ្រង់បង្គាប់យុនតប៉ែងឆាណា ឬដែលហៅថា ប៊ុនកោជី ឬដែលហៅក្លាយមកថាស្ដេចកោសី ព្រាហ្មណ៍ហៅថាវិស្សកម្ម ឬវិស្ណុកម្ម អោយចុះមកបើកដីនិងមេឃ ទើបស្ដេចព័នកោសីនិម្មិតរាងកាយជាផ្លែឈើ ១ យ៉ាង មានគ្រាប់ខាងក្នុងជារូបទារក ធ្លាក់ចុះពីមេឃវិលរមៀលធ្លាក់មក ៤៩ ដង ( ត្រឡប់ ) ទើបផ្លាស់ប្រែជារាងកាយមនុស្ស ត្រង់ក្បាលដុះស្នែង ងស្ចើត រង្វង់ភ្នែកមូលធំ មានចង្កូមលៀនចេញមកក្រៅមាត់ មានរោមដុះពេញខ្លួន នៅដៃឆ្វេងមានកាន់ពន្លាក ដៃស្ដាំកាន់ពូថៅធំ ហើយចោះដាប់ទីងងឹតអ័ព្ទនេះដោយកំលាំងឥទ្ធិរិទ្ធិបែកចេញជាពីរចំណែកៗ ដែលមានលក្ខណៈថ្លានោះក្លាយទៅជាមេឃ ចំណែកកករល្អក់នោះធ្លាក់ចុះទៅក្រោម ក្លាយទៅជាផែនដី ។ វេលាដែលស្ដេចព័នកោសីទ្រង់កសាងមេឃនិងផែនដីនោះ ស្មានមើលប្រហែលជាពីរម៉ឺនឆ្នាំ លុះកន្លងកាលមកជាយូរអង្វែងចំហាយមេឃ និងចំហាយដីប៉ះសម្ពស្សគ្នាទៅកើតជាដុំសិលាមូលមានទំហំធំ ហើយបែកចេញជាដុំតូចៗទៀត ១២ ដុំ ដុំសិលាដែលកើតឡើងអំពីចំហាយដីមេឃ ទាំង

១៣ ដុំនេះ ប្រែក្លាយជាមនុស្សឡើងចំនួន ១៣ នាក់ ដុំមុនដំបូងជាបងប្រុសច្បង បានធ្វើជាហាងតេ គឺមហាក្សត្រ តាមតម្រារបស់ចិនបានសំដែងទុកថា មនុស្សទាំង ១៣ នាក់នេះជាអំបូរព្រះឥស្វរ ទើបមានពូជពង្សវង្សមនុស្សជាប់តគ្នារៀង១មកជាលំដាប់ ដោយនិយមឧត្តុនិយម និងឧបបាតិកកំណើត ដោយហេតុចំហាយមេឃជាភេទប្រុស ចំហាយដីជាភេទស្រី ។ តមកទៀត ព្រះសែកក្មៀម្ងនីហ៊ុត ទ្រង់ប្រើព័នកោសីអោយទៅរញ្ជើញស៊ឹងខ័យ យីហាជីជិន គឺព្រះអាទិត្យ និងថាំងប៊ី យីហាធៀនហៀន គឺព្រះចន្ទ ឯតំបន់ណាហាំទឹកអោយដើរមកឆ្លុះលោកតាមចក្ររាសី ។ មនុស្សដែលកើតឡើងក្នុងសម័យជាន់ក្រោយមក បានអាស្រ័យពន្លឺនេះជាគ្រឿងញុំាងជីវិត និងញុំាងសេចក្តីចំរើនអោយកើតឡើងដរាបមក ។

ក្នុងតម្រាបុរាណរបស់ក្រិក បានកត់ត្រាទុកដោយជនជាតិសាលដេ ឈ្មោះប៊ីរូស័ស កាលមុនគ្រិស្តសករាជប្រហែល ៣០០ ឆ្នាំ មានសេចក្តីថ្លែងពីកំណើតមនុស្សយ៉ាងចំឡែកទុកថា ក្នុងអតីតកាលជាអង្វែងមកហើយនោះ មានទីយ៉ាងធំទូលាយសំបើមណាស់ មានតែងងឹតស្អាប់អ័ព្ទអួរដេរដាស ហើយមានទឹកពាសពេញទូទៅជាលំនៅរបស់សត្វនានា មានរូបរាងមុខគួរអោយខ្ពើម ឯមនុស្សនោះសោត មានស្លាបមួយក៏មាន មានមុខមួយក៏មាន មានមុខពីរក៏មាន ទាំងប្រុសទាំងស្រី អ្នកខ្លះមានគូថជាពពែ មានស្នែងដុះនៅលើក្បាល អ្នកខ្លះមានជើងមានក្រចកដូចសេះ អ្នកខ្លះមានខ្នងជាសេះ មានមុខជាមនុស្ស និងសត្វស្លាបផ្សេង១ សត្វល្អូនវារ និងសត្វឯទៀត១ច្រើនជាអនេក ។ ព្រះជាម្ចាស់ដែលទ្រង់គ្រប់គ្រងនោះ ទ្រង់ព្រះនាមថាបែល ហើយមានស្រីឈ្មោះអូម្ពូរ៉ីកា ដែលជាអ្នកគ្រប់គ្រងមនុស្ស និងសត្វទាំងពួង ។ លុះកាលតមក ព្រះជាម្ចាស់ដែលទ្រង់ព្រះនាមព្រះបែលនោះ បានទ្រង់ញែកបំបែកងងឹតចេញហើយ ទ្រង់បណ្តាលអោយនាងអូមរ៉ីកាដាច់ខ្លួនជាពីរកំណាត់ គឺមួយកំណាត់ទ្រង់បណ្តាលអោយកើតឡើងជាលោក មួយកំណាត់ទៀត ទ្រង់សាង

ឡើងជាព្រះអាទិត្យ ព្រះចន្ទ និងជាពពួកផ្កាយ ហើយទ្រង់បណ្ដាលអោយទឹកហូរចូលទៅក្នុងពសុធា ។ សព្វសត្វដែលមានជីវិតទាំងពួង ដែលមានមកពីដើម មិនអាចនឹងធន់កំដៅរបស់ដួងអាទិត្យបាន ក៏អន្តរធានបាត់បង់សាបសូន្យអស់ទៅ ទើបព្រះវិបែលកាត់ព្រះសិរបស់ព្រះអង្គចេញ ហើយទ្រង់បង្គាប់អោយទេវទូតមួយអង្គយកព្រះលោហិតដែលហូរចេញពីព្រះសិរនោះទៅផ្សំនឹងដី ហើយអោយសាងដីផ្សំនឹងលោហិតនេះជាមនុស្ស និងសត្វក្នុងលោក អោយមានរូបរាងដូចគ្នាជាពួក១ តាំងអំពីកាលនោះមក ទើបមនុស្សមានពូជពង្សវង្សត្រកូលមកតាំងអំពីប្រទេសសាលដេរហូតមកដល់សព្វថ្ងៃនេះ ។

ពោលអំពីកំណើតរបស់មនុស្សជាតិ ដែលអ្នកប្រាជ្ញបុរាណ និងសម័យបច្ចុប្បន្ននេះបានពោលអាងនោះ សុទ្ធតែមានសេចក្ដីផ្សេង១គ្នា ដូចបានសំដែងខាងដើមនេះ ត្រង់សេចក្ដីដែលថ្លែងថាមនុស្សកើតពីធាតុ គឺចំហាយមេឃ និងចំហាយដីក៏មានសេចក្ដីល្មមស្ដាប់បានតាមគោលវិជ្ជាការ ដែលអាចសន្និដ្ឋានថាសេចក្ដីពិត ក៏សឹងថាបាន ។

តាមយោបល់របស់មនុស្សក្នុងបុរាណសម័យ ចែកធាតុចេញជា ៤ ផ្នែក គឺ បឋវីធាតុ ( ធាតុដី ) អាបោធាតុ ( ធាតុទឹក ) វាយោធាតុ ( ធាតុខ្យល់ ) តេជោធាតុ ( ធាតុភ្លើង ) ប្រកបផ្សំគ្នាសមសួនធួនល្មមតាមធម្មតានិយម ធ្វើអោយកើតជារាងកាយ មានរូបរាងចំរើនឡើងតាមលំដាប់ ដោយមានការដឹងខ្លួន ស្គាល់រសដឹងសេចក្ដី ដឹងគំនិតគិតគូរ ចេះត្រិះរិះកិច្ចការទាំងពួង កាលបើមានចំណែកណាមួយខ្វះខាត និងទ្រុឌទ្រោមទៅ ក៏កើតជំងឺឈឺចាប់ ចំណែកផ្សេង១របស់រាងកាយក៏មិនធ្វើការទាក់ទងគ្នា ហើយឈប់ស្ងៀម មានអាការស្ពឹកស្ពឹងទៅក្នុងកាលនោះយើងហៅថា ស្លាប់ រាងកាយក៏ត្រជាក់ស្រេប អវយវៈផ្សេង១ ក៏រលួយរលាយពុកផុយអស់ទៅ មានទំនងដូចគ្នាគ្រប់រូប តាំងអំពីបុព្វបុរសមុនបង្អស់ ដរាបមកដល់

ឥឡូវនេះ ។

ឯអ្នកដែលប្រកាន់ជឿថា មនុស្សកើតមកពីព្រះជាម្ចាស់សួគ៌នោះ យល់ថា ព្រះជាម្ចាស់សួគ៌ទ្រង់មានឫទ្ធានុភាពច្រើនណាស់ ទ្រង់សាងអ្វីៗបានតាមប្រាថ្នា តែប្រសិនបើសួរថា ព្រះជាម្ចាស់កើតមកពីអ្វី គង់មិនមានអ្នកឆ្លើយដោះដោយច្បាស់លាស់បាន ។

ប្រសិនបើយល់ថា ព្រះជាម្ចាស់ទ្រង់សាងលោក និងមនុស្សអោយកើតមកសំរាប់ប្រដាប់លោក ម្តេចក៏មិនទ្រង់សាងមនុស្សល្អៗមកប្រដាប់លោក ហេតុអ្វីក៏ទ្រង់សាងមនុស្សដែលមានឥច្ឆា ឈ្នានីស រំលោភលើអ្នកដទៃ ដែលមានលក្ខណៈជាមនុស្សពាល ជាចោរ ជាដើម ។

ដែលថាមនុស្សកើតមកពីសត្វតិរច្ឆាននោះ ហាក់ដូចជាមិនសមហេតុផលដែរ ព្រោះមនុស្សជាសត្វមួយពួក ដែលមានសតិបញ្ញា និងគំនិតគិតគូរដ៏ខ្ពង់ខ្ពស់ មិនគួរយល់ថាជាពួកពូជពង្សវង្សត្រកូលសត្វតិរច្ឆានសោះឡើយ ។

ហេតុនេះ បរិយាយដែលនិយាយថា មនុស្សជាតិកើតមកពីអ្វី នៅតែងងឹតងងល់មិនទាន់ដាច់ស្រេចនៅឡើយ ។

*( ពីទស្សនាវដ្តី កម្ពុជសុរិយា លេខ ១០ / ១៩៤០ )*

# រឿង ក្អែក និង មៀម

ក្នុងសម័យដែលព្រះពុទ្ធជាបរមគ្រូនៃយើងទាំងឡាយ ទ្រង់បានត្រាស់ដឹងក្នុងលោកហើយ ព្រះអង្គទ្រង់គង់នៅនាវត្តជេតពន ជិតក្រុងសាវត្ថី ។ ជម្លោះរវាងក្អែក និងមៀម ចេះតែមានការបៀតបៀនគ្នាជានិច្ច ជាប់តាំងពីព្រេងនាយមក, ជួនកាលក្នុងវេលាថ្ងៃ ក្អែកដេញចឹកសម្លាប់មៀម, ដល់វេលាយប់ មៀមដេញចឹកសម្លាប់ក្អែកវិញ ពីព្រោះភ្នែកមៀមភ្លឺក្នុងពេលយប់ជាងពេលថ្ងៃ ។ ជួនកាលយប់ខ្លះមៀមចឹកសម្លាប់ក្អែកអស់ជាច្រើន ក្អែកខ្លះដាច់កធ្លាក់ចុះពីចុងឈើមកលើផ្ទៃដីត្រង់អាស្រមរបស់ភិក្ខុមួយរូប ដែលនៅក្នុងទីបរិវេណជិតព្រំវត្តជេតពន ជាកន្លែងដែលលោកតែងបោសសំអាតជាប្រក្រតី ។ រាល់តែព្រឹក ភិក្ខុតែងតែឃើញក្បាលក្អែកដាច់ធ្លាក់ចុះមកក្នុងទីជិតអាស្រមរបស់ខ្លួន ក៏យកហេតុនោះទៅប្រាប់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះនាំរឿងដ៏ចំឡែកនោះទៅក្រាបបង្គំទូលព្រះពុទ្ធជាម្ចាស់ទៀត ទើបព្រះអង្គទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ ក្អែក និង មៀម នោះ ដែលកើតហេតុទាស់ទែងនឹងគ្នា មិនមែនទើបតែនឹងមានក្នុងកាលឥឡូវនេះទេ គឺមានតាំងតែពីដើមយូរអង្វែងណាស់មកហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសួរថា ចុះក្អែក និងមៀម ដែលមានពំនៀវនឹងគ្នាយ៉ាងនេះ តើកើតមានតាំងពីកាលណាមក ព្រះអង្គ ? ព្រះសម្ពុទ្ធទ្រង់សំដែងប្រាប់ភិក្ខុទាំងឡាយនោះថា :

រឿងវិវាទរវាងក្អែក និងមៀមនេះ មានតាំងពីបឋមកប្បដែលទើបនឹងកកើតដីទឹកឡើងជាដំបូង, កាលបើផែនដីកើតឡើងហើយ ឯពួកមនុស្ស និងពួកសត្វក៏កើតមានឡើងដែរ ។ សម័យនោះ ទាំងមនុស្ស ទាំងសត្វ នៅមានឋានៈស្មើៗគ្នា គេមិនទាន់តាំងនរណាមួយ អោយជាអ្នកមានឥស្សរភាព សំរាប់ត្រួតត្រាមើលការខុស

ត្រូវដល់គ្នានឹងគ្នានៅឡើយទេ, ម៉្លោះហើយមនុស្ស និង សត្វទាំងនោះ កាលបើមានកិលេស គឺ លោភៈ ទោសៈ មោហៈ កើតចំរើនឡើងហើយ ក៏ចេះតែមានការរំលោភឈ្លានពានបៀតបៀនគ្នាទៅវិញទៅមក ។ កាលជាខាងក្រោយមក ពួកមនុស្សបានប្រជុំពិភាក្សាគ្នាថា យើងគួរតែជ្រើសរើសនរណាម្នាក់ដែលមានរូបសម្បត្តិសមរម្យ មានប្រាជ្ញាឈ្លាសវៃ ព្រមទាំងមានចរិយា ឫកពា សណ្ដាប់ធ្នាប់ល្អ គួរជាទីពេញចិត្តនៃជនទាំងពួង អោយធ្វើជាធំ ( ស្ដេច ) សំរាប់ត្រួតត្រាមើលការខុសត្រូវរបស់មនុស្សទូទៅ លុះប្រឹក្សាព្រមព្រៀងគ្នាហើយ ក៏លើកបុរសម្នាក់ដែលគេយល់ថា មានលក្ខណៈសមរម្យអោយធ្វើជាស្ដេចឡើង ហើយថ្វាយព្រះនាមថា ព្រះបាទសន្មតរាជ ( ស្ដេចកើតឡើងដោយប្រជាជនសន្មត ) មានតាំងពីកាលនោះមក ។

ចំណែកខាងពួកសត្វចតុប្បាទ ( សត្វជើង ៤ ) បានប្រជុំប្រឹក្សាគ្នារើសរកសត្វអោយធ្វើជាស្ដេចដែរ លុះប្រឹក្សាទៅឃើញថា សត្វសីហៈ ជាសត្វសមរម្យ មានឥទ្ធិពលខ្លាំងពូកែលើសសត្វទាំងឡាយឯទៀត អាចនឹងត្រួតត្រាលើសត្វដទៃបាន ក៏ព្រមព្រៀងគ្នាលើកសត្វសីហៈ តាំងអោយធ្វើជាស្ដេចឡើង ហៅថា រាជសីហៈ ឬ រាជសីហ៍ ( សីហៈ ជាស្ដេចនៃសត្វចតុប្បាទទាំងឡាយ ) មានតាំងពីកាលនោះមក ។

ចំណែកខាងពួកមច្ឆា ( ត្រី ) ក្នុងមហាសមុទ្រ ក៏មានយោបល់យល់ឃើញដូចជាពួកសត្វចតុប្បាទដែរ លុះប្រឹក្សាគ្នាទៅ មានការព្រមព្រៀងគ្នាហើយ ក៏លើកត្រីឈ្មោះអានន្ទ អោយធ្វើជាស្ដេចត្រួតត្រាលើត្រីទាំងឡាយទូទៅ ( អានន្ទមច្ឆា ជាស្ដេចនៃត្រីទាំងឡាយ ) មានតាំងពីកាលនោះមក ។

គ្រានោះ ពួកបក្សី ( សត្វស្លាប ) ក្នុងហិមវន្តប្បទេស បានប្រជុំគ្នានឹងភ្នំមួយ ប្រឹក្សាគ្នាថា ពួកមនុស្ស គេជ្រើសរើសគ្នាតាំងអោយធ្វើជាស្ដេចសំរាប់ត្រួតត្រា មានរួចហើយ, ឯខាងពួកសត្វចតុប្បាទ និងពួកមច្ឆា គេក៏បានរៀបចំគ្នាអោយមានស្ដេចអស់ហើយដែរ, នៅឡើយតែពួកយើងជាបក្សី មិនទាន់មានស្ដេចដូចគេ

នៅឡើយ, ការនៅដោយគ្មានសេចក្ដីគោរព កោតខ្លាចគ្នាទៅវិញទៅមកដូច្នេះនេះ ជាការពុំគួរដល់ពួកយើងរាល់គ្នាទេ, បើដូច្នេះ ពួកយើងគួរតែជ្រើសរើសយកអ្នកណាមួយអោយធ្វើជាស្ដេចឡើង ។ ខណៈនោះ មៀមមានសេចក្ដីព្រួយដោយខ្លាចក្រែងឋានៈស្ដេចនោះបានទៅលើក្អែក ក៏ខំដើរធ្វើអន្តរាគមន៍នឹងបក្សីឯទៀត ពីមួយទៅមួយថា ពួកយើងកុំយកក្អែកអោយធ្វើជាស្ដេច ព្រោះក្អែកនេះ រូបអាក្រក់ណាស់ ហើយខ្មៅឃ្លីក គ្មានសល់ចន្លោះត្រង់ណាទេ បើរូបខ្មៅហើយ ចិត្តក៏ខ្មៅអាក្រក់ដែរ ទាំងឫកពាក៏ថោកទាបទៀត ជាអ្នករបិញរបុញ ខិលខូចណាស់, បើពួកយើងលើកក្អែកអោយធ្វើជាស្ដេច ពួកយើងមុខជាត្រូវបានទទួលទុក្ខវេទនាអំពីក្អែកនោះវិញ ពុំខានឡើយ ។ ឯក្អែកបានដឹងឧបាយកលរបស់មៀមដែលដើរញុះញង់ដូច្នោះហើយ ក៏គិតទុកក្នុងចិត្តថា មិនអីទេ មៀមឯងគង់តែនឹងដឹងគ្នា ។

ក្នុងពេលដែលពួកសត្វបក្សីមកជួបជុំគ្នាហើយ មានបក្សីមួយឡើងប្រកាសថា អ្នករាល់គ្នា ចូរស្ដាប់ខ្ញុំ, ឥឡូវនេះ យើងគួរជ្រើសរើសអ្នកណាអោយធ្វើជាស្ដេច ? បក្សីទាំងអស់នាំគ្នាគយគន់រកមើលក្នុងចំណោមបក្សីទាំងនោះទៅឃើញមៀមជាសត្វអង់អាចគួរអោយធ្វើជាស្ដេច ហើយក៏បញ្ចេញមតិយល់ស្របគ្នាថា ពួកយើងពេញចិត្តនឹងមៀមនេះ គួរយកមៀមអោយធ្វើជាស្ដេច។ គ្រានោះ មានបក្សីមួយទៀតឡើងប្រកាសថា ឥឡូវ បើអ្នករាល់គ្នាពេញចិត្តនឹងមៀមហើយ, យើងសូមប្រកាស ៣ ដងថា អ្នកទាំងអស់គ្នា ប្រាកដជាពេញនឹងមៀមមែនឬ ? បើអ្នកណាមិនពេញចិត្តទេ ចូរឆ្លើយមក ! ប្រកាសលើកទី ១ បក្សីទាំងអស់នៅស្ងៀម, ប្រកាសលើកទី ២ ក៏គ្មានបក្សីណាឆ្លើយ ប៉ុន្តែ ក្អែកខំប្រឹងទ្រាំអត់ មិនទាន់ថាអ្វីក្នុងលើកទី ១ និងលើកទី ២ លុះដល់ប្រកាសលើកទី ៣ ក្អែកក៏ស្ទុះឡើងជិទាស់ភ្លាមថា ខ្ញុំមិនពេញចិត្តទេ បើយកមៀមអោយធ្វើជាស្ដេច ។ - ហេតុអ្វីបានជាអ្នកឯងមិនពេញចិត្តនឹងមៀម ? - បានជាខ្ញុំមិនពេញចិត្ត ព្រោះមៀមមានលក្ខណៈមួយ

ខុសពីគេឯទៀត ។ - មៀមមានលក្ខណៈខុសពីគេត្រង់ណាខ្លះ ចូរអ្នកឯងថា មកមើល ? - ខ្ញុំមិនហ៊ានថាទេ បើលុះតែអ្នកទាំងអស់គ្នាអនុញ្ញាតអោយ ហើយរ៉ាប់រងទទួលខុសត្រូវផង ទើបខ្ញុំហ៊ានថា ។ - អើមិនអីទេ យើងទាំងអស់គ្នាអនុញ្ញាតអោយហើយ ចូរថាមកចុះ ! - ខ្ញុំស្ទើរតែមិនហ៊ានថាទេ ប៉ុន្តែ បើអ្នករាល់គ្នាទទូចបង្ខំអោយខ្ញុំថាហើយ ខ្ញុំត្រូវតែប្រថុយថាទៅចុះ អ្នករាល់គ្នាចូរសង្កេតមើលមុខ និងភ្នែករបស់មៀមនេះទៅចុះ មានលក្ខណៈខុសពីគេឯទៀត មុខគាត់នេះ ខឹងដូចជាដូចខឹង, ភ្នែកធំក្រហមលៀន, ជាពិសេស ចូរសង្កេតមើលទឹកមុខចុះ គាត់នេះមិនទាន់ខឹង មុខក្រញូវអាក្រក់ម្ល៉េះទៅហើយ ចំណង់បើដល់ខឹងឡើង តើមុខនឹងឡើងអាក្រក់យ៉ាងណាទៅទៀត ហេតុនេះបានជាខ្ញុំមិនពេញចិត្ត បើយើងលើកមៀមអភិសេកអោយធ្វើជាស្តេចកាន់អំណាចទៅ មុខមៀមមិនទាន់ខឹង អាក្រក់ម្លឹងទៅហើយ កាលបើដល់ពេលគាត់ខឹងឡើង នឹងទៅជាយ៉ាងណាទៅទៀត វាមុខជាធ្វើយើងទាំងអស់គ្នាអោយបែកបាក់ខ្ទេចខ្ទីស្លាប់អស់ជាមិនខាន ដូចជាអំបិលដែលគេដាក់ក្នុងអំបែងកំពុងក្តៅ ។

ក្អែកកាលបើនិយាយរិះគន់មៀមយ៉ាងនេះហើយ ក៏ស្រែកដោយសម្រែកយ៉ាងខ្លាំងថា « បើយកមៀមអោយធ្វើជាស្តេច យើងមិនព្រមជាដាច់ខាត »ហើយស្ទុះហើររត់ទៅ ។ ឯមៀម កើតសេចក្តីក្តៅក្រហាយខ្លាំង ក៏ស្ទុះហើរដេញពាមព្យាបាទក្អែកបាត់ទៅ ។ គ្រានោះ ពួកបក្សីបែកគ្នាជាពីរក្រុម ៖ មួយក្រុមកាន់ជើងខាងក្អែក, មួយក្រុមទៀត កាន់ជើងខាងមៀម ។ បក្សីណាដែលកាន់ខាងក្អែក បក្សីនោះហៅថា ទិវាចរ ( ពួកបក្សីចេញស្វែងរកចំណីតែក្នុងវេលាថ្ងៃ ) បក្សីណាដែលកាន់ខាងមៀម បក្សីនោះហៅថា រត្តិចរ ឬរាត្រិចរ ( ពួកបក្សីចេញស្វែងរកចំណីតែក្នុងវេលាយប់ ) ដើម្បីគេចចៀសមិនអោយជួបនឹងក្អែក ។ ក្អែក និង មៀមដែលកើតហេតុវិវាទទាស់ទែង ព្យាបាទ ចងពំនៀរនឹងគ្នាទៅវិញទៅមកនោះ មាន

តាំងពីកាលនោះមក ។

បន្ទាប់ពីនោះមក បក្សីទាំងឡាយ ក៏នាំគ្នាលើកហង្សអោយធ្វើជាស្ដេចឡើង ទើបមានពាក្យហៅជាប់មកថា « ហំសរាជា ស្ដេចហង្ស ឬ រាជហង្ស ហង្សជាស្ដេចនៃពួកបក្សី » មានតាំងពីកាលនោះមក ។

*( តិកនិបាតជាតក )*

*« កុំប្រព្រឹត្តអំពើបាប ចូរសាបព្រោះបណ្ដុះអំពើល្អ ចូរធ្វើចិត្តអោយបានបរិសុទ្ធ » ។ នេះគឺជាឱវាទរបស់ព្រះពុទ្ធ ។*

- ធម្មបទ -

***

# រឿង ពស់ និង ស្កា

កាលព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទាំងឡាយ ព្រះអង្គបានត្រាស់ដឹងក្នុងលោកហើយ ទ្រង់គង់នៅនាវត្តជេតពន ជិតរាជធានីសាវត្ថី ។ គ្រានោះ ភិក្ខុទាំងឡាយនាំគ្នាដើរចូលទៅកាន់ស្រុកមួយ ដើម្បីបិណ្ឌបាត, លុះដល់ពាក់កណ្ដាលផ្លូវបានប្រទះឃើញពស់ និង ស្កា កំពុងតែទាស់ទែងគ្នា បៀតបៀនគ្នាដោយកម្លាំងកាយទៅវិញទៅមក ។ លុះដល់ទីបំផុតនៃការឈ្លោះគ្នា ពស់ក៏ដល់នូវទុក្ខលំបាក ពិការ

ផមផយកម្លាំង ដោយការចាញ់ឧបាយកលរបស់ស្ទា ។ ភិក្ខុទាំងនោះ កាលបើត្រឡប់មកពីបិណ្ឌបាតវិញហើយ នាំគ្នាចូលទៅកាន់សំណាក់ព្រះពុទ្ធជាម្ចាស់ ហើយក្រាបបង្គំទូលអំពីដំណើរដែលខ្លួនបានឃើញពស់ និងស្ទា ដែលកើតវិវាទទាស់ទែងនឹងគ្នាថ្វាយព្រះអង្គទ្រង់ព្រះសណ្ដាប់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងពីរ គឺពស់ និងស្ទានោះ មិនមែនទើបតែកើតវិវាទនឹងគ្នាក្នុងកាលឥឡូវនេះទេ គឺកើតវិវាទនឹងគ្នាយ៉ាងនេះ តាំងពីព្រេងនាយម្ល៉េះ, កាលនោះ តថាគតជាពោធិ-សត្វនៅឡើយ, ពោធិសត្វនោះ កើតក្នុងត្រកូលនៃព្រាហ្មណ៍នៅក្នុងស្រុកមួយជិតក្រុងពារាណសី លុះមានវ័យចំរើនឡើងហើយ ក៏ចេញទៅបំពេញវិជ្ជា ឯនគរតក្ក-សិលា ។ ការសិក្សាវិជ្ជារបស់ពោធិសត្វនោះមិនយូរប៉ុន្មាន ក៏បានចេះដឹងសព្វគ្រប់ហើយត្រឡប់មកនៅគ្រប់គ្រងគេហដ្ឋាន ប្រកបអាជីវភាពតាមប្រពៃណីរបស់ត្រកូល, លុះដល់បច្ឆិមវ័យ ពោធិសត្វក៏លះបង់ឃរាវាស ចេញទៅបួសជាឥសី តាំងអាស្រមនៅក្នុងហិមវន្តប្បទេស បានបំពេញតបធម៌ ហើយញ៉ាំងអភិញ្ញា ៗ និងសមាបត្តិអោយកើតឡើង នៅជាសុខសាន្តក្នុងទីនោះ ដោយអាស្រ័យនូវមើមឈើ និងផ្លែឈើជាអាហារ ។

នៅចុងទីចង្ក្រមនៃតាបសពោធិសត្វនោះ មានស្ទាមួយផ្ទើរងនៅក្នុងដំបូកមួយ, មានពស់មួយនៅនឹងគល់ឈើជិតស្ទានោះដែរ ។ សត្វទាំងពីរនោះវេលាឃើញគ្នាកាលណា រមែងតែឈ្លោះបៀតបៀនគ្នាជាធម្មតា ។ ពស់ជាសត្វល្ងង់ហើយខ្ជិល មិនចេះផ្ទើរងនៅ ឃើញស្ទាមានរូងនៅស្រួល ក៏គិតថាអញនឹងសម្លាប់ស្ទាយកធ្វើជាអាហារផង និងយករូងវានៅផង ។ ឯស្ទាបានដឹងថាពស់បំរុងនឹងព្យាបាទខ្លួនអោយវិនាសជីវិត ក៏ប្រុងស្មៀតប្រយ័ត្នខ្លួនជានិច្ច ដើម្បីតទល់នឹងពស់នោះវិញដែរ ។ ពោធិសត្វបានឃើញពស់ និងស្ទាទាស់ទែងគ្នាស្ទើរតែរាល់ថ្ងៃ ក៏ព្យាយាមអោយឱវាទចំពោះសត្វទាំងពីរ អោយមានសាមគ្គីរួបរួមគ្នា កុំអោយទាស់ទែងនឹងគ្នា

តទៅទៀត ។ ឯពស់និងស្កា ដោយអំណាចបានស្តាប់ឱវាទតាបសហើយ ក៏ផ្អាកឈប់ឈ្លោះគ្នាដែរ ប៉ុន្តែកំហឹងនិងការចងគំនុំនឹងគ្នាទៅវិញទៅមកពុំរលត់បាត់នៅឡើយ ។

ថ្ងៃមួយ ពស់ចេញទៅស្វែងរកអាហារខាងក្រៅបាត់ទៅ ស្កាដេកហាមាត់បញ្ចេញចង្កូមដាក់ក្បាលប៉ប៉ុមនឹងមាត់រូង កំពុងលក់ដកដង្ហើមចេញ-ចូលឮសូរឃ្លឹៗ ខ្ញុំ ។ តាបស់ដើរទៅជិតដំបូក បានឃើញស្កានោះកំពុងដេកលក់ដូច្នោះ ក៏ស្រែកសួរថា នែស្កា ! ឯងដេកធ្វើអាការៈដូច្នេះ ហាក់ដូចជាប្រុងស្មៀតការពារនឹងភ័យអ្វីមួយដែលនឹងមានមកដល់ខ្លួនឯងឬ ? ស្កា - ខ្ញុំសព្វថ្ងៃនៅជាមួយបច្ចាមិត្ត គួរតែខ្ញុំប្រុងប្រយ័ត្នជានិច្ចគ្រប់ឥរិយាបថដូច្នេះទើបបាន ។ តាបស - អ្នកណាជាបច្ចាមិត្តនឹងឯងដែលប្រុងនឹងធ្វើឯងអោយមានភ័យ ? ស្កា - ពស់ជាបច្ចាមិត្តនឹងខ្ញុំ ។ តាបស - ឯងកុំភ័យព្រួយបារម្ភអ្វី យើងនឹងធ្វើមិនឱ្យពស់នោះប្រទូស្តបៀតបៀនដល់ឯងទៀតទេ, កុំឱ្យឯងរង្កៀសចិត្តនឹងពស់នោះតទៅទៀត ។ ស្កា - ឱវាទរបស់លោក ខ្ញុំស្តាប់បានអស់ហើយ ប៉ុន្តែនៅមិនទាន់អស់ប៉ោយពីក្នុងចិត្តខ្ញុំសោះ ។ តាបសពោធិសត្វ ឋិតនៅជាសុខក្នុងឈានសមាបត្តិ លុះដល់ទីបំផុតនៃអាយុ ក៏បានទៅកើតក្នុងព្រហ្ម-លោកនាយទៅ ។ ឯពស់ និងស្កា នោះ គ្រាន់តែមិនបានឈ្លោះបៀតបៀនក្នុងជាតិនោះ ដោយអំណាចឱវាទនៃពោធិសត្វ ប៉ុន្តែ កំហឹងនិងការចងពំនៀរគុំគួននឹងគ្នាទៅវិញទៅមក ជាប់មានតាំងពីកាលនោះមក ។

*( ទុកនិបាតជាតក )*

> *« គេអាចឈ្នះសត្រូវរាប់ពាន់នាក់ ក្នុងលានប្រយុទ្ធរាប់ពាន់កន្លែង,*
> *តែនរជនណាអាចជំនះខ្លួនឯងបាន ជាជ័យជំនះប្រសើរបំផុត » ។*
>
> - ធម្មបទ -

# រឿង ខ្លាឃ្មុំ និង ដើមពង្រ

ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធជាបរមសាស្តានៃយើង ទ្រង់គង់នៅទៀបឆ្នេរនៃស្ទឹងរោហិណី ដើម្បីសំដែងធម៌រំងាប់នូវអធិករណ៍ នៃពួកព្រះញាតិរបស់ព្រះអង្គ ។ ក្នុងពេលនោះ ព្រះអង្គទ្រង់លើកយកធម៌ និងរឿងផ្សេងៗ ជាច្រើនមកសំដែង ដើម្បីអោយពួកព្រះញាតិទាំងនោះស្តាប់ហើយ នឹងលះបង់នូវការវិវាទដែលជាហេតុនាំអោយចងពៀរវេរានឹងគ្នាតទៅក្នុងពេលអនាគតទៀត ។ ក្នុងទីនេះ ខ្ញុំសូមលើកយកចំពោះតែរឿងខ្លាឃ្មុំ និងដើមពង្រ ដែលចងពៀរនឹងគ្នាមកដំណាលជូនជាសណ្តាប់ ដូចតទៅនេះ :

នៅខាងក្រៅទីក្រុងពារាណសី មានស្រុកមួយ ច្រើនតែពួកជាងឈើនៅអាស្រ័យ ។ បណ្តាពួកជាងឈើដែលនៅក្នុងស្រុកនោះ មានជាងឈើម្នាក់ តែងទៅនាំយកឈើទាំងឡាយអំពីព្រៃមកធ្វើគ្រឿងរថ ( រទេះ ) សម្រាប់លក់ចិញ្ចឹមជីវិត ។ កាលនោះ មានដើមពង្រមួយដើមធំ ដុះនៅក្នុងហិមវន្តប្បទេស ។ មានខ្លាឃ្មុំមួយស្វែងរកចំណីបរិភោគ ហើយមកដេកក្បែរគល់ពង្រនោះ ។ ចួនជាក្នុងថ្ងៃនោះ មានខ្យល់បក់មក មែកពង្រស្ងួតក្រៀមមួយមែកបាក់ធ្លាក់ចុះមកដោយកម្លាំងខ្យល់ ក៏សង្កត់កខ្លាឃ្មុំ, ខ្លាឃ្មុំមានសេចក្តីឈឺចាប់យ៉ាងខ្លាំង ទាំងមានសេចក្តីភិតភ័យដោយមិនដឹងជាអ្វីក៏ស្ទុះរត់ចេញទៅខាងក្រៅ, បន្តិចត្រឡប់មករកមើលត្រង់កន្លែងនោះវិញមិនឃើញមានអ្វីប្លែកសោះ ឃើញតែមែកពង្រដែលបាក់ធ្លាក់មកនោះ ។ ខ្លាឃ្មុំកើតសេចក្តីក្រោធមិនសមហេតុសមផលត្រឡប់ជាខឹងចងគំនុំនឹងដើមពង្រ ដោយគិតថា ឥឡូវនឹងថាមានសីហៈ ឬខ្លាធំណាមួយមកដេកព្យាបាទដល់អញក៏ទេដែរ, ទំនងជាមានទេវតានៅនឹងដើមឈើនេះកាច់មែកពង្រទម្លាក់មកលើអញ ដែលអញកំពុងដេកក្នុងទីនេះ មិនអីទេ គង់តែនឹងដឹងគ្នា ។ ខ្លាឃ្មុំខឹងណាស់ ក៏ស្ទុះទៅប្រហារ

ដើមពង្រនោះដោយចង្កូម ហើយគំរាមរុក្ខទេវតាថា អញគ្មានត្រូវការស៊ីស្លឹកនិងមែកឈើរបស់អ្នកឯងទេ ម្ដេចក៏ឯងមកបៀតបៀនអញ អញមានទោសកំហុសដូចម្ដេច? អើមិនអីទេ ចាំមើលតែពីរបីថ្ងៃទៀត អញនឹងអោយគេកាប់គាស់រំលើងដើមឈើព្រមទាំងឫសគល់របស់អ្នកឯង ហើយអោយគេកាត់ជាកំណាត់តូច កំណាត់ធំផងទៀត ពុំខាន ។ គ្រានោះ ជាងឈើនោះឯងបាននាំកម្មករពីរបីនាក់បរទេះចូលទៅក្នុងព្រៃ ដើម្បីរកឈើធ្វើគ្រឿងរទេះ ។ លុះដល់ក្នុងព្រៃហើយក៏បញ្ឈប់រទេះទុកក្នុងទីមួយ នាំគ្នាកាន់កាំបិត និងពូថៅដើរចូលទៅជិតដើមពង្រនោះ ។ ខ្លាឃ្មុំឃើញជាងឈើនោះគិតថា « អីត ថ្ងៃនេះ អញបានឃើញខ្នងបច្ចាមិត្តហើយ » ក៏ស្ទុះមកឈរជិតដើមពង្រ ។ ចំណែកខាងជាងឈើដើរបណ្ដើរ គយគន់រកមើលបណ្ដើរ ក្រែងប្រទះឈើដែលខ្លួនត្រូវការ ។ ខ្លាឃ្មុំស្រែកសួរថា នែជាងឈើ ! អ្នកឯងកាន់ដឹងជាប់នឹងដៃដើរចូលមកក្នុងព្រៃ ប្រាថ្នារកកាប់ឈើអ្វី ? ជាងឈើ - ខ្ញុំមករកកាប់ឈើណាដែលមានសាច់ជាប់ល្អយកទៅធ្វើគ្រឿងរទេះ ។ ខ្លាឃ្មុំ - ខ្ញុំនៅក្នុងព្រៃនេះ ខ្ញុំស្គាល់ឈើគ្រប់ទាំងអស់ គឺឈើណាជាប់ ណាមិនជាប់ ឥតមានកំបាំងពីខ្ញុំទេ ។ ជាងឈើឱមែនហើយ អ្នកឯងនៅព្រៃស្គាល់ឈើល្អ និងឈើមិនល្អ ចុះឈើអ្វីដែលមានសាច់ជាប់មាំល្អ ? ខ្លាឃ្មុំ - រាំងភ្នំក្ដី គគីរក្ដី ថ្នឹកក្ដី សុក្រំក្ដី ដើមត្រចៀកប្រើសក្ដី ឈើទាំងនេះសុទ្ធតែឈើមានខ្លឹមមែនហើយ ប៉ុន្តែ មិនសូវជាប់មាំល្អប៉ុន្មានទេ បើបានឈើផ្នួនៈ ( ពង្រ ) ជាប់មាំល្អណាស់ ប្រើប្រាស់ទៅមិនងាយនឹងខូចទេ បើបែរជាយកទៅធ្វើជាគ្រឿងរទេះ មានខ្នងកង់ជាដើម ក៏រឹតតែជាប់មាំប្រសើរណាស់ទៅទៀត ។ ជាងឈើឮពាក្យខ្លាឃ្មុំប្រាប់ហើយក៏មានសោមនស្សរីករាយសប្បាយចិត្តគិតថា ថ្ងៃនេះអញមានភ័ព្វល្អណាស់តើ ចូលមកក្នុងព្រៃ មានសត្វតិរច្ឆានប្រាប់ឈើដែលគួរយកទៅធ្វើគ្រឿងរទេះ ក៏សួរទៅខ្លាឃ្មុំថា ចុះដើមពង្រនោះមានភាពបែបដូចម្ដេចខ្លះទៅ ព្រោះខ្ញុំមិនដែលស្គាល់ ? ខ្លាឃ្មុំ - ស្លឹកវារាងធំទ្រវែងបន្តិច, មែកវា

រាងស៊ាយាសំយុងចុះក្រោម, ផ្លែវារាងមូលជមបន្តិចជាចង្កោម ៗ ពួកមនុស្សតែង បេះយកទៅធ្វើជាអាហារបរិភោគ ឈើនេះសំខាន់ណាស់ បើយកទៅធ្វើជាកាំភ្លី ជា ខ្នងកង់ក្តី ជាដុំក្តី ជាប់ហើយធន់ផងទៀត គ្មានឈើណាពិសេសជាងពង្រនេះទៅ ទៀតទេ ។ ជាងឈើ - ចុះកន្លែងណា ដែលមានដើមពង្រ ? ខ្លាឃ្មុំ - បើអ្នកឯងមិន ស្គាល់ទេ ចូរមើលមកខ្ញុំ ខ្ញុំឈរជិតដើមឈើណា ដើមឈើនោះឯងហៅថា ពង្រ ។ ខ្លាឃ្មុំលុះបានប្រាប់ជាងឈើឱ្យស្គាល់ច្បាស់ហើយក៏មានចិត្តត្រេកអរណាស់ដោយ គិតថា នឹងបានសម្រេចដូចបំណងរបស់ខ្លួន ហើយថយទៅសំងំនៅក្នុងទីមួយលប ចាំមើលក្បែរនោះដែរ ។ ខណៈនោះ ជាងឈើក៏រៀបចំប្រាប់ពូនឹងកាប់ដើមពង្រ នោះ ។

រុក្ខទេវតា ដែលនៅនឹងដើមឈើនោះគិតថា ឱអញ គ្រោះថ្នាក់ដល់ហើយ តើ ! អន្តរាយនេះប្រាកដជាកើតមកពីខ្លាឃ្មុំនោះឯង ជាអ្នកញុះញង់បង្កហេតុ, ឯមែក ពង្របាក់ធ្លាក់ទៅលើវានោះដោយសារខ្យល់ទេ មិនមែនអញធ្វើឡើយ សូម្បីតែវត្ថុ អ្វីបន្តិចបន្តួចក៏អញមិនដែលធ្វើឱ្យធ្លាក់ចុះទៅលើវាដែរ, ឥឡូវ វាត្រឡប់ជាចងគំនុំ ខុសទំនងមិនសមហេតុសមផល ធ្វើវិមានរបស់អញឱ្យវិនាស ណ្ហើយចុះអញ បើ បំណាច់នឹងវិនាស ក៏ត្រូវតែធ្វើខ្លាឃ្មុំនោះឱ្យវិនាសដូចអញដែរ, ក៏តំណែងភេទជា បុរសម្នាក់ បែបភាពជាអ្នកធ្វើការក្នុងព្រៃ ហើយដើរចូលទៅជិតជាងឈើនោះ សួរ ថា នែជាងឈើ ! អ្នកឯងកាប់ឈើនេះបំរុងនឹងយកទៅធ្វើអ្វី ? ជាងឈើ - យកទៅ ធ្វើខ្នងកង់រទេះ គេថា ឈើហ្នឹងជាប់ ។ រុក្ខទេវតា - អ្នកណាប្រាប់អ្នកឯង ? ជាង ឈើ - ខ្លាឃ្មុំប្រាប់ខ្ញុំ ។ រុក្ខទេវតា - បើខ្លាឃ្មុំប្រាប់ ការនោះប្រាកដមែនហើយ ប៉ុន្តែ ឈើនេះបើយកទៅប្រើសុទ្ធតែវាមិនសូវជាជាប់អំណត់ប៉ុន្មានទេ បើបានស្បែកខ្លា ឃ្មុំត្រង់ករវា ប្រមាណប៉ុន ៤ ធ្នាប់ទទឹង យកមកពាសព័ទ្ធមណ្ឌលខ្នងកង់ពីខាងក្រៅ អោយដូចជាគេព័ទ្ធបន្ទះដែក ហើយយកខ្លាញ់វាមកលាបសាច់ឈើនោះខ្លះផង ហ្នឹង

រឹតតែជាប់អំណត់ណាស់ទៅទៀត ។ ជាងឈើ - អោយខ្ញុំទៅរកស្បែក និងខ្លាញ់ខ្លា ឃ្មុំនោះពីណាបាន ។ រុក្ខទេវតា - អ្នកឯងកុំល្ងង់ពេក, ដើមពង្រនេះដុះនៅក្នុងព្រៃ មិនរត់ទៅណាបាត់ទេ, ខ្លាឃ្មុំណាដែលប្រាប់អ្នកឯងថា ឈើហ្នឹងជាប់ អ្នកឯងចូរទៅ កាន់សំណាក់ខ្លាឃ្មុំនោះនិយាយបញ្ឆោតវាថា ឈើដែលអ្នកឯងបង្ហាញខ្ញុំនោះ, ឥឡូវ អោយខ្ញុំកាប់កាត់ត្រង់កន្លែងណាខ្លះ ចូរនាំវាអោយមកបង្ហាញ, កាលបើវាមកហើយ កំពុងតែយកចុងមាត់បង្ហាញថា អ្នកឯងចូរកាត់ត្រង់នេះ ឬចូរកាត់ត្រង់នោះ, អ្នកឯង យកពូថៅធំដ៏មុតកាប់សម្លាប់ ហើយពន្លះយកស្បែក ព្រមទាំងសាច់វាយកទៅ បរិភោគទៅ ។ ជាងឈើបានធ្វើតាមពាក្យដែលរុក្ខទេវតានោះបង្គាប់ហើយ ក៏ សម្លាប់ខ្លាឃ្មុំនោះបានហើយ, អារពន្លះយកស្បែក សាច់ និងខ្លាញ់ រួចហើយទើប កាប់ដើមពង្រនោះជាខាងក្រោយនាំយកទៅ ព្រោះហេតុនោះបានជា ខ្លាឃ្មុំ កាលណា បើវាប្រទះឃើញដើមពង្រ តែងតែស្ទុះទៅខ្វារដោយក្រចក ខាំកេរដោយចង្កូម ជា ធម្មតា ព្រោះមានពំនៀរនឹងគ្នា ជាប់តាំងពីកាលនោះមក ។

*( តេរសនិបាតជាតក )*

ពីទស្សនាវដ្ដី « ពន្លឺពុទ្ធចក្រ »
លេខ ១២ ឆ្នាំ ១៩៦៣

*« សេចក្ដីស្អប់ មិនអាចបញ្ចប់សេចក្ដីស្អប់បានជាដាច់ខាត មានតែសេចក្ដីស្រឡាញ់ទេ ដែលអាចបញ្ចប់សេចក្ដីស្អប់បាន ។ នេះជាច្បាប់ពីបុរាណ ។*

- ធម្មបទ -

# សុន្ទរកថា របស់
# សម្តេចព្រះមហាឃោសានន្ទ
# ក្នុងឱកាសទទួលរង្វាន់សន្តិភាព (*)

នៅទីក្រុងតូក្យូ, : 9-5-1998



( រូបថត របស់ មូលនិធិដើម្បីសន្តិភាព រិស្សូ កូសី-កៃ )

ជាបឋម សូមអនុញ្ញាតអោយខ្ញុំព្រះករុណា អាត្មាភាព បានសំដែងនូវកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅ ព្រមទាំងអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះអង្គការ រិស្សូ កូសី-កៃ និងមូលនិធិ នីវ៉ាណូ ដើម្បីសន្តិភាព ដែលមានព្រះតេជព្រះគុណ នីក្យូ នីវ៉ាណូ ជាស្ថាបនិកដ៏ល្បីល្បាញ និងព្រះតេជព្រះគុណ នីតិកូ នីវ៉ាណូ ជាប្រធានដ៏ឧត្តម ព្រមទាំងសមាជិក សមាជិកា ទាំងអស់ នៃអង្គការប្រកបដោយកិត្តិស័ព្ទនេះ ។

ថ្ងៃនេះ គឺជាទិវាប្រវត្តិសាស្ត្រប្រកបដោយមហាកិត្តិយសដ៏ឧត្តុង្គឧត្តមបំផុត ដែលខ្ញុំព្រះករុណា អាត្មាភាព មានវាសនាដ៏ខ្ពង់ខ្ពស់ បានមកចូលរួមរង្វាន់សន្តិភាព ពីមូលនិធិនីវ៉ាណូ ដើម្បីសន្តិភាព នៅក្នុងពិធីដ៏ឧឡារិកអធិកអធម នាពេលនេះ ។

ពីលើវេទិកានេះ ខ្ញុំព្រះករុណា អាត្មាភាព សូមឆ្លៀតឱកាសដ៏មហាប្រសើរនេះ ដើម្បីថ្លែងនូវសេចក្តីគោរព និងកោតសរសើរដោយស្មោះ ចំពោះសកម្មជនសន្តិភាពទាំងឡាយ ដែលបានទម្លាយរបាំងព្រំដែនជាតិសាសន៍ វប្បធម៌ និង

(*) សម្តេចព្រះមហាឃោសានន្ទ ជាព្រះសង្ឃខ្មែរទីមួយ ដែលបានទទួលរង្វាន់សន្តិភាព ពីមូលនិធិដើម្បីសន្តិភាពរបស់អង្គការ រិស្សូ កូសី-កៃ នៃប្រទេសជប៉ុន ។

សាសនា ដើម្បីវត្ថុបំណងដ៏ពិសិដ្ឋរបស់មនុស្សជាតិ គឺសន្តិភាពដ៏ស្ថិតស្ថេរមួយ នៅលើពិភពលោក ។

ខ្ញុំព្រះករុណា អាត្មាភាព បានខិតខំប្រឹងប្រែងរួមវិភាគទានដ៏ស្ទួចស្ទើងចំពោះចលនាសន្តិភាពខាងលើនេះ ។ មួយជំហានម្តង មួយជំហានម្តង យើងបានធ្វើដំណើរធម្មយាត្រា ជាមួយសកម្មជនសន្តិភាពទាំងឡាយនោះ នៅទូទាំងពិភពលោក ដើម្បីសន្តិភាពពិតប្រាកដមួយ ។

ការងាររបស់យើងដើម្បីសន្តិភាព គឺការងារព្រះធម៌របស់ព្រះពុទ្ធ ។ ការត្រាស់ដឹងរបស់ព្រះពុទ្ធ ប្រៀបបានទៅនឹងដើមពោធិព្រឹក្សមួយដើម ។ គឺព្រឹក្សានៃការត្រាស់ដឹង ។ ដើមឈើមានឫស មានតួដើម មានមែក មានស្លឹក មានផ្កា និងផ្លែ ។

- ផ្លែ គឺអរិយសច្ចៈ ៤, គឺទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ និងមគ្គសច្ចៈ ដែលជាផ្លូវកណ្តាលសំរាប់ប្រតិបត្តិដើម្បីរំលត់ទុក្ខ ។ នោះហើយគឺជាផ្លែរបស់ដើមពោធិ ។

ព្រះពុទ្ធបរមគ្រូ មានពុទ្ធដីកាថា ព្រះអង្គបានបង្រៀនអោយដឹងពីចតុរារិយសច្ចៈ ចំពោះអ្នកទាំងឡាយណាដែលយល់ពីវេទនា ដោយធ្វើសមាធិកម្មដ្ឋាន ។ វេទនាជាបាលី មានន័យថា ការឈឺចាប់ ហេតុដូច្នេះហើយបានជាគេហៅការឈឺចាប់ថា វេទនា ។

- សុខវេទនា ក៏ជាការឈឺចាប់ - វិបរិណាមទុក្ខតា
- ទុក្ខវេទនា ក៏ជាការឈឺចាប់ - ទុក្ខទុក្ខតា
- ឧបេក្ខាវេទនា ក៏ជាការឈឺចាប់ - សង្ខារទុក្ខតា

ប៉ុន្តែ យើងទាំងអស់គ្នាមិនបានដឹងអំពីសេចក្តីទុក្ខនោះទេ ។ យើងបរិភោគអាហារល្អៗ ហើយមានអារម្មណ៍ឆ្ងាញ់ ប៉ុន្តែ ភ្លាមនោះ យើងត្រូវទៅបង្គន់

នោះជាការទទួលអារម្មណ៍មិនល្អ នោះជាទុក្ខ ។ ទុក្ខវេទនា គឺសេចក្ដីទុក្ខនេះឯង ។ ឧបេក្ខាវេទនា គឺសង្ខារទុក្ខតា ក៏ជាទុក្ខដែរ ។

បញ្ឈប់ទុក្ខវេទនា គឺបញ្ឈប់ការឈឺចាប់ ។

ធ្វើសមាធិ គឺជាការព្យាបាល គឺនិរោធ ឬការបញ្ចប់ការឈឺចាប់ នេះជាផ្លែរបស់ដើមពោធិ ។

- មែកទាំងឡាយនៃដើមពោធិ គឺបដិច្ចសមុប្បាទ ឬធម៌ដែលកើតមានឡើងដោយសារបច្ច័យទាក់ទងគ្នាទៅវិញទៅមក ។ មាននេះកើតឡើង ក៏ព្រោះតែមាននោះកើតឡើង ។ ការដែលនេះរលត់ទៅ ក៏ព្រោះតែនោះបានរលត់ទៅ ។ វេទនាគឺជាមូលហេតុ បើយើងបញ្ឈប់វេទនាបាន ទើបយើងបញ្ឈប់តណ្ហា និងការឈឺចាប់បាន ។

- ផ្កានិងស្លឹក ជាពោធិបក្ខិយធម៌ទាំង ៣៧ នៃការត្រាស់ដឹងគឺ :

- សតិប្បដ្ឋាន ៤
- សមប្បធាន ៤ ( ការប្រឹងប្រែង )
- ឥទ្ធិបាទ ៤
- ឥន្ទ្រិយ ៥
- ពល ៥
- ពោជ្ឈង្គ ៧
- អដ្ឋង្គិកមគ្គ ៨

ទាំងអស់នេះទៅប្រមូលផ្ដុំក្នុងវេទនា ។ ដូច្នេះ ស្លឹកនិងផ្កាមកជាមួយគ្នាក្នុងវេទនា ។ ចាប់ផ្ដើមពីការប៉ះពាល់ វេទនាក៏កើតឡើង ។ ឫសនៃដើមពោធិ គឺសភាវៈ ៦ យ៉ាង គឺ : លោភៈ, ទោសៈ, និងមោហៈ ; អលោភៈ, អទោសៈ, ហើយនិងអមោហៈ ។

. ឫសទាំងអស់មកផ្តុំគ្នាក្នុងវេទនា ។ ប្រសិនបើយើងត្រួតត្រាវេទនាយើងបាននោះ យើងនឹងអាចប្តូរសភាវៈទាំង ៦ អោយទៅជាការត្រាស់ដឹង ។

បញ្ឈប់លោភៈ បញ្ឈប់ទោសៈ បញ្ឈប់មោហៈ ដើម្បីបណ្តុះទាន ករុណា និងបញ្ញា ។

ការលោភលន់ប្រៀបទៅនឹងមាន់ឈ្មោល ។ ការត្រេកត្រអាល និងលោភៈ កើតមកពីសុខវេទនា ។

បើយើងធ្វើសមាធិពីវេទនាហើយ យើងនឹងឃើញការកើតឡើង និងការអស់ទៅនៃសុខវេទនានេះនៅគ្រប់ពេល យើងអាចបញ្ឈប់វេទនានៅក្នុងភ្នែក ក្នុងត្រចៀក ក្នុងច្រមុះ ក្នុងអណ្តាត ក្នុងរាងកាយ និងក្នុងចិត្ត ហើយបន្ទាប់មក យើងពង្រីកទាន និងអលោភៈ ។

ទោសៈដូចជាសត្វពស់ ហើយទោសៈកើតពីទុក្ខវេទនា ឬការមិនសប្បាយក្នុងអារម្មណ៍ ។ ប្រសិនបើយើងដឹងថា ត្រូវធ្វើយ៉ាងណាដើម្បីបញ្ឈប់ទុក្ខវេទនាដោយធ្វើសមាធិ ពេលនោះយើងអាចបញ្ឈប់ទោសៈបានហើយ ។ មោហៈដូចសាច់ជ្រូក ប្រសិនយើងអាចបញ្ឈប់ឧបេក្ខាវេទនាបាន នោះយើងអាចបំបាត់មោហៈបានហើយ ។ បើយើងធ្វើបានដូច្នេះ ពេលនោះយើងអាចក្លាយជាព្រះពុទ្ធបាន ឬជាអ្នកដែលបានត្រាស់ដឹងម្នាក់ ។ ហេតុនេះទើបព្រះពុទ្ធបានមានដីកាថា « ធម៌ទាំងអស់ប្រមូលផ្តុំគ្នានៅក្នុងវេទនា » ។

. តួដើមឈើ គឺនាម និងរូប ។ នោះគឺសង្ខារធាតុទាំង ៥ ។ ប៉ុន្តែយើងអាចសង្ខេបធាតុផ្សំទាំង ៥ នោះមកត្រឹមនាម និងរូប ។

ពួកគេជាចុងភៅកំពុងរៀបចំម្ហូប សំរាប់អោយវេទនាបរិភោគ ។ វេទនាជាអ្នកហូប ។ អ្នកដែលបរិភោគនូវចំណីគ្រប់យ៉ាង គឺវេទនា ។ វេទនាមានមាត់ ៦ សំរាប់បរិភោគវត្ថុទាំងអស់ ។ តាមរយៈភ្នែក វាបរិភោគរូបសញ្ញា :

- សុខរូបសញ្ញា អោយសុខវេទនា
- ទុក្ខរូបសញ្ញា អោយទុក្ខវេទនា
- អរូបសញ្ញា អោយឧបេក្ខាវេទា
- សំដីពិរោះ អោយសុខវេទនា
- សំដីទ្រគោះបោះបោក អោយទុក្ខវេទា
- ក្លិនក្រអូប អោយសុខវេទនា
- ក្លិនស្អុយ អោយទុក្ខវេទនា
- ពុំមានក្លិន អោយឧបេក្ខាវេទនា

ព្រះពុទ្ធបានសំរចសម្មាសម្ពោធិញ្ញាណ តាមរយះអនាបានុស្សតិកម្មដ្ឋាន ។ អ្នកណាជាព្រះពុទ្ធ ? ព្រះពុទ្ធ គឺមនុស្សម្នាក់ដែលមានសតិដឹងអំពីដង្ហើមចេញចូល ។ ក្រោយពេលធ្វើការស្វែងរកអស់រយះពេល ៦ ឆ្នាំ ទីបំផុតព្រះអង្គបានរកឃើញ និងបានប្រតិបត្តិដោយខ្លួនព្រះអង្គផ្ទាល់ ។

គេហូបអាហារព្រោះគេឃ្លាន ។ ការបញ្ឈប់មិនហូប និងការបញ្ឈប់ការស្រេកឃ្លាន គឺជាសេចក្តីទុក្ខដូចគ្នា ។ ក៏ដូចគ្នានឹងវេទនាដែរ ចិត្តគឺជាមាត់ដ៏ធំបំផុត ។

គំនិតល្អ ជាសុខវេទនា

គំនិតមិនល្អ ជាទុក្ខវេទនា

គ្មានការយកចិត្តទុកដាក់នឹងគំនិតនានា ជាឧបេក្ខាវេទនា ។

វេទនាប្រៀបបាននឹងម៉ាស៊ីនថតសំឡេង ។ វាថតសំឡេងគ្រប់យ៉ាងដោយប្រើម៉ាស៊ីនថតទាំង ៦ របស់វា ។ វេទនាមានមាត់ ៦ សំរាប់បរិភោគនូវអ្វីៗទាំងអស់ ។ យើងជាអ្វីដែលយើងបរិភោគ ។ យើងជាពិភពលោក ហើយយើងបរិភោគពិភពលោក ។ ប្រសិនបើយើងយល់ច្បាស់ពីរឿងនេះ យើងនឹងយល់អំពី

អ្វីទាំងអស់ដែលព្រះពុទ្ធបានបង្រៀន ។ យើងមានពិភពខាងក្នុង និងពិភពខាងក្រៅ ។ ពិភពខាងក្នុង គឺមាត់ទាំង ៦ ពិភពខាងក្រៅ គឺអាហារទាំង ៦ បែប : រូប ក្លិន រស សំឡេង សម្ផស្ស និងមនោ ។ យើងបរិភោគអ្វី យើងក្លាយជារបស់នោះ ។ ឥឡូវ អ្នកបរិភោគធម៌ អ្នកនឹងក្លាយជាព្រះពុទ្ធ ។ ធម៌ គឺសន្តិភាព ។

ដូច្នេះ បើយើងចង់កសាងសន្តិភាព យើងចាំបាច់ត្រូវស្គាល់ព្រះធម៌ ។ ហើយព្រះធម៌ទាំងអស់ប្រមូលផ្ដុំក្នុងវេទនា ។ ដូច្នេះ ត្រូវយើងមានសតិស្មារតីភ្ញាក់រលឹកក្នុងវេទនាគ្រប់ៗជំហាន ។ មួយជំហានម្ដង មួយជំហានម្ដង យើងក៏អាចធ្វើតាមព្រះពុទ្ធបានដែរ ។ កាលណាយើងកើតទុក្ខ យើងអាចធ្វើសមាធិមួយជំហានម្ដង មួយជំហានម្ដង រហូតដល់ឈប់កើតទុក្ខ ។

បើយើងចង់បញ្ឈប់សេចក្ដីទុក្ខ យើងត្រូវបញ្ឈប់វេទនា ដែលជាប្រភពនៃលោភៈ និងមោហៈ ។ ទាំងអស់នេះជាកេរដំណែលរបស់ព្រះពុទ្ធ ជាមរតករបស់ព្រះពុទ្ធ ។ យើងទាំងអស់ជាកូនចៅរបស់ព្រះពុទ្ធ យើងត្រូវដើរតាមដានលំអានបិតាដ៏មានព្រះភាគរបស់យើង ។ លំអាននោះ គឺការអនុវត្តន៍នូវសតិភ្ញាក់រលឹកក្នុងវេទនា ។ អ្នកទាំងអស់គ្នា គួរអនុវត្តតាមផ្លូវសន្តិភាព ។

សូមសព្វសត្វលោកទាំងឡាយ អនុវត្តតាមមាគ៌ាសន្តិភាពនេះ សូមអ្នកទាំងឡាយនោះបានសំរេចដូចសេចក្ដីប្រាថ្នា ។

សូមអរព្រះគុណ,

សូមអរគុណ,

# សុន្ទរកថា របស់ សម្តេចព្រះមហាឃោសានន្ទ

ក្នុងឱកាសសាំប៉ូស៊ីយោម នៅទីក្រុងក្យូតូ

ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៨

------------

## អំពីព្រះពុទ្ធសាសនា ជាមូលដ្ឋាននៃ សកម្មភាពទាំងឡាយក្នុងការរស់នៅជាមួយគ្នា

យើងទាំងអស់គ្នា សុទ្ធតែកើតពីធម្មជាតិដូចគ្នា ។ សព្វថ្ងៃ យើងទាំងអស់គ្នារស់នៅលើផែនដី ដែលជាផ្ទះរួមរបស់យើង ។ ពិភពលោកជាជីវិតរួមរបស់យើង ។ ការរស់នៅជាមួយគ្នា គឺការរក្សាជីវិតក្នុងពិភពលោក ដោយការស្ថាបនា




ទិដ្ឋភាពរួមនៃការប្រជុំ នៅទីក្រុង ក្យូតូ, ប្រទេសជប៉ុន ( រូបថត អង្គការ រីស្សូ កូសី_កៃ )

សន្តិភាពនៅក្នុងចិត្ត និងកាយ របស់មនុស្សម្នាក់ៗនៅក្នុងគ្រប់សង្គម ហើយនិងក្នុងពិភពលោកយើងទាំងមូល ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់បានរកឃើញសេចក្តីពិតដែលនាំអោយកើតសេចក្តីសុខសន្តិភាពនៅក្នុងធម្មជាតិ ។ ធម្មជាតិនៃពិភពលោករាប់ទាំងវត្ថុឥតវិញ្ញាណ សុទ្ធតែស្ថិតនៅក្នុងលក្ខណៈបីយ៉ាងគឺ : អនិច្ចំ ទុក្ខំ អនត្តា ។

អនិច្ចំ គឺអ្វីៗសុទ្ធតែប្រែប្រួលឥតឈប់ឈរ ហើយគ្មានអ្វីដែលស្ថិតស្ថេរនោះឡើយ ។ ទុក្ខំ គឺសេចក្តីទុក្ខដែលជាធម្មជាតិរបស់ជីវិត ។ មានជីវិត គឺមានទុក្ខជាមួយគ្នា ។ អនត្តា គឺអ្វីៗសុទ្ធតែមិនមែនជារបស់ខ្លួន និងគ្មានសារសំខាន់ទេ ។ ប៉ុន្តែ មនុស្សចចេសមានះ ចង់ចាប់យកអ្វីដែលកំពុងប្រែប្រួល ចង់ចាប់យកអ្វីដែលគ្មានសារសំខាន់នោះជាវត្ថុមានសារសំខាន់ ចង់យកអ្វីដែលមិនមែនជារបស់ខ្លួន ថាជារបស់ខ្លួន ។ ដោយហេតុនោះ សេចក្តីទុក្ខក៏កើតមាន ។ តណ្ហាលោភិយ សេចក្តីលោភ ការចង់បានហួសប្រមាណ បាននាំអោយមនុស្សគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន គិតតែសេចក្តីសុខម្នាក់ឯង ។

ប៉ុន្តែ ព្រះពុទ្ធបានរកឃើញថា នៅក្នុងលោកយើងនេះ គ្មានអ្វីដែលអាចរស់នៅបានតែឯកឯង ដោយគ្មានទំនាក់ទំនងជាមួយអ្នកដទៃឡើយ ។

ធម៌របស់ព្រះពុទ្ធ ជាមូលដ្ឋាននៃសន្តិភាពរបស់មនុស្សសត្វទាំងឡាយ នៅក្នុងលោកទាំងមូល ។

មានសកម្មភាពជាមូលដ្ឋានដំបូងបង្អស់ ៣ ក្នុងធម៌ព្រះពុទ្ធ ដែលនាំអោយមានសន្តិភាព គឺ :

- សព្វបាបស្ស អករណំ - ការមិនធ្វើបាបអាក្រក់គ្រប់យ៉ាង ដោយកាយវាចាចិត្ត ;
- កុសលស្សូបសម្បទា - ការសាងកុសលអោយបានសមស្រួន ដោយកាយវាចាចិត្ត ;
- សចិត្តបរិយោទបនំ - ការសំអាតចិត្តរបស់ខ្លួន ។

ការប្រតិបត្តិនូវគោលធម៌ទាំង ៣ ខាងលើនេះ នឹងនាំមកនូវសេចក្តីសុខ

សន្តិភាពដល់អ្នកប្រព្រឹត្តផង ដល់សង្គមផង ដល់ពិភពលោកទាំងមូលផង ។ មនុស្សទាំងអស់ត្រូវការសន្តិភាព ប៉ុន្តែ គេមិនអាចទទួលសុខសន្តិភាពបានទេ ប្រសិនបើគេពុំមានស្មារតីគ្រប់ពេលវេលាក្នុងរាងកាយ ក្នុងវេទនា ក្នុងចិត្ត ហើយនិងក្នុងធម៌ ។ ធម៌ទាំងអស់នេះ មករួមនៅក្នុងអរិយសច្ចៈទាំង ៤ គឺ :

១. ទុក្ខៈ . សេចក្តីទុក្ខកើតពីការកើត . ស្លាប់

២. សមុទយៈ . ហេតុដែលនាំអោយកើតសេចក្តីទុក្ខ

៣. និរោធៈ . ធម៌ជាគ្រឿងរំលត់ទុក្ខ

៤. មគ្គៈ . ការប្រតិបត្តិដើម្បីរំលត់ទុក្ខ ។

សត្វលោកទាំងអស់ ត្រូវការរស់នៅដោយមានព្រហ្មវិហារធម៌ទាំង ៤ ជាគ្រឿងទ្រទ្រង់ ។ ពិភពលោកនេះ លុះត្រាតែមានព្រហ្មវិហារធម៌ទាំង ៤ សំរាប់ទ្រទ្រង់ ទើបបានសុខ គឺ :

. មេត្តា គឺសេចក្តីរាប់អានចំពោះសព្វសត្វ

. ករុណា គឺសេចក្តីអាណិតចំពោះសព្វសត្វ

. មុទិតា គឺសេចក្តីត្រេកអរចំពោះសព្វសត្វដែលបានសុខចំរើន

. ឧបេក្ខា គឺសេចក្តីស្មោះស្មគ្រចំពោះសព្វសត្វ, គឺការតាំងចិត្តជាកណ្តាលកុំញាប់ញ័រដោយលោកធម៌ ៨ ប្រការ ។

ធម៌បួននេះ ជាមូលដ្ឋាននៃសេចក្តីសុខនៅក្នុងពិភពលោក ។ មនុស្សលោកទាំងអស់ ត្រូវមានសេចក្តីស្រឡាញ់រាប់អានគ្នា ត្រូវមានចិត្តអាណិតអាសូរគ្នាជួយសង្គ្រោះគ្នាទៅវិញទៅមក ត្រូវត្រេកអរនឹងសេចក្តីសុខរបស់អ្នកដទៃ ទើបគេអាចរកឃើញសេចក្តីសុខពិតនៅក្នុងខ្លួនផ្ទាល់របស់គេ ក្នុងគ្រួសារ ក្នុងសង្គម និងក្នុងពិភពលោកទាំងមូលបាន ។

សត្វលោកចែកជា ៤ ពួក គឺ :

. ពួកខ្លះចេញពីទីងងឹត ទៅកាន់ទីភ្លឺ

. ពួកខ្លះចេញពីទីងងឹត ហើយទៅកាន់ទីងងឹតមួយទៀត

. ពួកខ្លះចេញពីទីភ្លឺ ទៅកាន់ទីភ្លឺមួយទៀត

. ពួកខ្លះចេញពីទីភ្លឺ ទៅកាន់ទីងងឹត ទៅតាមការសេពរបស់ខ្លួន ។ ដូច្នេះ មនុស្សទាំងអស់ ត្រូវមានការយល់គ្នាទៅវិញទៅមក ។

ពួកគេទាំងអស់ ត្រូវការទំនាក់ទំនងល្អជាមួយគ្នាទៅវិញទៅមក ទើបអាចជួយគ្នាអោយដើរឆ្ពោះទៅរកផ្លូវល្អបាន ។ ដូច្នេះ ទំនាក់ទំនង និងការចងសាមគ្គីជាមួយគ្នាទៅវិញទៅមក មានសារសំខាន់ណាស់ ។ មនុស្សគ្រប់រូប ត្រូវមានការយោគយល់គ្នាអោយបានល្អទៅវិញទៅមក ។ ពួកគេត្រូវការសហប្រតិបត្តិការគ្នាផងដែរ ។

ដើម្បីសាងសន្តិភាព ដើម្បីអាចរស់នៅជាមួយគ្នាកើត ជាការងាយស្រួលណាស់ នោះគឺកុំភ្លេចការដកដង្ហើមរបស់ខ្លួនឯង ។ ម្នាក់ៗ ត្រូវប្រព្រឹត្តតែអំពើល្អ នៅគ្រប់ដង្ហើមចេញចូលរបស់ខ្លួន ។

ព្រះពុទ្ធជាម្ចាស់ទ្រង់មានពុទ្ធដីកាថា អ្នកដែលភ្លេចដកដង្ហើមចេញចូល អ្នកនោះមានឈ្មោះថាស្លាប់ទាំងរស់ ។ ការភ្លេចដកដង្ហើមចេញចូល ឈ្មោះថា **ស្លាប់** ។ ធម្មជាតិ ជាមូលដ្ឋាននៃការបង្រៀនរបស់ព្រះពុទ្ធ ។ ធមិរបស់ព្រះអង្គគឺ **ធម្មជាតិ** ទុក្ខជាធម្មជាតិរបស់សត្វលោក ។ ព្រះពុទ្ធបានរកឃើញសេចក្តីទុក្ខ និងការរំលត់ទុក្ខ ។ ទុក្ខមានច្រើនកងដែលកើតឡើងដោយហេតុគឺ តណ្ហា : កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ដូច្នេះ ដើម្បីរំលត់ទុក្ខ ត្រូវរំលត់តណ្ហា ។ ដើម្បីរំលត់តណ្ហា ឬលោភៈ យើងត្រូវដើរតាមផ្លូវកណ្តាល ។ ផ្លូវកណ្តាលនេះ ប្រកបដោយអង្គ ៨ និងជាផ្លូវតែមួយគត់ ដែលនាំអោយមនុស្សគ្រប់រូបអាចរស់នៅជាមួយគ្នាដោយសុខសន្តិភាព ក្នុងពិភពលោកដ៏តូចចង្អៀត និងផុយស្រួយនេះបាន ។ យើងត្រូវប្រតិបត្តិតាមផ្លូវកណ្តាលទាំង ៨ នេះ អោយបានទន្ទឹមគ្នា គឺ :

១. ការយល់ត្រូវ ( សម្មាទិដ្ឋិ )

២. ការត្រិះរិះត្រូវ ( សម្មាសង្កប្បោ )

៣. ការនិយាយស្ដីត្រឹមត្រូវ ( សម្មាវាចា )

៤. ការងារត្រឹមត្រូវ ( សម្មាកម្មន្តោ )

៥. ការរកចិញ្ចឹមជីវិតត្រឹមត្រូវ ( សម្មាអាជីវោ )

៦. ការប្រឹងប្រែងត្រឹមត្រូវ ( សម្មាវាយាមោ )

៧. ការភ្ញាក់រលឹកត្រឹមត្រូវ ( សម្មាសតិ )

៨. ការតម្កល់ចិត្តអោយនឹងត្រឹមត្រូវ ( សម្មាសមាធិ ) ។

កំណត់សំគាល់ជាកូនសោររបស់ព្រះពុទ្ធ គឺការយល់ត្រូវ ឬសម្មាទិដ្ឋិ ។ ប្រសិនបើយើងប្រព្រឹត្តបានល្អតាមផ្លូវទាំង ៨ នេះហើយ យើងនឹងអាចរស់នៅជាមួយគ្នាបានដោយសុខសន្តិភាព ។

នៅលើពិភពលោកដ៏ទំនើបយើងនេះ មនុស្សបានស្វែងរកសន្តិភាពក្នុងការឆ្នៃប្រឌិតបង្កើតសម្ភារៈយ៉ាងសម្បូរហូរហៀរ។ តែតាមពិត សម្ភារៈទាំងនោះ មិនអាចដោះស្រាយបញ្ហាសុភមង្គល និងសន្តិភាពបានទេ ។ ផ្ទុយទៅវិញ សម្ភារៈបានបង្កើតគម្លាតគ្នារវាងមនុស្សលោកទៅវិញ ។ យើងត្រូវការប្រើប្រាស់សម្ភារៈ ប៉ុន្តែកុំធ្វើជាអ្នកទោសរបស់សម្ភារៈ ។ សម្ភារៈអាចដោះស្រាយបានតែសេចក្ដីត្រូវការជាបន្ទាន់ចំពោះមុខតែប៉ុណ្ណោះ ប៉ុន្តែ មិនមែនដើម្បីបង្កើតសុខៈជាអចិន្ត្រៃយ៍ទេ ។ ដូច្នេះ ក្នុងការប្រើប្រាស់សម្ភារៈ យើងត្រូវយល់ពីសារៈរបស់សម្ភារៈនោះ ។

ផ្លូវជាកណ្ដាលមានប្រយោជន៍ក្នុងការប្រើសម្ភារៈគ្រប់បែបយ៉ាង ម្នាក់ៗត្រូវពេញចិត្តនឹងខ្លួនឯង និងភាពគ្រប់គ្រាន់របស់ខ្លួន កុំចង់បានហួសពីសេចក្ដីត្រូវការ ឬក៏តិចជាងសេចក្ដីត្រូវការច្រើនពេក ។

ធម៌ព្រះពុទ្ធ បានបង្រៀនអោយស្គាល់ខ្លួនឯង និងភាពគ្រប់គ្រាន់របស់ខ្លួន ។ ធម៌ គឺស្គាល់ខ្លួនឯង ដឹងប្រមាណ ដឹងល្មម ។

នៅទីបញ្ចប់ អាត្មាភាពចង់បញ្ជាក់ថា យើងត្រូវមានធម៌ក្នុងខ្លួនយើងម្នាក់ៗ គឺ *អត្តាហិ អត្តនោ នាថោ កោហិ នាថោ បរោសិយា* គឺចង់បានសុខ លុះត្រាតែយើងម្នាក់ៗទីពឹងខ្លួនឯងចេះស្គាល់ប្រមាណ ស្គាល់ល្មម ដោយខ្លួនឯង ។

ចង់បានសុខ មនុស្សត្រូវទីពឹងខ្លួនឯង, ទីពឹងខ្លួនឯង គឺទីពឹងព្រះធម៌ ។ ទីពឹងព្រះធម៌ គឺទីពឹងសតិប្បដ្ឋាន ៤ គឺ :

១. ការកំណត់រាងកាយ គឺដឹងដង្ហើមចេញចូល ឥរិយាបថទាំង ៤ គឺ ដេក ដើរ ឈរ អង្គុយ ស៊ីចុក ស្លៀកពាក់ ... ។

២. កំណត់នូវវេទនា គឺ សុខ ទុក្ខ ឧបេក្ខា នៅក្នុងភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ។

៣. ការកំណត់ចិត្ត គឺ ចិត្តលោភៈ ទោសៈ មោហៈ, ចិត្តអលោភៈ ចិត្តអទោសៈ ចិត្តអមោហៈ ។

៤. ធម៌ គឺអរិយសច្ចៈទាំង ៤ គឺ សេចក្ដីទុក្ខ ហេតុដែលនាំអោយកើតទុក្ខ ការរំលត់ទុក្ខ និងការប្រតិបត្តិដើម្បីរំលត់ទុក្ខ ។

ធម៌ទាំងឡាយទាំងពួង មកប្រជុំគ្នានៅវេទនា គឺ :

- ទុក្ខវេទនា ( ទទួលអារម្មណ៍ឈឺចាប់ ) ទុក្ខទុក្ខតា
- សុខវេទនា ( ទទួលអារម្មណ៍សុខ ) វិបរិណាមទុក្ខតា
- ឧបេក្ខាវេទនា ( ទទួលអារម្មណ៍ជាកណ្ដាល ) សង្ខារទុក្ខតា

ដូច្នេះ ក្នុងការប្រតិបត្តិធម៌ក្នុងជីវិតប្រចាំថ្ងៃពេលណា យើងមានសុខ-វេទនាកើតឡើង យើងត្រូវកំចាត់បង់នូវចិត្តលោភៈ ។ កាលណាទុក្ខវេទនាកើតឡើង យើងត្រូវកំចាត់បង់នូវទោសៈ ។ កាលណាឧបេក្ខាវេទនាកើតឡើង យើងត្រូវកំចាត់បង់នូវមោហៈ ។

ដោយសារធម៌ទាំងអស់មកប្រជុំគ្នានៅក្នុងវេទនា : សុខវេទនា ទុក្ខវេទនា ឧបេក្ខាវេទនា វេទនាក្នុងភ្នែក វេទនាក្នុងច្រមុះ វេទនាក្នុងត្រចៀក វេទនាក្នុង

អណ្តាត វេទនាក្នុងកាយ វេទនាក្នុងចិត្ត ដូច្នេះ យើងត្រូវមានសតិស្មារតីភ្ញាក់រលឹកជានិច្ច ជាពិសេស សតិភ្ញាក់រលឹកនៅក្នុងវេទនានោះឯង ។

កាលណា មនុស្សទាំងអស់ព្យាយាមមួយជំហានម្តង មួយជំហានម្តង ក្នុងការយកព្រះធម៌ព្រះពុទ្ធទៅដាក់ក្នុងខ្លួន គឺមានស្មារតីភ្ញាក់រលឹកនៅក្នុងវេទនាគ្រប់ៗពេល គ្រប់ៗគ្នាហើយ ពេលនោះ មនុស្សនឹងបានរស់នៅយ៉ាងសុខដុមជាមួយគ្នាមិនខាន ។

សូមអោយអ្នកទាំងឡាយ ទាំងបុរស ទាំងស្ត្រី បានប្រកបតែសេចក្តីសុខ សូមអោយចំរើនក្នុងព្រះពុទ្ធសាសនា សូមកុំអោយមានរោគ សូមអោយសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា ។



សម្តេចព្រះមហាឃោសានន្ទ ទទួលរង្វាន់សន្តិភាព ពីព្រះតេជព្រះគុណ និឃិក្ខូ នីវ៉ាណូ ប្រធានមូលនិធិដើម្បីសន្តិភាព នៃអង្គការ រីស្សូ កូសី-កៃ (រូបថត របស់អង្គការ រីស្សូ កូសី-កៃ )

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ឆ្នាំទី ៥២ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ

ព.ស ២៥៤២ គ.ស ១៩៩៨

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ណារក្ខ**

នាយកការផ្សាយ : **ឈន វឿម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**

*

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និង សាសនា - ភ្នំពេញ

**ក្របមុខ** : ទិដ្ឋភាពនៃកិច្ចប្រជុំជាលក្ខណៈគ្រួសាររបស់មន្ត្រីសង្ឃ និងមន្ត្រីធម្មការខេត្ត ក្រុង ដើម្បីលើកកំពស់ការប្រតិបត្តិពុទ្ធសាសនា ( រូបថត ពុទ្ធសាសនបណ្ឌិត្យ )

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました

この本が、日本の宗教者とカンボジアの人々との友情のきずなとなりカンボジアの宗教と文化の発展に貢献できれば幸いです

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនានិងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន ( JSRC ) ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាព រវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## Acknowledgement

The *Kambujasuriya Magazine* is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC = SVA), Phnom Penh.

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

I. អក្សរសិល្ប៍ពុទ្ធសាសនា


. ធម៌គ្រឹះនៃពុទ្ធសាសនា . តចប់ (ឈេន អៀម) ........................ ១


II. អក្សរសាស្ត្រទូទៅ


. ព្រះត្រៃបិដកជាគ្រូអាចារ្យដ៏ប្រសើរបំផុតរបស់យើង (ឱម ខៃម) ...... ៣៩

. ព្រះធម៌អនិច្ចា (ពីកម្ពុជសុរិយា ១៩៦៧) ........................ ៤៦

. រឿងរើសកូនប្រសារ (ធន់ ហ៊ិន) ........................ ៥៤

. តម្លង់ ៧ សន្តាន (ពីកម្ពុជសុរិយា ១៩៣៩) ........................ ៦៣

. ក្បាលដីស្រុក និង ក្បាលដីព្រៃ (ធន់ ហ៊ិន) ........................ ៦៦

. បទរលកខ្ទប់ច្រាំង (ធន់ ហ៊ិន) ........................ ៦៩

. ក្រៀលដៀលក្រួច (វណ្ណ ស៊ុនហេង) ........................ ៧១

. វប្បធម៌សន្តិភាព (ឌីម សោភ័ណ) ........................ ៧៣

. ចម្លើយកំណាព្យប្រស្នា (វណ្ណ ស៊ុន ហេង) ........................ ៨០


III. កំណត់ និង ប្រវត្តិការណ៍


. កិច្ចប្រជុំជាលក្ខណៈគ្រួសាររបស់មន្ត្រីសង្ឃជាន់ខ្ពស់ (ឱម ខៃម) ...... ៨១

. សេចក្តីប្រកាសរួមនៃកិច្ចប្រជុំពេញអង្គមន្ត្រីសង្ឃជាន់ខ្ពស់ ........ ៨៥

# ធម៌គ្រឹះ នៃ ពុទ្ធសាសនា (ត-ចប់)

ដោយ លោក ភីទ័រ ដ. សន្តិនា
( By Peter D. Santina )
បកប្រែដោយ : **ឈុន អៀម**

**x**

## បដិច្ចសមុប្បាទធម៌ (*)

ថ្ងៃនេះ នៅក្នុងការប្រជុំលើកទីដប់នេះ យើងនឹងលើកយកប្រធានបទ ដ៏សំខាន់ក្រៃលែងមួយ នៅក្នុងការសិក្សាពុទ្ធសាសនា, ហើយប្រធានបទនេះ គឺការប្រៀនប្រដៅអំពីបដិច្ចសមុប្បាទធម៌ ។ ខ្ញុំបានចាប់អារម្មណ៍អំពីហេតុពិត ដែលថា មនុស្សជាច្រើនជឿថា បដិសច្ចសមុប្បាទធម៌ គឺជា ប្រធានបទមួយពិបាកណាស់, ប៉ុន្តែ ខ្ញុំនឹងមិននិយាយថា ពុំមានសេចក្ដីពិតនៅក្នុងជំនឿនេះទេ ។ តាមពិត, នាសម័យមួយនោះ, ព្រះអានន្ទបានកត់សំគាល់ថា ថ្វីបើខាងក្រៅមើលឃើញមានការពិបាក ប៉ុន្តែ តាមពិតទៅ បដិច្ចសមុប្បាទធម៌ គឺងាយស្រួលណាស់ ; ហើយព្រះពុទ្ធទ្រង់បានបន្ទោសព្រះអានន្ទ ដោយទ្រង់មានពុទ្ធដីកាថា តាមការណ៍ជាក់ស្ដែង

(*) ធម៌ ឬសភាវៈ ដែលកើតមានឡើងដោយសារបច្ច័យ គឺគ្រឿងអាស្រ័យទាក់ទងគ្នា ដូចជា សង្ខារកើតមានឡើង ព្រោះមានអវិជ្ជាជាបច្ច័យ, វិញ្ញាណកើតមានឡើង ព្រោះមានសង្ខារជាបច្ច័យ ឬថា អវិជ្ជាជាបច្ច័យនាំឱ្យកើតមានសង្ខារ, សង្ខារជាបច្ច័យនាំឱ្យកើតមានវិញ្ញាណ ។ ល ។ វចនានុក្រមខ្មែរ _ ជ.ណា.

បដិច្ចសមុប្បាទធម៌ មានគម្ពីរភាពជ្រាលជ្រៅណាស់ ។ មែនហើយ នៅក្នុងបដិច្ចសមុប្បាទធម៌ យើងមានព្រះធម៌មួយ ក្នុងបណ្ដាព្រះធម៌ដ៏សំខាន់ និងជ្រាលជ្រៅបំផុតក្នុងពុទ្ធសាសនា ។ តែថា ពេលខ្លះ ខ្ញុំមានអារម្មណ៍ថា សេចក្ដីខ្លាចរបស់យើងអំពីបដិច្ចសមុប្បាទធម៌ បានកើតមានឡើងដោយគ្មានហេតុ-ផល ត្រឹមកំរិតណាមួយនោះ ។ ពុំមានអ្វីជាហេតុពិបាកដោយឡែកណាមួយទេ, តួយ៉ាង នៅក្នុងពាក្យបដិច្ចសមុប្បាទ ( Dependent origination ) ។ ទីបំផុតទៅ, យើងទាំងអស់គ្នាចេះដឹងហើយថា បដិច្ចៈ ( dependent = ដែលអាស្រ័យគ្នា ) មានន័យយ៉ាងណា, ហើយសមុប្បាទ ( origination = ការកើតឡើង, ការកើតចេញពីប្រភពដើម ឬការងើបឡើង ) មានន័យយ៉ាងណា ។ គឺនៅពេលដែលយើងចាប់ផ្ដើមពិនិត្យដំណើរប្រព្រឹត្តទៅ និងការអនុវត្តន៍បដិច្ចសមុប្បាទប៉ុណ្ណោះ ទើបយើងទទួលស្គាល់ការណ៍ពិតថា យើងមានព្រះធម៌ជាពាក្យប្រៀនប្រដៅមួយ ដ៏មានគម្ពីរភាព និងមានអត្ថរសទូលំទូលាយណាស់ ។ សញ្ញាបញ្ជាក់ខ្លះអំពីការណ៍ពិតនេះ អាចដកស្រង់ចេញមកពីឱវាទរបស់ព្រះពុទ្ធផ្ទាល់ ។ ជាញឹកញាប់ណាស់ យើងឃើញថា ព្រះពុទ្ធទ្រង់បានទេសនាអំពីបទពិសោធន៍ នៃការត្រាស់ដឹងរបស់ព្រះអង្គតាមមាគ៌ាណាមួយ ក្នុងបណ្ដាមាគ៌ាទាំងពីរ, ឬមួយក្នុងគន្លងដែលបានយល់ដឹងចតុរារិយសច្ច ( អរិយសច្ចៈបួន ), ឬមួយក្នុងគន្លងដែលបានយល់ដឹងធម្មជាតិ នៃបដិច្ចសមុប្បាទ ។ ជាញឹកញាប់ព្រះពុទ្ធទ្រង់បានអធិប្បាយថា ដើម្បីសំរេចបាននូវការត្រាស់ដឹង បុគ្គលត្រូវយល់អរិយសច្ចៈបួន ; ឬដូចគ្នានេះដែរ បុគ្គលត្រូវយល់បដិច្ចសមុប្បាទ ។

ផ្អែកលើគ្រឹះនៃឱវាទព្រះពុទ្ធផ្ទាល់, យើងអាចមើលឃើញទំនាក់ទំនងដ៏ជិតស្និទ្ធរវាងអរិយសច្ចៈបួន និងបដិច្ចសមុប្បាទ ។ តើអ្វីខ្លះទៅ ដែលអរិយសច្ចៈបួន និងបដិសច្ចសមុប្បាទមានរួមគ្នា ។ គោលការណ៍ដែលធម៌ទាំងពីរមានរួមគ្នា គឺគោលការណ៍ហេតុភាព ពោលគឺ ក្រឹត្យក្រមហេតុ និងផល, ក្រឹត្យក្រមកម្ម និងវិបាក ។

នៅក្នុងឧទ្ទេសកថារបស់យើងពីខាងដើម យើងបាននិយាយថា អរិយសច្ចៈបួន ត្រូវបានចែកចេញជាពីរក្រុម ។ ពីរប្រការដំបូង . គឺទុក្ខ និងហេតុនៃទុក្ខ, និងពីរប្រការចុងក្រោយគឺ ការបញ្ចប់ទុក្ខ ហើយនិងមាគ៌ាដើម្បីបញ្ចប់ទុក្ខ ។ នៅក្នុងក្រុមទាំងពីរនេះ, គឺ ក្រឹត្យក្រមនៃហេតុ និងផល ដែលគ្រប់គ្រងទំនាក់ទំនងរវាងក្រុមទាំងពីរ ។ និយាយម្យ៉ាងទៀត, ទុក្ខ គឺជាផលនៃហេតុរបស់ទុក្ខ ; ហើយដូចគ្នានេះដែរ ការបញ្ចប់ទុក្ខ គឺជាផលនៃមាគ៌ាដើម្បីបញ្ចប់ទុក្ខ ។ ក្នុងទីនេះដែរ ទាក់ទងនឹងបដិច្ចសមុប្បាទ គោលការណ៍ជាមូលដ្ឋានដើម្បីដំណើរការ គឺ គោលការណ៍ហេតុ និងផល ។ នៅក្នុងបដិច្ចសមុប្បាទ យើងមានសេចក្តីពិពណ៌នារៀបរាប់យ៉ាងលំអិតអំពីអ្វីៗដែលកើតមានយ៉ាងពិតប្រាកដនៅក្នុងដំណើរប្រព្រឹត្តទៅនៃហេតុភាព ។ ចូរយើងលើកយកឧទាហរណ៍ពីរ-បី ដែលកំណត់ចរិតនៃបដិច្ចសមុប្បាទ ។ ដំបូង ចូរយើងលើកយកឧទាហរណ៍មួយដែលព្រះពុទ្ធអង្គឯងធ្លាប់បានប្រើ ។ ព្រះពុទ្ធទ្រង់មានបន្ទូលថា អណ្តាតភ្លើងឆេះនៅក្នុងចង្កៀងប្រេង គឺអាស្រ័យប្រេង ហើយនិងបញ្ចេះ ។ កាលណាប្រេងហើយនិងបញ្ចេះនៅតែមាន អណ្តាតភ្លើងនៅក្នុងចង្កៀងប្រេងនៅតែឆេះ ។ ប្រសិនបើប្រេងឬបញ្ចេះ ណាមួយក្នុងចំណោមវត្ថុទាំងពីរនេះមិនមានទេ, អណ្តាតភ្លើងនឹងឈប់ឆេះ ។ ឧទាហរណ៍នេះ ចង្អុលបញ្ជាក់គោលការណ៍បដិច្ចសមុប្បាទ ប្រៀបទៅនឹងអណ្តាតភ្លើងនៅក្នុងចង្កៀងប្រេង ។ ចូរយើងលើកយកឧទាហរណ៍អំពីពន្លក ។ អាស្រ័យដោយមានគ្រាប់ពូជ, ដី, ទឹក អាកាស ( ខ្យល់ ) និងពន្លឺថ្ងៃ ពន្លកវមែងដុះឡើង ។ តាមការណ៍ពិត នៅមានឧទាហរណ៍រាប់មិនអស់អំពីបដិច្ចសមុប្បាទ ពីព្រោះ វាគ្មានបាតុភូតណាមួយកំពុងមានអត្ថិភាព ដែលមិនមែនជាផលនៃបដិច្ចសមុប្បាទនោះទេ ។ បាតុភូតទាំងអស់នេះកើតឡើង ដោយអាស្រ័យកត្តាហេតុភាពមួយចំនួន ។ នេះហើយគឺជាគោលការណ៍បដិច្ចសមុប្បាទ ។

ដោយឡែក យើងជាប់ចិត្តគិតពីគោលការណ៍បដិច្ចសមុប្បាទ ក្នុងឋានៈដែលគោលការណ៍នេះអនុវត្តចំពោះបញ្ហានៃទុក្ខ និងការកើតទៀត ។ យើងជាប់ចិត្តថាតើបដិច្ចសមុប្បាទ ពន្យល់អំពីស្ថានភាព ដែលនៅក្នុងស្ថានភាពនេះ យើងកំពុងរស់នៅយ៉ាងណាដែរ ។ នៅក្នុងន័យនេះ វាមានសារសំខាន់ត្រូវចងចាំថា បដិច្ចសមុប្បាទជាសារវ័ន្ត និងជាដំបូងបង្អស់ គឺជាពាក្យប្រៀនប្រដៅដែលទាក់ទងជាមួយបញ្ហានៃទុក្ខ ហើយនិងបញ្ហាដែលថា តើត្រូវរំដោះខ្លួនយើងឱ្យផុតពីទុក្ខយ៉ាងដូចម្ដេច, ហើយមិនមែនជាការពិពណ៌នាអំពីការវិវត្តន៍នៃចក្រវាលទេ ។ ខ្ញុំសូមរៀបរាប់ដោយសង្ខេប នូវសមាសភាគ ឬបច្ច័យ (links) ទាំងដប់ពីរ ដែលបង្កើតឡើងជាបដិច្ចសមុប្បាទ ។ សមាសភាគ ឬ បច្ច័យទាំងដប់ពីរនោះគឺ ៖ អវិជ្ជា, សង្ខារ, វិញ្ញាណ, នាម-រូប, សឡាយតនៈ, ផស្សៈ, វេទនា, តណ្ហា, ឧបាទាន, ភព, ជាតិ ( កំណើត ), និងជរា-មរណៈ ។

មានមាតិកាសំខាន់ពីរ ដែលនាំឱ្យយើងយល់សមាសភាគទាំងដប់ពីរនេះបាន ។ មាតិកាមួយគឺ យល់សមាសភាគទាំងនោះតាមអនុក្រម (តាមលំដាប់លំដោយ) លើរយៈពេលនៃជីវិតកាលទាំងបី ៖ ជីវិតអតីតៈ, ជីវិតបច្ចុប្បន្ន និងជីវិតអនាគត ។ ក្នុងករណីនេះ អវិជ្ជា និងសង្ខារ គឺជារបស់ជីវិតអតីតៈ ។ អវិជ្ជា និងសង្ខារនេះបង្ហាញប្រាប់នូវលក្ខខ័ណ្ឌទាំងឡាយដែលទទួលរ៉ាប់រងឱ្យកើតមានឡើងនូវជីវិតជាតិនេះ ។ សមាសភាគរបស់បដិច្ចសមុប្បាទដូចតទៅនេះគឺ វិញ្ញាណ, នាម និងរូប, សឡាយតនៈ, ផស្សៈ, វេទនា, តណ្ហា, ឧបាទាន, ភព ជារបស់ជីវិតបច្ចុប្បន្ន ។ សង្ខេបមក សមាសភាគទាំងប្រាំបីនេះ កផ្តុំជាអភិក្រមនៃការវិវត្តន៍នៅក្នុងជាតិនេះ ។ សមាសភាគពីរចុងក្រោយគឺ ជាតិ និង ជរា-មរណៈ ជារបស់ជីវិតអនាគត ។ យោងតាមឧបាយ ឬគម្រោងនេះ ( scheme ), យើងអាចមើលឃើញថា តើសមាសភាគទាំងដប់ពីរ របស់បដិច្ចសមុប្បាទ ត្រូវបានបែងចែកទៅលើរយៈពេលនៃជីវិត

កាលទាំងបីយ៉ាងណានោះហើយ, ហើយថាតើសមាសភាគពីរមុនគេ គឺអវិជ្ជា និងសង្ខារ បង្កើតចេញជាលទ្ធផលឱ្យកើតមានជាជីវិតបច្ចុប្បន្ននេះ ជាមួយនឹងបុគ្គល-ភាព ឬអត្តភាពប្រកបដោយកាយ-ចិត្ត របស់ខ្លួនយ៉ាងណា, ហើយថាតើបន្តទៅទៀត អំពើទាំងឡាយធ្វើឡើងនៅក្នុងជាតិនេះ ហុចផលទៅឱ្យកំណើតថ្មីនៅក្នុងជាតិខាងមុខយ៉ាងណា ។ នេះគឺជាមាតិាប្រជាប្រិយ៍ និងមានឥទ្ធិពលខ្លាំងក្លាមួយ សម្រាប់បកស្រាយសមាសភាគទាំងដប់ពីរ នៃបដិច្ចសមុប្បាទ ។

ប៉ុន្តែ សម្រាប់ថ្ងៃនេះ ខ្ញុំនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការបកស្រាយមួយទៀត ស្តីពីទំនាក់ទំនងរវាងសមាសភាគទាំងដប់ពីរ របស់បដិច្ច-សមុប្បាទ ។ ការបកស្រាយនេះ ក៏មានឥទ្ធិពលខ្លាំងក្លាដែរ ហើយបានទទួលការគាំទ្រ និងការទទួលស្គាល់អំពីគ្រូអាចារ្យ និងអ្នកប្រាជ្ញពុទ្ធសាសនាទាំងឡាយ ។ ការបកស្រាយនេះ អាចឱ្យឈ្មោះថា ការបកស្រាយជាវដ្ត ( ឬជាខួប ) ពីព្រោះ វាមិនផ្អែកលើការបែងចែកសមាសភាគទាំងដប់ពីរក្នុងចំណោមជីវិតកាលទាំងបីទេ ។ ផ្ទុយទៅវិញ ការបកស្រាយនេះ ចែកសមាសភាគទាំងដប់ពីរទៅជាបីក្រុម, ឯក្រុមទាំងបីនោះគឺ កិលេស ( defilements ), កម្ម ( actions ), និងទុក្ខ ( sufferings) ។ ឧបាយ ឬគម្រោងនេះ មានអត្ថប្រយោជន៍ត្រង់មិនផ្អែកតែលើការបែងចែកពេលវេលាក្នុងចំណោមជីវិតកាលទាំងបីទេ ។ យោងតាមគម្រោងនេះ អវិជ្ជា, តណ្ហា, និងឧបាទាន ចាត់ចូលទៅក្នុងក្រុមកិលេស ។ សង្ខារ និងភព ចាត់ចូលក្នុងក្រុមកម្ម ។ សមាសភាគទាំងប្រាំពីរ ដែលនៅសល់ ពោលគឺ វិញ្ញាណ, នាម និងរូប, សឡាយតនៈ, វេទនា, ជាតិ, ជរា-មរណៈ ចាត់ចូលក្នុងក្រុមទុក្ខៈ ។ តាមរយៈការបកស្រាយនេះ យើងអាចមើលឃើញថា តើពាក្យប្រៀនប្រដៅស្តីពីអរិយសច្ចៈទាំងបួន ហើយជាពិសេស ពាក្យប្រៀនប្រដៅអំពីអរិយសច្ចៈទីពីរ គឺសមុទយទុក្ខជាប់ជាមួយនឹងពាក្យប្រៀនប្រដៅ ស្តីពីកម្មៈ និងការកើតទៀត យ៉ាងណា, ហើយថាតើ

ពាក្យប្រៀនប្រដៅដ៏សំខាន់ទាំងពីរនេះរួមគ្នា ពន្យល់ក្នុងបែបបទមួយពេញលេញជាង នូវអភិក្រមនៃការកើតទៀត និងប្រភពនៃទុក្ខបានយ៉ាងណា ។

លោក-អ្នក អាចនៅចាំបានថា នៅក្នុងបរិបទនៃអរិយសច្ចៈទាំងបួន យើងបាននិយាយហើយថា អវិជ្ជា, ឥច្ឆា និងព្យាបាទ គឺជាហេតុនៃទុក្ខ ។ ប្រសិនបើយើងពិនិត្យមើលក្នុងទីនេះ នូវសមាសភាគនៃបដិច្ចសមុប្បាទ ដែលបានរាប់បញ្ចូលក្នុងក្រុមកិលេស យើងនឹងឃើញ អវិជ្ជា, តណ្ហា និងឧបាទាន ។ ក្នុងទីនេះដែរ អវិជ្ជាគឺជាឫសគល់ធំបំផុត ។ គឺដោយសារតែអវិជ្ជា ទើបយើងអន្ទះសាចង់បានសេចក្តីសប្បាយរីករាយតាមផ្លូវវិញ្ញាណ ( ឥន្ទ្រីយ ), ចង់បានជីវិតរស់នៅ និងមិនចង់មានជីវិតរស់នៅ ។ ដូចគ្នានេះដែរ គឺដោយសារតែអវិជ្ជា ទើបយើងខំតោងស្អិតស្វែងរកសេចក្តីសប្បាយរីករាយតាមផ្លូវវិញ្ញាណ ( ឥន្ទ្រីយ ), បទពិសោធន៍ជាទីរីករាយ, គំនិតយោបល់ទាំងឡាយ ហើយប្រហែលមានអត្ថន័យបំផុត គឺ គំនិតស្តីពី អត្តៈមួយឯករាជ និងជាអចិន្ត្រៃយ៍ ។ អវិជ្ជានេះ - តណ្ហា និងឧបាទាន, គឺជាហេតុនៃកម្ម ( អំពើ ) ។

សមាសភាគទាំងពីរនៃបដិច្ចសមុប្បាទ ដែលបានចាត់ចូលក្នុងក្រុមកម្ម (អំពើ) គឺសង្ខារ, និងភព ។ សង្ខារយោងទៅរកការផ្ចិតជាប់អារម្មណ៍ ឬទម្លាប់ ដែលយើងបានបង្កបង្កើតឡើងនៅក្នុងចរន្តនៃខណៈចេតសិករបស់យើង - ពោលគឺសន្តតិចេតសិករបស់យើង ។ ការផ្ចិតជាប់អារម្មណ៍ ឬទម្លាប់ទាំងនេះ កកើតឡើងដោយអំពើដែលបានធ្វើជាញឹកញាប់ ដដែលៗ ។ យើងអាចបង្ហាញបញ្ជាក់រឿងនេះតាមរយៈឧទាហរណ៍មួយ ស្រង់ចេញមកពីភូមិវិទ្យា ។ យើងដឹងថា ទន្លេទាំងឡាយបង្កើតជ្រលងរបស់ខ្លួនតាមមធ្យោបាយអភិក្រមមួយនៃការហូរច្រោះញឹកញាប់ដដែលៗ ។ នៅពេលភ្លៀងធ្លាក់លើជម្រាលភ្នំ ឬទួល, ទឹកភ្លៀងនោះ តែងផ្តុំគ្នាទៅជាចរន្តទឹកហូរតូចៗ ។ ចរន្តទឹកតូចៗនេះ បង្កើតបានបន្តិចម្តងៗជាព្រែកមួយ ដោយ

ខ្លួនឯង ហើយរីកធំជាលំដាប់ទៅជាចរន្តទឹកហូរដ៏ធំមួយ ។ រយៈពេលក្រោយមក, នៅពេលដែលព្រៃកមានចរន្តទឹកហូរកាន់តែជ្រៅទៅៗ ហើយធំទៅៗ ដោយសារទឹកហូរ, ចរន្តទឹកហូរនោះក្លាយទៅជាទន្លេ ដែលកើតទៅជាច្រាំងត្រឹមត្រូវ និងមានជ្រលងច្បាស់លាស់ ។ ក្នុងបែបបទដូចគ្នា អំពើរបស់យើងក្លាយទៅជាទម្លាប់ ។ ទម្លាប់ទាំងនោះប្រែក្លាយជាផ្នែកនៃអត្តភាពរបស់យើង ហើយយើងប្រកាន់យកទម្លាប់ទាំងនោះទៅជាមួយយើងពីជាតិមួយទៅជាតិមួយ នៅក្នុងទ្រង់ទ្រាយជាសង្ខារ ឬថាមភាពទម្លាប់ ។ អំពើរបស់យើងនៅក្នុងជីវិតនេះ ត្រូវបានតាក់តែងឡើងដោយទម្លាប់ទាំងឡាយ ដែលយើងបានសន្សំទុកមកអំពីជាតិមុនៗ ជាអនេក ។ ដូច្នេះ ដើម្បីត្រឡប់ទៅរកការប្រៀបប្រដូចជ្រលងទន្លេ និងទឹកនៅក្នុងទន្លេវិញ យើងអាចនិយាយថា សង្ខារគឺជាជ្រលងទន្លេ ឯអំពើដែលយើងបានប្រព្រឹត្តនៅក្នុងជាតិនេះ គឺជាទឹកដ៏ត្រជាក់ ដែលហូរម្តងទៀត តាមរយៈជ្រលងហូរច្រោះបង្កើតឡើងដោយអំពើពីមុនៗ ។ អំពើទាំងឡាយដែលយើងប្រព្រឹត្តនៅក្នុងជាតិនេះ ត្រូវបានតាងឡើងដោយសមាសភាគ ដែលមានឈ្មោះថា ភព ។ ដូច្នេះ នៅទីនេះ ទាក់ទងទៅនឹងសង្ខារ និងភព យើងមានទម្លាប់ ដែលយើងបានធ្វើឱ្យធំធាត់ឡើងនៅក្នុងអំឡុងជាតិជាអនេក គួបផ្សំជាមួយនឹងអំពើប្រព្រឹត្តថ្មីៗក្នុងជាតិនេះ, ហើយសង្ខារ និងភពទាំងពីរនេះរួមគ្នា ហុចផលឱ្យជាកំណើតថ្មី និងទុក្ខ ។

សង្ខេបសេចក្តីមក, យើងមានកិលេសដែលអាចពិពណ៌នាថា ជាគ្រឿងសៅហ្មងនៃចិត្ត . គឺអវិជ្ជា, តណ្ហា និងឧបាទាន ។ គ្រឿងសៅហ្មងនៃចិត្តនេះហុចផលចេញជាអំពើ, អំពើទាំងឡាយដែលបានធ្វើនៅក្នុងជាតិមុន បានហុចផលឱ្យដល់ការតាក់តែងឡើងនូវថាមពលទម្លាប់ (the formulation of habit energy) ហើយអំពើទាំងឡាយធ្វើនៅក្នុងបច្ចុប្បន្នជាតិនិយាយជារួម ត្រូវបានគេជឿថាប្រព្រឹត្តទៅស្របតាមផ្នត់ ដែលកំណត់រួចហើយនៅក្នុងជាតិមុនៗ ។ រួមជាមួយគ្នា,

គ្រឿងសៅហ្មងនៃចិត្តទាំងនេះ និងអំពើទាំងឡាយនោះ ហុចផលឱ្យជាកំណើតថ្មីទៀត ។ និយាយម្យ៉ាងទៀត, គ្រឿងសៅហ្មងនៃចិត្ត និងអំពើទាំងអស់នោះហុចផលឱ្យជាវិញ្ញាណ, ជានាម និងរូប, ជាសឡាយតនៈ ( អាយតនៈប្រាំមួយ ), ជាផស្សៈ ពោលគឺការប៉ះទង្គិចរវាងសឡាយតនៈ និងកម្មវត្ថុរបស់សឡាយតនៈ, ជាវេទនាដែលកើតចេញពីផស្សៈនោះ, ជាជាតិ ( កំណើត ), ហើយនិងជាជរា និង មរណៈ ។ នៅក្នុងការបកស្រាយនេះ សមាសភាគប្រាំ ( បច្ច័យប្រាំ ) របស់បដិច្ចសមុប្បាទ ត្រូវបានចាត់ចូលក្នុងក្រុមកិលេស និងកម្ម ៖ អវិជ្ជា, តណ្ហា, ឧបាទាន, សង្ខារ និងភព គឺជាហេតុនៃការកើតទៀត និងទុក្ខៈ ។ វិញ្ញាណ, នាម និងរូប, សឡាយតនៈ ( អា-យតនៈទាំងប្រាំមួយ ), ផស្សៈ, វេទនា, ជាតិ និងជរា-មរណៈ គឺជាផលនៃកិលេស និងកម្ម ។ រួមជាមួយគ្នា កិលេស និងកម្ម ពន្យល់ប្រាប់នូវប្រភពនៃទុក្ខ ហើយនិងស្ថានភាពពិសេស១ ដែលនៅក្នុងស្ថានភាពដោយឡែក១នោះ យើងម្នាក់១បានរស់នៅ, យើងម្នាក់១បានកើត ។ លោក-អ្នក អាចរំលឹកឡើងវិញថា នៅក្នុងឧទ្ទេស-កថាមួយរបស់យើងពីខាងដើម, យើងបាននិយាយពីហេតុការណ៍ ដែលថាកិលេសរមែងមានជាទូទៅ សម្រាប់សព្វសត្វមានជីវិត, ឯអំពើវិញ ផ្សេងពីគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ។ បានជាដូច្នេះ គឺដោយហេតុថា កិលេសពន្យល់ប្រាប់ហេតុដែលថា យើងទាំងអស់គ្នាជាអ្នកទោសនៅក្នុងសង្សារ, ប៉ុន្តែ អំពើទាំងឡាយពន្យល់ប្រាប់ហេតុដែលថា សត្វទាំងឡាយខ្លះកើតមកជាមនុស្ស សត្វទាំងឡាយខ្លះទៀត កើតជាទេវតា ហើយសត្វទាំងឡាយផ្សេងទៀត កើតជាសត្វតិរច្ឆាន ។ នៅក្នុងន័យនេះ សមាសភាគទាំងដប់ពីរនៃបដិច្ចសមុប្បាទ បង្ហាញនូវរូបភាពមួយនៃសង្សារៈ មួយអន្លើដោយហេតុ និងផលរបស់វា ។

វានឹងគ្មានអត្ថន័យសំខាន់ណាមួយ នៅក្នុងការគូសវាសរូបភាពសង្សារៈនេះទេ ប្រសិនបើយើងមិនមានបំណងប្រើប្រាស់រូបភាពនេះ ដើម្បីកែប្រែស្ថាន-

ភាពរបស់យើង ដើម្បីឱ្យចេញផុតពីសង្សារៈ ។ គឺនៅក្នុងន័យនេះហើយ ដែលការទទួលស្គាល់វដ្តសង្សារ ( the circularity of samsara ) វដ្តបដិច្ចសមុប្បាទ ( the circularity of dependent origination ) គឺជាការចាប់ផ្ដើមនៃវិមុត្តិ ( liberation ) ។ តើដំណើររឿងនេះយ៉ាងម្ដេច ? ដរាបណា កិលេស និងកម្ម នៅតែមាន, ដរាបនោះ ការកើតទៀត និងទុក្ខ នឹងនៅតែកើតមាន ។ កាលណាយើងមើលឃើញថា ម្ដងហើយម្ដងទៀត, អវិជ្ជា, តណ្ហា, ឧបាទាន និងកម្ម នឹងនាំទៅរកការកើតទៀត និងទុក្ខ, យើងត្រូវទទួលស្គាល់នូវភាពចាំបាច់ ដើម្បីបំបាក់រង្វង់មូល ( វដ្ត ) អកុសលនេះ ។ ចូរយើងលើកយកឧទាហរណ៍ជាក់ស្ដែងមួយ ។ ចូរសន្មតថា លោក-អ្នក កំពុងស្វែងរកផ្ទះមិត្តភក្ដិម្នាក់ ដែលលោក-អ្នក មិនធ្លាប់ដែលបានមកសោះពីពេលមុន ។ ចូរសន្មតថា លោក-អ្នក បានបើកឡានរកប្រហែលកន្លះម៉ោង ឬលើសនេះផង ហើយខកខានមិនបានរកឃើញផ្ទះមិត្តភក្ដិរបស់លោក-អ្នកទេ ; ហើយចូរសន្មតថា ភ្លាមនោះ លោក-អ្នកបានស្គាល់តម្រុយមួយ ដែលលោក-អ្នក បានមើលឃើញកាលពីកន្លះម៉ោងមុន ។ ចូរសន្មតថា លោក-អ្នក បានមកជួបតម្រុយម្ដងទៀត ហើយវានាំឱ្យលោក-អ្នកនឹកឃើញថា លោក-អ្នក បានបរឡានរំលងតម្រុយនោះកាលពីកន្លះម៉ោងកន្លងទៅ ។ នៅពេលនោះ, ប្រហែលជាវានាំឱ្យលោក-អ្នក ចាប់អារម្មណ៍ផងដែរថា លោក-អ្នក បានបើកបរជុំវិញជាច្រើនជុំ ហើយលោក-អ្នកត្រូវតែឈប់ ហើយបើកមើលមគ្គុទ្ទេសក៏ផ្លូវ (ផែនទីប្រាប់ផ្លូវ) របស់លោក-អ្នក, សាកសួរផ្លូវពីអ្នកថ្មើរជើងណាម្នាក់ ដើម្បីបញ្ឈប់ដំណើរបើកបរជុំវិញជាច្រើនជុំ ហើយទើបមកដល់ទីដៅ ។ នេះក៏ព្រោះតែហេតុយ៉ាងនោះហើយ ទើបព្រះពុទ្ធបានមានបន្ទូលថា អ្នកដែលមើលឃើញបដិច្ចសមុប្បាទ មើលឃើញព្រះធម៌ ហើយអ្នកដែលឃើញព្រះធម៌ មើលឃើញព្រះពុទ្ធ ។ ព្រោះហេតុនោះហើយ ទើបព្រះពុទ្ធទ្រង់មានបន្ទូល, ដូចខ្ញុំបាននិយាយខាងដើមរួចហើយ, ថាការយល់ដឹងបដិច្ច-

សមុប្បាទ គឺជាកូនសោទៅរកវិមុត្តិ ( ការរួចផុតទុក្ខ ) ។ ដូច្នេះ ពេលណា យើង មើលឃើញដំណើរប្រព្រឹត្តទៅរបស់បដិច្ចសមុប្បាទ, ពេលនោះ យើងអាចចាប់ ផ្ដើមរៀបចំបំបាក់រង្វង់មូល ( វដ្ដ ) ដ៏អកុសលនៃបដិច្ចសមុប្បាទបាន ។ យើងអាច ធ្វើការងារនេះបាន ដោយត្រូវបន្សាត់បង់នូវគ្រឿងសៅហ្មងនៃចិត្ត ( ឧបក្កិលេស-ចិត្ត ) - អវិជ្ជា, តណ្ហា, ឧបាទាន ។ ពេលណា គ្រឿងសៅហ្មងទាំងនេះ ( ឧបក្កិ-លេស ) ត្រូវបានលុបបំបាត់ហើយ, ពេលនោះ កម្មទាំងឡាយ ( អំពើ ) មិនត្រូវ បានប្រព្រឹត្តទេ, ហើយថាមភាពទម្លាប់ (habit energy) នឹងមិនកើតឡើងទេ ។ ពេលណា កម្មទាំងឡាយឈប់, ពេលនោះ ការកើតទៀត និងទុក្ខៈ នឹងឈប់ដែរ ។

ខ្ញុំចង់ចំណាយពេលបន្តិច និយាយពីអត្ថន័យដ៏សំខាន់មួយទៀត របស់ បដិច្ចសមុប្បាទ ពោលគឺ បដិច្ចសមុប្បាទដ៏ជាសំនួនវោហារនៃមជ្ឈិមមគ្គ ។ ក្នុង អំឡុងពេលធ្វើឧទ្ទេសកថាមួយ របស់យើងនៅខាងដើម, យើងមានឱកាសនិយាយ ដល់មជ្ឈិមមគ្គ, ហើយនៅឱកាសនោះ យើងដាក់កំហិតខ្លួនយើងនិយាយត្រឹមតែ អត្ថន័យជាគ្រឹះបំផុតប៉ុណ្ណោះ ។ យើងបាននិយាយថា មជ្ឈិមមគ្គ មានន័យថា ចៀស វាងអច្ចន្តភាពនៃការលង់ខ្លួនទៅក្នុងកាមសុខ ( សេចក្ដីស្រើបស្រាលតាមផ្លូវអា-យតនៈ ) និងអច្ចន្តភាពនៃអត្តកិលមថានុយោគ ( self mortification ) ។ នៅក្នុង បរិបទនេះ មជ្ឈិមមគ្គ មានន័យដូចគ្នានឹងមត្តញ្ញុតា ( ភាពស្គាល់ ឬដឹងប្រមាណ ) ។ ឥឡូវ នៅក្នុងបរិបទនៃបដិច្ចសមុប្បាទវិញ, មជ្ឈិមមគ្គ មានអត្ថន័យមួយទៀត ដែល ទាក់ទងដល់អត្ថន័យខាងដើម ប៉ុន្តែជ្រាលជ្រៅជាង ។ នៅក្នុងបរិបទនេះ មជ្ឈិមមគ្គ មានន័យថា ចៀសវាងអច្ចន្តភាពទាំងឡាយនៃសស្សតទិដ្ឋិ ( eternalism ) និង ឧច្ឆេទទិដ្ឋិ ( nihilism ) ។ តើរឿងនេះយ៉ាងដូម្ដេច ? អណ្ដាតភ្លើងនៃចង្កៀង ប្រេងកើតមានដោយពឹងផ្អែកលើប្រេង និងបញ្ចោះ កាលណាគ្មានប្រេង ឬគ្មាន បញ្ចោះទេ, អណ្ដាតភ្លើងនឹងរលត់ ។ ដោយហេតុនេះ អណ្ដាតភ្លើងទាំងមិនអាច

ឋិតថេរ ទាំងមិនអាចឯករាជបានទេ ។ ដូចគ្នានេះដែរ អត្តភាពរបស់យើងរាល់គ្នានេះពឹងផ្អែក ឬអាស្រ័យលើការរួមផ្សំលក្ខខ័ណ្ឌទាំងឡាយ -កិលេស និងកម្ម (អំពើ) ។ អត្តភាពទាំងមិនឋិតថេរ ទាំងមិនឯករាជ ។ ដោយទទួលស្គាល់ចរិតមានលក្ខខ័ណ្ឌនៃអត្តភាពរបស់យើង, យើងចៀសវាងបាននូវអច្ចន្តភាពនៃសស្សតទិដ្ឋិ ពោលគឺការអះអាងថា មានអត្តៈមួយឯករាជ និងជាអចិន្ត្រៃយ៍ ។ មួយវិញទៀត ដោយការទទួលស្គាល់ថា អត្តភាពនេះ, ជីវិតនេះមិនមែនកើតមានឡើងតាមរយៈចៃដន្យ ឬដោយសំណាងដ៏សាមញ្ញនោះទេ, ប៉ុន្តែ ជាជំនួយទៅវិញ វាមានលក្ខខ័ណ្ឌដោយសារមានហេតុសមស្រប, យើងចៀសវាងបាននូវអច្ចន្តភាពនៃឧច្ឆេទទិដ្ឋិ ពោលគឺអច្ចន្តភាពនៃការបដិសេធទំនាក់ទំនងរវាងអំពើ ( កម្ម ) និងផលវិបាក ។ ចំណែកឧច្ឆេទទិដ្ឋិ គឺជាបឋមហេតុនៃការកើតទៀត នៅក្នុងទុគ្គតិភព (states of woe) និងត្រូវតែបានបោះបង់ចោល, ឯសស្សតទិដ្ឋិផងដែរ ក៏មិននាំទៅរកវិមុត្តិ ( ការរំដោះផុតទុក្ខ ) ទេ ។ អ្នកណាមួយដែលតោងស្អិតនូវអច្ចន្តភាពនៃសស្សតទិដ្ឋិ, នឹងប្រព្រឹត្តអំពើជាកុសល ហើយនឹងទៅកើតជាថ្មីក្នុងសុគតិភព (states of happiness) ក្នុងឋានៈជាមនុស្ស ឬក៏ជាទេពតា, ប៉ុន្តែ អ្នកនោះនឹងមិនសំរេចបានវិមុត្តិទេ ។ តាមរយៈការចៀសវាងអច្ចន្តភាពទាំងពីរយ៉ាងនេះ, តាមរយៈការយល់ដឹងមជ្ឈិមមគ្គ យើងអាចសំរេចបានសេចក្តីសុខ ( សុភមង្គល ) នៅក្នុងជាតិនេះ និងក្នុងជាតិខាងមុខ ដោយការប្រព្រឹត្តធ្វើកុសលកម្ម ហើយចៀសវាងអកុសលកម្ម ហើយជាយថា-ហេតុ យើងអាចសំរេចបាននូវវិមុត្តិរសថែមទៀត ។

ព្រះពុទ្ធទ្រង់បានកសាងព្រះធម៌ ( ពាក្យប្រៀនប្រដៅ ) របស់ព្រះអង្គដោយសេចក្តីសីវិតសំរាំងគ្មានព្រំដែន ។ ព្រះធម៌របស់ព្រះអង្គ មានពេលខ្លះប្រហាក់ប្រហែលទៅនឹងចរិតរបស់មេខ្លាប្រព្រឹត្តចំពោះកូនរបស់ខ្លួន ។ កាលណា មេខ្លាពាំនាំយកកូនរបស់ខ្លួននៅក្នុងមាត់ដោយធ្មេញ វាតែងប្រយ័ត្នប្រយែងបំផុត មើលថាការ

ខាំរបស់វាមិនឱ្យតឹងពេក ឬមិនឱ្យធូរពេក ។ ប្រសិនបើវាខាំកូនរបស់វាត្រង់ក វាអាចនឹងបង្កឱ្យរបួស ឬឱ្យស្លាប់កូនរបស់វា ។ ប្រសិនបើការខាំពាំធូរពេក កូនរបស់វានឹងធ្លាក់ ហើយនឹងរបួស ។ ដូចគ្នានេះដែរ ព្រះពុទ្ធទ្រង់យកព្រះទ័យទុកដាក់ មើលថាយើងត្រូវចៀសវាងអច្ឆន្តភាពទាំងឡាយនៃសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ ពីព្រោះ ព្រះអង្គឃើញថា ការឱបក្រសោបយកអច្ឆន្តភាពនៃសស្សតទិដ្ឋិ នឹងប្រៀបបានទៅនឹងច្រវាក់មួយខ្សែដែលចងឆ្នាក់យើងនៅក្នុងសង្សារៈ ។ ព្រះពុទ្ធទ្រង់យកព្រះទ័យទុកដាក់ប្រៀនប្រដៅយើងឱ្យចៀសវាងជំនឿថាមានអត្តៈមួយឯករាជ និងជាអចិន្ត្រៃយ៍ ។ ពីព្រោះ ព្រះអង្គទ្រង់ទតឃើញលទ្ធភាពនៃការរំដោះផុតពីការបំផ្លាញដោយចង្កូមមុតស្រួចនៃជំនឿក្នុងអត្តៈ ទើបព្រះពុទ្ធទ្រង់សុំឱ្យយើងចៀសវាងអច្ឆន្ត-ភាពនៃសស្សតទិដ្ឋិ ។ ប៉ុន្តែ ការយល់ដឹងថា ការឱបក្រសោបយកអច្ឆន្តភាពនៃឧច្ឆេទទិដ្ឋិ នឹងនាំទៅកាន់មហន្តរាយ . ពីការកើតជាថ្មីនៅក្នុងទុគ្គតិភព ទើបព្រះអង្គទ្រង់យកព្រះទ័យទុកដាក់ប្រៀនប្រដៅអំពីតថភាពនៃក្រឹត្យក្រមហេតុ និងផល អំពីការទទួលខុសត្រូវខាងសីលធម៌ ។ ពីព្រោះ ព្រះអង្គទតឃើញថា គេនឹងធ្លាក់ទៅក្នុងទុគ្គតភាពនៃឋាននរក ដោយការបដិសេធនូវក្រឹត្យក្រុនៃការទទួលខុសត្រូវខាងសីលធម៌ ទើបព្រះអង្គបានប្រៀនប្រដៅយើងឱ្យជៀសវាងអច្ឆន្តភាព ឧច្ឆេទទិដ្ឋិ ។ កម្មវត្ថុនេះត្រូវបានសំរេចឡើងគួរឱ្យកោតសរសើរ តាមរយៈការប្រៀនប្រដៅអំពីបដិច្ចសមុប្បាទ ដែលការពារការយល់ដឹងរបស់យើងអំពីចរិត (ធម្មជាតិ) មានលក្ខ-ខ័ណ្ឌពឹងផ្អែក និងមិនឋិតថេរនៃអត្តភាពនេះ និងការយល់ដឹងរបស់យើងអំពីតថភាពនៃក្រឹត្យក្រមហេតុ និងផល ។

នៅក្នុងបរិបទនៃបដិច្ចសមុប្បាទ, យើងបានរៀបរាប់អំពីចរិត ឬ ធម្ម-ជាតិពឹងផ្អែកមិនឋិតថេរនៃអត្តភាព គឺអត្តៈ តាមមធ្យោបាយគូសបញ្ជាក់នូវចរិតពឹងផ្អែករបស់វា ។ នៅក្នុងពេលពីរសប្តាហ៍កន្លងទៅ យើងនឹងទៅដល់អនិច្ចតា ( ភាព

មិនឋិតថេរ ) និងអនត្តតា (impersonality) នៃអត្តៈ តាមរយៈការពិនិត្យធម្មជាតិរួមផ្សំរបស់វា ( its composite nature ) និងតាមរយៈការវិភាគធម្មជាតិរួមផ្សំនេះ ទៅជាផ្នែករួមផ្សំ ( បតិដ្ឋាភាគ ) ។ ដោយសារមធ្យោបាយទាំងនេះ យើងនឹងបំភ្លឺឱ្យឃើញសច្ចធម៌នៃអនត្តៈដែលបើកទ្វារទៅកាន់ការត្រាស់ដឹង ។

*

* *

## XI

## លក្ខណៈសកលបីយ៉ាង ( ត្រៃលក្ខណៈ )

( three characterstics )

ប្រធានបទថ្ងៃនេះគឺ លក្ខណៈសកលបីយ៉ាងនៃជីវិត ( អត្ថិភាព ) ។ នេះជាផ្នែកមួយដ៏សំខាន់នៃព្រះធម៌របស់ព្រះពុទ្ធ ។ ដូចគ្នានឹងអរិយសច្ចៈបួនយ៉ាង, កម្មៈ, ការប្រៀនប្រដៅអំពីបដិច្ចសមុប្បាទ, និងខន្ធទាំងប្រាំ ( បញ្ចក្ខន្ធ ) ដែរ, ការប្រៀនប្រដៅអំពីត្រៃលក្ខណៈ គឺជាផ្នែកនៃអ្វីដែលយើងអាចហៅថាខ្លឹមសារទ្រឹស្តីនៃបញ្ញា ។ និយាយម្យ៉ាងទៀត កាលណាយើងនិយាយពីចំណេះដឹង និងពីការយល់ដឹងដែលទាក់ទងដល់បញ្ញា, យើងតែងតែនឹកឃើញពាក្យប្រៀនប្រដៅនេះ ។

មុនយើងពិនិត្យមើលលក្ខណៈទាំងឡាយនេះ ម្តងមួយៗ យើងត្រូវក្តាប់ឱ្យបាន ថាតើលក្ខណៈទាំងនោះមានន័យយ៉ាងម៉េច ហើយតើវាមានប្រយោជន៍ក្នុង

ផ្លូវអ្វីខ្លះ ។ ដំបូងបង្អស់, តើអ្វីជាលក្ខណៈ ហើយអ្វីមិនមែនជាលក្ខណៈ ។ លក្ខណៈ គឺជាអ្វីមួយ ដែលអាស្រ័យនៅយ៉ាងចាំបាច់ជាមួយនឹងអ្វីមួយទៀត ។ ពីព្រោះ លក្ខណៈ អាស្រ័យនៅនឹងអ្វីមួយយ៉ាងចាំបាច់ ដូច្នេះ វាអាចប្រាប់យើងអំពីចរិត (ឬ ធម្មជាតិ) នៃវត្ថុនោះ ។ ចូរយើងលើកយកឧទាហរណ៍មួយ ។ យ៉ាងណាមិញ កម្ដៅ គឺជាលក្ខណៈរបស់ភ្លើង, ប៉ុន្តែ មិនមែនជាលក្ខណៈមួយរបស់ទឹកទេ ។ កម្ដៅ គឺជា លក្ខណៈរបស់ភ្លើង ពីព្រោះ កម្ដៅតែងអាស្រ័យជានិច្ច និងឥតប្រែប្រួល ជាមួយ ភ្លើង ។ ម្យ៉ាងទៀត កម្ដៅរបស់ទឹក រមែងពឹងផ្អែកលើកត្តាខាងក្រៅ ដូចជា ចង្ក្រាន អគ្គិសនី, កម្ដៅថ្ងៃ ។ល។ ប៉ុន្តែ កម្ដៅនៃភ្លើង គឺជា ធម្មជាតិរបស់ភ្លើង ។ គឺនៅ ក្នុងន័យនេះ ទើបព្រះពុទ្ធទ្រង់ប្រើពាក្យលក្ខណៈ (characteristic) ដើម្បីយោង ទៅរកហេតុការណ៍ទាំងឡាយអំពីចរិត ( ឬធម្មជាតិ ) នៃជីវិត, ដែលតែងអាស្រ័យ ជានិច្ចជាមួយជីវិត ហើយដែលតែងឃើញជានិច្ចនៅក្នុងជីវិត ( existence ) ។ លក្ខណៈកម្ដៅ គឺអាស្រ័យជានិច្ចជាមួយភ្លើង ។ ដូច្នេះ យើងអាចយល់ដឹងអ្វីមួយ អំពីចរិត ( ធម្មជាតិ ) នៃភ្លើងតាមរយៈកម្ដៅ ។ យើងអាចដឹងថាភ្លើងគឺក្ដៅ ។ យើង អាចដឹងថា យើងអាចប្រើប្រាស់ភ្លើងសម្រាប់ចម្អិនអាហាររបស់យើង សម្រាប់ កម្ដៅខ្លួនយើង, ។ល។ ចរិតកម្ដៅប្រាប់ឱ្យយើងដឹងនូវអ្វីមួយអំពីភ្លើង, តើត្រូវ ប្រើប្រាស់ភ្លើងយ៉ាងណា និងត្រូវធ្វើអ្វីខ្លះជាមួយភ្លើង ។ ប្រសិនបើយើងត្រូវគិត អំពីលក្ខណៈនៃកម្ដៅ ដោយអាស្រ័យនៅជាមួយទឹក, វានឹងមិនជួយយើងឱ្យប្រើ ប្រាស់ទឹកបានទេ ពីព្រោះ កម្ដៅមិនអាស្រ័យជានិច្ចជាមួយនឹងទឹកឡើយ ។ យើងមិន អាចចម្អិនអាហាររបស់យើងដោយទឹកបានទេ ។ យើងមិនអាចកម្ដៅខ្លួនយើង ជាមួយទឹកបានទេ ។ ដូច្នេះ កាលណាព្រះពុទ្ធទ្រង់សំដែងថា មានលក្ខណៈបីយ៉ាង របស់ជីវិត, ព្រះអង្គសំដៅថា លក្ខណៈទាំងនោះតែងមានវត្តមានជានិច្ចនៅក្នុងជីវិត ហើយលក្ខណៈទាំងនោះជួយយើងឱ្យយល់នូវអ្វីដែលត្រូវធ្វើចំពោះជីវិត ។

លក្ខណៈបីយ៉ាងនៃជីវិតដែលយើងចងចាំនៅក្នុងចិត្ត គឺ លក្ខណៈនៃអនិច្ចៈ, ទុក្ខៈ និងអនត្តៈ ។ លក្ខណៈទាំងបីយ៉ាងនេះ មានវត្តមានជានិច្ចនៅក្នុងជីវិត ឬអាស្រ័យជានិច្ចជាមួយជីវិត, ហើយវាប្រាប់យើងអំពីធម្មជាតិនៃជីវិត ។ វាជួយយើងឱ្យដឹងនូវអ្វីដែលត្រូវធ្វើចំពោះជីវិត ។ អ្វីដែលយើងបានចេះចាំដើម្បីអភិវឌ្ឍទុកដូចជាលទ្ធផលនៃការយល់ដឹងនូវលក្ខណៈទាំងបីយ៉ាង គឺ អភិនិក្ខមនៈ ឬ អភិនិ-ស្រ្កមណ៍ (Renunciation) ។ ពេលណាយើងបានយល់ដឹងថា ជីវិតត្រូវបានកំណត់ជាសាកលដោយលក្ខណៈអនិច្ចៈ ទុក្ខៈ និងអនត្តៈ ហើយយើងត្រូវលុបបំបាត់ចំណង់ ( ការជាប់ជំពាក់ចិត្ត ) របស់យើងចំពោះជីវិត ។ ពេលណាយើងលុបបំបាត់ចំណង់ចំពោះជីវិតបានហើយ, យើងបានដើរដល់មាត់ទ្វារនៃនិព្វានហើយ ។ នេះគឺជាគោលបំណងដែលការយល់ដឹងនូវត្រៃលក្ខណៈត្រូវបំរើ ។ វាជួយកំចាត់រាគៈ ( attachement ) តាមរយៈការកំចាត់សម្មោហៈ ( សេចក្តីភាន់នៃវិញ្ញាណ ឬគំនិត ) គឺការយល់ខុសថា ជីវិតឋិតថេរជាអចិន្រ្តៃយ៍, ជាទីត្រេកត្រអាល, ហើយមានអ្វីមួយទាក់ទងជាមួយអត្តៈ ។ ព្រោះហេតុនេះហើយ ការយល់ដឹងនូវត្រៃលក្ខណៈ គឺជាភាគនៃអត្ថរសរបស់បញ្ញា ។

ចូរយើងក្រឡេកមើលលក្ខណៈទីមួយ ក្នុងបណ្តាលក្ខណៈបីនៃជីវិត, គឺលក្ខណៈនៃអនិច្ចធាតុ ។ ហេតុពិតនៃអនិច្ចធាតុ ត្រូវបានគេទទួលស្គាល់ មិនមែនតែនៅក្នុងទ្រឹស្តីពុទ្ធសាសនាប៉ុណ្ណោះទេ ប៉ុន្តែ នៅក្នុងទីដទៃទៀតនៃប្រវត្តិសាស្រ្តនៃទស្សនវិជ្ជា ។ គឺទស្សនវិទូក្រិកបុរាណ លោកហេរ៉ាក្លីតុស (Heraclitus) ដែលបានកត់ត្រាទុកថា គេមិនអាចចុះទៅក្នុងស្ទឹងដដែលពីរដងបានទេ ។ កំណត់សម្គាល់នេះ ដែលសំដៅន័យដល់ធម្មជាតិប្រែប្រួលជាអចិន្រ្តៃយ៍ និងមិនឋិតថេរនៃវត្ថុទាំងឡាយ គឺជាសេចក្តីសង្កេតបែបពុទ្ធសាសនាសុទ្ធសាធ ។ នៅក្នុងគម្ពីរពុទ្ធសាសនា, គេនិយាយថា លោកទាំងបី មិនឋិតថេរទេ បីដូចជាពពកនាសរទរដូវ ; ជាតិ និងមរណៈ

បីដូចជារបាំងមួយ ; ហើយជីវិតមនុស្សបីដូចជាចំណាំងផ្លេកបន្ទោរ ឬទឹកជ្រោះហូរ ។ ទាំងអស់នេះ គឺជារូបភាពបង្អិតបង្ហំនៃអនិច្ចតាធម៌ ហើយវាជួយឱ្យយើងយល់ដឹងថា វត្ថុទាំងអស់ ( អ្វីៗទាំងអស់ ) មានលក្ខណៈជាអនិច្ចតាធម៌ ។

ប្រសិនបើយើងក្រឡេកមើលបុគ្គលភាពរបស់យើងផ្ទាល់, យើងនឹងឃើញថា សរីរាង្គរបស់យើងគឺ អនិច្ចៈ ។ វាចំណុះក្រោមការប្រែប្រួលជាប្រចាំ ។ យើងកាន់តែស្គមទៅ ។ យើងកាន់តែចាស់ ហើយមានសក់ស្កូវ, ធ្មេញបាក់ សក់ជ្រុះ ។ ប្រសិនបើគេត្រូវការភ័ស្តុតាងបញ្ជាក់អនិច្ចតាធម៌ ចំពោះរូបកាយរបស់គេ, គេគ្រាន់តែក្រឡេកមើលរូបថតផ្ទាល់របស់គេនៅលើប័ណ្ណបើកបរផ្ទាល់របស់គេ ឬនៅលើលិខិតឆ្លងដែនប៉ុន្មានឆ្នាំកន្លងមក ។ ដូចគ្នានេះដែរ ស្ថានភាពចិត្តរបស់យើងក៏ជាអនិច្ចៈ ។ នៅខណៈមួយ យើងសប្បាយរីករាយ, ហើយនៅខណៈមួយទៀតយើងបែរជាក្រៀមក្រំ ។ កាលនៅក្មេង យើងពុំសូវយល់ដឹងអ្វីមួយច្បាស់ទេ ។ ដល់ពេលធំឡើងនៅក្នុងបឋមវ័យ យើងយល់ដឹងច្រើនឡើង ។ លុះដល់ចូលក្នុងវ័យចាស់ យើងបានបាត់បង់អានុភាពនៃសមត្ថភាពខួរក្បាលរបស់យើង ហើយប្រែក្លាយទៅដូចជាកូនក្មេង ។ ចិត្តរបស់យើងក៏មានលក្ខណៈអនិច្ចៈដែរ ។ នេះគឺជាហេតុពិតផងដែរ ចំពោះអ្វីៗទាំងអស់ដែលយើងឃើញនៅជុំវិញយើង ។ អ្វីៗដែលយើងមើលឃើញជុំវិញយើង ក៏ជាអនិច្ចៈ ។ គ្មានអ្វីមួយត្រូវឋិតថេរជារៀងរហូតទេ . ទាំងអគារធំៗប្រើជាការិយាល័យ, ទាំងព្រះវិហារ, ទាំងទន្លេ . ស្ទឹង និងកោះ, ទាំងជួរភ្នំទាំងមហាសាគរ ។ យើងដឹងច្បាស់ណាស់ថា ធាតុភូតធម្មជាតិទាំងអស់នោះ, សូម្បីធាតុភូតទាំងនោះកើតមានឡើងហាក់ដូចជាឋិតថេរបំផុត, សូម្បីតែប្រព័ន្ធព្រះអាទិត្យ ( សុរិយប្រព័ន្ធ ) ខ្លួនឯង នៅថ្ងៃណាមួយ នឹងត្រូវទ្រុឌទ្រោម ហើយប្រែក្លាយជារលត់រលាយ ។

អភិក្រមនៃការប្រែប្រួលជាអចិន្ត្រៃយ៍នេះនៃវត្ថុទាំងអស់. ទាំងផ្ទាល់ខ្លួន

និងមិនផ្ទាល់ខ្លួន, ទាំងខាងក្រៅ និងខាងក្នុង ៈ តែងប្រព្រឹត្តទៅជាអចិន្ត្រៃយ៍ សូម្បីខ្លួនយើងក៏មិនអាចដឹងបានផង ហើយអភិក្រមនេះប៉ះពាល់ដល់ខ្លួនយើងយ៉ាងជ្រាលជ្រៅ នៅក្នុងជីវិតរៀងរាល់ថ្ងៃរបស់យើង ។ ទំនាក់ទំនងរបស់យើងជាមួយបុគ្គលទាំងឡាយឯទៀត ឋិតក្រោមលក្ខណៈនៃអនិច្ចតាធម៌ និងការផ្លាស់ប្តូរ ។ មិត្តប្រែក្លាយជាសត្រូវ, សត្រូវប្រែក្លាយជាមិត្ត ។ សូម្បីសត្រូវប្រែក្លាយជាញាតិសន្តាន ។ ញាតិសន្តានប្រែក្លាយជាសត្រូវ ។ ប្រសិនបើយើងក្រឡេកមើលជីវិតរបស់យើងឱ្យជិតដល់ទៅ យើងអាចមើលឃើញ ថាតើទំនាក់ទំនងរបស់យើងទាំងអស់ ជាមួយមនុស្សទាំងឡាយដទៃ ត្រូវបានជិតដាមដោយអនិច្ចតាធម៌យ៉ាងណា ។ ទ្រព្យសម្បត្តិទាំងឡាយរបស់យើង ក៏មិនឋិតថេរ ( អនិច្ចៈ ) ដែរ ។ វត្ថុទាំងឡាយនោះដែលយើងស្រឡាញ់យ៉ាងខ្លាំង ៈ ដូចជាផ្ទះសម្បែងរបស់យើង, រថយន្តរបស់យើង សម្លៀកបំពាក់របស់យើង ទាំងអស់នេះជាអនិច្ចៈ ។ អ្វីៗទាំងអស់នោះ នឹងត្រូវពុកផុយ ហើយត្រូវវិនាសអន្តរាយជាយថាហេតុ ។ ដូច្នេះ នៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរបស់យើង, ទោះបីវាជាបុគ្គលផ្ទាល់ខ្លួន ឬជាសម្ភារៈ, ឬទោះបីទាក់ទងទៅនឹងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ, ឬទោះបីវាជាទ្រព្យសម្បត្តិទាំងឡាយរបស់យើង, អនិច្ចតាធម៌ គឺជាហេតុពិតមួយ ដែលត្រូវបានបញ្ជាក់ដោយការពិនិត្យសង្កេតផ្ទាល់យ៉ាងជិតដល់ ។

ការយល់ដឹងនូវអនិច្ចតាធម៌ គឺមានសារសំខាន់ណាស់, មិនមែនគ្រាន់តែសម្រាប់ការប្រតិបត្តិធម៌របស់យើងយ៉ាងសាមញ្ញនោះទេ ប៉ុន្តែ សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់យើងផងដែរ ។ ថាតើញឹកញយប៉ុន្មានដងហើយ ដែលមិត្តភាពត្រូវរង្គោះរង្គើ ហើយត្រូវបញ្ចប់, ពីព្រោះ មនុស្សម្នាក់ក្នុងចំណោមមនុស្សដែលពាក់ព័ន្ធមិនបានកត់ចំណាំនូវហេតុពិតដែលប្រាប់ថា អាកប្បកិរិយា, អត្ថប្រយោជន៍ និងអ្វីៗដទៃទៀតរបស់មិត្តខ្លួនបានផ្លាស់ប្តូរ ។ ថាតើញឹកញយប៉ុន្មានដងហើយ ដែលអាពាហ៍

ពិពាហ៍ត្រូវបរាជ័យ ពីព្រោះ តែមនុស្សម្នាក់ ឬពីរនាក់នៃអាពាហ៍ពិពាហ៍ មិនបានកត់សំគាល់ឃើញនូវហេតុពិតដែលប្រាប់ថា ដៃគូខាងប្រុសឬខាងស្រី បានផ្លាស់ប្តូរចិត្ត ។ នេះគឺពីព្រោះតែយើងចាក់សោខ្លួនយើងនៅតែខាងក្នុងគំនិតនឹងថ្កល់, ឥតប្រែប្រួលស្ថានៗនៃចរិត និងបុគ្គលភាពរបស់មិត្ត និងញាតិសន្តានរបស់យើង ដែលយើងមិនបានធ្វើឱ្យមិត្តភាពរបស់យើងជាមួយគេរីកចំរើនជាវិជ្ជមាន ហើយដោយសារតែកង្វះខាតនេះ យើងមិនសូវបានយល់គ្នាទៅវិញទៅមក ។ ដូចគ្នានេះដែរ នៅក្នុងមុខរបរ ឬក្នុងជីវភាពសាធារណៈរបស់គេ, គេមិនអាចសង្ឃឹមទទួលជោគជ័យបានទេ ប្រសិនបើគេមិនបានតាមទាន់ស្ថានភាពប្រែប្រួល ឧទាហរណ៍ដូចជា និន្នាការថ្មីៗនៅក្នុងវិជ្ជាជីវៈ ឬមុខវិជ្ជារបស់គេ ។ ដូច្នេះ ទោះបីវាទាក់ទងទៅនឹងជីវភាពផ្ទាល់ខ្លួនរបស់យើងក្តី ឬទាក់ទងទៅនឹងជីវភាពសាធារណៈរបស់យើងក្តី ការយល់ដឹងនូវអនិច្ចតា-ធម៌ គឺជាការចាំបាច់ ប្រសិនបើយើងជាមនុស្សម៉ត់ចត់ និងមានគំនិតច្នៃប្រឌិតនៅក្នុងស្ថានភាពដែលយើងកាន់កាប់កិច្ចការផ្ទាល់ខ្លួន ឬកិច្ចការវិជ្ជាជីវៈរបស់យើង ។

នៅពេលការយល់ដឹងនូវអនិច្ចតាធម៌ រមែងផ្តល់អត្ថប្រយោជន៍ភ្លាមៗទាំងនេះ, ចាប់ពីពេលនេះទៅ វាមានប្រសិទ្ធភាពយ៉ាងពិសេស សម្រាប់ជាជំនួយដល់ការប្រតិបត្តិព្រះធម៌របស់យើង ។ ការយល់ដឹងអំពីអនិច្ចតាធម៌ គឺជាថ្នាំបន្សាបឥច្ឆា និងព្យាបាទៈ ។ វាជាការលើកទឹកចិត្តផងដែរ ចំពោះការប្រតិបត្តិព្រះធម៌របស់យើង ។ ហើយនៅទីបំផុត វាជាកូនសោមួយ សម្រាប់ការយល់ដឹងធម្មជាតិចុងក្រោយនៃវត្ថុអ្វីៗ ពោលគឺ បែបបទដែលវត្ថុទាំងឡាយមានពិតប្រាកដ ។

ការរំលឹកសេចក្តីស្លាប់ ( មរណានុស្សតិ ) ត្រូវបានគេពោលដោយពិសេសថា ទុកដូចជាមិត្តសម្លាញ់ម្នាក់ និងជាគ្រូអាចារ្យម្នាក់ចំពោះគេ ដែលប្រាថ្នាប្រតិបត្តិព្រះធម៌ ។ មរណានុស្សតិ ដើរតួរជាការរារាំងដល់ឥច្ឆា និងព្យាបាទៈ ដ៏ហួសហេតុ ។ តើជម្លោះ ការមិនចុះសម្រុងគ្នាតូចតាច, មហិច្ឆតាប្រចាំជីវិត និងភាពជា

សត្រូវនឹងគ្នាប៉ុន្មានលើក ប៉ុន្មានដង បានសាបរលាបទៅជាគ្មានន័យ មុនពេលមានការទទួលស្គាល់នូវភាពចៀសមិនផុតនៃមរណៈ ។ អស់កាលជាច្រើនសតវត្សហើយ គ្រូអាចារ្យប្រដៅពុទ្ធសាសនា បានលើកទឹកចិត្តឱ្យអ្នកប្រតិបត្តិព្រះធម៌ ដ៏ស្មោះត្រង់ រំលឹកនូវសេចក្តីស្លាប់, រំលឹកនូវអនិច្ចតាធម៌នៃបុគ្គលភាពនេះ ។ កាលពីប៉ុន្មានឆ្នាំកន្លងទៅ ខ្ញុំមានមិត្តម្នាក់ដែលបានធ្វើដំណើរទៅប្រទេសឥណ្ឌា ដើម្បីរៀនសមាធិ ។ គេបានទៅកាន់សំណាក់គ្រូអាចារ្យប្រដៅពុទ្ធសាសនា ជាអ្នកប្រាជ្ញ និងមានកេរ្តិ៍ឈ្មោះម្នាក់ ហើយបានសុំឱ្យលោកជួយបង្រៀនសមាធិ ។ លោកគ្រូមានសេចក្តីធុញទ្រាន់ មិនចង់បង្រៀនមិត្តខ្ញុំទេ ពីព្រោះ លោកគ្រូនោះមិនមានជំនឿចំពោះសេចក្តីស្មោះត្រង់របស់មិត្តខ្ញុំឡើយ ។ មិត្តរបស់ខ្ញុំនៅតែទទូចសុំគាត់ជាញឹកញាយ ។ នៅទីបំផុត លោកគ្រូបាននិយាយប្រាប់គាត់ថា « លោកឯងនឹងស្លាប់, ចូរធ្វើសមាធិលើន័យនេះទៅ » ។ ការធ្វើសមាធិលើសេចក្តីស្លាប់ មានអត្ថប្រយោជន៍យ៉ាងក្រៃលែង ។ យើងទាំងអស់គ្នា ត្រូវតែខំរំលឹកនូវភាពទៀងទាត់នៃសេចក្តីស្លាប់របស់យើង ។ ចាប់ពីពេលយើងកើត យើងតែងខិតដោយទប់មិនបានទៅកាន់សេចក្តីស្លាប់ ។ រំលឹកឃើញសេចក្តីនេះ និងរំលឹកឃើញថា នៅពេលស្លាប់, ទ្រព្យសម្បត្តិ, គ្រួសារ និងកេរ្តិ៍ឈ្មោះ និងគ្មានប្រយោជន៍អ្វីឡើយសម្រាប់យើង, យើងត្រូវបង្វែរចិត្តរបស់យើងទៅរកការប្រតិបត្តិព្រះធម៌ ។ យើងដឹងថា សេចក្តីស្លាប់ គឺពិតប្រាកដណាស់ ។ មិនដែលមានសត្វណាមួយបានគេចផុតពីសេចក្តីស្លាប់ឡើយ ។

ប៉ុន្តែថា នៅពេលដែលសេចក្តីស្លាប់នេះឯង គឺពិតប្រាកដ ឯពេលនៃការស្លាប់ គឺមិនទៀងទាត់ទេ ។ យើងអាចស្លាប់នៅពេលណាមួយ ។ គេនិយាយថា ជីវិតគឺបីដូចជាភ្លើងទៀននៅកណ្តាលវាល ឬបីដូចជាក្រពេញទឹក ។ នៅពេលណាមួយ ជីវិតនេះអាចរលត់បាត់ទៅ ។ នៅពេលណាមួយ ជីវិតនេះអាចផ្ទុះបែកទៅ ។ ការយល់ដឹងថា ពេលវេលានៃការស្លាប់ គឺមិនទៀង ហើយយល់ដឹងថាឥឡូវ យើងមាន

ស្ថានភាព និងឱកាស ដើម្បីប្រតិបត្តិព្រះធម៌ យើងត្រូវតែប្រតិបត្តិព្រះធម៌នោះភ្លាមទៅ ដើម្បីកុំឱ្យយើងខ្ជះខ្ជាយឱកាសនេះ និងជីវិតដ៏ថ្លៃថ្លាជាមនុស្សនេះ ។

នៅទីបំផុត ការយល់ដឹងអនិច្ចតាធម៌ គឺជាជំនួយមួយដល់ការយល់ដឹងនូវធម្មជាតិចុងក្រោយនៃវត្ថុទាំងឡាយ ។ ដោយមើលឃើញថា វត្ថុទាំងអស់សុទ្ធតែត្រូវវិនាសទៅ ហើយប្រែប្រួលរាល់ខណៈ យើងក៏ចាប់ផ្ដើមមើលឃើញផងដែរថា វត្ថុទាំងឡាយគ្មានអត្ថិភាពជាសារវន្តផ្ទាល់ខ្លួនវាទេ ( អនត្តៈ ) ។ ទាំងនៅក្នុងបុគ្គលរបស់យើង ទាំងនៅក្នុងវត្ថុទាំងឡាយជុំវិញយើង គ្មានអ្វីមួយដូចជា អត្តៈ នោះទេ ។ ដូច្នេះ ក្នុងន័យនេះ អនិច្ចតាធម៌ គឺទាក់ទងដោយផ្ទាល់ទៅនឹងលក្ខណៈទីបី នៃត្រៃ-លក្ខណៈ គឺលក្ខណៈអនត្តៈ ។ ការយល់ដឹងនូវអនិច្ចតាធម៌ គឺជាកូនសោមួយចំពោះការយល់ដឹងអនត្តតាធម៌ ។ យើងនឹងនិយាយឱ្យច្រើនអំពីរឿងនេះ នៅពេលក្រោយ ។ សម្រាប់ពេលនេះ, ចូរយើងបន្តទៅនិយាយពីលក្ខណៈទីពីរនៃត្រៃ-លក្ខណៈ គឺ លក្ខណៈនៃទុក្ខៈ ឬទុក្ខតាធម៌ ។

ព្រះពុទ្ធទ្រង់បាសំដែងថា អ្វីជាអនិច្ចៈ គឺ ទុក្ខៈ , ហើយអ្វីជាអនិច្ចៈ និងទុក្ខៈ គឺជាអនត្តៈ ។ អ្វីដែលជាអនិច្ចៈ គឺ ទុក្ខៈ ពីព្រោះ អនិច្ចតាធម៌ គឺជាឱកាសមួយនាំឱ្យមានទុក្ខ ដរាបណា អវិជ្ជា, តណ្ហា និងឧបាទាន នៅតែមាន ។ តើដំណើររឿងនោះយ៉ាងដូចម្ដេច ? នៅក្នុងអវិជ្ជា ឬការមិនស្គាល់នូវធម្មជាតិពិតនៃវត្ថុទាំងឡាយ, យើងអន្ទះសាចង់បាន ហើយឱបក្រសោបយកវត្ថុទាំងឡាយក្នុងសេចក្ដីសង្ឃឹម ដ៏គ្មានខ្លឹមសារថា វត្ថុទាំងនោះអាចគង់វង្សឋិតថេរ, អាចផ្ដល់សុភមង្គលជាអចិន្ត្រៃយ៍ ។ ការខកខានមិនបានយល់ថា យុវវ័យ, សុខភាព, និងជីវិតផ្ទាល់ ក៏អនិច្ចៈ ពោលគឺ មិនឋិតថេរ, យើងបែរជាអន្ទះសាចង់បានវា, យើងឱបក្រសោបវា ។ យើងទទូចចង់ឱ្យយុវវ័យរបស់យើងនៅដដែល និងចង់ឱ្យជីវិតរបស់យើងបានវែងឆ្ងាយ បើទោះបីជា យុវវ័យ និងជីវិតនោះមិនឋិតថេរ ( អនិច្ចៈ ) តាមធម្មជាតិ, វារមែងរអិលតាមចង្អៀក

ម្រាមដៃ ដូចជាដីខ្សាច់ ។ កាលណា រឿងនេះកើតមាន, អនិច្ចតាធម៌ គឺជាឱកាសមួយនាំឱ្យមានទុក្ខ ។ ដូចគ្នានេះដែរ, យើងខកខានមិនបានទទួលស្គាល់ធម្មជាតិអនិច្ចៈ នៃទ្រព្យសម្បត្តិ, អំណាច និងកិត្តិយស ។ យើងអន្ទះសាចង់បាន និងឱបក្រសោបវា ។ ពេលណាវាត្រូវចប់, អនិច្ចតាធម៌ គឺជាឱកាសមួយនាំឱ្យមានទុក្ខ ។ អនិច្ចតាធម៌ នៃស្ថានភាពទាំងអស់នៅក្នុងសង្សារ គឺជាឱកាសដោយឡែកមួយនាំឱ្យមានសេចក្តីទុក្ខ កាលណាវាកើតមាននៅក្នុងភព ដែលគេហៅថា សុគតិភព ( the so-called fortunate realm ) ។ គេតែងនិយាយថា សេចក្តីទុក្ខរបស់ទេពតា គឺជាសេចក្តីទុក្ខធំជាងសេចក្តីទុក្ខរបស់សត្វមានជីវិតទាំងឡាយ ដែលកំពុងរស់នៅក្នុងភពខាងក្រោម កាលណាទេពតាទាំងឡាយនោះមើលឃើញថា លោកហៀបនឹងច្យុតចាកស្ថានសួគ៌ មកយោនយកកំណើតនៅភពក្រោមវិញ ។ សូម្បីទេពតាទាំងឡាយ ក៏រន្ធត់ញាប់ញ័រ ពេលណាព្រះពុទ្ធទ្រង់បានរំលឹកទេពតាទាំងឡាយនោះអំពីអនិច្ចតាធម៌ ។ ហេតុបានជាដូច្នោះ ពីព្រោះ សូម្បីតែបទពិសោធន៍ដ៏ជាទីពេញចិត្តទាំងនោះ ដែលយើងអន្ទះសាចង់បាន ហើយតោងស្អិត ក៏វាមិនឋិតថេរ ( អនិច្ចៈ ) ដូច្នេះ អនិច្ចតា-ធម៌ គឺជាឱកាសមួយនាំឱ្យមានសេចក្តីទុក្ខ ហើយអ្វីគ្រប់យ៉ាងជាអនិច្ចៈ ក៏ជាទុក្ខផងដែរ ។

ឥឡូវ យើងបានមកដល់សាកលលក្ខណៈទីបី នៃជីវិត គឺលក្ខណៈនៃអនត្តា ឬគ្មានបុគ្គលភាព ឬក៏គ្មានសារធាតុ ។ នេះគឺនៅក្នុងន័យជាលក្ខណៈមួយ ក្នុងបណ្តាលក្ខណៈពិសេស ដ៏លេចធ្លោយ៉ាងជាក់ស្តែង នៃពុទ្ធសាសនវាទ និងក្នុងបណ្តាពាក្យប្រៀនប្រដៅទាំងឡាយ ( ព្រះធម៌ ) របស់ព្រះពុទ្ធ ។ នៅក្នុងអំឡុងពេលនៃការអភិវឌ្ឍន៍ចុងក្រោយនៃសាសនា និងទស្សនវិជ្ជាក្នុងប្រទេសឥណ្ឌា, និកាយសាសនាហិណ្ឌូខ្លះ ( Some Hindu schools ) កាន់តែប្រែក្លាយដូចគ្នាច្រើនឡើងទៅនឹងព្រះធម៌ ( ពាក្យប្រៀនប្រដៅ ) របស់ព្រះពុទ្ធនៅក្នុងបច្ចេកទេសធ្វើសមាធិរបស់គេ

និងនៅក្នុងគំនិតទស្សនវិជ្ជាខ្លះរបស់គេ ។ ដូច្នេះ វាប្រែក្លាយជាការចាំបាច់នាំឱ្យត្រូវបង្ហាត់ពុទ្ធសាសនាត្រូវចង្អុលប្រាប់ថា វានៅមានលក្ខណៈពិសេស ដ៏លេចធ្លោមួយនៅឡើយ ដែលផ្ដាច់ពុទ្ធសាសនាចេញពីនិកាយសាសនាហិណ្ឌូ ដែលដូចគ្នាយ៉ាងខ្លាំងទៅនឹងពុទ្ធសាសនា ។ លក្ខណៈពិសេសដ៏លេចធ្លោនោះ គឺ ការប្រៀនប្រដៅអំពីអនត្តាធម៌ ។

មានពេលខ្លះ ការបង្រៀនអំពីអនត្តាធម៌នេះ គឺជាឱកាសមួយនាំឱ្យមានការច្រឡំបល់ ពីព្រោះ ជាញឹកញាយយើងឆ្ងល់ ថាតើគេអាចបដិសេធអត្តៈយ៉ាងដូចម្ដេចបាន ។ នៅទីបំផុត យើងតែងនិយាយស្ដីថា « ខ្ញុំ (អត្តៈ) កំពុងនិយាយ » ឬ « ខ្ញុំ (អត្តៈ) កំពុងដើរ » ឬថា « ខ្ញុំ (អត្តៈ) មានឈ្មោះយ៉ាងនេះ-យ៉ាងនោះ » ឬក៏ « ខ្ញុំ (អត្តៈ) ជាឪពុក ឬជាកូន របស់មនុស្សនេះ-មនុស្សនោះ » ។ ដូច្នេះ តើយើងអាចបដិសេធតថភាពរបស់ « អត្តៈ » នោះយ៉ាងដូចម្ដេច ? ដើម្បីបំភ្លឺរឿងនេះ ខ្ញុំគិតថា វាមានសារសំខាន់ដើម្បីរំលឹកឡើងវិញថា ការទាត់ចោល « ខ្ញុំ » (អាត្មា) របស់ពុទ្ធសាសនា គឺពុំមែនជាការបដិសេធនូវកំណត់សម្គាល់ដ៏សមស្របនេះ ពោលគឺ ឈ្មោះ « ខ្ញុំ, អញ, អាត្មា ... » ទេ ។ ផ្ទុយទៅវិញ វាជាការបដិសេធមតិ ឬគំនិតដែលថា ឈ្មោះ « ខ្ញុំ, អញ, អាត្មា, .... » នេះ តំណាងឱ្យតថភាពមួយជាសារវន្ត, ជាអចិន្ត្រៃយ៍ ( ឋិតថេរ ) និងឥតប្រែប្រួល ( និច្ចៈ ) ។ កាលណាព្រះពុទ្ធមានបន្ទូលថា កត្តា ( ខន្ធ ) ប្រាំយ៉ាងនៃបទពិសោធន៍ផ្ទាល់ខ្លួនមិនមែនជាអត្តៈទេ, ហើយអត្តៈ ក៏គេរកមិនឃើញនៅក្នុងកត្តា ( ខន្ធ ) ទាំងប្រាំនោះដែរ គឺព្រះអង្គបានសំដៅន័យថា ផ្អែកលើការវិភាគ, ឈ្មោះ « ខ្ញុំ, អញ, អាត្មា,... » នេះ មិនបានឆ្លើយតបទៅនឹងសារជាតិ ឬអង្គធាតុណាមួយទេ ។ ព្រះពុទ្ធទ្រង់បានយកឧទាហរណ៍អំពីរទេះ និងអំពីព្រៃ ដើម្បីពន្យល់នូវទំនាក់ទំនងរវាងស័ព្ទ « ខ្ញុំ, អញ, អាត្មា, ... » ហើយនិងសមាសភាគនៃបទពិសោធន៍ផ្ទាល់ខ្លួន ។ ព្រះពុទ្ធបានពន្យល់ថា ពាក្យរទេះ គ្រាន់តែ

ជាឈ្មោះស្រួលសម្គាល់នូវសមូហភាពនៃផ្នែកទាំងឡាយដែលត្រូវផ្គុំគ្នា នៅក្នុងបែបបទដោយឡែកណាមួយ ។ កង់ទាំងឡាយ ពុំមែនជារទេះទេ ។ ភ្លៅក៏ពុំមែន ហើយតួក៏ពុំមែនដែរ ។ ល ។ ដូចគ្នានេះដែរ ដើមឈើមួយដើម១ ក៏ពុំមែនជាព្រៃ ។ ដើមឈើមួយដើម១មួយចំនួន ក៏ពុំមែនជាព្រៃដែរ ។ ព្រៃមិនអាចបំបែកចេញពីដើមឈើមួយដើម១បានទេ ។ ពាក្យថា ព្រៃ គឺគ្រាន់តែជាឈ្មោះសម្គាល់ការប្រជុំនៃដើមឈើនីមួយ១ ច្រើនដើមប៉ុណ្ណោះ ។ នេះគឺជាទម្ងន់នៃការបដិសេធអត្តៈរបស់ព្រះពុទ្ធ ។ ការបដិសេធរបស់ព្រះពុទ្ធ គឺការបដិសេធជំនឿថាមានអង្គធាតុមួយពិតប្រាកដ, ឯករាជ, អចិន្ត្រៃយ៍ ដែលត្រូវបានតាងដោយស័ព្ទ « ខ្ញុំ, អញ, អាត្មា, .... » ។ អង្គធាតុអចិន្ត្រៃយ៍មួយបែបនេះ ត្រូវតែមានឯករាជភាព, ត្រូវតែមានអធិបតេយ្យនៅក្នុងគន្លងដែលព្រះរាជាជាម្ចាស់លើមនុស្សទាំងអស់នៅជុំវិញព្រះអង្គ ។ អង្គភាពនោះ ត្រូវតែមានលក្ខណៈឋិតថេរ, ឥតប្រែប្រួល និងមិនងាយប្រែប្រួល, ប៉ុន្តែ អង្គធាតុមួយឋិតថេរបែបនេះ, អត្តៈមួយបែបនេះ មិនអាចរកឃើញនៅក្នុងទីណាមួយបានទេ ។

ព្រះពុទ្ធទ្រង់បានអនុវត្តការវិភាគតទៅនេះ ចំពោះរូបកាយ និងចិត្ត ដើម្បីបញ្ជាក់ថា អត្តៈមិនឋិតនៅកន្លែងណាមួយដើម្បីរកឱ្យឃើញ ឬមួយនៅក្នុងសរីរាង្គ ឬមួយនៅក្នុងចិត្ត ។ សរីរាង្គមិនមែនជាអត្តៈទេ ។ ពីព្រោះ ប្រសិនបើសរីរាង្គជាអត្តៈ, អត្តៈនោះត្រូវតែជាអនិច្ចៈ ត្រូវតែឋិតក្រោមការប្រែប្រួល, ពុកផុយ, វិនាស, និងមរណៈ ។ ដូច្នេះ សរីរាង្គមិនអាចជាអត្តៈទេ ។ អត្តៈមិនមែនជាម្ចាស់លើសរីរាង្គទេ, ក្នុងន័យថា ខ្ញុំ, អញ, អាត្មា, ... ជាម្ចាស់រថយន្តមួយ, ឬទូរទស្សន៍មួយ, ពីព្រោះអត្តៈមិនអាចគ្រប់គ្រងត្រួតត្រាលើសរីរាង្គបានទេ ។ សរីរាង្គធ្លាក់ខ្លួនឈឺ, ចេះនឿយហត់ ហើយចាស់គ្រាំគ្រា ផ្ទុយពីបំណងប្រាថ្នារបស់យើង ។ សរីរាង្គមានរាងរៅ ដែលជាញឹកញាប់ មិនស្របតាមសេចក្តីប្រាថ្នាចង់បានរបស់យើង ។ ដូច្នេះ គ្មានចំណុចត្រង់ណាមួយជាអត្តៈ ជាម្ចាស់លើសរីរាង្គទេ ។ អត្តៈមិននៅក្នុងសរីរាង្គទេ ។ ប្រសិន

បើយើងរុករកក្នុងសរីរាង្គរបស់យើងតាំងតែពីលើក្បាលរហូតដល់ចុងជើង យើងមិនឃើញមានកន្លែងត្រង់ណាមួយដែលអត្តៈឋិតនៅទេ ។ អត្តៈមិននៅក្នុងឆ្អឹងទេ ទាំងមិននៅក្នុងឈាម, ទាំងមិននៅក្នុងខួរឆ្អឹង, ទាំងមិននៅក្នុងសក់, ទាំងមិននៅក្នុងទឹកមាត់ស្តោះចោលទេ ។ អត្តៈមិនឃើញមាននៅកន្លែងណាមួយក្នុងសរីរាង្គទេ ។ ដូចគ្នានេះដែរ, ចិត្តមិនមែនជាអត្តៈទេ ។ ចិត្តតែងឋិតក្រោមការប្រែប្រួលជានិច្ច ។ ចិត្តតែងលោតចុះលោតឡើង ដូចសត្វស្វា ។ ចិត្តរីករាយនៅខណៈមួយ ហើយទុក្ខព្រួយនៅខណៈបន្ទាប់ ។ ដូច្នេះ ចិត្តមិនអាចជាអត្តៈបានទេ ពីព្រោះ ចិត្តតែងប្រែប្រួលជាប្រចាំ ។ អត្តៈមិនមែនជាម្ចាស់លើចិត្តទេ ពីព្រោះ ចិត្តប្រែក្លាយជាសប្បាយរីករាយ ឬក្រៀមក្រំ ផ្ទុយពីបំណងប្រាថ្នារបស់យើង ។ ទោះបីយើងដឹងថា គំនិតខ្លះជាកុសល, ហើយគំនិតខ្លះទៀត ជាអកុសល ។ ដូច្នេះ អត្តៈមិនមែនជាម្ចាស់លើចិត្តទេ ពីព្រោះ ចិត្តប្រព្រឹត្តទៅដោយមិនចំណុះអត្តៈ ឡើយ ។ អត្តៈមិននៅក្នុងចិត្តទេ ។ ទោះបីជាយើងស្វែងរកដោយប្រុងប្រយ័ត្នយ៉ាងណាក៏ដោយ នូវអត្ថរស ( the contents ) នៃចិត្តរបស់យើង, ទោះបីយើងស្វែងរកយ៉ាងប្រុងប្រយ័ត្នយ៉ាងណាក៏ដោយ នូវគំនិត អារម្មណ៍ និងមតិរបស់យើង, យើងមិនអាចរកឃើញអត្តៈនៅកន្លែងណាមួយបានទេ ។ មានលំហាត់យ៉ាងសាមញ្ញមួយ ដែលយើងម្នាក់ៗអាចធ្វើបាន ។ យើងទាំងអស់គ្នាអាចអង្គុយដោយស្ងប់ស្ងៀមមួយរយៈពេលខ្លី ហើយផ្ចង់អារម្មណ៍មកក្នុងសរីរាង្គ និងចិត្តរបស់យើង ។ ហើយដោយគ្មានការលើកលែងណាមួយទេ, យើងនឹងឃើញថា យើងមិនអាចរកឃើញកន្លែងណាដែលអត្តៈឋិតនៅក្នុងសរីរាង្គ ឬក្នុងចិត្តទេ ។ សេចក្តីសន្និដ្ឋានឋិតនៅថា អត្តៈ គឺគ្រាន់តែជាឈ្មោះសម្រួលសម្រាប់ហៅសម្ពហភាពនៃកត្តាទាំងឡាយប៉ុណ្ណោះ ។ វាគ្មានអត្តៈទេ, គ្មានព្រលឹងទេ, គ្មានសារជាតិទេ, គ្មានខ្លឹមនៃបទពិសោធន៍ផ្ទាល់ខ្លួនឯណាក្រៅតែពីកត្តាផ្លូវកាយ និងចិត្តនៃបទពិសោធន៍ផ្ទាល់ខ្លួន ដែលប្រែប្រួលជានិច្ច, អាស្រ័យគ្នាទៅវិញទៅមក,

ហើយមិនឋិតថេរ ដូចជា អារម្មណ៍, មតិ, គំនិត, ទម្លាប់ និងអាកប្បកិរិយារបស់យើង ។

ព្រោះហេតុអ្វីបានជាយើងយកចិត្តទុកដាក់បដិសេធគំនិតអំពីអត្តៈ ? តើយើងអាចបានអត្ថប្រយោជន៍យ៉ាងណា ដោយការបដិសេធគំនិតអំពីអត្តៈ ? ក្នុងទីនេះដែរ, យើងអាចទទួលបានអត្ថប្រយោជន៍នៅក្នុងផ្លូវពីរយ៉ាងដ៏សំខាន់ ។ ដំបូងបង្អស់, នៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើងជាកិរិតលោកិយនេះ យើងអាចទទួលបានអត្ថប្រយោជន៍នៅក្នុងហេតុដែលថា យើងក្លាយជាមនុស្សមានគំនិតច្នៃប្រឌិតច្រើនឡើង, កាន់តែគ្មានគំនិតព្រួយកង្វល់ ហើយកាន់តែបើកទូលាយ ។ ដរាបណាយើងនៅតែប្រកាន់ខ្ជាប់នូវអត្តៈ យើងនឹងត្រូវតែការពារខ្លួនយើងជានិច្ច ការពារទ្រព្យសម្បត្តិ, កម្មសិទ្ធិ, កិត្តិយស, មតិយោបល់ ហើយរហូតដល់ពាក្យសំដី របស់យើង ។ ប៉ុន្តែ ពេលណាយើងបោះបង់ចោលជំនឿក្នុងអត្តៈមួយឯករាជ និងអចិន្ត្រៃយ៍នេះ យើងនឹងអាចចុះសម្រុងជាមួយមនុស្សដទៃ និងស្ថានភាពទាំងឡាយដោយគ្មានការភ័យខ្លាច មិនទុកចិត្តគេឡើយ ។ យើងនឹងអាចចុះសម្រុងយ៉ាងងាយដោយឯករាជ ហើយប្រកបដោយការច្នៃប្រឌិត ។ ការយល់ដឹងនូវអត្តៈដោយប្រការនេះ បានជាជំនួយមួយសម្រាប់ការរស់នៅ ។

កាន់តែមានសារសំខាន់ជាងនេះទៀតនោះ ការយល់ដឹងនូវអនត្តាធម៌ គឺជាកូនសោមួយចំពោះការត្រាស់ដឹង ។ ជំនឿក្នុងអត្តៈ គឺមានន័យស្មើគ្នានឹងអវិជ្ជា ហើយអវិជ្ជា គឺជាគ្រឹះដ៏ធំបំផុតនៃកិលេសធម៌ទាំងបី ។ ពេលណាយើងកំណត់សម្គាល់ គិតស្មាន ឬប្រឌិតបង្កើតខ្លួនយើងថាជាអង្គធាតុមួយហើយ យើងបង្កើតបានភ្លាមនូវដំណើរបំបែកក្រុម, គឺការញែកបំបែកខ្លួនយើងចេញពីមនុស្ស និងវត្ថុទាំងឡាយនៅជុំវិញយើង ។ ពេលណាយើងមានមតិបញ្ញត្តិអំពីអត្តៈនេះហើយ យើងតែងមានប្រតិកម្មតបទៅនឹងមនុស្ស និងវត្ថុទាំងឡាយនៅជុំវិញយើង ឬមួយដោយ

មានតម្រេកស្រឡាញ់ ( desire ) ឬមួយដោយមានសេចក្តីស្អប់ខ្ពើម ( Aversion )។ នៅក្នុងន័យនេះ អត្តៈ គឺជាតួអាក្រក់ដ៏ពិតប្រាកដនៅក្នុងរឿងនេះ ។ ដោយមើលឃើញថា អត្តៈ គឺជាប្រភព និងជាហេតុនៃសេចក្តីទុក្ខគ្រប់យ៉ាង និងដោយមើលឃើញថា ការបដិសេធនូវអត្តៈ គឺជាហេតុនៃការបញ្ចប់សេចក្តីទុក្ខ ប្រសើរជាជាងការខិតខំការពារ ឃុំគ្រង និងថែរក្សាអត្តៈ, ព្រោះហេតុអ្វី ក៏យើងមិនខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីបដិសេធ និងលុបបំបាត់នូវគំនិតអំពីអត្តៈនេះ ? ព្រោះហេតុអ្វីក៏យើងមិនទទួលស្គាល់ថា បទពិសោធន៍ផ្ទាល់ខ្លួន គឺដូចជាដើមចេកមួយដើម ឬដូចជាខ្ទឹមបារាំងមួយមើម តែកាលណាយើងបកវាមួយស្រទាប់ម្តងៗ តែកាលណាយើងពិនិត្យមើលវាដោយស្មារតីរិះគន់ និងដោយស្មារតីវិភាគ យើងឃើញថា វាជាវត្ថុទទេគ្មានស្នូលជាសារវន្ត ជាសារជាតិទេ ពោលគឺ វាគ្មានអត្តៈឡើយ ។

កាលណាយើងយល់ថា វត្ថុគ្រប់យ៉ាងសុទ្ធតែមិនឋិតថេរ ( អនិច្ចៈ ) ពោរពេញដោយសេចក្តីទុក្ខ ហើយគ្មានអត្តៈទេ ហើយកាលណា ការយល់ដឹងរបស់យើងនូវសច្ចធម៌ទាំងឡាយនេះ មិនមែនជាការយល់ដឹងតាមផ្លូវបញ្ញា ឬតាមការរៀននៅសាលាសុទ្ធសាធនោះទេ ប៉ុន្តែ តាមរយៈការសិក្សា ការពិចារណា និងការត្រិះរិះ ស៊ីង.ស្មាធិ៍, ហេតុការណ៍នៃអនិច្ចំ ទុក្ខំ និងអនត្តា ប្រែក្លាយជាផ្នែកនៃបទពិសោធន៍ផ្ទាល់របស់យើង ។ តាមរយៈការយល់ដឹងអំពីអនិច្ចំ ទុក្ខំ អនត្តា យើងនឹងបានរំដោះខ្លួនចេញផុតទោសកំហុសជាត្រីះ ដែលឃុំឃាំងយើងនៅក្នុងវដ្តនៃការកើត-ស្លាប់ គឺទោសកំហុសនៃការមើលឃើញវត្ថុទាំងឡាយថាឋិតថេរ ( និច្ចៈ ), ទោសកំហុសនៃការមើលឃើញវត្ថុទាំងឡាយថា ជាទីរីករាយត្រេកត្រអាល និងទោសកំហុសនៃការមើលឃើញវត្ថុទាំងឡាយថាជា អត្តៈ ។ កាលណាភាពភាន់ច្រឡំ ( សម្មោហៈ ) ទាំងនេះត្រូវបានបំបាត់ហើយ បញ្ញាក៏រមែងកើតឡើង ។ បីដូចជា កាលណាអន្ធការភាពត្រូវបានកំចាត់បង់ហើយ ពន្លឺក៏បានរះឡើង ។ ហើយកាលណាបញ្ញាកើតឡើង, គេ

វរំមែងទទួលក្រេបរសនៃសន្តិភាព និងសេរីភាពនៃព្រះនិព្វាន ។

សប្តាហ៍នេះ យើងបានដាក់កំហិតខ្លួនយើងត្រឹមការក្រឡេកមើលបទពិសោធន៍ផ្ទាល់ខ្លួន ទាក់ទងកាយ និងចិត្ត ។ សប្តាហ៍ក្រោយ យើងនឹងពិនិត្យស៊ីជម្រៅទៅក្នុងការវិភាគបទពិសោធន៍ផ្ទាល់ខ្លួនបែបពុទ្ធសាសនា ទាក់ទងនឹងធាតុទាំងឡាយនៃសកលចក្រវាលកាយ និងចិត្តរបស់យើង ។

## XII

## បញ្ចក្ខន្ធ ( ខន្ធទាំងប្រាំ )

## ( The Five Aggregates )

នេះជាសម័យប្រជុំចុងក្រោយ ក្នុងចង្កោមនៃសម័យប្រជុំទាំងដប់ពីរលើក ដែលយើងបានចំណាយពេលជាមួយគ្នា, ហើយនៅក្នុងសម័យប្រជុំចុងក្រោយនេះ យើងនឹងពិនិត្យមើលពាក្យប្រៀនប្រដៅ ស្តីពីខន្ធទាំងប្រាំ ( រូប, វេទនា, សញ្ញា, សង្ខារ និងវិញ្ញាណ ) ។ និយាយមួយបែបទៀត យើងនឹងពិនិត្យមើលការវិភាគបទពិសោធន៍ផ្ទាល់ខ្លួនតាមពុទ្ធសាសនា ឬការវិភាគរបស់ពុទ្ធសាសនា អំពីអត្តភាព ( personality ) ។

ក្នុងរយៈពេលធ្វើឧទ្ទេសកថាចុងក្រោយទាំងស្រុង ខ្ញុំមានឱកាស គឺមានពេលវេលាមួយចំនួន ដើម្បីបញ្ជាក់ចំណុចដែលថា ពុទ្ធវចនៈត្រូវបានគេឃើញថា ទាក់ទងទៅនឹងជីវភាព និងទស្សនៈបច្ចុប្បន្ន ក្នុងវិស័យវិទ្យាសាស្ត្រ, ចិត្តសាស្ត្រជាដើម ។ ក្នុងទិនេះ ចំពោះទំនាក់ទំនងទៅនឹងការវិភាគបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងខន្ធទាំងប្រាំ នេះក៏ជាករណី ( ត្រូវសិក្សា ) ផងដែរ ។ ចិត្តវិទូ និងគ្រូពេទ្យខាងចិត្តរោគ

( psychiatrists ) បច្ចុប្បន្ន បានយកចិត្តទុកដាក់យ៉ាងពិសេសក្នុងការវិភាគនេះ ។ គេបានរហូតដល់ផ្តល់យោបល់ថា នៅក្នុងគម្ពីរអភិធម្ម និងនៅក្នុងការវិភាគបទពិ-សោធន៍ផ្ទាល់ខ្លួននៅក្នុងបញ្ចក្ខន្ធ, យើងមានសមមូលខាងចិត្តវិជ្ជាទៅនឹងតារាងធាតុទាំងឡាយ ដែលវិទ្យាសាស្ត្រសម័យថ្មីបានរកឃើញ ។ អ្វីដែលយើងមាននៅក្នុងការវិភាគរបស់ពុទ្ធសាសនាលើបទពិសោធន៍ផ្ទាល់ខ្លួន គឺជាបញ្ជីសារពើភ័ណ្ឌ និងការវាយតម្លៃមួយដ៏ម៉ត់ចត់បំផុត អំពីធាតុទាំងឡាយនៃបទពិសោធន៍របស់យើង ។

អ្វីដែលយើងនឹងធ្វើថ្ងៃនេះ គឺជាការបន្ត និងការសើរើតសំរាំងជាមូលដ្ឋានអំពីអ្វីដែលយើងបានធ្វើនៅចុងនៃឧទ្ទេសកថា កាលពីចុងសប្តាហ៍កន្លងទៅ ។ កាលនោះ យើងបានចំណាយពេលទៅលើការប្រៀនប្រដៅ ( ព្រះធម៌ ) ស្តីពីអនិច្ចំ, ទុក្ខំ និងអនត្តា ។ នៅពេលពិនិត្យមើលការប្រៀនប្រដៅ ស្តីពីអនត្តា យើងបានពន្យល់យ៉ាងខ្លី ថាតើការវិភាគអំពីបទពិសោធន៍ផ្ទាល់ខ្លួន អាចត្រូវបានគេអនុវត្តទៅតាមខ្សែបន្ទាត់ពីរយ៉ាង ពោលគឺ ទាក់ទងទៅនឹងកាយ និងទាក់ទងទៅនឹងចិត្តយ៉ាងដូចម្តេច ។ លោក-អ្នកនឹងនឹកឃើញថា យើងបានពិនិត្យមើលកាយ និងចិត្ត ដើម្បីមើលឱ្យឃើញ ថាតើនៅក្នុងកាយឬក្នុងចិត្ត យើងអាចរកឃើញទីតាំងនៃអត្តៈ រួចហើយយើងបានឃើញថា អត្តៈ មិនឃើញមាននៅក្នុងកាយ ឬចិត្តទេ ។ យើងបានសន្និដ្ឋានថាឈ្មោះ « អត្តៈ » គឺគ្រាន់តែជាពាក្យសម្រួល សម្រាប់សម្គាល់ចង្កោមនៃកត្តាទាំងឡាយខាងកាយ និងចិត្តប៉ុណ្ណោះ ក្នុងបែបដូចគ្នានឹងឈ្មោះ « ព្រៃ » ដែលជាពាក្យសម្រួលសម្រាប់សម្គាល់សមូហភាពមួយនៃដើមឈើទាំងឡាយដូច្នោះ ។ សប្តាហ៍នេះ យើងនឹងបន្តការវិភាគរបស់យើងវែងឆ្ងាយបន្តិចទៀត, ជាជាងការគ្រាន់តែពិនិត្យមើលបទពិសោធន៍ផ្ទាល់ខ្លួនយ៉ាងសាមញ្ញ ទាក់ទងទៅនឹងកាយ និងចិត្ត, យើងនឹងធ្វើវិភាគបទពិសោធន៍ផ្ទាល់ខ្លួនទាក់ទងនឹងបញ្ចក្ខន្ធ ។

ដំបូង ចូរយើងពិនិត្យមើល រូបក្ខន្ធ ។ រូបក្ខន្ធ ត្រូវគ្នានឹងអ្វីដែលយើងនឹង

ឱ្យឈ្មោះថា កត្តាសម្ភារៈ ឬកត្តារូបកាយ ។ វារួមបញ្ចូលមិនមែនគ្រាន់តែរូបកាយផ្ទាល់របស់យើងប៉ុណ្ណោះទេ, ប៉ុន្តែ រួមទាំងវត្ថុសម្ភារៈទាំងឡាយផងដែរ ដែលនៅជុំវិញយើង ដូចជា ព្រះធរណី, មហាសាគរ, ដើមឈើ, អគារទាំងឡាយ ជាដើម ។ និយាយដោយចំ រូបក្ខន្ធរួមមាន ឥន្ទ្រិយាយតនៈប្រាំ និងឥន្ទ្រិយរូបារម្មណ៍របស់ខ្លួននីមួយៗ ( the corresponding physical objects of the sense organs ) ។ អាយតនៈ និងរូបារម្មណ៍ទាំងនោះ គឺចក្ខុ (ភ្នែក) និងវត្ថុមើលឃើញ, សោតៈ (ត្រចៀក) និងសំឡេង - សូរ, ឃានៈ (ច្រមុះ) និងក្លិន, ជិវ្ហៈ (អណ្ដាត) និងរសជាតិ, ផស្សៈ (ស្បែក) និងវត្ថុប៉ះពាល់ត្រូវ ។

ប៉ុន្តែ រូបធាតុ ( physical elements ) តែខ្លួនឯងប៉ុណ្ណោះ មិនទាន់គ្រប់គ្រាន់ដើម្បីបង្កើតចេញជាបទពិសោធន៍ទេ ។ ការប៉ះពាល់ត្រូវយ៉ាងធម្មតា រវាងភ្នែក និងវត្ថុមើលឃើញ ឬរវាងត្រចៀក និងសូរ - សំឡេង មិនអាចបាុចលទ្ធផលជាបទពិសោធន៍បានដោយគ្មានវិញ្ញាណ (consciousness) នោះទេ ។ ភ្នែកអាចឋិតជាប់ជាមួយវត្ថុមើលឃើញ ដោយគ្មានកំណត់ពេល ដោយគ្មានបង្កើតចេញនូវបទពិសោធន៍ ។ ត្រចៀកក៏ដូច្នោះដែរ អាចឋិតនៅផ្ទាល់ចំពោះសូរ - សំឡេង ដោយគ្មានកំណត់ពេល ដោយគ្មានការផលិតបាននូវបទពិសោធន៍ ។ ទាល់តែមានសហ-វត្តមាននៃវិញ្ញាណនៅជាមួយផង ទើបអាយតៈ ( the sense organ ) ហើយនិងកម្មវត្ថុ ( រូបារម្មណ៍ ) របស់អាយតនៈ ផលិតចេញបាននូវបទពិសោធន៍ ។ និយាយម្យ៉ាងទៀត, គឺកាលណាភ្នែក ( ចក្ខុ ) និងកម្មវត្ថុមើលឃើញ ហើយនិងវិញ្ញាណរួមជាមួយគ្នា ទើបបទពិសោធន៍របស់កម្មវត្ថុមើលឃើញ ត្រូវផលិតឡើងបាន ។ ហេតុនេះ វិញ្ញាណ គឺជាធាតុដ៏ចាំបាច់នៅក្នុងការផលិត ឬបង្កើតចេញនូវបទពិសោធន៍ ។

មុនយើងបន្តការពិចារណារបស់យើងអំពីកត្តាផ្លូវចិត្ត ឬកត្តាចេតសិក នៃ

បទពិសោធផ្ទាល់ខ្លួន ខ្ញុំសូមនិយាយយ៉ាងសង្ខេបអំពីអត្ថិភាពនៃអាយតៈមួយផ្សេងទៀត ហើយនិងកម្មវត្ថុរបស់វា, ហើយនៅទីនេះ ខ្ញុំនិយាយអំពីឥន្ទ្រិយទីប្រាំមួយ គឺចិត្ត ។ នេះគឺជាការបន្ថែមលើឥន្ទ្រិយាយតនៈប្រាំ - ចក្ខុ, សោតៈ, ឃានៈ, ជិវ្ហៈ និងផស្សៈ ។ បើដូចជាឥន្ទ្រិយាយតនៈទាំងប្រាំ មានរូបារម្មណ៍របស់ខ្លួននីមួយៗផ្ទាល់, ចិត្តក៏មានអារម្មណ៍របស់ខ្លួន ( its objects ) ផ្ទាល់ គឺមតិអារម្មណ៍ ឬគំនិត, ឬធម្មារម្មណ៍ ( properties ) ។ ហើយដូចនៅក្នុងករណីឥន្ទ្រិយាយតនៈដែរ, វិញ្ញាណ (consciousness) តែងមានវត្តមានដើម្បីភ្ជាប់ចិត្ត និងអារម្មណ៍របស់ចិត្តជាមួយគ្នា ទើបអាចផលិតចេញបាននូវបទពិសោធន៍ ។

ឥឡូវ ចូរយើងពិនិត្យមើលកត្តាចេតសិកនៃបទពិសោធន៍ ( the mental factors of experience ) ហើយចូរយើងមើលឱ្យឃើញ ថាតើយើងយល់ដឹងបានថា វិញ្ញាណប្រែក្លាយកត្តាសារីរិកនៃបទពិសោធន៍ ( the physical factors of experience ) ទៅជាបទពិសោធន៍សសញ្ញីផ្ទាល់ខ្លួន ( personal conscious experience ) យ៉ាងដូចម្តេច ។ ដំបូងបង្អស់, យើងត្រូវរំលឹកថាវិញ្ញាណ គឺជាសេចក្តីដឹងសុទ្ធសាធ, ឬជាវេទយិតភាពសុទ្ធសាធ ចំពោះកម្មវត្ថុណាមួយ ( mere awareness, or mere sensitivity to an object ) ។ កាលណាកត្តាសារីរិកនៃបទពិសោធន៍, យកជាឧទាហរណ៍ គឺភ្នែក ( ចក្ខុ ) និងវត្ថុដែលមើលឃើញ, បានប៉ះទង្គិចគ្នាហើយ, ហើយកាលណា វិញ្ញាណក៏បានមកចូលរួមផងដែរ ជាមួយកត្តាសារីរិកនៃបទពិសោធន៍, ចក្ខុវិញ្ញាណកើតឡើង ។ នេះគឺជាសេចក្តីដឹងដ៏សុទ្ធសាធនៃវត្ថុដែលមើលឃើញ, មិនមែនជាអ្វីមួយ ដូចអ្វីដែលយើងអាចហៅថា បទពិសោធន៍ផ្ទាល់ខ្លួននោះទេ ។ បែបបទ ឬមាតិា ដែលបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងត្រូវកើតចេញបាន គឺតាមរយៈការប្រព្រឹត្តទៅនៃកត្តាចេតសិកនៃបទពិសោធន៍សំខាន់ៗបីផ្សេងទៀត ហើយកត្តាចេតសិកទាំងបីនោះគឺ : វេទនាខន្ធ

( the aggregate of feeling ) សញ្ញាខន្ធ ( the aggregate of perception ) និងសង្ខារក្ខន្ធ ( the aggregate of mental formation or volition ) ។ មុខងារនៃខន្ធទាំងបីនេះ សម្រាប់ធ្វើឱ្យសេចក្ដីដឹងដ៏សុទ្ធសាធអំពីវត្ថុនេះ ប្រែក្លាយទៅជាបទពិសោធន៍ផ្ទាល់ខ្លួន ។

វេទនាខន្ធ ( the aggregate of feeling or sensation ) មានបីប្រភេទគឺ - សោមនស្ស, ទោមនស្ស, និងឧបេក្ខា ។ កាលណា វត្ថុណានីមួយត្រូវបានពិសោធន៍ហើយ , បទពិសោធន៍នោះតែងផ្ដិតជាប់សភាវៈនៃចិត្តវេគណាមួយ ក្នុងបណ្ដាចិត្តសភាវៈទាំងនេះ : ចិត្តសភាវៈសោមនស្ស, ឬចិត្តសភាវៈទោមនស្ស ឬក៏ចិត្តសភាវៈឧបេក្ខា ។

បន្ទាប់មក ចូរយើងពិនិត្យមើល សញ្ញាខន្ធ ។ នេះគឺជាខន្ធដែលមនុស្សជាច្រើនពិបាកយល់ដឹងបាន ។ កាលណាយើងនិយាយអំពី សញ្ញា ( perception ) យើងតែងនឹកឃើញនូវសកម្មភាពនៃការទទួលស្គាល់ ឬ សកម្មភាពអត្តសញ្ញាណកម្ម ( activity of identification ) ។ ក្នុងន័យមួយ, យើងកំពុងនិយាយអំពីការផ្ដល់ឈ្មោះមួយទៅឱ្យវត្ថុនៃបទពិសោធន៍ ។ មុខងារនៃសញ្ញា គឺដើម្បីធ្វើឱ្យបទពិសោធន៍មិនជាក់លាក់មួយឱ្យក្លាយទៅជាបទពិសោធន៍ដែលទទួលស្គាល់បាន និងធ្វើអត្តសញ្ញាណកម្មបាន ។ ក្នុងទីនេះ យើងកំពុងនិយាយអំពីការបង្កបង្កើតមតិបញ្ញត្តិមួយអំពីវត្ថុដោយឡែកណាមួយ ។ ឧទាហរណ៍ ជាមួយវេទនា (feeling) ដែលនៅក្នុងនេះ យើងមានធាតុចិត្តវេគមួយ ក្នុងន័យជា សោមនស្ស ទោមនស្ស ឬឧបេក្ខា ; ជាមួយសញ្ញា ( perception ) យើងមានធាតុមតិបញ្ញត្តិមួយ ក្នុងន័យបញ្ចូលមតិឬគំនិតមួយជាក់លក្ខណ៍ ច្បាស់លាស់ អំពីវត្ថុនៃបទពិសោធន៍ ។

ទៅទីបំផុត, មានសង្ខារក្ខន្ធ ។ ខន្ធនេះអាចត្រូវបានគេពិពណ៌នាថាជាចម្លើយកើតឡើងតបទៅនឹងវត្ថុនៃបទពិសោធន៍ ។ នៅក្នុងន័យនេះ វាវំលែកអត្ត-

ន័យអំពីទម្លាប់ផងដែរ ។ យើងបានចំណាយពេលមួយចំនួន ពិភាក្សាសមាសភាគនៃសង្ខារ ក្នុងកាលដែលយើងបានពិចារណាសមាសភាគទាំងដប់ពីរនៃបដិច្ច-សមុប្បាទ ។ លោក-អ្នក នឹងនៅចាំបានថា នាឱកាសនោះ យើងបានរៀបរាប់ពីសង្ខារថាជាអារម្មណ៍ ឬហទយគតភាព ( the impression ) បង្កើតឡើងដោយអំពើពីកាលមុន, ដ៏ជាថាមភាពទម្លាប់បង្គរទុកតាំងពីជាតិមុនៗច្រើនអនេក ។ ក្នុងទីនេះ, ក្នុងឋានៈជាខន្ធមួយ ក្នុងចំណោមខន្ធទាំងប្រាំផងដែរ, សង្ខារក្ខន្ធដើរតួដូចគ្នា ។ ប៉ុន្តែ សង្ខារក្ខន្ធនេះ មិនត្រឹមតែមានតម្លៃអចល ( នឹងថ្កល់ ) ប៉ុណ្ណោះទេ វាក៏មានតម្លៃវេគយុត្ត ( a dynamic value ) ផងដែរ ពីព្រោះ បីដូចជាប្រតិកម្មទាំងឡាយរបស់យើងត្រូវបានកកើតឡើងដោយអំពើពីមុនៗ, ឯចម្លើយតបរបស់យើងនៅក្នុងពេលនេះ ក៏អាងហេតុផល និងតម្រង់ទៅក្នុងមាគ៌ាដោយឡែកមួយ ដោយសង្ខារដូចគ្នាដែរ ។ ដោយហេតុនេះ សង្ខារមានទំហំសីលធម៌ ក៏ដូចគ្នានឹងសញ្ញាមានទំហំមតិបញ្ញត្តិ ( a conceptual dimension ) ហើយវេទនាមានទំហំចិត្តវេគ ( an emotional dimension ) ដូច្នោះដែរ ។ លោក-អ្នក នឹងកត់សំគាល់ថា ខ្ញុំប្រើពាក្យ « mental formation » (សង្ខារ ?) និង « volition » ( ចេតសិក ) ជាមួយគ្នា ។ នេះក៏ព្រោះតែពាក្យនិមួយៗ តាងមួយភាគពីរ ( 1/2 ) របស់អត្ថន័យនៃសង្ខារ - mental formation តាងន័យពាក់កណ្តាលដែលឆ្លងមកពីអតីតៈ, ហើយ volition តាងន័យពាក់កណ្តាលដែលកំពុងប្រព្រឹត្តទៅក្នុងកាលឥឡូវនេះ ។ ដូច្នេះ សង្ខារប្រព្រឹត្តទៅដើម្បីកំណត់ចម្លើយតបរបស់យើងទៅនឹងវត្ថុទាំងឡាយនៃបទពិសោធន៍ ហើយចម្លើយតបទាំងនោះមានផលវិបាកខាងសីលធម៌ ក្នុងន័យជាកុសល, អកុសល ឬអព្យាកតៈ ។

ឥឡូវ យើងអាចមើលឃើញ ថាតើកត្តាកាយ និងចិត្តនៃបទពិសោធន៍ប្រព្រឹត្តទៅរួមគ្នា ដើម្បីបង្កើតចេញនូវបទពិសោធន៍ផ្ទាល់ខ្លួនយ៉ាងណា ។ ដើម្បី

ពន្យល់ឱ្យច្បាស់ជាងបន្តិចទៀត, ចូរយើងលើកយកជំនួយពីឧទាហរណ៍ជាក់ស្តែងមួយគូ ។ យ៉ាងណាមិញ, ក្រោយពេលចប់ឧទ្ទេកថាក្នុងថ្ងៃនេះ, លោក-អ្នក សំរេចចិត្តធ្វើដំណើរកំសាន្តនៅក្នុងឧទ្យាន ។ ក្នុងពេលលោក-អ្នក កំពុងដើរក្នុងឧទ្យាន, លោក-អ្នក ចោលភ្នែកទៅប៉ះវត្ថុមើលឃើញមួយ ។ នៅពេលអារម្មណ៍របស់លោក-អ្នក កំពុងផ្តោតទៅលើវត្ថុមើលឃើញនោះ, វិញ្ញាណរបស់លោក-អ្នក បានចាប់ភ្លឹកលើវត្ថុមើលឃើញ ដែលមិនទាន់បានកំណត់ច្បាស់នៅឡើយ ។ សញ្ញាខន្ធរបស់លោក-អ្នក នឹងធ្វើអត្តសញ្ញាណកម្មថា វត្ថុមើលឃើញនោះ យកជាឧទាហរណ៍, គឺជាសត្វពស់មួយ ។ ពេលណារឿងនោះកើតឡើងហើយ, លោក-អ្នក នឹងឆ្លើយតបចំពោះវត្ថុមើលឃើញនោះ ដោយវេទនាខន្ធ គឺវេទនា ( feeling ) នៃសេចក្តីទោមនស្ស ឬនិយាយឱ្យចំតែម្តងទៅ គឺវេទនានៃការភ័យខ្លាច ។ នៅទីបំផុត, លោក-អ្នក នឹងធ្វើប្រតិកម្មចំពោះវត្ថុមើលឃើញនោះដោយសង្ខារក្ខន្ធ ( the aggregate of mental formation or volition ) ជាមួយនឹងអំពើប្រកបដោយបំណងប្រហែលចង់រត់ចេញឱ្យឆ្ងាយ ឬប្រហែលរើសយកថ្មមួយដុំ ( ទុកគប់ពស់ ) ។ ក្នុងរាល់សកម្មភាពប្រចាំថ្ងៃរបស់យើង, យើងឃើញថា តើខន្ធទាំងប្រាំធ្វើសកម្មភាពរួមគ្នា ដើម្បីបង្កើតចេញនូវបទពិសោធន៍ផ្ទាល់ខ្លួនយ៉ាងណាហើយ ។ ជាឧទាហរណ៍, នៅខណៈនេះតែម្តង, វាមានការប៉ះទង្គិចរវាងធាតុពីរនៃរូបក្ខន្ធ - សូរសំឡេងរបស់ខ្ញុំ និងត្រចៀករបស់លោក-អ្នក ។ វិញ្ញាណរបស់លោក-អ្នក ប្រែក្លាយជាដឹងនូវសូរសំឡេងរបស់ខ្ញុំ ។ សញ្ញាខន្ធរបស់លោក-អ្នក ធ្វើអត្តសញ្ញាណកម្ម នូវពាក្យទាំងឡាយដែលខ្ញុំកំពុងនិយាយ ។ វេទនាខន្ធរបស់លោក-អ្នក ឆ្លើយតបដោយចម្លើយចិត្តវេត - សោមនស្ស, ទោមនស្ស ឬ ឧបេក្ខា ។ សង្ខារក្ខន្ធរបស់លោក-អ្នក ឆ្លើយតបដោយប្រតិកម្មកើតមានជាស្វ័យប្រវត្តិ - អង្គុយដោយយកចិត្តទុកដាក់, គំនិតរវើរវាយ, ឬស្ងាប ។ យើងអាចវិភាគបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងទាំង

អស់បានក្នុងទំនាក់ទំនងជាមួយបញ្ចក្ខន្ធ ។

មានចំណុចមួយដែលត្រូវរំលឹកឡើងវិញ ទាក់ទងទៅនឹងធម្មជាតិនៃបញ្ចក្ខន្ធ, ហើយចំណុចនោះ គឺថា ខន្ធនីមួយៗ និងខន្ធទាំងអស់ តែងឋិតក្នុងការផ្លាស់ប្តូរជាប្រចាំ ។ ធាតុទាំងឡាយដែលកត្តិជារូបក្ខន្ធ គឺមិនឋិតថេរ ហើយស្ថិតក្នុងស្ថានភាពប្រែប្រួលជាប្រចាំ ។ យើងអាចឆ្លើយតបថ្ងៃនេះ ចំពោះស្ថានភាពពិសេសណាមួយដោយមានវេទនារម្មណ៍សោមនស្ស ។ ថ្ងៃស្អែក យើងអាចឆ្លើយតបចំពោះស្ថានភាពដដែល ដោយមានវេទនារម្មណ៍ទោមនស្ស ។ ថ្ងៃនេះ យើងអាចមើលដឹងវត្ថុមួយក្នុងបែបបទមួយដោយឡែក ។ នៅពេលក្រោយបន្តិចមក, ក្រោមកាលៈទេសៈផ្សេងគ្នា សញ្ញា ( ការយល់ដឹង ) របស់យើងនឹងប្រែប្រួល ។ នៅពេលព្រលប់ យើងមើលឃើញខ្សែពួរ សម្គាល់ថាជាពស់ ។ នៅពេលពន្លឺភ្លើងពិលផ្តោតត្រង់ទៅលើវត្ថុនោះ យើងមើលស្គាល់វត្ថុនោះជាខ្សែពួរ ។ ដូច្នេះ សញ្ញា ( perceptions ) របស់យើងក៏ដូចជាវេទនារបស់យើង (our feelings) ហើយក៏ដូចវត្ថុសម្ភារៈនៃបទពិសោធន៍របស់យើងដែរ តែងប្រែប្រួល និងមិនឋិតថេរទេ ។ ដូច្នេះទៀត, សង្ខាររបស់យើង ( our mental formation ) តែងមិនឋិតថេរ ហើយប្រែប្រួលជានិច្ច ។ យើងផ្លាស់ប្តូរទម្លាប់របស់យើងបាន ។ យើងអាចរៀនធ្វើចិត្តឱ្យសប្បុរស និងមានមេត្តា ។ យើងអាចបណ្តុះអាកប្បកិរិយាលះបង់ ( បរិច្ចាគ ) និង ឧបេក្ខា . ល . និង . ល . ។ វិញ្ញាណក៏មិនឋិតថេរដែរ ហើយតែងប្រែប្រួលជាប្រចាំ ។ វិញ្ញាណកើតមានឡើងដោយអាស្រ័យមានវត្ថុមួយ និងអាយតនៈ ។ វិញ្ញាណមិនអាចកើតមានដោយឯករាជ្យទេ ។ ដូចយើងបានឃើញរួចហើយ កត្តាកាយ និងចិត្តទាំងអស់នៃបទពិសោធន៍របស់យើង ដូចជាសរីរាង្គរបស់យើង, វត្ថុសម្ភារៈនៅជុំវិញយើង, ចិត្តរបស់យើង, និងគំនិតរបស់យើង គឺជាសភាវៈមិនឋិតថេរ ហើយប្រែប្រួលជាប្រចាំ ខន្ធទាំងអស់នេះប្រែប្រួលជាប្រចាំ និងមិនឋិតថេរ ។ ខន្ធទាំងអស់នោះ ជា

អភិក្រម ( ដំណើរប្រព្រឹត្តទៅ ) មិនមែនជាវត្ថុទេ ។ ខន្ធទាំងអស់នោះ ជាវេគយុត្ត ( dynamic ) មិនមែនអចលទេ ( not static ) ។

តើមានប្រយោជន៍អ្វីចំពោះការវិភាគបទពិសោធន៍ផ្ទាល់ខ្លួននេះ ដោយប្រៀបផ្ទឹមនឹងបញ្ចក្ខន្ធ ? តើមានប្រយោជន៍អ្វីចំពោះការបង្រួញឯកភាពជាក់ស្តែងនៃបទពិសោធន៍ផ្ទាល់ខ្លួននេះ ទៅជាធាតុផ្សេងៗនៃរូប, វេទនា, សញ្ញា, សង្ខារ និងវិញ្ញាណ ? គោលបំណងនៃការវិភាគនេះ គឺដើម្បីបង្កើតបញ្ញាអំពីអនត្តៈ ។ អ្វីដែលយើងប្រាថ្នាសម្រេចឱ្យបាន គឺដើម្បីមកឱ្យបានដល់ផ្លូវមួយនៃការពិសោធន៍ពិភពលោក ដែលមិនកសាងឡើងនៅលើ ឬនៅជុំវិញគំនិតអំពីអត្តៈ ។ យើងចង់ឃើញបទពិសោធន៍ផ្ទាល់ខ្លួនក្នុងឋានៈជាអភិក្រម, ក្នុងឋានៈជាដំណើរប្រព្រឹត្តទៅមិនផ្ទាល់ខ្លួន ( impersonal functions ) ជាជាងក្នុងឋានៈជាអត្តៈមួយ ហើយនិងជាអ្វីដែលមានឥទ្ធិពលទៅលើអត្តៈ ពីព្រោះ នេះនឹងបង្កើតឡើងនូវឥរិយាបថមួយ ជាឧបេក្ខា, ជាឥរិយាបថមួយដែលនឹងជួយយើងជំនះអារម្មណ៍ច្របូកច្របល់នៃសេចក្តីសង្ឃឹម និងសេចក្តីភ័យខ្លាច ។ យើងសង្ឃឹមចង់បានសេចក្តីសុខ, យើងខ្លាចរអាសេចក្តីឈឺចាប់, យើងភ័យខ្លាចការបាត់បង់ ។ យើងសង្ឃឹមចង់បានកិត្តិយស, យើងភ័យខ្លាចមានទុយិស ។ យើងរស់នៅក្នុងស្ថានភាពផ្លាស់ប្តូររវាងសេចក្តីសង្ឃឹម និងភ័យខ្លាច ។ យើងពិសោធសេចក្តីសង្ឃឹម និងសេចក្តីភ័យខ្លាចទាំងឡាយនេះ ពីព្រោះ យើងយល់សេចក្តីសុខ និងសេចក្តីឈឺចាប់ . ល . ក្នុងឋានៈជាអត្តៈ ។ យើងយល់វាជាសេចក្តីសុខ និងសេចក្តីឈឺចាប់ផ្ទាល់ខ្លួន, ជាសេចក្តីសរសើរ និងសេចក្តីបន្ទោសផ្ទាល់ខ្លួន . ល . ។ ប៉ុន្តែ ពេលណាយើងយល់វាក្នុងឋានៈជាអភិក្រមទាំងឡាយមិនផ្ទាល់ខ្លួន ( អនត្តៈ ) ហើយពេលណាតាមរយៈការយល់ដឹងនេះ យើងបន្សាត់បង់នូវគំនិតអំពីអត្តៈបាន, យើងអាចជំនះលើសេចក្តីសង្ឃឹម និងសេចក្តីភ័យខ្លាចបាន ។ យើងអាចសម្លឹងមើលសេចក្តីសុខ និងសេចក្តីឈឺចាប់, សេចក្តីសរសើរ

និងសេចក្ដីនិន្ទា និងអ្វីៗដទៃទៀតដោយឧបេក្ខា , ដោយចិត្តស្មើ, ហើយបន្ទាប់មក យើងនឹងមិនឋិតនៅក្រោមអតុល្យភាពនៃការប្រែប្រួល រវាងសេចក្ដីសង្ឃឹម និង សេចក្ដីភ័យខ្លាចទៀតឡើយ ។

*

* *

## សេចក្ដីសន្និដ្ឋាន

ខ្ញុំសូមចំណាយពេលបន្តិច ទុកដូចជាសេចក្ដីសន្និដ្ឋាន ដើម្បីឆ្លុះបញ្ចាំង ទៅលើអ្វីដែលយើងបានធ្វើប៉ុន្មានសប្ដាហ៍កន្លងមក ហើយភ្ជាប់វាទៅនឹងអ្វីដែល យើងអាចធ្វើក្នុងពេលនេះ និងក្នុងពេលអនាគត ។

ព្រះធម៌របស់ព្រះពុទ្ធទូលំទូលាយពេកណាស់ ហើយមានគម្ពីរភាពក្រៃ លែង ។ តាមការណ៍ពិត ពេលប៉ុន្មានសប្ដាហ៍កន្លងទៅ យើងគ្រាន់តែបានពិនិត្យមើល ច្បោលៗ នូវព្រះធម៌ជាគ្រឹះរបស់ព្រះពុទ្ធមួយចំនួនប៉ុណ្ណោះ, ហើយការពិនិត្យមើល នេះទៀត គ្រាន់តែសើរៗផងដែរ ។ ប៉ុន្តែយើងអាចដឹងថា អ្វីដែលយើងបានសិក្សា មកក៏មានច្រើន, ហើយលោក-អ្នក មានអារម្មណ៍ថា គេពុំអាចប្រតិបត្តិតាមអ្វីទាំង អស់នោះ ដែលយើងបានសិក្សាទេ ។ តាមការណ៍ពិត, គេនិយាយថា វាជាការពិបាក សូម្បីសម្រាប់បព្វជិតរស់នៅដាច់ពីគេឯងដើម្បីប្រតិបត្តិតាមព្រះធម៌ជាគ្រឹះទាំងអស់ របស់ព្រះពុទ្ធក៏ដោយ ។ មិនតិចតួចទេ ដែលវាមានការពិបាកសម្រាប់ជនជាគ្រហស្ថ ទាំងប្រុស ទាំងស្រី ដូចយើងនេះ ដែលមានបន្ទុកទទួលខុសត្រូវផ្លូវលោក យ៉ាង

ច្រើន ។ ប៉ុន្តែថា ប្រសិនបើមនុស្សម្នាក់ សំរេចជោគជ័យក្នុងការអប់រំបន្ទុំចិត្តដោយស្មោះស្ម័គ្រ ហើយប្រតិបត្តិតាម សូម្បីតែធម៌បន្តិចបន្តួច ក្នុងចំណោមព្រះធម៌ ដ៏ច្រើនរបស់ព្រះពុទ្ធ ក៏បន្ទាប់មក គេនឹងបានសំរេចជោគជ័យក្នុងការធ្វើឱ្យជីវិតនេះកាន់តែមានន័យដែរ ។ គេនឹងប្រាថ្នាក្នុងចិត្តថា ក្នុងអនាគត គេនឹងជួបប្រទះតែនឹងកាលៈទេសៈដ៏ល្អទៀត អនុគ្រោះដល់ការប្រតិបត្តិព្រះធម៌ និងដល់ការសំរេចបាននូវវិមុត្តិជាយថាហេតុ ។

មនុស្សម្នាក់ៗ អាចសំរេចគោលដៅដ៏ខ្ពស់បំផុតក្នុងពុទ្ធសាសនាបាន ទោះជាគ្រហស្ថក្តី ជាបព្វជិតក្តី ។ អ្វីទាំងអស់ដែលយើងត្រូវការធ្វើ គឺតាំងសេចក្តីព្យាយាមដ៏ស្មោះស ដើម្បីដើរតាមមាគ៌ាដ៏ប្រសើរប្រាំបីយ៉ាង ( អរិយដ្ឋង្គិកមគ្គ ) ។ គេនិយាយថា អ្នកទាំងឡាយដែលបានរកឃើញសច្ចធម៌ ដូចជា ព្រះសាក្យមុនីសម្មា-សម្ពុទ្ធ និងសាវ័កសំខាន់ៗរបស់ព្រះអង្គ មិនមែនចេះតែធ្វើព្រាវៗទេ ។ លោក-អ្នកទាំងឡាយនោះ មិនបានធ្លាក់ចុះពីលើមេឃដូចជាទឹកភ្លៀងទេ ហើយក៏មិនមែនផុសចេញពីព្រះធរណីដូចជាធញ្ញជាតិ ( grain ) ដែរ ។ ព្រះពុទ្ធ និងសាវ័កទាំងឡាយរបស់ព្រះអង្គពីមុនមក ក៏ជាសត្វធម្មតា ( ordinary sentient beings ) ដូចលោក-អ្នករាល់គ្នា និងខ្ញុំដែរ ។ ពីមុន លោកទាំងឡាយនោះ ក៏រងការឈឺចាប់ដោយមន្ទិលសៅហ្មងនៃចិត្ត, កាមៈ, ព្យាបាទៈ និងអវិជ្ជា ។ គឺតាមរយៈការសេពគប់ព្រះធម៌តាមរយៈការធ្វើឱ្យវាចា និងអំពើបរិសុទ្ធ, តាមរយៈការធ្វើឱ្យចិត្តរីកចំរើន, និងតាមរយៈការចាប់យកបានបញ្ញា ទើបលោកទាំងឡាយនោះបានប្រែក្លាយទៅជាសត្វ បានរំដោះ និងភ្លឺស្វាង មានសមត្ថភាពប្រៀនប្រដៅ និង ជួយអ្នកឯទៀតឱ្យរកឃើញសច្ចធម៌ ។ ដោយហេតុនេះ គេគ្មានមន្ទិលសង្ស័យទេថា ប្រសិនបើយើងធ្វើខ្លួនយើងតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, យើងក៏អាចចាប់យកគោលដៅចុងក្រោយបំផុតរបស់ព្រះពុទ្ធសាសនាបានដែរ ។

វាគ្មានប្រយោជន៍អ្វី ដោយគ្រាន់តែស្តាប់ព្រះធម៌ ឬអានព្រះធម៌ ដោយសុទ្ធសាធនោះទេ ។ ដូចគ្នាដែរ វាគ្មានប្រយោជន៍អ្វី ដោយគ្រាន់តែសរសេរអត្ថបទអំពីព្រះធម៌ឬទេសនាអំពីព្រះធម៌ ប្រសិនបើយើងមិនប្រតិបត្តិតាមព្រះធម៌នោះទេ ។ គេបាននិយាយថា អ្នកទាំងឡាយនោះក្នុងចំណោមយើងនេះ ដែលហៅខ្លួនឯងថាជាពុទ្ធសាសនិក អាចទទួលបានអត្ថប្រយោជន៍ដោយការស្តាប់ស្ទង់ម្តងម្កាល ។ ប្រសិនបើយើងឃើញថា កន្លងទៅប៉ុន្មានឆ្នាំ ការប្រតិបត្តិព្រះធម៌របស់ព្រះពុទ្ធរបស់យើង បាននាំមកនូវការកែប្រែដ៏តិចតួចណាមួយក្នុងគុណភាពនៃបទពិសោធន៍របស់យើង ( ហើយវានឹងជាការកែប្រែដ៏តិចតួចមួយ ), បន្ទាប់មក យើងនឹងដឹងថាព្រះធម៌បានជះឥទ្ធិពលខ្លះហើយ ។ ប្រសិនបើយើងទាំងអស់គ្នាប្រតិបត្តិតាមព្រះធម៌នោះគេពុំមានសេចក្តីសង្ស័យទេថា យើងនឹងរកឃើញនូវអត្ថប្រយោជន៍របស់ព្រះធម៌ ។ ប្រសិនបើយើងខិតខំចៀសវាងការធ្វើបាបអ្នកដទៃ, ប្រសិនបើយើងខិតខំឱ្យអស់លទ្ធភាពដើម្បីជួយអ្នកដទៃ នៅពេលណាយើងអាចជួយបាន, ប្រសិនបើយើងខិតខំតាំងចិត្តមិនប្រមាទ, ប្រសិនបើយើងខិតខំអភិវឌ្ឍសមត្ថភាពរបស់យើងដើម្បីធ្វើចិត្តឱ្យមូល, ប្រសិនបើយើងបណ្តុះបញ្ញា តាមរយៈការសិក្សា ការពិចារណាម៉ត់ចត់ និងការជញ្ជឹងគិត, នោះគេគ្មានសេចក្តីសង្ស័យទេថា ព្រះធម៌នឹងផ្តល់អត្ថប្រយោជន៍ដល់យើង ។ ជាដំបូង ព្រះធម៌នឹងនាំយើងទៅកាន់សេចក្តីសុខ និងសេចក្តីចំរុងចំរើននៅក្នុងជាតិនេះ និងជាតិក្រោយ ។ ជាយថាហេតុ ព្រះធម៌នឹងនាំយើងទៅដល់គោលដៅចុងក្រោយ គឺការរំដោះផុតទុក្ខ ដ៏ជាបរមសុខឋិតថេរអចិន្ត្រៃយ៍ នៃព្រះនិព្វាន ។

*

* *

# ព្រះត្រៃបិដក
# ជាគ្រូអាចារ្យដ៏ប្រសើរបំផុតរបស់យើង

**ឱម ខែម**

I. សេចក្តីផ្តើម

ពុទ្ធធមិ ឬធម្មៈ ដែលព្រះសម្មាសម្ពុទ្ធបានសំដែងក្នុងរយៈកាល ៤៥ ឆ្នាំនោះ បុរាណាចារ្យបានចងក្រងទុកជាឯកសារ ដោយអោយឈ្មោះថា បិដក ។ បិដកនេះចែកជា ៣ ផ្នែក ; ផ្នែកទី ១ និយាយពីរឿងវិន័យ ហៅថា វិន័យបិដក, ផ្នែកទី ២ និយាយអំពីចំណេះដឹង និងការប្រតិបត្តិព្រះពុទ្ធសាសនាក្នុងជីវភាពរស់នៅ ហៅថា សុត្តន្តបិដក, និងផ្នែកទី ៣ និយាយអំពីសភាវធមិជាន់ខ្ពស់ ហៅថា អភិធម្មបិដក ។

**ធមិ** ក្នុងទីនេះ គឺពាក្យណែនាំ, ពាក្យប្រៀនប្រដៅ, ពាក្យប្រាប់អំពីហេតុ-ផល, អំពើល្អ-អាក្រក់, គុណ-ទោស, បុណ្យ-បាប, ចំរើន-វិនាស, គួរ-ពុំគួរ ជាដើម ដែលព្រះមានព្រះភាគទ្រង់សំដែងប្រាប់ដល់សត្វលោក ។ ព្រះធមិនេះ បើពោលទៅតាមអង្គ មាន ៩ គឺ : សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។

ច្បាប់ជាពុទ្ធប្បវេណី ដែលតាំងទុកដើម្បីរៀបចំគ្រប់គ្រងភិក្ខុសង្ឃអោយមានសណ្តាប់ធ្នាប់ល្អ ហៅថា **វិន័យ** ។ វិន័យនេះ ជាច្បាប់សំរាប់ទូន្មានកាយ និងវាចារបស់បព្វជិត ដើម្បីអោយមានរបៀបបែបបទដូចគ្នា, ព្រោះថា កុលបុត្តអ្នកចូលមកទទួលបព្វជ្ជា ជាសាមណេរ និង ឧបសម្បទាជាភិក្ខុ ក្នុងព្រះពុទ្ធសាសនានេះ

សុទ្ធសឹងតែចេញមកពីប្រទេស និងជាតិត្រកូលផ្សេងៗគ្នា ទាំងនិស្ស័យចិត្តថ្លើម និងសណ្តាប់ធ្នាប់ ឬការប្រព្រឹត្ត ក៏រមែងមិនសូវដូចគ្នា, កាលបើមកកាន់ភេទជាសមណៈហើយ ទោះបីមានជាតិត្រកូលផ្សេងគ្នា មាននិស្ស័យចិត្តគំនិត និងសណ្តាប់ធ្នាប់ ឬការប្រព្រឹត្តផ្សេងគ្នា ក៏នឹងបានទៅជាបព្វជិតមានរបៀបបែបបទដូចគ្នា គួរជាទីជ្រះថ្លាពេញចិត្តនៃជនទាំងពួង ។

ព្រះសម្មាសម្ពុទ្ធជាបរមសាស្តា ទ្រង់រៀបចំវិន័យដើម្បីជាខ្នាតបន្ទាត់សំរាប់អោយបព្វជិតប្រព្រឹត្តប្រតិបត្តិ អោយមានរបៀបត្រូវគ្នាតាមសិក្ខាបទដែលជាមាត្រាមួយៗ ។ ច្បាប់អាណាចក្រ ត្រូវមានអាជ្ញាសំរាប់គ្រប់គ្រងប្រជាករជាពលរដ្ឋរៀបចំប្រទេសជាតិអោយមានរបៀបល្អ ។ យ៉ាណាមិញ, ចំណែកខាងព្រះពុទ្ធ-សាសនា ក៏ត្រូវមានវិនយប្បញ្ញត្តិ ជាពុទ្ធអាជ្ញាសំរាប់គ្រប់គ្រងភិក្ខុសង្ឃអោយមានរបៀបល្អ ក៏យ៉ាងនោះដែរ ។

ពាក្យថា វិន័យនេះ មានគោល ៣ ផ្នែកគឺ **បញ្ញត្តិ ១ អនុញ្ញាត ១ អភិសមាចារ ១** ។ ខដែលព្រះសម្ពុទ្ធទ្រង់ហាមមិនអោយបព្វជិតប្រព្រឹត្តពាយងាយតាមអំពើចិត្ត ព្រមទាំងប្រាប់ទោសកំហុសធ្ងន់ស្រាលផង ហៅថា **បញ្ញត្តិ** ឬ **ពុទ្ធប្បញ្ញត្តិ** ។ ខដែលទ្រង់យល់ព្រមអោយធ្វើ អោយប្រព្រឹត្តបាន ហៅថា **អនុញ្ញាត** ឬ **ពុទ្ធានុញ្ញាត** ។ ការប្រព្រឹត្តរៀបរយល្អ ឬកិច្ចវត្តដែលបព្វជិតត្រូវប្រព្រឹត្ត ត្រូវបំពេញអោយបរិបូណ៌ ហៅថា **អភិសមាចារ** ។ រួមទាំង ៣ ផ្នែកនេះ ហៅថា **វិន័យ** ។

តើធម៌ និងវិន័យ ទាំងនេះឋិតនៅឯណា ? . ធម៌និងវិន័យ ឋិតនៅជាមួយនឹងអ្នកកាន់កាប់ គឺជនណាបានរៀន បានចងចាំ បានប្រតិបត្តិ, ធម៌និងវិន័យ ឋិតនៅលើជននោះឯង ។

**II.** ប្រវត្តិសង្ខេប ៖

ព្រះត្រៃបិដក ជាគម្ពីរទ្រឹស្តីមូលដ្ឋានរបស់ពុទ្ធសាសនា ដែលបានអភិវឌ្ឍ ម្តងបន្តិចៗ ពីការទន្ទេញផ្ទាល់មាត់ ទៅជាចារឹកនៅលើស្លឹករឹត រួចហើយក៏បោះពុម្ព ជាសៀវភៅ ដែលជាការនិយមរបស់សម័យសព្វថ្ងៃ ។ តាមប្រវត្តិ, ព្រះត្រៃបិដក ដែលចារឹកជាតួអក្សរ និងជាភាសាបាលីលើកដំបូងបង្អស់នោះ ធ្វើនៅប្រទេសលង្កា ក្នុងអំឡុង ព.ស ៤៣៣ ។ ចំពោះប្រទេសខ្មែរ, ព្រះត្រៃបិដកបានចាប់កំណើតឡើង លើសាស្ត្រាស្លឹករឹតជាយូរមកហើយ ដោយសរសេរជាអក្សរខ្មែរ អានជាបាលី ។ លុះដល់ថ្ងៃ ៣ កើត ខែបុស្ស ឆ្នាំមមី ត្រីស័ក ព.ស ២៤៧២ ត្រូវនឹងថ្ងៃទី២ មករា ១៩៣០ ក្រុមជំនុំព្រះត្រៃបិដកនៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ បានចាប់ផ្តើមផ្ទៀង ផ្ទាត់អោយបានត្រឹមត្រូវ និងប្រែពីភាសាបាលីមកជាភាសាខ្មែរនៅក្នុងព្រះរាជបណ្ណា-ល័យកម្ពុជា ក្រុងភ្នំពេញ ។ ការកសាងព្រះត្រៃបិដកនេះ នៅក្រោមព្រះរាជូបត្ថម្ភ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជាធិបតី ។

ការប្រែបិដកពីភាសាបាលីមកជាភាសាខ្មែរ បានចាប់ផ្តើមពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៦៨ ទើបចប់ បោះពុម្ពជាសៀវភៅ មានចំនួន ១១០ ភាគ ។ ក្នុងភាគ នីមួយៗមានទាំងបាលីទាំងសម្រាយ, បាលីនៅទំព័រខាងឆ្វេង សម្រាយនៅទំព័រខាង ស្តាំ គ្រប់សៀវភៅទាំងអស់, ហៅថា ព្រះត្រៃបិដកបាលី-ខ្មែរ ។

**III.** ខ្លឹមសារសង្ខេបនៃព្រះត្រៃបិដក

[ក]. **វិន័យបិដក**

ជាគម្ពីរប្រមូលនូវវិន័យ សិក្ខាបទ សំរាប់ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ដែល ចែកចេញជា ៥ គម្ពីរ ( បោះពុម្ពជាសៀវភៅចំនួន ១៣ ភាគ ពីភាគ ១ ដល់ភាគ ១៣ ) ។ ឈ្មោះគម្ពីរទាំង ៥ នោះគឺ ៖

១. មហាវិភង្គ ឬភិក្ខុវិភង្គ : និយាយពីសិក្ខាបទ ២២៧ ក្នុងបាតិមោក្ខ ផ្នែកភិក្ខុសង្ឃ ។

២. ភិក្ខុនីវិភង្គ : និយាយពីសិក្ខាបទ ៣១១ ក្នុងបាតិមោក្ខ ផ្នែកភិក្ខុនីសង្ឃ ។

៣. មហាវគ្គ : និយាយពីពុទ្ធប្បវត្តិពីដំបូងៗ សិក្ខាបទក្រៅបាតិមោក្ខ និងពិធីកម្មខាងព្រះវិន័យ ។

៤. ចុល្លវគ្គ : និយាយពីពិធីកម្មខាងព្រះវិន័យ, ប្រវត្តិកំណើតភិក្ខុនិ និងប្រវត្តិនៃការធ្វើសង្គាយនា ។

៥. បរិវារ : និយាយពីវត្តប្រតិបត្តិវាយរង ការសួរ-ការឆ្លើយ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹងខាងវិន័យ ដែលមាននិយាយរួចហើយ ក្នុងភិក្ខុវិភង្គ ភិក្ខុនីវិភង្គ មហាវគ្គ និងចុល្លវគ្គ ។

## [ខ]. សុត្តន្តបិដក

ជាគម្ពីរដែលប្រមូលផ្តុំ កត់ត្រានូវព្រះធម្មទេសនា ការអធិប្បាយធម៌ និងរឿងរ៉ាវផ្សេងៗ ដែលទាក់ទងទៅនឹងបុគ្គល ឬ ឱកាសនានា ។ សុត្តន្តបិដក ឬ ព្រះសូត្រ ចែកចេញជាឈ្មោះគម្ពីរ ឬនិកាយ មាន ៥ ( បោះពុម្ពជា សៀវភៅចំនួន ៦៤ ភាគ ពីភាគ ១៤ ដល់ភាគ ៧៧ ) ។ ឈ្មោះគម្ពីរទាំង ៥ នោះគឺ :

១. ទីឃនិកាយ : គម្ពីរប្រជុំសូត្រដែលមានខ្នាតវែង មានទាំងអស់ចំនួន ៣ សូត្រ ចែកចេញជា ៣ វគ្គ គឺ : សីលខន្ធវគ្គ សូត្រនិយាយពីរឿងសីល មានទាំងអស់ ១៣ សូត្រ ; មហាវគ្គ មានទាំងអស់ ១០ សូត្រ ; បាដិកវគ្គ មានទាំងអស់ ១១ សូត្រ ។

២. មជ្ឈិមនិកាយ : ជាគម្ពីរប្រជុំសូត្រ ដែលមានខ្នាតវែងជាមធ្យម ចំនួន

១៥២ សូត្រ ចែកចេញជា ៣ បណ្ណាសកៈ ក្នុងមួយបណ្ណាសកៈ មានសូត្រចំនួន ៥០ លើកលែងតែបណ្ណាសកៈទី ៣ ដែលមានចំនួន ៥២ ។

៣. សំយុត្តនិកាយ ៖ ជាគម្ពីរប្រមូលនូវធម៌ ឬរឿងរ៉ាវជាពួកៗ ហៅថា សំយុត្ត ។ គម្ពីរសំយុត្តនិកាយមានទាំងអស់ ៧.៧៦២ សូត្រ ឬ ៥៦ សំយុត្ត ។ សំយុត្តនេះចែកជា៥ វគ្គ មានសគាថវគ្គជាដើម ។

៤. អង្គុត្តរនិកាយ ៖ ជាគម្ពីរដែលមានព្រះសូត្រចាត់ជាពួកៗ ហៅថានិបាត តាមលំដាប់ចំនួន ដូចជាធម្មៈពួក ១ ធម្មៈពួក ២, ពួក ៣ ជាដើម ។ គម្ពីរនេះមានទាំងអស់ចំនួន ១១ និបាត រួមសូត្រទាំងអស់ ៩.៥៥៧ សូត្រ ។

៥. ខុទ្ទកនិកាយ ៖ ជាគម្ពីរប្រជុំនូវព្រះធម៌ ពាក្យអធិប្បាយ និងរឿងរ៉ាវតូចតាចរាយរង ដែលរួមទាំងភាសិតរបស់ព្រះសាវ័ក ប្រវត្តិផ្សេងៗ និង ជាតក ជាដើម ។

### [គ]. អភិធម្មបិដក

អភិធម្មបិដក ជាគម្ពីរដែលនិយាយពីគោលធម៌សុទ្ធៗ មិនទាក់ទងដល់បុគ្គល ហេតុការណ៍ និងរឿងរ៉ាវផ្សេងៗឡើយ ជាវិជ្ជាសុទ្ធៗ មិនមាននិទាន ឬ អធិប្បាយលាយឡំដោយការសប្បាយទេ ។ អភិធម្មបិដក ចែកជា ៧ គម្ពីរធំៗ ( បោះពុម្ពជាសៀវភៅ ៣៣ ភាគ ពីភាគ ៧៨ ដល់ភាគ ១១០ ) ។ ឈ្មោះគម្ពីរទាំង ៧ នោះគឺ ៖ .

១. ធម្មសង្គណី ៖ ពោលពីការរួមក្រុមធម៌ គឺការចាត់អោយមានរបៀបនូវធម្មៈទាំងឡាយ ដែលនៅរាយប៉ាយច្រើនកន្លែង អោយមកនៅជាក្រុម ជាពួក, ...

២. វិភង្គ ៖ គម្ពីរនេះនិយាយពីការចែក (វិភង្គ) គឺញែកក្រុមធម៌ផ្សេងៗ អោយឃើញពិស្តារ ល្អិតល្អន់ ដូចជា ខន្ធ ៥ អាយតនៈ ១២ បែងចែកអោយល្អិត ថាតើមានអ្វីខ្លះ, ...

៣. ធាតុកថា : និយាយពីរឿងធាតុ ពោលគឺ នាំយកមាតិកាក្នុងធម្ម. សង្គណី និងបទក្នុងវិភង្គ ចំនួន ១២៥ យ៉ាង ព្រមទាំងមេបទក្នុងធម្មសង្គណី មកសង្គ្រោះជាមួយធម៌ ៣ យ៉ាងគឺ ខន្ធ អាយតនៈ និងធាតុ ថាតើចូលគ្នាបាន ឬមិនបានយ៉ាងណា ។

៤. បុគ្គលបញ្ញត្តិ : និយាយពីការបញ្ញត្តិបុគ្គល ដោយពោលដល់គុណធម៌ខ្ពស់ទាបរបស់បុគ្គល ។ បុគ្គលបញ្ញត្តិមានទាំងអស់ ៦ យ៉ាង គឺតាំងពីខន្ធបញ្ញត្តិ រហូតដល់បុគ្គលបញ្ញត្តិ ។

៥. កថាវត្ថុ : គឺជាគម្ពីរមួយដែលអដ្ឋកថាពោលថា ព្រះមានព្រះភាគទ្រង់បានសំដែងជាមេបទតែបន្តិចបន្តួចទេ ក្រោយពីនោះ ព្រះមោគ្គលិបុត្តតិស្សត្ថេរបានរៀបរៀងឡើងក្នុងសង្គាយនាលើកទី ៣ ។

គម្ពីរនេះបញ្ចុះដោយពាក្យសួរ និងពាក្យឆ្លើយ ដើម្បីដោះស្រាយ និងដេញដេងចំពោះលទ្ធិដទៃក្រៅពីពុទ្ធសាសនា ឬ ដែលបែកចេញពីពុទ្ធសាសនា តែពុំមានលក្ខណៈត្រឹមត្រូវ ។ កថាវត្ថុ មានពាក្យសួរ-ឆ្លើយទាំងអស់ ២១៩ កថា ( ភ.៨៤-៨៦ ) ។

៦. យមកៈ គឺជាគម្ពីរដែលពោលពីធម៌ ដែលជាគូ មានទាំងអស់ ១០ គូ គឺតាំងពីមូលយមកៈ រហូតដល់ឥន្ទ្រិយយមកៈ ។

៧. មហាបដ្ឋាន : គឺជាគម្ពីរដែលពោលពីទីតាំងទាំង ២៤ ដោយសំដែងថា អ្វីជាបច្ច័យរបស់អ្វីផ្នែកខាងធម៌មានចាប់តាំងអំពីហេតុបច្ច័យ រហូតដល់អវិគត. បច្ច័យ ( ភ.៨៤-១១០ ) ។

ព្រះត្រៃបិដកនេះ ទុកថាជាមូលដ្ឋាននៃវប្បធម៌ក្នុងផ្នែកអក្សរសាស្ត្រមួយដ៏ប្រសើររបស់ជាតិយើង ព្រោះថា គម្ពីរព្រះពុទ្ធសាសនានេះហើយជាជំនួយដល់ការល្អលាស់ខាងអក្សរសាស្ត្រ និងភាសាជាតិយើង, នាំអោយចំរើនជឿនលឿនតាម

ផ្លូវពុទ្ធនិយមបានច្រើនណាស់ ។

ដោយសារតែព្រះសង្ឃ៏តិកាចារ្យជំនាន់មុន បានប្រមូលមករៀបរៀងអោយនៅជួបជុំជាបិដកទាំង ៣ ដូច្នេះហើយ បាជាធម៌និងវិន័យរបស់ព្រះបរមគ្រូនៃយើង បានឋិតនៅចិរកាលសព្វគ្រប់ទាំងអស់ ឥតមានវិនាសបាត់ទៅតាមមនុស្ស ឬតាមកាលៈទេសៈ ត្រង់ប្រការណាមួយឡើយ ។ ដូច្នេះ យើងអាចពោលថា ធម៌ និងវិន័យ ដែលព្រះមានព្រះភាគសំដែង-បញ្ញត្តហើយ ឋិតនៅក្នុងគម្ពីរព្រះត្រៃបិដកទាំងអស់ ដោយពិត ។

ពុទ្ធសាសនិកទាំងឡាយ ! នេះជាកាលគួរ ជាឱកាសល្អបំផុតហើយ ដែលយើងបានកើតមកទាន់ព្រះពុទ្ធសាសនា កើតក្នុងប្រទេសដែលមានព្រះពុទ្ធសាសនា ហើយបានកាន់ព្រះពុទ្ធសាសនាទៀត ។ ព្រះពុទ្ធបរមគ្រូ ទ្រង់ចូលបរិនិព្វានចោលយើងទៅមែន ប៉ុន្តែ យើងពុំមែនជាមនុស្សកំព្រា ឥតមានគ្រូអាចារ្យទេ ព្រោះព្រះអង្គបានសាងគ្រូអាចារ្យប្រសើរបំផុត គឺធម៌ និងវិន័យ ដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកនេះឯង ។ បើយើងចង់ដើរទៅរកសុខស្ងប់ គឺព្រះនិព្វាន ត្រូវយើងសូមអោយគ្រូអាចារ្យយើងបង្ហាញផ្លូវចុះ ។ យើងកុំនៅឃ្លាតពីគ្រូអាចារ្យរបស់យើង ប៉ុន្តែយើង កុំគ្រាន់តែនៅជិតគ្រូអាចារ្យ ដូចជាកង្កែបនៅក្រោមផ្កាឈូកអោយសោះ ។ គ្រូអាចារ្យ គឺព្រះត្រៃបិដកនេះ នឹងជួយសង្គ្រោះយើងអោយរួចពីទុក្ខក្នុងបច្ចុប្បន្ន និងទុក្ខក្នុងវដ្តសង្សារ ទៅកាន់ត្រើយគឺព្រះនិព្វានបាន បើយើងបានរៀន បានចងចាំ បានប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់លោក ។ ចូរយើងកុំឃើញតែប្រយោជន៍បច្ចុប្បន្ន ចូរគិតប្រយោជន៍អនាគតផង ។ ចូរយើងកុំធ្វេសប្រហែសស្មារតី ចូរនឹកអោយជាប់ជានិច្ចនិរន្តរ៍នូវព្រះបណ្តាំនៃព្រះពុទ្ធបរមគ្រូ ដែលទ្រង់ផ្តាំទុកជាព្រះបច្ឆិមវាចា ថា *អប្បមាទេន សម្បាទេថ* អ្នកទាំងឡាយចូរញុំាងករណីយកិច្ចទាំងពួងអោយសំរេច ដោយមិនធ្វេសប្រហែសចុះ ! ។

# ព្រះធម៌អនិច្ចា (*)

( បទកាកគតិ )

ព្រះធម៌អនិច្ចា ព្រះធម៌លោកថា ដូចព្រះអាទិត្យ
រះឡើងពីព្រឹក សន្សឹករីងឫទ្ធិ ភ្លឺផ្លេកពេកពិត
ពាលពេញរស្មី ។

រះរៀងទៅត្រង់ ត្រចះត្រចង់ រុងរឿងរង្សី
ប្រែពីត្រង់ទៅ ដោយនូវសេចក្ដី ត្រជាក់រស្មី
ពុំដែលនឹងនៅ ។

សែងសូរ្យរង្សី ស្រឡាញ់រស្មី ស្រយុតទាបទៅ
ជិះជិតគងភ្នំ ស្រទំទាបទៅ រមិលមើលទៅ
ពពកសាត់ឆ្ងាយ ។

គួរអនិច្ចា ព្រះសែងសុរិយា ដូចរូបទាំងឡាយ
រីឯពពក សាត់ជ្រកទៅឆ្ងាយ បីដូចកលកាយ
វិញ្ញាណយើងឯង ។

ដើរចេញចោលរាង ចោលរូបភ្លាកភ្លាង ចាកចេញដូចផ្សែង
រីឯព្រះសូរ្យ គួរូបអង្គឯង ប្រាកដជាក់ស្ដែង
ដូចរូបទាំងឡាយ ។

វិញ្ញាណចេញទៅ ពុំដែលនឹងនៅ រូបរែងក្លែងក្លាយ
រលុបរលាយ ទន់ទាបទៅឆ្ងាយ ពុំដែលនៅអាយ
ឱ្យយល់រស្មី ។

(*) កម្ពុជសុរិយា លេខ ៣៩/១៩៦៧

គួរគិតអនិច្ចា  រាល់រូបអាត្មា  បារម្ភសេចក្តី
កាលនឹងរលត់  ភាំងផុតស្មារតី  បាត់ផ្សែងរស្មី
ត្រជាក់ស្ងួនស្ងួនស្ងុង ៗ

ស្រេចទៅជាខ្មោច  លន្លង់លន្លោច  ស្រឡោចស្រឡុង
ស្រឡេតក្នុងចិត្ត  អាណិតព្រឺព្រុង  វិញ្ញាណស្ងួនស្ងុង
ស្ងប់ស្ងាត់ឈប់ឈឹង ៗ

រមិលទៅយល់  បីដូចនូវគល់  គួរគិតរំពឹង
រាល់រូបរាល់កាយ  ទាំងឡាយនោះនឹង  ស្ងួនស្ងុងភ្លេចភ្លឹង
ដូចគ្នានោះឯង ៗ

អសុភនោះនៃ  ហើបហើមបីថ្ងៃ  ហួសហើយគួរស្ញែង
រលួយរលេះ  របេះអង្គឯង  អសោចិ៍ក្រៃលែង
អាក្រក់អប្រិយ ៗ

រលេះទ្រុឌទ្រោម  រលួយទាំងព្រម  សាច់ស្អុតអ្វីៗ
អស់ទាំងឆ្អឹងឆ្អែង  បាត់ផ្សែងរស្មី  នរអ្នកប្រុសស្រី
គួរគិតអនិច្ចា ៗ

ឱរូបអញអើយ  មិនដឹងម្តេចឡើយ  កំណត់ថ្ងៃណា
ដូចថ្ងៃរសៀល  ជ្រេងជ្រេសុរិយា  ទន់ទាបហើយណា
ជិះជិតគងភ្នំ ៗ

មើលទៅស្រយុត  នឹងអស្តង្គត  រលត់រលំ
រណាបបាំងបាត់  ស្ងប់ស្ងាត់ជ្រងំ  កំបាំងនឹងភ្នំ
ព្រះសុមេរុបាំងផ្សែង ៗ

នេះហើយរូបកាយ  រូបយើងទាំងឡាយ  បីដូច្នោះឯង

កាលនឹងរលត់ ភាំងផុតបាត់ផ្សែង ប្រាកដយល់ស្តែង
គួរតិតទុក្ខ ។

អនិច្ចារូបអើយ រូបចាស់ម្ល៉េះហើយ ដូចឈើប្របច្រាំង
គិតហើយរៀងយល់ អំពល់ទុក្ខ សេចក្តីមរណា
ជិតនឹងខ្លួនណាស់ ។

កុំឱ្យឆ្ងាយឆ្ងល់ ជរាមកដល់ រាល់រូបចាស់ៗ
ដំណឹងដាស់តឿន ក្នុងខ្លួនច្រើនណាស់ តឿនឱ្យខ្លួនចាស់
ធ្មេញបាក់សក់ស្កូវ ។

សរសៃស្អុតស្អេះ ឈើខ្នងចង្កេះ វេះរួយទន់ទៅ
ទន់ទោរអាក្រក់ សក់សោតសឹងស្កូវ ភ្នែកងងឹតទៅ
មើលអ្វីមិនជាក់ ។

ត្រចៀកថ្លង់ផង និយាយច្រើនដង មិនទាន់បានភ្ញាក់
នេះឯងដំណឹង មកតឿនអស់អ្នក មិនគួរឱ្យភ្ញាក់
បារម្ភក្នុងខ្លួន ។

រំពឹងទៅមុខ បារម្ភឃើញទុក្ខ គិតឱ្យថៃធ្ងន
កុំចាំកូនចៅ ធ្វើបុណ្យឱ្យធ្ងួន ក្រែងវាមិនជួន
ដូចខ្លួននៅរស់ ។

កូនចៅថាធ្វើ មានកាលទេះទើ ក្រោយខ្លួនស្លាប់ទៅ
ស្រឡាញ់ក្នុងកាប់ ទ្រព្យនោះទុកនៅ ក្រោយខ្លួនស្លាប់ទៅ
ដណ្តើមចែកទ្រព្យ ។

រីប្តីប្រពន្ធ បើប្តីស្លាប់មុន មានកាលចិត្តជា
ស្លៀកសស្លុតមុខ កើតទុក្ខវេទនា អាសូរចិត្តគ្នា

ធ្វើបុណ្យជូនទៅ ។

មានកាលឥតការ ប្តីស្លាប់កាលណា ពុំដែលនឹងនៅ
រកកល់រវៀស គ្រលៀសរកផ្លូវ មានប្តីទៀតទៅ
មុខរីកញញឹម ។

មួយសោតឯប្តី បើនឹងស្រដី សោតសឹងស្មើនឹម
ប្រពន្ធស្លាប់មុន កុំឱ្យសង្ឃឹម មានទៀតញញឹម
ប៉ប្រិមរីករាយ ។

ស្រឡាញ់រូបរ័ក្ស បម្រុងស្នៀកពាក់ តែងខ្លួនជជាយ
បណ្តើរតាមក្រោយ បង់ជោយគឃ្លាយ មិនឱ្យឃ្លាតឆ្ងាយ
ស្រឡាញ់លើសដើម ។

រីអ្នកស្លាប់មុន ឥតការឥតគុណ ស្លាប់ទៅក្រញើម
ក្រញឹងរងទុក្ខ នរកគួរស្បើម កាលរស់ពីដើម
ភ្លេចគិតធ្វើបុណ្យ ។

នេះហើយតីការ គម្ពីរលោកថា លោកទុកជាគុណ
គួរគិតអនិច្ចា ប្រាជ្ញាជាទុន ទុកទៅជាមុន
ទៅបរលោកនាយ ។

គួរធ្វើឱ្យហើយ កុំឱ្យលង់ឡើយ សេចក្តីមិនងាយ
កុំឱ្យបង្អង់ វេរង់អាយនាយ រូបវែងរលាយ
រលត់ឆាប់ណាស់ ។

គិតអ្វីមិនទាន់ រហ័សរូសរាន់ រាល់រូបឯចាស់
បើដល់កំណត់ រលត់ឆាប់ណាស់ គួរគិតក្រឡាស់
រំពឹងអនិច្ចា ។

មិនដឹងឬអ្វី រូបយើងសេចក្ដី ពីដើមនោះណា
យើងគេទាំងឡាយ សប្បាយចិត្តថ្លា ស្ថិតស្ថាងអាត្មា
កាលខ្លួនក្រមុំ ។
ងូតទឹកដុសក្អែល ក្រចកក្អិះឆ្កៀល លាបប្រេងបំព្រំ
យកសាងសិតសក់ កញ្ចក់ឆ្លុះជុំ កំលោះក្រមុំ
ផាំងឯងខ្លួនល្អ ។
ស្លៀកហូលពាក់ព្រៃ អប់អង្គបន្លែ ត្រអាលឯងអរ
អប់អស់ពោល្បំ ធរផ្ញុំខ្លាយខ្ចរ ទាំងក្លិនកេសរ
រំចេកស្លាកែត ។
ក្លិនប៉ុងកាចាត ពុំសែនស្អាងស្អាត រស់ជាតិដោយហេតុ
ដោយកលគន្ធ- ពិដោរផ្អិនផ្អែត រស់ជាតិដោយហេតុ
ដោយស្មគ្រស្មោះសរ ។
ទោះទៅស្ថានណា ចេញចរយាត្រា ចិត្តជាអំណរ
បង់បោយយាងយាស គ្រវាសចេញចរ ចិត្តចើកស្មោះសរ
អរឯងកន្លែង ។
កំពុងសោឡស រូបរាងស្រៀវស្រស់ រស់ជាតិពីក្មេង
សង្វាតអស់អញ ស្រឡាញ់លាបប្រេង សិតសក់ផៃផេង
ចិញ្ចែងកាយា ។
ក្រមួនមាត់ទូល លាយផ្ការំដួល រំដេញដីកា
ក្រចេះចួងចន្ទន៍ មាន់ហាមចម្ប៉ា ស្ថិតស្ថាងអាត្មា
កាលខ្លួននៅក្មេង ។
ហាក់ជាញ៉ាំញ៉ើ ធ្វើខ្លួនបញ្ញើ ក្នុងចិត្តកន្លែង

លុះដល់មួយភែ នោះនៃយល់ផ្សេង សាមសិបថែមធេង
ធ្លាក់សាច់ស្រយាក ។
ធ្លាក់ដល់សែសិប សម្បុរស្រអិប ស្រអាប់ជ្រីវជ្រាក
ហាសិបបង់ទាំង កំឡាំងពីរភាគ ថមថយស្រយាក
ស្រយុតទន់ទោរ ។
លុះដល់កំណត់ ហុកសិបប្រាកដ រីងរីតអន់អោ
សក់សស្កូវព្រោង ខ្នងកោងតោៗ ចិត្តសិបស្ញប់ស្ញោរ
រីងរៃផ្សេះៗ ។
ធ្មេញបាក់ស្បៀបស្បប និយាយហបៗ ទឹកមាត់ពភ្លេះ
សំបោរហូរហៀរ ចង្កាស្វាស្វេះ ដង្ហើមផ្សេះៗ
រល់តផុតទៅ ។
ជាខ្មោចតម្រង់ ដង្កូវរុកក្នុង រលុះជ្រាំជ្រៅ
រលុបរលាយ ខ្ចាត់ខ្ចាយចេញទៅ ឥតមានអ្វីនៅ
ជារូបទៀតឡើយ ។
វិញ្ញាណចេញទៅ ចាកទីលំនៅ ឥតកោះឥតត្រើយ
ឥតកូនឥតចៅ ម្នាក់នៅផងឡើយ សូន្យសុងទៅហើយ
បីដូចជាផ្សែង ។
លន្លង់លន្លោច សូន្យទៅជាខ្មោច កណ្តោចកណ្តែង
កណ្តាលប្រឹថពី ក្នុងទីនោះឯង គួរឱ្យចំបែង
ចិត្តគិតអាល័យ ។
មកទីលំនៅ មកអស់កូនចៅ មិនដាច់សង្ស័យ
មិនដឹងធ្វើម្តេច មិនដាច់អាល័យ សង្រេងសង្រៃ

ឥតឯតណានា ។

អនិច្ចារូបអើយ គន់គិតទៅហើយ គួរឱ្យវេទនា
សូន្យទៅជាខ្មោច លន្លោចកំព្រា ម្នាក់ឯងឥតគ្នា
កំដរទៅឡើយ ។

មានតែសីលទាន តាំងចិត្តប្រណិធាន ទុកទៅជាត្រើយ
ជាទីពំនាក់ ពឹងពាក់ឱ្យហើយ កុំឱ្យយូរឡើយ
ដ្បិតទៅម្នាក់ឯង ។

ព្រះធម៌ទេសនា សម្ដេចសាស្តា ព្រះអង្គចារចែង
ចងទុកជាច្បាប់ សណ្ដាប់សំដែង និទានថ្លាថ្លែង
ក្នុងព្រះធម៌ថា ។

នរអ្នកប្រុសស្រី កើតក្នុងលោកិយ កំណាញ់ឫស្យា
ច្រើនតែលោភទ្រព្យ ខ្ជាប់ក្នុងសញ្ញា កម្រចិត្តថ្លា
ក្លានឹងបុណ្យឡើយ ។

ឃើញមួយតែលោភ មោហោមកគ្រប កំណាញ់ឥតត្រើយ
ពីក្មេងដល់ចាស់ ពុំអស់ចិត្តឡើយ ប្ដូរខ្លួនជាត្រើយ
នឹងទ្រព្យសម្បត្តិ ។

ខំហើយរឹងខំ រិះរកសន្សំ ថែទាំខិតខាត់
ពុំដឹងឡើយខ្លួន ថែខ្លួនប្រយ័ត្ន អស់ទ្រព្យសម្បត្តិ
ឥតអៀនខ្មាសណាស់ ។

មានហើយចង់មាន លោភលន់ពុំបាន ប្រណីខ្លួនចាស់
ចេះតែប្រឹងប្រែង ខ្នះខ្នែងក្រឡាស់ ប្ដូរខ្លួនកញ្ចាស់
នឹងអស់ទ្រព្យធន ។

ដឹងខ្លួនជិតក្ស័យ ចិត្តគិតអាល័យ ស្តាយកូនប្រពន្ធ
វង្វេងស្មារតី ភិតភ័យលើសលន់ ព្រែងខ្លួនមិនធន់
ស្លាប់ចោលទៅបាត់ ។

កំពុងឈឺដាប និយាយខ្សាបៗ ពីទ្រព្យសម្បត្តិ
ផ្តាំកូនប្រពន្ធ ឱ្យប្រុងប្រយ័ត្ន កុំឱ្យបង់បាត់
ខូចខាតអសារ ។

ថាបើអញស្លាប់ ដុតខ្មោចឱ្យឆាប់ សម្រេចកិច្ចការ
កុំយកទ្រព្យអញ ធ្វើបុណ្យឡើយណា ចូរថែរក្សា
ឱ្យគង់ទុកទៅ ។

នេះហៅល្ងង់ខ្លៅ គិតតែកូនចៅ ភូមិស្ថានលំនៅ
ពុំគិតខ្លួនស្លាប់ ចោលបាត់បង់ទៅ អ្នករស់គេនៅ
សប្បាយរីករាយ ។

ហេតុនេះប្រុសស្រី ក្មេងក្តីចាស់ក្តី ចូរកុំរាយមាយ
ត្រូវអាណិតខ្លួន ស្លាប់ទៅលោកនាយ ពុំដែលវេចស្តាយ
យកទ្រព្យទៅបាន ។

មានតែធម៌ថ្លៃ ជាប់ជានិស្ស័យ ទៅជាមួយប្រាណ
នាំឱ្យសោយសុខ នៅនាសួគ៌ស្ថាន សប្បាយក្សេមក្សាន្ត
ឥតទុក្ខភ័យឡើយ ។

ដូច្នេះចូរខំ កសាងសន្សំ សីលទានឱ្យហើយ
ទាន់ខ្លួននៅរស់ កុំធ្វើតោះតើយ គ្រាន់ជាកោះត្រើយ
ទីពឹងជាតិមុខ ៕

***

# រឿងរើសរកកូនប្រសា

មានរឿងមួយដំណាលថា មានគ្រួសារមួយគឺប្តីប្រពន្ធ មានតែកូនស្រីពីរនាក់ ។ លុះកូនស្រីទាំងពីរនាក់ចំរើនវ័យវឌ្ឍនាការធំពេញក្រមុំពេលណាហើយ ឪពុកម្តាយ ក៏គិតគូរអំពីការរៀបចំទុកដាក់អោយមានគូស្រករ មានប្តីសី ដើម្បីកសាងជាគ្រួសារតរៀងទៅ ។ ប៉ុន្តែ ទាំងពីរនាក់ប្តីប្រពន្ធនោះ កើតមានយោបល់ខ្វែងគ្នាចំពោះការរកអនាគតកូនប្រសា ។ បុរសជាប្តីមានគំនិតថា កូនប្រសានោះ ទោះបីជាមិនបានរៀនសូត្រក៏ហិចុះ អោយតែវាចេះរកស៊ី ធ្វើស្រែចម្ការដូចគេឯង ចេះមើលថែធូនប្រពន្ធកូន នោះជាការល្អ ល្មមព្រមលើកអោយហើយ ។ ចំណែកឯប្រពន្ធវិញគាត់មានគំនិតថា កូនប្រសារបស់គាត់ ក្រៅពីចេះការងារដូចគេឯង នោះត្រូវតែជាអ្នកធ្លាប់បានបួសរៀនទៀតផង ទើបព្រមលើកកូនស្រីអោយ ។ គាត់តែងជជែកយកឈ្នះជានិច្ចជាមួយបុរសជាប្តី ដោយប្រកាន់យកគំនិតតែមួយគត់ ថា : « កូនប្រសាបើមិនបានជាប់ឈ្មោះថាជាអន្ទិតទេ ខ្ញុំមិនខ្ចីអោយកូនទេ » ។

ការខ្វែងយោបល់គ្នានេះ រួមផ្សំនឹងការស៊ើបសួរចង់ចូលមករកចែចូវពីសំណាក់ញាតិជិតឆ្ងាយផង ក៏ធ្វើអោយប្តីប្រពន្ធទាំងពីរនាក់កើតការបែកបាក់គ្នាបែកផ្ទះសម្បែងពីគ្នា តែមិនបានលែងលះគ្នាតាមផ្លូវច្បាប់ទេ ។ ទាំងពីរនាក់សុខចិត្តចែកកូនគ្នា ប្តីយកកូនស្រីបង ប្រពន្ធយកកូនស្រីប្អូន ។ ក្រោយពីនោះមក អ្នកទាំងពីរក៏រៀបចំទុកដាក់អោយកូនស្រីរបស់ខ្លួនមានគូស្រករ តែរៀងៗខ្លួនទៅ ។

សម័យថ្ងៃមួយ បុរសជាប្តីនឹកចង់ល្បងប្រាជ្ញាកូនប្រសាទាំងពីរនាក់មើល ។ គាត់ក៏នាំកូនប្រសារបស់គាត់ទៅផ្ទះខាងប្រពន្ធរបស់គាត់ ដើម្បីបបួលកូនប្រសារបស់ប្រពន្ធគាត់ ធ្វើដំណើរកំសាន្តមួយតាមទូក ។ កាលបើបានជួបជុំគ្នាហើយ

ឪពុកក្មេកនិងកូនប្រសាទាំងពីរនាក់ រួមត្រូវជាបីនាក់ ក៏ចែវទូកចេញទៅ ។ ម្ដាយក្មេក នៅផ្ទះជាមួយកូនស្រីទាំងពីរនាក់ ។

លុះចែវទូកបានបន្តិចទៅ ពួកគេក៏ប្រទះទាមួយហ្វូងតូចកំពុងហែលទឹក ។ បុរសជាឪពុកក្មេក ក៏សួរទៅកូនប្រសារបស់ខ្លួនថា :

« មើល៍ កូន, សត្វទា ហេតុអីបានជាវាអណ្ដែតទឹក ?

- បាទ, លោកឪពុក មកពីខ្លួនវាមានដុះរោមយ៉ាងក្រាស់នៅជុំវិញ » ។

ឮកូនប្រសារបស់ខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះពេញចិត្តណាស់ ក៏ងក់ក្បាល ហើយញញឹម រួចសួរទៅកូនប្រសាខាងប្រពន្ធថា :

« មើល៍ អាអន្ទិត, ទា ហេតុអីបានជាវាអណ្ដែតទឹក ?

- បាទ, លោកឪពុក មកពីកំណើតវា » ។

ឮកូនប្រសារបស់ប្រពន្ធខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះនឹកក្នាញ់ណាស់ ក៏ធ្វើមុខស្មើ តែមិនមាននិយាយស្ដីអ្វីតទៅទៀតឡើយ ។

លុះចែវបានបន្តិចទៀតទៅ ពួកគេក៏ប្រទះឫស្សីស្រុកមួយកំណាត់អណ្ដែតនៅលើផ្ទៃទឹក ។ គេក៏ស្រង់ឫស្សីមួយកំណាត់នោះពីក្នុងទឹកពិនិត្យមើលឃើញម្ខាងមានពណ៌ខៀវ ឯម្ខាងទៀត មានពណ៌សបន្តិច ។ បុរសជាឪពុកក្មេក ក៏សួរទៅកូនប្រសារបស់ខ្លួនថា :

« មើល៍ កូន, ឫស្សីមួយកង់នេះ ម៉េចបានជាម្ខាងខៀវ ម្ខាងសអញ្ចឹង ?

- បាទ, លោកឪពុក អាម្ខាងដែលស មកពីវាត្រូវថ្ងៃ ព្រោះវានៅខាងលើ ហើយអាម្ខាងដែលខៀវនោះ មកពីវានៅខាងក្រោម អត់មានត្រូវថ្ងៃ » ។

ឮកូនប្រសារបស់ខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះពេញចិត្តណាស់ ក៏ងក់ក្បាល ហើយញញឹម រួចសួរទៅកូនប្រសាខាងប្រពន្ធថា :

« មើល៍ អាអន្ទិត, ឫស្សីមួយកង់នេះ ម៉េចបានជាម្ខាងខៀវ ម្ខាងស

អញ្ចឹង ?

- បាទ, លោកឪពុក មកពីកំណើតវា » ។

ឮកូនប្រសារបស់ប្រពន្ធខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះនឹកក្នាញ់ណាស់ ក៏ធ្វើមុខស្មើ តែមិនមាននិយាយស្ដីអ្វីតទៅទៀតឡើយ ។

លុះដើរទៅកាន់តែឆ្ងាយបន្តិចទៀត ស្រាប់តែគេឃើញក្រសាមួយយំ រួចទទះស្លាបហើរទៅ ។ បុរសជាឪពុកក្មេក ក៏សួរទៅកូនប្រសារបស់ខ្លួនថា :

« មើល៍ កូន, អាសត្វក្រសាហ្នឹង ហេតុអីបានជាវាយំឮខ្លាំងម្ល៉េះ ?

- បាទ, លោកឪពុក ក្រសាវាយំឮខ្លាំង មកពីកវាវែង » ។

ឮកូនប្រសារបស់ខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះពេញចិត្តណាស់ ក៏ងក់ក្បាល ហើយញញឹម រួចសួរទៅកូនប្រសាខាងប្រពន្ធថា :

« មើល៍ អាអន្ថិត, អាសត្វក្រសាហ្នឹង ហេតុអីបានជាវាយំឮខ្លាំងម្ល៉េះ ?

- បាទ, លោកឪពុក មកពីកំណើតវា » ។

ឮកូនប្រសារបស់ប្រពន្ធខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះនឹកក្នាញ់ណាស់ ក៏ធ្វើមុខស្មើ តែមិនមាននិយាយស្ដីអ្វីតទៅទៀតឡើយ ។

លុះដើរពីនោះបានបន្តិចទៀតទៅ ស្រាប់តែគេប្រទះសត្វក្ដាន់មួយ បោលយ៉ាងលឿន ដោយសារវាផ្អើលនឹងមនុស្ស ។ ឃើញដូច្នោះ បុរសជាឪពុកក្មេក ក៏សួរទៅកូនប្រសារបស់ខ្លួនថា :

« មើល៍ កូន, សត្វក្ដាន់ ហេតុអីក៏វារត់បានលឿនម្ល៉េះ ?

- បាទ, លោកឪពុក ក្ដាន់វារត់លឿន ព្រោះវាមានជើងច្រើន ដល់ទៅបួនឯណោះ » ។

ឮកូនប្រសារបស់ខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះពេញចិត្តណាស់ ក៏ងក់ក្បាល ហើយញញឹម រួចសួរទៅកូនប្រសាខាងប្រពន្ធថា :

« មើល៍ អាអន្ទិត, សត្វក្តាន់ ហេតុអ្វីក៏វារត់លឿនម្ល៉េះ ?

- បាទ, លោកឪពុក មកពីកំណើតវា » ។

ឮកូនប្រសារបស់ប្រពន្ធខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះនឹកក្នាញ់ណាស់ ក៏ធ្វើមុខស្មើ តែមិនមាននិយាយស្តីអ្វីតទៅទៀតឡើយ ។

លុះធ្វើរបន្តទៅមុខទៀត គេក៏ប្រទះនឹងដំបូកត្រឃិលមួយ ស្ថិតនៅកណ្តាលបឹងដែលមានស្មៅដុះព័ទ្ធជុំវិញ លើកលែងតែកំពូលលើនៅចំកណ្តាលដែលមានតែដីដំបូកទទេ ហើយរលីងស្អាត ។ ឃើញដូច្នោះ បុរសជាឪពុកក្មេក ក៏សួរទៅកូនប្រសារបស់ខ្លួនថា :

« មើល៍ កូន, ដំបូកនេះ ហេតុអ្វី ក៏ផ្នែកខាងក្រោមមានស្មៅដុះជុំវិញ ?

- បាទ, លោកឪពុក ផ្នែកខាងក្រោមមានស្មៅដុះ ព្រោះមានទឹកទៅដល់ហើយអាកំពូលវាខាងលើនោះ ទឹកទៅមិនដល់ ទើបបានជាគ្មានស្មៅដុះ » ។

ឮកូនប្រសារបស់ខ្លួនឆ្លើយដូច្នោះ បុរសជាឪពុកក្មេកនោះពេញចិត្តណាស់ ក៏ងក់ក្បាល ហើយញញឹម រួចសួរទៅកូនប្រសាខាងប្រពន្ធថា :

« មើល៍ អាអន្ទិត, ដំបូកនេះ ហេតុអ្វី ក៏ខាងក្រោមមានស្មៅដុះព័ទ្ធជុំវិញ ហើយត្រង់កំពូលខាងលើនោះ ម៉េចក៏អត់មានស្មៅដុះអញ្ចឹង ?

- បាទ, លោកឪពុក មកពីកំណើតវា » ។

ឮកូនប្រសារបស់ប្រពន្ធខ្លួនឆ្លើយតែដដែលៗ ដូច្នោះ បុរសជាឪពុកក្មេកនោះខឹងពន់ពេកណាស់ តែពុំមាននិយាយស្តីថាអ្វីឡើយ គ្រាន់តែនឹកក្នុងចិត្តថា « អានេះបានចំជាល្ងង់ រកអ្នកណាប្រដូចគ្មាន ។ ដែលវាធ្លាប់បានបួសរៀន អញស្មានតែវាគ្រាន់បើដែរ ដឹងអីតម្រក់អញ្ចឹងទេ ! » ។

បុរសជាឪពុកក្មេក ក៏បញ្ជាអោយកូនប្រសាធ្វើរទូកត្រឡប់ទៅផ្ទះវិញ ក្នុងក្តីទោមនស្សនឹងកូនប្រសាខាងប្រពន្ធនោះពន់ពេក ។ គាត់មានគំនិតថា « កាលបើទៅ

ដល់ផ្ទះវេលាណា អញមិនបង្អង់ទេ អញនឹងយករឿងនេះទៅនិយាយផ្ចាញ់ផ្ចាល អោយប្រពន្ធអញ និងកូនប្រសាខាងប្រពន្ធអញ អាមាសមុខទាំងអស់គ្នាម្តង អោយសមមុខអ្នករើសរកកូនប្រសា ចាំទាល់តែអន្ទិតដែលបានបួសរៀននៅវត្ត ទើបព្រមលើកកូនអោយ » ។

លុះឡើងពីទូករួចរាល់ហើយ បុរសនោះក៏ប្រញាប់រូតរះសំដៅទៅរកផ្ទះប្រពន្ធ ។ លុះបានជួបគ្នាហើយ បុរសនោះក៏តាំងនិយាយចំអកឡកឡឺយអោយនាងជាប្រពន្ធថា :

« ហ៊ឹះ ! អាអន្ទិត កូនប្រសាឯងនោះ វាសមមុខឯងហើយ ! ដើរជាមួយគ្នាមួយព្រឹកថ្ងៃត្រង់ អញសួរពីនេះពីនោះតែបន្តិចបន្តួចសោះ វាឆ្លើយមកគ្មានដឹងខ្យល់អីទេ ។ ចំណែកកូនប្រសាអញវិញ វាឆ្លើយទៅនឹងសំណួរអញមួយៗ បានពេញជាសមហេតុសមផលរបស់វាណាស់ ។ អញ្ចឹង បានគេហៅថាអ្នកចេះ !

ចុះឪវាឯង សួរវាពីរឿងអ្វីខ្លះទៅ ?

អញសួរថា សត្វទា ហេតុអ្វីបានជាវាអណ្តែតលើទឹក ។ កូនប្រសាអញឆ្លើយថា មកពីវាមានរោមដុះយ៉ាងក្រាស់នៅជុំវិញខ្លួនវា ; ឯកូនប្រសាឯងវិញ វាឆ្លើយថា មកពីកំណើត ។ រួចអញឃើញឫស្សីមួយកង់អណ្តែតទឹក អញសួរថា ហេតុអីបានជាឫស្សីនោះ ម្ខាងពណ៌ខៀវ ម្ខាងពណ៌ស ។ កូនប្រសាអញឆ្លើយថា អាម្ខាងពណ៌ស មកពីវានៅខាងលើ ហើយត្រូវថ្ងៃ ឯអាម្ខាងពណ៌ខៀវនោះ មកពីវានៅខាងក្រោម ក្នុងទឹក អត់មានត្រូវថ្ងៃ ; ឯកូនប្រសាឯងវិញ វាឆ្លើយថា មកពីកំណើត ។ រួចអញ ឃើញសត្វកុកក្រសាវាយំ អញសួរថាកុកក្រសា ហេតុអីបានជាវាយំឮម្ល៉េះ ។ កូនប្រសាអញថា អាសត្វក្រសាវាយំឮ មកពីកវាវែង ; ឯកូនប្រសាឯងវិញ វាឆ្លើយថា មកពីកំណើត ។ រួចអញឃើញសត្វក្តាន់មួយបោល អញសួរថា សត្វក្តាន់ម៉េចក៏រត់លឿនម្ល៉េះ ។ កូនប្រសាអញថា ក្តាន់វារត់លឿន មកពីវាមានជើង

ច្រើនណាស់ គឺដល់ទៅប្ងួន ; ឯកូនប្រសារបស់ឯងវិញ វាថាមកពីកំណើត ។ ចុង ក្រោយបង្អស់ អញឃើញដំបូកត្រងិលមួយនៅកណ្ដាលបឹង ។ អញសួរថា ដំបូក ហ្នឹង ហេតុអីក៏បានជាអាកំពូលនៅចំត្រង់កណ្ដាលបែរជារលីងណិល អត់មានស្មៅ ដុះ ហើយនៅខាងក្រោមជុំវិញ ម៉េចក៏មានស្មៅដុះ ។ កូនប្រសាអញឆ្លើយថា អាខាង ក្រោមដែលមានស្មៅដុះ មកពីមានទឹកឡើងទៅដល់ ; ឯកូនប្រសារបស់ឯង វាឆ្លើយ ថា មកពីកំណើត ។ មើល៍, ឯងជួយស្ដាប់មើល ! កូនអញវាឆ្លើយមកដូចជាត្រឹមត្រូវ សមរម្យល្មមស្ដាប់បានរបស់ផងវា, អញស្ដាប់ៗទៅគួរអោយពេញចិត្តកូនប្រសា អញណាស់ ។ ចំណែកឯអាអន្ថិតកូនប្រសាឯងនោះ វាចេះឆ្លើយតែមួយមុខហ្នឹង ! ស្អីក៏មកពីកំណើត ! ស្អីក៏មកពីកំណើត ! មិនដឹងជាមកពីកំណើតអម្បែងក្បាលវាអី ក៏ច្រើនម្ល៉េះ មិនចេះអស់ មិនចេះហើយអញ្ចឹង ! អញមិនដែលឮ ! ហ៊ឺះ ! អាកូន ប្រសារបៀបហ្នឹង, ទៅ ! ឯងយកទៅ ! អញសុំលាទៅវិញហើយ ! » ។

បុរសនោះ ហៀបតែនឹងឈានជើងដើរចេញទៅវិញហើយ ប៉ុន្ដែ នាងជា ប្រពន្ធបានឃាត់មិនទាន់អោយទៅ ដោយនិយាយថា :

« ឈប់សិន ឪវា ! កុំទាន់អាលទៅវិញអី ! » ឪវាឯងមិនទាន់សួរវាអោយ វាពន្យល់ប្រាប់អោយអស់អាថ៌សេចក្ដីផងនោះ អីក៏ប្រញាប់ដៀលត្មះអោយវាម្ល៉េះ ? មើល៍, សួរវាអោយច្បាស់សិនមើល ! ហេតុដូចម្ដេចក៏បានជាវាឆ្លើយអញ្ចឹង ! ខ្ញុំជឿ ថាវាមានមូលហេតុរបស់វាណាំ ! » ។

បុរសជាប្ដីឮដូច្នោះហើយ ក៏ហាក់ដូចជាយល់ស្របតាមសំណូមពររបស់ ប្រពន្ធខ្លះដែរ ទើបទម្លាក់តួខ្លួនអង្គុយចុះនៅលើគ្រែវិញ ។ នាងជាប្រពន្ធក៏ហៅកូន ប្រសារបស់ខ្លួន ព្រមទាំងកូនប្រសាខាងប្ដីផង អោយមកអង្គុយជិតឪពុកក្មេក ។ ឪពុក ក្មេកគិតថា គាត់កំពុងតែបានឱកាសនឹងបំបាក់មុខប្រពន្ធគាត់ ព្រមទាំងកូនប្រសាម្ដង ទៀតហើយ ។ គាត់ក៏ចាប់ផ្ដើមនិយាយទៅកាន់កូនប្រសាខាងប្រពន្ធគាត់ ដោយប្រើ

សំដីបែបចំអកអោយបន្តិចផងថា ៖

« មើល៍, អាអន្ថិត ឆ្លើយប្រាប់អញអោយច្បាស់ផងមើល៍ ពីរឿងដែលឯងថា មកពីកំណើតស្អីគេនោះ ស្អីក៏មកពីកំណើត ! ស្អីក៏មកពីកំណើត ! អញរកយល់ផងមិនបានទេ » ។

កូនប្រសានោះក៏ឆ្លើយពន្យល់រៀបរាប់បញ្ជាក់ តាមលំដាប់លំដោយអោយឪពុកក្មេកស្តាប់ ដូចតទៅនេះថា ៖

« បាទ, លោកឪពុក ដែលខ្ញុំថា សត្វទា វាអណ្តែតទឹកមកពីកំណើតនោះ គឺមិនមែនដោយសារខ្លួនវាមានដុះរោមពន្ធជុំវិញនោះទេ, ព្រោះអី ? លោកឪពុកគិតមើល, ទូកវាមានដុះរោមឯណា ម៉េចក៏វាអណ្តែតទឹកដែរ ? »

ឪពុកក្មេកល្ងង់ខ្លៅនោះ ក៏លាន់មាត់ថា « យី ! ត្រូវរបស់វាអញ្ចឹងមែនរ៉ឺ ! ដូចជាសមរម្យមែន តាមស្តាប់ទៅ » ។ គាត់ក៏ងក់ក្បាល ញញឹម ហើយបន្ថន់សំដីជាងមុនបន្តិច នៅពេលដែលគាត់សុំអោយកូនប្រសានិយាយតទៅទៀត ។

« ចុះរឿងឫស្សីនោះ កូន, កូនឯងប្រាប់ឪពុកមើល៍ ?

- បាទ, លោកឪពុក រឿងឫស្សីហ្នឹង អាម្ខាងពណ៌ស អាម្ខាងទៀតពណ៌ខៀវនោះ មិនមែនដោយសារអាខាងលើវាត្រូវថ្ងៃ ទើបបានជាវា-ស ហើយអានៅខាងក្រោមនោះវាអត់ត្រូវថ្ងៃ ទើបបានជាវាខៀវនោះទេ ។ លោកឪពុក មិនគិតមើលពីផ្លែឪឡឹកមើល៍ ហេតុម្តេចក៏បានជាអាខាងលើដែលត្រូវថ្ងៃនោះ មានពណ៌ខៀវ ហើយអានៅខាងក្រោមដែលឥតត្រូវថ្ងៃផងនោះ បែរជាមានពណ៌សទៅវិញ, ហ្នឹងមិនមកពីកំណើត ? »

ឪពុកក្មេកល្ងង់ខ្លៅនោះ កាន់តែពេញចិត្តនឹងសេចក្តីពន្យល់នេះណាស់ ។ គាត់ក៏ងក់ក្បាល ញញឹម ទាំងលាន់មាត់ថា « អញ្ចឹងមែនរ៉ឺ ! » រួចគាត់កាន់តែបន្ថន់សំដីជាងមុនថែមទៀត នៅពេលដែលគាត់និយាយទៅកូនប្រសាថា ៖

« មើល៍ កូន ! ឥឡូវកូនឯងឆ្លើយបញ្ជាក់ប្រាប់ឪ ពីរឿងក្រោយៗ ទាំងប៉ុន្មាននោះ តទៅទៀតមើល៍ ! ពុកស្ដាប់ទៅដូចជាគួរអោយចូលចិត្តពេកណាស់ ។ ទៅ ! កូនឯងនិយាយតទៅទៀតទៅ កូន ! »

- បាទ, លោកឪពុក បើថាសត្វក្រសាវាយំឮខ្លាំង ដោយសារវាមានកវែងនោះ ចុះសត្វហ៊ីង សត្វកង្កែប វាមានកវែងឯណា ហេតុម្ដេចក៏បានជាវាយំឮម្ល៉េះ ហើយឮបានឆ្ងាយទៀតផង ? ចំណែកសត្វក្ដាន់ដែលរត់លឿន ថាមកពីវាមានជើងច្រើនណាស់ ដល់ទៅបួន ។ នេះមិនពិតទេ លោកឪពុក ។ លោកឪពុកមិនគិតមើលចុះឯសត្វម្រោមព្រះវិញ ហេតុម្ដេចក៏បានជាវាមិនរត់អោយបានលឿនដែរទៅ បើវាមានជើងដល់ទៅរាប់រយ ឬក៏អាចថាដល់ទៅមួយពាន់ឯណោះផង ម្ដេចក៏បានជាវាវារយឺតៗ អីម្ល៉េះ ?

- យី ! កូននិយាយនេះបានចំជាសមហេតុសមផលណាស់ហ្ន៎ ! ស្ដាប់កូនឯងនិយាយយូរៗទៅ ឪកាន់តែចូលចិត្តមែនទែន ។ អញ្ចឹង និយាយតទៅទៀតកូន ឪចាំស្ដាប់ ។ កូននិយាយពីដំបូកនោះមើល៍ !

- ទេ ! លោកឪពុក កូនអត់ហ៊ាននិយាយទៀតទេ !

- ម៉េចបានជាអត់ហ៊ាន ? ខ្លាចអី ? និយាយទៀតទៅ កូន !

- ខ្ញុំអត់ហ៊ាននិយាយទេ ព្រោះខ្លាចលោកឪពុកខឹង ។

- ទេ, ឪអត់ខឹងទេកូន ! កូននិយាយទៅ ! ឪកំពុងតែចង់ស្ដាប់កូនខ្លាំងណាស់ណ៎ា !

- លោកឪពុក ប្រាកដជាអត់ខឹងទេឬ ? អញ្ចឹង, ខ្ញុំនិយាយហើយណ៎ា !

- និយាយទៅកូន, និយាយទៅ !

កូនប្រុសានិយាយ : ដែលថាដំបូកផ្នែកខាងក្រោមមានស្មៅដុះ មកពីមានទឹកឡើងទៅដល់ ឯអាផ្នែកខាងលើចំត្រង់កំពូលកណ្ដាលនោះ វាឥតមានស្មៅដុះ

មកពីឥតមានទឹកទៅដល់នោះ ដូចជាមិនត្រឹមត្រូវទេ ។ សូមលោកឪពុកពិចារណាមើល, មិនអីទុំះហ្ន៎ ! ក្បាលលោកឪពុក ( កូនប្រសានិយាយផង លើកដៃចង្អុលផង ) ផ្នែកខាងលើចំត្រង់កំពូលកណ្ដាលនោះ មកពីឥតមានទឹកទៅដល់ដែរឬ បានជាឥតមានសក់ដុះ ? » ។

កូនប្រសានិយាយមិនទាន់ផុតពីមាត់ផង ស្រាប់តែឪពុកក្មេកដឹងខ្លួនទាន់ ក៏លាន់មាត់ថា « ហ៊ឺះ ! » រួចហើយ ដោយពុំមាននិយាយលាអ្នកណាមួយម៉ាត់សោះ បុរសនោះក៏ស្ទុះដើរចេញទៅ ក្នុងចិត្តមួម៉ៅខ្លាំងណាស់ ដោយហេតុតែនឹកអាមាសមុខនឹងកូនប្រសាខាងប្រពន្ធរបស់ខ្លួននោះ ហួសពេកពោង ។

***

**ជំបូន្មាន**

អ្នករៀនទាំងឡាយ

ប្រយ័ត្នវាយមាយ ព្រោះក្ដីសល់វល់ ត្រូវខំមាត់រៀន ចំណេះសាកល

ឱ្យត្រាតែដល់ ត្រើយត្រាណវិទ្យា ។

វិទ្យាជាទ្រព្យ

ប្រើបានគ្រប់សព្វ លើសទ្រព្យនានា អ្នកមានទ្រព្យស្រាប់ អាប់ឥតវិជ្ជា

មិត្តភក្ដិផងគ្នា គេច្រើនមើលងាយ ។ ល ។

សម្ដេចព្រះសង្ឃរាជ **ជួន ណាត**

រឿង

# តម្លង់ ៧ សន្តាន

មានបុរសស្ត្រីប្តីប្រពន្ធ នាំគ្នាទៅសួរបងប្អូននៅភូមិព្រៃសណ្តែក ដើរៗទៅ ប្រទះនឹងអាតម្លង់ ៧ សន្តាន កំពុងតែទឹមគោភ្ជួរស្រែ ។ បុរសស្ត្រីប្តីប្រពន្ធនោះសួរថា អ្នកអើយអ្នក ផ្លូវណាកាត់ត្រង់ទៅលើភូមិព្រៃសណ្តែក ដ្បិតខ្ញុំខានមកយូរឆ្នាំហើយ មិនដឹងជាផ្លូវណាកាត់ទៅអោយត្រង់ ។ អាតម្លង់ ៧ សន្តាន ស្រាប់តែខឹងឆ្លើយថា គោអញមួយនឹមនេះ សុទ្ធតែកូនក្រោលបង្គោលស្នឹង អាក្រហមមួយនេះម្តាយក្មេកគាត់ចែកអោយ ឯអាស្ទែងកន្ទែក ឪអញគាត់អោយ អញមិនលួចគោអាណាយកមកទឹមទេ ។

ឯបុរសប្តីប្រពន្ធដែលសួរផ្លូវនោះឮហើយនិយាយគ្នាថា អ្នកនេះ យើងសួរផ្លូវគាត់ គាត់និយាយពីគោ ហើយស្តីគំរោះគំរើយអោយយើងផង ។ ណ្ហើយគេហ៎, យើងកុំខ្ចីសួរវា យូរឆាប់គង់តែនឹងទៅដល់ផ្ទះបងប្អូនមិនខាន ហើយក៏បណ្តើរគ្នាហួសទៅ ។ ឯអាតម្លង់ ៧ សន្តាននោះ ក៏ខំភ្ជួរស្រែមិនឈប់ ដល់ពេលជិតថ្ងៃត្រង់មេតម្លង់ជាប្រពន្ធ ក៏ទូលបាយទៅអោយប្តីបរិភោគ លុះដល់ដាក់ល្អីបាយនៅក្រោមម្លប់ឈើនៅភ្លឺស្រែ ប្តីនោះ លុះបានឃើញប្រពន្ធយកបាយមកអោយ ក៏ឈប់លែងភ្ជួរស្រែ បរិភោគបាយនិយាយទាំងខឹងប្រាប់ប្រពន្ធថា មានបុរសប្តីប្រពន្ធបណ្តើរគ្នាមកពីណា ហើយប្រកាន់ថាអញលួចគោវា, ឯគោមួយនឹមនេះ ប្រាកដជាម៉ែឪអញចែកមក ។ មេប្រពន្ធឃើញមាត់ប្តីនិយាយហាបៗ នឹកស្មានថាស្តីអោយខ្លួន ស្រាប់តែខឹង ហើយឆ្លើយតបទៅវិញថា អញគិតថា ប្តីមកភ្ជួរស្រែទាល់ថ្ងៃ ខំប្រញាប់ប្រញាល់ទូលបាយមកអោយស៊ី ឥឡូវទៅជាថា ឯងមានប្រុសមានសហាយ អញសហាយនឹងឈ្មោះអាណា គាត់រកមុខអោយឃើញ, ប្តីមិតតែពមបាយអស់មួយល្អី ប្រពន្ធថាអ្វីក៏

មិនឮផង ។ លុះប្ដីបរិភោគរួច មេប្រពន្ធកន្ត្រាក់យកល្អី ប្ដីសួរថា ឯងមានការអ្វីឯផ្ទះ បានជាប្រញាប់ម្ល៉េះ មេប្រពន្ធថា អញមុខជាប្រាប់ម៉ែឪអញមិនខាន ហើយកណ្ដៀតល្អីត្រឡប់ទៅដល់ផ្ទះ ជួបនឹងម្ដាយនិយាយទាំងខឹងមុខក្រហមប្រាប់ម្ដាយថា កូនប្រ-សាម៉ែឯងវាល្អហើយ ខ្ញុំទូលបាយទៅអោយស៊ី ដាក់ល្អីស្ទើរតែមិនទាន់ វាស្ដីអោយខ្ញុំថាមានប្រុស មានសហាយ ។

ឯម្ដាយនោះខឹងញ័រឡើងថា ហាងឯងដូច្នេះទេតើបានជាមុខក្រហម អញថាកូនថាចៅបានជានៅចាំផ្ទះអោយវា ឥឡូវវាថាឯងលួចផ្ទាំវាយកទៅដូរដូង មេអន្តរធានឯង ក្រោយៗកុំនិយាយដូច្នេះមិនត្រូវទេ សូម្បីតែផ្ទាំមួយឆ្នុក ក៏អញមិនលួចយកផង បើទុកជាអញយកមែន ម្ដាយនិងកូនមិនត្រូវហាងឯងពោលអោយអញខ្មាសគេ ចាំឪហាងឯងមក អញប្រាប់អោយជេរវាយប្រដៅហាងឯងមិនខាន ។

លុះយូរបន្តិច ប្ដីមកពីកាប់បង្គោលធ្វើរបងបង្កាមិនអោយគោ-ក្របីចូលស៊ីសំណាប សន្ទូង ប្រពន្ធនិយាយប្រាប់ប្ដីថា កូនស្រីយើងវាទៅជូនបាយប្ដី ខ្ញុំចាំផ្ទះអោយវា វាមកវិញវាថា ខ្ញុំជាម្ដាយលួចផ្ទាំវាដូរដូង ខ្ញុំខឹងណាស់ ។

ប្ដីស្ដាប់មិនឮខឹងនឹងប្រពន្ធជេរថា មេចោរគ្រហាងឯងប្រចណ្ឌអញអីម្ល៉េះ អញមិនស្លៀកពាក់តែងតួដើរលេងចង់ស្រីឯណា អញទៅកាប់ឈើធ្វើរបងទេតើ អញអត់តែម្ដងនេះទេ ក្រោយៗ បើហាងឯងនៅតែស្ដីប្រចណ្ឌអញទៀត មុខជាអញធាក់អោយដួលទាំងជំហរមិនខាន ហាមប្រពន្ធហើយបរិភោគបាយរួចទៅចងសន្ទូចបានត្រីត្រឡប់មកផ្ទះវិញ វេលាថ្ងៃល្ងាច ប្រពន្ធក៏ធ្វើត្រីស្ល-អាំងអោយប្ដីបរិភោគខ្លះ រំលែកទុកព្រឹកខ្លះ ដើម្បីនឹងធ្វើសំរាប់យកទៅប្រគេនលោកកូនឯវត្ត និងកូនប្រុសតូចម្នាក់អោយនៅរៀនអក្សរជាមួយនឹងលោកបងនោះ ។

លុះព្រឹកឡើង ម្ដាយនោះដាំបាយដួសដាក់ មានម្ហូបពីល្ងាចស្រាប់ ទូលយកទៅដល់កុដិប្រគេនលោកកូន ហើយនិយាយថា ខ្ញុំករុណារលីកលោកកូនណាស់

មួយទៀត ប្អូនតូចនោះ តើរៀនអក្សរគ្រាន់បើឬទេ លោកកូននោះមាន ពុទ្ធដីកាថា ចំរើនពរញោម អាត្មាសព្វថ្ងៃនេះកំពុងស្រឡាញ់សីលធ្ងន់ណាស់ អាត្មាមិនសឹកទេ ម្តាយក៏ហៅកូនតូចដែលនៅបំរើបងនោះថា អានាងលាលោកបងទៅផ្ទះនឹងម្តាយ បានមួយថ្ងៃ ពីរថ្ងៃសិន ដ្បិតឪឯងរលឹកណាស់ អាកូនតូចឆ្លើយប្រាប់ម្តាយថា ត្រី ងៀតលោកបងនៅពីរកន្ទុយទុកក្នុងកុដិ ពេលល្ងាច ខ្ញុំយកពីរចំរៀកដុតស៊ីបាយ ដែលសល់ពីលោកឆាន់ពេលព្រឹកនោះ ។

ឯលោកសង្ឃដែលគង់នៅជិតកុដិប៉ុន្មាន១ បានឮម្តាយលោក និងកូន និយាយតែដោយខ្លួន មិនទទួលសំរុងគ្នាដូច្នោះ លោកទាំងអស់ទប់ពុំបាន ក៏សើច ទ្រហឹងអឹងអាប់ ឯសិកានោះក៏សំពះលាលោកកូនត្រឡប់ទៅដល់ផ្ទះវិញ ហើយលុត ជង្គង់ជូនបុណ្យប្តីថា ខ្ញុំជូនបុណ្យអ្នកផង ប្តីឆ្លើយថា អើអញឃើញបាយសម្ល ខ អាំង ព្យួរទុកនៅសង្រែក អញស៊ីអស់ទៅហើយ ប្រពន្ធក៏មើលមុខប្តី ប្តីមើលមុខប្រពន្ធ ប៉ប្រិចភ្នែកម៉ក់១ធ្វើវាហីតែដោយខ្លួន លុះយូរបន្តិច ស្រាប់តែប្អូនស្រីបង្កើតខាងប្តី នៅភូមិដទៃឆ្ងាយមកដល់ បានផ្ញើពងមួយផ្តិល និងស្លឹកប្រស់ស្វាមួយសំណុំមកផ្ញើ បង ហើយនិយាយសួរបងថា បងបានភ្ជួររាស់ដកស្ទូងបានស្រែប៉ុន្មានហើយ នោះ បងទាំងប្តីប្រពន្ធឆ្លើយប្រាប់ទៅប្អូនស្រីវិញថា អើហាង ល្មមទុកដាក់អោយវាមានប្តី ទៅចុះ តែហាងមើលកុំអោយតែចេះលេងបៀ ផឹកស្រា ជក់អាភៀន ។

នោះមេប្អូនស្តាប់មិនឮទៀត និយាយឆ្លើយប្រាប់ទៅបងទាំងពីរនាក់ថា ខ្ញុំ ស្តាយត្រឡាចខ្ញុំមួយទ្រើងណាស់ កំពុងតែផ្កាក្តិបតូច១ ស្រាប់តែមេជ្រូកវាទៅឈ្លូស គល់ដាច់ងាប់អស់ បងទាំងពីរនាក់ថា អើហាងល្មមទៅផ្ទះក៏ទៅចុះ ល្ងាចណាស់ ហើយ ក្រែងកូនវាយំរក ប្អូនស្រីនោះក៏ត្រឡប់មកផ្ទះវិញ ។

# ក្បាលដំរីស្រុក និង ក្បាលដំរីព្រៃ

មានរឿងមួយដំណាលថា មានថ្ងៃមួយនោះ នាសម័យពីមុន មិនទាន់ជាយូរប៉ុន្មានទេ នៅក្នុងខេត្តកំពង់ឆ្នាំយើងនេះ មានចៅហ្វាយស្រុកម្នាក់ បានជិះដំរីជាមួយមេឃុំរបស់លោក ដើម្បីទៅទារពន្ធពីប្រជារាស្ត្រដែលរស់នៅក្នុងភូមិមួយឈ្មោះហៅថា ភូមិក្បាលដំរី ។ ដោយហេតុតែកាលនោះ ប្រទេសកម្ពុជាយើងសម្បូរព្រៃឈើពេក ខណៈដែលលោកទាំងពីរនាក់បរដំរីលេចវាលចូលព្រៃ បត់បែនចុះឡើងតាមផ្លូវលំនានា លោកមេឃុំហាក់ដូចជារកចំណាំមិនបាន ក៏ទៅជាច្រឡំផ្លូវបណ្តាលឱ្យវង្វេងនៅក្នុងព្រៃធំមួយ ។ នៅពេលដែលលោកទាំងពីរនាក់កំពុងផ្សងព្រេងរកផ្លូវទៅកាន់ភូមិនោះមិនឃើញ, ជួនជាជួបមាណពម្នាក់ ស្លៀកពាក់តាមទម្លាប់ជាកសិករ កំពុងពុនជ័រទឹកមួយបំពង់យ៉ាងធំល្មម ។ មាណពនោះដើរក្នុងដំណើររាងកោងខ្នងបន្តិច ដើម្បីទប់ខ្លួនឱ្យមានលំនឹងជាមួយនឹងទម្ងន់ជ័រទឹក ។

កាលបើបានឃើញមាណពនោះហើយ លោកចៅហ្វាយស្រុកត្រេកអរខ្លាំងណាស់ ។ លោកយល់ថា ទោះបីជាយ៉ាងណាក៏ដោយ ក៏មាណពនោះប្រាកដជាស្គាល់អស់ទីកន្លែងនៅម្តុំនោះជាមិនខាន ។ គិតដូច្នោះហើយ លោកក៏ប្រញាប់ស្រែកហៅទៅមាណពនោះថា :

" នែ ! អ្នកពុនជ័រ ! "

អ្នកពុនជ័រ ឮគេស្រែកហៅដូច្នោះ ទោះបីជាមិនចំឈ្មោះខ្លួនក៏ដោយ ក៏យល់យ៉ាងច្បាស់ថា មានគេហៅខ្លួនហើយ ។ មាណពនោះ ក៏ឆ្លើយទាំងមិនបានជាគិតថា :

« អើ ! បាទ ! ហៅខ្ញុំឬ ? ហីហៅមានការអីដែរ ?

- អើ ! អញនេះជាចៅហ្វាយស្រុកណាំ ! អញហៅឯង ព្រោះអញមានការចង់សួរឯងបន្តិចណាំ ! ។

- អូបាទ ! សូមអភ័យទោសព្រះតេជព្រះគុណ ។ ខ្ញុំបាទអត់ដឹងថា ព្រះតេជព្រះគុណជាចៅហ្វាយស្រុកទេ ! សូមព្រះតេជព្រះគុណ មេត្តាអនុគ្រោះចំពោះខ្ញុំបាទផង ទាន !

- អើ ! វាគ្មានជាការទាស់ខុសអីទេ គ្រាន់តែប៉ុណ្ណឹងនោះ ។ មើល៍ ! ឯងជួយប្រាប់អញផងមើល អញចង់ដឹងថា ក្បាលដីរនៅឯណា ? »

ឮសំណួរនេះភ្លាម មាណពមិនបានជាគិតវែងឆ្ងាយ ក៏លើដៃចង្អុលចំទៅក្បាលដីរដែលលោកចៅហ្វាយស្រុកនិងមេឃុំកំពុងជិះនោះ ទាំងចិត្តដ៏សែនបរិសុទ្ធរួចហើយក៏ឆ្លើយដោយត្រង់ៗតែម្តងថា :

« បាទទាន ! មិនអីនោះ នៅចំពីខាងមុខព្រះតេជព្រះគុណអង្គុយហ្នឹង ! ហ្នឹងឯងហើយក្បាលដីរនុ៎ះ ទានប្រោស ! » ។

លោកចៅហ្វាយស្រុកគិតថា សម្តីរបស់មាណពនេះ គឺជាការឆ្លើយចំអកឡកឡឺយ លែបខាយលេងសើចផង និងជាការឆ្លើយបញ្ឆោះបន្ទោកមកលើសំណួរដ៏ប្រាកដប្រជារបស់លោកផង ។ លោកក៏និយាយបញ្ឆាក់ទៅកាន់អ្នកពុនជ័រម្តងទៀត ។ លើកនេះ លោកតម្លើងសំឡេងបែបធ្ងន់បន្តិច ក្នុងបំណងធ្វើឱ្យបុរសនោះមានការកោតខ្លាចខ្លះ ហើយឈប់ឆ្លើយលេងជាល្បែងដូច្នេះតទៅទៀត ថា :

« នែ ! ដែលអញសួរឯងពីក្បាលដីរនេះ មិនមែនក្បាលដីរព្រៃទេណាំ ! អញសួរពីក្បាលដីរហ្នឹង គឺក្បាលដីរស្រុកណាំ !

- បាទទាន ! ក្បាលដីរព្រៃ ក៏ដូចក្បាលដីរស្រុកដែរ នៅត្រង់ហ្នឹងដូចគ្នា » មាណពអ្នកពុនជ័រឆ្លើយតបទៅលោកចៅហ្វាយស្រុកវិញ ប្រកបដោយទឹកចិត្ត

ដ៏សែនបរិសុទ្ធ សែនស្មោះត្រង់បំផុត ដូចមុនដដែល ។

លោកចៅហ្វាយស្រុកមិននឹកស្មានថា មាណពនោះនៅតែហ៊ានប្រើសម្ដីឡកឡឺយជាល្បែងលេងជាមួយលោកបែបនេះទៀតសោះ ។ លើកនេះ ដោយនឹកខឹងនឹងមាណពនោះខ្លាំងពេក លោកក៏ប្រើសម្ដីខ្លាំងៗ ដៀលទៅកាន់មាណពតុនជ័រថា ៖

« នែ ! អាតុនជ័រ !

- បាទ ទាន !

- អាឯងអីក៏កោងម្ល៉េះ អ្ហ៎ ?

- បាទទាន មកពីខ្ញុំតុនជ័រ ! » ។

***

**សុភាសិត**

• ស្មៅចិញ្ចៀន វៀនដុះផុង ក្នុងវារី

នៅសល់ពី ទឹកជ្រៅ បានពីរផ្ទាប់ ខ្យល់បក់បោក ខោកឥតស្រាក ងាកវេជាប់

នៅមិនងាប់ ជាប់រហូត លូតឡើងបាន ។

• ជនបណ្ឌិត ពិតពិរោះ ឈ្មោះឥតអាក់

មានឧបសគ្គ ស្ទាក់រារាំង ទាំងប៉ុន្មាន ប្រឹងរុករាន ឈានឥតខ្សោយ ដោយក្លាហាន

ត្រាតែប្រាណ បានរួចទុក្ខ សុខដូចស្មៅ ។

**សេខ នាង**

# បទរលកខ្ទប់ច្រាំង

*វាចារំលឹក*

នៅក្នុងពាក់កណ្តាលទសវត្ស ៦០ នៃគ.ស. ខ្ញុំបានអានអត្ថបទកំណាព្យរបស់លោកកវីនិពន្ធ អៀង សាយ ដែលមានឈ្មោះថា « បទរលកខ្ទប់ច្រាំង » ។ ខ្ញុំបានសង្កេតឃើញថាបទនេះ ក្រៅពីការចាប់ចុងចួនតាមក្បួនរបស់វា នៅមានការពិរោះ ព្រោះមានការរណ្តំគ្នានៃពាក្យទាំងឡាយ ។ ជាអកុសល ខ្ញុំមិនបានចាំអត្ថបទដើមនៃកំណាព្យរបស់លោក អៀង សាយ ទេ ខ្ញុំនៅចាំបានតែមួយឃ្លាប៉ុណ្ណោះ ដែលជាទុនសម្រាប់ឱ្យខ្ញុំដឹងថា បទរលកខ្ទប់ច្រាំងត្រូវតាក់តែងរបៀបណា ។

ដើម្បីជាជំនួយក្នុងការរក្សាវប្បធម៌របស់ខ្មែរយើង ខ្ញុំក៏បានតាក់តែងកំណាព្យនេះឡើង គ្រាន់នឹងទុកជាគំរូផង ជាការអានកំសាន្តលេងសម្រាប់ជនានុជនទាំងឡាយ ដែលមានចិត្តស្នេហាចំពោះវប្បធម៌របស់ខ្លួនផង ។

បទរលកខ្ទប់ច្រាំង គឺជាបទកំណាព្យដែលចែកចេញជាបួនឃ្លា ក្នុងមួយឃ្លាៗ មានប្រាំបួនព្យាង្គ ( បទពាក្យ ៩ ) ហើយមានការបែងចែកលំអិតពីការចាប់ចុងចួន និងការរណ្តំគ្នានៃពាក្យ ដូចតទៅ ៖

- ព្យាង្គទី៣ និងព្យាង្គទី៤ នៃឃ្លាទី១ ចួនគ្នា
- ព្យាង្គទី៦ និងព្យាង្គទី៧ នៃឃ្លាទី១ ចួនគ្នា
- ព្យាង្គទី៩ នៃឃ្លាទី១ និងព្យាង្គទី៣ នៃឃ្លាទី២ ចួនគ្នា
- ព្យាង្គទី១ និងព្យាង្គទី៤ នៃឃ្លាទី១ សូរស័ព្ទដូចគ្នា (ឬ ព្យញ្ជនៈដូចគ្នា)
- ព្យាង្គទី២ និងព្យាង្គទី៥ នៃឃ្លាទី១ សូរស័ព្ទដូចគ្នា (ឬ ព្យញ្ជនៈដូចគ្នា)
- ព្យាង្គទី៣ និងព្យាង្គទី៦ នៃឃ្លាទី១ សូរស័ព្ទដូចគ្នា (ឬ ព្យញ្ជនៈដូចគ្នា)

ហើយតែដូច្នេះជារៀងរហូតទៅចំពោះឃ្លាបន្តបន្ទាប់ តទៅទៀត ។



## បទរលកខ្ទប់ច្រាំង ទី១

### ពាល និង បណ្ឌិត

វីពាលពិត វីតពេញពាល រាលឡើងធំ ជួបជាមុំ ជុំជាមិត្ត គិតរឿងខ្លៅ
ឥតមានខ្លាច អាចមាត់ខ្លាំង តាំងឃោរឃៅ ទោះប្រដៅ ទៅប្រដេញ ពេញអសារ ។
ពួជអ្នកល្ងង់ ពង្សអ្នកល្ងើ បើធ្វើធំ ជួញគំនុំ ជុំគំនិត វីតផ្តាច់ការ
ពួកអស់ហ្នឹង ពឹងអំនួត អួតអាងថា ខ្លួនអស្ចារ្យ ក្លាអស់ចិត្ត ឥតមើលគេ ។
អ្នកចេះដឹង នឹងចេះដោះ អស់បញ្ហា បើមានការ បាមកកាន់ គ្រាន់ជាមេ
មានគំនិត មិត្តគំនាប់ ផ្គាប់ផ្គុនទ្វេ គួររិះរេ គេរាប់រក យកជានាយ ។
ចេះតាមក្បួន ចួនតាមច្បាប់ ស្រេចថាចេះ រៀនរួចត្រិះ រិះរកត្រូវ ទៅបានឆ្ងាយ
ចេះមិនឆោត ចោតមិនឆេះ ចេះសប្បាយ ចេះមិនក្លាយ ចាយមិនខ្លាច ប្រាជ្ញាកើន ។

***

## បទរលកខ្ទប់ច្រាំង ទី២

នាយសមសួន នួនសាច់ស កវែងសម រាងមូលក្លំ រាំមិនក្លាយ សាយអស់អង្គ
ដើរទន់ល្វៃ ដៃទន់ល្វក់ សក់ខ្មៅយង់ វីពួជពង្ស រុងពន់ពេក ប្លែកលើសស្រី ។
បងស្រឡាញ់ បាញ់ស្រឡះ ប៉ះលើស្ងួន ចាំឱ្យនួន ជូនរាណិត ចិត្តបេតី
ប្រាប់ឪម៉ែ ប្រែឱ្យមក លកលៃស្តី បានស្រស់ស្រី បីស្រួលស្រេប ផើបនែបនិត្យ ។

***

# ក្រៀលដៀលក្រួច

កាកគតិ

* ថ្ងៃត្រង់គ្រលួច ស្តាប់ក្រៀលដៀលក្រួច តាមភាសាសត្វ
ក្រួចសោតក៏គ្រាន់ មិនអន់ស្មៀមស្ងាត់ ដៀលក្រៀលវិញថ្វាត់
ថ្វីមាត់ទាំងទ្វេ ។

* ពាក្យក្រៀលដៀលក្រួច ថាមាត់ក្រហួច ទាបតូចម្ល៉េះទេ
ហើរហោះមិនខ្ពស់ រស់ត្បុលក្រោមទេ ទាំងពងទាំងមេ
ត្រូវគេក្លែមស្រោ ។

* អញពូជពង្សក្រៀល ហៀវហោះឆ្ងាត់ឆ្ងៀល នៅលើវេហាស៍
ទ្រនំអញខ្ពស់ លើចុងរុក្ខា អញស៊ីមំសា
មច្ឆាតូចធំ ។

* ឯងក្រួចអន់អាប់ រស់ដូចជាស្លាប់ យ៉ាប់ឥតទ្រនំ
ពេលព្រៃស្បូវឆេះ ម្ល៉េះឯងទូញយំ ក្នុងភ្លើងក្តៅធំ
ទាំងក្រុមគ្រួសារ ។

* ថ្ងៃបាក់រសៀល ក្រួចឮដំនៀល ដៀលក្រៀលវិញថា
ក្រៀលអើយក្រៀលគ្រោង ឃ្លោងតែអាត្មា អាប់ឥតប្រាជ្ញា
នរណាខ្លាចឯង ។

* ខ្លួនធំមែនពិត តែបើពិនិត្យ ឥតអ្វីឱ្យក្រែង
ទាំងកទាំងជើង ស្តើងដូចដើមព្រែង ងាយណាស់ព្រះស្តែង
តែងជាប់ជង់គេ ។

* ឯងអាងហោះហើរ តែពេលឯងដើរ លំបាកម្ល៉េះទេ
លើកជើងលបៗ ដូចទៅលួចគេ ម្ដេចមិនគិតគ្មេរ
បែរជាជេរអញ ។

* អញរត់អញហើរ តាមចិត្តចង់ប្រើ សីងលឿនត្រចាញ់
ត្បុលព្រៃស៊ិបទ្រុប វាងលុបសំណាញ់ គេចព្រានប្រមាញ់
ចាប់អញពុំបាន ។

* សត្វក្រៀលជៀលក្រួច ក្រួចមាត់ក្រហួច ក្របួចវិញថ្កាន
ម្នាក់ៗមិនអន់ សីងគ្រាន់គ្រប់ប្រាណ នេះហើយសន្តាន
ជាតិមនុស្សអួតអាង ។

* មនុស្សអញនិយម តម្កើងឫកធំ ចរិតក្អេងក្អាង
ដូចក្អាត់ក្នុងក្អម មិនព្រមភ្លឺស្វាង មនុស្សចេះដោយយ៉ាង
សងខាងឫកគ្នា ។

* ពាក្យចាស់ពោលថា បណ្ឌិតអាចារ្យ ត្រូវចងសាមគ្គា
វីអ្នកចេះច្រើន ចម្រើនវិជ្ជា តោងចិត្តសាធារណ៍
ជួយគ្នាល្ងិតល្ងង់ ៕

21 - 11 - 98

**ចរណ្ណ ស៊ិនហេង**

## កម្រងកំណាព្យ

# វប្បធម៌សន្តិភាព

បុរាណលោកបានស្តីប្រដៅ
រស់ក្នុងសង្គមវឱ្យនធមិ
ចេះគួរចេះសមចេះរាក់ទាក់
ចេះរស់ចេះរកចេះតស៊ូ
ជួបគ្នាចេះលើកដៃសំពះ
ចាស់ជូនពរវិញអោយរងំ
ខុសឆ្គងលើគេចេះសុំទោស
ចាកផុតគំនុំទៅថ្ងៃមុខ
សង្គមរស់នៅបានស្ងប់សុខ
រកស៊ីមានបានទ្រព្យសែនសល់
សង្គមឥឡូវខុសឆ្ងាយណាស់
ប្រព្រឹត្តអាក្រក់វង្វេងធមិ
ម៉ែឪបញ្ជូនទៅសាលា
អោយកសាងខ្លួនជាអ្នកបុណ្យ
តែខ្លះគេចវេះពីសាលា
ផឹកស្រាវាំវែកភ្លេចលំនៅ
ខ្លះទៀតធ្លាក់ខ្លួនកាន់តែងប់
បង្កើតក្រុមពាលដើររុកគួន

អប់រំកូនចៅអោយធ្វើល្អ
ទោះមានឬក្រតែថ្លៃថ្នូរ ។
យកចិត្តទុកដាក់ជាគំរូ
ចេះគិតចេះគួរចេះគួរសម ។
ក្មេងគោរពចាស់ដោយសមរម្យ
សុំអោយបានជួបតែក្តីសុខ ។
សុំការសន្តោសអោយផុតទុក្ខ
ទើបសេចក្តីសុខកើតមានដល់ ។
ប្រាសចាកក្តីទុក្ខក្តីកង្វល់
ព្រោះផលបានមកពីសីលធមិ ។
ក្មេងលែងស្គាល់ចាស់លែងស្គាល់ល្អ
ឃើញខ្មៅថា ស ភ្លេចបាបបុណ្យ ។
អោយខំសិក្សាធ្វើជាទុន
ស្គាល់ទោសស្គាល់គុណស្គាល់រាក់ជ្រៅ ។
ចូលបារាំច្រៀងលុះយប់ជ្រៅ
ម៉ែឪខ្វាយខ្វល់ព្រោះចាំកូន ។
សេពគប់មិត្តភក្តិដើរខុសក្បួន
ជួនប្លន់ជួនលួចជក់គ្រឿងញៀន ។

ម៉ែឪនៅផ្ទះពុំបានដឹង    រំពឹងថាកូនបានទៅរៀន
អោយលុយអោយកាក់តាមខ្លួនមាន    កូនមិនទៅរៀនទៅតែជា ។
រំពឹងលើគ្រូប្រាក់ខែតិច    រកល្បិចដោះស្រាយតែគ្រូសារ
បើកបង្រៀនគួរយកដុល្លារ    សិស្សណាមករៀនបានលេខល្អ ។
សិស្សណាមិនរៀនបានពិន្ទុតិច    ជាល្បិចរកប្រាក់តាមមានក្រ
បង្កអំពើអយុត្តិធមិ    អ្នកក្ររៀនធ្លាក់អ្នកមានជាប់ ។
អុះឱ ! កូនខ្មែរទាំងប្រុសស្រី    ឋិតក្នុងយុវវ័យត្រូវអោយគាប់
សុភាពរាបសារតាមទម្លាប់    រៀនគាប់រៀនគួររៀនធ្វើសម ។
ជាកុលបុត្រខ្មែរខ្សែអង្គរ    រុងរឿងបវរដ៏ឧត្តម
កសាងប្រាសាទដ៏ស្កុកស្គម្ភ    គ្រប់ជ្រុងជ្រោយមុំសមជាខ្មែរ ។
ប្រាសាទបាយ័នមានមុខបួន    ប្រាសាទបាពួនជាហួរហែ
ញញឹមប្រិមប្រិយសម្រស់ខ្មែរ    រួចបែរសំដៅទិសទាំងបួន ។
• បង្ហាញនូវទឹកចិត្តមេត្តា    ស្រឡាញ់រាប់គ្នាជាបងប្អូន
ខុសឆ្គងសន្តោសអោយសោះសូន្យ    ល្អួកល្អួនស្មោះស្ម័គ្រគ្រួមមេត្រី ។
• ករុណាអាណិតចិត្តសន្តោស    បើមានទុក្ខទោសជួយប្រណី
ជួយអោយផុតទោសបានសេរី    សួស្តីមង្គលវិបុលសុខ ។
• មុទិតារក្សាចិត្តបានល្អ    អបអរសាទរមិនរើសមុខ
ដល់ជនដទៃដែលផុតទុក្ខ    បានសុខរកស៊ីកើតមានបាន ។
លះបង់នូវចិត្តពាលឫស្យា    ច្រណែននិន្ទាញាតិសន្តាន
លោភលន់រិះគន់កើតរំខាន    មិនអោយគេបានក្តីសុខា ។
• ឧបេក្ខាគឺការមិនលំអៀង    មានចិត្តវៃវៀងដោយបញ្ញា
បំបាត់អគតិពីកាយា    ចាប់យកធម្មាជាទីអាង ។

បំបាត់នូវឆន្ទាគតិ អោយចេះត្រិះរិះរកភស្តុតាង
គួរយកសមត្ថភាពជាទីអាង កុំលើកតម្កើងព្រោះស្រឡាញ់ ។
កុំអោយលំអៀងព្រោះតែស្អប់ បន្ទុះបង្អាប់ដោយគ្មាន់ខ្ញាញ់
អ្នកនេះមិនមែនបក្សពួកអញ ផ្ចាញ់គ្នាដោយទោសាគតិ ។
មួយទៀតលំអៀងព្រោះមិនយល់ មិនខ្វល់មិនគិតមិនត្រិះរិះ
ដោយសារខ្លួនឯងគ្មានចំណេះ ច្រណែនអ្នកចេះដេញគេចោល ។
ខ្លះទៀតលំអៀងព្រោះភ័យខ្លាច ស្ថិតក្រោមអំណាចជនកំរោល
កំរើកតែខ្លួនដូចស្រមោល ច្បោលៗផ្ដាប់ចិត្តតែចៅហ្វាយ ។
នេះគឺអគតិធម៌ទាំងបួន បើនៅជាប់ខ្លួននាំអន្តរាយ
ខូចទាំងការងារស្លាប់ទាំងកាយ គួរចៀសអោយឆ្ងាយកុំអោយបៀត ។
ព្រះពុទ្ធលោកតែងប្រៀនប្រដៅ សាសនិកទូទៅខំខ្មីឃ្មាត
អោយយកព្រះធម៌ធ្វើជាញាតិ រាប់រកកុំឃ្លាតកុំវង្វេង ។
លោកអោយលះបង់ក្ដីលោភៈ លោភលន់ឥតអាក់កាប់ចាក់គ្នា
ចង់បានទ្រព្យគេធ្វើចិត្តមារ កាប់សម្លាប់គ្នាគ្មានប្រណី ។
ទោសៈគឺការខឹងក្រេវក្រោធ ដោយក្ដីល្ងង់ឆោតភ្លេចខន្តី
គុំគួនរករឿងជនដទៃ នាំទោសនាំពៀរដល់អាត្មា ។
មោហៈគឺក្ដីភ្លាតវង្វេង វិលវល់ឥតក្រែងដល់អ្នកណា
មើលឃើញលាមកថាជាផ្កា នាំក្ដីទុក្ខាទៅអវិចី ។
រីឯកាយកម្មការប្រព្រឹត្ត អំពើទុច្ចរិតគឺមានបី
ការកាប់សម្លាប់អ្នកដទៃ នាំក្ដីគុំគួននាំជាប់គុក ។
មួយទៀតលួចប្លន់ទ្រព្យធនគេ ព្រះមិនជួយទេនាំតែទុក្ខ
ត្រូវគេចាប់ចងទៅដាក់គុក កើតទុក្ខខូចឈ្មោះផៅសន្តាន ។

មួយទៀតរំលោភលើរាងកាយ នាំអោយអន្តរាយចិត្តសាមាន្យ
វាយដំច្រំធាក់លើខ្លួនប្រាណ ព្រះមិនប្រទានលើកទោសា ។
រីឯវចីកម្មក៏មានបួន កម្មកើតផ្ទួនៗព្រោះវាចា
និយាយកុហកដោយមុសា អោយគេសោកាព្រោះតែខ្លួន ។
ឬក៏ញុះញង់អោយប្រេះឆា បែកបាក់ព្រាត់គ្នាពុំសមសួន
អោយគេឃ្លាតគ្នាដើម្បីខ្លួន កើតក្ដីគុំគួនលុះមរណា ។
ខ្លះទៀតគ្រេវគ្រោធកើតមោហៈ ភ្លេចការរាក់ទាក់សុវាចា
ទ្រគោះបោះបោកដោយទោសា ភ្លេចថាគេឈឺចាប់ពេកក្រៃ ។
គេមិនតបតព្រោះគេខ្លាច តែជនកំណាចគំនិតខ្លី
វាអាចតតប ឬដាល់វៃ កើតរឿងអប្រិយខ្មាសគេឯង ។
ខ្លះទៀតនិយាយមិនបានការ បញ្ចេញវោហារអោយគេក្រែង
ក្អេងក្អាងដូចក្អាត់ឥតខ្លាចក្រែង ខ្លួនឯងរស់ក្នុងត្លុកក្របី ។
ដើរភរដើរភូតដើរបោកប្រាស ខំដើរបញ្ឆោសច្បាប់លោកីយ
មិនគិតថាខ្លួនអាយុខ្លី មានថ្ងៃគេធ្វើទុក្ខទោសា ។
រីឯមនោកម្មក៏មានបី ចិត្តមិនប្រក្រតីដោយប្រាថ្នា
សម្លឹងរំពៃនឹកគិតថា ត្រូវធ្វើយ៉ាងណាដើម្បីមាន ។
ខ្លះទៅមានចិត្តចង់ឆបោក ប្រព្រឹត្តល្មោភគ្រោកទាំងបំពាន
បំបាត់ទ្រព្យគេមកធ្វើមាន ខ្លះហ៊ានសម្លាប់ចាប់ទារប្រាក់ ។
អំពើទាំងនេះខុសផ្លូវច្បាប់ ដោយចិត្តបង្អាប់ភ្លេចធម្មៈ
ត្រូវច្បាប់ចាប់ចងដាក់ច្រវាក់ ស្លាប់ទៅនឹងធ្លាក់ដល់អវចី ។
នេះជាកំហុសមកពីចិត្ត ដែលគិតលោភលន់ខុសប្រក្រតី
បាត់បង់សីលធម៌ច្បាប់លោកីយ ធ្វើអ្វីតាមចិត្តវាបញ្ជា ។

ព្រះពុទ្ធលោកបានប្រៀបប្រដៅ យកឈ្នះចិត្តខ្មៅដោយធម្មា
ត្រិះរិះពិចារណាគ្រប់ៗគ្នា កុំវាកុំរេកដើរខុសផ្លូវ ។
ខ្មែរយើងរងទុក្ខមករាប់ឆ្នាំ ដោយកម្មកើតមកពីល្ងង់ខ្លៅ
ដណ្តើមអំណាចដណ្តើមត្រូវ កើតរឿងអាស្រូវច្បាំងគ្នាឯង ។
រីអ្នករងគ្រោះគឺរាស្ត្រខ្មែរ ទីក្រុងស្រុកស្រែសែនចំបែង
ច្របូកច្របល់គ្រប់កន្លែង រាស្ត្ររាប់ម៉ឺនសែនស្លាប់ពិការ ។
ព្រាត់ប្រាសបងប្អូនញាតិសន្តាន គ្មានពេលសុខសាន្តរងទុក្ខា
នេះជាកំហុសលោកអ្នកណា អោយរាស្ត្រខេមរាសែនវេទនា ។
កំហុសកើតមកពីពុំគិត យកចិត្តចចេសគ្រប់ៗគ្នា
ពុំគិតដោះស្រាយតាមធម្មា សាមគ្គីរួមគ្នាទើបជាតិរស់ ។
យករាស្ត្រធ្វើជាតុលាការ ដោះស្រាយបញ្ហាដ៏ខ្ពង់ខ្ពស់
ប្រជាធិបតេយ្យមកជំនួស ដោះស្រាយជម្លោះដោយបោះឆ្នោត ។
អោយរាស្ត្រសំរេចយកបក្សណា សូមកុំស្មានថារាស្ត្រលោកឆោត
បក្សណាធ្វើល្អរាស្ត្រលោកកោត បោះឆ្នោតជូនលោកអោយដឹកនាំ ។
នេះហើយដំណោះស្រាយបញ្ហា ដោយអហិង្សាតាមលំនាំ
ប្រជាធិបតេយ្យដ៏សក្តិសម សន្តិភាពរឹងមាំជូនដល់ជាតិ ។
ថ្ងៃទី ២៦ ខែកក្កដា គឺជាទិវាប្រជាជាតិ
ប្រជាខេមរាប្រឹងខ្មីឃ្មាត នាំគ្នាប្រជ្រៀតចូលបោះឆ្នោត ។
ជ្រើសរើសសភាតំណាងរាស្ត្រ ដើម្បីបញ្ចៀសនូវពាក្យចោទ
ធ្វើតាមរបៀបធ្លាប់ពិសោធន៍ ពិភពលោកកោតខ្មែរធ្វើល្អ ។
ពុំមានកើតឡើងនូវហិង្សា ទាំងការឃោសនាក៏រ៉ូវរអរ
ដំណើរប្រព្រឹត្តដោយយុត្តិធម៌ កម្រជាតិណានឹងធ្វើបាន ។

ទាំងនេះបង្ហាញនូវទឹកចិត្ត     រាស្ត្រខ្មែរលោកពិតជាចង់បាន
នូវសន្តិភាពសុខក្សេមក្សាន្ត     ជួបជុំសន្តានញាតិប្រុសស្រី ។
សាមគ្គីកសាងប្រទេសជាតិ     អោយបានផុតឃ្លាតពីទុក្ខភ័យ
ពីភាពទុរភិក្សភាពក្រក្រី     កាប់គាស់រានដីធ្វើចំការ ។
ដាំដុះបង្កបង្កើនផល     ជួយផ្តល់បង់ពន្ធជូនរដ្ឋ
ធ្វើការអភិវឌ្ឍន៍ជាតិខេមរា     រុងរឿងថ្លៃថ្លាព្រោះសន្តិភាព ។
រាស្ត្រសូមលើកដៃសូមអង្វរ     ដោយចិត្តស្មោះសរពុំឃ្លៀងឃ្លាត
លោកអ្នកនយោបាយដឹកនាំជាតិ     កុំនាំមកទៀតនូវសង្គ្រាម ។
រាស្ត្រភ័យរាស្ត្រព្រួយរាស្ត្របារម្ភ     ក្រៀមក្រំខ្លោចផ្សាធុំតែឈាម
កំព្រាព្រាត់ប្រាសហើយអត់ឃ្លាន     ពោះវៀនរុំរ៉ៃកើតឈឺផ្សា ។
កូនចៅភ័យខ្លាចពុំបានរៀន     ល្ងង់ខ្លៅរាប់លានគ្មានវិជ្ជា
អនាគតនាំមកក្តីវេទនា     ព្រោះគ្មានវិជ្ជាបំរើការ ។
ប្រទេសបាត់បង់ធនធានមនុស្ស     គ្មានសោះជំនាញក្នុងការងារ
មិនចេះដឹកនាំរាស្ត្រប្រជា     យូរទៅវេទនាកើតអន្តរាយ ។
វិការអភិវឌ្ឍន៍មិនទៅមុខ     ពុំបានក្តីសុខមិនសប្បាយ
អ្នកវិនិយោគទុនផងទាំងឡាយ     ខ្វល់ខ្វាយមិនហ៊ានបណ្តាក់ទុន ។
រដ្ឋាភិបាលគ្មានស្ថិរភាព     ដូចទូកពេញប្រៀបបន្ទុកធ្ងន់
ប្រឹងអុំឆ្លងកាត់ទឹកជំនន់     ភ័យស្លន់ខ្លាចលិចខ្ទេចទាំងជាតិ ។
លទ្ធផលសង្គ្រាមគឺហិនហោច     រងទុក្ខផ្សាខ្លោចឥតឃ្លាឃ្លាត
ហេដ្ឋារចនាសម្ព័ន្ធជាតិ     រវាតខ្ទេចខ្ទីគ្មានសល់អ្វី ។
សល់តែកំទេចផ្ទះបែកបាក់     ពិការគ្រោះថ្នាក់ជនក្រក្រី
ខ្វះទីជំរកខ្វះចំណី     រស់នៅគ្មានន័យគ្មានខ្លឹមសារ ។

ហេតុនេះយើងខ្ញុំសូមលើកដៃ　សូមរតនត្រ័យជួយមេត្តា
ណែនាំចិត្តខ្មែរទាំងអស់គ្នា　ដើរតាមមាគ៌ាសន្តិភាព ។
ចេះយោគចេះយល់ចេះជួយគ្នា　សាមគ្គីសាមគ្គាកុំរវាត
កសាងរដ្ឋបាលរបស់ជាតិ　កុំឃ្លាតពីធម៌អហឹង្សា ។
អាណិតដល់រាស្ត្រលោកភ័យខ្លាច　សង្គ្រាមកំណាចមកផ្គន្ទា
ព្រោះលោកធ្លាប់ជួបក្តីវេទនា　កំព្រាព្រាត់ប្រាសរងទុក្ខា ។
សូមអោយបានសុខបានសេរី　ចាកផុតទុក្ខភ័យក្នុងលោកា
ផុតកម្មផុតពៀរពីជាតិណា　សូមបានសុខាតទៅអើយ ! ៕

**ខឹម សោភ័ណ**

## សុភាសិត

សូវស្តាយបាន ប្រសើរជាងស្តាយបង់ សូវស្លាប់អង្គ ប្រសើរជាងខូចឈ្មោះ ។

ម្យ៉ាងទៀត

សូវមើលសៀវភៅ　ប្រសើរជាងមើលរបាំ
សូវស្តាប់ធម៌ចាំ　ប្រសើរជាងស្តាប់ចម្រៀង
សូវនិយាយធម៌　ប្រសើរជាងនិយាយដៀង
សូវគិតធម៌មិនទៀង ប្រសើរជាងគិតព្យាបាទ ។

**យូរ - អ៊ុន**

# ចម្លើយកំណាព្យប្រស្នា

ចុះក្នុងកម្ពុជសុរិយា លេខ ៤ ខែតុលា-វិច្ឆិកា-ធ្នូ ១៩៩៧

ពាក្យប្រាំពីរ

មុននឹងអធិប្បាយស្រាយប្រស្នា សូមលើកហត្ថាឡើងកំបង់
បង្គំព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ត្រៃរត្នផ្លូវផង់ថ្លៃវិសេស ។
គុណម្ដាយឪពុកផ្ដល់សង្ខារ គុណគ្រូអាចារ្យផ្ដល់ចំណេះ
គុណមិត្តជិតឆ្ងាយស្រាយតម្រិះ ជួយឱ្យចាំចេះចងប្រស្នា ។
តទៅសូមឆ្លើយនូវសំណួរ ដែលសួរចុះក្នុងកម្ពុជសុរិយា
លេខបួនកៅប្រាំពីរខែតុលា កំណាព្យប្រស្នារបស់ខ្ញុំ ។
* « *កើតមកជាមនុស្សទោះប្រុសស្រី អ្នកមានភ្នែកបីថ្លៃឧត្ដម*
*ឈ្មោះថា (ត្រីនេត្រ) ន័យបឋម នោះទើបសក្តិសមអរិយបុគ្គល ។*
* *១ មំសចក្ខុគឺភ្នែកសាច់ កើតមកមានស្រេចយើងងាយយល់*
*ម្នាក់១មានពីរកម្មសិទ្ធិផ្ទាល់ មិនអាចប៉ះពាល់ទិញដូរបាន ។*
* *២ បញ្ញាចក្ខុល្អថ្លៃថ្លា ភ្នែកគឺប្រាជ្ញាជាត្រើយត្រាន*
*មើលឃើញឆ្ងាយជិតឥតសល់ខាន ភ្នែកនេះចំណានគឺចំណេះ ។*
* *៣ ធម្មចក្ខុភ្លឺអនន្ត ភ្នែកគឺអរិយមគ្គជាក់ឥតតិះ*
*លោកុត្តរធម៌ល្អវិសេស ចាកផុតកិលេសផងទាំងពួង » ។*
* នូវនរៈអ្នកឯណា កបដោយកិរិយាអរិយវង្ស
តែងមានភ្នែកបីជួយទ្រទ្រង់ ឆ្លងផុតអន្លង់ចតុរាបាយ ។

21 - 11 - 98

**ចណ្ណ ស៊ុនហេង**

# កិច្ចប្រជុំជាលក្ខណៈគ្រួសារ លើកទី ១ របស់មន្ត្រីសង្ឃជាន់ខ្ពស់ នៃគណៈមហានិកាយ និង មន្ត្រីធម្មការខេត្ត ក្រុង ដើម្បីលើកស្ទួយកិត្យានុភាពនៃពុទ្ធសាសនា



កិច្ចប្រជុំពេញអង្គរបស់មន្ត្រីសង្ឃជាន់ខ្ពស់លើកដំបូង ជាលក្ខណៈគ្រួសារ ដោយមានការនិមន្ត-អញ្ជើញ ចូលរួមពីព្រះរាជាគណៈគ្រប់ថ្នាក់ ព្រះមេគណ និងមន្ត្រីធម្មការគ្រប់ខេត្ត ក្រុង ត្រូវបានបើកធ្វើរយៈពេល ៣ ថ្ងៃ ( ១៦-១៧-១៨ វិច្ឆិកា ១៩៩៨ ) នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្រោមអធិបតីភាពសម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជគណៈមហានិកាយ ។ កិច្ចប្រជុំជាគ្រួសារនោះ គឺការជំរុញអោយកើតមានឡើងនូវការលើកំពស់ការប្រតិបត្តិពុទ្ធសាសនា ក្នុងភាពបរិសុទ្ធ ត្រឹមត្រូវ ម៉ត់ចត់ ក្នុងចំណោមពុទ្ធបរិស័ទ (ភិក្ខុ សាមណេរ គ្រហស្ថ) ទាំងនៅទីក្រុង ទាំងនៅជនបទ ។

នៅក្នុងសង្គថាបើក, សម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជគណៈមហានិកាយ បានមានព្រះពុទ្ធដីកាថា : យើងជាពុទ្ធសាសនិក ទាំងសង្ឃទាំងគ្រហស្ថ សុទ្ធតែមានតួនាទីយ៉ាងធំធេងក្នុងការផ្សព្វផ្សាយរសជាតិព្រះពុទ្ធវចនៈឱ្យបានជ្រួតជ្រាបទូទៅ ដើម្បីជំរុញសេចក្តីលោភៈ ទោសៈ មោហៈ ដែលកំពុងមានឥទ្ធិពលឱ្យបានស្ងប់ សុខដុម ក្សេមក្សាន្ត ដល់សត្វលោកទាំងអស់ ព្រមទាំងស្វែងរកមធ្យោបាយដើម្បីជំរុញ និងលើកស្ទួយសាសនានៃព្រះពុទ្ធបរមគ្រូរបស់យើងឱ្យមានដំណើរទៅកាន់វឌ្ឍនភាពជាស្ថាពរ ក្នុងមាតុភូមិរបស់យើង ។

យើងបានដឹងច្បាស់លាស់ហើយ ពាក្យដែលព្រះពុទ្ធបានប្រៀនប្រដៅនោះថា « ការរួបរួមគ្នានាំអោយមានសេចក្តីសុខ ការបែកបាក់គ្នាជាបក្សពួកនាំឱ្យមានទុក្ខព្រួយ » ជាដើម ។ ប៉ុន្តែ មិនដឹងជាអកុសលអ្វីមកនាំឱ្យយើងជាពុទ្ធសាសនិកដូចគ្នា ដែលនៅក្នុងប្រទេសជាមួយគ្នាក្តី ផ្សេងពីគ្នាក្តី ត្រឡប់ជាមានបក្សពួក មានឈ្មោះផ្សេងពីគ្នាទៅវិញ ។

សម្តេចព្រះមហាសុមេធាធិបតី បានមានពុទ្ធដីកាបន្ថែមទៀតថា ប្រជាជនកម្ពុជា បានគោរពប្រតិបត្តិពុទ្ធសាសនា ព្រោះក្នុងពុទ្ធសាសនា មានអត្ថបទប្រកបដោយខ្លឹមសារយ៉ាងបរិបូណ៌ សំរាប់ណែនាំឱ្យមានសីលធម៌ ឱ្យមានសាមគ្គីភាព និងសន្តិភាព ដែលជាមូលដ្ឋាននៃឯករាជ្យសង្គម ហើយមានអត្ថន័យប្រកបដោយហេតុផល គួរដល់វិចារណញ្ញាណ ។ ព្រះពុទ្ធជាម្ចាស់ ពិតជាព្រះបិតានៃសន្តិភាព មានន័យថាព្រះសង្ឃជាមហាសន្តិបុគ្គល ហើយទ្រង់សំដែងធម៌ដើម្បីសន្តិភាព ដើម្បីរំលត់ភ្លើងទុក្ខ និងភ្លើងកិលេសនៃលោកសន្និវាសពិត១ ។

ពុទ្ធសាសនា ជាសាសនាក្នុងលោកយើងនេះដែលពុំព្រមទទួលនូវជំនឿ ពុំសមហេតុពុំសមផលនោះឡើយ ។ ព្រះធម៌ពុំមែនដូចច្បាប់នៃសាសនា ឯទៀតនោះទេ គឺពុំមែនបង្ខិតបង្ខំឱ្យមនុស្សគោរពតាមដោយឥតពិចារណា ហើយដោយបង្គាប់

ឱ្យមនុស្សនោះជឿដោយងងឹតងងល់ វាជាច្បាប់របស់ព្រះម្ចាស់សួគ៌នោះដែរ ។ កិច្ចប្រតិបត្តិរបស់ពុទ្ធសាសនា ជាការប្រយុទ្ធចំពោះជំនឿពុំមានមូលដ្ឋាន ពុំស្របទៅតាមលំនាំនៃតក្កវិជ្ជា ។

សម្តេចព្រះមហាសុមេធាធិបតី ក៏បានមានពុទ្ធដីកាបញ្ជាក់យ៉ាងច្បាស់ផងទៀត ពីការកត់សំគាល់ឃើញនៅតាមប្រទេសនានាជាច្រើន លើពិភពលោកឥឡូវនេះ តាមរយៈទស្សនកិច្ចនៅក្រៅប្រទេស គឺគេកាន់តែយល់ហើយថា មានតែពុទ្ធ-សាសនាទេ ដែលអាចបំភ្លឺផ្លូវ និងដឹកនាំមនុស្សលោកទៅរកកោះត្រើយសុខក្សេមក្សាន្តបាន ព្រោះពុទ្ធសាសនា ជាសាសនាតែមួយក្នុងលោក ដែលអាចពន្យល់ និងបំភ្លឺបានអំពីបុព្វហេតុនៃទុក្ខ និងបាបកម្ម ព្រមទាំងបង្ហាញនូវឱកាស សំរាប់ស្រាយបញ្ហាអកុសលទាំងអស់នោះបាន ។

ឯកឧត្តម ហៀន វណ្ណារត្ន រដ្ឋលេខាធិការក្រសួងធម្មការ បានសំដែងស្វាគមន៍យ៉ាងកក់ក្តៅចំពោះកិច្ចជួបប្រជុំនេះ ។ ជាការពិតណាស់ គឺមានតែមានភាពអហិង្សា ដែលត្រូវយកមកប្រើជាមួយនឹងធមិសាមគ្គី សំរាប់ការប្រៀនប្រដៅមនុស្សឱ្យទៅបានប្រសើរនោះ ។ ដើម្បីនឹងជំរុញឱ្យការងារព្រះពុទ្ធសាសនារីកចំរើនទាំងការរៀនសូត្រ ទាំងការប្រតិបត្តិបានល្អ ក៏អាស្រ័យមានការអប់រំឱ្យបានខ្ជាប់ខ្ជួនចំពោះព្រះសង្ឃជាមួយធមិសាមគ្គីភាព និងត្រូវរួមគ្នាជាមួយខាងពុទ្ធបរិស័ទផង ។

អង្គប្រជុំបានដំណើរការអស់រយៈពេល ៣ ថ្ងៃ ក្នុងបរិយាកាសរីករាយ ហើយទទួលលទ្ធផលគួរកត់សំគាល់ ។ ឆ្លងតាមសកម្មភាពរបស់អង្គប្រជុំ សមាជិកមន្ត្រីសង្ឃ និងមន្ត្រីធម្មការខេត្ត ក្រុង សុទ្ធតែបានតាមដានស្តាប់ និងត្រិះរិះពិចារណាលើខ្លឹមសារនៃប្រធានបទ និងបទអន្តរាគមន៍របស់មន្ត្រីសង្ឃនានា និងមន្ត្រីធម្មការខេត្ត ក្រុង ដែលបានសំដែងមតិផ្ទាល់ទៅលើការប្រតិបត្តិពុទ្ធសាសនា ព្រមទាំងបាន

រិះគន់ញែកបំភ្លឺ និងផ្តល់យោបល់បន្ថែមទៅលើបាតុភាព និងប្រពលភាពក្នុងជំនឿ និងក្នុងការប្រតិបត្តិធម៌វិន័យរបស់បព្វជិតខ្លះ បានធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងឥទ្ធិពលនៃពុទ្ធសាសនា ដែលមន្ត្រីសង្ឃយើងគ្រប់ថ្នាក់ត្រូវតែដោះស្រាយ កែលំអ និងមានវិធានការម៉ឺងម៉ាត់ ។



សមាជិកអង្គប្រជុំសំដែងមតិទៅលើស្ថានភាពនៃពុទ្ធសាសនា ព្រមទាំងរិះគន់ញែកបំភ្លឺ និងផ្តល់យោបល់បន្ថែមទៅលើវិធានការដែលមន្ត្រីសង្ឃគ្រប់ថ្នាក់ត្រូវយកចិត្តទុកដាក់ និងអនុវត្ត (រូបថត ពុទ្ធសាសនបណ្ឌិត្យ)

ជាទីបញ្ចប់, អង្គប្រជុំបានឯកភាពគ្នាចេញសេចក្តីប្រកាសរួម ដែលមាន ៩ ចំណុច សំរាប់ធ្វើជាគោលការណ៍ប្រតិបត្តិ ដើម្បីជាគុណប្រយោជន៍ដល់ការលើកស្ទួយព្រះពុទ្ធសាសនា សំដៅធ្វើឱ្យព្រះពុទ្ធសាសនា រក្សាបានតម្លៃខ្ពស់ខាងសីលធម៌ និងរក្សាបាននូវទីតាំងរបស់ខ្លួនក្នុងសង្គម ក្នុងភាពបរិសុទ្ធត្រឹមត្រូវ ម៉ត់ចត់តាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាត ។

***

# សេចក្តីប្រកាសរួម
# នៃកិច្ចប្រជុំពេញអង្គមន្ត្រីសង្ឃជាន់ខ្ពស់
# លើកទី ១ នៃគណៈមហានិកាយ

នៅចុងសតវត្សទី ២០ នេះ ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងវិបត្តិមួយដ៏ជ្រៅ និងស្មុគស្មាញក្នុងគ្រប់វិស័យដែលទាក់ទងទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់សង្គម ពោលគឺ សីលធម៌ និងស្មារតី សុខភាព និងជីវភាព គុណភាពបរិដ្ឋាន និងនយោបាយបានផងដែរ ។

គឺក្នុងទស្សនៈវិស័យនេះហើយ ដែលការប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដែលមានអាយុជាង ២០ សតវត្សមកហើយ នៅតែសមស្របសំរាប់បញ្ហារបស់សត្វលោក ក្នុងពេលបច្ចុប្បន្ននេះ ។

ព្រះសង្ឃពុទ្ធសាសនិកកម្ពុជា បានផ្តុំជាអង្គការមួយ មានការចាត់តាំងយ៉ាងរឹងមាំ ហើយបានទទួលការឧបត្ថម្ភពីព្រះមហាក្សត្រ ដែលជាព្រះរាជអគ្គ-សាសនូបត្ថម្ភ និងជាប្រមុខកំពូលរបស់សាសនា ។

រចនាសម្ពន្ធ័ដ៏ជាប់លាប់នេះ ស្ថិតនៅក្រោមការដឹកនាំរួមរបស់សម្តេចព្រះសង្ឃរាជ និងព្រះរាជរដ្ឋាភិបាល ដែលមានក្រសួងធម្មការ និងសាសនា ជាអ្នកទទួលភារកិច្ចដឹកនាំ តម្រង់ទិសការប្រតិបត្តិតាមគោលពុទ្ធសាសនាបីយ៉ាង (*) នៅទូទាំងប្រទេស ។

(*) គោលពុទ្ធសាសនាទាំងបី : ឰសព្វបាបស្ស អករណំ មិនឱ្យធ្វើអំពើអាក្រក់គ្រប់យ៉ាង, កុសលស្សូប-សម្បទា ឱ្យបំពេញកុសល ( អំពើល្អ ) គ្រប់យ៉ាង, សចិត្តបរិយោទបនំ ឱ្យធ្វើចិត្តឱ្យស្អាត ឱ្យបរិសុទ្ធ ។

ដើម្បីផ្តល់កំលាំងដ៏មានប្រសិទ្ធភាពមួយក៏រឹតថែមទៀត ដល់ការរក្សានិងទ្រទ្រង់កិត្យានុភាពនៃពុទ្ធសាសនា និងអ្នកកាន់ពុទ្ធសាសនា ពិសេស ឥទ្ធិពលខាងសីលធម៌ដែលកាន់តែខិនថយមកលើប្រជាជនកម្ពុជា ដែលភាគច្រើនលើសលប់ ជាអ្នកប្រតិបត្តិដ៏ខ្ជាប់ខ្ជួននូវពុទ្ធសាសនា, យើងជាមន្ត្រីសង្ឃខាងគណៈមហានិកាយ នៃកម្ពុជា មាននាទីយ៉ាងធំធេង ក្នុងការ :

១. ថែរក្សា និងផ្សព្វផ្សាយព្រះពុទ្ធវចនៈឱ្យបានជ្រួតជ្រាបទូទៅក្នុងសភាពពិត ដោយខិតខំជំរុញឱ្យមានការសិក្សារៀនសូត្រ និងការប្រតិបត្តិធម៌វិន័យម៉ត់ចត់តាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាត និងច្បាប់របស់រដ្ឋ ។

២. រាំងខ្ទប់រាល់ឧបាយកលទាំងឡាយ ដែលប៉ុនប៉ងយកពុទ្ធសាសនាធ្វើជាមធ្យោបាយបំរើមហិច្ឆតាលោភលន់ ដើម្បីបន្ទាបបន្ថោក ឬបំផ្លាញពុទ្ធសាសនា ។

៣. អប់រំដឹកនាំប្រជាជនឱ្យល់ពីទិដ្ឋធម្មិកត្ថប្រយោជន៍ ឱ្យយល់ពីគោលនយោបាយរបស់ប្រទេស ដើម្បីឆ្ពោះទៅរកការបង្រួបបង្រួមជាតិ កសាងសង្គមជាតិឱ្យរីកចំរើន និងសុខសន្តិភាព ។

៤. ព្រះសង្ឃ និងគ្រហស្ថ គប្បីប្រុងប្រយ័ត្នស្មារតីទៅលើទិដ្ឋភាព នៃ " សេចក្តីទុក្ខ " គឺ :

ក/ ភាពក្រខ្សត់ ទុរភិក្ស ការគាបសង្កត់តាមផ្លូវកាយ ផ្លូវចិត្ត អយុត្តិធម៌ក្នុងសង្គម អំពើពុករលួយ និងអវិជ្ជា ។

ខ/ ពួកមនុស្សដែលប្រព្រឹត្តផ្ទុយនឹងផលប្រយោជន៍ប្រជាជន ពួកអ្នកអុជអាល ញុះញង់ឱ្យបែកបាក់សាមគ្គីជាតិ ពួកអ្នកចូលចិត្តបង្កសង្គ្រាម បង្កឱ្យមានអរិភាពក្នុងសង្គម តាមឧបាយកលដ៏ខ្មៅងងឹតរបស់ពួកគេ ។

៥. ជួយថែរក្សាកេរមរតក អរិយធម៌ វប្បធម៌ ប្រពៃណីជាតិឱ្យបានគង់វង្ស និងល្អប្រសើរ ។ ព្រះសង្ឃត្រូវជំរុះឧបាទាន និងការប្រតិបត្តិណាដែលមាន

មន្ទិលសៅហ្មងដល់ព្រហ្មចរិយធម៌របស់ព្រះអង្គ, ទប់ស្កាត់ឱ្យបាននូវការហូរចូលវប្បធម៌ពាលអាវ៉ាសែពីបរទេស ។

៦. សាលាគណ សាលាអនុគណ និងវត្តទាំងអស់ ត្រូវមានផែនការកម្មវិធីឱ្យបានច្បាស់លាស់ ; គោរពឱ្យបានម៉ឺងម៉ាត់នូវឋានានុក្រម ដែលចាត់តាំងរួចសព្វគ្រប់ហើយ ; រួបរួមគ្នាដើម្បីដោះស្រាយបញ្ហារួម ចៀសវាងការដោះស្រាយទៅតាមបុគ្គល ។ វត្តនីមួយៗ ត្រូវមានការចាត់តាំងគណៈកម្មការខាងផ្ទៃកគ្រហស្ថឱ្យបានត្រឹមត្រូវ សមស្របទៅតាមមូលដ្ឋាននីមួយៗ ។

៧. ចូលរួមធ្វើវិភាគទានយ៉ាងទូលំទូលាយតាមគំនិត និងប្រពៃណីពុទ្ធសាសនា ដើម្បីស្ដាបនា ថែរក្សាបរិដ្ឋានធមជាតិ ដោយក្នុងរយៈពីរទសវត្សចុងក្រោយនេះ មានគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ទាំងធនធានមនុស្ស ទាំងធនធានធម្មជាតិ ដោយសេចក្ដីលោភ និងតណ្ហា និងដោយគំនិតអត្តទត្ថរបស់មនុស្សមួយចំនួនតូច ។ បរិដ្ឋានជាមាតាផ្ដល់កំណើត និងជីវិតឱ្យមនុស្សជាតិ ។

៨. បញ្ហាដែលទាក់ទងនឹងការបួសបន្តពូជសង្ឃ ដែលខ្វះការថែទាំ និងសិក្សាឱ្យបានត្រឹមត្រូវ ជាបញ្ហាគន្លឹះសំរាប់កសាងកំលាំងពិត និងជាកូនសោ សំរាប់ការអភិវឌ្ឍន៍ពុទ្ធសាសនា ; ដាច់ខាតត្រូវជំរុញព្រះសង្ឃ ពិសេស ព្រះសង្ឃដែលនៅវ័យក្មេងឱ្យរៀនសូត្រធម៌វិន័យ ភាសាបាលី ភាសាបរទេស និង ចំណេះវិជ្ជាជីវៈដទៃផ្សេងទៀត ដែលមានប្រយោជន៍ដល់ផ្លូវលោក និងផ្លូវធម៌ ។ ត្រូវរៀនសូត្រគម្ពីរព្រះត្រៃបិដក ដែលក្រសួងបានចែកជូន ពុំមែនសំរាប់តាំងលំអក្នុងទូនោះទេ ។

៩. មន្ត្រីសង្ឃយើងត្រូវបង្កើនការចូលរួមកិច្ចការសង្គម និងកិច្ចការមនុស្សធម៌ឱ្យបានដូចប្រទេសដែលបានអភិវឌ្ឍជឿនលឿនលើពិភពលោក ។ កាយវិការរបស់ព្រះសង្ឃចំពោះប្រជាជន ត្រូវបង្ហាញចេញជាការពិតជាក់ស្ដែង ។ ត្រូវនិមន្តទៅប្រោសសត្វតាមមូលដ្ឋានរបស់វត្តនីមួយៗ ជាប្រចាំតាមការគួរ ។

តាមរយៈការបំពេញការងារខាងលើ វត្តអារាម ពិសេស មន្ត្រីសង្ឃយើង នឹងមានកិត្យានុភាព និងឥទ្ធិពលគ្របដណ្តប់ទៅលើពុទ្ធបរិស័ទ និងសង្គមជាតិ ទាំងមូល ។ នោះការប្រៀនប្រដៅរបស់ព្រះសង្ឃទៅលើសង្គមជាតិ ប្រាកដជា ប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។

ធ្វើនៅវត្តឧណ្ណាលោម, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

សម្តេចព្រះសង្ឃរាជគណៈមហានិកាយ

ព្រះហស្តលេខា និង ត្រា

ព្រះមហាសុមេធាធិបតី **ទេព វង្ស**

សេចក្តីប្រកាសរួមនេះ ត្រូវបានមន្ត្រីសង្ឃគ្រប់ថ្នាក់
ព្រះរាជាគណៈ ព្រះមេគណគ្រប់ខេត្ត ក្រុង ចុះហត្ថ-
លេខាគ្រប់អង្គ ។

**សុភាសិត**

សៀវភៅនេះ ជាគ្រឿងដៃ នៃពួកសេក្ខ
មានចិត្តត្រេក ផ្តេកស្មោះត្រង់ អង្គសិក្ខា
សៀវភៅនេះ ជាមិត្តភក្តិ អ្នកសិក្សា
ដែលប្រាថ្នា ការចេះដឹង ពំនឹងខ្លួន ។

ពុទ្ធសាសនបណ្ឌិត្យ

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| characterstics | characteristics | 13 | 7 |
| ខេត្តកំពង់ឆ្នាំ | ខេត្តកំពង់ឆ្នាំង | 66 | 3 |